សាកលវិទ្យាល័យ ខេមរៈ
KHEMARAK UNIVERSITY

មហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និង ច្បាប់
Faculty of Economical Science and law

ឯកទេស : រដ្ឋបាលសាធារណៈ
Speciality : Public Administration

និក្ខេបបទថ្នាក់បណ្ឌិត
DISSERTATION

ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា
Poverty Reduction in Cambodia

ករណីសិក្សា : ស្រុកជុំគីរី ខេត្តកំពត ពីឆ្នាំ ១៩៩៣-២០០៨
Case study : Chum Kiri district, Kampot Province, From 1993-2008

បេក្ខជនបណ្ឌិត : ស៊ុំ សារឹម
សាស្ត្រាចារ្យណែនាំ : បណ្ឌិត សយ រាសី
បណ្ឌិត ឈុន ណារ៉ែត

ភ្នំពេញ-២០១១

ឧទ្ទិស្សាដៃ

ខ្ញុំសូមឧទ្ទិសស្នាដៃនេះដល់:

- លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលនាំអោយមានអភិបាលកិច្ចល្អ។
- វិញ្ញាណក្ខ័ន្ធបញ្ញាវន្ត ប្រជាពលរដ្ឋខ្មែរ និងអ្នកស្នេហាជាតិទាំងអស់ ដែលបានបូជាជីវិតរបស់ខ្លួន ដើម្បីបុព្វហេតុជាតិ និងមាតុភូមិកម្ពុជាជាទីស្រឡាញ់។

សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ស៊ីវ សារឹម** ជាបេក្ខជនបណ្ឌិត វដ្ឋបាលសាធារណៈ នៃសកលវិទ្យាល័យខេមរៈ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ :

-មាតា បិតា ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សា និងឧបត្ថម្ភគាំទ្រដល់ការសិក្សាចាប់តាំងពីបឋមសិក្សារហូតអោយកូនទទួលបានឱកាសសិក្សាថ្នាក់បណ្ឌិតនាពេលនេះ។

-រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដែលបានបង្កលក្ខណៈដ៏ល្អប្រសើរដល់ខ្ញុំបាទបានបន្តការសិក្សាថ្នាក់បណ្ឌិតនេះ។

-ក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កលក្ខខ័ណ្ឌដ៏ល្អ ដល់ការសិក្សាថ្នាក់បណ្ឌិតនេះ។

-លោកបណ្ឌិត **សុខ ទូច** សាកលវិទ្យាធិការ នៃសកលវិទ្យាល័យខេមរៈ ដែលផ្តល់នូវគំនិត និងឱកាសសិក្សាដ៏ល្អប្រសើរបំផុតដល់ខ្ញុំបាទ។

-លោកបណ្ឌិត **សយ រាសី** និងលោកបណ្ឌិត **ឈុន ណារ៉ែត** ដែលជាសាស្ត្រាចារ្យណែនាំដែលបានផ្តល់គំនិត ឯកសារ និងការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ដើម្បីអោយខ្ញុំបានសម្រេចនូវស្នាដៃនេះ។

-ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ បណ្ឌិត ដែលជាគណៈកម្មការវាយតម្លៃនិក្ខេបបទរបស់ខ្ញុំបាទទាំងអស់ ដែលបានជួយផ្តល់នូវយោបល់ល្អៗ និងការតម្រង់ទិសឯកសារនានា ដើម្បីសុក្រិតកម្មលើនិក្ខេបបទនេះអោយកាន់តែមានលក្ខណៈវិទ្យាសាស្ត្រ។

-លោកសាកលវិទ្យាធិការរង សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ នៃសាកលវិទ្យាល័យខេមរៈ ដែលបានផ្តល់ការណែនាំ អប់រំ និងជួយផ្តល់ឯកសារនានាដល់ការស្រាវជ្រាវរបស់ខ្ញុំបាទ។

អំណរអំណាច

ខ្ញុំបាទឈ្មោះ **ស៊ីវ សារឹម** ជានិស្សិតថ្នាក់បណ្ឌិត នៃសាកលវិទ្យាល័យខេមរៈ សូមធានា និងទទួលខុសត្រូវថា ខ្លឹមសារនៃនិក្ខេបបទស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំបាទ ដោយគ្មានពាក់ព័ន្ធជាមួយនិក្ខេបបទ ឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលបានលើកឡើងនៅក្នុងអត្ថបទនេះគឺថ្មី ហើយក៏ពុំទាន់មានជនណាមួយយកទៅប្រើប្រាស់នៅក្នុងនិក្ខេបបទ ឬរបាយការណ៍ស្រាវស្រាវរបស់គេឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១១

ហត្ថលេខា

ស៊ីវ សារឹម

មាតិកា

ចំណងជើង **ទំព័រ**

ឧទ្ទិសស្នាដៃ i
សេចក្តីថ្លែងអំណរគុណ ii
អំណះអំណាង iii
មាតិកា iv

ជំពូកទី១
សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ២
១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ២
១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ២
១.៦ វិធីសាស្ត្រស្រាវជ្រាវ ៤
១.៧ របកគំហើញនៃការស្រាវជ្រាវ ៥
១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៨

ជំពូកទី២
បញ្ញត្តិនៃភាពក្រីក្រ និងរំលឹកទៅលើទ្រឹស្តី

២.១ បញ្ញត្តិនៃភាពក្រីក្រ ១០
    ២.១.១ និយមន័យ ១០
២.២ ទ្រឹស្តីពាក់ព័ន្ធនឹងភាពក្រីក្រ ១០
    ២.២.១ ទ្រឹស្តីកសិកម្ម និងការអភិវឌ្ឍន៍ជនបទក្នុងការកាត់បន្ថយភាពក្រីក្រ ១០
        ក.តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ..... ១០
        ខ-គោលនយោបាយក្នុងវិស័យកសិកម្មរដ្ឋាភិបាលអាណត្តិទី៤ ..... ១៨
    ២.២.២ ទ្រឹស្តីយេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ ១៩

២.២.៣ ទ្រឹស្តីវិស័យព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ ២៧
២.២.៤ ទ្រឹស្តីវិមជ្ឈការក្នុងការកាត់បន្ថយភាពក្រីក្រ ៣១
២.៣ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ៣៣
២.៣.១ សមាសធាតុនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ៣៣
២.៣.២ ការបង្កើតកាលានុវត្តភាព ៣៩
ក-ពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ៤១
ខ-ការពន្លឿនកំណើនសេដ្ឋកិច្ច ៤២
គ-សម្រួលដល់ការអភិវឌ្ឍន៍ផ្នែកឯកជន ៤៣
ឃ-ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ៤៤
ង-ការពង្រឹងវិស័យថាមពល ៤៥
ច-ការជម្រុញការអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយចីរភាព ៤៦
ឆ-ការកែលម្អការគ្រប់គ្រងធនធានទឹក ៤៧
ជ-ជម្រុញការអភិវឌ្ឍន៍ជនបទ និងវិមជ្ឈការ ៤៨
ឈ-ធានានូវការគ្រប់គ្រងធនធានធម្មជាតិអោយបានត្រឹមត្រូវ ៤៩
ញ-លើកទឹកចិត្តសកម្មភាពបង្កើតចំណូលនៅក្នុងទីជនបទ ៤៩
ដ-ការកាត់បន្ថយភាពក្រីក្រនៅតាមទីប្រជុំជន ៤៩
ថ-ការអនុវត្តន៍គោលនយោបាយជីធ្លី ៥០
២.៣.៣ ការបង្កើតនូវសុវត្ថិភាព ៥២
ក-ផ្តល់ឥណទានមីក្រូហិរញ្ញវត្ថុដល់ពលរដ្ឋក្រីក្រ ៥២
ខ-ការចូលរួមក្នុងសកលភាវូបនីយកម្ម ៥៣
គ-កម្មវិធីសុវត្ថិភាពសង្គម ៥៣
ឃ-កិច្ចការពារបរិស្ថាន ៥៥
ង-ការដោះមីន ៥៥
២.៣.៤ ការពង្រឹងសមត្ថភាព ៥៥
ក-គោលនយោបាយសុខាភិបាល ៥៦
ខ-ទឹក និងអនាម័យ ៥៨
គ-គោលនយោបាយអប់រំ ៥៨
២.៣.៥ ការផ្តល់នូវសិទ្ធិអំណាច ៥៩
ក-ប្រសិទ្ធិភាពនៃការគ្រប់គ្រង ៥៩

ខ-ការអនុវត្តន៍ច្បាប់ ៦១
គ-ការបង្កើតបរិស្ថានអំណោយផលសម្រាប់អង្គការក្រៅរដ្ឋាភិបាល ៦១
២.៣.៦ ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធ ៦២
ក-ទំនាក់ទំនងជាមួយអ្នកផ្តល់ជំនួយ និងចលនាឆ្ពោះទៅរកភាពជាដៃគូ ៦២
ខ-ការកៀងគរចំណូល ៦៤

ជំពូកទី ៣
ស្ថានភាពក្រីក្រចន្លោះឆ្នាំ១៩៩៣-២០០៨

៣.១ បរិបទនៃប្រទេសកម្ពុជា ៦៦
៣.២ និន្នាការនៃភាពក្រីក្រ ឆ្នាំ១៩៩៤-២០០៤ ..... ៨២
៣.៣ ស្ថានភាពក្រីក្រនៅកម្ពុជាចន្លោះឆ្នាំ ២០០៤-២០០៨ ..... ៩៩

ជំពូកទី៤
វិភាគលើមូលហេតុនៃភាពក្រីក្រនៅកម្ពុជា

៤.១ មូលហេតុនៃភាពក្រីក្រ ១១៣
៤.១.១ មូលហេតុនៃនយោបាយ ១១៣
៤.១.២ មូលហេតុនៃសង្គម ១២៥
៤.២ ករណីសិក្សានៅស្រុកជុំគីរី ខេត្តកំពត ១៤៦
៤.២.១ ស្ថានភាពភូមិសាស្ត្ររបស់ស្រុកជុំគីរី ១៤៦
៤.២.២ ស្ថានភាពកសិកម្មនៅស្រុកជុំគីរី ១៤៩
៤.២.៣ ស្ថានភាពក្រីក្ររបស់ប្រជាពលរដ្ឋស្រុកជុំគីរី ១៥៣
ក-ផែនការកាត់បន្ថយភាពក្រីក្រស្រុកជុំគីរី តាមវិស័យកសិកម្ម(១៩៩៦-២០០៣) ១៥៤
ខ-ការកាត់បន្ថយភាពក្រីក្រស្រុកជុំគីរី តាមវិស័យកសិកម្ម(២០០៤-២០០៨) ១៥៧
៤.២.៤ ផែនការសកម្មភាពរយៈពេល៥ឆ្នាំ(២០០៩-២០១៣)របស់ស្រុកជុំគីរី ១៦៦
ក-ចក្ខុវិស័យ ១៦៦
ខ-យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ស្រុក ដើម្បីកាត់បន្ថយភាពក្រីក្រ ១៦៧
គ-អំពីការងារអភិបាលកិច្ចល្អជាអាទិភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ១៦៧
ឃ-អំពីការងាររដ្ឋបាលមូលដ្ឋាន ១៦៧

ង-អំពីការងារនគរបាល កងរាជអាវុធហត្ថ និងផ្នែកសឹករងស្រុក ១៦៨
ច-អំពីការងារអភិវឌ្ឍន៍គ្រប់វិស័យ ១៦៨
៤.៣ យុទ្ធវិធីកាត់បន្ថយភាពក្រីក្រសម្រាប់កសិករនៅកម្ពុជា ១៧៥
៤.៣.១ ពង្រីកវិស័យកសិកម្ម ដែលជាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ ១៧៥
៤.៣.២ ការអភិវឌ្ឍន៍កសិកម្ម គន្លឹះនៃការកាត់បន្ថយភាពក្រីក្រ ១៧៩
៤.៣.៣ បង្កើតយន្តការចាំបាច់បន្ទាន់ចូលរួមកាត់បន្ថយការលំបាករបស់កសិករ ១៨៥
៤.៣.៤ បណ្តុះធនធានអោយមានការចងក្រងជាសមាគមន៍កសិករ និងការអភិវឌ្ឍន៍ ២១២

ជំពូកទី១
សន្និដ្ឋាន និង អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ២២៧
៥.២ អនុសាសន៍ ២៤២

គន្ថនិទ្ទេស

ឧបសម្ព័ន្ធ

ជំពូកទី១
សេចក្តីផ្តើម

១.១ ចំណាំបញ្ហានៃការស្រាវជ្រាវ

បណ្តាប្រទេសក្នុងពិភពលោក តែងតែខិតខំរកមធ្យោបាយផ្សេងៗក្នុងការលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋរបស់ខ្លួនអោយកាន់តែមានសភាពប្រសើរឡើងដូចជា ការចូលរួមចំណែកក្នុងការកាត់បន្តភាពក្រីក្ររបស់ប្រជាពលរដ្ឋ ព្រោះថា ភាពក្រីក្រ គឺជាឧបសគ្គដ៏ធំនៅក្នុងការអភិវឌ្ឍន៍ជាតិទាំងអស់នៅលើពិភពលោក។ ភាពក្រីក្រនេះបានកើតឡើងដោយសារកត្តាមួយចំនួន ដូចជា វិបត្តិសេដ្ឋកិច្ច សង្គ្រាម អំពើពុករលួយ វប្បធម៌ចាស់គំរឹល។ល។

នៅកម្ពុជា ដោយសារការកើតមានឡើងនូវសង្គ្រាមស៊ីវិលអស់រយៈពេលប្រហែលបីទសវត្សកន្លងមក ជាពិសេសនៅក្នុងរបបប្រល័យពូជសាសន៍(ឆ្នាំ១៩៧៥-១៩៧៩) បានបន្សល់ទុកនូវ ស្ត្រីមេម៉ាយ កុមារកំព្រា ជនពិការ អនក្ខរជន និងប្រជាជនក្រីក្រជាច្រើនសម្រាប់ជាមរតកដល់រដ្ឋាភិបាលជំនាន់ក្រោយៗ។

បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ប្រទេសកម្ពុជា បានដំណើរការបោះឆ្នោតជាតិលើកទីមួយ ក្រោមការរៀបចំរបស់អង្គការសហប្រជាជាតិ។ ចាប់តាំងពីមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទីមួយមក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចគ្រប់វិស័យ ការកែលម្អក្របខ័ណ្ឌគតិយុត្ត និងការបង្កើតឡើងនូវស្ថាប័នមួយចំនួន ដើម្បីបំពេញការងារជូនជាតិ និងប្រជាពលរដ្ឋកម្ពុជាយើង។

នាឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលអាណត្តិទី២ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រត្រីកោណ ដែលក្នុងនោះមានយុទ្ធសាស្ត្របីសំខាន់ៗរួមមាន: ១-ធានានូវសន្តិភាព ស្ថេរភាព និងសន្តិសុខសាធារណៈ ២-ធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍អន្តរជាតិ និងតំបន់ និង ៣-អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ផ្អែកលើយុទ្ធសាស្ត្រនេះបានធ្វើអោយប្រទេសកម្ពុជាមាន សន្តិភាព ស្ថេរភាព និងសន្តិសុខ ពេញផ្ទៃប្រទេស ដោយបានផ្តួលរំលំទាំងស្រុងរបនាសម្ព័ន្ធខ្មែរក្រហម និងធ្វើសមាហរណកម្មកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការគ្រប់ភាគីអោយមកនៅក្រោមដំបូលតែមួយរបស់រាជរដ្ឋាភិបាល។ បន្ទាប់ពីរាជរដ្ឋាភិបាលរក្សាបាននូវសុវត្ថិភាព ស្ថេរភាពនយោបាយ សន្តិភាព សន្តិសុខក្នុងប្រទេសកម្ពុជា ក៏បានចូលជាសមាជិកនៃសមាគមនអាស៊ាន (ASEAN) និងអង្គការពាណិជ្ជកម្មពិភពលោក(WTO)។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវឯកសារក្របខ័ណ្ឌមួយចំនួនក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋរួមមាន: ឯកសារបឋមស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ យុទ្ធសាស្ត្រជាតិតាក់បន្ថយភាពក្រីក្រ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ល។

បន្ទាប់មកទៀត រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដែលមានអភិបាលកិច្ចល្អជាស្នូលនៃយុទ្ធសាស្ត្រនេះ។ យុទ្ធសាស្ត្រចតុកោណ ជាឧបករណ៍ទ្រទ្រង់ការអនុវត្តន៍កម្មវិធី

នយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភា ដើម្បីឈានឆ្ពោះទៅសម្រេចអោយបាននូវការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍ វឌ្ឍនភាព និងវិបុលភាព ព្រមទាំងភាពសុខដុមរមនា និងសុភមង្គលជូនប្រជាជនកម្ពុជា។ ជាលទ្ធផល ភាពក្រីក្រនៅកម្ពុជា ត្រូវបានកាត់បន្ថយជារៀងរាល់ឆ្នាំ ហើយទិសដៅរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភានៅក្នុងការកាត់បន្ថយភាពក្រីក្រនេះ គឺជានាសម្រេចអោយបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រអោយបានលើស១ភាគរយក្នុងមួយឆ្នាំ។

យោងតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលខាងលើ និងក្នុងនាមខ្លួនជារដ្ឋបាលថ្នាក់ក្រោមជាតិមួយ ស្រុកជុំគីរី ខេត្តកំពត បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួន ដើម្បីឈានទៅរកការអភិវឌ្ឍន៍ក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវកម្រិតជីវភាព ក៏ដូចជាការចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយផ្លែផ្កាជាដំហានៗផងដែរ។

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយផ្អែកលើការលើកឡើងខាងលើយើងអាចចោទជាសំណួរចំនួន បី ដូចខាងក្រោម:

- តើភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋស្រុកជុំគីរីមានស្ថានភាពបែបណា?
- តើមូលហេតុអ្វី ដែលបង្កអោយមានភាពក្រីក្រនៅកម្ពុជា ក៏ដូចជានៅស្រុកជុំគីរី ខេត្តកំពត?
- តើស្រុកបានប្រើយុទ្ធវិធីយ៉ាងណា នៅក្នុងការកាត់បន្ថយភាពក្រីក្រ?

១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម:

- សិក្សាការអនុវត្តន៍អំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។
- បំភ្លឺអំពីភាពក្រីក្រ នៅស្រុកជុំគីរី ឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០០៨ ។
- បង្ហាញអំពីបណ្តាយន្តការ ដែលបានប្រើប្រាស់នៅក្នុងការកាត់បន្ថយភាពក្រីក្រ។

១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើករណីសិក្សាភាពក្រីក្ររបស់ប្រជាជននៅស្រុកជុំគីរី ខេត្តកំពត ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨ ហើយមិនតែប៉ុណ្ណោះនៅក្នុងការសិក្សានេះក៏មានការពិពណ៌នាអំពីភាពក្រីក្រនៅទូទាំងប្រទេសកម្ពុជាដូចជា នៅតំបន់ទីក្រុង និងនៅតាមជនបទផងដែរ ពីចន្លោះឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨។

១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវប្រធានបទនេះ នឹងចូលរួមចំណែកជាវិភាគទានដ៏សំខាន់ខាងផ្នែកចំណេះដឹងទៅលើវិស័យអប់រំ ច្បាប់ រដ្ឋបាលសាធារណៈ និងវិស័យនយោបាយ ព្រមទាំងចំណេះដឹងរបស់មនុស្សទូទៅនៅកម្ពុជា។ ហើយក៏ដូចជា ឯកសារស្រាវជ្រាវបែបវិទ្យាសាស្ត្រមួយថែមទៀត លើវិស័យរដ្ឋបាល

សាធារណៈ ដែលបំពេញអោយសេចក្តីត្រូវការចាំបាច់ដល់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ ដែលកំពុងស្រេកឃ្លាន និងជួបប្រទះនូវកង្វះខាតខាងឯកសារ។ ព្រមទាំងចូលរួមជាទស្សនាទានដ៏សមខាន់ក្នុងកិច្ចការអភិវឌ្ឍន៍សង្គមជាតិដោយនិរន្តរភាព និងបញ្ចៀសបាននូវភាពខុសឆ្គង ដែលកើតមាននៅក្នុងដំណើរការកសាងលទ្ធិប្រជាធិបតេយ្យ និងសេរីពហុបក្សក្នុងទិសដៅឆ្ពោះទៅកាន់នីតិរដ្ឋ ហើយជាមូលដ្ឋានត្រូវតែកាត់បន្ថយភាពក្រីក្រនេះជាមុនសិន។ ដូច្នេះ ការសរសេរឡើងនូវស្នាដៃនេះពុំមែនដើម្បីតែការពារយកសញ្ញាបត្រនោះទេ ក៏ប៉ុន្តែក៏ជាការរួមចំណែកមួយ ក្នុងកិច្ចការស្រាវជ្រាវ ប្រមូលផ្តុំ និងចងក្រងឯកសារ ដើម្បីទុកជាសម្បត្តិវប្បធម៌ដ៏មានតម្លៃរបស់ជាតិ និងបន្សល់ទុកនូវស្នាដៃសម្រាប់អ្នកសិក្សា និងកូនចៅជំនាន់ក្រោយអោយបានយល់ជ្រាប និងជាលំអានសម្រាប់ជាមូលដ្ឋានដំណើរជីវិត និងសង្គមជាតិយើង។ ម្យ៉ាងទៀត សារៈសំខាន់នៃការស្រាវជ្រាវនេះអាចនិយាយបានថា:

-ចំពោះអ្នកស្រាវជ្រាវផ្ទាល់: លទ្ធផលនៃការសិក្សានេះបានធ្វើអោយអ្នកសិក្សាផ្ទាល់រីកចម្រើនទាំងចំណេះដឹង ទាំងបទពិសោធន៍ ជាពិសេសមានការរីកចម្រើនផ្នែកស្មារតី និងមានមោទនភាពខ្ពស់ចំពោះខ្លួនឯងដែលបានផ្តល់នូវទស្សនាទានផ្នែកចំណេះដឹងដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ។

-ចំពោះសង្គម: ក្រោយពីការទទួលបានលទ្ធផលនៃការសិក្សាឯកសារស្នាដៃនេះ អាចជួយជាស់តឿនដល់សង្គមអោយឃើញពីសមិទ្ធផលពីបញ្ហាប្រឈម និងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីប្រែក្លាយកម្ពុជាអោយចាកផុតពីភាពក្រីក្រ មិនតែប៉ុណ្ណោះរក្សាការពារអោយមានសន្តិភាព សុវត្ថិភាព សោភណ្ឌភាព និងការអភិឌ្ឍលើគ្រប់វិស័យ ដែលទាំងអស់នេះកើតឡើងពីការដឹកនាំរបស់ប្រមុខរាជរដ្ឋាភិបាល ដែលមានសម្តេចហ៊ុន សែន ជានាយករដ្ឋមន្ត្រី។

-ចំពោះស្ថាប័ន: ឯកសារស្នាដៃនេះផ្តល់ជាគំនិតយ៉ាងសំខាន់ដល់ស្ថាប័នដែលពាក់ព័ន្ធទាំងផ្នែកឯកជន និងផ្នែកសាធារណៈ ដើម្បីជួយបង្កើនល្បឿននៃការអភិវឌ្ឍន៍ជនបទអោយមានការរីកចម្រើនគ្រប់ទិសទីទូទាំងប្រទេសជាតិយើងទាំងមូល។

-ចំពោះការអប់រំកសិករនៅស្រុកជុំគីរី ខេត្តកំពត: នេះជាឯកសារស្នាដៃសំខាន់សម្រាប់បង្ហាញពីសមិទ្ធផលដែលរាជរដ្ឋាភិបាល និងប្រជាជនទូទាំងស្រុកជុំគីរី ខេត្តកំពតបានសម្រេចជាផ្លែផ្កា និងកំពុងស្វែងរកនូវគន្លឹះថ្មីៗ ដើម្បីបន្តអនុវត្តបណ្តាគម្រោងអភិវឌ្ឍន៍ស្រុកប្រកបដោយប្រសិទ្ធភាព និងចីរភាពនៃកំណើនសេដ្ឋកិច្ច ដើម្បីរក្សានិរន្តរភាព នៃការអភិវឌ្ឍន៍ ហើយវាក៏ជាកម្លាំងចលករមួយជួយលើកទឹកចិត្តប្រជាជនអោយមានការខិតខំប្រឹងប្រែងតទៅទៀតផងដែរ។

-សម្រាប់វិទ្យាសាស្ត្រ: ការសិក្សានេះបានបង្ហាញអំពីវិធីសាស្ត្រស្រាវជ្រាវយ៉ាងច្បាស់ បានបង្ហាញអំពីការវិភាគ ហើយព្រមទាំងបានបង្ហាញអំពីរបកគំហើញផងដែរ ដែលជាលទ្ធផលនៃការស្រាវជ្រាវរបស់យើង។

១.៦ វិធីសាស្ត្រស្រាវជ្រាវ

ក-ត្រីវិស័យនៃការស្រាវជ្រាវ

ក្នុងចំណុចនេះយើងបានប្រើ **ត្រីវិស័យនៃការស្រាវជ្រាវ** ដើម្បីធ្វើការសិក្សានិក្ខេបបទនេះស្ថិតនៅលើមូលដ្ឋានបីយ៉ាងគឺ:

- ប្រើ Descriptive Method Research or Documentary Method Research ។
- ធ្វើការសិក្សាដោយយោងតាមដំណើរវិវឌ្ឍន៍នៃស្ថានភាពសង្គម និងនយោបាយខ្មែរ។
- ផ្អែកទៅលើមូលដ្ឋាននៃទស្សននយោបាយ គោលនយោបាយជាតិ និងទ្រឹស្តីផ្នែកវិទ្យាសាស្ត្រសង្គមដែលពាក់ព័ន្ធនឹងដំណើរការកាត់បន្ថយភាពក្រីក្រ។
- ឯកសារបទដ្ឋានគតិយុត្ត និងច្បាប់ផ្សេងៗរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានបោះពុម្ពផ្សាយ និងមានតំកល់ទុកនៅក្នុងក្រុងភ្នំពេញ នៅតាមបណ្ណាល័យនានា ព្រមទាំងសៀវភៅ និងកម្រងអត្ថបទពិសេសផ្សេងៗទៀត។

ម្យ៉ាងទៀតជម្រើសដ៏សមរម្យបំផុតយកមកប្រើប្រាស់ក្នុងគម្រោងស្រាវជ្រាវ គឺយើងខ្ញុំបានគោរពតាមការណែនាំ និងតាមគម្រោងសកម្មភាពរបស់ខ្លួនឯងផ្ទាល់ ដែលជាជំនួយក្នុងការពិពណ៌នា ក៏ដូចជា ការវិភាគទៅលើដើមហេតុនៃប្រភពបង្កអោយមានភាពក្រីក្រ។ ដូច្នេះ វិធីសាស្ត្រសមស្របដែលបានប្រើនៅខាងលើត្រូវបានបង្កើតឡើង ដើម្បីស្វែងយល់ និងវិភាគអោយបានស៊ីជម្រៅចំពោះ "**ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ឆ្នាំ ១៩៩៣-២០០៨**" និងឈានឆ្ពោះទៅដល់ការផ្តល់អនុសាសន៍ ដើម្បីកែលម្អនៅក្នុងដំណើរការនៃការកាត់បន្ថយភាពក្រីក្រ។

ខ-តំបន់សិក្សា

ការស្រាវជ្រាវរបស់យើងខ្ញុំផ្អែកទៅលើឯកសារច្បាប់ នយោបាយ ប្រវត្តិសាស្ត្រ សេដ្ឋកិច្ច សង្គមសាស្ត្រ ដែលជាឯកសារទាំងអស់នេះ ខ្ញុំបាទបានចុះទៅធ្វើការស្រាវជ្រាវ ជាពិសេស គឺនៅស្ថាប័ននានានៅក្នុងប្រទេស ជាពិសេសខ្ញុំបាទក៏បានចុះទៅសិក្សានៅឯស្រុកជុំគីរី ក្នុងខេត្តកំពតផ្ទាល់តែម្តង ពីព្រោះជាស្រុកកំណើតរបស់ខ្ញុំ។ ក្រៅពីនេះ យើងបានទៅស្វែងរកឯកសារស្ទើរគ្រប់បណ្ណាល័យទាំងអស់នៅបណ្តាសាកលវិទ្យាល័យនានានៃរាជធានីភ្នំពេញ។

គ-ប្រភេទទិន្នន័យ

ដើម្បីសម្រួលដល់ការសិក្សាស្រាវជ្រាវ ចំពោះទិន្នន័យដែលយកមកធ្វើការសិក្សាមានពីរប្រភេទគឺ: ទី១ ជាប្រភេទទិន្នន័យផ្ទាល់(Primary Data) និងទី២ ទិន្នន័យមានស្រាប់(Secondary Data)។

ឃ-វិធីប្រមូលទិន្នន័យ

ទិន្នន័យ និងព័ត៌មានចាំបាច់ដែលទាក់ទងទៅនឹងការសិក្សាត្រូវបានប្រមូល និងចម្រាញ់យកតែទិន្នន័យ ឬព័ត៌មានណាដែលមានសារៈប្រយោជន៍ និងពាក់ព័ន្ធចំពោះប្រធានបទដូចជា:

ការប្រមូលទិន្នន័យផ្ទាល់: បានចូលរួមចំណេះសំណាល និងសាកសួរសំណួរមួយចំនួន ចំពោះវាគ្មិនឥស្សរជននយោបាយ អង្គការក្រៅរដ្ឋាភិបាល និងបានសាកសួរដោយផ្ទាល់ចំពោះអាជ្ញាធរដែនដីស្រុកជុំគីរី ខេត្តកំពត ហើយក៏បានចូលរួមក្នុងសិក្ខាសាលា និងសន្និសីទនានាពីភាពក្រីក្រដោយផ្ទាល់តែម្តង។

ការប្រមូលទិន្នន័យមានស្រាប់: ដើម្បីអោយការសិក្សាស្រាវជ្រាវ លើប្រធានបទនេះកាន់តែមានសុក្រិត្យភាពថែមទៀតនោះ គឺចាំបាច់ត្រូវដកស្រង់តាមរយៈឯកសារនានា គឺឯកសារដើមដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់នានាដែលពាក់ព័ន្ធ និងដំណើរការរបស់ស្ថាប័ននយោបាយ និងសេចក្តីសម្រេចនានា និងព្រះរាជសារជាដើម និងដកស្រង់តាមស្នាដៃនិពន្ធ ព្រឹត្តិប័ត្រ ទស្សនាវដ្តី និងសារព័ត៌មានជាតិ និងអន្តរជាតិ។ល។

១-វិធីសាស្ត្រវិភាគទិន្នន័យ

ការវិភាគទិន្នន័យ ដោយប្រើប្រាស់វិធីសាស្ត្រអធិប្បាយប្រៀបធៀប និងធ្វើការវិភាគបែបពិពណ៌នា ព្រមទាំងធ្វើការប្រៀបធៀបទ្រឹស្តីពាក់ព័ន្ធផ្សេងៗទៀត។ល។ ហើយនៅក្នុងការសរសេរ យើងប្រើទិន្នន័យទីពីរ (Secondary Data) ច្រើនលើសលប់ជាងទិន្នន័យទីមួយ។

១.៧ របកគំហើញនៃការស្រាវជ្រាវ

រាជរដ្ឋាភិបាលកំពុងតែតម្រង់ទិសឆ្ពោះទៅតាមផ្លូវនីតិរដ្ឋ ដើម្បីកាត់បន្ថយភាពក្រីក្រ។ ជាមួយគ្នានេះដែរ យើងសង្កេតឃើញថា តាមលទ្ធផលនៃការសិក្សាបានបង្ហាញថា មូលហេតុដែលបណ្តាលអោយមានភាពក្រីក្រនៅកម្ពុជាយើងនោះ គឺបណ្តាលមកពីហេតុផល: ទី១-ហេតុផលផ្ទាល់ខ្លួនអ្នកក្រីក្រភាគច្រើននៅកម្ពុជាមានការអប់រំតិចតួច ឬគ្មានការអប់រំសោះ ទាំងចំណេះដឹងទូទៅ ទាំងបច្ចេកទេសជំនាញវិជ្ជាជីវៈ។ ការងារផលិតកម្មដូចជា កសិកម្មពឹងផ្អែកទាំងស្រុងទៅលើធម្មជាតិ ចំណែកឯសិប្បកម្ម និងផលិតកម្មផ្សេងៗ ច្រើនធ្វើឡើងទៅតាមទំនៀមទម្លាប់តៗគ្នា ដើម្បីជីវភាពប្រចាំថ្ងៃ។ មិនតែប៉ុណ្ណោះ ពួកគេពឹងផ្អែកទាំងស្រុងលើការងារដោយប្រើកម្លាំងបាយ។ នៅពេលសេដ្ឋកិច្ចទីផ្សារ និងបច្ចេកវិទ្យាទំនើបបានរីកដុះដាល ដែលពួកគេមិនអាចចូលចុះចំពោះមុខការងារថ្មី ដែលទាមទារជំនាញ និងការអប់រំខ្ពស់បានឡើយ។ ដូច្នេះ ពួកគេគ្មានឱកាសណាដើម្បីអោយក្លាយខ្លួនជាអ្នកមានបានឆាប់រហ័សបានឡើយ។ ទី២-ហេតុផលនៃការស្ថិតនៅក្រៅសង្គម អ្នកក្រីក្រនៅកម្ពុជាភាគច្រើន មានការភ័យខ្លាចក្នុងការទាក់ទងមិត្តភ័ក្តិ ឬអាជ្ញាធរព្រោះខ្មាស់អៀន ហើយគិតថា គ្មាននរណាអាចជួយពួកគាត់បានទេ។ ពួកគេកាន់តែស្ថិតនៅក្នុងភាពឯកកោ និងក្តីអស់សង្ឃឹមទាល់ច្រកបាត់បង់លទ្ធភាពតស៊ូរស់បន្តជំរុញអោយជីវិតរីកចម្រើនរុងរឿង។ ដោយហេតុនេះ គេមិនអាចសម្រេចការងារអ្វី ឬប្រើប្រាស់ឱកាសដើម្បីដោះស្រាយបញ្ហាលំបាកបានឡើយ។ សភាពការណ៍ដូច្នេះ ជាទូទៅនាំអោយអ្នកទ័លក្រក្លាយជាអ្នកសុំទាន ឬចោរលួច ឆក់ ប្លន់ បង្ខំចិត្តធ្វើជាស្រីពេស្យា ឬលក់កូនក្រមុំអោយទៅធ្វើស្រីពេស្យា ធ្វើអត្តឃាត និងធ្វើជាឧក្រិដ្ឋជន

ផ្សេងទៀត។ លើសពីនេះទៀត អ្នកខ្លះក្លាយខ្លួនជាជនអនាថា គ្មានជម្រក ខ្លះរហូតដល់ជាប់ចាយស្លាប់ក៏មាន។ ភាពខ្ជិលច្រអូស កង្វះទ្រព្យធនធាន និងដីធ្លី អ្នកក្រីក្រជាច្រើនត្រូវបន្ទោសថា មកពីពួកគេខ្ជិលធ្វើការបានជាក្រ ទោះជាអ្នកខ្លះធ្វើការស្ទើរតែគ្មានពេលសម្រាកក៏ដោយ។ ដោយការគិះជៀលពីអ្នកដទៃ(អ្នកមានទ្រព្យធនជាងគេ និងភាពលោភលន់ធ្វើអោយពួកគេលក់ផ្ទះលក់ដីធ្លី ដែលជាធនធានសម្រាប់ផលិតកម្ម កសិកម្ម ឬវិនិយោគទុនទិញយក ហើយពួកគេបានថយខ្លួនបន្លាស់ទីលំនៅផ្សេង អ្នកខ្លះទៅប្រកបរបរផ្សេងខុសពីរបរដែលខ្លួនធ្លាប់មានបទពិសោធន៍។ ពួកគេភាគច្រើន មិនអាចកែប្រែជីវភាពរបស់គេអោយធូរធារបានទេ ព្រោះគេមិនចេះយកលុយដែលបានពីលក់ធនធានទាំងនោះទៅវិនិយោគលើអ្វីមួយឡើយ។ កត្តានេះហើយ ដែលធ្វើអោយអ្នកក្រីក្រ ចាប់ផ្តើមបាត់បង់ទ្រព្យសម្បត្តិដ៏សំខាន់របស់ខ្លួន គឺដីធ្លីដែលជាមធ្យោបាយផលិតកម្ម។ អ្នកខ្លះរំកិលចូលមកក្នុងក្រុងដោយតាំងលំនៅ តំបន់អាណាធិបតេយ្យ នាំអោយខូចសណ្តាប់ធ្នាប់សង្គម។ ដូច្នេះ អ្នកក្រកាន់តែក្រទៅ ហើយអ្នកមានដែលគេចេះកេងប្រវ័ញ្ចដោយសារដីធ្លី ឬកម្លាំងពលកម្មនោះកាន់តែមានទៅ ដែលជាហេតុនាំអោយមានគម្លាតរវាងអ្នកក្រ និងអ្នកមានក្នុងសង្គមកាន់តែរីកធំទៅៗ។ បញ្ហាទាំងនេះជាបន្ទុកយ៉ាងធ្ងន់ដល់សង្គម ដែលជាអ្នកដោះស្រាយ ពិសេសរដ្ឋាភិបាលមានការលំបាកក្នុងការដោះស្រាយពីព្រោះ រដ្ឋាភិបាលពេលខ្លះមិនអាចជួយពួកគេគ្រប់ពេលបានទេ ប្រសិនបើពួកគេមិនចេះជួយខ្លួនឯងផងទេនោះ។ ការពិតហេតុផលនេះវាពាក់ព័ន្ធទៅនឹងពួកគេខ្វះការយល់ដឹង និងបទពិសោធន៍។ កត្តាខ្វះការយល់ដឹង អ្នកក្រីក្រភាគច្រើនមិនអាចមើលឃើញបញ្ហារបស់ខ្លួន ជាទស្សនៈទូលំទូលាយទេ ព្រោះពួកគេខ្វះការអប់រំ ខ្វះគំនិតច្នៃប្រឌិត ខ្វះប្រាជ្ញាគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាដែលពួកគេកំពុងជួបប្រទះ។ ដូចជា ករណីជាច្រើននៅក្នុងជីវភាពរស់នៅរបស់អ្នកទាំងនោះ ក្រោយពីពួកគេធ្វើការយ៉ាងលំបាក ដោយបង្ហូរញើសដើម្បីទទួលបានប្រាក់ចំណូល ដ៏ស្តួចស្តើង ចំណូលមួយថ្ងៃសម្រាប់តែមួយថ្ងៃ តែពួកគេខិតខំរំលែកប្រាក់កាសនេះយកទៅផឹកស៊ី លេងល្បែង ស៊ីសង នៅពេលដែលកូនគេយំស្រែកទារកបាយនៅឯផ្ទះ។ ការលេងល្បែងនេះ ពេលខ្លះគាត់មានសំណាងឈ្នះ ហើយក្លាយទៅជាអ្នកមានមួយរយៈពេលតូចដែរ តែតាមធម្មតាគាត់កាន់តែក្រទៅៗ។ ម្យ៉ាងទៀតឥទ្ធិពលពីគ្រួសារ អ្នកដែលកើតមកក្នុងគ្រួសារឈាមជ័រជាអ្នកក្រ ពិបាកនឹងរំដោះខ្លួនចេញពីភាពក្រីក្រណាស់ ពីព្រោះអ្នកជំនាន់មុនគ្មានសមត្ថភាពរំដោះកូនចៅជំនាន់ក្រោយគាត់ចេញពីគ្រោះនៃភាពក្រីក្របានឡើយ។ ពេលឪពុកម្តាយជំពាក់បំណុលគេ កូនចៅជំនាន់ក្រោយជាអ្នកត្រូវរកសងកេមិនចេះចប់។ ផ្ទុយទៅវិញ វប្បធម៌របស់ខ្មែរ គ្រួសារអ្នកមាន តាមធម្មតាពួកគេជួយញាតិមិត្ត ហើយគេខំសន្សំទ្រព្យអោយបានច្រើន ដើម្បីធ្វើជាកេរ្តិ៍មរតកសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។ អ្នកមានកូចតិច គេមានឱកាសច្រើនណាស់ដើម្បីរៀនសូត្របានខ្ពង់ខ្ពស់។ ម្យ៉ាងវិញទៀត ភាពក្រីក្រច្រើនតែធ្លាក់ទៅលើគ្រួសារណាដែលមានកូនច្រើន ជនពិការ និងជនចាស់ជរា ឬគ្រួសារដែលអ្នកដឹកនាំ គ្រួសារជាស្ត្រីមេម៉ាយ ព្រោះពួកនេះងាយរងគ្រោះជាទីបំផុត។ រីឯបញ្ហាសាសនា ប្រជាជនកម្ពុជាភាគច្រើនជឿជាក់លើសាសនាអបិយ៍ជំនឿ និងកម្មផលនិយម។ អ្នកក្រភាគច្រើនយល់ថា ពួកគេក្រដោយសារ កម្មពៀរបស់គេពីអតីតកាល ឬពីជាតិមុន។ ម្ល៉ោះហើយពួកគេគ្មានសង្ឃឹម និងកម្លាំងចិត្តតស៊ូប្រឆាំងនឹងភាពក្រីក្រដែលកំពុងជួប

ប្រទះពេលបច្ចុប្បន្ននេះទេ។ ពួកគាត់បែរជាខិតខំធ្វើបុណ្យ ដើម្បីកសាងកុសលសម្រាប់ជាតិក្រោយៗទៀត គាត់មិនបានកែច្នៃជីវិតគាត់ក្នុងភាពរុងរឿងសម្រាប់បច្ចុប្បន្នឡើយ។ តាមពិតសាសនា គឺជាអត្តសញ្ញាណរបស់ប្រជាជាតិមួយ ដែលមានតម្លៃវប្បធម៌ និងអរិយធម៌របស់ជាតិយើង។ បញ្ហាទំនៀមទម្លាប់ ក្រុមកុលសម្ព័ន្ធជាជនជាតិភាគតិច ដែលរស់នៅតាមតំបន់ភ្នំ គឺជាអ្នកក្រ ជាប្រពៃណី ពួកគេពិបាកនឹងផ្លាស់ប្តូរ ទម្លាប់រស់នៅដោយប្រមូលផ្តុំ និងការធ្វើសកម្មដោយរបៀបបុរាណរបស់គេណាស់។ គេទម្លាប់រស់នៅដោយសារការបរបាញ់ ដុតព្រៃ ដាំដំណាំសម្រាប់តែមួយចំអែតក្រពះប៉ុណ្ណោះ។ ដូច្នេះ ជំនឿស៊ុបខ្លាំងពេកទៅលើអបិយជំនឿ ក៏រួចចំណែកធ្វើអោយមានភាពក្រីក្រផងដែរ។ ចំពោះហេតុផលធម្មជាតិលក្ខខ័ណ្ឌធម្មជាតិ គឺជាហេតុផលសំខាន់ ដែលជះឥទ្ធិពលដល់ភាពក្រីក្រនៅកម្ពុជា។ ប្រជាជនកម្ពុជារស់នៅភាគច្រើនប្រកបរបរកសិកម្ម ដែលមានលក្ខណៈអន់ថយបុរាណ និងការពឹងផ្អែកទៅលើធម្មជាតិទាំងស្រុង។ នៅពេលដែលធនធានបរិស្ថានធម្មជាតិនៅកម្ពុជាត្រូវបានបំផ្លិចបំផ្លាញនោះ ជាហេតុបង្កអោយមានការប្រែប្រួលខាងធាតុអាកាស នាំអោយមានវិនាសសកម្មធម្មជាតិ ដូចជា ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។ នៅកម្ពុជាអាកាសធាតុក្តៅនៅជនបទជាពិសេសនៅរដូវប្រាំងមនុស្ស សត្វពិបាកនឹងទ្រាំដោយសារកំដៅព្រះអាទិត្យ។ នៅតាមជនបទ ទឹកបឹងត្រពាំងរីងស្ងួតគ្មានសល់ជាហេតុធ្វើអោយមានជំងឺ និងសម្លាប់សត្វ ចិញ្ចឹមនៅតំបន់ជនបទស្ទើរតែទាំងអស់ជាពិសេសកន្លែងដែលឆ្ងាយពីទឹក។ ចំណែកឯហេតុផលនយោបាយ និងហេតុផលសេដ្ឋកិច្ច គឺជាផលប៉ះពាល់ដ៏សំខាន់ក្នុងការអភិវឌ្ឍន៍កម្ពុជា។

ក្រោយពីបានសិក្សាលើប្រធានបទខាងលើរួចមក ខ្ញុំបាទសូមផ្តល់ជាទស្សនាទានមួយចំនួន ដែលជាដំណោះស្រាយដ៏ល្អសម្រាប់ការកាត់បន្ថយភាពក្រីក្រដូចជាខាងក្រោមនេះ :

-ត្រូវបង្កើតអភិបាលកិច្ចល្អ តម្លាភាពអោយបានប្រសើរ បង្កលក្ខណៈអោយមានការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិល និងផ្នែកឯកជន ដោយលើកទឹកចិត្តអោយមានការប្តូរយោបល់ និងទស្សនៈទូលំទូលាយ។

-ត្រូវជួយអោយអស់លទ្ធភាពក្នុងការរក្សាលំនឹងតម្លៃផលិតផលកសិកម្ម លើទីផ្សារ និងជួយរក្សាទីផ្សារសម្រាប់លក់ចេញ និងសិក្សាអោយបានស៊ីជម្រៅ តម្រូវការទីផ្សារ ដើម្បីតម្រង់ទិសដៅការផលិត និងចុះអប់រំដោយប្រចាំនូវវិធីដាំដុះ ការប្រើប្រាស់ជី និងបច្ចេកទេសទាន់សម័យដល់ប្រជាកសិករក្នុងការបង្កបង្កើនផល។

-ធ្វើយ៉ាងណាទាក់ទាញពួកវិនិយោគបរទេសអោយវិនិយោគដោយផ្ទាល់ ទៅលើវិស័យកសិកម្មដោយកាត់បន្ថយអោយនៅកម្រិតអប្បបរិមាណនូវរបបការិយាធិបតេយ្យ ស្មុគស្មាញ និងការសុំគ្រលំរាំងអ្នកផ្តល់ និងអ្នកទទួលកុងត្រា។

-លុបបំបាត់ការរំលោភដីធ្លីប្រជាពលរដ្ឋ តែផ្ទុយទៅវិញត្រូវបង្កលក្ខណៈអោយប្រជាពលរដ្ឋទទួលបានដីសម្រាប់ប្រកបរបរចិញ្ចឹមជីវិតអោយបានសមរម្យ។

-សូមអោយរដ្ឋាភិបាលបន្តការអភិវឌ្ឍន៍ជនបទជាយដែន និងតំបន់ដាច់ស្រយាល ដូចជា កសាងផ្លូវ មន្ទីពេទ្យ សាលារៀន...។ លើកទឹកចិត្តប្រជាពលរដ្ឋក្រីក្រ គ្មានដីធ្លី អ្នកក្រីក្រនៅក្នុងទីក្រុង និងកងទ័ពរំសាយដែលជួបប្រទះនឹងភាពក្រីក្រ អោយពួកគេទៅរស់នៅទីនោះ និងធ្វើយ៉ាងនេះដើម្បីអោយប្រជាពលរដ្ឋទាំងនោះ

បានពង្រីផ្ទៃដីស្រែចំការ និងកាត់បន្ថយការរស់នៅកកកុញនៅទីប្រជុំជន ឬទីក្រុង ដែលធ្វើអោយបរិស្ថានអាប់អួរ ជាពិសេសជួយការពារព្រំដែនពីការរំលោភពីប្រទេសជិតខាង ដែលមានមហិច្ឆិតារេលបត្របាក់ទឹកដីរបស់យើង។

-សូមរដ្ឋាភិបាលយកចិត្តទុកដាក់ពង្រីកធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងសក្តានុពលរបស់សង្គមជាតិ ដែលកំពុងតែត្រូវការអ្នកចេះពិត មានឯកទេសពិត ដើម្បីចូលរួមចំណែកជួយកាត់បន្ថយភាពក្រីក្រអោយបានឆាប់។

ចំណែកឯទស្សនាទានទី២ ដែលជាដំណោះស្រាយដ៏ល្អសម្រាប់ការកាត់បន្ថយភាពក្រីក្រក្នុងចំណោមកសិករត្រូវអនុវត្តដូចជា: ត្រូវចុះជម្រុញណែនាំកសិករគ្រប់ស្រុកអោយយកចិត្តទុកដាក់ការងារថែទាំដំណាំស្រូវនៅចុងរដូវ ដូចជា ការទប់ទឹក ការពារភ្លើងឆេះស្រូវនៅរដូវប្រាំង។ ជួយជម្រុញការថែទាំដំណាំស្រូវរដូវស្សាស្រូវប្រាំងអោយមានការដាំដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរយៈពេលខ្លីរដូវប្រាំង និងជម្រុញការដាំដំណាំបន្លែអោយអស់លទ្ធភាព។ ហើយជាពិសេសត្រូវបន្តធ្វើការផ្សព្វផ្សាយដោយយកចិត្តទុកដាក់ ធ្វើប្រពលវប្បកម្មស្រូវប្រាំង។ ហើយត្រូវធ្វើការបណ្តុះបណ្តាលអោយប្រជាជនចេះធ្វើថ្នាំពុលធម្មជាតិ ដើម្បីការពារជំងឺស្រូវ។ រីឯនៅពេលទំនេរត្រូវជម្រុញអោយមានការចិញ្ចឹមសត្វ បំផុសការដាំដំណាំសម្រាប់ចំណីសត្វផងដែរ។

ចំពោះអាជ្ញាធរដែនដី ត្រូវតែធ្វើខ្លួនជាអ្នកផ្តល់សេវាអោយប្រជារាស្ត្រយ៉ាងពិតប្រាកដដូចជា:

-ត្រូវចុះតាមដានស្ថានភាពជំងឺឆ្លងនានា លើសត្វពាហនៈ និងជម្រុញការចាក់ថ្នាំការពារ ជំងឺឆ្លងសត្វ។ ព្រមទាំងជម្រុញអនុវត្តនូវខ្លឹមសារនៃសេចក្តីប្រកាសលេខ០២ សប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការលុបបំបាត់ការប្រើឧបករណ៍ឆក់ត្រី និងឧបករណ៍នេសាទស្បៃមុង។

-ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់នូវបទបញ្ជាលេខ០១ បប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការទប់ស្កាត់ ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋធ្វើជាកម្មសិទ្ធិ។

-ខិតខំជម្រុញការផ្សព្វផ្សាយវារីវប្បកម្មទឹកសាប និងសមុទ្រអោយបានគ្រប់តំបន់ ក្នុងទូទាំងខេត្តកំពត។

-បន្តផ្សព្វផ្សាយច្បាប់ជលផលដល់គ្រប់សហគមន៍ និងតាមមូលដ្ឋានក្នុងទូទាំងខេត្ត។

-បង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា ដែលជួយលើវិស័យកសិកម្ម។

១.៨ វេនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីអំពី "**ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ចន្លោះឆ្នាំ ១៩៩៣-២០០៨**" ព្រមទាំងលើកយកករណីសិក្សាទៅលើស្រុកជុំគីរី ខេត្តកំពត មកបង្ហាញផងដែរ ដូច្នេះ ចេញពីចំណុចនេះ យើងបានធ្វើការសិក្សាទៅលើ ៥ជំពូក ដូចខាងក្រោម:

ជំពូក ១-សេចក្តីផ្តើម

ជំពូក ២-បញ្ញត្តិនៃភាពក្រីក្រ និងរំលឹកទ្រឹស្តី

ជំពូក ៣-ស្ថានភាពក្រីក្រនៅកម្ពុជា និងករណីសិក្សា នៅស្រុកជុំគីរី ខេត្តកំពត

ជំពូក ៤-វិភាគលើមូលហេតុ នៃភាពក្រីក្រនៅកម្ពុជា
ជំពូក ៥-សន្និដ្ឋាន និងអនុសាសន៍
ជាចុងក្រោយមានសន្និដ្ឋាន អនុសាសន៍ ឯកសារយោង និងឧបសម្ព័ន្ធ។

ជំពូកទី២
បញ្ហាត្តិនៃភាពក្រីក្រ និងរំលឹកទៅលើទ្រឹស្តី

២.១ បញ្ហាត្តិនៃភាពក្រីក្រ

២.១.១ និយមន័យ

យើងអាចអោយនិយមន័យ ភាពក្រីក្រ គឺជាស្ថានភាពដែលមានប្រាក់ចំណូលទាប មានការខ្វះខាតផ្នែកសម្ភារៈរូបវន្ត ផ្នែកកម្មសិទ្ធិ ទ្រព្យចាំបាច់ កង្វះខាតខាងការទទួលសេវាកម្មមូលដ្ឋានចាំបាច់ការគ្មានកាលានុវត្តភាព ខ្វះការអប់រំ ភាពគ្មានសិទ្ធិអំណាច និងទទួលការរើសអើងនៅក្នុងសង្គមទៀតផង[1]។

ម្យ៉ាងទៀត ភាពក្រីក្រគោកយ៉ាកបែបនេះ គេសង្កេតឃើញជនទាំងនោះបានប្រព្រឹត្តអំពើៈ ជើរសុំទាន ចោកម្ម ចាប់ជំរិត អំពើពេស្យាចារ រើសសំរាម..។ល។ ហើយលើសពីនេះយើងអាចពន្យល់បន្ថែមលើអត្ថន័យខាងលើបានថា អ្នកក្រីក្រ គឺជាក្រុមជនគ្មានឧត្តមភាព ដូចជា អ្នកផ្លាស់ទីលំនៅក្នុងស្រុក ជនភៀសខ្លួធ្វើមាតុភូមិនិវត្តន៍ ស្ត្រីមេម៉ាយដោយសារសង្គ្រាម កុមារកំព្រារ កុមាររស់នៅលើចិញ្ចើមថ្នល់ ជនរស់នៅក្នុងតំបន់អណាធិបតេយ្យ ជនបាត់បង់សមត្ថភាពពលកម្ម មនុស្សចាស់មានកម្លាំងបន្តិចបន្តួច មនុស្សគ្មានវិជ្ជាជីវៈ គ្មានចំណេះដឹង ។ល។ ទាំងអស់នេះហើយ គឺជាភាពក្រីក្រ ដែលមនុស្សគ្រប់រូបភ័យខ្លាច ហើយព្យាយាមជៀសវាងមិនអោយជួបប្រទះឡើយ។

២.២ ទ្រឹស្តីពាក់ព័ន្ធនឹងភាពក្រីក្រ

២.២.១ ទ្រឹស្តីកសិកម្ម និងការអភិវឌ្ឍន៍ជនបទក្នុងការកាត់បន្ថយភាពក្រីក្រ

ក.តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២

តាមរយៈចតុកោណទី១.ស្តីពីការលើកស្ទួយវិស័យកសិកម្មរួមមានៈ ម៉ុំទី១. ការលើកកម្ពស់ផលិតភាពកសិកម្ម និងពិធីកម្មកសិកម្ម។ ក្នុងនីតិកាលកន្លងមក រាជរដ្ឋាភិបាលសម្រេចបាននូវជោគជ័យគួរជាទីលើកទឹកចិត្តក្នុងការជម្រុញលើកកម្ពស់កំណើនសេដ្ឋកិច្ច។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណា កំណើននេះនៅមានមូលដ្ឋានតូចចង្អៀតនៅឡើយ ដោយសារវាពឹងផ្អែកជាសំខាន់ទៅលើវិស័យតែពីរប៉ុណ្ណោះ នោះគឺ ឧស្សាហកម្មកាត់ដេរ និងវិស័យទេសចរណ៍។ នេះជាប្រការ ដែលធ្វើអោយសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈងាយទទួលរងគ្រោះដោយសារអស្ថេរភាព និងវិបត្តិផ្សេងៗពីក្រៅប្រទេស។ ក្នុងន័យនេះ យើងមានសេចក្តីត្រូវការដ៏ចាំបាច់ក្នុងការពង្រឹង និងពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចជាតិ ដោយប្រើប្រាស់សក្តានុពលភាពសេដ្ឋកិច្ចក្នុងវិស័យផ្សេងៗទៀតអោយបានកាន់តែច្រើន ជាពិសេស វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដែលមានសក្តានុពលកំណើនដ៏ធំធេង

[1] ទស្សនៈ U.N.D.P(2005)

ហើយថែមទាំងអាចផ្តល់ឥទ្ធិពលជាវិជ្ជមានយ៉ាងធាប់រហ័ស ទៅលើកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីលើកកម្ពស់ជីវភាពប្រជាជននៅតាមទីជនបទទៀតផង[២]។

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់ ផលិតភាពកសិកម្ម និងពិពិធកម្ម (Diversification) វិស័យកសិកម្មអោយក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្តល់ជីវភាពបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ ក្នុងទិសដៅនេះរាជរដ្ឋាភិបាលនឹងបង្កើតការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដើម្បីធានាបាននិរន្តរភាពកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានានូវសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើអោយប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើតការនាំចេញកសិផល។ ក្នុងន័យនេះ ការបង្វែរទិសពីការអភិវឌ្ឍន៍តាមបែប "បែកទូលាយ" ឬតាមបែប "វិបុលកម្ម" ទៅកាន់ការអភិវឌ្ឍន៍តាមបែប "ស៊ីជម្រៅ" ឬតាមបែប "ប្រពលវប្បកម្ម" ពោលគឺ ការពង្រឹងសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់តាមរយៈប្រពលវប្បកម្មបានក្លាយទៅជាអាទិភាពដ៏ខ្ពស់បំផុតមួយរបស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលនឹងជម្រុញបង្កើតបរិយាកាសល្អ សម្រាប់ការចូលរួមរបស់ផ្នែកឯកជន ដើម្បីការលូតលាស់នៃវិស័យកសិកម្ម តាមរយៈការប្រឹងប្រែងពន្លឿនការផ្តល់កម្មសិទ្ធិដីធ្លីនៅតាមតំបន់ជនបទ ក្នុងទិសដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីកសិកម្ម ការពង្រីក និងបែងចែកដីធ្លីកសិកម្ម ក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រងធនធានទឹក ដោយយកចិត្តទុកដាក់ផងដែរដល់ការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ការបន្តបង្កើត និងពង្រឹងគុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក ព្រមទាំងការកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និងការពឹងផ្អែកទាំងស្រុងលើលក្ខខ័ណ្ឌធម្មជាតិ ។ល។

ក្នុងទិសដៅជម្រុញផលិតភាពកសិកម្ម រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់បន្ថែមទៀត ចំពោះការពង្រីកសេវាកម្មគាំទ្រដល់វិស័យនេះ ដូចជា ការស្រាវជ្រាវ និងផ្សព្វផ្សាយ ការអភិវឌ្ឍន៍ទីផ្សារកសិកម្ម ការបែងចែកសម្ភារៈ ពូជ ជី និងការផ្តល់ឥណទានជនបទ។ល។ ក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពជាពិសេស ទៅលើការតម្រង់ទិសកិច្ចការ វិនិយោគសាធារណៈ និងការលើកទឹកចិត្តវិនិយោគឯកជនអោយឆ្ពោះទៅរកវិស័យកសិកម្ម សំដៅការលើកកម្ពស់កំណើនកសិផល និងធានាគុណភាពកសិផលកម្ពុជាអោយឆ្លើយតបទៅនឹងការតម្រូវនៃស្តង់ដារអន្តរជាតិ។

រាជរដ្ឋាភិបាលបានបន្តផ្តល់អាទិភាពទៅលើកិច្ចការអភិវឌ្ឍន៍តំបន់ព្រំដែន និងតំបន់ដាច់ស្រយាលដើម្បីទប់ស្កាត់ការធ្វើចំណាកចោលស្រុក តាមរយៈការរៀបចំ និងកសាងតំបន់ទីប្រជុំជនមួយចំនួន ដែលមាន

---

[២] ទស្សនៈទានរបស់រាជរដ្ឋាភិបាលអាណត្តិទី៣ (សុន្ទរកថាស្តីពី "យុទ្ធសាស្ត្រចតុកោណ" របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន) ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤

បណ្តាញហេដ្ឋារចនាសម្ព័ន្ធសមស្រប សម្រាប់សម្រួលដល់ជីវភាពរស់នៅ និងការចូលរួមទៅក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនៅទីនោះ។

រាជរដ្ឋាភិបាលបន្តជម្រុញចលនា "ភូមិមួយ-ផលិតផលមួយ" ដើម្បីលើកស្ទួយគំនិតច្នៃប្រឌិត និងជំនឿលើខ្លួនឯងរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ ដោយឈរលើគោលការណ៍សំខាន់ៗបួនយ៉ាងគឺ: (ទី១) ការរិះរកវិធីផលិត ដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃបរិស្ថានភូមិឋាន និងសមស្របទៅតាមសេចក្តីត្រូវការរបស់ទីផ្សារ (ទី២) ការបង្កលក្ខណៈងាយស្រួល និងការផ្តល់ការលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការផលិត ដូចជាការស្វែងរកទីផ្សារ ការផ្តល់ឥណទាន ការផ្ទេរបច្ចេកវិទ្យា និងការផ្តល់ពូជ (ទី៣) ការជួយបណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រង និងធនធានមនុស្ស និង(ទី៤) បង្កលក្ខណៈងាយស្រួលអោយប្រជាពលរដ្ឋបង្កើតសហគមន៍កសិកម្ម ក្នុងទិសដៅធានាតម្លៃផលិតផល។

មុំទី២. កំណែទម្រង់ដីធ្លី និងការបោសសំអាតមីន:

ដី និងទឹក គឺជាធនធានធម្មជាតិសំខាន់ពីរជាមូលដ្ឋាន ដែលអាចយកមកប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ។ ដោយបន្តអនុវត្តច្បាប់ភូមិបាល និងគោលនយោបាយដីធ្លី រាជរដ្ឋាភិបាលប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និងដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ធានាសុវត្ថិភាពនៃកម្មសិទ្ធិលើដីធ្លី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុន ដោយមិនប្រើប្រាស់ មិនធ្វើផលិតកម្ម ឬអាជីវកម្ម ។ល។ រាជរដ្ឋាភិបាលពិនិត្យឡើងវិញនូវដីទំនេររបស់រដ្ឋ ឬដីរដ្ឋ ដែលឯកជនកាន់កាប់ ដោយមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក។ រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពដល់ការពង្រឹងសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ដែលត្រូវការដីសម្រាប់សង់លំនៅដ្ឋាន និងធ្វើអាជីវកម្មកសិកម្មជាគ្រួសារ ក្នុងក្របខ័ណ្ឌដីសម្បទាន ដើម្បីគោលដៅសង្គមកិច្ច ដោយឈរលើគោលការណ៍ជួយគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ។

រាជរដ្ឋាភិបាលយល់ច្បាស់ថា ការបោសសំអាតមីនមិនមែនគ្រាន់តែជាបញ្ហាសន្តិសុខមួយមុខប៉ុណ្ណោះទេ ប៉ុន្តែវាពាក់ព័ន្ធទៅនឹងបញ្ហាសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ជារួម ជាពិសេសបញ្ហាការផ្តត់ផ្តង់ដី និងការផ្តល់សុវត្ថិភាពក្នុងការប្រកបអាជីវកម្មនៃគ្រួសារកសិករក្រីក្រនៅទីជនបទជាក់ស្រយាល។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងអនុវត្តការងារតាមនីតិវិធី ដែលបានរៀបចំ ដើម្បីធានាសកម្មភាពកម្ចាត់មីន ដែលកំពុងអនុវត្តនៅកម្ពុជាអោយមានសុវត្ថិភាព មានការសម្របសម្រួល និងមានផែនការល្អ និងអនុវត្តតាមស្តង់ដារជាតិ និងកាតព្វកិច្ចអន្តរជាតិ។

មុំទី៣. កំណែទម្រង់វិស័យនេសាទ និងជលផល:

មច្ឆជាតិមានសារៈសំខាន់ជាអាយុជីវិត សម្រាប់ប្រជាជនកម្ពុជារាប់លាននាក់ ដោយផ្តល់ជាស្បៀងអាហារ ជាចំណូល និងការរស់នៅ ហើយគួបផ្សំនឹងអង្ករ ត្រីដែលជាផ្នែកមួយសំខាន់នៃសន្តិសុខស្បៀងបានផ្តល់

ប្រូតេអ៊ីនចំនួនបីភាគបួនដល់ប្រជាជនចំនួន ២លាននាក់។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាល បានដាក់ចេញនូវ វិធានការអភិវឌ្ឍន៍វិស័យជលផលប្រកបដោយចីរភាព និងមានសមធម៌ ដោយប្រគល់សិទ្ធិអំណាចទៅអោយ សហគមន៍ជនបទ និងកម្មវិធីនានា ហើយទទួលខុសត្រូវគ្រប់គ្រងធនធានជលផលដោយខ្លួនឯង។

រាជរដ្ឋាភិបាលនឹងបង្វែរឡូត៍នេសាទចប់កិច្ចសន្យាមួយចំនួន ទុកជាកន្លែកអភិរក្សពូជត្រីសម្រាប់បង្កើត ផ្តល់ស្តុកធម្មជាតិផង និងរក្សាពូជត្រីដែលស្ទើរផុតពូជអោយកើនមានសម្បូរឡើងវិញផង ព្រមទាំងជម្រុញបង្កើន ទំហំដែននេសាទសម្រាប់ជូនប្រជាពលរដ្ឋប្រើប្រាស់ និងជម្រុញការអភិវឌ្ឍន៍ផ្នែកវារីវប្បកម្ម ដើម្បីឆ្លើយតបទៅ នឹងតម្រូវការសាច់ត្រីកើនឡើងផង ព្រមទាំងបន្តយសម្គាធលើធនធានជលផលធម្មជាតិផងដែរ។

មុំទី៤. កំណែទម្រង់ព្រៃឈើ:

គោលដៅនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល នៅក្នុងព្រៃឈើ គឺធានាអោយបាននូវការគ្រប់គ្រងព្រៃឈើ ប្រកបដោយចីរភាព ដោយឈរលើមូលដ្ឋាននៃសសរទ្រូងបីសំខាន់ៗ:

ទី១. គោលនយោបាយគ្រប់គ្រងព្រៃឈើ ប្រកបដោយចីរភាព ដោយមានការត្រួតពិនិត្យអាជីវកម្មព្រៃ ឈើយ៉ាងហ្មឺងម៉ាត់ និងសមស្របតាមនិយាមនៃការគ្រប់គ្រងព្រៃឈើអន្តរជាតិ ដែលតម្រូវអោយមានទំហំព្រៃ ឈើបម្រុងទុកគ្រប់គ្រាន់សម្រាប់ទប់ទល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ និងសម្រាប់ការពារភាពរាំងស្ងួត និង ទឹកជំនន់ ព្រមទាំងមានព្រៃលិចទឹកសម្រាប់ទុកជាជម្រកមច្ឆជាតិ។

ទី២. ប្រព័ន្ធការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចម្រុះ និងប្រភេទដែលកម្រ។

ទី៣. ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើមួយ ដែលរឹងមាំមានតម្លាភាព និងមានការ គ្រប់គ្រងដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងតំបន់នោះ។

រាជរដ្ឋាភិបាលបានផ្អាក និងពិនិត្យអាជីវកម្មព្រៃឈើសម្បទាន ដែលនៅសេសសល់ទាំងអស់ឡើងវិញ ដើម្បីវាយតម្លៃស្ថានភាពបច្ចុប្បន្ន សំដៅទៅលើការគ្រប់គ្រងអោយមានប្រសិទ្ធភាព។ ទន្ទឹមនេះរាជរដ្ឋាភិបាល នឹងបន្តជម្រុញគោលនយោបាយដាំដុះព្រៃឈើឡើងវិញ[៣]។

ដោយឡែកនៅប្រទេសកម្ពុជាយើង វិស័យកសិកម្មគ្រួសារមានតួនាទីយ៉ាងសំខាន់ ដោយផ្តល់នូវឱកាស ការងារដល់មនុស្សប្រមាណជាពីរភាគបីនៃប្រជាជនសរុប និងរួមចំណែកដល់សន្តិសុខស្បៀង និងសេដ្ឋកិច្ចជាតិ។ លើសពីនេះទៅទៀត កសិកម្មមានតម្លៃផ្នែកវប្បធម៌ និងបរិស្ថាន និងមានមុខងារសំខាន់សម្រាប់សង្គមកម្ពុជា។ ស្ថិតក្រោមបរិបទនៃការផ្លាស់ប្តូរយ៉ាងល្បឿនផ្នែកនយោបាយ សេដ្ឋកិច្ច និងបច្ចេកវិទ្យា ការគម្រាមកំហែងចំពោះ និរន្តរភាព និងផលិតភាព នៃកសិកម្មគ្រួសារកាន់តែមានលក្ខណៈកើនខ្លាំងឡើងៗ[៤]។

---

[៣] ទស្សនៈទានរបស់រាជរដ្ឋាភិបាលអាណត្តិទី៣(សុន្ទរកថាស្តីពី "យុទ្ធសាស្ត្រចតុកោណ" របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន) ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤

[៤] NGO ស្តីពី "ការកាត់បន្ថយភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣" ខែមីនា ឆ្នាំ២០០៤ ទំព័រទី១

បញ្ហាសំខាន់ៗដែលជាកង្វល់ចំពោះកសិកម្ម និងការអភិវឌ្ឍន៍ជនបទ មានដូចខាងក្រោម:

-កំណើននៃសំពាធលើធនធានដីធ្លី ដែលបណ្តាលមកពីកំណើននៃការធ្វើសម្បទានព្រៃឈើ និងសម្បទានដីកសិកម្ម ការរកចំណេញពីការតំឡើងថ្លៃដីធ្លី និងកំណើនប្រជាពលរដ្ឋ។ ស្ថានភាពនេះរារាំងលទ្ធភាពក្នុងការទទួលបាននូវធនធានព្រៃឈើ និងដីធ្លីរបស់ប្រជាកសិករ ដែលកំពុងតែកើនឡើង។

-កំណើននៃការហូរចូលនូវផលិតផលពីបណ្តាប្រទេសផ្សេងៗទៀត។ ជាទូទៅ ទំនិញទាំងអស់ ដែលនាំចូលមានលក្ខណៈប្រកួតប្រជែងជាងទំនិញក្នុងស្រុក ដែលជាហេតុបន្ទុចបង្អាក់ដល់កសិករតូចតាច ជាពិសេសកសិករដែលធ្វើស្រែចំការ ដើម្បីចិញ្ចឹមជីវិតមិនអោយវិនិយោគក្នុងវិស័យកសិកម្ម។ កសិករកម្ពុជាគ្មានលក្ខណៈប្រគួតប្រជែងទេ ព្រោះពួកគេមានលទ្ធភាពតិចតួចក្នុងការទទួលបានបច្ចេកវិទ្យាគ្រាប់ពូជ ប្រព័ន្ធធារាសាស្ត្រ និងឧបករណ៍ផ្សេងៗទៀត។ លើសពីនេះទៅទៀត ពួកគេមិនទាន់មានការរៀបចំល្អនៅឡើយទេ។ ការចូលជាសមាជិករបស់កម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក(WTO) និងតែតែធ្វើអោយស្ថានភាពនេះកាន់តែអាក្រក់ទៅៗ ប្រសិនបើគ្មានយន្តការសមស្របសម្រាប់លើកកម្ពស់សមត្ថភាបកសិកម្មក្នុងស្រុក ដើម្បីដោះស្រាយដោយជោគជ័យជាមួយពាណិជ្ជកម្មសេរីទេនោះ។

-មានការពឹងផ្អែកយ៉ាងខ្លាំងទៅលើទំនិញនាំចូល មានន័យថា ជាការចំណាយខ្ពស់ ជាពិសេស ការចំណាយលើជី និងថ្នាំសម្លាប់សត្វល្អិត ដែលធ្វើអោយបាត់បង់អស់នូវចំណូលរបស់កសិករតូចតាច។ យ៉ាងហោចណាស់ទឹកប្រាក់ប្រមាណ ៥០លានដុល្លារ ត្រូវបានចំណាយដើម្បីទិញទំនិញទាំងនេះក្នុងមួយឆ្នាំៗ។

-ចំនួនយុវជននៅតាមជនបទកំពុងតែកើនឡើង ប៉ុន្តែជាទូទៅពួកគេគ្មានឱកាសទទួលបាននូវជំនាញវិជ្ជាជីវៈផ្សេងៗក្នុងវិស័យកសិកម្ម សហគ្រាសជនបទ និងការអភិវឌ្ឍន៍មូលដ្ឋានឡើយ។ កត្តានេះនាំអោយប៉ះពាល់ដល់ការអភិវឌ្ឍន៍រយៈពេលវែងនៅសហគមន៍ជនបទ។

-ចំនួនកសិករតូចតាចកាន់តែច្រើនឡើងជំពាក់បំណុលគេ ជាពិសេសដោយសារការចំណាយលើការថែទាំងសុខភាព និងចំណាយលើវត្ថុធាតុដើមផ្នែកកសិកម្ម។ ជាទូទៅដោយសារពួកគេជាកសិកម្មធ្វើស្រែចំការដើម្បីចិញ្ចឹមជីវិត ហើយពួកគេគ្មានលទ្ធភាពក្នុងការធ្វើសកម្មភាពណាផ្សេងក្រៅពីកសិកម្ម ដើម្បីរកចំណូលនោះឡើយ។ ដូច្នេះ ពួកគេត្រូវខ្ចីបុលពីអ្នកចងការប្រាក់ឯកជន និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។ បើទោះបីជាសេវាកម្មនៃស្ថាប័នមីក្រូហិរញ្ញវត្ថុ នៃអង្គការក្រៅរដ្ឋាភិបាលកំពុងតែកើនឡើងៗក៏ដោយ ក៏អត្រាការប្រាក់សម្រាប់កសិកររនៅតែមានកម្រិតខ្ពស់នៅឡើយ។ បន្ថែមលើពីនេះទៀត ពួកគេពុំបានវិនិយោគថវិការបស់ខ្លួនលើផលិតកម្ម កសិកម្មឡើយ ដោយសារកង្វះខាតនៃការទទួលបានព័ត៌មានបច្ចេកទេស។

បើទោះបីជាមានសារៈសំខាន់ និងមានការគម្រាមកំហែងចំពោះកសិកម្ម ដែលមានលក្ខណៈជាគ្រួសារយ៉ាងណាក៏ដោយ ក៏គេពុំឃើញមានអាទិភាព និងកម្មវិធីច្បាស់លាស់ណាមួយតម្រង់ទិសទៅគាំទ្រការអភិវឌ្ឍន៍កសិកម្ម ចំពោះកសិករតូចតាចឡើយ តែផ្ទុយទៅវិញ រាជរដ្ឋាភិបាលបានផ្តោតលើកសិ-ពាណិជ្ជកម្ម និងកសិកម្មដែលមានលក្ខណៈទ្រង់ទ្រាយធំនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ខ្លួនទៅវិញ។

ដូច្នេះ នៅត្រង់ចំណុចនេះរាជរដ្ឋាភិបាល និងសហគមន៍ប្រទេសផ្តល់ជំនួយ សហការជាមួយវិស័យឯកជនអង្គការក្រៅរដ្ឋាភិបាល និងកសិករនៅតាមជនបទ ដើម្បីរៀបចំនូវគោលនយោបាយ និងកម្មវិធីផ្សេងៗ សម្រាប់លើកកម្ពស់ដល់កសិករតូចតាច និងការអភិវឌ្ឍន៍កសិកម្មដោយមិនប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី។ យើងមានជំនឿយ៉ាងមុតមាំថា ស្ថេរភាពសេដ្ឋកិច្ច សង្គមកិច្ច និងស្ថេរភាពនយោបាយនៅកម្ពុជាពឹងផ្អែកជាសំខាន់លើការធ្វើអោយប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់គ្រួសារកសិករតូចតាចប្រមាណជាង ២.៥ លាននាក់។ ក្នុងន័យនេះ ដើម្បីអោយជំនឿយ៉ាងមុតមាំរបស់យើង ក្លាយទៅជាការពិតជាក់ស្តែង ចាំបាច់ត្រូវតែលើកឡើងនូវសំណើមួយចំនួនចំពោះរាជរដ្ឋាភិបាល ដូចជា: ទី១-យើងសូមស្នើយ៉ាងទទូចថា គប្បីជាក់កំហិតចំពោះសម្បទានដីកសិកម្ម[5]។ ការផ្តល់សម្បទានបែបនេះ គប្បីមានការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ផង។ គប្បីមានការវិភាគត្រឹមត្រូវអំពីការខាតបង់ និងផលចំណេញលើទិដ្ឋភាពសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន។ លទ្ធភាពសម្រាប់កសិករតូចតាចក្នុងការទទួលផលពីព្រៃឈើ និងដីធ្លី គប្បីជាអាទិភាពមួយ។ ទី២- ការផ្សព្វផ្សាយកសិកម្ម ត្រូវពង្រឹងតាមរយៈការបង្កើតនូវប្រព័ន្ធនៃការផ្សព្វផ្សាយកសិកម្មមួយ ដែលមានប្រសិទ្ធភាព មានលក្ខណៈវិមជ្ឈការនៅថ្នាក់ស្រុក។ ការិយាល័យនេះគួរមានប្រព័ន្ធផ្តល់សេវាចម្រុះបំពេញកិច្ចការទាំងឡាយ ដូចជា ការផ្សព្វផ្សាយព័ត៌មាន សម្រួលការគាំទ្រដល់អង្គការ កសិករ និងបណ្តាញការងារកសិករ ព្រមទាំងធានាបរិស្ថានគាំពារមួយសម្រាប់ប្រព័ន្ធផ្តល់សេវាចម្រុះ។ ទី៣-លើសពីនេះទៀត ដើម្បីកែលម្អការផ្សព្វផ្សាយវិស័យកសិកម្ម ក៏តម្រូវអោយមានការគាំទ្រផងដែរ ចំពោះកសិករតូចតាច ដើម្បីអោយពួកគាត់អាចដោះស្រាយបានដោយជោគជ័យនូវបរិបទនៃការផ្លាស់ប្តូរយ៉ាងលឿនលើវិស័យសេដ្ឋកិច្ច សង្គម នយោបាយ បច្ចេកវិទ្យា និងបរិស្ថាន។ អោយមានការជួយកសិករក្នុងការរៀបចំពួកគេជាសមាគម និង/ជាសហករណ៍។ គប្បីមានអង្គការតំណាងពិតប្រាកដចំពោះផលប្រយោជន៍កសិករ និងអនុញ្ញាតអោយកសិកររួមសកម្មភាពរួមសម្រាប់ផលប្រយោជន៍ទៅវិញទៅមក និងសម្រាប់សហគមន៍។ អ្នកតំណាងអង្គការកសិករ គួរត្រូវបានអញ្ជើញចូលរួមក្នុងរាល់ដំណើរការនៃការពិគ្រោះយោបល់ពាក់ព័ន្ធនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍កសិកម្ម។ ការគាំទ្រផ្នែកបច្ចកទេស ការគ្រប់គ្រងឥណទាន និងរកទីផ្សារលក់ផលិតផល គួរតែត្រូវបានផ្តល់ជូនដល់អង្គការកសិករទាំងនេះ។ ទី៤-គប្បីមានការវិនិយោគលើគម្រោងសាល្បងផ្សេងៗ ដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់យុវជននៅជនបទ យុវកសិករទាក់ទងនឹងការអភិវឌ្ឍន៍សហគ្រាសជនបទ ការអភិវឌ្ឍន៍មូលដ្ឋានភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង។ ជោគជ័យនៃគម្រោងនេះនឹងផ្តល់ផលប្រយោជន៍រយៈពេលវែងដល់សហគមន៍ជនបទ តាមរយៈវត្តមាននៃធនធានមនុស្ស ដែលមានសមត្ថភាពនៅថ្នាក់មូលដ្ឋាន។ ទី៥-គប្បីពង្រឹងការអនុវត្តន៍ច្បាប់លើសារធាតុគីមី សម្រាប់កសិកម្ម ជាពិសេសថ្នាំសម្លាប់សត្វល្អិតតាមរយៈការ

[5] CEDAC(២០០២) មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ភ្នំពេញ។

គ្រប់គ្រង ការនាំចូល ការផលិត ការចែកចាយ ការរកទីផ្សារ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ថ្នាក់លេខ១[៦] និង ថ្នាំផ្សេងទៀត ជាពិសេស DDI និង Endosulfan[៧]។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល និងក្រសួងបរិស្ថាន សកម្មបន្ថែមទៀតក្នុងការផ្សព្វផ្សាយដល់សាធារណៈជនតាមរយៈសារព័ត៌មាន វិទ្យុ និង ទូរទស្សន៍ អំពីបញ្ហាដែលបណ្តាលមកពីថ្នាំសម្លាប់សត្វល្អិត។ រៀបចំការបណ្តុះបណ្តាលអំពីថ្នាំសម្លាប់សត្វល្អិត និងសុខភាពចំពោះមន្ត្រីសុខាភិបាល ដើម្បីអោយពួកគេបានយល់អំពីជំងឺ ឬបញ្ហាសុខភាពពាក់ព័ន្ធនឹងការប្រើ ប្រាស់ថ្នាំសម្លាប់សត្វល្អិត[៨]។

រាជរដ្ឋាភិបាល ប្រទេសផ្តល់ជំនួយ ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល ប្រមូលផ្តុំធនធាន និង ប្រមូលផ្តុំជំនាញលើការស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មានអំពីការអនុវត្តន៍ថ្មីៗពាក់ព័ន្ធទៅនឹងវត្ថុធាតុដើមពី បរទេស ដែលមានតម្លៃថោក កសិកម្មមិនបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងបរិស្ថាន ព្រោះថា ទាំងអស់នេះ គឺជាវិធីសាស្ត្រដែលអាចកាត់បន្ថយភាពក្រីក្រ។ ឧទាហរណ៍ ប្រព័ន្ធអេកូឡូស៊ី នៃការធ្វើប្រពលវប្បកម្មដំណាំស្រូវ (SRI) គឺជាវិធីសាស្ត្រមួយដ៏មានជោគជ័យបំផុតក្នុងការសម្រេចអោយបាននូវដំណើនផលស្រូវយ៉ាងខ្លាំង ដោយមិនពឹងផ្អែកលើវត្ថុធាតុនាំចូលពីបរទេសដូចជា ជី និងថ្នាំសម្លាំសត្វល្អិត[៩]។ បច្ចុប្បន្ននេះកសិកម្មកម្ពុជា ប្រមាណជា ១០ ០០០នាក់ បានប្រើប្រាស់ប្រព័ន្ធនេះហើយមានប្រព័ន្ធនេះសក្តានុពលពង្រីកយ៉ាងឆាប់រហ័ស។ អង្គការក្រៅរដ្ឋាភិបាល អង្គការរដ្ឋ ម្ចាស់ជំនួយ និងអង្គការអន្តរជាតិ(ដូចជា GTZ, Oxfam, JICA និងADB) បានផ្តល់ធនធានដើម្បីគាំទ្រគម្រោងប្រពលវប្បកម្មដំណាំស្រូវនេះ។ បើមានការគាំទ្រកាន់តែខ្លាំងបន្ថែមទៀតពី ម្ចាស់ជំនួយពីរាជរដ្ឋាភិបាល និងពីអង្គការក្រៅរដ្ឋាភិបាល កសិកររនៅកម្ពុជានឹងអាចប្រើប្រាស់ប្រព័ន្ធនេះក្នុងរយៈ ពេលពី ៥ ទៅ ១០ឆ្នាំខាងមុខ ដែលអាចជួយកាត់បន្ថយបញ្ហាបច្ចុប្បន្នពាក់ព័ន្ធទៅនឹងគ្រួសារ និងសន្តិសុខស្បៀង។

ពាក់ព័ន្ធនឹងបញ្ហាធារាសាស្ត្រវិញ ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលគាំទ្រប្រព័ន្ធធារាសាស្ត្រ ខ្នាតតូចតាម រយៈការជួយសហគមន៍ ដើម្បីរៀបចំខ្លួនគេក្នុងសហគមន៍ប្រើប្រាស់ទឹកជាជាងការផ្តោតលើប្រព័ន្ធធារាសាស្ត្រ

---

[៦] អនុក្រឹត្យរបស់រាជរដ្ឋាភិបាល នៅខែតុលា ឆ្នាំ១៩៩៨ រាល់ថ្នាំសម្លាប់សត្វល្អិតថ្នាក់លេខ១ ទាំងអស់ត្រូវបានហាមឃាត់នៅ កម្ពុជា។ ប៉ុន្តែអនុវត្តមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

[៧] Endosulfan ត្រូវហាមឃាត់ នៅខែមីនា ឆ្នាំ២០០៣ ដោយក្រសួងពាណិជ្ជកម្ម តាមសំណើរបស់ក្រសួងសុខាភិបាល។ DDT ស្ថិតក្នុងថ្នាំសម្លាប់សត្វល្អិតប្រភេទលេខ២ ហើយស្ថិតក្នុងបញ្ជីនៃអនុសញ្ញាក្រុងស្តុកខុល ស្តីពីថ្នាំធ្វើអោយកង្វក់សរីរាង្គ POPs(ប្រទេសកម្ពុជា ជាហត្ថលេខីចំពោះអនុសញ្ញានេះ)។

[៨] ឧទាហរណ៍ EJF (២០០២) មរណភាពដោយសារកម្រិតបន្តិចបន្តួច: បញ្ហាថ្នាំសម្លាប់សត្វល្អិត និងដំណោះស្រាយនៅ កម្ពុជា មូលនិធិយុត្តិធម៌បរិស្ថាន ក្រុងឡុងដ៏ចក្រភពអង់គ្លេសCEDAC (២០០៣) ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនៅ កម្ពុជា ឯកសារចុះតាមមូលដ្ឋានរបស់CEDACមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ភ្នំពេញ។

[៩] ឃុាំង សាំងកុមារ (២០០១) ការពិសោធន៍របស់កសិកររនៅក្នុងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ(SRI): លទ្ធផលរដូវឆ្នាំ ២០០០ ភ្នំពេញ ឃុាំង សាំងកុមា(២០០២) ប្រព័ន្ធអេកូឡូស៊ីនៃប្រពលវប្បកម្មដំណាំស្រូវនៅកម្ពុជា លទ្ធផល និង បទសោធន៍នៅមូលដ្ឋាន ឆ្នាំ២០០០-២០០១

ខ្នាតធំ។ ហើយជាបន្ត រាជរដ្ឋាភិបាលត្រូវមានការអនុម័តគោលនយោបាយ និងកម្មវិធីដើម្បីគាំទ្រការផលិតគ្រាប់ពូជនៅសហគមន៍ និងផ្លាស់ប្តូរគំនិតផ្តួចផ្តើម ដែលអាចធានាសិទ្ធិរបស់សហគមន៍កសិករតូចតាចក្នុងការទទួលគ្រាប់ពូជ។ ក្នុងន័យនេះ កិច្ចខិតខំប្រឹងប្រែង ដើម្បីអភិវឌ្ឍន៍មិនគួរប្រើផ្តោតលើការបង្កើតអោយមានការពឹងផ្អែករបស់កសិករតូចតាចលើក្រុមហ៊ុនគ្រាប់ពូជនោះទេ តែផ្តោតលើការពង្រឹងសហគមន៍ក្នុងការបង្កាត់ពូជ និងផ្លាស់ប្តូរគ្រាប់ពូជ។ ក៏ប៉ុន្តែ ក៏ត្រូវមានបទបញ្ញត្តិស្តីពី គុណភាពគ្រាប់ពូជ ដែលដាក់លក់ផងដែរ។ ជាចុងក្រោយ ជាមួយនឹងការកើនឡើងនៃភាពមិនច្បាស់លាស់ និងការពួយប្រារម្ភអំពីផលប៉ះពាល់ជាអវិជ្ជមាន ដែលអាចកើតមានពីផលិតផលដែលកែប្រែពូជ(Genetically Modified Organism-GMOs) មកលើសុខភាពអេកូឡូស៊ី និងមកលើជីវភាពរស់នៅរបស់កសិករតូចតាចយើងគាំទ្រយ៉ាងពេញទំហឹង ចំពោះគំនិតផ្តួចផ្តើមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបញ្ឈប់ផលិតផល GMOs នៅកម្ពុជា។ រាល់ជំនួយជាស្បៀងអាហារទាំងអស់ត្រូវបានត្រួតពិនិត្យអោយបានត្រឹមត្រូវ ដើម្បីធានាថា ស្បៀងទាំងនោះមិនមែនជាផលិតផល GMOs។

ដើម្បីឆ្លើយតបទៅនឹងទ្រឹស្តីនេះ ជាឧទាហរណ៍ ស្រុកជុំគីរី សំបូរទៅដោយប្រជាជនប្រកបរបរកសិកម្ម ដូច្នេះ ផែនការកាត់បន្ថយភាពក្រីក្រនៅស្រុកជុំគីរី តាមវិស័យកសិកម្ម ត្រូវបានផ្តោតជាសំខាន់ទៅលើ:[90] ១-រក្សាបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសមស្រប និងគោលនយោបាយលើកទឹកចិត្ត និងបរិស្ថានដែលមានភាពអនុគ្រោះ។ ២-ពន្លឿនការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រប្រកបដោយចីរភាព រួមទាំងធានាដល់កសិករអាចគ្រប់គ្រងទឹកបានយ៉ាងខ្លាំងឡើងៗ។ ៣-អភិវឌ្ឍន៍ការដាំដុះមានផលិតភាពខ្ពស់ និងឈរលើមូលដ្ឋានដាំដំណាំច្រើនមុខ។ ៤-អនុវត្តន៍អោយបានឆាប់រហ័សនូវការចេញកម្មសិទ្ធិ និងការបែងចែកដីកសិកម្ម ដែលទទួលបានការដោះមីន។ ៥-រកទីផ្សារនាំស្រូវចេញ និងកសិផលផ្សេងទៀត ទន្ទឹមនឹងការពង្រឹងការកែច្នៃកសិផល និងប្រព័ន្ធគ្រប់គ្រងគុណភាពកសិផល។ ៦-ពង្រឹងសេវា និងការគ្រប់គ្រងវិស័យកសិកម្មសំខាន់ៗរួមមាន ការផ្សព្វផ្សាយកសិកម្ម ការស្រាវជ្រាវ ការអភិវឌ្ឍន៍ផ្នែកទីផ្សារឥណទាន និងមានការបែងចែកវត្ថុធាតុដើមកសិកម្ម។ ៧-ពង្រឹងការចិញ្ចឹមសត្វ ផ្តោតលើការថែរក្សាសុខភាពសត្វ អាហារសត្វ ការគ្រប់គ្រងកសិដ្ឋានក្នុងការចិញ្ចឹមមាន់ ការចិញ្ចឹមជ្រូក និងការផលិតចំណីសត្វ។ ៨-ការពង្រឹង ការគ្រប់គ្រង និងការដាក់អោយប្រើប្រាស់បច្ចេកទេសវិទ្យាសាស្ត្រសមស្របសម្រាប់ចិញ្ចឹមសត្វតាមវាលស្រែ និងការចិញ្ចឹមសត្វទូទៅ។ ៩-ការពង្រឹងសមត្ថភាពរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧត្តុនិយម ទាំងនូវថ្នាក់កណ្តាល និងខេត្ត/ក្រុង។

[90] រាជរដ្ឋាភិបាលសហការជាមួយ UNDP unifem និង Bank របាយការណ៍ឆ្នាំ២០០៣ ស្តីពីការវិភាគយេនឌ័រនៅកម្ពុជា

ខ-គោលនយោបាយក្នុងវិស័យកសិកម្មរដ្ឋាភិបាលអាណត្តិទី៤

រាជរដ្ឋាភិបាល បន្តអភិវឌ្ឍន៍វិស័យកសិកម្មអោយរីកចម្រើន អោយក្លាយជាវិស័យនាំមុខមួយពិតប្រាកដ នៃសេដ្ឋកិច្ចជាតិ ធ្វើជាប្រភពកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ពង្រីកមូលដ្ឋាននៃសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈការលើកទឹកចិត្តដល់វិស័យឯកជនអោយចូលរួមក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម កសិ-ឧស្សាហកម្ម កសិ-ពាណិជ្ជកម្ម និងឧស្សាហកម្មកែច្នៃម្ហូបអាហារ ការជម្រុញ និងលើកទឹកចិត្តដល់ការដាំដុះ ដំណាំ ដោយប្រើប្រាស់ជីធម្មជាតិ ការលើកកម្ពស់គុណភាព និងទិន្នផលកសិផលក្នុងស្រុក ដើម្បីបម្រើទីផ្សារក្នុងប្រទេស និងជម្រុញការនាំចេញកសិផល។

រាជរដ្ឋាភិបាល បន្តជំរុញការអភិវឌ្ឍន៍ចម្ការកៅស៊ូទាំង៣ ប្រភេទ គឺចម្ការកៅស៊ូរដ្ឋ ចម្ការកៅស៊ូឯកជនធំៗ និងចម្ការកៅស៊ូគ្រួសារ ដោយខិតខំពង្រីកផ្ទៃដីដាំកៅស៊ូ និងលើកទឹកចិត្តកសិករអោយបង្វែរពីការដាំដំណាំផ្សេងៗមកដាំកៅស៊ូវិញនៅលើដី ដែលអាចដាំកៅស៊ូបាន បន្តធ្វើឯកជនភាវូបនីយកម្មលើចម្ការកៅស៊ូរដ្ឋ ខិតខំស្វែងរកថវិកាពីប្រភពផ្សេងៗ ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍន៍កៅស៊ូគ្រួសារ និងឯកជន និងលើកទឹកចិត្ត ការវិនិយោគផ្នែកសិប្បកម្ម ឧស្សាហកម្ម ដែលប្រើជ័រកៅស៊ូ និងឈើកៅស៊ូ សម្រាប់ផលិតចេញជាផលិតផលសម្រេច។

ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

រាជរដ្ឋាភិបាល ពង្រីកការគ្រប់គ្រងការថែរក្សា និងការធ្វើអាជីវកម្មធនធានព្រៃឈើ និងធនធានជលផល អោយបានត្រឹមត្រូវតាមគោលការណ៍ច្បាប់ ដោយធានាផលប្រយោជន៍របស់ប្រជាជនទូទៅ និងផលប្រយោជន៍សហគមន៍ ក្នុងគោលដៅធានាប្រសិទ្ធភាពសេដ្ឋកិច្ច និងចីរភាពនៃធនធានព្រៃឈើ និងជលផល តាមរយៈចលនាដាំដុះព្រៃឈើឡើងវិញ ការអភិវឌ្ឍន៍វារីវប្បកម្ម ការទប់ស្កាត់ និងការដាក់ទោសយ៉ាងម៉ឺងម៉ាត់តាមច្បាប់ ចំពោះរាល់សកម្មភាពបំផ្លិចបំផ្លាញធនធានព្រៃឈើ និងធនធានជលផលរបស់ជាតិ។

រាជរដ្ឋាភិបាល បន្តថែរក្សា អភិរក្ស ការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងធនធានដីវចម្រុះរបស់ប្រទេសជាតិ អោយមានចីរភាពក្នុងប្រព័ន្ធអេកូឡូស៊ី ដោយទប់ស្កាត់រាល់សកម្មភាពបំផ្លាញគុណភាពបរិស្ថាន និងធនធានធម្មជាតិ ជាមួយនឹងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច តាមរយៈការបង្កើនការចូលរួមពីសហគមន៍មូលដ្ឋាន ការពង្រឹងស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន ការធ្វើសមាហរណកម្មគោលនយោបាយបរិស្ថានទៅក្នុងផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ព្រមទាំងការពង្រឹងការអនុវត្តច្បាប់ស្តីពីបរិស្ថាន។

ការគ្រប់គ្រងធនធានទឹក

រាជរដ្ឋាភិបាល បន្តគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកអោយមានប្រសិទ្ធិភាពចីរភាព និងមានសមធម៌ សំដៅធានាការថែរក្សាប្រព័ន្ធអេកូឡូស៊ី ពង្រីកលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជន និងកាត់បន្ថយផលប៉ះពាល់បណ្តាលមកពីទឹក ដូចជា គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលធ្វើអោយបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិសាធារណៈ តាមរយៈការស្តារ ការកសាង ការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវ

ប្រព័ន្ធធារាសាស្ត្រ ទាំងតូច មធ្យម និងធំ ដើម្បីពង្រីកលទ្ធភាពដោះស្រាយទឹកសម្រាប់បង្កបង្កើនផលផង សម្រួលដល់ការធ្វើដំណើររបស់ប្រជាជនផង និងការអនុវត្តន៍វារីវប្បកម្មផង។

កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន

រាជរដ្ឋាភិបាល បន្តពង្រឹងការគ្រប់គ្រង និងបែងចែក និងការប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និងមានប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការពង្រឹងការចុះបញ្ជីដីធ្លី ការផ្តល់កម្មសិទ្ធិដីធ្លី ដើម្បីធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ការលុបបំបាត់ភាពអនាធិបតេយ្យ រំលោភកាន់កាប់ដីគ្រប់ប្រភេទ ដោយខុសច្បាប់(ដីបឹង ដីព្រៃ ដីលិចទឹក ដីឆ្នេរ ដីភ្នំ ដីកោះ) ការទប់ស្កាត់ការប្រមូលដីទុកមិនប្រើប្រាស់ មិនធ្វើអាជីវកម្ម និងការដោះស្រាយទំនាស់ដីធ្លីប្រកបដោយតម្លាភាព និងយុត្តិធម៌ ដោយធ្វើការសិក្សាហ្មត់ចត់មុនការផ្តល់សម្បទានដីសេដ្ឋកិច្ច និងពង្រឹងការគ្រប់គ្រងប្រភេទដីនេះ អោយបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋាន និងកិច្ចសន្យា។ រាជរដ្ឋាភិបាលជម្រុញការបែងចែកដីក្នុងក្របខ័ណ្ឌសម្បទានសង្គមកិច្ច ជូនប្រជាពលរដ្ឋក្រីក្រ ដែលគ្មានដីពិតប្រាកដ ដោយរួមទាំងការវិនិយោគសាធារណៈនានា សំដៅបង្កើតលក្ខខ័ណ្ឌនៃការរស់នៅសមរម្យ ជូនប្រជាពលរដ្ឋដែលទទួលបានដីថ្មី។ រាជរដ្ឋាភិបាល ជម្រុញការកសាងព្រំប្រទល់រដ្ឋបាលឃុំ/សង្កាត់ និងការកសាងយុទ្ធសាស្ត្រជាតិនៃការអភិវឌ្ឍន៍ទីក្រុង ទីប្រជុំជន និងបន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីធ្លីពីកសិករ ដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ។

រាជរដ្ឋាភិបាល បន្តជំរុញសកម្មភាពបោសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ព្រមទាំងបង្កើនការយល់ដឹងជាសាធារណៈ អំពីគ្រោះថ្នាក់ដែលបណ្តាលមកពីមីន ដើម្បីកាត់បន្ថយចំនួនអ្នករងគ្រោះដោយសារមីន និងបង្កើនផ្ទៃដីដោះមីនរួមអោយដល់៤៥ ០០០ហិកតា នៅឆ្នាំ២០១០ សំដៅបម្រើដល់ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចជាពិសេស ការបែងចែកដីធ្លីដល់ប្រជាជនដែលខ្វះដី ការប្រកបរបរកសិកម្មប្រកបដោយសុវត្ថិភាព និងសន្តិសុខរបស់ប្រជាជននៅតំបន់ជនបទ។

២.២.២ ទ្រឹស្តីយេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ

ក្រសួងកិច្ចការនារី បានអនុវត្តន៍ផែនការ "នារីរតនៈទី២" ដែលជាផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ២០០៤-២០០៨ របស់ខ្លួន ប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។ ដោយមានកិច្ចសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងសង្គមស៊ីវិល ក្រសួងបានទទួលជោគជ័យក្នុងការបញ្ជ្រាបយេនឌ័រ និងការបញ្ចូលសិទ្ធិស្ត្រីទៅក្នុងគោលនយោបាយជាតិសំខាន់ៗរួមមាន គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ផែនការសកម្មភាពអភិបាលកិច្ចលើកទីពីរ សូចនាករតាមដានរួមរបស់រាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី/ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងផែនការអភិវឌ្ឍន៍ និងវិនិយោគឃុំ/សង្កាត់។

ក្រសួងបានជម្រុញអោយមានបង្កើត និងការពង្រឹងយន្តការស្ថាប័ន ដើម្បីគាំទ្រដល់ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការជម្រុញអោយមានសមភាពយេនឌ័រ។ ក្រុមការងារបច្ចេកទេសយេនឌ័រ ដែលដឹកនាំដោយក្រសួងកិច្ចការនារី ត្រូវបានបង្កើតឡើង ដែលជាផ្នែកមួយនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ក្រសួង ស្ថាប័នស្នើរតែទាំងអស់របស់រាជរដ្ឋាភិបាល បានបង្កើតក្រុមការងារបញ្ជាបយេនឌ័រ របស់ខ្លួនទៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងនោះក្រសួង ស្ថាប័នចំនួន១៥ បានបង្កើតផែនការយុទ្ធសាស្ត្របញ្ជាបយេនឌ័ររបស់ខ្លួនរួចហើយ។ បច្ចុប្បន្ន កម្មវិធីកំណែទម្រង់រដ្ឋបាល ដែលរួមមាន កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ កំណែទម្រង់វិមជ្ឈការ និងវិសហ-មជ្ឈការ និងវិធានការសង្គតិភាព និងសុខដុមនីយកម្ម បានផ្តល់យន្តការដ៏សំខាន់សម្រាប់បង្កើនប្រសិទ្ធភាព ក្នុងដំណើរការដោះស្រាយបញ្ហាយេនឌ័រ។

ក្រសួងបានធ្វើការស្វែងរកការគាំទ្រមតិប្រកបដោយជោគជ័យ ក្នុងការបង្កើនកិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី ហើយសិទ្ធិស្ត្រីត្រូវបានលើកយកមកពិចារណាក្នុងការរៀបចំ និងការអនុវត្តន៍ច្បាប់នានា និងក្នុងការបណ្តុះបណ្តាលផ្នែកច្បាប់។ តាមរយៈការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ក្រសួងក៏បានចូលរួមចំណែកក្នុងការបង្កើនការយល់ដឹងអំពីសិទ្ធិនារី ហើយទស្សនៈអំពីសមភាពយេនឌ័រ និងសិទ្ធិនារីកំពុងមានការប្រែប្រួលនៅកម្ពុជា។ ឆ្នាំ២០០៥ ច្បាប់ស្តីពីការទប់ស្កាត់ អំពើហិង្សាលើស្ត្រី និងកិច្ចការពារជនរងគ្រោះ ត្រូវបានទទួលការអនុម័តពីរដ្ឋសភា។ ឆ្នាំ២០០៧ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏បានទទួលការអនុម័តពីរដ្ឋសភាផងដែរ។ ទន្ទឹមនឹងនេះ ក្រសួងកិច្ចការនារី ត្រូវបានទទួលតួនាទីជាប្រធានគណៈកម្មាធិការជាតិដឹកនាំការទប់ស្កាត់ការជួញដូរមនុស្ស។

ក្នុងវិស័យអប់រំ ក្រសួងបានបង្កើនអត្រាឈ្មោះចូលរៀនរបស់កុមារា និងកុមារី ហើយគម្លាតយេនឌ័រក្នុងវិស័យអប់រំ ក៏ត្រូវបានកាត់បន្ថយផងដែរ។ ទោះបីជាអត្រាអនក្ខរភាពក្នុងចំណោមស្ត្រីពេញវ័យ នៅមានកម្រិតខ្ពស់បន្តិចបន្តួចក៏ដោយ ប៉ុន្តែជាទូទៅ គម្លាតយេនឌ័រក្នុងអត្រាអក្ខរភាពមានកម្រិតតិចតួចបំផុត ហើយយុវជន និងយុវនារីក្រោមអាយុ២០ឆ្នាំ ទទួលបានការអប់រំប្រហាក់ប្រហែលគ្នា។ ក្រសួងបានគាំទ្រ និងជម្រុញអោយមានការសាងសង់អន្តេវាសិកដ្ឋានសម្រាប់ក្មេងស្រី ការអប់រំកុមារតូច និងការផ្តល់ជំនាញថៃទាំកុមារតាមរយៈការជម្រុញនូវការបង្កើតមតេ្តយ្យសហគមន៍។ ក្រសួងក៏បានអនុវត្តយ៉ាងសកម្មនូវកម្មវិធីជាតិ ស្តីពីការបង្កើនសីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ។

ក្រសួងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតជំនាញ និងសមត្ថភាពដល់ស្ត្រី ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតនៃអភិបាលកិច្ច។ ជាទូទៅនៅក្នុងអាណត្តិនេះ សមាមាត្រដែលបានជាប់ឆ្នោតជាសមាជិកការដ្ឋសភាជាតិ បានកើនឡើងគួរអោយកត់សម្គាល់ ពី ៥% ក្នុងឆ្នាំ១៩៩៣ ដល់១១% ក្នុងឆ្នាំ១៩៩៨ និង១៩% ក្នុងឆ្នាំ២០០៣។ សមាមាត្រស្ត្រី ដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា

ឃុំ/សង្កាត់ កើនពី៨% ក្នុងឆ្នាំ២០០២ ដល់១៥% ក្នុងឆ្នាំ២០០៧ ហើយបច្ចុប្បន្នមានស្ត្រី ៣០% ក្នុងចំណោមអ្នកដឹកនាំថ្នាក់ភូមិ។

ក្នុងវិស័យសុខភាព ក្រសួងបានចូលរួមចំណែកក្នុងការបង្កើនការទទួលបានសេវាសុខភាពបឋមសុភាពបន្តពូជ អាហារូបត្ថម្ភ ការទប់ស្កាត់នឹងជំងឺគ្រុនចាញ់ និងការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍។ ក្រសួងក៏បានបង្កើនផែនការយុទ្ធសាស្ត្រ ស្តីពីស្ត្រី ក្មេងស្រី និងជំងឺអេដស៍ ២០០៨-២០១២ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងដ៏កាចសាហាវនេះ។

ក្នុងវិស័យសេដ្ឋកិច្ច ក្រសួងបានបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការការពារសិទ្ធិកម្មការិនីតាមរយៈការស្វែងរកការគាំទ្រមតិ និងការធ្វើអន្តរាគមន៍ផ្នែកនយោបាយ។ ការងារដែលមានប្រាក់ឈ្នួលសម្រាប់ស្ត្រីមានការកើនឡើង។ ស្ត្រីបានចូលរួមយ៉ាងច្រើននៅក្នុងការងារមានប្រាក់ឈ្នួលក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម។ លើសពីនេះទៀត ក្រសួងបានពង្រីកបន្ថែមនូវមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី សម្រាប់ផ្តល់ការបណ្តុះបណ្តាល និងព័ត៌មានសម្រាប់ការអភិវឌ្ឍន៍សហគ្រិន និងបំណិនជីវិតសម្រាប់ស្ត្រី នៅតាមបណ្តាខេត្ត ក្រុងចំនួន ១១[11]។

ជាទម្លាប់នៅប្រទេសកម្ពុជា គេចាត់ទុកស្ត្រីថា ជាអ្នកដែលនៅក្រោមបង្គាប់បុរស។ ស្ត្រីក៏មាននិន្នាការទទួលរងគ្រោះកាន់តែធ្ងន់ធ្ងរថែមទៀតពីផលវិបាកនៃភាពក្រីក្រ។ ជាទូទៅស្ត្រីរស់នៅក្នុងស្ថានភាពមួយដ៏លំបាកនៅក្នុងប្រទេសពោល គឺពួកគេមានឱកាសទទួលបានការសិក្សាធ្វើការមានប្រាក់ខែ មានកម្មសិទ្ធិដីធ្លី និងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិផ្សេងៗទៀត មានធនាគារនឹងមានអំណាចតិចជាងបុរស។

អំពើហិង្សាលើរាងកាយ និងលើផ្លូវភេទ នៅតែបន្តកើនឡើងដែលបង្កជាកង្វល់ដ៏ធ្ងន់ធ្ងរមួយ។ ជាប្រការមួយគួរអោយព្រួយបារម្ភនៅពេលដែលរកឃើញថា ស្ត្រីខ្មែរប្រមាណ២៥% បានទទួលរងអំពើហិង្សាក្នុងគ្រួសារ។ ក៏ប៉ុន្តែ អំពើនេះកម្រនឹងឈានដល់ការដាក់ទោសណាស់ បើទោះបីជានៅពេលដែលស្ត្រីទាំងនោះទទួលរងរបួសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ គប្បីយល់ថា អំពើហិង្សាចំពោះស្ត្រី និងកុមារ បណ្តាលមកពីភាពក្រីក្រ ដែលធ្វើអោយពួកគេធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រកាន់តែធ្ងន់ធ្ងរ[12]។

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ(NPRS) បានលើកឡើងយ៉ាងច្រើនពីសមភាពយេនឌ័រ និងចំណុចជាច្រើនដែលទាមទារអោយអនុវត្ត ដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ។ នៅមានភាពមិនច្បាស់លាស់នៅឡើយថា តើរដ្ឋាភិបាលមានបំណងនឹងអនុវត្តន៍ផែនការសកម្មភាពរបស់ខ្លួន ដើម្បីសម្រេចអោយបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាយ៉ាងដូចម្តេចនោះ។ យើងត្រូវផ្តោតទៅលើបញ្ហាគន្លឹះដូចជា:

---

[11] ទីស្តីការគណៈរដ្ឋមន្ត្រី "សមិទ្ធផលសំខាន់ៗ របស់រាជរដ្ឋាភិបាល ២០០៤-២០០៧ " ទំព័រទី១៤៥

[12] NGO ស្តីពី "ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣" ខែមីនា ឆ្នាំ២០០៤ ទំព័រទី៦៥

វិស័យសុខាភិបាល: ប្រជាជនខ្មែរជាង ៨០% រស់នៅជនបទ ដែលនៅទីនោះពួកគេមានឱកាសតិចតួចក្នុងការទទួលបាននូវការសិក្សា ទទួលបានសេវាសុខភាពមូលដ្ឋាន និងទទួលព័ត៌មាន ដែលផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន។ គ្រូពេទ្យបម្រើការងារនៅទីក្រុងមានចំនួនច្រើនជាងនៅជនបទ ហើយវេជ្ជបណ្ឌិតភាគច្រើន គឺបុរស។ ដោយសារមានភាពក្រីក្រ ទើបបណ្តាលអោយប្រជាជននៅទីជនបទកាន់តែមានការលំបាកក្នុងការរកចំណូល ហេតុនេះហើយបានមនុស្សជាច្រើនបានធ្វើដំណើរមកទីក្រុង ដើម្បីស្វែងរកការងារធ្វើ។ គឺក្នុងពេលនេះហើយដែលកម្មករចំណាកស្រុកជួបប្រទះនូវគ្រោះថ្នាក់កាន់តែខ្លាំង ដូចជា ស្ថានភាពរស់នៅមិនសមរម្យ ម្ហូបអាហារមិនគ្រប់គ្រាន់ មេរោគអេដស៍ និងជំងឺអេដស៍ មានផ្ទៃពោះដោយសាមុីខ្លួនមិនចង់បាន ពេស្យាចារ ការជួញដូរផ្លូវភេទ និងអំពើហិង្សាផ្នែកយេនឌ័រ។

នៅឆ្នាំ១៩៩៥ ដោយមានការណែនាំអំពីគោលនយោបាយពន្យាកំណើត ថ្នាំគ្រាប់ពន្យាកំណើតត្រូវបានផ្តល់ជូនយ៉ាងទូលំទូលាយដល់ស្ត្រី និងបុរស។ បច្ចុប្បន្ននេះ ស្ត្រី ២៤% កំពុងប្រើប្រាស់ថ្នាំគ្រាប់ពន្យាកំណើត ហើយប្រទេសកម្ពុជា បានឆ្លងកាត់នូវរយៈពេលមួយដែលមានការធ្លាក់ចុះនូវលទ្ធភាពផ្តល់កំណើតកូនពី ៥.៤ មក ៤.០ នាក់ ក្នុងស្ត្រីម្នាក់ដែលដល់អាយុផ្តល់កំណើត។ ការផ្តល់សេវាសុខភាពគាំពារមាតានៅមានកម្រិតទាប ហើយនៅតែមិនទាន់បានឆ្លើយតបទៅនឹងតម្រូវការក្នុងការពន្យាកំណើតឡើយ។ ទន្ទឹមនឹងនេះស្ត្រីជាច្រើនមិនបានទទួលសេវាពន្លូតកូនប្រកបដោយសុវត្ថិភាពនៅឡើយទេ។

ជារៀងរាល់ឆ្នាំនៅប្រទេសកម្ពុជា ស្ត្រី ២ ០០០នាក់ បានស្លាប់ក្នុងកំឡុងពេលឆ្លងទន្លេ ហើយស្ត្រីជាង ២០០.០០០នាក់ ទទួលរងបញ្ហាលំបាកផ្សេងៗក្នុងពេលមានគត់ ដោយសារតែការទទួលបាននូវសេវាសុខភាពគាំពារមាតានៅមានកម្រិតទាប ហើយជារឿយៗគឺជាផលវិបាកនៃភាពក្រីក្រ។ អត្រាមរណៈមាតាក្នុងរយៈពេលពីឆ្នាំ១៩៩៤-២០០០ មានចំនួន៤៧៣នាក់ ក្នុងអត្រាកំណើនចំនួន ១០០.០០០នាក់ ដែលជាតួលេខមួយគួរអោយព្រួយបារម្ភ។ មូលហេតុវេជ្ជសាស្ត្រសំខាន់ៗសម្រាប់ស្ត្រី ដែលបានស្លាប់ក្នុងពេលឆ្លងទន្លេ(អត្រាមរណៈមាតា) មាន:

- ការធ្លាក់ឈាមក្រោយពេលសម្រាល
- ព្រាយក្រឡាភ្លើង
- ការសម្រាលកូនមិនរួច
- ការពន្លូតកូន ដែលគ្មានសុវត្ថិភាព
- ការរាលដាលមេរោគក្នុងខ្លួន
- ខ្វះអាហារូបត្ថម្ភ(ជំងឺខ្វះឈាមក្រហម)
- មេរោគអេដស៍-ជំងឺអេដស៍។

វិស័យអប់រំ: អនក្ខរកម្ម គឺជារនាំសម្រាប់ពលរដ្ឋក្រីក្រ ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់គេ។ បញ្ហានេះបានជះឥទ្ធិពលយ៉ាងខ្លាំងរហូតដល់ផាត់ស្ត្រីចេញពីដំណើរការអភិវឌ្ឍន៍។ អត្រាអនក្ខរកម្មមានកម្រិតខ្ពស់ពេល

គឺស្ត្រីពេញវ័យប្រមាណ ៤៥% មិនចេះអក្សរទាំងស្រុង(ធៀបទៅនឹងបុរស ២៤.៧) ហើយយុវជនប្រមាណជា ២៥% ក៏មិនចេះអក្សរដែរ។ ស្ត្រីចំនួន ៧០.៨% និងបុរស៥០.៤% មិនចេះសរសេរសម្រាប់បម្រើតម្រូវការចាំបាច់ប្រចាំថ្ងៃឡើយ[១៣]។ ឱកាសក្នុងការបណ្តុះបណ្តាលសម្រាប់ស្ត្រីមានការកំណត់ចំពោះតែ "ជំនាញសម្រាប់ស្ត្រី" មួយចំនួន ដូចជា រៀនអ៊ុតសក់ ជាដើម។

អត្រាភាពក្រីក្រកាន់តែមានកម្រិតខ្ពស់ ចំពោះគ្រួសារទាំងឡាយដែលមេគ្រួសារមិនដែលបានចូលសាលារដ្ឋសោះតែម្តង ឬមួយក៏បានរៀននៅសាលាបឋមសិក្សាតិចតួច។ មួយភាគនៃចំណាយសម្រាប់ការសិក្សានៅក្នុងចំណាយសម្រាប់ទិញរបស់របរប្រើប្រាស់ នៅក្នុងគ្រួសាររបស់ពលរដ្ឋក្រីក្រមានចំនួនតិចជាង ១.១%។

ការទទួលបានការសិក្សាសម្រាប់ក្មេងស្រីមានភាពល្អប្រសើរឡើង និងការកំណត់ផ្តល់អាហារូបករណ៍សម្រាប់ក្មេងស្ត្រី ដែលមកពីគ្រួសារពលរដ្ឋក្រីក្រ នៅក្នុងផែនការសកម្មភាព NPRS ត្រូវបានទទួលស្វាគមន៍យ៉ាងខ្លាំង។ ការប្តេជ្ញាចិត្តនេះទាមទារអោយមានការគាំទ្រតាមរយៈការបែងចែកធនធានពិតប្រាកដ ដែលមានលក្ខណៈបន្ត និងជានិរន្តន៍ ដើម្បីធានាអោយផែនការនេះផ្តល់ផលប្រយោជន៍ដល់អ្នកដែលត្រូវការបំផុត។ ទន្ទឹមនឹងនេះ ត្រូវចាត់វិធានការ ដើម្បីធានាដល់ការដោះស្រាយនូវអត្រាបោះបង់ចោលការសិក្សា ដែលមានកម្រិតខ្ពស់របស់ក្មេងស្រី។

កង្វះខាតក្នុងការទទួលបានព័ត៌មាន និងការអប់រំអំពីច្បាប់ និងសិទ្ធិ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ។ ការមិនយល់ដឹងអំពីការការពារតាមផ្លូវច្បាប់ បានធ្វើអោយពលរដ្ឋក្រីក្រងាយនឹងទទួលរងនូវការកេងប្រវ័ញ្ច។ នេះក៏ជាករណីមួយពាក់ព័ន្ធទៅនឹងការទទួលបានព័ត៌មាន និងការធ្វើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលផងដែរ។ បើគ្មានលទ្ធភាពទទួលបានព័ត៌មានដូច្នេះទេ ពលរដ្ឋក្រីក្រជាពិសេសស្ត្រីក្រីក្រត្រូវបានដាក់ចេញពីការចូលរួមនៅក្នុងសកម្មភាពសហគមន៍ និងមិនអាចជួយផ្តល់ព័ត៌មាន ដែលអាចបំពេញបាននូវគម្លាតរវាងនយោបាយរបស់រាជរដ្ឋាភិបាល និងការអនុវត្តន៍នយោបាយទាំងនេះឡើយ។

អំពើហិង្សាយេនឌ័រ: ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនៅមិនទាន់អនុម័តនៅឡើយ ដោយសារការអូសបន្លាយដោយការបោះឆ្នោតសភាជាតិ។ សភាជាតិថ្មី គប្បីចាត់វិធានការជាបន្ទាន់ក្នុងការធ្វើនីតិកម្មផ្នែកនេះ និងលៃយ៉ាងណាអោយច្បាប់នេះត្រូវបានអនុវត្តអោយបានត្រឹមត្រូវដូចជា ការរំលោភសេពសន្ថវៈ អំពើហិង្សាប្រឆាំងនឹងអ្នករកស៊ីផ្លូវភេទ ការជួញដូរស្ត្រី និងកុមារទៅកាន់ប្រទេសជិតខាងដែលកំពុងតែកើនឡើង[១៤]។

ការកើនឡើងនូវអំពើរំលោភសេពសន្ថវៈ ដែលបានលើកឡើងនៅក្នុងរបាយការណ៍បង្ហាញអោយឃើញថា តម្រូវការក្នុងការកសាងយុទ្ធសាស្ត្រនានា ដែលមានប្រសិទ្ធភាព។ ការអប់រំអំពីយេនឌ័រសម្រាប់ប្រជាពលរដ្ឋទូទៅដើម្បីលុបបំបាត់ទស្សនៈចាស់គំរិលនានា អំពីតួនាទីរបស់ស្ត្រីនៅក្នុងសង្គមកម្ពុជា គឺជាដំណើរការយូរអង្វែង។

---

[១៣] រាជរដ្ឋាភិបាលសហការជាមួយ UNDP Unifem និង World Bank របាយការណ៍ឆ្នាំ២០០៣ ស្តីពីការវិភាគយេនឌ័រនៅកម្ពុជា

[១៤] ឯកសារតាមវិស័យ និងបញ្ហានានារបស់ NGO ស្តីពី "ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣" ខែមីនា ឆ្នាំ២០០៤ ទំព័រទី៦៧

ប៉ុន្តទោះបីជាយ៉ាងនេះក៏ដោយនៅក្នុងរយៈពេលខ្លីប្រព័ន្ធច្បាប់ និងតុលាការគួរចាត់វិធានការតឹងតែង ដើម្បីធានាអោយជនជាប់ចោទពីបទរំលោភសេពសន្ធវៈត្រូវបានចាប់ខ្លួន និងកាត់ក្តីហើយនៅពេលដែលរកឃើញថាមានពិរុទ្ធភាពត្រូវដាក់ទោសអោយបានសមស្របតាមទម្ងន់ទោស។ ការដាក់ទោសស្រាលចំពោះអំពើរំលោភសេព-សន្ធវៈជម្រុញអោយមានឥរិយាបទមួយយល់ថា អំពើនេះមិនមែនជាបទល្មើសធ្ងន់ធ្ងរ ឬក៏ជាបទល្មើសមួយដែលប្រហែលជាមិននាំអោយមានការដាក់ទោសឡើយ។

ច្បាប់ប្រឆាំងនឹងការជួញដូរ ដែលបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី ចាំបាច់ត្រូវបញ្ចូននូវប្រភេទទាំងអស់នៃការជួញដូរ ដូចជា ការជួញដូរសរីរាង្គមនុស្ស ការកេងប្រវ័ញ្ចការងារ ការជួញដូរផ្លូវភេទ និងការជួញដូរទារក។ រដ្ឋាភិបាល គួរអនុវត្តអោយបានសកម្មនូវអនុស្សរណៈ ស្តីពីការជួញដូររវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលបានចុះហត្ថលេខានៅឆ្នាំ១៩៩២ ហើយក៏បានជម្រុញអោយអាជ្ញាធរថៃអនុវត្តដូចគ្នាដែរ។

ស្ត្រីក្នុងភាពជាអ្នកដឹកនាំ: តួនាទីរបស់ស្ត្រី នៅក្នុងជីវិតនយោបាយនៅកម្ពុជា កំពុងតែមានការវិវត្តន៍ឈានឡើង ប៉ុន្តែវានៅតែជាការវិវត្តន៍មួយដ៏យឺតដោយហេតុថា ស្ត្រីមួយចំនួនតូចប៉ុណ្ណោះបានឈានដល់កម្រិតនៃអំណាចពិតប្រាកដ។ ជាលទ្ធផលការបោះឆ្នោតឆ្នាំ២០០៣ មានស្ត្រី ១២រូប បានជាប់ឆ្នោតនៅក្នុងសភាជាតិ ដែលមានការកើនឡើង ៥នាក់ លើសការបោះឆ្នោតឆ្នាំ១៩៩៨។

បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៨ មានរដ្ឋមន្ត្រីជាស្ត្រីតែ ២នាក់ ប៉ុណ្ណោះ ក្នុងចំណោមក្រសួងចំនួន ២៥ ហើយមានរដ្ឋលេខាធិការជាស្ត្រី ៤នាក់ ក្នុងចំណោមរដ្ឋលេខាធិការសរុបចំនួន ៥០នាក់។ យ៉ាងណាក៏ដោយនេះគឺជាការរីកចម្រើនជាងមុន បើទោះបីជាគ្មានអភិបាលខេត្ត/ក្រុង ជាស្ត្រីក៏ដោយ។ កាលពីមុនមានស្ត្រីតែ ២នាក់ ប៉ុណ្ណោះដែលត្រូវបានតែងតាំង នៅក្នុងមុខតំណែងនយោបាយ ហើយក៏គ្មានស្ត្រីជារដ្ឋមន្ត្រី ជារដ្ឋលេខាធិការ ឬជាអភិបាលខេត្ត/ក្រុងដែរ។ មានស្ត្រីតែ ៩% ប៉ុណ្ណោះ ក្នុងចំណោមមន្ត្រីរាជការសរុបចំនួន ១៦៩.០០០នាក់ ហើយមានចៅក្រមជាស្ត្រីជាស្រី ៨នាក់ ប៉ុណ្ណោះ ក្នុងចំណោមចៅក្រម ១១០នាក់ ហើយក៏គ្មានព្រះរាជាជាស្រីដែរ។

នៅមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០០២ មានការពិភាក្សាគ្នាជុំវិញការផ្តល់កូតាកៅអី ៣០%សម្រាប់ស្ត្រី។ ប៉ុន្តែសំណើរនេះត្រូវបានបដិសេធទៅវិញ ហើយស្ត្រីចំនួន ៨.៥% បានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ/សង្កាត់។ ការចូលរួមរបស់ស្ត្រីកាន់តែច្រើននៅក្នុងនយោបាយថ្នាក់មូលដ្ឋាន គឺជាជំហានមួយដ៏សំខាន់ក្នុងដំណើរឆ្ពោះទៅបង្កើនវប្បធម៌នៃការទទួលយកស្ត្រីចូលកាន់អំណាច ព្រមទាំងជម្រុញការផ្តល់អំណាចដល់ស្ត្រី ដែលជាអ្នករួមវិភាគទានដ៏មានតម្លៃចំពោះជោគវាសនាអនាគតរបស់ប្រទេសផងដែរ។

សេដ្ឋកិច្ច និងកសិកម្ម: នៅប្រទេសកម្ពុជា ៦៥% នៃពលកម្មកសិកម្ម និង៧៥% នៃផលិតផលជលផលស្ថិតក្នុងដៃស្ត្រី។ ភាពក្រីក្រមិនអាចកាត់បន្ថយបានឡើយល្មឹកណាគោលនយោបាយកម្មវិធី និងថវិកានានាមិនបានដោះស្រាយដោយសមធម៌នូវស្ថានៃតម្រូវការរបស់ស្ត្រីកម្ពុជានោះទេ។

ស្ត្រីនៅជនបទទទួលខុសត្រូវចំពោះការផលិតស្បៀងអាហារចំនួន ៨០% ហើយស្ត្រីជាង ៦៥% គឺជាកសិករ។ ពាក់កណ្តាលនៃស្ត្រីទាំងនោះ គឺជាអ្នកមិនចេះអក្សរ ឬមិនបានបញ្ចប់ថ្នាក់បឋមសិក្សាផង។ ស្ត្រី ៧៨% ជាអ្នកប្រកបរបរកសិកម្ម ដើម្បីចិញ្ចឹមជីវិតធៀបទៅនឹងបុរសចំនួន ២៩%។ នៅជនបទ ស្ត្រីប្រមាណតែ ៤% និងបុរសតែ ១០% ប៉ុណ្ណោះ ដែលជាអ្នកធ្វើការទទួលប្រាក់បៀវត្សរ៍។

គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ច្រើនតែធ្វើការក្នុងវិស័យកសិកម្ម ជាងគ្រួសារដែលមានបុរសជាមេគ្រួសារ ក៏ប៉ុន្តែពួកគេក៏ហាក់ដូចជា គ្មានដីធ្វើស្រែ ឬមួយក៏មានដីដ៏តិចតួចបំផុត។ ស្ទើរតែ ៨០% នៃកសិករទាំងនេះប្រកបរបរកសិកម្ម ដើម្បីចិញ្ចឹមជីវិតដែលមានស្ត្រីចំនួន ៥៦% ជាកម្លាំងពលកម្មចាំបាច់ក្នុងកសិកម្មដើម្បីចិញ្ចឹមជីវិត និង៤៥% នៃកម្លាំងពលកម្មធ្វើការក្នុងវិស័យកសិកម្មសម្រាប់ទីផ្សារ។ ស្ត្រីភាគច្រើនក៏ជាអ្នកបម្រើនៅក្នុងផ្ទះ ដែលមិនបានទទួលប្រាក់បៀវត្សរ៍នោះទេ។

ការទទួលបាននូវសេវាផ្សព្វផ្សាយដែលពុំមានគុណភាព គឺជាបញ្ហាដ៏ធ្ងន់ធ្ងរសម្រាប់កសិករបុរស និងកសិករស្ត្រី ហើយស្ត្រីទទួលបានកាន់តែតិចនូវសេវាផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដែលមានតិចតួចស្រាប់។ ការស្រាវជ្រាវកសិកម្ម និងការផ្សព្វផ្សាយកសិកម្មមិនបានផ្តោតទៅលើសកម្មភាពរបស់កសិកស្ត្រីឡើយ បើទោះបីជាបុរស និងស្ត្រីហាក់ដូចជាមានកិច្ចការដាច់ដោយឡែកពីគ្នាក្តី។

បើទោះបីជាប្រជាជនកម្ពុជាជាង ៧០% បម្រើការនៅក្នុងការបង្កបង្កើនផលកសិកម្មក៏ដោយ កសិករ រវាង១២% ទៅ១៥% គ្មានដីកសិកម្មសម្រាប់បង្កបង្កើនផលឡើយ។ ការទទួលបានធនធម្មជាតិផ្សេងៗទៀតរបស់ពលរដ្ឋក្រីក្រដូចជា ព្រៃឈើ ជលផល និងធនធានពាក់ព័ន្ធនានានៅមានកម្រិតទាបនៅឡើយ។

ស្ត្រីពិការ: ជនពិការត្រូវរើសអើងនៅគ្រប់ស្រទាប់ និងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងសង្គម។ ប្រការនេះបណ្តាលអោយជនពិការរស់នៅក្នុងភាពឯកោ ដោយត្រូវបានផាត់ចេញពីចរន្តសំខាន់ៗនៃសង្គម និងមិនទទួលបាននូវសិទ្ធិ និងឱកាសស្មើភាពដូចជនដទៃឡើយ។ រីឯស្ត្រីពិការវិញជួយប្រទះនូវការរើសអើងទ្វេដង គឺជាស្ត្រីផង និងជាជនពិការផង។

បញ្ហាពិការភាពហាក់ដូចជាមិនត្រូវបានយកចិត្តទុកដាក់ឡើយ។ នៅពេលទិវាជនពិការថ្មីៗ នេះ (ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៣) គេបាននិយាយថា ប្រជាជនកម្ពុជាតិចជាង ២% គឺជាជនពិការ។ ក៏ប៉ុន្តែធនាគារពិភពលោកប៉ាន់ស្មានថា ចំនួនជនពិការរស់នៅប្រទេសកម្ពុជាមានចំនួន ២០%។

ចំពោះបញ្ហាទឹក និងអនាម័យវិញ ស្ត្រីពិការ គឺជាអ្នកដែលងាយរងគ្រោះបំផុត។ គ្មានបង្គន់អនាម័យ ឬបន្ទប់ទឹកត្រឹមត្រូវសម្រាប់ស្ត្រីជនពិការឡើយ។ ក្នុងករណីជាច្រើនទៀត ស្ត្រីទាំងនេះរស់នៅក្នុងបរិយាកាសមួយដែលមិនអំណោយផលដល់សុខភាព។

ជនពិការភ្នែក ពិការត្រចៀក និងនិយាយមិនកើត មិនបានទទួលការអប់រំឡើយ។ ពួកគេភាគច្រើនមិនចេះអាន ឬសរសេរឡើយ។ លើសពីនេះទៅទៀត ក្មេងពិការមិនអាចទៅសាលារៀន ឬឈប់រៀនដោយសារតែអគារសិក្សាគ្មានផ្លូវដែរសម្រាប់ជនពិការ។

ស្ត្រីពិការកាន់តែទទួលរងគ្រោះថែមទៀតពីអំពើហិង្សាក្នុងគ្រួសារ។ ភាគច្រើនប្តីបានបោះបង់នាងចោលពេលនាងធ្លាក់ខ្លួនពិការ និងមានករណីជាច្រើនទៀតផងដែរ ដែលស្ត្រីពិការកំពុងត្រូវបានទទួលរងនូវការកេងប្រវ័ញ្ច។

ភាពក្រីក្រអាចនឹងកាត់បន្ថយបាន តែនៅពេលដែលតម្រូវការរបស់ក្រុមដែលងាយរងគ្រោះបំផុតត្រូវបានដោះស្រាយជាពិសេសស្ត្រីពិការ។ ដើម្បីអោយបញ្ហាត្រូវបានដោះស្រាយនោះ រាជរដ្ឋាភិបាលគួរតែ: ទី១-ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារត្រូវបានអនុម័តដោយសភាជាតិ និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត និងចាត់ទុកបញ្ហាជាអាទិភាព។ ទី២-រដ្ឋាភិបាលគួរធានាអោយមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវច្បាប់ការងារ ច្បាប់ប្រឆាំងការជួញដូរ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ។ ការបង្កើនតម្លាភាពនៅក្នុងប្រព័ន្ធប៉ូលីស និងតុលាការតម្រូវអោយមានការគាំទ្រ និងការតាមដានជាប្រចាំ។ ទី៣-គួរមានគ្លីនិកព្យាបាលកម្មករអោងចក្រមានមណ្ឌលសុខភាពពេលថ្ងៃ និងការការពារសុខភាពអោយបានល្អប្រសើរ ជាពិសេសពាក់ព័ន្ធនឹងលក្ខខ័ណ្ឌអនាម័យ បន្ទាប់ធ្វើការ និងការងាររបស់កម្មករ។ ទី៤-ត្រូវបំពេញអោយមានបានតាមលក្ខខ័ណ្ឌក្នុងការធ្វើរបាយការណ៍តាមអនុសញ្ញា CEDAW ដើម្បីបង្ហាញថា រដ្ឋាភិបាលមានបំណងនឹងលុបបំបាត់ការរើសអើងចំពោះស្ត្រី។ CEDAW ជម្រុញអោយមាន ការអនុវត្តន៍ពេញលេញនូវវិធានការណ៍ទាំងឡាយ ដើម្បីធានាអោយសិទ្ធិចំពោះការងារ សិទ្ធិចំពោះជីវិត សាធារណៈ សិទ្ធិសមភាព សិទ្ធិសង្គម និងសេដ្ឋកិច្ចពិតជាត្រូវបានទទួលការការពារ។ រដ្ឋាភិបាល គួរតែធានាអោយមានប្រព័ន្ធពេញលេញក្នុងការអនុវត្តន៍សិទ្ធិ និងបន្តធ្វើអោយប្រសើរឡើងនូវការអប់រំនៅសហគមន៍ និងការទទួលបានព័ត៌មានអំពើសិទ្ធិស្ត្រី។ ទី៥-ធានាអោយមានកំណើនថវិកាជាតិ សម្រាប់វិស័យអប់រំសំដៅផ្តល់វឌ្ឍនភាពជានិរន្តន៍ ចំពោះបញ្ហាយេនឌ័រ ឧទាហរណ៍ តាមរយៈការផ្តល់អាហារូបករណ៍ និងអន្តេវាសិកដ្ឋានសម្រាប់សិស្សស្រី។ លើពីនេះទៅទៀត ថវិកាសម្រាប់វិស័យសុខាភិបាល និងកសិកម្មគួរត្រូវបានបង្កើន ដើម្បីផ្តល់សេវាសុខភាព និងលើកកម្ពស់កម្រិតជីវភាពអោយកាន់តែប្រសើរសម្រាប់ស្ត្រី។ យុទ្ធសាស្ត្រ និងការបែងចែកថវិកាត្រូវធ្វើឡើងសំដៅដោះស្រាយតម្រូវការរបស់កុមារ និងស្ត្រីពិការ។ ទី៦-មូលដ្ឋានទិន្នន័យស្តីពីយេនឌ័រ គួរត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយអោយកាន់តែទូលាយ ដើម្បីផ្តល់នូវសូចនាករដ៏មានសារៈប្រយោជន៍ផ្សេងៗ ស្តីពីកំណើនក្នុងវិស័យនេះ និងបង្ហាញវិភាគទានរបស់ស្ត្រី ចំពោះការអភិវឌ្ឍន៍សង្គម។ ហើយគួរមានកូតាមួយសម្រាប់ចំនួនស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ សភាជាតិ និងមុខតំណែងរដ្ឋាភិបាល ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ រីឯរដ្ឋាភិបាលគួតផ្តល់ឱកាសបន្ថែមទៀតសម្រាប់ស្ត្រីអោយទទួលបានការជ្រើសរើស ដើម្បីធានាអោយពួកគេមានឱកាសស្មើគ្នាក្នុងការទទួលបានមុខតំណែងធ្វើសេចក្តីសម្រេច។ ចំពោះរាល់ផែនការអភិវឌ្ឍន៍ទាំងអស់គួរមានសូចនាករ និងការវិភាគយេនឌ័រ និងយុទ្ធសាស្ត្រយេនឌ័រ ដើម្បីជួយដល់ពលរដ្ឋក្រីក្រ។

២.២.៣ ទ្រឹស្តីវិស័យព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ

ធនធានព្រៃឈើជាមូលដ្ឋាននៅប្រទេសកម្ពុជា ត្រូវបានគេប៉ាន់ស្មានថាគ្របដណ្តប់លើផ្ទៃដីប្រទេសជាង៣ក់កណ្តាល ភាគច្រើននៃធនធានព្រៃឈើត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលជាងដប់ ទៅដប់ប្រាំឆ្នាំចុងក្រោយនេះ។ ដូចដែលយើងបានដឹងជាទូទៅមកហើយថា តំបន់សំខាន់ៗត្រូវបានគេដាក់អោយស្ថិតនៅក្នុងដែនព្រៃសម្បទាន ហើយតំបន់ផ្សេងៗទៀតត្រូវបានកាន់កាប់ដោយអ្នកដែលមិនមែនជាសម្បទានិក ហើយនៅតំបន់ទាំងនោះមានកំណើនប្រជាជន និងមានកំណើននៃការប្រើប្រាស់ធនធានព្រៃឈើជាផលឈើជាអុស រីឯអនុផលព្រៃឈើជាច្រើនប្រភេទទៀតកំពុងតែធ្វើអោយធនធានដែលនៅសេសសល់ទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងក្លា។ ជាងនេះទៅទៀត វិសាលភាពព្រៃកំពុងតែថយចុះជាបន្តបន្ទាប់ ដោយសារតែការបង្វែរផ្ទៃដីព្រៃអោយទៅជាដីកសិកម្ម និងដំណាំចំការធំៗរបស់អ្នកជំនាញ និងក្រុមអ្នកមានទ្រព្យសម្បត្តិមួយចំនួនតូច។

ការគំរាមកំហែងមួយទៀតនោះ គឺគម្រោងសាងសង់ផ្លូវនានារបស់ក្រុមហ៊ុនព្រៃសម្បទានរួមជាមួយហិរញ្ញវត្ថុទ្វេភាគី និងពហុភាគីបានធ្វើអោយគេងាយចូលទៅកាន់តំបន់មានព្រៃឈើ។ ផ្លូវទាំងនេះកំពុងជួយសម្រួលយ៉ាងច្រើនដល់ការតាំងទីលំនៅថ្មីនៅក្នុងតំបន់ព្រៃ ហើយជនទាំងនោះស្វែងរកការកាប់ឆ្ការព្រៃ ដើម្បីនឹងទទួលបានកម្មសិទ្ធិនៅលើផ្ទៃដីដែលកាប់ឆ្ការថ្មីនោះជាបន្តបន្ទាប់។ មានផលប៉ះពាល់យ៉ាងច្រើនជាមួយព្រៃឈើកម្ពុជា និងការអភិវឌ្ឍន៍ទាំងនេះ ពោលគឺសក្តានុពលពាណិជ្ជកម្មនៃព្រៃឈើនាពេលអនាគត និងប្រជាជនដែលតាំងលំនៅតាមលក្ខណៈប្រពៃណីនៅក្នុង និងជុំវិញតំបន់ព្រៃ។

នៅពេលដែលធនធានព្រៃឈើជាមូលដ្ឋានស្ថិតនៅក្រោមគំរាមកំហែងបែបនេះ មានសក្តានុពលដ៏សំខាន់សម្រាប់បង្ការភាពក្រីក្រតាមរយៈការអភិវឌ្ឍន៍ព្រៃឈើសង្គម និងប្រព័ន្ធគ្រប់គ្រងព្រៃឈើរួមគ្នា ដែលស្ថាបនាផ្អែកលើសមាហរណកម្មព្រៃឈើ ដែលមានលក្ខណៈប្រពៃណីជាមួយដំណើរ ទៅក្នុងប្រព័ន្ធកសិកម្មរបស់ប្រជាជនខ្មែរ និងក្រុមជនជាតិភាគតិច។ លើសពីនេះទៅទៀត ការប្រឹងប្រែងដោយសហគមន៍មូលដ្ឋានដើម្បីបញ្ឈប់ការកាប់ឈើខុសច្បាប់នាពេលថ្មីៗនេះ កំពុងទទួលបានការគាំទ្រដ៏ខ្លាំងក្លាពីសំណាក់អាជ្ញាធរមូលដ្ឋាននៅក្នុងតំបន់នានាជាច្រើន។ ត្រង់ចំណុចនេះបញ្ហាគន្លឹះ គឺត្រូវត្រួតពិនិត្យលើបញ្ហាដូចតទៅ:

ការកាប់ឈើខុសច្បាប់ និងការត្រួតពិនិត្យដោយឯករាជ្យ: នៅក្នុងប្រទេសកម្ពុជា ការកាប់ឈើមានការកើនឡើងដល់កម្រិតខ្ពស់។ ទោះបីជាការកាប់ឈើជាញឹកញាប់ត្រូវបានបង្ហាញថា ជាសកម្មភាពការងាររបស់អ្នកភូមិក៏ដោយក៏ជាទូទៅសកម្មភាពនេះត្រូវបានរៀបចំដោយក្រុមទាហាន ឬប៉ូលីស ព្រមទាំងមានការឃុបឃិតពីមន្ត្រីរដ្ឋាភិបាលថែមទៀត។ ការប្រមូលផលឈើ កែច្នៃឈើ ការដឹកជញ្ជូន និងលក់ត្រូវឆ្លងកាត់បណ្តាញឈ្មួញកណ្តាលជាមួយនឹងការទប់ស្កាត់យូរៗម្តងពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។ ការកាប់ឈើក្នុងទ្រង់ទ្រាយធំក៏កំពុងកើតឡើងក្រោមរូបភាពជាដីសម្បទានរបស់ក្រុមហ៊ុន និងចំការកៅស៊ូ។ ជាទូទៅតំបន់គោលដៅសម្រាប់ការអភិវឌ្ឍន៍ដំណាំចំការធំៗ ត្រូវបានកំណត់នៅក្នុងតំបន់ព្រៃ ដែលមានតម្លៃបំផុតជាជាងតំបន់ដែលគ្មានព្រៃ ឬដីវាលដែលវាមានលក្ខណៈសក្តិសមនឹងបង្វែងទៅជាតំបន់ធ្វើកសិកម្ម។

ការអនុវត្តន៍ការត្រួតពិនិត្យប្រកបដោយភាពឯករាជ្យ លើបញ្ហាស្មុគស្មាញនៃការកាប់ឈើខុសច្បាប់ត្រូវបានបញ្ឈប់ក្នុងខណៈពេលដែលអង្គការ Globle Witness ត្រូវបានដកចេញមិនអោយធ្វើសកម្មភាពជាបន្តនាដើមឆ្នាំនេះ។ ម្ចាស់ជំនួយបានស្វែងរកផងដែរក្នុងការភ្ជាប់អ្នកជំនួយបរទេសរបស់ពួកគេ ជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងធនធានព្រៃឈើ ដើម្បីទទួលបានជាអតិបរមានូវផលប្រយោជន៍សាធារណៈ។ នេះជាហេតុចម្បងសម្រាប់ការត្រួតពិនិត្យប្រកបដោយភាពឯករាជ្យ ដូចជា ឯកសារស្តីពី "គម្រោងត្រួតពិនិត្យពីឧក្រិដ្ឋកម្មព្រៃឈើ" ក្នុងឆ្នាំ១៩៩៩[១៥]។

ការអភិវឌ្ឍន៍ខ្នាតធំ ឬតូចលើវិស័យព្រៃឈើកសិកម្ម និងដំណាំចំការៈ ការផ្តោតជាគន្លឹះនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល គឺការជម្រុញវិស័យកសិ-ឧស្សាហកម្ម តាមរយៈការអភិវឌ្ឍន៍ដំណាំចំការ ហើយផ្សារភ្ជាប់នឹងការកែច្នៃដំណាំផ្តល់ប្រាក់(ដូចជា ស្វាយចន្ទី ដូងប្រែង ដៅស៊ូ និងសណ្តែកសៀង) បន្ទាប់ពីបានទទួលផល។ ការអនុវត្តន៍នាពេលបច្ចុប្បន្នរបស់រដ្ឋាភិបាលបង្ហាញថា រដ្ឋាភិបាលបានសម្រេចចិត្តជម្រុញការអភិវឌ្ឍន៍ដំណាំចំការ ដែលមានទ្រង់ទ្រាយធំ។ ការសម្រេចចិត្តនេះកំពុងតែមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសហគមន៍ជនបទ ព្រោះវាទាក់ទងទៅនឹងការផ្លាស់ប្តូរតំបន់ព្រៃឈើជាច្រើនសម្រាប់អភិវឌ្ឍន៍ផ្នែកកសិកម្ម។

ប្រសិនបើការសម្រេចចិត្តទាំងនេះត្រូវបានអនុវត្ត នោះបំលែងតំបន់ដីព្រៃនឹងបង្កើនល្បឿន ហើយគ្រួសារ និងក្រុមហ៊ុនមួយចំនួនតូចនឹងក្លាយទៅជាម្ចាស់នៃដីព្រៃដ៏ធំធេងយ៉ាងពិតប្រាកដ ហើយវិសមភាពក្នុងការបែងចែកប្រាក់ចំណូលទំនងជាបន្តមានសភាពអាក្រក់ឡើងៗ។

ការកាប់ឈើច្បោះដំរៈ ការកាប់ឈើច្បោះនៅតែបន្ត ថ្វីបើមានការហាមឃាត់នៅក្នុងច្បាប់ព្រៃឈើក្តី[១៦] ហើយទោះជាមានការយល់ដឹងកាន់តែច្រើននៃអ្នកភូមិ ដែលមានប្រាក់ចំណូលខ្ពស់បានមកពីការដងជំរំទឹកដ៏ដោយ[១៧]។ នាពេលថ្មីៗនេះការកាប់ដើមច្បោះជំរាគច្រើនកំពុងកើតឡើង ក្រោមរូបភាពក្លែងក្លេទនៃដីសម្បទាន

---

[១៥] ឯកសារស្តីពី គម្រោងឧក្រិដ្ឋកម្មព្រៃឈើ និងការរាយការណ៍ បញ្ជាក់ថា "ដើម្បីបន្តលើកទឹកចិត្តរាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់អោយអនុវត្តច្បាប់ព្រៃឈើអោយមានប្រសិទ្ធភាព IMF បានបញ្ជាក់អំពីការបង្កើតនូវប្រព័ន្ធតាមដានព្រៃឈើជាអចិន្ត្រៃយ៍ ធ្វើជាការចាប់ផ្តើមកម្មវិធីទ្រទ្រង់ផ្នែកម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួន" ហើយ "ក្នុងលទ្ធភាពទី៣ រដ្ឋាភិបាលស្នើរអោយមានក្រុមផ្តល់យោបល់ឯករាជ្យ ដែលនឹងផ្សព្វផ្សាយជាសាធារណៈនូវការវាយតម្លៃរបស់ខ្លួនអំពីកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលអំពីបញ្ហាព្រៃឈើ។ ការវាយតម្លៃ ដែលមានលក្ខណៈឯករាជ្យនេះ មានបំណងផ្តល់នូវការធានាដល់សហគមន៍ម្ចាស់ជំនួយអន្តរជាតិ ស្តីពីខ្លឹមសារនៃការប៉ាន់ស្មានក្នុងការរាយការណ៍ផ្ទាល់របស់រដ្ឋាភិបាល និងលើការប្តេជ្ញាជាមូលដ្ឋានរបស់រដ្ឋាភិបាល ចំពោះការធ្វើអោយព្រៃឈើមាននិរន្តរភាព "រាជរដ្ឋាភិបាលកម្ពុជា ឧក្រិដ្ឋកម្មព្រៃឈើ" និងការរាយការណ៍ឯកសារគម្រោង ខែកក្កដា ឆ្នាំ១៩៩៩ ទំព័រទី៤

[១៦] មាត្រា២៩ ក៣. នៃច្បាប់ព្រៃឈើៈ "ត្រូវបានហាមឃាត់ក្នុងការប្រមូលផល ដូចបានរៀបរាប់ខាងក្រោម ទោះនៅទីណាក្តី នៅក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍...ឈើច្រើនប្រភេទដែលសហគមន៍បានចោះ ជា ច្បោះ ដើម្បីយកជំរំសំរាប់ការប្រើប្រាស់តាមទម្លាប់"។

[១៧] Tom D. Evans, et al: ការសិក្សាពើជំរំទឹក និងការចិញ្ចឹមជីវិតរស់ប្រជាជនដែលទាក់ទងទៅនឹងការអភិរក្ស និងការគ្រប់គ្រងព្រៃឈើនៅខេត្តមណ្ឌលគីរី នៃប្រទេសកម្ពុជា សមាគមអភិរក្សសត្វព្រៃ, ភ្នំពេញ ខែមករា ឆ្នាំ២០០៣។ Ian -

និងការអភិវឌ្ឍន៍ចំណាំចំការធំៗ ហើយនេះបញ្ជាក់ថាការឯកភាពលើព្រៃសម្បទាន គឺមានបំណងកាត់ដើមច្បោះ របស់អ្នកភូមិនៅក្នុងតំបន់សម្បទាន។ ទិន្នន័យសារពើភ័ណ្ឌដែលបានប្រើប្រាស់សម្រាប់យុត្តិកម្ម លើការអនុម័តផែនការគ្រប់គ្រងព្រៃសម្បទានមិនបានទទួលស្គាល់ភាគច្រើន ការកាប់ឈើដែលបានអនុញ្ញាតអោយកាប់ប្រចាំឆ្នាំ គឺជាឈើច្បោះដ៏យឡើយ។ ជំនាញការដែលធ្វើការក្នុងគម្រោងសិក្សាអំពីឥណទាននេះកៅស៊ូសំយោគបានជំនួសកៅស៊ូធម្មជាតិទៅហើយ[១៨]។ ផ្ទុយមកវិញតម្លៃអន្តរជាតិសម្រាប់តម្លៃដ៏យឈើបានកើនឡើងតាំងពីឆ្នាំ ១៩៧០ម្ល៉េះ ព្រោះតែការបាត់បង់ព្រៃឈើទ្រង់ទ្រាយធំ ដែលបានកើនឡើងក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះនៅតំបន់អាស៊ីអាគ្នេយ៍[១៩]។ ម្យ៉ាងវិញទៀត ការចោះដើមច្បោះយកដំរទឹកមិនបាននាំមកនូវការអភិរក្សព្រៃឈើរបស់ប្រទេសកម្ពុជា និងផលប្រយោជន៍សំខាន់ផ្នែកបរិស្ថាននោះទេ។

ការកាត់បន្ថយភាពក្រីក្រ ឬការបង្កើតភាពក្រីក្រ: គោលដំហរទប់ស្កាត់របស់រដ្ឋាភិបាល និងម្ចាស់ជំនួយ គឺថាកំណែទម្រង់គោលនយោបាយដែលបានគ្រោង និងអនុវត្តសំដៅកាត់បន្ថយភាពក្រីក្រ។ ហើយនៅបច្ចុប្បន្ននេះស្ទើរតែគ្រប់សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល និងផែនការសកម្មភាពរបស់ម្ចាស់ជំនួយ គឺសុទ្ធតែបានធ្វើឡើងដោយផ្អែកលើផលប៉ះពាល់នៃការកាត់បន្ថយភាពក្រីក្រ។ ទោះបីជាយ៉ាងនេះក៏ដោយការអនុវត្តន៍ជាក់ស្តែងរបស់រាជរដ្ឋាភិបាល ដែលតែងតែត្រូវបានផ្តល់ហិរញ្ញវត្ថុ និងផ្តល់ភាពស្របច្បាប់ពីសហគមន៍ម្ចាស់ជំនួសកំពុងជម្រុញកម្ពុជាអោយស្ថិតនៅលើគន្លងនៃកំណើនវិសមភាព ហើយអាចជម្រុញអោយប្រជាជនមួយភាគធំនៅជនបទមានភាពក្រីក្រកាន់តែធ្ងន់ធ្ងរឡើងៗ។ ជាពិសេសភាពក្រីក្រកើតមានចំពោះសហគមន៍ដែលពឹងផ្អែកលើព្រៃឈើដែលសហគមន៍កាន់តែមានលទ្ធភាពតិចតួចក្នុងការទទួលបានធនធានព្រៃឈើ ពោលគឺផលិតផលដែលគេពឹងផ្អែកយ៉ាងខ្លាំងសម្រាប់រកប្រាក់ចំណូលនោះ ត្រូវបានអ្នកជំទែជណ្តើមយកដោយមិនស្របច្បាប់ ឬការយកម្រៃពន្ធជាស្ទើរតែស្មើនឹងតម្លៃពេញនៃតម្លៃទីផ្សារទៅហើយ[២០] ហើយបច្ចុប្បន្នព្រៃរបស់ពួកគេត្រូវបានដក

G. Baird, "ឈើផ្តល់ដំរទឹកប្រភេទDipterocarpus,ការគ្រប់គ្រង និងការធ្វើអាជីវកម្ម: ការអនុវត្តរបស់ Brao ក្នុងភាគឦសាននៃប្រទេសកម្ពុជា "និក្ខេបបទអក្សរសាស្ត្រថ្នាក់អនុបណ្ឌិត ដេប៉ាតឺម៉ង ភូមិវិទ្យានៃសាកលវិទ្យាល័យវីកតូរៀ ឆ្នាំ ២០០៣។ Andrew, John P, ម៉ម សម្បត្តិ, ហុង គឹមលី និងលីប៊ុនថៃ "ការសម្របខ្លួនរបស់ប្រជាជនជាតិភាគតិចលើការចយចុះនៃធនធានធម្មជាតិ បទពិសោធន៍របស់ឃុំក្នុងទាំងពីរនៅភាគឦសាននៃប្រទេសកម្ពុជា" ភ្នំពេញ CIDSE ពង្រាងនៅឆ្នាំ២០០៣

[១៨] សូមអាន "អភិជនកៅស៊ូ?" របស់ទស្សនាវដ្តី Economist ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣ និង "ដែលបង្កសំឡេងរំពង" របស់ទស្សនាវដ្តី Economist ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩

[១៩] Renee Ankarfjard & Miran Kegl, "Tapping oleoresin from Dipterocarpus alatus (Dipterocarpaceae) in a Lao Village", Economic Botany, Vol52, No.1,1998,pp. 7-14; Rosemary Gianno, ការធ្វើអាជីវកម្មលើផលិតផលដំរទឹកក្នុងតំបន់ព្រៃទំនាប Malayan, Wallaceana Vol.43 , 1986, pp.3-6

[២០] ព្រំ តុលា និង Bruce Mckenney: ការធ្វើអាជីវកម្មផលិតផលព្រៃឈើក្នុងប្រទេសកម្ពុជា : ករណីសិក្សាពីដំរទឹក ការត្រួតពិនិត្យការអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ Vol.7, No.2 មេសា-មិថុនា ២០០៣។

ហូតតាមរយៈការជម្រុញគម្រោងអភិវឌ្ឍន៍ដែលយល់ដឹងមិនល្អ ដូចជា ចំការកៅស៊ូទុំរឹងជាដើម។ ចំពោះប្រជាជនជាច្រើននៅតាមទីជនបទអនាគតនៅតែមានភាពអាប់អួរ។

កម្ពុជាស្ថិតនៅលើផ្លូវបំបែក និងប្រឈមមុខនឹងមហន្តរាយដ៏ធំ ដូចជា នៅប្រទេសហៃទីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកជាមួយនឹងការធ្លាក់ចុះជាបន្តទៅក្នុងភាពក្រីក្រភាគច្រើន ដោយបាត់បង់ស្ទើរតែទាំងស្រុងនូវវិសាលភាពព្រៃឈើ និងកំពុងរងនូវការគំរាមកំហែង នៃអស្ថេរភាពសង្គម។ ផ្អែកលើការគ្រប់គ្រងព្រៃឈើដោយព្រៃសម្បទានការកាប់ឈើប្រចាំឆ្នាំ និងដីសម្បទានមានទ្រង់ទ្រាយធំនឹងនាំអោយកម្ពុជាឆ្ពោះទៅរកស្ថានភាពបែបនេះ។

ជម្រើសដ៏ល្អនោះ គឺអ្នកតាក់តែងគោលនយោបាយរបស់ប្រទេសកម្ពុជាអាចជ្រើសរើសយកការចម្លងគំរូអភិវឌ្ឍន៍ ដែលមានលក្ខណៈសមធម៌នៃប្រទេសដែលមានការគ្រប់គ្រង ការពារធនធានព្រៃឈើតាមរបៀបដែលផ្តល់សេចក្តីត្រូវការ សម្រាប់ការចិញ្ចឹមជីវិតរបស់សហគមន៍ជនបទ ហើយលៃយ៉ាងណាថែរក្សាគន្លឹះនៃប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធផ្លូវទឹក។ ប្រការតម្រូវអោយអនុវត្តលើជម្រើសយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើមួយដែលទទួលស្គាល់ថា កម្ពុជានឹងអាចរក្សាព្រៃរបស់ខ្លួនបាន ប្រសិនបើសហគមន៍ក្លាយជាស្នូលនៃការគ្រប់គ្រង និងត្រូវបានផ្តល់សិទ្ធិដើម្បីការពារគ្រប់គ្រង និងទទួលផលប្រយោជន៍ពីតំបន់ព្រៃឈើ។

ដើម្បីតម្រង់ឆ្ពោះទៅរកនិរន្តរភាព និងការគ្រប់គ្រងប្រកបដោយសមធម៌នៃព្រៃឈើកម្ពុជា ត្រូវមានផែនការច្បាស់លាស់ជាជំហានៗ ដែលមានលក្ខណៈបន្ទាន់។ ជំហានទាំងនេះរួមមាន: ទី១-ធ្វើការវាយតម្លៃវិសាលភាពព្រៃដោយឯករាជ្យ និងគ្រប់ជ្រុងជ្រោយ ធ្វើជាមូលដ្ឋានសម្រាប់រៀបរាប់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍។ ទី២-រៀបរាប់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍។ ទី៣-រៀបចំ និងអនុម័តច្បាប់ទ្រព្យសម្បត្តិរដ្ឋ(ដែលរួមបញ្ចូលទាំងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍) ដែលធានាតម្លាភាពទាក់ទងទៅនឹងការកំណត់ព្រំដែន ការប្រើប្រាស់ និងការគ្រប់គ្រង។ ទី៤-ធ្វើការប្តេជ្ញាចិត្តច្បាស់លាស់មួយដោយមានការឯកភាពគ្នា ជាមួយនឹងការសិក្សារបស់ធនាគារពិភពលោក និងប្រាក់កម្ចីនវាអនុវត្តន៍ស្តីពីការគ្រប់គ្រងព្រៃឈើសម្បទាន ដែលច្បាប់បានហាមឃាត់ការកាប់នូវរាល់ដើមឈើច្បោះដំរ ដែលនឹងដាក់បញ្ចូលទៅក្នុងការវាយតម្លៃ ថាតើសម្បទានទាំងនោះអាចធានាភាពស្ថិតស្ថេរដែរ ឬទេ?។ ទី៥-ដកហូតការទទួលខុសត្រូវក្នុងការត្រួតពិនិត្យឧក្រិដ្ឋកម្មព្រៃឈើ ពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដោយផ្តល់ការទទួលខុសត្រូវនេះទៅស្ថាប័នផ្សេងៗ ដែលមិនពាក់ព័ន្ធការអនុម័ត និងការគ្រប់គ្រងព្រៃសម្បទាន។ ទី៦-បង្កើតយន្តការត្រួតពិនិត្យដោយឯករាជ្យក្នុងការស៊ើបអង្កេតបទឧក្រិដ្ឋកម្មព្រៃឈើ និងភាពស្របច្បាប់របស់រដ្ឋាភិបាល ក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទងទៅនឹងការប្រើប្រាស់ និងការគ្រប់គ្រងធនធានព្រៃឈើ។ និងជាចុងក្រោយ គឺត្រូវមានការបង្កើតយន្តការតាមដានឯករាជ្យមួយ ដែលនឹងធ្វើការតាមដានឧក្រិដ្ឋកម្មព្រៃឈើ និងភាពស្របច្បាប់ នៃការសម្រេចចិត្តរបស់រដ្ឋាភិបាលទាក់ទងនឹងការប្រើប្រាស់ និងការគ្រប់គ្រងនៃធនធានព្រៃឈើ។

២.២.៤ ទ្រឹស្តីវិមជ្ឈការក្នុងការកាត់បន្ថយភាពក្រីក្រ

ដោយមានការជម្រុញលើកទឹកចិត្តពីលទ្ធផលឆ្នាំទី១ នៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ រាជរដ្ឋាភិបាល កម្ពុជាតាមរយៈគណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងបណ្តុះបណ្តាលស្ថាប័ន ព្រមទាំងម្ចាស់ជំនួយផ្សេងៗទៀតបានបន្តពង្រឹង និងពង្រីកសកម្មភាពនានា នៅក្នុងឆ្នាំទី២ សំដៅសម្រេចអោយបាននូវគោលបំណងនៃគោលនយោបាយវិមជ្ឈការ។ សមិទ្ធផល ដែលសម្រេចបានរួមមានការចេញលិខិតបទដ្ឋានដើម្បីជាមគ្គុទេសក៍នៃការអនុវត្តន៍វិមជ្ឈការ ការពង្រឹងប្រព័ន្ធ នៃការគាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់ និងកិច្ចសហប្រតិបត្តិការជាមួយគម្រោងផ្សេងៗ ដែលបានគាំទ្រដោយម្ចាស់ជំនួយ ដូចជា កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ដើម្បីគាំទ្រគម្រោងវិមជ្ឈការ(UNDP SDP) គម្រោងសម្រាប់អភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ/សង្កាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី(CCDP/ADB) GTZ, មូលនិធិ Konrad Adenauer និងគម្រោងគាំទ្រឃុំ/សង្កាត់(CCSP)។

ជាទូទៅ សង្គមស៊ីវិលបានគាំទ្រដល់ការអនុវត្តន៍កម្មវិធីវិមជ្ឈការ។ តាមរយៈ CCSP ការិយាល័យទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាលមួយត្រូវបានបង្កើតឡើងនៅក្នុងនាយកដ្ឋានរដ្ឋបាល។ ការិយាល័យទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាលនេះ មានតួនាទីបង្កើនការផ្លាស់ប្តូរ និងជាចន្លុះក្នុងការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋាភិបាលជម្រុញភាពជាដៃគូរវាងសង្គមស៊ីវិល និងរដ្ឋាភិបាលក្នុងបញ្ហាវិមជ្ឈការផងដែរ។ សម្ព័ន្ធភាពរបស់អង្គការក្រៅរដ្ឋាភិបាល ដែលគួរអោយជឿជាក់មួយកំពុងសកម្មចូលរួមជម្រុញភាពជាដៃគូរ រវាងក្រុមប្រឹក្សាឃុំ/សង្កាត់ និងសង្គមស៊ីវិលក្នុងការអនុវត្តន៍គម្រោងនានា។ ក្រុមការងារស្តីពីភាពជាដៃគូរវិមជ្ឈការបានប្រសូត្រចេញពីសិក្ខាសាលាថ្នាក់ជាតិដ៏ធំមួយ ដែលដឹកនាំដោយអង្គការ CIDSE ដើម្បីតម្រង់ទិសភាពជាដៃគូរក្នុងចំណោមក្រុប្រឹក្សាឃុំ/សង្កាត់ និងបណ្តាអង្គការបម្រើការងារនៅថ្នាក់សហគមន៍ក្នុងការអនុវត្តន៍គម្រោង។ ក្រៅពីនេះមានអង្គការក្រៅរដ្ឋាភិបាលជាច្រើនទៀត មិនត្រឹមតែកំពុងចូលរួមយ៉ាងសកម្មក្នុងការផ្តល់មូលនិធិដល់គម្រោងឃុំ/សង្កាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់មូលនិធិដល់ការកសាងសមត្ថភាពរបស់សមាជិក ក្រុមប្រឹក្សាឃុំ/សង្កាត់បន្ថែមទៀតផងដែរ។ អង្គការ Concern Worldwide កំពុងតម្រង់ទិសសកម្មភាពរបស់ខ្លួន ដើម្បីធ្វើការអោយកាន់តែជិតស្និទជាមួយរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងកម្មវិធីកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ/សង្កាត់។ អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម Buddhism for Development កំពុងផ្តួចផ្តើមគំនិតស្តីពីការកសាងសមត្ថភាពអំពីតម្លាភាពរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។ ជាការពិតណាស់ បច្ចុប្បន្ននេះមានគំនិតផ្តួចផ្តើមសមស្របជ៏សំបូរបែបរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងវិស័យវិមជ្ឈការ[២១]។

បញ្ហាសំខាន់ៗត្រង់ចំណុចនេះលៃយ៉ាងណាអោយគម្រោងអភិវឌ្ឍន៍ឃុំ/សង្កាត់ នាំទៅរកការកាត់បន្ថយភាពក្រីក្រពីព្រោះ ឃុំ/សង្កាត់ ស្ទើរតែទាំងអស់បានរៀបចំផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និងផែនការវិនិយោគឃុំ/

[២១] ឯកសារតាមវិស័យ និងបញ្ហារបស់ NGO ស្តីពី "ការកាត់បន្ថយភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣" ខែមីនា ឆ្នាំ២០០៤ ទំព័រទី១៣

សង្កាត់ តាមរបៀបមួយដែលអាចចាត់ទុកថា ជាដំណើរការមួយដែលមានការចូលរួមយ៉ាងខ្លាំងក្លា។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយគ្មានវិធានការណាមួយត្រូវបានប្រកាន់យក ដើម្បីធានាអោយគម្រោងទាំងអស់ដែលត្រូវបានធ្វើក្នុងដំណើរការនៃការចូលរួមនេះ គឺជាគម្រោងដែលនឹងមានឥទ្ធិពលខ្លាំងបំផុតដល់ការកាត់បន្ថយភាពក្រីក្រនៅឡើយ។ ក្នុងករណីជាច្រើន ការជ្រើសរើសគម្រោង និងដំណើរការនៃការផ្តល់អាទិភាពគម្រោងតែងតែផ្អែកទៅលើនីតិវិធីនៃការបោះឆ្នោតមួយចំនួន ដែលមានភាពមិនច្បាស់លាស់ទាំងនៅថ្នាក់ភូមិ និងគណៈកម្មាធិការផែនការ និងគម្រោងថវិកា។ ជំនួយដែលផ្តល់ជូនដោយក្រុមគាំទ្រ ផ្នែកបច្ចេកទេសមានទំហំស្តួចស្តើង ដែលនាំអោយមានបញ្ហាលំបាកដល់លទ្ធភាពអនុវត្តផ្នែកបច្ចេកទេស ដើម្បីដំណើរការគម្រោងដែលបានជ្រើសរើសហើយទីបញ្ចប់ គឺឥទ្ធិពល និងផលប៉ះពាល់នៃជំនួយនោះ ឬការកាត់បន្ថយភាពក្រីក្រនៅក្នុងកម្រិតឃុំ/សង្កាត់។

តម្រូវការពីឃុំ/សង្កាត់ គួរបញ្ជូលទៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីជាព័ត៌មានផ្នែកគោលនយោបាយ ការបែងចែកធនធាន។

គេនៅតែធ្វើផែនការថ្នាក់ខេត្តរបស់បណ្តាក្រសួងដោយគ្មានការពិភាក្សាជាមុន និងគ្មានការសម្របសម្រួលជាមួយឃុំ/សង្កាត់ទេ។ ដូច្នេះ ផែនការរបស់ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ខេត្តត្រូវលើកបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុកសម្រាប់អោយឃុំ/សង្កាត់ពិចារណា។ ប្រការនេះចោទជាបញ្ហាចំពោះសារៈសំខាន់នៃដំណើរការធ្វើផែនការដោយមានការចូលរួម។ គោលការណ៍ "ទទួលយក ឬបោះបង់ចោល" នៅតែឃើញមានអនុវត្តជាទូទៅ ហើយគេហាក់ដូចជាមើលឃើញថា តំណាងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ខេត្ត មិនបានបញ្ចូលស្មារតីវិមជ្ឈការទៅក្នុងឥរិយាបទរបស់ខ្លួនឡើយ។

មានការផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការធ្វើផែនការមូលដ្ឋាន តែទិដ្ឋភាពផ្សេងៗទៀតក្នុងវិមជ្ឈការ ដូចជា វិមជ្ឈការសារពើពន្ធ និងការរកចំណូលនៅមូលដ្ឋាន មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។

ការធ្វើផែនការមូលដ្ឋាន និងដំណើរការនៃការចូលរួម គឺជាមូលដ្ឋានគ្រឹះនៃវិមជ្ឈការ។ តែទោះជាយ៉ាងណាក៏ដោយ ការផ្តល់មូលនិធិគ្រប់គ្រាន់ដល់មូលដ្ឋានសម្រាប់អនុវត្តគម្រោង ក៏ទាមទារអោយមានការធានាផងដែរ ដើម្បីធ្វើអោយមាននិរន្តរភាពផលប្រយោជន៍ និងមានជំនឿជឿជាក់ក្នុងកិច្ចដំណើរការ។ ប្រសិនបើគ្មានមូលនិធិគ្រប់គ្រាន់ទេ វិមជ្ឈការអាចប្រែទៅជាក្តីសុបិន្តមួយដែលគ្មានបានការ ហើយប្រជាជននៅក្នុងឃុំ/សង្កាត់នឹងបាត់បង់ការចាប់អារម្មណ៍ ឬមួយប្រឆាំងនឹងវិមជ្ឈការ ប្រសិនបើគ្មានលទ្ធផលជាក់ស្តែងទេនោះ។

គួរមានតម្លាភាពទាំងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងទាំងក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ: ទន្ទឹមនឹងមានគោលការណ៍ណែនាំពីការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងឃុំ/សង្កាត់ ប្រព័ន្ធ និងការទទួលខុសត្រូវក្នុងការធ្វើសវនកម្មមិនទាន់ត្រូវបានរៀបចំឡើងនៅឡើយ។ ក្នុងករណីខ្លះដែលមានការធ្វើសវនកម្ម ប៉ុន្តែរបាយការណ៍សវនកម្មមិនត្រូវបានផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធទេ។

មេឃុំ/ចៅសង្កាត់ នៅតែបន្តជាអ្នកសម្រេចចិត្តផ្តាច់មុខ។ ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ផ្តាច់ការតាមបែបប្រពៃណីនៅតែបន្តកើតមាន បើទោះបីជាមានការជម្រុញអោយមានដំណើរការនៃការចូលរួមក៏ដោយ។

ក្នុងករណីជាច្រើនសេចក្តីសម្រេចចិត្តត្រូវបានធ្វើឡើងដោយមេឃុំ/ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយគ្មានការចូលរួមពីអ្នកដែលទទួលរងផលប៉ះពាល់ឡើយ[២២]។

២.៣ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល

ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គឺជាគោលដៅអភិវឌ្ឍន៍ចម្បងរបស់រាជរដ្ឋាភិបាល ដោយសារភាពក្រីក្រ គឺជាការខាតបង់ខាងសេដ្ឋកិច្ច ដែលធ្វើអោយសីលធម៌ធ្លាក់ចុះ និងបណ្តាលអោយមានការបែកបាក់ក្នុងសង្គម។ រាជរដ្ឋាភិបាល បានប្រកាសនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការប្រឹងប្រែងរួមគ្នាក្នុងកម្រិតជាតិ និងប្រកបដោយចីរភាព ដើម្បីកំចាត់ភាពក្រីក្រគោកយ៉ាកអោយអស់ពីកម្ពុជា ដើម្បីអោយប្រជាជនកម្ពុជាទាំងអស់អាចទទួលបានផលពីកំណើនសេដ្ឋកិច្ច និងអាចរួមចំណែកនៅក្នុងដំណើរការនៃកិច្ចការអភិវឌ្ឍន៍។ ការកាត់បន្ថយភាពក្រីកក្រអោយបានឆាប់រហ័ស គឺជាការចូលរួមវិភាគទានមួយដ៏មានសារៈសំខាន់នៅក្នុងដំណើរការបង្រួបបង្រួមជាតិ និងការធ្វើអោយវប្បធម៌ជាតិរស់ឡើងវិញជាថ្មី និងជាគន្លឹះនៃការថែរក្សាស្ថេរភាពនយោបាយ និងស្ថេរភាពសង្គម។

២.៣.១ សមាសធាតុនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការចាប់ផ្តើមរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទីពីរ ២០០១-២០០៥ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវយុទ្ធសាស្ត្រដ៏ចម្បងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ នោះគឺការខិតខំសម្រេចអោយបាននូវៈ ១-កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងរយៈពេលវែង ក្នុងអត្រាពី ៦ ទៅ ៧% ២-បែងចែកដោយសមធម៌នូវផ្លែផ្កានៃកំណើនសេដ្ឋកិច្ចរវាងអ្នកមាននិងអ្នកគ្មាន រវាងទីក្រុងនិងជនបទ និងរវាងភេទខុសគ្នា និង៣-ធានាបាននូវការប្រើប្រាស់ និងការគ្រប់គ្រងប្រកបដោយចីរភាពនៃបរិស្ថាន និងធានធានធម្មជាតិ[២៣]។ បាវចនាជាតិយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺ "ការកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ក្នុងរយៈពេលវែង ដោយធានានូវចីរភាពខាងបរិស្ថាន និងសមធម៌សង្គម"។ ដូច្នេះ គោលនយោបាយជួយជនក្រីក្ររបស់រាជរដ្ឋាភិបាលត្រូវតម្រង់ទិសទៅរកការបង្កើតឡើងនូវបរិស្ថានសមស្របមួយដើម្បីជម្រុញ និងបង្កើតអោយមានកំណើនសេដ្ឋកិច្ចដោយគ្មាន ការរិចរិលបរិស្ថាន និងការបែងចែកចំណូលប្រកបដោយសមធម៌។ ចំណុចសំខាន់ៗនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទីពីរ១៩៩៨-២០០៣នេះ គឺមានគោលបំណងកាត់បន្ថយភាពក្រីក្រតាមរយៈ : ក-ការពង្រឹងសន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម។ ខ-ការជម្រុញការវិនិយោគ។ គ-កៀងគរធនធានក្នុងស្រុក។ ឃ-ជម្រុញវិនិ-

[២២] ឯកសារតាមវិស័យ និងបញ្ហារបស់ NGO ស្តីពី "ការកាត់បន្ថយភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣" ខែមីនា ឆ្នាំ២០០៤ ទំព័រទី១៥

[២៣] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៣៧

យោគលើវិស័យអាទិភាព និងការកែលម្អវិស័យកសិកម្ម។ ង-ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។ ច-ការអភិវឌ្ឍន៍ធនធានមនុស្ស។ ឆ-ត្រូវពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល។

ទី១: គឺជាការពង្រឹងសន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម ដោយប្រកាន់យកដំហរម៉ឺងម៉ាត់ក្នុងការពង្រឹងការអនុវត្តច្បាប់លើកកម្ពស់សិទ្ធិមនុស្ស ជម្រុញប្រជាធិបតេយ្យ ដើម្បីបង្កើតឡើង និងពង្រឹងនូវបរិស្ថាននយោបាយ និងសន្តិសុខអោយបានល្អ ដើម្បីធានានូវការអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរយៈពេលវែង។

ទី២: គឺជាការកែទម្រង់នយោបាយសារពើពន្ធ តាមរយៈសកម្មភាពនានា ដើម្បីបង្កើនការកៀងគរធនធានក្នុងស្រុក និងអនុវត្តកំណែទម្រង់ថវិកាក្នុងគោលបំណងជម្រុញ និងធ្វើវិចារណកម្មចំណាយសាធារណៈ។ សកម្មភាពសំខាន់នៃគោលនយោបាយនេះ គឺការកាត់បន្ថយជាបណ្តើរៗនូវចំណាយយោធា និងសន្តិសុខ ហើយប្រើប្រាស់ថវិកា ដែលសន្សំបាននេះសម្រាប់ការវិនិយោគសាធារណៈក្នុងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធសង្គម។ គោដៅរបស់យើង គឺដៀសវាងការធ្វើហិរញ្ញប្បទានឱនភាពថវិកាដោយធនាគារ ហើយបង្កើនជាបណ្តើរៗនូវអតិរេកថវិការចរន្តក្នុងគោលដៅបង្កើត និងជម្រុញសន្សំដើម្បីធ្វើហិរញ្ញប្បទាន វិនិយោគសាធារណៈ។ ជាងនេះទៀត ជាយុទ្ធសាស្ត្ររយៈពេលវែងកម្ពុជាមិនអាចពឹងផ្អែកទៅលើមូលធនពីបរទេសជានិច្ចនោះទេ។ ហេតុនេះ យើងត្រូវខិតខំប្រឹងប្រែងបង្កើនការសន្សំក្នុងស្រុកដោយរួមទាំងការសន្សំជាលក្ខណៈឯកជន និងសាធារណៈ។ ដូចនេះ ក្រៅពីបណ្តាកិច្ចប្រឹងប្រែងដាក់ចេញនូវវិធានការ ដើម្បីអោយប្រសើរឡើងនូវការគ្រប់គ្រងចំណាយសាធារណៈ និងជម្រុញការប្រមូលចំណូល រាជរដ្ឋាភិបាលប្តេជ្ញាពង្រឹង និងអភិវឌ្ឍន៍ឧស្សាហកម្មហិរញ្ញវត្ថុ និងប្រព័ន្ធធានាគារ ដើម្បីជម្រុញលើកទឹកចិត្តការសន្សំឯកជនអោយដល់កម្រិតមួយ ដែលឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលកំពុងតែកើនឡើង។

ទី៣: គឺការជម្រុញ និងសម្រួលដល់ការវិនិយោគ ការកៀងគរជំនួយពីបរទេស និងការទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស។ កម្ពុជាត្រូវការនូវការវិនិយោគក្នុងបរិមាណដ៏គំហុកក្នុងរវាងប៉ុន្មានឆ្នាំខាងមុខនេះ ដើម្បីបង្កើនឡើងនូវថាមពលសេដ្ឋកិច្ច និងជំរុញល្បឿនដើម្បីការហក់ឡើង។ ដោយហេតុនេះហើយ ទើបរាជរដ្ឋាភិបាលទទួចចង់បាននូវការយោគយល់ពីដៃគូអភិវឌ្ឍន៍កម្ពុជា និងម្ចាស់ជំនួយនានាចំពោះចំណុចដ៏មានសារៈសំខាន់នេះ ហើយកំពុងស្វះស្វែងរកការបង្កើនជំនួយក្នុងអំឡុងប៉ុន្មានឆ្នាំខាងមុខ ដើម្បីអោយកម្ពុជាអាចត្រៀមខ្លួនបានយ៉ាងល្អសម្រាប់ការហក់ឡើងនៃសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ហើយកំពុងតែអនុវត្តវិធានការចាំបាច់ទាំងឡាយ ដើម្បីធ្វើអោយបរិយាកាសវិនិយោគកាន់តែមានភាពប្រសើរឡើង។ រាជរដ្ឋាភិបាល កំពុងផ្តោតការយកចិត្តទុកដាក់ពង្រឹងនូវបរិស្ថានសង្គមមួយ ដែលមានស្ថេរភាព សុវត្ថិភាព គណនេយ្យភាព និងភាពអាចប៉ាន់ប្រមាណបាន ហើយសង្ឃឹមថាកត្តាទាំងអស់នេះនឹងបង្កើតលក្ខខ័ណ្ឌអនុគ្រោះ និងជម្រុញការវិនិយោគនៅកម្ពុជា។

ទី៤: គឺការបង្វែងចំណាយវិនិយោគទៅខាងវិស័យអាទិភាព និងការកែលម្អផលិតភាពកសិកម្ម ដើម្បីកសាងនូវមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើនសេដ្ឋកិច្ច។ នៅក្នុងស្ថានភាពដែលប្រជាជន ៩០% រស់នៅក្នុងទីជនបទយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ ត្រូវផ្តោតទៅលើការបង្កើននូវផលិតភាពនៃវិស័យកសិកម្មតាមរយៈការពង្រឹង និងការអភិវឌ្ឍន៍សេវាគាំទ្រដល់វិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព រួមមានការស្រាវជ្រាវកសិកម្ម ការផ្សព្វផ្សាយកសិកម្ម ការគ្រប់គ្រងទឹកក្នុងស្រែ ការផ្តត់ផ្តង់ និងការចែកចាយសម្ភារៈ កសិកម្ម ដែលមានគុណភាព(ដូចបានអនុវត្តក្នុងក្របខ័ណ្ឌនៃគម្រោងពិសេស ដើម្បីសម្រេចបាននូវសន្តិសុខស្បៀងនៅក្នុងប្រទេសកម្ពុជា ដែលឧបត្ថម្ភដោយអង្គការ FAO) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសមស្រប ដូចជា ប្រព័ន្ធធារា-សាស្ត្រតូចៗដែលគ្រប់គ្រងដោយកសិករដោយផ្ទាល់ និងការកសាងផ្លូវថ្នល់ពីស្រែចំការទៅកាន់ទីជនបទ ការរៀបចំ និងការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយ និងផែការសកម្មភាពស្តីពីធនធានទឹក ការប្រយុទ្ធប្រឆាំងនឹងការរឹបអូសយកដីខុសច្បាប់ និងភាពគ្មានដីធ្លី ការអភិវឌ្ឍន៍ និងការអនុវត្តន៍គោលនយោបាយកាន់កាប់ និងប្រើប្រាស់ដីធ្លីអោយបានសមស្រប និងកិច្ចការពារបរិស្ថាន។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាល កំពុងយកចិត្តទុកដាក់ពង្រឹង និងពង្រីស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីពង្រីកាលានុវត្តភាពសេដ្ឋកិច្ចដូចជា ផ្លូវថ្នល់ ធារាសាស្ត្រ ការផ្តត់ផ្តង់ទឹក ថាមពលអគ្គីសនី និងទូរគមនាគមន៍ និងដើរតួនាទីយ៉ាងសំខាន់ និងជាលក្ខខ័ណ្ឌ ដែលមិនអាចខ្វះបាននៅក្នុងសេចក្តីព្យាយាមទាំងនេះ។ ក្នុងលក្ខខ័ណ្ឌនៃស្ថានភាពវិនិយោគ នាពេលបច្ចុប្បន្ន យើងអាចមានសង្ឃឹមថាក្នុងកំឡុងពេលប្រាំឆ្នាំខាងមុខ យើងនឹងអាចកសាងបាននូវបណ្តាញហេដ្ឋារចនាសម្ព័ន្ធ ដូចបានលើកឡើងខាងលើរហូតដល់កម្រិតមួយដែលឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋាននៃខឿនសេដ្ឋកិច្ច។ គ្រប់ស្រទាប់ថ្នាក់។

ទី៥: គឺការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងពិភពលោកក្នុងគោលបំនងបង្កើននូវរិមាត្រសេដ្ឋកិច្ចដោយការពង្រីកទីផ្សារ ធ្វើអោយប្រសើរឡើងនូវចលនភាពនៃកត្តាផលិតកម្ម និងកាត់បន្ថយថ្លៃដើមនៃផលិតផលនាំចូល និងនាំចេញ។ ក្នុងន័យនេះ ការរួមចំណែករបស់កម្ពុជា នៅក្នុងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចសកលភាវូបនីយកម្ម និងបង្កើនភាពទាក់ទាញកាន់តែខ្លាំងចំពោះវិនិយោគជម្រុញផលិតភាពនៃកត្តាផលិតកម្ម ហើយបង្កើត និងធ្វើអោយរីកចម្រើនូវឧត្តមភាពប្រៀបធៀបរបស់ជាតិតាមរយៈ ការរួមចំណែកនៅក្នុងការប្រកួតប្រជែង និងឯកទេសកម្ម។ ប្រសិនបើប្រៀបធៀបជាមួយប្រទេសនៅអាស៊ីអាគ្នេយ៍កម្ពុជាមានឧត្តមភាពប្រៀបធៀបក្នុងការផលិតកសិផល(ស្រូវ ពោត និងបន្លែ) និងកែច្នៃផលិតផលសាច់។ ប្រសិនការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាចអនុវត្តបានត្រឹមត្រូវ និងតាមគោលការណ៍វានោះនឹងដើរតួនាទី យ៉ាងសំខាន់ និងមានផលវិជ្ជមានដោយផ្ទាល់ និងដោយប្រយោលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ[២៤]។

ទី៦: បទពិសោធន៍នៃប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបង្ហាញថា ការវិនិយោគខាងធនធានមនុស្ស ជាពិសេសការវិនិយោគខាងវិស័យអប់រំ ការស្រាវជ្រាវកសិកម្ម ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើតការងារ និង

[២៤] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៣៩

សុខភាព គឺជាគន្លឹះក្នុងការធានានូវការហក់ឡើងនៃសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ដូចដែលបានលើកឡើងខាងលើ ការវិនិយោគក្នុងបរិមាណដ៏គំហុកគួបផ្សំជាមួយថាមពលរាងកាយ បញ្ញាស្មារតីនៃធនធានមនុស្ស ដល់មានការអប់រំខ្ពស់ គឺជាការចាំបាច់សម្រាប់ការហក់ឡើងនៃសេដ្ឋកិច្ច។ ដោយសារហេតុនេះ ទើបការអភិវឌ្ឍន៍ខាងធនធានមនុស្ស និងខាងសង្គមរឹតតែមានសារៈសំខាន់ និងមានលក្ខណៈបន្ទាន់ថែមទៀតនៅក្នុង បរិការណ៍នៃសមាហរណកម្មនៃសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងទៅក្នុងពិភពលោក។ រាជរដ្ឋាភិបាល បានធ្វើការប្រឹងប្រែងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ក្នុងការបង្កើនការវិនិយោគលើវិស័យនេះ តាមរយៈធនធាន ថវិកាជាតិ និងការកៀងគរកជំនួយបរទេស។

ទី៧: គឺការថែរក្សា និងពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល។ រាជរដ្ឋាភិបាល បានផ្តល់ការយកចិត្តទុកដាក់ពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ដែលបានផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដ៏មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះកម្ពុជាក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រើសិនបើគ្មានជំនួយបែបនេះទេ កម្ពុជាប្រហែលជាមិនអាចសម្រេចបាននូវវឌ្ឍនភាព និងភាពសំបូររុងរឿងគួអោយកត់សម្គាល់បែបនេះឡើយ ហើយនឹងមិនអាចជំនះបាននូវការលំបាក ដែលប្រទេសជាតិនឹងត្រូវប្រឈមមុខនាពេលអនាគតឡើយ។

ទោះជាយ៉ាងណាក៏ដោយ ការកាត់បន្ថយភាពក្រីក្រ មិនអាចសម្រេចទៅបានក្នុងរយៈពេលមួយយ៉ាងខ្លីនោះទេ។ ជារួមគោលនយោបាយកាត់បន្ថយភាពក្រីក្រត្រូវបានផ្សព្វផ្សាយ និងបានជ្រួតជ្រាបយ៉ាងទូលំទូលាយរួចមក ហើយទាំងនៅរាជរដ្ឋាភិបាល ទាំងនៅក្រៅរដ្ឋាភិបាល។ ការខ្វះចន្លោះសំខាន់នោះគឺ ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នៃគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងការត្រួតពិនិត្យ និងវាយតម្លៃអំពីលទ្ធផលដែលសម្រេចបាន ឬដែលសម្រេចមិនបានតាមគោលដៅ។ ឯកសារស្តីពីយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ និងសង្កត់ធ្ងន់លើសកម្មភាពជាក់ស្តែង ការជាក់ចេញ និងត្រួតពិនិត្យគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ដែលមានលក្ខណៈសមស្របសាមញ្ញ និងងាយស្រួលកែសម្រួលអោយស្របតាមពេលវេលា និងតាមការចាំបាច់។

រាជរដ្ឋាភិបាលទទួលស្គាល់ថា កំណើនសេដ្ឋកិច្ចខ្ពស់តែមួយមុខអាចនឹងមិនគ្រប់គ្រាន់ ដើម្បីកាត់បន្ថយភាពក្រីក្រអោយបានខ្លាំងក្លាឡើយ ព្រោះដោយសារមានវិសមភាពដ៏ធំធេង ដែលចេះតែកើនឡើងដែលមានការពាក់ព័ន្ធជាមួយនឹងបែបផែននៃកំណើន។ ប្រការនេះធ្វើអោយកំណើនតែមួយមុខមិនអាចកាត់បន្ថយភាពក្រីក្របានឡើយ។ កំណើនសេដ្ឋកិច្ចមានសារៈសំខាន់ណាស់សម្រាប់ការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែល្បឿន និងទំហំដែលវាអាចកាត់បន្ថយភាពក្រីក្រ គឺអាស្រ័យទៅលើសមាសធាតុរបស់វា។ ពលរដ្ឋក្រីក្រកម្ពុជាមានចំនួនច្រើនណាស់ ដែលក្នុងនោះមានរួមបញ្ចូលទាំងបណ្តាជនដែលអាចរស់តាមគេមិនទាន់នៅពេលដែលសេដ្ឋកិច្ចមានការកើនឡើង។ ជនទាំងនោះរួមមាន ជនពិការ មនុស្សចាស់ អ្នកគ្មានដីធ្លី ព្រមទាំងជនគ្មានការងារធ្វើ កសិករគ្មូចតាច និងជាពិសេសប្រជាជនក្រីក្រនៅតាមទីប្រជុំជន។ ការខុសគ្នាខាងភេទ និងអនក្ខរភាព អាចធ្វើអោយជនក្រីក្រជាច្រើនគ្មានលទ្ធភាពរួមចំណែកនៅក្នុងកំណើនសេដ្ឋកិច្ច។ ហេតុនេះហើយ ការកាត់បន្ថយភាពក្រីក្រនៅ

កម្ពុជា អាស្រ័យលើចរិតលក្ខណៈនៃកំណើនដែលក្នុងនោះប្រភេទនៃប្រាក់ចំណូលដែលត្រូវបានទទួលពីកំណើននោះ លទ្ធភាពនៃកំណើនសេដ្ឋកិច្ចក្នុងការបង្កើតការងារ ជាពិសេសការបង្កើតការងារសម្រាប់ក្រុមពលរដ្ឋដែលងាយនឹងទទួលការរងគ្រោះ គឺសុទ្ធតែជាកត្តាដែលមានសារៈសំខាន់យ៉ាងខ្លាំង។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តកម្មវិធីដែលមានគោលដៅផ្តល់ការគាំទ្រ និងការពារជនក្រីក្រដោយផ្ទាល់ ដូចជា កម្មវិធីស្បៀងពលកម្ម ដែលអង្គការ WFP ធ្លាប់បានអនុវត្ត និងការជួយឧបត្ថម្ភជាស្បៀងអាហារ ដែលរាជរដ្ឋាភិបាលតែងតែជួយដល់ជនរងគ្រោះនៅពេលមានសភាពការណ៍បន្ទាន់[២៥]។

គោលនយោបាយភាគច្រើនរបស់រាជរដ្ឋាភិបាល នឹងជះឥទ្ធិពលដល់ជនក្រីក្រនៅកម្ពុជាដោយផ្ទាល់ ឬដោយប្រយោល។ ផ្នែកនេះផ្តោតទៅលើវិស័យដែលមានសារៈសំខាន់បំផុត សម្រាប់ការធ្វើសកម្មភាពដូចដែលបានសង្ខេបនៅក្នុងតារាងខាងក្រោម។ ម្យ៉ាងទៀត ការកៀងគរចំណូល និងទំនាក់ទំនងជាមួយម្ចាស់ជំនួយដែលនឹងត្រូវបានលើកយកមកពិភាក្សានៅចុងបញ្ចប់នៃផ្នែកនេះ ក៏ជាបញ្ហាមានសារៈសំខាន់ណាស់ផងដែរ។ បណ្តាគោលនយោបាយជាអាទិភាពនានានឹងត្រូវបានពិនិត្យឡើងវិញនៅពេលរៀបចំឯកសារពេញលេញស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងក្នុងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទីពីរ។ ម្យ៉ាងរាជរដ្ឋាភិបាល បានដាក់ចេញរួមមកហើយនូវវិធានការកាត់បន្ថយភាពក្រីក្រនៅក្នុងបរិការណ៍នៃកម្មវិធីចំណូល-ចំណាយរយៈពេលមធ្យមនៃថវិកាឆ្នាំ២០០១។

ការផ្សាភ្ជាប់រវាងនិច្ចយកម្មនៃភាពក្រីក្រទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល[២៦]

ទិដ្ឋភាពនៃភាពក្រីក្រ	គោលនយោបាយរបស់រាជរដ្ឋាភិបាល
ការគ្មានកាលានុវត្តភាព	**ការបង្កើនកាលានុវត្តភាព**
-ប្រាក់ចំណូលជាមធ្យមនៅទាប	-ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច
-ភាពក្រីក្រ ជាពិសេសនៅជនបទមានទំហំធំធេង	-កំណើនសេដ្ឋកិច្ច
-ភាពគ្មានដីធ្លី និងការមិនអាចរកដីបាន	-ការលើកស្ទួយការអភិវឌ្ឍន៍ផ្នែកឯកជន
-កុមារីទទួលបានការអប់រំទាប	-ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត រួមទាំងធារាសាស្ត្រ និងផ្លូវលំជនបទ
-ការគ្មានលទ្ធភាពរកទ្រព្យសម្បត្តិ និងទទួលបាននូវបណ្តុះបណ្តាល	-វិធានការក្នុងការជម្រុញការអភិវឌ្ឍន៍វិស័យកសិកម្ម

[២៥] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៤២

[២៦] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៤១

-ការគ្មានហេដ្ឋារចនាសម្ព័ន្ធ	-ការធ្វើកំណែទម្រង់ដីធ្លី
ភាពងាយទទួលរងគ្រោះ -លទ្ធភាពនៅទាបក្នុងការទទួលឥណទាន និងមូលធន -ការខូចខាតផលដំណាំ -អាកាសធាតុប្រែប្រួល -ការរិចរិលបរិស្ថាន -ការកើនឡើងនូវអំពើហិង្សាចំពោះស្ត្រី ការចាប់រំលោភ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ -បញ្ហាសុខភាព និងស្ត្រី ដែលងាយរងគ្រោះដោយសារឆ្លងមេរោគហ៊ីវ/អេដស៍ -បញ្ហាគ្រាប់មីន	**ការពង្រឹងសន្តិសុខ** -គម្រោងមីក្រូហិរញ្ញវត្ថុ -កម្មវិធីសុវត្ថិភាពសង្គម -កិច្ចការពារបរិស្ថាន -ការបង្កើនសេវាសុខាភិបាល -ការដោះមីន -កែលម្អប្រព័ន្ធធារាសាស្ត្រ និងការស្តារប្រព័ន្ធស្រោចស្រព -ការដាំដំណាំចម្រុះ ដើម្បីបង្កើនស្ថេរភាពដីវិសាស្ត្រ និងប្រសិទ្ធភាពសេដ្ឋកិច្ច
សមត្ថភាពទាប -ផលិតផការងារមានកម្រិតទាប -ទឹកមិនស្អាតនិងការខ្វះអនាម័យ -ចំណាយលើការព្យាបាលខ្ពស់	**ការពង្រឹងសមត្ថភាព** -ការផ្តល់សេវា -ការបង្កើនចំណាយសាធារណៈលើវិស័យសុខាភិបាល អប់រំ កសិកម្ម និងអភិវឌ្ឍន៍ជនបទ
ការស្ថិតនៅក្រៅសង្គម -អនក្ខរកម្ម -ការមិនអាចចូលរួមក្នុងការសម្រេចចិត្ត -អំពើពុករលួយ -ការរើសអើងដោយឈរលើមូលដ្ឋានភេទ និងជាតិសាសន៍ -ស្ត្រីដែលមានតួនាទីសម្រេចនៅមានចំនួនតិចតួច -ស្ត្រីមានបន្ទុកដ៏ធ្ងន់ធ្ងរក្នុងការងារផ្ទះ ចិញ្ចឹម និងថែរក្សាកូន អ្នកជំងឺ និងមនុស្សចាស់ជរា។	**ការផ្តល់អំណាច** -កំណែទម្រង់តុលាការ -គោលនយោបាយអប់រំ -ការបង្កើតលក្ខខ័ណ្ឌអនុគ្រោះសម្រាប់អង្គការក្រៅរដ្ឋាភិបាល -អភិបាលកិច្ច និងវិធានការប្រឆាំងអំពើពុករលួយ -វិមជ្ឈការ

ហានិភ័យពីខាងក្រៅសំខាន់ ដែលប៉ះពាល់ដល់ភាពក្រីក្រ គឺកលយុគហិរញ្ញវត្ថុដែលធ្វើអោយស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានអស្ថេរភាព និងគ្រោះធម្មជាតិនានា។ គ្រោះទឹកជំនន់នៅក្នុងឆ្នាំ២០០០ បានធ្វើអោយប៉ះពាល់ដល់គោលដៅនៃកំណើនសេដ្ឋកិច្ច និងការខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ ដូច្នេះ បញ្ហាជាអាទិភាពចំពោះមុខ គឺត្រូវបង្វែរធនធានដើម្បីស្តារហេដ្ឋារចនាសម្ព័ន្ធ ដែលខូចខាតដោយសារទឹកជំនន់។ យ៉ាងណាក៏ដោយ គ្រោះធម្មជាតិនេះ មិនបង្ករផលប៉ះពាល់ជាដុំកំភួនចំពោះកម្មវិធីកំណែទម្រង់យ៉ាងធំទូលាយ និងស៊ីជម្រៅប្រកបដោយមហិច្ឆតា ដែលរាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្តនោះឡើយ។ រាជរដ្ឋាភិបាលនឹងប្រកាន់យកវិធានការចំបាច់សព្វបែបយ៉ាង ដើម្បីជម្រុញល្បឿននៃកំណែទម្រង់អោយកាន់តែមានប្រសិទ្ធភាពឡើងថែមទៀត។ ទន្ទឹមនឹងនេះ ហានិភ័យក្នុងប្រទេសសំខាន់ គឺសមត្ថភាពស្ថាប័ន និងរដ្ឋបាលនៅមានកម្រិត ការិយាល័យនិយម ស្ថេរភាពនយោបាយ ដែលនៅផុយស្រួយ និងប្រព័ន្ធថវិកា និងហិរញ្ញវត្ថុ ដែលមិនទាន់រឹងមាំនៅឡើយ។ ដូច្នេះ នេះបញ្ហាប្រឈមក្នុងការសម្របសម្រួលដំណើរការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងសមត្ថភាពស្ថាប័នដែលមានកម្រិតនឹងបង្កើតឡើងជាហានិភ័យដ៏សំខាន់។ ម្យ៉ាងទៀត ការកែលម្អ និងការបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តន៍ថវិកាជាពិសេស ក្នុងការអនុវត្តន៍ចំណាយសាធារណៈលើវិស័យជាអាទិភាពមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាអោយបាននូវការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រអោយបានជោគជ័យ។

២.៣.២ ការបង្កើតភាណឌុភត្តភាព

យុទ្ធសាស្ត្រនាពេលបច្ចុប្បន្ននេះ ក្នុងការបង្កើតភាណឌុភត្តភាព គឺមានដូចតទៅ: ការពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការពន្លឿនកំណើនសេដ្ឋកិច្ច ការជម្រុញការអភិវឌ្ឍន៍វិស័យឯកជន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងផ្នែកថាមពល ការធានានូវការអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវវិស័យសិកម្ម ការកែលម្អការគ្រប់គ្រងធនធានទឹក ការជម្រុញការអភិវឌ្ឍន៍ជនបទ និងវិមជ្ឈការ ការធានានូវការគ្រប់គ្រងធនធានធម្មជាតិអោយបានល្អ ការលើកទឹកចិត្តបណ្តាលសកម្មភាពដែលបង្កើតប្រាក់ចំណូល ការអនុវត្តន៍គោលនយោបាយជីធ្លី និងការបង្កើនសេវាមីក្រូហិរញ្ញវត្ថុសម្រាប់ប្រជាជនក្រីក្រ។ ទោះបីជាបណ្តាកម្មវិធីដែលមានគោលដៅច្បាស់លាស់សម្រាប់តំបន់ជនបទអាចអោយផលយ៉ាងឆាប់រហ័ស ចំពោះប្រជាជននៅជនបទ ក៏ដោយយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រក៏ត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការអភិវឌ្ឍន៍នៃវិស័យឧស្សាហកម្ម និងសេវាកម្មផងដែរ។ យុទ្ធសាស្ត្ររបស់យើង គឺមិនត្រឹមតែធ្វើទំនើបការបូនីយកម្មនៃវិស័យកសិកម្មប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវជម្រុញការអភិវឌ្ឍន៍វិស័យដទៃទៀត ដែលអាចក្លាយទៅជាក្បាលរទេះភ្លើងដ៏មានថាមពល ដើម្បីអូសទាញកម្ពុជាពីច្រវាក់ខ្នោះឃ្នងនៃភាពក្រីក្រតោកយ៉ាកនេះ[២៧]។

[២៧] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៤៣

ចំណែកនៃវិស័យឧស្សាហកម្មនៅក្នុង ផសស ត្រូវបានរំពឹងថានឹងកើនឡើងពី ២០% ក្នុងឆ្នាំ១៩៩៩ ដល់ប្រមាណ ២២,៦% ក្នុងឆ្នាំ២០០៣ ក៏ប៉ុន្តែចំណែកនៃវិស័យកសិកម្មនឹងធ្លាក់ចុះពី ៣៦,៩% រហូតដល់ ៣២,២%។ សេវាកម្មនឹងរក្សាបាននូវកំណើនថេរ ពី ៤៣,១% ដល់ ៤៥,២%។ រាជរដ្ឋាភិបាលបានអនុម័តនូវ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មដូចតទៅ: ឧស្សាហកម្មសម្រាប់បម្រើអោយការនាំចេញ ដែលផ្អែក លើធនធានធម្មជាតិដែលមានលក្ខណៈអតិពលកម្ម និងដែលទាក់ទងនឹងវិស័យទេសចរណ៍។ ដោយចាប់ផ្តើម ដំណើរការពីការបង្កើតផលិតផលអតិពលកម្ម ដើម្បីនាំចេញដូចជា សំលៀកបំពាក់វាយនភ័ណ្ឌឧស្សាហកម្មកម្ពុជា អាចឈានជាបណ្តើរៗឆ្ពោះទៅរកសកម្មភាពដែលទំនើប និងទាន់សម័យខាងបច្ចេកវិទ្យានិងអតិមូលធនកាន់តែ ច្រើនឡើងៗ។ សំខាន់ជាងនេះទៅទៀតគឺ ត្រូវតែអភិវឌ្ឍន៍ ឧស្សាហកម្មដោយឈរលើឧត្តមភាព ប្រៀបធៀប របស់ប្រទេសដោយជម្រុញវិស័យឧស្សាហកម្ម ដែលផ្អែកលើធនធានធម្មជាតិ នៃប្រភេទផ្សេងៗគ្នា រួមមានកសិ-ពាណិជ្ជកម្ម ឧស្សាហកម្មដោយប្រើប្រាស់ផលិតផលព្រៃឈើ និងផលិតផលជលផលជាមូលដ្ឋាន។ សហគ្រាស ធុនតូច និងមធ្យម ដូចជា ម៉ាស៊ីកិនស្រូវ និងការគ្រប់គ្រងក្រោយពេលច្រូតកាត់ ការកែច្នៃ ម្ហូបអាហារ ផលិតផល ចំណីសត្វផលិតផលគ្រឿងសង្ហារឹម ផលិតកម្មឥដ្ឋ និងក្បឿង គឺជាប្រភពដ៏សំខាន់នៃការបង្កើនចំណូលសម្រាប់ ជនក្រីក្រ។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍន៍សហគ្រាសតូចៗ និងផ្នែកក្រៅផ្លូវការ ដែលវិមាត្រតូចមានសក្តានុពល ដើម្បីស្រូបយកចំនួន នៃពលរដ្ឋក្រី ដែលចេះតែកើនឡើងជាប្រចាំ។

ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ មកឧស្សាហកម្មសំលៀកបំពាក់បានរក្សានៅអត្រាកំណើន ដ៏ខ្ពស់បង្កើតបាននូវការងារសម្រាប់កម្មករ កម្មការិនីរាប់សែននាក់ ដែលភាគច្រើនក្នុងចំណោមនោះ គឺជាអ្នកមក ពីតំបន់ជនបទ។ ចំពោះបញ្ហានេះ រាជរដ្ឋាភិបាលបានធ្វើអោយមានការចម្រើនគួរអោយកត់សម្គាល់នៅក្នុងការ លើកម្ពស់សិទ្ធិការងារ ដែលមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការផ្តល់អំណាច។ ទាំងនេះរួមបញ្ចូលនូវការអនុម័តច្បាប់ការងារឆ្នាំ១៩៩៧ ដែលមានសង្គមភាពជាមួយនិយាមអន្តរជាតិ សេចក្តី សម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទទួលយកលក្ខខ័ណ្ឌគោរពសិទ្ធិការងារនៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពី វាយនភ័ណ្ឌជាមួយសហរដ្ឋអាមេរិក និងការកែលម្អជាបណ្តើរៗនូវលិខិតបទដ្ឋាននានាជាទៃទៀត។ ក៏ប៉ុន្តែផ្នែក ឧស្សាហកម្ម និងផលិតកម្មកម្មន្តសាល ជាពិសេសសំលៀកបំពាក់កាលពីពេលថ្មីៗនេះ មានការកើនឡើង យឺត ជាងបណ្តាឆ្នាំមុនៗ។ ដូច្នេះហើយ ទើបរាជរដ្ឋាភិបាលបានសម្រេចធ្វើការសិក្សាអំពីបទពិសោធន៍នៃបណ្តា ប្រទេសជិតខាង។ ក្នុងការពង្រឹងគ្រឹះសម្រាប់កំណើនឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការ អភិវឌ្ឍន៍ នៃឧស្សាហកម្មអេឡិចត្រូនិច និងប្រដាប់ប្រដារក្មេងលេង ឧស្សាហកម្មអតិពលកម្ម ដែលកម្ពុជាមាន ឧត្តមភាពប្រៀបធៀបនៅក្នុងផ្នែកទាំងអស់នេះ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល គឺផ្តោតការ យកចិត្តទុកដាក់ទៅលើការវិនិយោគធុនធ្ងន់នៅក្នុងការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខណៈដែលមាន ការខិតខំ ដើម្បីធានានូវបរិស្ថានដ៏ត្រឹមត្រូវមួយសម្រាប់ការវិនិយោគទុកផ្នាល់ពីបរទេស និងការវិនិយោគក្នុងស្រុក។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍន៍ប៉ូលនៃកំណើនដោយការភ្ជាប់ពីភ្នំពេញ(មជ្ឈមណ្ឌលឧស្សាហកម្ម

និងហិរញ្ញវត្ថុ) ទៅសៀមរាប(ឧស្សាហកម្មទេសរណ៍) ក្រុងព្រះសីហនុ(តំបន់កែច្នៃនាំចេញ) និងកំពង់ចាម (កសិ-ពាណិជ្ជកម្ម) និងបង្កើតតំបន់អភិវឌ្ឍន៍ពិសេសនៅតាមតំបន់ព្រំដែន។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដើម្បីទាញយកផលយោជន៍ពីការផ្លូចផ្តើមគំនិត ខាងផ្នែកសេដ្ឋកិច្ចផ្សេងៗ ក្នុងក្របខ័ណ្ឌអាស៊ានដែលរួមានជាអាទិ៍ គម្រោងការផ្នែកសហប្រតិបត្តិការ និងឧស្សាហកម្មអាស៊ាន(AICO)[២៨] តំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA) និងតំបន់វិនិយោគអាស៊ាន(AIA) និងដើម្បីទាក់ទាញយកផលចំណេញក្នុងខណៈដែលប្រទេសមួយចំនួន ក្នុងតំបន់បានបាត់បង់នៅឋានៈនៃ "ប្រព័ន្ធអនុគ្រោះទូទៅ" (GSP) និង "ប្រជាជន ដែលទទួលបានការអនុគ្រោះបំផុត" (MFN)[២៩]។

ក-ពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច

យុទ្ធសាស្ត្រជាបឋម គឺការបន្ត និងជម្រុញពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្នគួបផ្សំជាមួយនឹងការបើកចំហរសេដ្ឋកិច្ច និងការតម្រង់ទិសទៅរកទីផ្សារ។ កម្ពុជាត្រូវការបន្តដំណើររបស់ខ្លួនក្នុងការធ្វើសមាហរណកម្មស៊ីជម្រៅជាមួយនឹងសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក និងបន្តមាគ៌ាសេដ្ឋកិច្ចដែលផ្តោតទៅលើការពង្រីកទំនាក់ទំនងជាមួយក្រៅប្រទេស ព្រមទាំងបន្តអនុវត្តគោលនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលឈរលើលើមូលដ្ឋានទីផ្សារ។ ក្នុងន័យនេះដែរ រាជរដ្ឋាភិបាលនឹងបន្តជម្រុញអនុវត្តនូវគោលនយោបាយអត្រាប្តូរប្រាក់ ដែលផ្អែកលើទីផ្សារ និងប្រព័ន្ធអត្រាប្តូរប្រាក់សេរី។ យើងនឹងបន្តការកែទម្រង់ពាណិជ្ជកម្មនៅក្នុងបរិការណ៍នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ផងដែរ។ រាជរដ្ឋាភិបាលផ្តោតកិច្ចខិតខំប្រឹងប្រែងជាសំខាន់លើការពង្រឹងស្ថាប័ន ដើម្បីធានាបរិស្ថានម៉ាក្រូសេដ្ឋកិច្ចមួយ ដែលមានស្ថេរភាពក្នុងគោលដៅបង្កើតកំណើនសេដ្ឋកិច្ច។

គោលដៅសេដ្ឋកិច្ចរបស់ខ្លួន រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនកំណើនសេដ្ឋកិច្ចពី ៦ ទៅ ៧% ក្នុងរយៈពេលមធ្យម ដោយរក្សាអតិផរណាក្នុងកម្រិតក្រោម ៤% រក្សាឱនភាពគណនីចរន្តក្រៅប្រទេសក្នុងកម្រិតមួយដែលមានចីរភាព និងទៅលើការគ្រប់គ្រងដោយហ្មត់ចត់នូវបំណុលក្រៅប្រទេស។ ដើម្បីសម្រេចអោយបាននូវគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តកំណែទម្រង់សារពើពន្ធជាមូលដ្ឋាន ដែលសំដៅបង្កើនចំណូល និងកែលម្អបែបផែន និងប្រសិទ្ធភាពនៃចំណាយថវិកា។ ចំណុចសំខាន់ៗនៃកម្មវិធីកែទម្រង់រចនាសម្ព័ន្ធ គឺពង្រឹងការគ្រប់គ្រងធនធានសាធារណៈ និងព្រៃឈើ កែលម្អរដ្ឋបាលពន្ធដារ អនុវត្តកំណែទម្រង់ រដ្ឋបាល និងយោធាជំរុញការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការអភិវឌ្ឍន៍ផ្នែកឯកជន និងកំណែទម្រង់ពាណិជ្ជកម្ម។ រាជរដ្ឋាភិបាល មានការប្តេជ្ញាចិត្តក្នុងការពិនិត្យឡើងវិញនូវក្របខ័ណ្ឌគោលនយោបាយសារពើពន្ធក្នុងគោលដៅបង្កើន

---

[២៨] AICO- ASEAN Industrial Cooperation Scheme

[២៩] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៤៤

ចំណូលថវិកាពង្រឹងការប្រមូលពន្ធ និងធានាបាននូវសមធម៌ និងលុបបំបាត់នូវឧបសគ្គ ដែលបន្ទុចបង្អាក់ការ វិនិយោគឯកជន។ ប្រការនេះទាមទារអោយមានការអភិវឌ្ឍន៍នូវក្របខ័ណ្ឌពន្ធជាមួយដ៏ទំនើប និងនីតិវិធីប្រកបដោយតម្លាភាពសម្រាប់គ្រប់គ្រងការធ្វើសម្បទានធនធានធម្មជាតិ ដោយរួមមាន ការជីកយករ៉ែប្រេងកាត និងការធ្វើអាជីវកម្មព្រៃឈើ ដើម្បីកែលម្អ និងធានបាននូវការប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាព និងចីរភាព និងបង្កើនចំណូលថវិកា។

ឯកជនភាវូបនីយកម្ម និងការកែលម្អកិច្ចដំណើរការរបស់អង្គការសេវាសាធារណៈរបស់រដ្ឋ គឺជាអាទិភាពដ៏ចម្បងមួយ។ ទន្ទឹមនឹងនេះ ចាំបាច់ត្រូវធ្វើការកែទម្រង់សហគ្រាសសាធារណៈបន្ថែមទៀត ដើម្បីបង្កើនផលិតភាព និងសម្រួលដល់ការទាក់ទាញមូលធនក្នុងស្រុក និងមូលធនពីបរទេស។ ការអនុវត្តន៍នូវគោលការណ៍ស្វ័យ-កិបាលហិរញ្ញវត្ថុ នៃអង្គភាពសេវាកម្មសាធារណៈរបស់រដ្ឋ ដែលនៅសេសសល់នឹងជួយទាក់ទាញការវិនិយោគ និងជួយជំរុញអោយទីផ្សារមានដំណើរការប្រកបដោយប្រសិទ្ធភាព។ ការកែលម្អកិច្ចដំណើរការនៃប្រព័ន្ធធនាគារពាណិជ្ជកម្មមានសារៈសំខាន់ណាស់នៅក្នុងការបង្កើតនូវបរិស្ថានអំណោយផលដល់កំណើន ដែលនាំមុខដោយវិស័យឯកជន ហើយដែលក្នុងនោះការវិនិយោគទុកផ្នាល់ពីបរទេសមានតួនាទីឈានមុខគេ។ ម្យ៉ាងវិញទៀត ការកេតម្រូវចនាសម្ព័ន្ធធនាគារនៅក្នុងបរិការណ៍ នៃច្បាប់ថ្មីស្តីពីស្ថាប័នហិរញ្ញវត្ថុ និងធនាគារ គឺជាចំណែកដ៏សំខាន់នៃកិច្ចប្រឹងប្រែងនេះ។

ខ-ការពន្លឿនកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចមានសារៈសំខាន់បំផុតចំពោះការកាត់បន្ថយភាពក្រីក្រ ព្រោះវាផ្តល់នូវកាលានុវត្តភាពក្នុងការបង្កើតចំណូល និងធនធានដើម្បីជាទុកសម្រាប់ផ្តល់ហិរញ្ញប្បទាន ដល់យន្តការកាត់បន្ថយភាពកក្រីក្រអោយបានឆាប់រហ័ស។ ការបន្តអនុវត្តកម្មវិធីកំណែទម្រង់បច្ចុប្បន្ន នឹងជួយបង្កើតលក្ខខ័ណ្ឌសម្រាប់បង្កើនប្រាក់សន្សំក្នុងស្រុក និងបង្កើនសកម្មភាពវិនិយោគឯកជនក្នុងស្រុក និងពីបរទេស ដើម្បីសម្រេចបាននូវគោលដៅនៃកំណើន ៧% ក្នុងទសវត្សខាងមុខ។ ប្រការនេះទាមទារអោយមានការរក្សានូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការបន្តកំណែទម្រងទីផ្សារ និងការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ច ដែលតម្រង់ទិសឆ្ពោះទៅខាងក្រៅប្រទេស។ វាក៏ទាមទារផងដែរនូវការអភិវឌ្ឍន៍ស្ថាប័នសេដ្ឋកិច្ចសង្គម និងនយោបាយអោយបានកាន់តែខ្លាំងក្លាឡើង ដើម្បីទទួលបាននូវអភិបាលកិច្ចល្អថែមទៀតនៅកម្ពុជា។ បើតាមស្ថិតិនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ១៩៩៩ ប្រសិនបើយើងសម្រេចបានអត្រាកំណើនពី ៦ ទៅ %ក្នុងមួយឆ្នាំ និងប្រសិនបើកំណើននោះត្រូវបានបែងចែកដោយសមធម៌នៅក្នុងចំណោមអ្នកក្រីក្រនោះ យើងត្រូវការពេលមិនដល់ប្រាំឆ្នាំឡើយ សម្រាប់ទាញជនក្រីក្រជាមធ្យមអោយចាក់ផុតពីភាពក្រីក្រយោកយ៉ាក។ ប៉ុន្តែដើម្បីអោយជីវិតពលរដ្ឋក្រីក្របំផុតមានភាពប្រសើរឡើង យើងត្រូវការលើសពីកំណើនទៅទៀត។ ពេលវេលាដែលត្រូវការ ដើម្បីអោយប្រជាជនក្រីក្របំផុត ដែលស្ថិតនៅក្រោមបន្ទាត់ក្រីក្រស្បៀងអាហារចាកចេញបានពីភាពក្រីក្របាន គឺមានរយៈពេលលើសពី ១៥ឆ្នាំ ប្រសិនបើយើងសម្រេច

បាននូវកំណើនក្នុងអត្រា ៣% ក្នុងមួយឆ្នាំជាបន្តបន្ទាប់។ ដូច្នេះ យើងត្រូវការដាក់ចេញនូវកម្មវិធីដែលមានគោលដៅច្បាស់លាស់ ដើម្បីផ្តល់ផលចំណេញអោយជនក្រីក្រនៅក្នុងទម្រង់នៃការពង្រឹងធនធានមនុស្ស និងធនធានរូបវន្ត តាមរយៈការធ្វើអន្តរាគមន៍ផ្សេងៗ(ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ទីផ្សារ) ដែលជួយបង្កើនផលចំណូលដែលគេទទួលបានពីធនធានទាំងនោះ[៣០]។

ជាមួយនឹងកំណើនដែលឈរលើមូលដ្ឋានដ៏ទូលំទូលាយ យើងក៏ត្រូវចាត់វិធានការផងដែរ ដើម្បីផ្តល់អោយបានច្រើននូវឥណទាន ការអប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងទឹកស្អាត និងអនាម័យដល់ជនក្រីក្រ។ រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែង ដើម្បីសម្រួលអោយពលរដ្ឋក្រីក្រអាចធ្វើដំណើរយ៉ាងងាយស្រួលទៅកាន់ទីផ្សារតាមរយៈការកសាងផ្លូវលំជនបទ ការផ្តល់ព័ត៌មាន និងការអភិវឌ្ឍន៍ទីផ្សារជនបទ។ ម្យ៉ាងវិញទៀត ក៏មានការយកចិត្តទុកដាក់ជួយដល់ផលិតកររអោយទទួលបាននូវផលចំណេញពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនថែមទៀតផង។ ម្ចាស់ជំនួយភាគច្រើនក៏បានសង្កត់ធ្ងន់ទៅលើអភិបាលកិច្ចអោយកាន់តែល្អ ដើម្បីអោយរដ្ឋអាចឆ្លើយតបបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាពចំពោះតម្រូវការរបស់ពលរដ្ឋក្រីក្រ ក៏ដូចជាការធ្វើវិមជ្ឈការនៃអំណាច និងធនធានពីរាជរដ្ឋាភិបាលកណ្តាលទៅដល់ស្ថាប័នមូលដ្ឋាន និងខេត្ត/ក្រុង ដើម្បីសម្រួលដល់ការរួមចំណែកនៃពលរដ្ឋក្រីក្រនៅក្នុងការធ្វើសេចក្តីសម្រេចនានា[៣១]។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ដែលគ្រោងនឹងធ្វើឡើងនាពេលខាងមុខ និងការបង្កើតឡើងនៃក្រុមប្រឹក្សាឃុំ/សង្កាត់ នឹងជួយដល់ការអភិវឌ្ឍន៍ស្ថាប័នមូលដ្ឋាន និងលើកស្ទួយលទ្ធិប្រជាធិបតេយ្យមូលដ្ឋាន ដែលបង្គប់នូវសក្តានុពលភាពយ៉ាងធំ សម្រាប់ការរួមចំណែកកាត់បន្ថយភាពក្រីក្រអោយបានកាន់តែលឿន។

គ-សម្រួលដល់ការអភិវឌ្ឍន៍ផ្នែកឯកជន

រាជរដ្ឋាភិបាល មានកាតព្វកិច្ចក្នុងការអភិវឌ្ឍន៍ និងពង្រឹងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ និងសមត្ថភាពស្ថាប័នដែលសម្រួលដល់សកម្មភាពធុរៈកិច្ច និងការវិនិយោគឯកជននៅកម្ពុជា។ រាជរដ្ឋាភិបាល ចាត់ទុកវិស័យឯកជនជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។ វិស័យឯកជន ដែលមានការលូតលាស់ល្អអាចបំពេញតួនាទីជំនួសការវិនិយោគសាធារណៈ នៅក្នុងវិស័យសង្គមកិច្ច តាមរយៈការស្រូបយកកម្លាំងពលកម្មដ៏លើសលប់នៃវិស័យសាធារណៈ និងការផ្តល់នូវធនធានចាំបាច់ ដើម្បីស្រូបយកតម្រូវការងារដែលចេះតែកើនឡើង។ ប៉ុន្តែការអភិវឌ្ឍន៍វិស័យឯកជនត្រូវបានជួបការលំបាក ដោយសារកង្វះខាតនូវច្បាប់ ស្ថាប័ន និយ័តកម្ម និងប្រភពហិរញ្ញប្បទាន ដែលនៅមានកម្រិត។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងកែលម្អនូវបរិយាកាសសម្រាប់

---

[៣០] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបម្រុងស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៤៦

[៣១] ឧទាហរណ៍នៃកុងសង់ស៊ុសរបស់ម្ចាស់ជំនួយក្នុងបញ្ហានេះ គឺជាយុទ្ធសាស្ត្រសម្រាប់កិច្ចប្រតិបត្តិការនៅកម្ពុជារបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងឆ្នាំ២០០០ និងយុទ្ធសាស្ត្រក្នុងការផ្តល់ជំនួយអោយកម្ពុជារបស់ធនាគារពិភពលោកឆ្នាំ២០០០។

ធុរៈកិច្ចដោយជានាអោយបាននូវប្រព្រឹត្តកម្មស្មើភាពមួយសម្រាប់វិស័យឯកជន រួមមានការធ្វើអោយស៊ីសង្វាក់គ្នារវាងបណ្តាច្បាប់ និងលិខិតបទដ្ឋាន ការអនុម័តក្រមពាណិជ្ជកម្មដ៏ទូលំទូលាយមួយ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ ការរក្សាភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងការបង្កើនគុណភាពនៃប្រព័ន្ធតុលាការ។ ក្នុងន័យនេះ ច្បាប់មួយចំនួននៃក្រមពាណិជ្ជកម្មថ្មី ត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីរួចហើយ ដើម្បីពិនិត្យ និងសម្រេច។

រាជរដ្ឋាភិបាលមានគោលដៅ កែលម្អបរិយាកាសសម្រាប់ធុរៈកិច្ច និងការរៀបចំនូវបរិស្ថានមួយ ដែលអំណោយផលដល់ការអភិវឌ្ឍន៍ផ្នែកឯកជន ដែលជាកត្តាដែលមិនអាចខ្វះបានសម្រាប់កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការសម្រេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព។ វេទិការាជរដ្ឋាភិបាលផ្នែកឯកជនត្រូវបានរៀបចំក្នុងរយៈពេលប្រាំមួយខែម្តង ដើម្បីពិនិត្យមើលនូវការលំបាកនានា ដែលផ្នែកឯកជនកំពុងជួយប្រទះ និងលុបបំបាត់នូវឧបសគ្គដែលរារាំងវិនិយោគឯកជន។ នៅពេលប្រជុំចុងក្រោយដែលប្រព្រឹត្តទៅនៅក្នុងខែកក្កដា ឆ្នាំ២០០០ នេះសម្តេចនាយករដ្ឋមន្ត្រីបានសម្រេចអោយបង្កើតនូវក្រុមការងារចម្រុះ ដើម្បីដាក់ចេញនូវវិធានការកែលម្អបរិយាកាសធុរៈកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បញ្ហាប្រឈមនៃការអភិវឌ្ឍន៍ផ្នែកឯកជននៅកម្ពុជា គឺហេដ្ឋារចនាសម្ព័ន្ធមិនទាន់លូតលាស់ល្អ បញ្ហាសន្តិសុខ សម្រាប់វិនិយោគិននៅទីចុងកាត់មាត់ញក ភាពចន្លោះប្រហោងនៃប្រព័ន្ធគតិយុត្ត ការប្រាក់ខ្ពស់ការលំបាករកឥណទាន ការបង្វិលទុកមានការលំបាកបើក្រុមហ៊ុនទៅខ្វីពីធនាគារ គេអោយខ្វីតែ ៣០%ទេ ហើយទាល់តែមានប្លង់អចនទ្រព្យដាក់ធានាទើបធនាគារផ្តល់លុយអោយខ្វី ព័ត៌មានមិនគ្រប់គ្រាន់ស្តីពីតម្រូវការលើទីផ្សារ កង្វះខាតពលករមានជំនាញ និងអ្នកគ្រប់គ្រងដែលមានជំនាញខ្ពស់។ កង្វះខាត និង/ឬគុណភាពផ្លូវមិនសូវល្អ ដែលរារាំងដល់ច្រកចូលទីផ្សារ និងវត្ថុធាតុដើមគុណភាពនៃកំពង់ផែ ការផ្គត់ផ្គង់ចរន្តអគ្គីសនី និងទឹកអោយបានទៀងទាត់នៅតាមខេត្ត គឺជាបញ្ហាដែលសហគ្រិននានាបានលើកឡើង។ បញ្ហាសន្តិសុខផ្ទាល់ខ្លួននៅក្នុងទីជនបទ គឺជាកត្តាមួយដែលរារាំងធុរៈជនទាំងក្នុងស្រុក ទាំងមកពីបរទេសមិនអោយពង្រីកវិនិយោគរបស់គេឆ្ងាយពីក្រុងភ្នំពេញ។ សហគ្រាសតូច និងមធ្យមបានលើកឡើងនូវចន្លោះប្រហោងនៃបទបញ្ញត្តិស្តីពីការកាន់កាប់ដី ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍ធុរៈកិច្ចធុនតូច។

ឃ-ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ

ការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច គឺជាគោលនយោបាយមួយទៀត ដែលអាចកាត់បន្ថយរបាំងដែលរារាំងពលរដ្ឋក្រីក្រមិនអោយចូលរួមក្នុងវិស័យសេដ្ឋកិច្ចបាន។ ហេដ្ឋារចនាសម្ព័ន្ធមិនត្រឹមតែជះឥទ្ធិពលដល់បែបផែននៃកំណើនប៉ុណ្ណោះទេក៏ប៉ុន្តែការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ នឹងធ្វើអោយស្ថានភាពក្រីក្រកាន់តែមានកម្រិតធ្ងន់ធ្ងរឡើងថែមទៀត ពីព្រោះវារារាំងខ្ទប់មិនអោយពលរដ្ឋក្រីក្រទទួលបាននូវសេវាសុខភាព ការអប់រំ ហើយថែមទាំងបង្កើនបន្ទុកការងាររបស់ស្ត្រីទៀតផង។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមានសារៈ

សំខាន់ខ្លាំងណាស់នៅក្នុងបរិការណ៍នៃការបន្តការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដោយវាបង្កើតលក្ខណៈអោយពលរដ្ឋក្រីក្រមានលទ្ធភាពចូលទៅកាន់ទីផ្សារបានតែងាយស្រួល ដោយសារមានផ្លូវគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ទំនិញ។ ការកែលម្អហេដ្ឋានរចនាសម្ព័ន្ធគួបផ្សំនឹងការធានាអោយពលរដ្ឋក្រីក្រទទួលបានឥណទាន សេវាអប់រំ និងសុខភាព និងធានាថា ការអនុវត្តន៍គោលនយោបាយទីផ្សារបើកចំហរ និងមិនជួបឧបសគ្គដែលបណ្តាលមកពីពលរដ្ឋក្រីក្រ មិនបានចូលរួមចំណែកនៅក្នុងដំណើរការនៃការអភិវឌ្ឍន៍នោះឡើយ។ អាទិភាពជាគន្លឹះក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធរួមានការបង្កើតវិស័យថាមពលប្រកបដោយប្រសិទ្ធភាព អគ្គីសនីភាវូបនីយកម្មនៅជនបទ ការជួសជុល និងថែរក្សាប្រព័ន្ធផ្លូវថ្នល់ការកែលម្អ ការផ្គត់ផ្គង់ទឹក និងអនាម័យ ការពង្រឹងប្រព័ន្ធទូរគមនាគមន៍ ការបង្កើតឡើងនូវផែនការមេសម្រាប់ខេត្ត/ក្រុង ការរៀបចំផែនទីភូមិសាស្ត្ររដ្ឋបាលតាមជំនាញ និងការកសាងលំនៅឋាននៅទីជនបទ។ ហេដ្ឋារចនាសម្ព័ន្ធកសិកម្មដូចជា ផ្លូវ ប្រព័ន្ធជាវាសាស្ត្រ និងការរកទីផ្សារ ក៏មានសារៈសំខាន់ដែរក្នុងការកាត់បន្ថយភាពក្រីក្រ។ ការកសាងសមត្ថភាព ដើម្បីកែលម្អសេវាគាំទ្រ និងការងារកសិកម្មសំខាន់ៗដូចជា ការស្រាវជ្រាវបច្ចេកទេសកសិកម្ម ការរៀបចំផែនការត្រួតពិនិត្យ និងវាយតម្លៃលើគោលនយោបាយ ការផ្តល់ជាតុចូលកសិកម្ម និងការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងខាងកសិកម្មទៅអោយកសិករត្រូវតែបានអនុវត្តអោយស្របគ្នាជាមួយនឹងការអភិវឌ្ឍន៍នៃផ្នែកហេដ្ឋារចនាសម្ព័ន្ធ។

ខ-ការពង្រឹងវិស័យថាមពល

យោងតាមទិន្នន័យនៃការធ្វើអង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងឆ្នាំ១៩៩៩ គ្រួសារប្រហែល ១៧% មានអគ្គីសនីប្រើប្រាស់។ នៅតំបន់ជនបទ មានតែគ្រួសារ ២%ប៉ុណ្ណោះ មានអគ្គីសនីរដ្ឋប្រើប្រាស់ក្នុងខណៈដែល ៥.៤%ទៀតប្រើប្រាស់អគ្គីសនីឯកជន។ កង្វះអគ្គីសនីបានធ្វើអោយគុណភាពនៃការអប់រំ និងការថែរក្សាសុខភាពនៅទីជនបទធ្លាក់ចុះ ដែលជាមូលហេតុធ្វើអោយស្ថានភាពក្រីក្រនៅតំបន់ជនបទនៅតែបន្តមានអត្ថិភាពទៅទៀត។ ដូច្នេះ អគ្គីសនីភាវូបនីយកម្មនៅតំបន់ជនបទនឹងមិនត្រឹមតែអាចកែលម្អសេវាសង្គមសម្រាប់បម្រើអោយពលរដ្ឋក្រីក្រនៅក្នុងរយៈពេលមធ្យម និងវែងប៉ុណ្ណោះទេ តែថែមទាំងនឹងលើកស្ទួយផលិតភាពការងារនៅក្នុងវិស័យកសិកម្មទៀតផង។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៃការអភិវឌ្ឍន៍វិស័យថាមពលដ៏រឹងមាំនៅកម្ពុជា គឺជាការចំណាយខ្ពស់ក្នុងការផលិតថាមពលអគ្គីសនី។ ការកសាងស្ថានីយ៍វារីអគ្គីសនី ទោះបីជាអាចបណ្តាលអោយមានការរិចរិលបរិស្ថានក៏ដោយ តែវាអាចនឹងជួយដោះស្រាយបញ្ហាប្រឈមទាំងនោះបាន។ ក៏ប៉ុន្តែប្រទេសអ្នកផ្តល់ជំនួយមានទិន្នាការផ្តល់អាទិភាពដល់វិស័យដទៃទៀត ដែលអាចផ្តល់ផលភ្លាមៗដល់ជីវភាពរបស់ពលរដ្ឋ។ នាចុងខែធ្នូ ឆ្នាំ២០០០ រដ្ឋសភាជាតិនឹងអនុម័តច្បាប់អគ្គីសនី ដែលនឹងដាក់ចេញនូវក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងវិស័យថាមពល។

ច-ការជម្រុញការអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយចីរភាព

ដោយសារ ៤៥% នៃប្រជាជនរស់នៅក្នុងសហគមន៍ជនបទ និង ៧៥% នៃពលរដ្ឋក្រីក្រ គឺជាគ្រួសារដែលមានមេគ្រួសាជាកសិករ គន្លឹះសម្រាប់បង្កើនកំណើតសេដ្ឋកិច្ចប្រកបដោយចីរភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជនបទ គឺពន្លឿនការអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយចីរភាព។ សក្តានុពលនៃកំណើនកសិកម្មអាចសម្រេចបានតាមរយៈ : ១-ពន្លឿនការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ឯកជនធុនតូចអោយមានប្រសិទ្ធភាព និងអាចដំណើរការបានភ្លាមៗ ដូចជា អណ្តូងស្នប់រាក់ៗ និងប្រព័ន្ធម៉ាស៊ីនបូមទឹកតូចៗ ២-បង្កើនផលិតភាពស្រូវ ៣-កែលម្អប្រព័ន្ធដាំដុះរួមទាំងការពង្រីកមុខដំណាំដាំដុះ និងប្រពលវប្បកម្ម ៤-ពង្រីក និងកែលម្អការចិញ្ចឹមសត្វ ៥-ពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់បច្ចេកវិទ្យាសមស្របក្នុងការចិញ្ចឹមត្រីក្នុងស្រែ និងការចិញ្ចឹមត្រីជាទូទៅ និង៦-អភិវឌ្ឍន៍វិស័យកសិ-រុក្ខាសហគមន៍។ ប្រព័ន្ធធារាសាស្ត្រតូចៗ ដែលគ្រប់គ្រងដោយកសិករផ្ទាល់ គឺជាកាលានុវត្តភាពដ៏ល្អប្រសើរផុត ដោយសារប្រទេសកម្ពុជា មានផ្ទៃដាំដុះចំនួន ៤.៨លានហិកតា ដែលមានទឹកក្រោមដី ឬដែលមានទន្លេ ស្ទឹងហូរកាត់ខ្ជាត់ខ្ជែង។ ក៏ប៉ុន្តែការអភិវឌ្ឍន៍ធារាសាស្ត្រត្រូវតែបានធ្វើឡើងអោយបានទន្ទឹមគ្នានឹងការកែលម្អនូវសេវា និងការងារគាំទ្រផ្នែកធារាសាស្ត្រកសិកម្មសំខាន់ៗ ដូចជា គម្រោងសាកល្បងស្តីពីកម្មវិធីពិសេស ដើម្បីធានាសន្តិសុខស្បៀង ដែលឧបត្ថម្ភដោយអង្គការ FAO[៣២] ក្នុងគោលដៅទាញផលប្រយោជន៍ជាអតិបរមាពីការអភិវឌ្ឍន៍ ប្រព័ន្ធធារាសាស្ត្រជាដើម។ ជាមួយគ្នានេះ យើងនៅមានសក្តានុពលដ៏ល្អប្រសើរក្នុងរយៈពេលខ្លី និងក្នុងរយៈពេលវែង ដើម្បីបង្កើនទិន្នផលស្រូវ និងបង្កើនប្រពលវប្បកម្មដំណាំដាំដុះផ្សេងៗ។ ដំណាំស្រូវលើដីដែលមានទិន្នផលមធ្យម និងខ្ពស់អាចអនុញ្ញាតអោយប្រមូលផលបានរហូតដល់ ៥.៥តោន ក្នុងមួយហិកតាក្នុងមួយឆ្នាំ រោងចក្រផលិតចំណីសត្វ និងការចិញ្ចឹមសត្វក្នុងទ្រង់ទ្រាយធំដោយប្រើប្រាស់នូវដីដែលនៅទំនេរ។ កាលានុវត្តភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងវិស័យជលផល គឺការចិញ្ចឹមត្រីនៅក្នុងស្រែ និងការចិញ្ចឹមត្រីជាទូទៅ។

ការអភិវឌ្ឍន៍វិស័យនេះនៅជួបប្រទះនឹងការលំបាក ដោយសារតែយើងនៅមិនទាន់មានក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ ហេដ្ឋារចនាសម្ព័ន្ធនៅទន់ខ្សោយពុំទាន់មានការរៀបចំជាប្លង់មេអោយត្រឹមត្រូវ និងផែនការសកម្មភាពក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម។ ទីផ្សារនាំចេញអង្ករ និងដំណាំដទៃទៀតមិនទាន់ត្រូវបានស្រាវជ្រាវអោយបានច្បាស់លាស់ ហើយយើងត្រូវប្រឈមនឹងរបាំងជាច្រើនដែលរារាំងដល់កំណើននៃការនាំចេញក្នុងនោះមានគុណភាពនៅទាប កង្វះខាតនូវព័ត៌មានស្តីពីពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រនៅអន់ថយកង្វះខាតឧបករណ៍សម្ភារៈសម្រាប់ពេលច្រូតកាត់ និងក្រោយពេលច្រូតកាត់ សមត្ថភាពស្ថាប័ននៅខ្សោយ ទិន្នផលដំណាំនៅទាប សេវាគាទ្រកសិកម្មមិនទាន់គ្រប់គ្រាន់ ប្រព័ន្ធធារាសាស្ត្រមិនគ្រប់គ្រាន់ ហើយ

[៣២] FAO- Food and Agriculture Organization

មានផលិតភាពទៅទាប កសិករគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីទទួលបាននូវធនធានសម្រាប់ផលិតកម្ម និងការខ្វះខាតសមត្ថភាព ស្ថាប័នក្នុងការធ្វើផែនការ និងអនុវត្តសកម្មភាពអភិវឌ្ឍន៍កសិកម្ម។

រាជរដ្ឋាភិបាលបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីបង្កើនចីរភាពនៃធនធានព្រៃឈើ។ វិធានការទាំងនេះរួមមាន ការអនុវត្តន៍ប្រកបដោយជោគជ័យនូវគោលនយោបាយ ក្នុងការបង្ការឧក្រិដ្ឋកម្មការចាប់បានការកំចាត់ និងការត្រួតពិនិត្យសកម្មភាពខុសច្បាប់នានា។ រាជរដ្ឋាភិបាល បានបង្កើតឡើងនូវអង្គភាពផ្តល់របាយការណ៍ និងត្រួតពិនិត្យបទឧក្រិដ្ឋព្រៃឈើនៅក្នុងនាយករដ្ឋានរុក្ខប្រមាញ់ នៃក្រសួងកសិកម្ម និងនៅក្នុងក្រសួងបរិស្ថាន និងបង្កើតឡើងនូវចំណុចប្រមូលផ្តុំមួយនៅទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ត្រួតពិនិត្យរបាយការណ៍។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ Global Witnes ត្រូវបានតែងតាំងជាផ្លូវការដោយរាជរដ្ឋាភិបាលជាអ្នកឃ្លាំមើលឯករាជ្យ។ ការត្រួតពិនិត្យសកម្មភាពកាប់ឈើខុសច្បាប់ គួបផ្សំនឹងវិធានការដែលបានដាក់ចេញ និងគ្រោងទុកដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធព្រៃសម្បទាន និងធានាបាននូវការកៀងគរចំណូលអោយអស់លទ្ធភាពពីវិស័យព្រៃឈើ ដែលនឹងក្លាយទៅជាប្រភពហិរញ្ញវត្ថុមួយដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងវិស័យកសិកម្ម និងវិស័យដទៃទៀត។

ឆ-ការកែលម្អការគ្រប់គ្រងធនធានទឹក

អាទិភាពដ៏ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល គឺបង្កើនការផ្គត់ផ្គង់ទឹក និងហេដ្ឋារចនាសម្ព័ន្ធទាំងនៅទីក្រុង ទាំងនៅទីជនបទ ក្នុងគោលដៅការដោះស្រាយដើមហេតុចម្បងនៃភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាព សន្តិសុខស្បៀង និងសុខភាពរបស់ប្រជាជន។ យើងនឹងប្រើប្រាស់អោយមានប្រសិទ្ធភាពខ្ពស់នូវទឹកនៅក្រោមដីទាំងរាក់ ទាំងជ្រៅ ក្នុងគោលដៅធារាសាស្ត្រ និងគោលដៅនៃការផ្គត់ផ្គង់ទឹកតាមលំនៅឋាន។ ក្នុងករណីដែលលក្ខខ័ណ្ឌបច្ចេកទេស និងសេដ្ឋកិច្ចអនុញ្ញាតរាជរដ្ឋាភិបាលមានវិធានការស្តារឡើងវិញនូវមូលដ្ឋានធារាសាស្ត្រដែលមានស្រាប់ដោយរៀបចំអោយមានជាប្រព័ន្ធមេអោយមានលក្ខណៈស្តង់ការ ដើម្បីធានានូវសមធម៌ក្នុងការប្រើប្រាស់ទឹក និងដើម្បីលើកម្ពស់ផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងរយៈពេលខ្លី និងក្នុងរយៈពេលមធ្យម គឺលើកទឹកចិត្តដល់ផ្នែកឯកជន និងកសិករក្នុងការអនុវត្តន៍កម្មវិធីអណ្តូងរាក់ៗ និងម៉ាស៊ីនបូមទឹកតូចៗ។ បន្ទាប់ពីសមត្ថភាពស្ថាប័នទាំងនៅមជ្ឈឹមទាំងនៅខេត្ត ក្នុងការរៀបចំគ្រប់គ្រង និងដំណើរការនូវប្រព័ន្ធធារាសាស្ត្រត្រូវបានពង្រឹងរួចហើយ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវយុទ្ធសាស្ត្រក្នុងការពង្រីកប្រព័ន្ធធារាសាស្ត្រធំៗទៀត។ គោលដៅនៃគោលនយោបាយទឹករបស់រាជរដ្ឋាភិបាល គឺពង្រីកតំបន់ស្រោចស្រពពេញលេញពី១៦ ដល់ ២០% នៃតំបន់ ដាំស្រូវទាំងអស់នៅក្នុងអំឡុងពេល ៥ឆ្នាំ គឺ ២០០៣ តាមរយៈការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រសមស្រប ការបង្កើនការត្រួតពិនិត្យ និងភាពជាម្ចាស់នៅមូលដ្ឋាន ការជម្រុញការចូលរួមរបស់ផ្នែកឯកជនក្នុងការអភិវឌ្ឍន៍ ប្រព័ន្ធធារាសាស្ត្រ និងពង្រឹងសមត្ថភាពរបស់អង្គភាពរដ្ឋ និងសហគមន៍អ្នកប្រើប្រាស់ទឹកក្នុងកិច្ចដំណើរការ និងការថែទាំងប្រព័ន្ធធារាសាស្ត្រ។

រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានជលសាស្ត្រពាក់ព័ន្ធនឹងប្រភពទឹកទាំងអស់ ទាំងទឹកផ្ទៃលើ ទាំងទឹកក្រោមដី(អាងទន្លេ និងអាងទឹកក្រោមដី) អោយមានចីរភាព និងដ៏គួរអោយទុកចិត្តបានដែលនឹងផ្តល់ព័ត៌មានជាមូលដ្ឋាន ដើម្បីជួយដល់ការធ្វើផែនការយុទ្ធសាស្ត្រ និងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយចីរភាព ដើម្បីរក្សាបាននូវបរិស្ថានសម្រាប់បម្រើអោយគោលដៅផ្សេងៗដូចជា ធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកបរិភោគ ថាមពលវារីអគ្គីសនី ការដឹកជញ្ជូន ជលផល ការគ្រប់គ្រងទឹកជំនន់ និងកិច្ចការពារធនធានបរិស្ថានជាដើម។ ចំពោះបញ្ហានេះ រាជរដ្ឋាភិបាលមានផែនការនិង ១-រៀបចំទិន្នន័យលម្អិតនៃវិស័យទឹក ២-រៀបរូបមន្តសម្រាប់យុទ្ធសាស្ត្រវិនិយោគទុក ៣-បង្កើតក្របខ័ណ្ឌស្ថាប័នសម្រាប់ការធ្វើប្រតិបត្តិការ និងការថែរក្សាប្រព័ន្ធធារាសាស្ត្រ ៤-រៀបចំផែនការសកម្មភាពស្តីពីគោលនយោបាយអភិវឌ្ឍន៍ធនធានទឹកថ្នាក់ជាតិ និង ៥-ពង្រឹងការធ្វើផែនការគម្រោង និងសមត្ថភាពអនុវត្តគម្រោងក្នុងគ្រប់កម្រិតទាំងអស់។

៩-ជម្រុញការអភិវឌ្ឍន៍ជនបទ និងទីមជ្ឈការ

រាជរដ្ឋាភិបាលបានលើកឡើងនូវយុទ្ធសាស្ត្រមួយ ដែលឈរលើមូលដ្ឋាននៃការអភិវឌ្ឍន៍ជនបទពីក្រោមឡើងលើចម្រុះដោយមានការចូលរួមយ៉ាងទូលំទូលាយ និងដោយឈរលើគោលការណ៍វិមជ្ឈការ។ គោលដៅសំខាន់គឺ ត្រូវពង្រីកចំនួនគណៈកម្មការអភិវឌ្ឍន៍ភូមិ ដែលត្រូវបានបោះឆ្នោតជ្រើសរើស ដើម្បីជាតំណាងភូមិចំពោះមុខរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ភូមិបានដល់ ៦៩% នៃភូមិទាំងអស់នៅចុងឆ្នាំ២០០០នេះ[៣៣] ។ ប្រការនេះនឹងអនុញ្ញាតអោយសហគមន៍ចូលរួមយ៉ាងសកម្មនៅក្នុងស្ថាប័នមូលដ្ឋាន និងបង្កើនភាពជាម្ចាស់នៃគម្រោងអភិវឌ្ឍន៍ដោយផ្តល់អោយបុគ្គលម្នាក់ៗ គ្រួសារ និងសហគមន៍នីមួយៗនូវសិទ្ធិក្នុងការធ្វើសេចក្តីសម្រេច និងដោយធានាបាននូវគណនេយ្យភាព។ ការកែទម្រង់ស្ថាប័ន និងគោលនយោបាយកំពុងត្រូវបានទទួលការគាំទ្រ ដោយការវិនិយោគសាធារណៈជាយុទ្ធសាស្ត្រដោយរួមបញ្ចូលនូវការផ្គត់ផ្គង់ដល់ភូមិ និងផ្លូវលំជនបទ ដើម្បគាំទ្រដល់ការស្តារបនាឡើងវិញ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធជនបទដ៏មានសារៈសំខាន់នេះ និងដើម្បីបង្កើតការងារនៅទីជនបទ។ រាជរដ្ឋាភិបាល បានផ្តល់អាទិភាពទៅលើការបង្កើនចំណូលជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីរក្សានូវអន្តោប្រវេសន៍នៃប្រជាជនពីទីជនបទទៅកាន់ទីក្រុងអោយស្ថិតនៅត្រឹមកម្រិតមួយ ដែលអាចគ្រប់គ្រងបាន។

រាជរដ្ឋាភិបាលមានផែនការនឹងធ្វើវិមជ្ឈការ ប្រព័ន្ធរដ្ឋបាលរបស់ខ្លួនបន្ថែមទៀត ព្រមទាំងនឹងដាក់អោយអនុវត្តន៍នូវគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុនៅតាមមូលដ្ឋាន ដោយរៀបចំ និងដាក់ជូនសភាពិនិត្យ និងអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ/សង្កាត់។ យើងមានគម្រោងរៀបចំការបោះឆ្នោត ដែលនឹងប្រព្រឹត្តទៅនៅចុងឆ្នាំ២០០១ ខាងមុខ ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលនឹងមានថវិកាផ្ទាល់ខ្លួនរួមមានចំណូលសារពើពន្ធ និងចំណូលពុំមែនសារពើពន្ធ និងធនធានដែលផ្ទេរពីថវិការដ្ឋ។ ក្រុមប្រឹក្សានឹងទទួល

[៣៣] ក្រសួងផែនការៈ របាយការណ៍ឆ្នាំ១៩៩៩ ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា។ សេដ្ឋកិច្ចភូមិ និងការអភិវឌ្ឍន៍។

ខុសត្រូវក្នុងការផ្តល់សេវា ដោយរួមទាំងសេវាសង្គមដល់ភូមិនានា។ ក្រុមប្រឹក្សានឹងមានលទ្ធភាពកាន់តែខ្លាំងឡើងនៅក្នុងការសម្រេចចិត្ត ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍តំបន់របស់ខ្លួន[៣៤]។

ឈ-ធានានូវការគ្រប់គ្រងធនធានធម្មជាតិអោយបានត្រឹមត្រូវ

ការគ្រប់គ្រងធនធានធម្មជាតិបានល្អ និងការកាត់បន្ថយភាពក្រីក្រមានការទាក់ទាញគ្នាយ៉ាងជិតស្និត។ ម្យ៉ាងស្ថានភាពនៃពលរដ្ឋក្រីក្រអាចនឹងត្រូវបានធ្វើប្រសើរឡើង តាមរយៈការពង្រីកលទ្ធភាពទាញយកផលប្រយោជន៍ពីធនធានព្រៃឈើ ជលផល និងទឹក។ ដូច្នេះ កម្មវិធីកាត់បន្ថយភាពក្រីក្រត្រូវចុចអោយចំស្ថានភាពពិតប្រាកដរបស់ជនក្រីក្រ ដែលនៅរាយប៉ាយនៅតាមបណ្តាខេត្ត។ ឧទាហរណ៍ ការធានាអោយជនជាតិភាគតិចដែលរស់នៅតាមតំបន់ភ្នំអាចប្រើប្រាស់ដោយសេរីនូវធនធានព្រៃឈើ និងការគោរពកម្មសិទ្ធិដីធ្លីរបស់ពួកគេ គឺជាឧទាហរណ៍យ៉ាងសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ នៅតំបន់ភាគឦសាននៃប្រទេសកម្ពុជា។ ការផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ទន្លេសាបទាញយកផលពីធនធានជលផល និងធនធានទឹកមានសារៈសំខាន់ណាស់ក្នុងការកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅទីនោះ។ ម្យ៉ាងទៀត យើងត្រូវគ្រប់គ្រងធនធានធម្មជាតិអោយបានល្អ ដើម្បីជម្រុញអោយមានការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ញ-លើកទឹកចិត្តសកម្មភាពបង្កើតចំណូលនៅក្នុងទីជនបទ

ការលើកកម្ពស់សកម្មភាពបង្កើតចំណូលនៃសេដ្ឋកិច្ចជនបទ និងបង្កើតអោយមាននូវកំណើន និងការងារដែលលើកកម្ពស់សុវត្ថិភាពសន្តិសុខស្បៀង និងធ្វើសមាហរណកម្មប្រជាជននៅជនបទទៅក្នុងទីផ្សារក្នុងស្រុកដែលកំពុងតែរីកធំឡើងៗ។ សកម្មភាពទាំងនេះអាចផ្តល់នូវចំណូលបន្ថែមដល់អ្នកធ្វើការនៅក្នុងរដូវមិនធ្វើស្រែដែលប្រការនេះមានសក្តានុពលខ្ពស់ក្នុងការជះឥទ្ធិពលដល់ភាពក្រីក្រ។

ដ-ការកាត់បន្ថយភាពក្រីក្រនៅតាមទីប្រជុំជន

រាជរដ្ឋាភិបាលត្រូវមានកម្មវិធីដែលមានគោលដៅច្បាស់លាស់មួយ ក្នុងការដោះស្រាយភាពក្រីក្រនៅតាមទីប្រជុំជន។ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តបំពេញភារកិច្ច ដើម្បីការពារ និងកែលម្អនូវគុណភាពជីវិតរបស់ពលរដ្ឋក្រីក្រ ដែលរស់នៅក្នុងទីប្រជុំជនតាមរយៈការអភិវឌ្ឍន៍ និងគ្រប់គ្រងសេវាសង្គមអោយបានសមស្រប។ ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជនអាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ នៅតាមទីប្រជុំជនដោយការធ្វើសហហិរញ្ញប្បទានកម្មវិធីកាត់បន្ថយភាពក្រីក្រជាមួយអង្គការក្រៅរដ្ឋាភិបាលដូចជា អង្គការ Urban Sector Group (USG) ដើម្បីដោះស្រាយបញ្ហារបស់ប្រជាជនដែលតាំងទីលំនៅបណ្តោះអាសន្នជាមួយអង្គការ "មិត្តសំឡាញ់" ដើម្បីជួយក្មេង

[៣៤] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៥៣

អនាថា ដែលរស់នៅតាមដងផ្លូវ និងជាមួយអង្គការ Youth With A Mission (YWAM) ដើម្បីជួយដល់ក្រុមគ្រួសារដែលរស់នៅតាមចិញ្ចើមថ្នល់។ រាជរដ្ឋាភិបាលនឹងផ្តល់ការយកចិត្តទុកដាក់ថែមទៀតក្នុងការជួយពលរដ្ឋដែលតាំងទីលំនៅបណ្តោះអាសន្នដោយផ្តល់នូវមីក្រូឥណទាន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការជួយរកការងារអោយពួកគេធ្វើ។ យើងត្រូវមានកម្មវិធីដែលមានគោលដៅពិសេស ដើម្បីបង្កើនការទទួលបាននូវសេវាសុខភាព ការអប់រំ និងសេវាជាមូលដ្ឋាននានា ដូចជា ទឹក និងអគ្គីសនីជាដើម។ រដ្ឋនឹងកំណត់នូវស្ថានភាពគតិ-យុត្តរបស់ពួកគេ ដើម្បីបង្ការកុំអោយមានការបណ្តេញចេញតាមអំពើចិត្ត។ រាជរដ្ឋាភិបាលមានគោលបំណងធ្វើការអភិវឌ្ឍន៍ភាពជាដៃគូថ្មីជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីកែលម្អនូវស្ថានភាពរបស់គ្រួសារ និងក្មេងនៅតាមចិញ្ចើមផ្លូវ ដោយការធ្វើសហហិរញ្ញប្បទាន កម្មវិធីទ្រទ្រង់ ដើម្បីជួយអោយពួកគេទាំងអស់នោះត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញ។ រាជរដ្ឋាភិបាលនឹងសហការជាមួយអង្គការក្រៅរដ្ឋភិបាល ដោយផ្តោតការយកចិត្តទុកដាក់ចំពោះការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរកការងារអោយក្មេងនៅតាមចិញ្ចើមថ្នល់ធ្វើ និងបង្កលក្ខណៈអោយក្មេងនៅតាមចិញ្ចើមថ្នល់ដែលនៅតូចៗនៅឡើយមានលទ្ធភាពទទួលបាននូវការអប់រំ និងសេវាសុខភាពសាធារណៈ[៣៥]។

ថ-ការអនុវត្តន៍គោលនយោបាយដីធ្លី

គោលនយោបាយដីធ្លីនឹងផ្តោតទៅលើការបែងចែកដីធ្លី ការរៀបចំដីធ្លី និងរដ្ឋបាលដីធ្លី។ កម្មវិធីស្នូលនៃគោលនយោបាយដីធ្លីរួមមាន ការអភិវឌ្ឍន៍គោលនយោបាយដីធ្លីជាតិមួយ ការកែលម្អការគ្រប់គ្រងដីរបស់រដ្ឋ ការចាប់ផ្តើមចុះបញ្ជីដីធ្លីជាប្រព័ន្ធ កំណែទម្រង់សារពើពន្ធ ការបង្កើតក្របខ័ណ្ឌគតិយុត្ត ដើម្បីពង្រឹងសិទ្ធិលើទ្រព្យសម្បត្តិ ការបង្កើតនូវផែនប្លង់មេ និងការកំណត់តំបន់សម្រាប់ថ្នាក់ខេត្ត/ក្រុង និងថ្នាក់ជាតិ និងការអភិវឌ្ឍន៍លំនៅឋានជនបទ។ ក្នុងរយៈពេលមធ្យម និងរយៈពេលវែងរាជរដ្ឋាភិបាលកម្ពុជានឹងដោះស្រាយបញ្ហាទាំងនេះតាមរយៈការអនុម័ត និងការអនុវត្តន៍ច្បាប់ភូមិបាលថ្មី ក៏ដូចជាការអនុវត្តន៍ការងារចុះបញ្ជីដីធ្លីជាប្រព័ន្ធក្នុងកម្រិតជាតិ ដែលធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ផ្តល់មូលដ្ឋានសម្រាប់បន្តយដម្លៃកម្មសិទ្ធិដីធ្លី និងជួយសម្រួលការគ្រប់គ្រងដីធ្លី ការត្រួតពិនិត្យ និងការគ្រប់គ្រងធនធានធម្មជាតិ និងការការពារសម្បត្តិរដ្ឋ។ ការចាត់ថ្នាក់ការប្រើប្រាស់ដីធ្លីមានសារៈសំខាន់សម្រាប់ធ្វើការកំណត់ព្រំប្រទល់ប្រភេទដីផ្សេងៗដូចជា ដីព្រៃ ទ្រព្យរដ្ឋដាអចិន្ត្រៃយ៍ ទ្បត៍នេសាទ និងដីកសិកម្មផ្សេងទៀត ដែលអាចជួយអោយជនក្រីក្រអាចទទួលបានដីធ្លី និងកែលម្អការកាន់កាប់ដីធ្លី និងការនេសាទជាប្រពៃណី។

សិក្ខាសាលាស្តីពីការគ្មានដីធ្លីត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងខែសីហា ឆ្នាំ២០០០ កន្លងទៅនេះ ដើម្បីកំណត់នៅចំនួនប្រជាជនដែលគ្មានដី និងមូលហេតុដែលបណ្តាលអោយបាត់បង់ដី និង

[៣៥] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៥៥

រៀបចំគោលនយោបាយពាក់ព័ន្ធនឹងបញ្ហាដ៏សំខាន់នេះ។ រាជរដ្ឋាភិបាលកម្ពុជានឹងដាក់ចេញនូវវិធានការដូចខាងក្រោម ដើម្បីស្វែងរកនូវដំណោះស្រាយចំពោះបញ្ហាដ៏ស្មុគស្មាញនេះ[៣៦] :

ក-ធ្វើការសិក្សាស្រាវជ្រាវអោយបានម៉ត់ចត់អំពីលទ្ធភាពចូលទៅកាន់កាប់ដីធ្លី ភាពក្រីក្រ និងភាពងាយទទួលរងគ្រោះ ដើម្បីមានមូលដ្ឋានធ្វើកំណែទម្រង់គោលនយោបាយ។

ខ-កំណត់នូវក្រុមដែលគ្មានដី និងក្រុមដែលមានដីមិនគ្រប់គ្រាន់នៅថ្នាក់ស្រុក និងខេត្ត ដើម្បីធ្វើអោយពួកគេអាចទទួលបានការយកចិត្តទុកដាក់កាន់តែមានប្រសិទ្ធភាព។

គ-ហ្វឹកហ្វឺនអាជ្ញាធរខេត្ត និងមូលដ្ឋាន ដើម្បីរៀបចំផែនទីធនធានដី និងឯកសារនៃការរៀបចំផែនការផ្សេងៗទៀត ដែលអាចផ្តល់ទិន្នន័យសំខាន់ៗ ដល់ការគ្រប់គ្រងធនធានដីនៅក្នុងតំបន់នីមួយៗអោយកាន់តែមានប្រសិទ្ធភាព និងផ្តល់លទ្ធភាពអោយមានការត្រួតពិនិត្យជាប្រព័ន្ធនូវសភាពការណ៍ដីធ្លី និងស្ថានភាពដីធ្លីរបស់ពលរដ្ឋក្រីក្រ និងក្រុមដែលងាយរងគ្រោះ។

ឃ-ចាត់វិធានការដើម្បីធានាថា សហគមន៍ដែលបានបង្កើតឡើងនៅមូលដ្ឋានអាចប្រើប្រាស់ទៅតាមទម្លាប់របស់គេនូវធនធានដែលជាសម្បត្តិរួម(ដីធ្លី ព្រៃឈើ និងផ្លូវទឹក) និងមិនត្រូវបានដណ្តើមដោយក្រុមថ្មីៗផ្សេងទៀត។

ង-ពិនិត្យឡើងវិញនូវគោលនយោបាយផ្តល់ដីធ្លីដែលបានដោះស្រាយ ហើយផ្តល់អាទិភាពចំពោះជនភៀសសឹកអតីតយុទ្ធជន និងក្រុមជនក្រីក្រដទៃទៀត។

ច-ជានាសុវត្ថិភាពនៃការកាន់កាប់ដីចំពោះកសិករ តាមរយៈការកែលម្អចំណុចខ្សោយបច្ចុប្បន្ននៃការចាត់តែងដីធ្លី និងនៅលើច្បាប់ភូមិបាល។

ឆ-ចាប់ផ្តើមមកកម្មវិធីដែលមានគោលដៅបង្កើនលទ្ធភាពចូលទៅកាន់កាប់ដីធ្លី និងបង្កើនការផ្តល់ប័ណ្ណដីធ្លីដល់ម្ចាស់ដី និងអ្នកកាន់កាប់ដីធ្លីតូចតាច។

ជ-ពិនិត្យឡើងវិញនូវកម្មវិធីជួយចំពោះជនភៀសសឹក និងអ្នកធ្វើមាតុភូមិនិវត្តន៍ ដើម្បីរៀនសូត្រពីបទពិសោធន៍នាពេលកន្លងទៅ ជាពិសេសពាក់ព័ន្ធនឹងការបែងចែក និងការផ្តល់នូវដីធ្លី។

ឈ-កែលម្អលទ្ធភាពអាចមានលំនៅឋាន និងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងៗទៀត សម្រាប់ក្រុមជនងាយរងគ្រោះនៅភ្នំពេញ និងនៅទីក្រុងផ្សេងៗទៀត ដោយផ្តល់អាទិភាពដល់តំបន់តោកយ៉ាកនៃសំណង់បណ្តោះអាសន្ន។

ញ-ធ្វើការសិក្សាត្រួតពិនិត្យដើម្បីកំណត់ថា បញ្ហាភេទអាចប៉ះពាល់ដូចម្តេចខ្លះនៅក្នុងគោលនយោបាយដីធ្លី និងក្នុងប្រព័ន្ធចុះបញ្ជីដីធ្លី ការទទួលមរតកដីធ្លី ភាពជាម្ចាស់ដីធ្លី ដែលកើតឡើងពីអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិដីធ្លី ដែលជាលទ្ធផលនៃជម្លោះរវាងប្តី និងប្រពន្ធ។

---

[៣៦] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៥៥

២.៣.៣ ការបង្កើតឱកាសសុវត្ថិភាព

បន្ថយភាពងាយរងគ្រោះរបស់ពលរដ្ឋក្រីក្រដោយពង្រឹងសមត្ថភាព ដើម្បីទប់ទល់នឹងវិបត្តិពីខាងក្រៅ ហើយបង្កើតនូវចីរភាពជាទូទៅនៃជីវភាពរបស់ពួកគេ គឺជាបញ្ហាអាទិភាពមួយដោយសារក្នុងពេលកន្លងមករដ្ឋមិនទាន់បានយកចិត្តទុកដាក់អោយបានគ្រប់ជ្រុងជ្រោយចំពោះការជួយដល់ជនក្រីក្រទាំងឡាយ ដែលមានបំណងចង់ឈប់ប្រកបរបរកសិកម្ម។ នាពេលបច្ចុប្បន្ននេះ យើងកំពុងផ្តោតការយកចិត្តទុកដាក់ចំពោះការផ្តល់ឥណទានសម្រាប់អនុវត្តសកម្មភាពណាដែលបង្កើតប្រាក់ចំណូល ប៉ុន្តែទន្ទឹមនឹងនេះក៏មានការចាំបាច់ផងដែរក្នុងការគិតគូរពីភាពងាយប៉ះពាល់ដោយសារការប្រែប្រួលនៃប្រាក់ចំណូល ពីព្រោះបញ្ហានេះបណ្តាលអោយមានកង្វះប្រាក់កាស ដែលជាមូលហេតុធ្វើអោយមានការពន្យាពេលនៃការធ្វើវិនិយោគ និង/ឬ ជាមូលហេតុអោយមានការយកដីធ្លីទៅលក់ ដើម្បីយកប្រាក់មកទប់ទល់នឹងចំណាយផ្សេងៗ។ បញ្ហានេះអាចនឹងត្រូវដោះស្រាយបានតាមរយៈការផ្តល់នូវការធានារ៉ាប់រងប្រាក់សន្សំ និងឥណទានសម្រាប់ការប្រើប្រាស់។ ម្យ៉ាងវិញទៀត រដ្ឋអាចធានាបាននូវសន្តិសុខដោយបង្កើត និងពង្រីកការអនុវត្តន៍កម្មវិធីសុវត្ថិភាពសង្គម លើកស្ទួយកិច្ចការពារបរិស្ថាន និងការដោះមីន។

ក-ផ្តល់ឥណទានមីក្រូហិរញ្ញវត្ថុដល់ពលរដ្ឋក្រីក្រ

ការខ្វះខាតយ៉ាងខ្លាំងនៃសេវាហិរញ្ញវត្ថុនៅតំបន់ជនបទ គឺជាឧបសគ្គយ៉ាងធំធេងមួយចំពោះកំណើនកសិផល និងការអភិវឌ្ឍន៍ជនបទ។ អង្គការមិនមែនរដ្ឋាភិបាលកំពុងអនុវត្តនូវប្រតិបត្តិមីក្រូហិរញ្ញវត្ថុ ដែលបានផ្តល់នូវសេវាហិរញ្ញវត្ថុតែមួយគត់នៅតាមតំបន់ជនបទ។ អង្គការមិនមែនរដ្ឋាភិបាល បានផ្តល់នូវឥណទានដែលមានតម្លៃ ២៣លានដុល្លារអាមេរិក ចំពោះគ្រួសារចំនួន ៣៣៤.០០០ ហើយបានជួយបង្កើតការងារច្រើន និងបង្កើតប្រាក់ចំណូលសម្រាប់អ្នកក្រីក្រ។ គ្មានធនាគារពាណិជ្ជណាមួយ ដែលមានធនធាន ឬមានគោលបំណងដើម្បីពង្រីកប្រតិបត្តិការរបស់ពួកគេទៅកាន់តំបន់ជនបទឡើយ។ ក៏ប៉ុន្តែតាមការប៉ាន់ស្មាន ការខ្វះខាតឥណទានជនបទ គឺស្មើនឹង ៧០លានដុល្លារអាមេរិក។ ចាប់តាំងពីឆ្នាំ១៩៩៥ មករាជរដ្ឋាភិបាល បានផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពឥណទានមីក្រូហិរញ្ញវត្ថុ ដោយបង្កើតឡើងនូវធនាគារអភិវឌ្ឍន៍ជនបទ។ គោលដៅសំខាន់ គឺធានានូវការអភិវឌ្ឍន៍ឥណទានមីក្រូហិរញ្ញវត្ថុប្រកបដោយចីរភាព។ ធនាគារអភិវឌ្ឍន៍ជនបទកំពុងធ្វើប្រតិបត្តិការលក់ដុំ និងមិនផ្តល់កម្ចីពាណិជ្ជកម្មដោយផ្ទាល់ទេ។ រាជរដ្ឋាភិបាលយល់ឃើញថា មានតែការអភិវឌ្ឍន៍និងពង្រីកប្រព័ន្ធហិរញ្ញវត្ថុមិនជ្រៅការទេ ទើបអាចបំពេញតម្រូវការរបស់ជនក្រីក្រ និងអាចឆ្លើយតបចំពោះសភាពការណ៍នៅលើទីផ្សារបាន។ ដូច្នេះហើយ ធនាគារអភិវឌ្ឍន៍ជនបទ បានខិតខំជម្រុញ កម្មវិធីឥណទានមីក្រូហិរញ្ញ

វត្ថុរបស់អង្គការមិនមែនរដ្ឋាភិបាល ជាពិសេសដោយផ្តោតមុខព្រួញទៅរកអ្នកក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រទាំងឡាយ[៣៧]។

ខ-ការចូលរួមក្នុងសកលភាវូបនីយកម្ម

នៅក្នុងវិស័យក្រៅប្រទេស កម្ពុជាចាំបាច់ត្រូវបន្តពង្រីក និងពង្រឹងទំនាក់ទំនងអន្តរជាតិ និងប្តេជ្ញាបើកចំហទីផ្សារ និងការធ្វើពាណិជ្ជកម្មក្នុងឋានៈជាសមាជិកមួយរបស់អាស៊ាន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននឹងពង្រឹង និងពង្រីកការចូលរួមរបស់ខ្លួនក្នុងគណៈកម្មាធិការទន្លេមេគង្គ មហាអនុតំបន់ទន្លេមេគង្គ។ ប្រការនេះមានសារៈសំខាន់ណាស់ដោយសារទន្លេមេគង្គជាសរសៃឈាមនៃវិស័យកសិកម្ម និងនេសាទទឹកសាបនៅក្នុងប្រទេសកម្ពុជា។ កម្ពុជានឹងចូលប្រឡូកយ៉ាងស្វាហាប់ និងស៊ីជម្រៅលើឆាកអន្តរជាតិតាមរយៈការចូលរួមជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក។ កម្ពុជាត្រូវតែបន្តបង្កើនការចូលរួមជាលក្ខណៈអន្តរជាតិជាច្រើនទៀត ពីព្រោះការពិភាក្សា និងវិធានផ្សេងៗទៀតដូចជា នៅក្នុងវិស័យពាណិជ្ជកម្ម វិនិយោគទុនពីបរទេស និងនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ នឹងជះឥទ្ធិពលទៅលើការអភិវឌ្ឍន៍ និងកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយភាពក្រីករបស់រាជរដ្ឋាភិបាល។ កម្ពុជាត្រូវធានាថា ខ្លួនមិនត្រូវបានគេផាត់ចេញពីការចរចារទាំងនោះដោយសារតែការខ្វះសមត្ថភាព ឬខ្វះមធ្យោបាយក្នុងការចរចារឡើយ។ ក៏ប៉ុន្តែសមាហរណកម្មសេដ្ឋកិច្ចតែឯកឯង មិនអាចដោះស្រាយបញ្ហាក្រីក្របានឡើយ។ អត្ថបទប្រយោជន៍នៃកំណើនសេដ្ឋកិច្ចជាសកល ត្រូវបានបែងចែកមិនស្មើគ្នាឡើយ ដែលបណ្តាលអោយមានគម្លាតសេដ្ឋកិច្ចកាន់តែធំ ហើយរុញអោយស្ត្រីធ្លាក់ចូលក្នុងរណ្តៅនៃភាពក្រីក្របង្កើនវិសមភាពរវាងភេទខុសគ្នា ធ្វើអោយស្ថានភាពការងារកាន់តែយ៉ាប់យឺន និងបរិស្ថានការងារកាន់តែគ្មានសុវត្ថិភាព ជាពិសេស នៅក្នុងផ្នែកសេដ្ឋកិច្ចក្រៅផ្លូវការ និងនៅទីជនបទ។ នៅក្នុងខណៈដែលសកលភាវូបនីយកម្មផ្តល់នូវកាលានុវត្តភាពសេដ្ឋកិច្ចកាន់តែធំជាងនេះ និងស្វ័យភាពចំពោះស្ត្រីមួយចំនួន ស្ត្រីភាគច្រើនកំពុងខ្ចាតចេញពីចន្លោះនេះ ដោយសារតែមានវិសមភាពកាន់តែខ្លាំងឡើងទាំងរវាងប្រទេស ទាំងនៅក្នុងប្រទេសនីមួយៗ ដែលធ្វើអោយពួកគេមិនបានទទួលបាននូវអត្ថប្រយោជន៍សមស្របពីដំណើរការនេះ។ រាជរដ្ឋាភិបាលត្រូវធ្វើអន្តរាគមន៍ ដើម្បីផ្តល់នូវការហ្វឹកហ្វឺនបង្កើនជំនាញពង្រីកនូវការផ្តល់ឥណទាន និងជួយដល់ផ្នែកប្រជាជន ដែលងាយរងគ្រោះ ដើម្បីចូលរួមប្រកួតប្រជែងនៅក្នុងបណ្តាញសកល។

គ-កម្មវិធីសុវត្ថិភាពសង្គម

យោងតាមការអង្កេតសេដ្ឋកិច្ច-សង្គមក្នុងឆ្នាំ១៩៩៩ រដ្ឋត្រូវចំណាយថវិកាយ៉ាងហោចណាស់ចំនួន ១.៣ ពាន់លានរៀលក្នុងមួយថ្ងៃ ឬ១២៦លានដុល្លារក្នុងមួយឆ្នាំ ដើម្បីលុបបំបាត់ភាពក្រីក្រតាមរយៈការផ្ទេរថវិការទៅដល់ជនក្រីក្រតែម្តង។ ប្រសិនណាបើពលរដ្ឋក្រីក្រទទួលបាននូវអត្រាកំណើនសេដ្ឋកិច្ចត្រឹមតែមួយ

[៣៧]គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៥៧

ភាគរយក្នុងមួយឆ្នាំ យើងត្រូវចំណាយពេលចំនួន ២០ឆ្នាំ ដើម្បីអោយអ្នកក្រីក្រជាមធ្យមអាចចាកផុតពីភាពក្រីក្រ គោកយ៉ាកបាន។ ប៉ុន្តែបើអត្រាកំណើនមានចំនួន ៤% ក្នុងមួយឆ្នាំ យើងត្រូវចំណាយពេលតិចជាង ៦ឆ្នាំ ដើម្បីរំដោះអ្នកក្រីក្រជាមធ្យមអាចចាកផុតពីភាពក្រីក្រ។ ដូច្នេះ កំណើនសេដ្ឋកិច្ច ដែលលើកស្ទួយកម្រិតប្រើប្រាស់ពិតរបស់អ្នកក្រីក្រអាចមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការលុបបំបាត់ភាពក្រីក្រ។ កម្មវិធីដែលមានគោលដៅច្បាស់លាស់មានសារៈសំខាន់ណាស់ក្នុងការផ្តល់អោយនូវអត្ថប្រយោជន៍ចំពោះអ្នកក្រីក្រ តាមរយៈការកែលម្អនូវធនធានមនុស្ស និងធនធានរូបវន្តរបស់ពួកគេ និងតាមរយៈការធ្វើអន្តរាគមន៍ ដែលធ្វើអោយប្រាក់ចំណូលដែលពួកគេទទួលបានពីធនធានទាំងនោះមានការកើនឡើង។

កម្មវិធីសុវត្ថិភាពសង្គមរបស់រាជរដ្ឋាភិបាលនៅមានកម្រិតនៅឡើយ ទាំងជាទំហំ ទាំងជាផលប៉ះពាល់ទៅលើជនក្រីក្រ។ ថវិកាសម្រាប់ធ្វើអន្តរាគមន៍លើវិស័យសង្គមកិច្ចរបស់រាជរដ្ឋាភិបាល មានមិនគ្រប់គ្រាន់សម្រាប់បំពេញសេចក្តីត្រូវការដែលចេះតែកើនឡើង និងដើម្បីធានាសន្តិសុខសង្គមរបស់ប្រជាជននោះទេ។ នៅក្នុងឆ្នាំ១៩៩៩ ថវិកាអន្តរាគន៍លើវិស័យសង្គមកិច្ចមានចំនួន ១០៣ាន់លានរៀល(២៧លានដុល្លារ ឬប្រហែល ០,៩% នៃផលិតផលក្នុងស្រុកសរុប)។ ម្យ៉ាងវិញទៀត សមត្ថភាពស្ថាប័នក្នុងការអនុវត្តន៍ និងសមត្ថភាពធនធានមនុស្សនៅមានកម្រិតនៅឡើយ ដែលក្នុងផ្នែកណាមួយនោះ គឺបណ្តាលមកពីគ្មានការលើកទឹកចិត្ត។ ក៏ប៉ុន្តែថវិកាទាំងនេះភាគច្រើនត្រូវបានប្រើប្រាស់ដើម្បីជួយឧបត្ថម្ភដល់មន្ត្រីរាជការ។ ក្រសួងសង្គមកិច្ចបណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានដែលទទួលខុសត្រូវចំពោះក្រុមពលរដ្ឋដែលងាយទទួលការរងគ្រោះបានប្រើប្រាស់ថវិកា ដ៏តិចតួចស្តួចស្តើងរបស់ខ្លួន ដើម្បីចំណាយលើនីតិសម្បទាននៃប្រជាជនភៀសសឹក។ គណបក្សនយោបាយ និងអ្នកនយោបាយខ្លះក៏បានចូលរួមចំណែក ក្នុងការលើកស្ទួយស្ថានភាពរបស់អ្នកក្រីក្រដែរ ដូច្នេះជនក្រីក្រ និងជនងាយរងគ្រោះពឹងផ្អែកលើការផ្តល់ថវិកាក្រៅផ្លូវការ ពីភាគបាទក្រហមកម្ពុជាពីអ្នកផ្តល់ជំនួយតាមរយៈកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាល និងពឹងលើការដោះស្រាយផ្ទាល់ខ្លួន[៣៨]។

រួមជាមួយអ្នកផ្តល់ជំនួយនានាដូចជា កម្មវិធីស្បៀងអាហារពិភពលោក រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ បានដំណើរការគម្រោងបង្កើតការងារ និងប្រាក់ចំណូលដែលផ្អែកលើកម្មវិធីស្បៀងពលកម្ម។ កម្មវិធីនេះ មានការពាក់ព័ន្ធជាមួយនឹងសកម្មភាពឧបត្ថម្ភខាងផ្នែកសង្គមកិច្ចនៅតាមឃុំ ដោយតម្រង់ទិសឆ្ពោះទៅរកជនដែលងាយរងគ្រោះជាងគេ។ នៅក្នុងខណៈដែលកម្មវិធីស្បៀងពលកម្មជួយស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ការធ្វើអន្តរាគមន៍ខាងផ្នែកសង្គមកិច្ចជួយលើស្ទួយការអប់រំថ្នាក់បឋមជាមូលដ្ឋាន និងការអប់រំក្រៅផ្លូវការ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការលើកកម្ពស់សុខភាព និងជួយក្រុមដែលងាយរងគ្រោះដោយរួមទាំងក្មេងនៅតាមចិញ្ចើមថ្នល់ជនពិការ និងកុមារកំព្រាផង។

---

[៣៨] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៥៩

ឃ-កិច្ចការពារបរិស្ថាន

កិច្ចខិតខំប្រឹងប្រែងការពារបរិស្ថាន ត្រូវបានធ្វើឡើងតាមគោលការណ៍ដូចតទៅៈ ១-ទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ និងការប្រើប្រាស់ធនធានបរិស្ថាន ២-សារៈសំខាន់នៃសហគមន៍ៈ ត្រូវមានយន្តការធ្វើអន្តរាគមន៍ដើម្បីបណ្តុះបណ្តាលជំនាញសមស្របដល់សហគមន៍មូលដ្ឋាន ដើម្បីគ្រប់គ្រងធនធានធម្មជាតិ និងត្រូវរៀបចំអោយមានការថែរក្សា និងប្រើប្រាស់ចំណេះដឹងអេកូឡូស៊ីជាប្រពៃណីរបស់ស្ត្រី ដោយរួមមានចំណេះដឹងអេកូឡូស៊ីជាប្រពៃណីរបស់ស្ត្រីជនជាតិនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការធ្វើអភិរក្សដីរចម្រុះផ្សេងៗទៀត ៣-តម្រូវការសម្រាប់ការកសាងសមត្ថភាពស្ថាប័ន និង៤-ការទទួលស្គាល់នូវសារៈសំខាន់ នៃការអនុវត្តន៍ផែនការបរិស្ថានចម្រុះ។ ក្នុងរយៈពេលខ្លី និងក្នុងរយៈពេលមធ្យម វិធានចម្បងក្នុងកិច្ចការពារបរិស្ថាន គឺៈ ការអភិវឌ្ឍន៍ និងកិច្ចការពារតំបន់ឆ្នេរសមុទ្រ ការពង្រឹងការគ្រប់គ្រងព្រៃឈើអោយប្រើសើរជាមុន រួមទាំងកិច្ចការពារទីជំរាលសំខាន់ៗផង ការគ្រប់គ្រងការរិចរិលដី ការគ្រប់គ្រង ការបំពុលទីក្រុង និងការបំពុលដោយឧស្សាហកម្ម ការពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការកែលម្អការគ្រប់គ្រង ប្រព័ន្ធអេកូ-ឡូស៊ីបឹងទន្លេសាប និងការកសាងសមត្ថភាពក្នុងការកសាងផែនការបរិស្ថាន ការគ្រប់គ្រងធនធាន នៃបណ្តាស្ថាប័នដែលពាក់ព័ន្ធ និងពង្រឹងការកសាងសហគមន៍នានា រួមមានសហគមន៍ព្រៃឈើ សហគមន៍អ្នកនេសាទ សហ-គមន៍អ្នកប្រើប្រាស់ទឹក និងសហគមន៍ថែរទាំផ្លូវលំ។

ង-ការដោះមីន

អាទិភាពដ៏ចម្បងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងសុវត្ថិភាពរបស់ប្រជាជនកម្ពុជា គឺត្រូវធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លារួមគ្នា ដោយសហការជាមួយសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីបោសសំអាតមីននៅក្នុងតំបន់ដីកសិកម្ម លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះថ្នាក់របស់មីន បណ្តុះបណ្តាលស្តីពីវិធីដោះមីន និងបង្កើនការជួយឧបត្ថម្ភដល់ជនរងគ្រោះដោយសារមីន។ ចាប់តាំងពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពមីននៅក្នុងឆ្នាំ១៩៩២មកហើយ ដោះបានមីនប្រឆាំងមនុស្សចំនួន១០៥.៦៩៣គ្រាប់ មីនប្រឆាំងរថក្រោះចំនួន១.៦៩៦គ្រាប់ និងគ្រាប់មិនទាន់ផ្ទុះចំនួន ៥៣១.៧២៧គ្រាប់ ព្រមទាំងបោសសំអាតផ្ទៃដីបានចំនួន ៧៣ គីឡូម៉ែត្រការ៉េ។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប្រឹងប្រែងយ៉ាងខ្លាំងដើម្បីរៀបចំឡើងវិញនូវមជ្ឈមណ្ឌលសម្មភាពមីន និងដើម្បីកៀងគរ ការឧបត្ថម្ភរបស់អ្នកផ្តល់ជំនួយ ដើម្បីអនុវត្តសកម្មភាពកំចាត់មីន[៣៥]។

២.៣.៤ ការពង្រឹងសមត្ថភាព

រាជរដ្ឋាភិបាលត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវា និងការបន្តបង្កើនសមត្ថភាពរបស់ស្ថាប័នដែលមានការពាក់ព័ន្ធ។ ប្រការនេះតម្រូវអោយមានការយកចិត្តទុកដាក់លើគុណភាព និងលទ្ធភាពផ្តល់សេវាជូន

[៣៥] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៦០

ពលរដ្ឋក្រីក្រ និងលើឧត្តមភាពប្រៀបធៀបរបស់រាជរដ្ឋាភិបាលរបស់អង្គការមិនមែនរដ្ឋាភិបាល និងរបស់ផ្នែកឯកជនដែលអ្នកផ្តល់សេវាទាំងនេះ។ ជាពិសេសកិច្ចដំណើរការនេះត្រូវបានផ្តោតលើតួនាទីរបស់រដ្ឋាភិបាលបញ្ហាប្រសិទ្ធភាព និងបញ្ហាពាក់ព័ន្ធដទៃទៀត ដូចជា កម្រិតនៃការធ្វើវិមជ្ឈការ និងការអនុវត្តន៍កម្មវិធីកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាលជាដើម។

ការបង្កើនចំណាយថវិកាតែមួយមុខនោះនឹងមិននាំអោយមានការកាត់បន្ថយភាពក្រីក្រឡើយ។ ដូច្នេះរដ្ឋាភិបាលបានចាត់វិធានការផ្សេងៗ ដើម្បីធានាការផ្លាស់ប្តូរជាគុណភាព តាមរយៈការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យមុនចំណាយ និងការពង្រឹងសវនកម្មក្រោយចំណាយ ដើម្បីជម្រុញការអភិវឌ្ឍន៍អោយបានដល់ភូមិ-ឃុំ។ វិធានការនេះតម្រូវអោយមាននូវការកាត់បន្ថយភាពនីតិវិធីក្នុងការបើកផ្តល់ថវិកា និងផ្តល់អោយអង្គភាពចំណាយនៅថ្នាក់ខេត្ត និងថ្នាក់កណ្តាលនូវលទ្ធភាពក្នុងការគ្រប់គ្រងថវិកាផ្ទាល់របស់ខ្លួន ដោយកែប្រែអង្គភាពទាំងនេះអោយទៅជាមជ្ឈមណ្ឌលគ្រប់គ្រងថវិកា។

ក-គោលនយោបាយសុខាភិបាល[៤០]

ការវិនិយោគកាន់តែច្រើនទៅលើសេវាសុខាភិបាល ដើម្បីកាត់បន្ថយជំងឺ មិនមែនគោលដៅត្រឹមតែការកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ដោយសារវាបានកាត់បន្ថយចំនួនមនុស្សមានជំងឺ និងអ្នកដែលមិនអាចធ្វើការបាន ប៉ុន្តែសង្គមថែមទាំងទទួលបាននូវអត្ថប្រយោជន៍ពីការចុះថយអត្រានៃជំងឺឆ្លងថែមទាំងផង។ ក្រសួងសុខាភិបាលបានស្នើរឡើងនូវយុទ្ធសាស្ត្រសុខាភិបាលដូចតទៅ:

១-បង្កើនសុខមាលភាពរបស់ស្ត្រី និងកុមារ តាមរយៈការផ្តល់ជូនសេវាសុខភាពជាមូលដ្ឋានចំពោះគ្រប់ស្ត្រីទាំងអស់។

២-កាត់បន្ថយអត្រាជំងឺឆ្លងផ្សេងៗដូចជា ជំងឺគ្រុនចាញ់ កញ្ជ្រិល របេង រាគរូស ជំងឺប្រព័ន្ធដកដង្ហើម និងជំងឺកាមរោគ ជាពិសេស HIV/AIDS។

៣-បង្កើនអត្រាគ្របដណ្តប់នៃសេវាដែលមានគុណភាពល្អ។

៤-បង្កើនចំណេះដឹងរបស់មន្ត្រីសុខាភិបាល។

៥-ផ្គត់ផ្គង់ថ្នាំសង្កូវ និងសម្ភារៈបរិក្ខារផ្សេងៗ។

៦-ពង្រឹងសមត្ថភាពរបស់មន្ទីរពេទ្យបង្អែក តាមរយៈការប្រើប្រាស់បច្ចេកទេសគ្រប់គ្រង និងបច្ចេកវិទ្យាទំនើប។

៧-ជួយសម្រួលការអភិវឌ្ឍន៍វិស័យឯកជន។

៨-បង្កើនការយល់ដឹងជាសាធារណៈអំពីអនាម័យ។

---

[៤០] ក្រសួងសុខាភិបាល(១៩៩៩) ស្ថានភាពសុខាភិបាលក្នុងឆ្នាំ១៩៩៨ និងគោលដៅសកម្មភាពសុខាភិបាល ២០០១-២០០៣

សកម្មភាពជាអាទិភាពក្នុងការផ្តល់សេវាសុខាភិបាលចំពោះពលរដ្ឋក្រីក្រ ដែលក្រសួងសុខាភិបាលបាននឹងកំពុងដាក់អោយដំណើរការ ឬបានស្នើឡើងគឺ: ១-ការផ្តល់នូវសេវាសុខភាពជាមូលដ្ឋានចម្រុះជូនដល់ប្រជាជនទាំងអស់ដោយសង្កត់ធ្ងន់ទៅលើកុមារ និងស្ត្រីភេទដែលរស់នៅក្នុងតំបន់ដែលពុំមានសេវាគ្រប់គ្រាន់ ២-ការតម្រង់ការចំណាយលើសេវាសុខភាពសាធារណៈអោយកាន់តែចំទិសដៅល្អ ដើម្បីជាគុណប្រយោជន៍ដល់អ្នកក្រីក្រ និងការបង្កើតឡើងជាផ្លូវការនូវប្រព័ន្ធបង់កម្រៃ ដែលមានគោលការណ៍មិនយកកម្រៃពីអ្នកក្រីក្រ ៣-ការអភិវឌ្ឍន៍កម្មវិធីជាប្រចាំក្នុងការផ្តល់ថ្នាំសង្កូវសំខាន់ៗ ដើម្បីធានាអោយប្រជាជនទាំងអស់ជាពិសេសប្រជាជនក្រីក្រអាចទទួលបាននូវថ្នាំសង្កូវសំខាន់ៗ។ ក្នុងក្របខ័ណ្ឌនៃកម្មវិធីសកម្មភាពអាទិភាព(PAP) ចាប់តាំងពីខែឧសភា ឆ្នាំ ២០០០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយរួមជាមួយក្រសួងសុខាភិបាល បានដាក់អោយដំណើរការនូវការធ្វើវិមជ្ឈការក្នុងការគ្រប់គ្រងថវិកា ដោយផ្តល់អោយអ្នកគ្រប់គ្រងថវិកានៅតាមថ្នាក់ខេត្តស្រុកនូវភាពទន់ភ្លន់ច្រើនក្នុងការងារលទ្ធកម្ម។ ការបែងចែកថវិកាតាមមជ្ឈមណ្ឌលគ្រប់គ្រងថវិកា និងការដាក់ចេញអោយអនុវត្តនូវនីតិវិធីថវិកាថ្មីមានគោលដៅធានាអោយថវិកាធ្លាក់ទៅដល់មូលដ្ឋាន បង្កើនល្បឿននៃការបើកផ្តល់ថវិកា និងផ្តល់លទ្ធភាពអោយអ្នកគ្រប់គ្រងថវិកាអាចធ្វើផែនការជាមុន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង សុខាភិបាលបានរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុជូនមន្ត្រីនៅក្នុងខេត្តចំនួន ៧ ដែលអនុវត្តផែនការសកម្មភាពជាអាទិភាពចាប់ពីឆ្នាំ២០០០ តទៅ[៤១]។

ការរីករាលដាលនៃ HIV/AIDS នៅក្នុងប្រទេសកម្ពុជា គឺជាប្រការមួយដែលគួរអោយយកចិត្តទុកដាក់បំផុត ដែលអាចគំរាមកំហែងដល់ចីរភាពនៃការអភិវឌ្ឍន៍ប្រទេស។ តាមការប៉ាន់ស្មានមានប្រជាជនចំនួន ១៨០.០០០នាក់ ឬ៣,៧% នៃប្រជាជនពេញវ័យ(មានអាយុពី១៥-៤៩)បានត្រូវឆ្លងមេរោគ HIV។ បន្ទុកដ៏ធ្ងន់នៃជំងឺ និងមរណៈភាពដោយជំងឺ AIAS បានបង្កើនទំងន់ភាពក្រីក្រ និងបំណុល។ ឆ្លើយតបទៅនឹងការរីករាលដាលយ៉ាងឆាប់រហ័សនៃ HIV/AIDS រាជរដ្ឋាភិបាលបានអនុម័តនូវផែនការជាតិជាយុទ្ធសាស្ត្រស្តីពីការបង្ការ និងការត្រួតពិនិត្យជំងឺអេដស៍។ យុទ្ធសាស្ត្រនេះផ្តោតទៅលើការបង្ការ និងការអប់រំជាសធារណៈដោយសង្កត់ធ្ងន់លើការប្រើប្រាស់ស្រោមអនាម័យ។ ផែនការនេះទាមទារអោយមានការពង្រឹងតួនាទីដ៏សំខាន់របស់អាជ្ញាធរមូលដ្ឋាននិងព្រះសង្ឃក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីជំងឺឆ្លងនេះ។ ប៉ុន្តែដោយសាររដ្ឋាភិបាលបានជួបប្រទះនឹងកង្វះខាតថវិកាប្រហែល ៨០% សម្រាប់អនុវត្តកម្មវិធីនេះអោយមានប្រសិទ្ធភាពទូទាំងប្រទេសក្នុងគោលដៅត្រួតពិនិត្យ HIV/AIDS ក្នុងគ្រប់រូបភាព។ ទន្ទឹមនឹងនេះ ការសម្របសម្រួល ដើម្បីរៀបចំកម្មវិធី និងអនុវត្តកម្មវិធីបង្ការមេរោគ HIV/AIDS អោយមានប្រសិទ្ធភាពក៏នៅមានកម្រិតនៅឡើយ។ អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវសេវានានាជាច្រើនមានទាំងការអប់រំអំពីរបៀបចម្លង និងការឧបត្ថម្ភផ្នែកសង្គមកិច្ច ជាពិសេសក្នុងការចូលទៅដល់ប្រជាជនដែលរស់នៅក្នុងទីជនបទ ជាពិសេស

[៤១] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៦២

ស្ត្រី និងក្រុមជនងាយរងគ្រោះ។ យើងត្រូវចាត់វិធានការជាបន្ទាន់ក្នុងការពង្រីក និងបង្កើនកម្មវិធី HIV/AIDS ជាពិសេសនៅទីជនបទ និងគ្រួសារ ដែលស្ត្រីជាមេគ្រួសារ និងកុមារ ដែលបានឆ្លងមេរោគ HIV/AIDS។

ខ-ទឹក និងអនាម័យ

រដ្ឋាភិបាលកំពុងត្រៀមបង្កើតក្របខ័ណ្ឌគោលនយោបាយក្នុងការផ្គត់ផ្គង់ទឹក និងអនាម័យ ដែលនឹងផ្តោតទៅលើស្ថិយភាពហិរញ្ញវត្ថុ ការតំឡើងថ្លៃ ដើម្បីចាប់ផ្តើមប្រមូលកម្រៃការចូលរួមពីផ្នែកឯកជន ការសម្របសម្រួលជាមួយអ្នកផ្តល់ជំនួយ ការបែងចែកធនធានទឹក និងការទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋាន។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ចំពោះការអភិវឌ្ឍន៍វិស័យនេះ ដើម្បីបង្កើន និងលើកកម្ពស់សុខភាពរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រនៅជនបទ។ ទន្ទឹមនឹងនេះរដ្ឋបានផ្តោតការយកចិត្តដាក់ទៅលើការប្រើប្រាស់អោយកាន់តែប្រសើរឡើង នូវធនធានទឹកដែលមាននាពេលបច្ចុប្បន្នពង្រឹងសមត្ថភាពស្ថាប័ន បង្កើនបរិមាណផលិតកម្មរបស់រោងចក្រផលិតទឹកស្អាត ដែលមានស្រាប់អោយដល់កម្រិតនៃសមត្ថភាពផលិតរបស់រោងចក្រកែលម្អសកម្មភាពផលិតកម្ម និងពង្រីកបណ្តាញទឹកអោយបានដល់អ្នកប្រើប្រាស់ចុងក្រោយ។ យើងនឹងពង្រឹងថែមទៀតនូវគោលការណ៍ស្ថិយភាពគ្រប់គ្រង និងស្ថិយភាពហិរញ្ញវត្ថុ ដើម្បីអនុញ្ញាតអោយរោងចក្រទាំងនេះអាចធ្វើហិរញ្ញប្បទានលើការថែរទាំ និងការវិនិយោគដោយខ្លួនឯងបាន។ រដ្ឋាភិបាលមានគោលនយោបាយបង្កើនចំនួនអណ្តូងទឹកនៅជនបទដោយប្រើប្រាស់ថវិការដ្ឋ និងការជួយឧបត្ថម្ភរបស់អ្នកផ្តល់ជំនួយដោយសង្កត់ធ្ងន់លើការចូលរួមយ៉ាងសកម្មពីអ្នកទទួលផលនៅតាមមូលដ្ឋាននៅក្នុងកិច្ចដំណើរការ និងការថែរទាំជាពិសេសស្ត្រីដែលជាអ្នកទៅដងទឹក និងប្រើប្រាស់ទឹក។

គ-គោលនយោបាយអប់រំ[៤២]

គោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យអប់រំ គឺការអនុវត្តន៍នូវគោលការណ៍ "**អប់រំសម្រាប់ទាំងអស់គ្នា**" ត្រឹមកម្រិតថ្នាក់ទី៩ នៅក្នុងឆ្នាំ២០១០ ដោយធានាអោយបានថា សិស្សទាំងអស់អាចចូលរៀនបានដោយស្មើភាពគ្នា និងប្រកបដោយគុណភាពខ្ពស់ ជាពិសេសក្នុងចំណោមកុមារី។ រដ្ឋនឹងជម្រុញអោយមានការស្មើភាពគ្នារវាងកុមារ និងកុមារី និងធានាយ៉ាងណាអោយមាតាបិតាគិតគូរពីកូនស្រីអោយបានស្មើនឹងកូនប្រុសដែរ។ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពអោយសិស្ស និងនិស្សិត ដែលក្រីក្រជាងគេបានចូលរៀនបន្តចាប់ពីបឋមសិក្សាឡើងទៅ ទន្ទឹមនឹងការអនុវត្តន៍គោលនយោបាយអោយផ្នែកឯកជនជួយអភិវឌ្ឍន៍វិស័យអប់រំ។ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ទៅលើការពង្រឹងក្របខ័ណ្ឌគតិយុត្ត និងនិយ័តកម្ម ដើម្បីធានានូវគុណភាពអប់រំ និងត្រួតពិនិត្យតាមដានលទ្ធផល ដែលកម្រិតសិក្សានីមួយៗសម្រេចបាន។ យើងទទួលស្គាល់ថា ចំណាយថវិកាសរុបមិនគ្រប់គ្រាន់ ដើម្បីសម្រេចអោយបានតាមគោលដៅនយោបាយទាំងអស់ ដែលដាក់ចេញឡើយ។ ក៏

[៤២] ក្រសួងអប់រំ យុវជន និងកីឡា(២០០០) សមធម៌ ប្រសិទ្ធភាព និងគុណភាពនៃការធ្វើហិរញ្ញប្បទានក្នុងវិស័យអប់រំ: របៀបវារៈនៃគោលនយោបាយ ដែលស្នើរឡើងដើម្បីសកម្មភាព។

ប៉ុន្តែរាជរដ្ឋាភិបាលមានគម្រោងបង្កើនកញ្ចប់ថវិកាអប់រំជាទ្វេក្នុងរយៈពេល ៣ឆ្នាំខាងមុខ ដើម្បីធានាអោយបាននូវការអនុវត្តន៍គោលនយោបាយនេះ។

ការបង្កើនចំណាយថវិកាសម្រាប់វិស័យអប់រំ និងបង្ហាញយ៉ាងច្បាស់នូវការប្រកាន់យកគោលនយោបាយនិងយុទ្ធសាស្ត្រគាំពារជនក្រីក្រ។ ឧទាហរណ៍ អាទិភាពជាយុទ្ធសាស្ត្រគន្លឹះ គឺការកាត់បន្ថយចំណាយដោយផ្ទាល់និងដោយប្រយោលរបស់មាតាបិតាសិស្ស(ដែលជារបាំងមួយយ៉ាងធំ ដែលរារាំងមិនអោយសិស្សក្រីក្ររៀនបានវែងឆ្ងាយ) តាមរយៈការបង្កើនប្រាក់ខែរបស់គ្រូបង្រៀនអោយបានសមស្របនឹងការងារដែលបានបំពេញ។ ធ្វើដូច្នេះ យើងនឹងអាចលុបបំបាត់នូវកម្រៃក្រៅផ្លូវការពីមាតាបិតាសិស្ស។ យុទ្ធសាស្ត្រមួយទៀតដែលត្រូវអនុវត្តន៍ជាមួយនេះ គឺត្រូវបង្កើនថវិកាសម្រាប់កិច្ចដំណើរការរបស់សាលារៀនដោយអនុញ្ញាតអោយថ្នាក់ខេត្ត ស្រុក និងសាលារៀនគ្រប់គ្រងដោយផ្ទាល់នូវថវិកានេះ។ យុទ្ធសាស្ត្រទាំងនេះនឹងធានាបានចំនួនគ្រូ និងសិស្សកាន់តែកើនឡើង និងបង្កើនគុណភាពអប់រំនៅពេលដែលសាលារៀនមានសម្ភារៈសិក្សាគ្រប់គ្រាន់[៤៣]។

២.៣.៥ ការផ្តល់ឆ្ងវសិទ្ធិអំណាច

ក-ប្រសិទ្ធិភាពនៃការគ្រប់គ្រង

ក្នុងរយៈពេលខ្លី និងមធ្យម រាជរដ្ឋាភិបាលនឹងអនុវត្តសកម្មភាពជាអាទិភាពដូចតទៅ:

១-បង្កើតកន្សោមអាទិភាពមន្ត្រីរាជការនៅតាមក្រសួង/ស្ថាប័ន ដើម្បីបង្កើនគុណភាពក្នុងការផ្តល់សេវាសាធារណៈ និងបង្កើនផលិតភាព។

២-ដាក់អោយអនុវត្តនូវប្រព័ន្ធរដ្ឋបាលតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីអោយប្រជាពលរដ្ឋកាន់តែច្រើនអាចមានលទ្ធភាពទទួលបាននូវសេវាសាធារណៈសំខាន់ៗ។

៣-បង្កើនល្បឿនកំណែទម្រង់រដ្ឋ តាមរយៈការអនុវត្តន៍ផែនការសកម្មភាពក្នុងការកាត់រំសាយកងទ័ពកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់សារពើពន្ធ ក្នុងគោលដៅពង្រឹងនីតិរដ្ឋ និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចទីផ្សារ។

៤-អនុវត្តន៍អោយស៊ីជម្រៅនូវកម្មវិធីកំណែទម្រង់ក្នុងវិស័យយុត្តិធម៌ និងរៀបចំកម្មវិធីជាតិសម្រាប់កំណែទម្រង់តុលាការ។

៥-អនុវត្តវិធានការនានា ដែលមានចែងនៅក្នុងផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលកម្ពុជា យល់ឃើញយ៉ាងច្បាស់ថា អភិបាលកិច្ចល្អ គឺជាលក្ខខ័ណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងយុត្តិធម៌សង្គមប្រកបដោយចីរភាព។ រាជរដ្ឋាភិបាលបានរៀបចំនូវ

[៤៣] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៦៤

ផែនការសកម្មភាពអភិបាលកិច្ចល្អ(Governance Action Plan-GAP) សម្រាប់ពិភាក្សានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់(CG) ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២៥ ដល់ ២៦ ខែឧសភា ឆ្នាំ២០០០ នៅទីក្រុងប៉ារីស។

ផែនការសកម្មភាពអភិបាលកិច្ច(GAP) បានដាក់ចេញនូវវិធានការកំណែទម្រង់អភិបាលកិច្ចពីប្រភេទ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍នៃប្រទេសកម្ពុជាក្នុងរយៈពេលខ្លី និងក្នុងរយៈពេលមធ្យម។ កំណែទម្រងអភិបាលកិច្ចប្រភេទទីមួយ គឺបញ្ហាដែលពាក់ព័ន្ធសំខាន់ៗចំនួន បួន យ៉ាងដូចជា ១-កំណែទម្រង់ច្បាប់ និងតុលាការៈ ការកែលម្អនីតិវិធីច្បាប់ ការបង្កើននូវការផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិ ការបង្កើតនូវក្របខ័ណ្ឌគតិយុត្តសម្រាប់ផ្នែកឯកជន ការអភិវឌ្ឍន៍ធនធានមនុស្សសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធការពង្រឹងភាពសុចរិតរបស់តុលាការ ការដោះស្រាយនៅសេចក្តីត្រូវការរបស់ផ្នែកឯកជន ក្នុងការធ្វើអាជ្ញាកណ្តាលនៃវិវាទផ្នែកពាណិជ្ជកម្ម ២-កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកាត់បន្ថយនីតិវិធីត្រួតពិនិត្យគយ ការប្រយុទ្ធនឹងអំពើរត់ពន្ធ ការបង្កើតនូវរដ្ឋបាលគយទំនើប ការកែលម្អនីតិវិធីបង្វិលសងអាករលើតម្លៃបន្ថែម ការបង្កើតក្របខ័ណ្ឌ នីយ័តភាពនៃពន្ធលើប្រាក់ចំណេញ និងការធ្វើកំណែទម្រង់យ៉ាងគ្រប់ជ្រុងជ្រោយ នៃប្រព័ន្ធលើកទឹកចិត្តផ្នែកវិនិយោគ ការពង្រឹងប្រព័ន្ធថវិកា ការកែលម្អលទ្ធផលនៃអង្គភាពចំណាយ និងការពង្រឹងប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ៣-កំណែទម្រង់រដ្ឋបាលសាធារណៈ : ការធ្វើវិចារណកម្មនៃរចនាសម្ព័ន្ធ ការងារការពិនិត្យឡើងវិញនូវប្រាក់បំណាច់ និងប្រព័ន្ធគ្រប់គ្រងការលើកម្ពស់នូវផលិតភាព និងការលើកទឹកចិត្តការពង្រឹងនូវតម្លាភាព និងការចូលរួមការអនុវត្តន៍អោយប្រទាក់ប្រទ្បារវាងវិមជ្ឈការរដ្ឋបាល និងវិមជ្ឈការហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ខេត្ត/ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ៤-ការប្រឆាំងអំពើពុករលួយៈ ការរៀបចំអោយមានក្រមសីលធម៌ ការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការពង្រឹងការអនុវត្តន៍អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ ការលើកស្ទួយការអនុវត្តច្បាប់ និងការត្រួតពិនិត្យ។ រាជរដ្ឋាភិបាលទទួលស្គាល់ថាប្រសិនបើគ្មានវិធានការយ៉ាងម៉ឺងម៉ាត់ក្នុងផ្នែកខាងលើនោះទេ គុណធម៌ជាមូលដ្ឋាន នៃអភិបាលកិច្ចល្អនឹងមិនអាចចាក់ឬសជាប់នៅក្នុងប្រទេសកម្ពុជាបានឡើយ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកនូវបញ្ហាគោលនយោបាយសំខាន់ៗពីរ ដែលជាស្នូលនៃកំណែទម្រង់អភិបាលកិច្ចប្រភេទទីពីរៈ

ទី១-ការគ្រប់គ្រងធនធានធម្មជាតិ រួមទាំងការគ្រប់គ្រងដីធ្លី និងការគ្រប់គ្រងព្រៃឈើ។ ដំណោះស្រាយប្រកបដោយយុត្តិធម៌នូវជម្លោះដីធ្លី មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការធានានូវសន្តិភាពក្នុងសង្គម និងចីរភាពបរិស្ថាន។ កត្តាទាំងពីរនេះ គឺជាមូលដ្ឋានសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។

ទី២-ការកាត់រំសាយកងកម្លាំងប្រដាប់អាវុធ។

ខ-ការអនុវត្តន៍ច្បាប់

អាទិភាពរបស់រាជរដ្ឋាភិបាល គឺធ្វើការរៀបចំនូវវិស័យយុត្តិធម៌ និងប្រព័ន្ធតុលាការមួយ ដែលមិនលំអៀង និងមានប្រសិទ្ធភាព។ បញ្ហាទាំងអស់នេះពាក់ព័ន្ធទៅនឹងការធានាអោយបាននូវសន្តិសុខផ្ទាល់ខ្លួន ដោយគ្មានអំពើហិង្សា និងការគំរាមកំហែងទាំងនៅក្នុង និងក្រៅគ្រួសារ។ ទន្ទឹមនឹងនេះត្រូវបង្កលក្ខណៈអោយប្រជាពលរដ្ឋមានសិទ្ធិក្នុងការស្វែងរកយុត្តិធម៌ ការការពារកម្មសិទ្ធិផ្ទាល់ខ្លួន និងអនុវត្តន៍អោយបានត្រឹមត្រូវនូវកិច្ចសន្យា។ ប្រការទាំងនេះត្រូវទាមទារអោយមានវិសោធនកម្មលើច្បាប់ និងបទបញ្ញត្តិនានា ដែលអាចធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់ជនក្រីក្រ។ វិធានការដើម្បីដោះស្រាយបញ្ហាទាំងនេះរួមមាន បញ្ហាកំណែទម្រង់ដីធ្លី ការកាន់កាប់ដីធ្លី លទ្ធភាពទទួលយកដីមកប្រើប្រាស់សមភាពរវាងបុរស និងស្ត្រី និងនីតិរដ្ឋ។ ក៏ប៉ុន្តែសញ្ញាណ "កម្មសិទ្ធិដីធ្លី" គឺជារឿងមួយដែលពិបាកស្មុគស្មាញណាស់ ជាពិសេសនៅទីជនបទ។ ដូច្នេះ ទន្ទឹមនឹងការធ្វើវិសោធនកម្មលើច្បាប់នៃកម្មសិទ្ធិដីធ្លី។ ម្យ៉ាងវិញទៀត យើងត្រូវបង្កើតនូវក្របខ័ណ្ឌអោយបានគ្រប់ជ្រុងជ្រោយ និងមានសង្គតភាពដើម្បីអនុម័តច្បាប់ និងបទដ្ឋានដែលចាំបាច់។ ការបង្កលទ្ធភាពអោយជនក្រីក្របានប្រើប្រាស់ដី គឺជាការចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងក្នុងការបង្កើនចំណូល។ ទន្ទឹមនឹងការអនុវត្តន៍នូវគោលនយោបាយដីធ្លី ដែលបានគូសបញ្ជាក់ខាងលើរាជរដ្ឋាភិបាលនឹងធ្វើអន្តរាគមន៍ជាអាទិភាពក្នុងការពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រង និងអនុវត្តច្បាប់ និងរៀបចំនូវយន្តការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពខ្ពស់ ជាអាទិ៍ការកំណត់នូវស្ថានភាពរបស់ពលរដ្ឋ ដែលគ្មានដីធ្លី ការពង្រីកដីកសិកម្មតាមរយៈការរានដីការបង្ការនូវការរំលោភយកដីខុសច្បាប់ ការវាតទី និងរឹបអូសដីប្រជាជនដោយប្រើអំណាច និងការប្រមូលផ្តុំដីដ៏ច្រើននៅក្នុងដៃម្ចាស់ដីមួយក្តាប់តូច។ រាជរដ្ឋាភិបាលមានគោលនយោបាយពង្រឹងរដ្ឋបាលសុរិយោដី ដើម្បីធានាអោយបាននូវការអនុម័ត និងការអនុវត្តន៍អោយបានម៉ឺងម៉ាត់នូវច្បាប់ភូមិបាលថ្មី ដោយរៀបចំនូវយន្តការ និងប្រព័ន្ធផ្តល់កម្មសិទ្ធិ និងចុះបញ្ជីដីដែលមានតម្លាភាព ពង្រឹងសមត្ថភាពស្ថាប័ននៃអង្គភាពសុរិយោដី និងធានាអោយបាននូវកិច្ចការពារទ្រព្យសម្បត្តិរដ្ឋ។ ម្យ៉ាងវិញទៀត ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ យើងត្រូវយកចិត្តទុកដាក់ដល់ទិដ្ឋភាពផ្សេងៗ ដែលអាចមានផលប៉ះពាល់នាពេលអនាគតទៅលើស្ត្រី។ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ដោយគួបផ្សំនឹងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងជម្រុញការអភិវឌ្ឍន៍វិស័យឯកជនអោយទៅមុនយ៉ាងឆាប់រហ័ស។

គ-ការបង្កើតបរិស្ថានអំណោយផលសម្រាប់អង្គការក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាលអាចសហការជាមួយរាជរដ្ឋាភិបាល នៅក្នុងគ្រប់កម្រិតទាំងអស់ជាដៃគូរនៃការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ។ ដើម្បីអាចសម្រេចគោលដៅនេះបាន យើងត្រូវបង្កើតឡើងនូវក្របខ័ណ្ឌគាំទ្រមួយ ដែលមានតម្លាភាពសម្រាប់សម្របសម្រួលកិច្ចសហការនេះ។ សេចក្តីព្រាងច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល ត្រូវកំណត់ទិសដៅអោយបានច្បាស់លាស់ ដើម្បីអោយអង្គការក្រៅរដ្ឋាភិបាលអាចដំណើរការបាន។ ធ្វើ

យ៉ាងនេះទើបទាំងអង្គការមិនមែនរដ្ឋាភិបាល ទាំងមន្ត្រីរាជការយល់បានយ៉ាងច្បាស់លាស់អំពីបរិស្ថានសម្រាប់កិច្ចដំណើរការ។ ច្បាប់ដែលជួយគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាល នឹងផ្តល់លទ្ធភាពអោយអង្គការទាំងនេះអាចចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រដោយអង្គការទាំងនេះឆ្លើយតបបានយ៉ាងឆាប់រហ័ស និងប្រកបដោយភាពច្នៃប្រឌិតនៅពេលមានបញ្ហាកើតឡើង។ កម្មវិធីដែលអង្គការក្រៅរដ្ឋាភិបាលបានដាក់ចេញ ភាគច្រើនត្រូវបានរាជរដ្ឋាភិបាល អនុម័តទទួលយល់ព្រមក្នុងគុណប្រយោជន៍របស់ប្រជាជនទាំងមូលតែម្តង។ រាជរដ្ឋាភិបាលនឹងរៀបចំក្របខ័ណ្ឌការងារដោយផ្តល់ព័ត៌មានអោយបានគ្រប់គ្រាន់ស្តីពីសកម្មភាពអភិវឌ្ឍន៍នានា និងការចូលរួមចំណែកជាថវិការបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ ក្របខ័ណ្ឌនេះដែរ ត្រូវលើកទឹកចិត្តដល់យន្តការស្វ័យគ្រប់គ្រង។ យើងត្រូវសម្រេចបាននូវតុល្យភាពមួយសមស្របរវាងការត្រួតពិនិត្យ និងការសម្រួលដើម្បីអោយរាជរដ្ឋាភិបាលប្រើប្រាស់ធនធានដ៏កម្រនេះក្នុងការគ្រប់គ្រងប្រព័ន្ធមួយដ៏ស្មុគស្មាញ។

២.៣.៦ ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធ

ក-ទំនាក់ទំនងជាមួយអ្នកផ្តល់ជំនួយ និងចលនាឆ្ពោះទៅរកភាពជាដៃគូ

ភាពជាដៃគូ គឺជាការវិវត្តន៍ក្នុងរយៈពេលវែងក្នុងចំណោមដៃគូទាំងអស់ ដូចជា រាជរដ្ឋាភិបាល សង្គមស៊ីវិលផ្នែកឯកជន និងសហគមន៍ផ្តល់ជំនួយអន្តរជាតិ និងជាពិសេស គឺជាការផ្លាស់ប្តូរបែបផែនទំនាក់ទំនងទាំងក្នុងប្រទេស ទាំងក្រៅប្រទេស។ ការផ្លាស់ប្តូរនេះដែរ អាចប្រព្រឹត្តទៅប្រកបដោយជោគជ័យបានល្អឹតណាតែដៃគូទាំងអស់យល់យ៉ាងច្បាស់នូវទស្សនទានស្តីពី ភាពជាដៃគូថ្មីនេះ ហើយទទួលយកនិយមន័យ និងមានការយល់ដឹងជាទូទៅ និងការទទួលយកនីតិវិធីក្នុងការអនុវត្តន៍។ នៅពេលដែលរាជរដ្ឋាភិបាលមានបំណងប្រែក្លាយពី "ការពឹងផ្អែកលើអ្នកផ្តល់ជំនួយទៅកាន់កម្មសិទ្ធិរបស់ជាតិ" យើងត្រូវប្រែក្លាយអោយបានឆាប់ពីការត្រួតពិនិត្យទៅកាន់ការដឹកនាំ និងពីគ្រាន់តែដើរតួនាទីសម្របសម្រួលកាន់កិច្ចសហការគ្នា ដោយផ្តើមចេញពីមូលដ្ឋាននៃយន្តការសម្របសម្រួល និងគ្រប់គ្រងជំនួយក៏ដូចជាការពិភាក្សារបស់អ្នកផ្តល់ជំនួយក្នុងពេលបច្ចុប្បន្ននេះ។ ប្រការនេះនឹងអនុញ្ញាតអោយយើងឆ្លងកាត់អន្តរកាលពីដំណាក់កាលគ្រប់គ្រងដោយអន្លើៗ មកកាន់ដំណាក់កាលអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍តាមកម្មវិធីច្បាស់លាស់ដោយប្រើប្រាស់ផែនការសកម្មភាពជាអាទិភាព (PAP) របស់យើងនៅក្នុងវិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ និងកសិកម្ម[៦៦]។ ទន្ទឹមនឹងនេះប្រព័ន្ធនេះបានផ្សាភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងកម្មវិធីចំណាយសាធារណៈក្នុងរយៈពេលមធ្យម(MTEF) កម្មវិធីវិនិយោគសាធារណៈ (PIP) ដែលដំណើរការក្នុងក្របខ័ណ្ឌនៃប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ(PIMS)។ ប្រការទាំងនេះនឹងជួយសម្រួលអោយើងឈានឡើងពីការពឹងផ្អែកទាំងស្រុងទៅកាន់ចីរភាព។ ក៏ប៉ុន្តែដើម្បីសម្រេចបាននូវគោលដៅ

[៦៦] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៦៧

នេះរាជរដ្ឋាភិបាលកំពុងដាក់ចេញនូវវិធានការដើម្បីជៀសវាងនូវករណីអសកម្មនានា ដូចជា ការបាត់បង់ថវិកា និងអំពើពុករលួយក្នុងគោលដៅប្រមូលផ្តុំនូវថវិការបស់រដ្ឋ និងជំនួយពីក្រៅប្រទេសអោយនៅក្នុងកញ្ចប់តែមួយ។

តាមរយៈកិច្ចសហការក្នុងភាពជាដៃគូ ដៃគូទាំងអស់ត្រូវខិតខំរិះរកមធ្យោបាយថ្មីៗប្រកបដោយប្រសិទ្ធិភាពដើម្បីផ្ទេរនូវចំណេះដឹង និងពង្រឹងសមត្ថភាពជាតិអោយមានចីរភាព។ ភាគីទាំងអស់គួរតែចែករំលែកនូវទស្សនវិស័យរួម និងច្បាស់លាស់ដូចជា គោលដៅលទ្ធផល គោលការណ៍សម្រាប់កិច្ចដំណើរការតម្លៃ និងសីលធម៌ផ្សាស់នៃលទ្ធផលដែលសម្រេចបាន ការសន្យាធនធានរួមគ្នាការត្រួតពិនិត្យខាងផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្សជាដើម។ រាជរដ្ឋាភិបាលបានទទួលយកទាំងស្រុងនូវជំហរដែលអនុញ្ញាតអោយភាពជាដៃគូនីមួយៗមានដៃគូដឹកនាំដែលអាចជាក្រសួង ស្ថាប័ន សាលាខេត្ត ដៃគូជាតិ(សង្គមស៊ីវិល ឬផ្នែកជន) ឬទីភ្នាក់ងារផ្តល់ជំនួយក្រៅប្រទេស។ រចនាសម្ព័ន្ធនៃភាពជាដៃគូរត្រូវបង្ហាញពីគោលនយោបាយ និងយុទ្ធសាស្ត្រដែលលើកទឹកចិត្តដល់ការផ្ទេរចំណេះធ្វើ និងការអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពស្ថាប័នផ្សេងៗទៀតនៅក្នុងរដ្ឋាភិបាលសង្គមស៊ីវិល និងផ្នែកឯកជន។

អាទិភាពរបស់រាជរដ្ឋាភិបាល គឺជាការកែលម្អការសម្របសម្រួលជំនួយពីក្រៅប្រទេស និងការគ្រប់គ្រងជំនួយក្នុងគោលដៅតម្រង់ទិសអោយជំនួយទាំងនេះទៅដល់វិស័យអាទិភាព។ ដូចបានលើកឡើងខាងលើ យើងមិនបានសម្រេចនូវគោលដៅក្នុងការបែងចែកវិនិយោគរវាងតំបន់ទីក្រុង និងទីជនបទឡើយ នៅពេលដែលរាជ-រដ្ឋាភិបាលអនុវត្តន៍នូវផែនការសេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទីមួយ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រតាមរយៈការប្រើប្រាស់អោយមានប្រសិទ្ធភាពនូវជំនួយពីក្រៅប្រទេស យើងចាំបាច់ត្រូវស្វែងរករូបមន្ត និងយន្តការសម្របសម្រួលជំនួយដែលមានប្រសិទ្ធភាពពិប្រាកដ ដោយត្រូវផ្តោតការយកចិត្តទុកដាក់ចំពោះស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា និងធ្វើការពិនិត្យអំពើឧត្តមភាពប្រៀបធៀបរបស់អ្នកផ្តល់ជំនួយនីមួយៗ។

ការដាក់អោយអនុវត្តន៍ជាជំហានៗនូវវិធីសម្របសម្រួលតាមផ្នែក (SWAP) និងវិធីដទៃទៀតក្នុងវិស័យមួយចំនួនដូចជា អប់រំ និងសុខាភិបាល នឹងធ្វើអោយជៀសវាងនូវការផ្តល់ជំនួយត្រួតគ្នាជានាអោយបាននូវការបែងចែកប្រកបដោយវិចារណកម្ម និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធានដែលមាន។ វិធីទាំងនេះនឹងសម្រួលដល់ការអនុវត្តន៍សកម្មភាពដែលឆ្លុះបញ្ចាំងនូវយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ ដោយសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ សង្គមស៊ីវិល និងតួអង្គអភិវឌ្ឍន៍ផ្សេងៗទៀត។ ក៏ប៉ុន្តែការផ្តល់ជំនួយជាគម្រោងក៏អាចចូលរួមវិភាគទានប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយភាពក្រីក្រ ប្រសិនគម្រោងទាំងនេះមានសង្គតភាពជាមួយយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងអស់។ ម្យ៉ាងវិញទៀត គម្រោងជាច់ដោយឡែកអាចមានឥទ្ធិពលជាវិជ្ជមាន និងផ្តល់ប្រយោជន៍ដល់អ្នកក្រីក្របានកាន់តែច្រើនប្រសិនបើអ្នកក្រីក្រទាំងនោះ ឬតំណាងរបស់ពួកគេចូលរួមចាប់តាំងពីដើមទីក្នុងការលើកគម្រោង ការរៀបចំគម្រោង និងការអនុ-

វត្តន៍គម្រោង។ ដូច្នេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តពង្រឹងភាពជាដៃគូទ្វេភាគីជាមួយអ្នកផ្តល់ជំនួយទាំងអស់ ដើម្បីលើកស្ទួយដល់ជំនួយជាគម្រោង។

រាជរដ្ឋាភិបាល បានធ្វើការអនុវត្តន៍សាកល្បងនូវរូបមន្តភាពជាដៃគូ នៅក្នុងដំណើរការរៀបចំឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលនឹងផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទី២។ ឯកសារដ៏សំខាន់ទាំងពីរបស់រាជរដ្ឋាភិបាលនឹងត្រូវបានអនុវត្តនៅក្នុងក្របខ័ណ្ឌជាយុទ្ធសាស្ត្រតែមួយ ជាមួយនឹងសកម្មភាពជំទៃទៀត ដែលមានការពាក់ព័ន្ធនឹងស្ថានភាពក្រីក្រ។ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលដឹកនាំដោយឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដែលមានតំណាងមកពីក្រសួងស្ថាប័នផ្សេងៗ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងឯកសារបឋមស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ នៅក្នុងចន្លោះខែមិថុនា ឆ្នាំ២០០០ នេះដែរត្រូវបានគណៈកម្មាធិការផ្ញើសេចក្តីព្រាងលើកដំបូងជូនសមាជិកក្រុមការងារស្តីពីកំណែទម្រង់សារពើពន្ធ ដើម្បីផ្តល់មតិ និងអនុសាសន៍។ នៅក្នុងខែ កក្កដា និងសីហា ឆ្នាំ២០០០ គណៈកម្មការបានពិគ្រោះយោបល់ជាមួយអ្នកផ្តល់ជំនួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ(IFI) [៤៥] អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកឯកជនលើសេចក្តីព្រាងឯកសារបឋមស្តីពីយុទ្ធ-សាស្ត្រកាត់បន្ថយភាពក្រីក្រនេះ[៤៦]។

ខ-ការកៀងគរចំណូល

ការប្រមូលចំណូលបានតិចធ្វើអោយកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយភាពក្រីក្រជួបប្រទះនឹងការលំបាកយ៉ាងខ្លាំង។ ដោយសារទីចាត់ការគយ និងរដ្ឋាករ ជាស្ថាប័នមានសមត្ថកិច្ចប្រមូលចំណូលមួយភាគធំចូលថវិការដ្ឋ រាជរដ្ឋាភិបាលបានចាត់វិធានការពង្រឹងរដ្ឋបាលគយអោយឈានដល់កម្រិតអន្តរជាតិ។ រាជរដ្ឋាភិ-បាលបានប្តេជ្ញាចិត្តធ្វើវិសោធនកម្មលើច្បាប់ និងលិខិតបទដ្ឋានកាត់បន្ថយនីតិវិធីគយ ប្រយុទ្ធប្រឆាំងនឹងអំពើរត់ពន្ធ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការងារធ្វើពាណិជ្ជកម្ម ការរៀបចំស្ថិតិ ការផ្តល់ព័ត៌មាន និងរបាយការណ៍ការរៀបចំរដ្ឋបាល ពន្ធគយទំនើបមួយ។

រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការពង្រឹងចំណូល តាមរយៈការដាក់អោយអនុវត្តនូវអាករលើតម្លៃបន្ថែម(VAT) ចំពោះក្រុមហ៊ុនធំៗចំនួន ១.៥០០។ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមុឺងម៉ាត់ ដើម្បីពង្រឹងការប្រមូលចំណូលអោយស៊ីជម្រៅ តាមរយៈការបន្តអនុវត្តយ៉ាងមុឺងម៉ាត់នូវអាករលើតម្លៃបន្ថែមការកម្រិតអោយបានហ្មត់ចង់ចំពោះការលើកទឹកចិត្តផ្នែកសារពើពន្ធ បង្កើនការខិតខំប្រឹងប្រែងដើម្បីទារបំណុលពីផ្នែកឯកជន និងផ្ទៃទាំងស្រុង និងដោយត្រង់នូវចំណូលពុំមែនពន្ធទៅរតនាគារជាតិ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលកំពុង

---

[៤៥] IFIs - International Financial Institutions

[៤៦] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៦៩

រៀបចំក្របខ័ណ្ឌ ដើម្បីកែលម្អការប្រមូលពន្ធលើប្រាក់ចំណេញ និងការបង្កើនការផ្លាស់ប្តូរព័ត៌មានរវាងស្ថាប័ន ដែលមានការពាក់ព័ន្ធនឹងការប្រមូលពន្ធ។

សកម្មភាពសម្រាប់រយៈពេលខ្លី និងសម្រាប់រយៈពេលមធ្យម ដែលរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តអនុវត្ត ដូចមានចែងនៅក្នុងកម្មវិធីឥណទានការកាត់បន្ថយភាពក្រីក្រ និងកំណើន(PRGF) និងក្នុងកម្មវិធីឥណទាន កំណែទម្រង់រចនាសម្ព័ន្ធ(SAC) ត្រូវបានច្របាច់បញ្ចូលទៅក្នុងតារាងគោលនយោបាយនៃឧបសម្ព័ន្ធទី១[៤៧]។ សកម្មភាពនេះក៏បានឆ្លុះបញ្ចាំងនូវខ្លឹមសារសង្ខេបនៃឯកសារ ដែលរាជរដ្ឋាភិបាលបានរៀបចំសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ CGM[៤៨] ដែលបានប្រព្រឹត្តទៅនៅក្នុងខែឧសភា ឆ្នាំ២០០០ នាទីក្រុងប៉ារីស។ រាជរដ្ឋាភិបាលនឹងធ្វើការពិនិត្យឡើងវិញនូវតារាងគោលនយោបាយនេះ ក្នុងបរិការណ៍នៃការឯកភាពរវាងភាគីដែលមានការពាក់ព័ន្ធនៅពេលរៀបចំឯកសារចុងក្រោយស្តីពី យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ[៤៩]។

[៤៧] ព័ត៌មានពិស្តារមាននៅក្នុងឯកសារស្តីពី ឥណទានកាត់បន្ថយភាពក្រីក្រ និងកំណើន និងឥណទានសម្រាប់កំណែតម្រូវរចនាសម្ព័ន្ធ

[៤៨] CGM – Consultative Group Meetings

[៤៩] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមស្តីពី "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ទំព័រទី៧០

ជំពូកទី ៣
ស្ថានភាពក្រីក្រចន្លោះឆ្នាំ១៩៩៣-២០០៨

៣.១ បរិបទនៃប្រទេសកម្ពុជា

ដោយសារស្ថានភាពភូមិសាស្ត្រធម្មជាតិរបស់ប្រទេសកម្ពុជា ទទួលបាននូវលក្ខណៈអំណោយផលសម្រាប់ការអភិវឌ្ឍន៍ទោះបីដីមានសភាពមិនល្អ ជាពិសេស និងប្រព័ន្ធធារាសាស្ត្រស្មុគស្មាញក៏ដោយ ក៏ប្រទេសកម្ពុជាមានកំពង់ផែសមុទ្រសំបូរទៅដោយវាលរាប ដែលអាចដាំដុះបាន ត្រីទឹកសាបប្រកបដោយផលិតភាពខ្ពស់ និងសម្បត្តិព្រៃឈើដ៏ធំធេង។ ប្រទេសកម្ពុជាក៏មានសក្តានុពលទេសចរណ៍ដ៏ខ្លាំងក្លាដែរ។ សំខាន់ជាងនេះទៅទៀត ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ដែលមានការលូតលាស់យ៉ាងឆាប់រហ័ស ដោយមានព្រំដែនគោលដែលអាចផ្តល់ការចូលទៅកាន់ទីផ្សារប្រទេសថៃ និងប្រទេសវៀតណាមបាន។

ភាពក្រីក្រនៃប្រទេសកម្ពុជាបច្ចុប្បន្ន គឺបណ្តាលមកពីបញ្ហាជម្លោះដ៏តបីទសវត្សជាមូលដ្ឋាន។ សង្គ្រាមស៊ីវិលចាប់ផ្តើមនៅឆ្នាំ១៩៧០ ហើយត្រូវបញ្ចប់ដោយជ័យជំនះរបស់ខ្មែរក្រហម(KR) ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានសម្លាប់ស្ទើរតែមួយភាគប្រាំនៃប្រជាជនកម្ពុជា ឬមួយដោយចេតនា ឬតាមរយៈគោលនយោបាយដឹកនាំខុសទិស។ នៅក្នុងទសវត្សឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានងើបឡើងវិញយ៉ាងយឺតក្នុងបរិបទនៃជម្លោះ ដែលមាន "ប្រពលភាពកម្រិតទាប" និងភាពឯកោពីសហគមន៍អន្តរជាតិ។ ជម្លោះនេះបានបំផ្លាញគ្រប់ហេដ្ឋារចនាសម្ព័ន្ធកម្ចេចមូលធនមនុស្សរបស់ប្រទេសជាតិ និងបានធ្វើអោយទន់ខ្សោយ ឬបំលែងស្ថាប័នសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយទាំងឡាយ។

ចាប់តាំងពីចុងទសវត្ស ១៩៨០ ប្រទេសកម្ពុជាបានចេញដំណើរលើមូលដ្ឋានអន្តរកាលបីដំណាក់កាលពីសង្គ្រាមមកសន្តិភាព ពីនយោបាយគណបក្សតែមួយមកពហុបក្ស និងពីភាពឯកកោផ្នែកសេដ្ឋកិច្ចតម្រង់ទិសតាមបែបផែនគ្រាន់តែសម្រាប់រស់ មកជាសេដ្ឋកិច្ចដែលផ្អែកលើគោលការណ៍ទីផ្សារ និងធ្វើសមាហរណកម្មចូលក្នុងពាណិជ្ជកម្មព្រមទាំងលំហូរមូលធនអន្តរជាតិ។ រហូតដល់សព្វថ្ងៃគឺមានរយៈពេល ១៤ថ្ងៃ ហើយចាប់តាំងពីអន្តរកាលមកត្រូវបានរៀបចំជាផ្លូវការនៅក្នុងឆ្នាំ១៩៩១ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ប្រទេសកម្ពុជាបច្ចុប្បន្នស្ថិតនៅក្នុងអន្តរកាលពីសង្គមក្រោយជម្លោះមកជាប្រទេសកំពុងអភិវឌ្ឍន៍ "ធម្មតា" មួយ។ ផលប៉ះពាល់ទាំងឡាយនៅតែត្រូវបានមើលឃើញនៅឡើយ ជាពិសេសចំពោះស្ថាប័នដែលត្រូវបានតម្រង់ទិសជាដំបូងអោយរដ្ឋមានដំណើរការជានិន្នរភាពសិន តែឆ្លើយតបតិចតួចទៅនឹងសំណូមពរទាំងឡាយរបស់ប្រជាពលរដ្ឋ"។ ទោះយ៉ាងណាក្នុងមួយទសវត្សនៃសមាហរណកម្មអន្តរជាតិដោយសារវិនិយោគ និងកំណើនសេដ្ឋកិច្ច គេបានមើលឃើញថា ទាំងអ្នកដឹកនាំ និងប្រជាពលរដ្ឋក្នុងជំនាន់បច្ចុប្បន្នចាប់ផ្តើមកាន់កាប់ជោគវាសនារបស់ខ្លួនផ្ទាល់ដោយកំណត់គោលនយោបាយ និងជីវភាពអោយបានចេញផុតឆ្ងាយពីសំណល់សង្គ្រាម។

ទោះបីប្រទេសកម្ពុជាមានសភាពមិនធម្មតា ក្នុងការឆ្លងកាត់ហេតុការណ៍ក្រោយជម្លោះ (និង "បន្ទាប់ពីក្រោយជម្លោះ") ក៏នេះមិនមែនជាលក្ខណៈពិសេសម្រាប់ប្រទេសនេះតែមួយដែរ បញ្ហាទាំងឡាយដែលប្រទេសកម្ពុជាប្រឈមមុខ នឹងដំណោះស្រាយដែលប្រទេសនេះអាចប្រកាន់យកនោះ អាចត្រូវបានប្រៀបធៀបជាមួយនឹងបញ្ហា ព្រមទាំងដំណោះស្រាយក្នុងរដ្ឋ ដែលមានប្រាក់ចំណូលទាប និងស្ថិតក្រោយពេលជម្លោះដទៃទៀតដែរ។

ក្នុងទសវត្សមួយ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស រដ្ឋាភិបាលបានសម្រេចជោគជ័យក្នុងការពង្រឹងសន្តិភាព និងលើកកម្ពស់កំណើនសេដ្ឋកិច្ច។ ប្រជាជនទទួលស្គាល់ថា សន្តិភាពបានធ្វើអោយជីវិតរបស់ពួកគាត់មានភាពខុសពីមុនយ៉ាងច្រើន។ ក្រៅពីភាពប្រសើរឡើងនៃសន្តិសុខជារូបវន្ត សេរីភាពក្នុងការធ្វើដំណើរ ការធ្វើវិនិយោគលើទ្រព្យសម្បត្តិ ដែលអាចទាញយកផល និងការប្រមូលផ្តុំធនធានបានបើកឱកាសសម្រាប់ជីវភាពយ៉ាងទូលំទូលាយមែនទែន។ រដ្ឋាភិបាលបានបន្តយ៉ាងសកម្មនូវសមាហរណកម្មចូលក្នុងរចនាសម្ព័ន្ធតំបន់ និងពិភពលោក ដូចជា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN) និងអង្គការពាណិជ្ជកម្មពិភពលោក(WTO)។ ចាប់តាំងពីចុងទសវត្សឆ្នាំ៩០ រដ្ឋាភិបាលបានចាត់ចែងប្រកបដោយសុភវិនិច្ឆ័យអោយមានឱកាសទទួលបានកិច្ចព្រមព្រៀងវាយនភ័ណ្ឌ។

វិសាលភាព និងស្ថេរភាពក្រីក្រនៅប្រទេសកម្ពុជាបច្ចុប្បន្ន ព្រមទាំងដំណើរការដែលជួនកាលភាពក្រីក្រកើនឡើង ឬធ្លាក់ចុះ មិនអាចត្រូវបានយល់យ៉ាងសមស្របក្នុងភាពឯកកោនៃប្រវត្តិសាស្ត្រកន្លងទៅថ្មីៗបានឡើយ។ ជំពូកនេះនឹងផ្តល់ចំណេះដឹងមូលដ្ឋាន ដែលនៅក្នុងនោះស្ថានភាពក្រីក្របច្ចុប្បន្នរបត់កន្លងទៅថ្មីៗ និងទិដ្ឋភាពវិជ្ជមាននាពេលអនាគតនៅប្រទេសកម្ពុជាអាចត្រូវបានបង្កើតឡើងវិញ នៅក្នុងបរិបទនោះនឹងអាចត្រូវបានវាយតម្លៃ។

ដោយសារ គុណភាពភូមិសាស្ត្រពីធម្មជាតិផ្តល់អោយប្រទេសកម្ពុជាបាននឹងកំពុងខិតខំ ដើម្បីសម្រេចជោគជ័យ។ មិនដូចប្រជាជាតិអភិវឌ្ឍន៍តិចតួចជាច្រើន(ឧទាហរណ៍ ប្រទេស ឡាវ នេប៉ាល់ ឬអ៊ូហ្គានដា) ប្រទេសកម្ពុជា មិនមែនព័ទ្ធជុំវិញដោយដីទាំងអស់ ឬស្ថិតនៅឯកកោពីប្រទេសជិតខាងដោយដីនោះទេ: កំពង់ផែសមុទ្រនៅក្រុងព្រះសីហនុ ទីតាំងរបស់ក្រុងភ្នំពេញលើទន្លេមេគង្គ និងព្រំដែនវាលរាបដ៏វែងជាមួយប្រទេសជិតខាងយ៉ាងតិចចំនួនពីរក្នុងចំណោមប្រទេសចំនួនបីមានន័យថា គ្មានឧបសគ្គផ្នែកភូមិសាស្ត្រសម្រាប់ពាណិជ្ជកម្មអន្តរជាតិជាធំដុំឡើយ[៥០]។ ជាការពិតព្រំដែនជើងគោករវាងកម្ពុជា និងថៃ ព្រមទាំងវៀតណាម ដែលមានសេដ្ឋកិច្ចលូតលាស់យ៉ាងឆាប់រហ័ស បង្កើតបានជាសក្តានុពលយ៉ាងធំធេងនៃសេចក្តីត្រូវការនូវទំនិញ និងសេវាពីប្រជាជនកម្ពុជា។ ដោយមើលអោយឆ្ងាយពីប្រទេសជាតិខាង កម្ពុជាស្ថិតនៅក្នុងតំបន់ដែលមានសេដ្ឋកិច្ច

[៥០] តំបន់ត្រូពិច នៃប្រទេសកម្ពុជាអាចបៀបបានទៅនឹងទ្រនាប់កែវមួយ។ តំបន់ភ្នំប្រកបដោយព្រៃឈើ ជាពិសេសនៅតំបន់ឦសាន និងនីរតី ជំរាលជ្រោះ ទៅរកវាលរាបដ៏ធំទូលំទូលាយ ព្រមទាំងបឹងដ៏ធំ និងរាក់នៅចំកណ្តាល(បឹងទន្លេសាប) រួចបន្ទាប់មកសរសៀរតាម "ជំរាល" ទៅទីសអាគ្នេយ៍តាមទន្លេសាប ដែលភ្ជាប់នឹងទន្លេមេគង្គ ហើយហូរកាត់វាលរាបអាគ្នេយ៍ ហើយចាក់ចូលទៅក្នុងតំបន់ដីណ្តាទន្លេមេគង្គរបស់ប្រទេសវៀតណាម។

លូតលាស់យ៉ាងឆាប់បំផុតនៅក្នុងសកលោក។ ទោះបីវិបត្តិហិរញ្ញវត្ថុអាស៊ីនៅចុងទសវត្សឆ្នាំ៩០ បានកាត់បន្ថយអត្រាកំណើនសេដ្ឋកិច្ច ក៏ប្រទេសកម្ពុជាប្រាកដជាបានទាញយកផលចំណេញពី "ផលប៉ះពាល់ពីភាពជាប្រទេសជាតិខាង" ដោយមានសក្តានុពលទាក់ទាញការវិនិយោគពីតំបន់ និងអាចលក់នៅក្នុងទីផ្សារតំបន់។

ដោយប្រៀបធៀបជាមួយនឹងប្រទេសភ្នំជាច្រើន(ឧទាហរណ៍ ប្រទេស ឡាវ នេប៉ាល់ ប៊ូតង់ ឬតំបន់ជាច្រើនរបស់វៀតណាម) តំបន់ត្រូពិចនៃប្រទេស ក៏ផ្តល់អំណោយផលដល់កម្ពុជាដែរ។ តំបន់ភ្នំទាំងឡាយនៅតាមព្រំដែនខាងទិសឧត្តរ ឦសាន និងនីរតីមានសក្តានុពលផលិតភាពទាប ប៉ុន្តែតំបន់ភាគច្រើននៃប្រទេសកម្ពុជា ជាតំបន់វាលរាបស្មើគួរសម ដែលធ្វើអោយការបង្កបង្កើនផលកសិកម្ម និងការធ្វើវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍មិនអាចទាមទារចំណាយខ្ពស់សម្រាប់ការសម្របសម្រួល និងស្ថានភាពទេសភាពធម្មជាតិដីអាចដាំដុះបាន និងអនុញ្ញាតអោយគេអាចស្ថាបនាផ្លូវថ្នល់ដោយមិនបាច់ឡើងចំណោទទេ។ បឹងទន្លេសាបនៅចំកណ្តាលប្រទេស បានផ្តល់ដល់ភូមិខ្មែរដ៏ច្រើននូវលទ្ធភាពទទួលយ៉ាងល្អប្រសើរនូវការដឹកជញ្ជូនផ្លូវទឹកមកដល់ភ្នំពេញ និងជាយថាហេតុរហូតដល់ភាគខាងត្បូងប្រទេសវៀតណាម។ បឹងនេះក៏ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ីតែមួយគត់ដែលបានផ្តល់យ៉ាងហោចណាស់ក៏រហូតដល់សព្វថ្ងៃនេះ នូវផលត្រីទឹកសាបប្រកបដោយផលិតភាពខ្ពស់ជាងគេបំផុតលើសកលលោក និងជាប្រភពជីវជាតិប្រូតេអ៊ីនដ៏សំខាន់សម្រាប់ជាអាហាររបស់ប្រជាជនកម្ពុជា។

ហើយក៏មានបញ្ហីឈ្មោះកេរ្តិ៍មរតកមួយដែរ នេះជាអំណោយផលសម្រាប់កម្ពុជា ដែលត្រូវតែរាប់បញ្ចូលមរតបុរាណវត្ថុប្រាសាទទាំងឡាយនៅអង្គរ និងសក្តានុពលដ៏ធំធេងសម្រាប់វិស័យទេសចរណ៍ ដែលនេះជាតំណាងទីក្រុងវប្បធម៌។ ទេសចរណ៍ ដែលទាក់ទាញជាបឋមដោយប្រាសាទអង្គរ ជាកត្តាផ្តល់វិភាគទានដ៏សំខាន់ដល់កំណើនសេដ្ឋកិច្ចនៅកម្ពុជាក្នុងទសវត្សចុងក្រោយនេះ។ ប៉ុន្តែផលប៉ះពាល់របស់ការងារនេះទៅលើភាពក្រីក្រមានកម្រិតតិចតួចគួរកត់សម្គាល់ថា ខេត្តសៀមរាប ដែលប្រាសាទអង្គរស្ថិតនៅនោះ គឺជាខេត្តក្រជាគេបំផុតលំដាប់លេខ៣ ក្នុងប្រទេសនៅឆ្នាំ២០០៤។ ការទទួលបានផលចំណេញជានិរន្តរភាពពីប្រាសាទអង្គរទាមទារនូវអភិក្រមជាយុទ្ធសាស្ត្រ ជាងមុនសម្រាប់ការអភិវឌ្ឍន៍វិស័យទេសចរណ៍នេះ។

ជាចុងក្រោយវាហាក់ដូចជា មានការកើនឡើងនាឃៈពេល ពីរ បី ឆ្នាំទៀតខាងមុខ ដោយកម្ពុជានឹងមានប្រភពចំណូលដ៏សំខាន់មួយ គឺប្រេង និងឧស្ម័ន នៅក្នុងសមុទ្រកម្ពុជា។ ពីការរកឃើញនោះបានបញ្ជាក់ថាផ្នែកនៃតំបន់មួយអាចមានប្រេង ពី ៤០០ ទៅ ៥០០ លានបារែល និងឧស្ម័នប្រមាណ ២ ទៅ ៣ ពាន់លានម៉ែត្រគូប(trillion)[៥១]។ តាមការប៉ាន់ស្មាន ការរុករកនៅក្នុងតំបន់នេះ និងតំបន់ផ្សេងទៀត អាចមានច្រើនជាងនេះ។ ទោះបីវាមានការលំបាកក្នុងការប៉ាន់ប្រមាណជាមុននូវចំណូលដែលអាចយកបាន និងទំហំនៃបរិស្ថានធនធានទាំងនោះ និងតម្លៃប្រេងនាពេលអនាគតក៏ដោយ វានឹងប្រហែលជាអាចផ្តល់ជាចំណូលតាមពាណិជ្ជកម្មខ្នាតធំប្រមាណ ២ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ(Vallely, Dapice and Wilkinson 2006)។ ប្រសិនបើមាន

[៥១] អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៥

ការគ្រប់គ្រងបានល្អវានឹងផ្តល់ផលប្រយោជន៍ដ៏ធំក្នុងការលើកស្ទួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា ជាពិសេសអោយមានលក្ខណៈប្រសើរឡើងក្នុងការកាត់បន្ថយភាពក្រីក្រអោយបានឆាប់រហ័ស[៥២]។

នេះមិនមែនចង់បញ្ជាក់ថា ប្រទេសកម្ពុជាមិនទទួលរងការឈឺចាប់ដោយសារកត្តាមិនអោយអំណោយផលភូមិសាស្ត្រនោះទេ។ ជាទូទៅ ដីរបស់ប្រទេសកម្ពុជាមានគុណភាពទាប(ដោយមានការលើកលែងគួរអោយកត់សម្គាល់តែមួយចំនួនប៉ុណ្ណោះ)។ ប្រទេសកម្ពុជាក៏មានប្រព័ន្ធធារាសាស្ត្រស្មុគស្មាញដែលនៅរដូវវស្សាការជោរជន់ទឹកនៅទីប្រសព្វរបស់ទន្លេមគង្គ និងទន្លសាប នាំអោយទន្លេសាបហូរត្រឡប់ទៅបឹងវិញ ដែលពង្រីកវិសាលភាពរបស់ខ្លួន ១០ដង ធំជាងទំហំនៅរដូវប្រាំ ហើយជម្រៅជាង ២ដង លើផ្ទៃដែលគ្រប់ដណ្តប់ដោយទឹកជំនន់នោះ។ នៅពេលដែលទឹកជំនន់យ៉ាងខ្លាំងទាំងនេះជាផ្នែកមួយនៃខួបប្រចាំឆ្នាំជាធម្មតា និងសំខាន់ចំពោះការដាំដុះស្រូវ និងអេកូឡូស៊ីរបស់ទន្លេសាបដោយគ្មានការត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធទឹកទេនោះ ទឹកជំនន់ធំជាងធម្មតាអាចនឹងបំផ្លាញផលកសិកកម្ម ផ្ទះសម្បែង និងជីវភាពរស់នៅយ៉ាងធំធេង។

ប៉ុន្តែតុល្យភាពគ្មានទិដ្ឋភាពនៃទីតាំងតំបន់ត្រូពិច ដែលមិនអាចផ្លាស់ប្តូរ ឬក៏ជាតុអាកាសអាចបង្ខាំងប្រទេសកម្ពុជាមិនអោយសម្រេចទិសដៅអភិវឌ្ឍន៍របស់ខ្លួនឡើយ។ មានការជំណាលថា នៅក្នុងឆ្នាំ១៩៦៩ ប្រទេសកម្ពុជាបានទទួលប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ និងទេសចរច្រើនជាងប្រទេសថៃទៅទៀត[៥៣]។ ការត្រឡប់បញ្ច្រាសនៃភ័ព្វសំណាងតាំងពីពេលនោះមក គឺបណ្តាលមកយ៉ាងច្បាស់ដោយសារការចាប់ផ្តើមនៃអ្វីដែលប្រែក្លាយទៅជាសង្គ្រាមស៊ីវិលអស់រយៈពេលជិត ៣ទសវត្សរ៍ និងចុងទសវត្សរ៍ឆ្នាំ៦០។

ប្រទេសកម្ពុជាក្រោយសម័យអាណានិគម: សង្គ្រាម ការបដិវត្តន៍ និងការងើបឡើងវិញ: ប្រទេសកម្ពុជាបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ក្នុងរជ្ជកាលព្រះមហាក្សត្រ **នរោត្តម សីហនុ** ដែលបានដាក់រាជ្យនៅឆ្នាំ១៩៥៥ ដើម្បីឃោសនាការបោះឆ្នោត។ ប្រជាជនខ្មែរចាស់ៗជាច្រើននៅចងចាំរយៈពេលនោះថា គឺជាយុគ្គសម័យដ៏រុងរឿងយ៉ាងខ្លាំង។ ប៉ុន្តែនៅរវាងពាក់កណ្តាលឆ្នាំ១៩៦០ បញ្ហាសេដ្ឋកិច្ច អំពើពុករលួយ និងកង្វះខាតការអត់ឱនអនុគ្រោះរបស់រាជរដ្ឋាភិបាលចំពោះការប្រឆាំងតបតាមបែបប្រជាធិបតេយ្យ បាននាំអោយវណ្ណៈបញ្ញាវ័ន្តក្នុងទីក្រុង ដែលមិនសប្បាយចិត្តត្រិះរិះពិចារណារកជម្រើសនយោបាយមូលវិវដ្តនិយម(ជាឆ្វេង ឬស្តាំនិយម)។ រដ្ឋាភិបាលកម្ពុជា ក៏ពិបាករក្សាប្រទេសអោយរួចផុតពីសង្គ្រាមនៅវៀតណាម និងការគាបសង្កត់របស់ភាគីជម្លោះទាំងសងខាងអោយគាំទ្របុព្វហេតុរបស់ពួកគេរៀងៗខ្លួន។

នៅទីបំផុតសកម្មភាពធ្វើតុល្យភាពទទួលបរាជ័យ។ នៅឆ្នាំ១៩៧០ **សម្តេច សីហនុ** ត្រូវបានផ្តួលរំលំដោយរដ្ឋប្រហារដែលរៀបចំឡើងដោយឧត្តមសេនីយ៍ លន់ នល់ ។ ប្រទេសកម្ពុជា បានធ្លាក់យ៉ាងរហ័សទៅក្នុង

---

[៥២] ទោះបីយ៉ាងណាក៏មានប្រទេសដទៃទៀតមួយចំនួនមានបញ្ហាក្នុងការគ្រប់គ្រង ដូចជា ប្រទេសនីហ្សីរីយ៉ា ជាឧទារណ៍ស្រាប់ជាការពិតណាស់ក្នុងការរកឃើញប្រេង និងឧស្ម័ន គឺជាទ្រព្យដ៏អស្ចារ្យរបស់ប្រទេសកម្ពុជា បើសិនជាមានការយឺតយ៉ាវ និងការគ្រប់គ្រងមិនបានល្អ វានឹងមិនផ្តល់ផលប្រយោជន៍ដ៏ធំក្នុងការលើកស្ទួយដល់ការអភិវឌ្ឍន៍។

[៥៣] ទស្សនវដ្តី Financial Times ឆ្នាំ១៩៩៥ ដឹកសុន- Dixon ឆ្នាំ១៩៩៥

ក្នក់ភ្លើងសង្គ្រាមស៊ីវិលដ៏បង្ហូរឈាមយ៉ាងពេញទំហឹង។ នៅនិរទេសខ្លួន **សម្តេច សីហនុ** បានបង្កើត "រណសិរ្ស បង្រួបបង្រួមជាតិ" ជាមួយពួកកុំម្មុយនីស្ត ដែលក្លាយទៅជាខ្មែរក្រហម(KR) ហើយដែលចាប់ផ្តើមទាក់ទាញការ គាំទ្រយ៉ាងទូលំទូលាយពីប្រជាជនលើកទី១។ ប៉ុន្តែនៅក្នុងរណសិរ្សនោះខ្មែរក្រហមបានពង្រឹងអំណាចខ្លួន ដោយបោសសំអាតក្រុមសីហនុនិយម និងក្រុមនិយមកណ្តាល។ ជាមួយនឹងជោគជ័យរបស់ខ្មែរក្រហមនៅថ្ងៃទី ៧ មេសា ឆ្នាំ១៩៧៥ បនជ្រុលនិយមពោរពេញដោយគំនិតខាងស្នេហាជាតិជ្រុល និងការប្តេជ្ញាចិត្តអនុវត្ត កសិកម្ម កុំម្មុយនីស ដែលគ្មានការសម្រុះសម្រួលបានមកត្រួតត្រារដ្ឋបដិវត្តកម្ពុជាប្រជាធិបតេយ្យ(DK)។ ទីក្រុង ទាំងឡាយគ្មានប្រជាជនរស់នៅ ហើយសាសនា និងរូបិយវត្ថុត្រូវបានលុបបំបាត់ចោល។ ទោះបីភាពតឹងតែនៃ ការបដិវត្តន៍ប្រែប្រួលតាមតំបន់នានាក៏ជីវិតនៅគ្រប់ទីកន្លែងមានចរិកលក្ខណៈជាការងារពលកម្មធ្ងន់ធ្ងរ គ្មាន ឈប់សម្រាក ការបង្អត់អាហារ និងការគំរាមកំហែងសម្លាប់ចោល[៥៤]។ មានការប៉ាន់ស្មានថា នៅរវាងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប្រជាជនប្រមាណ ២លាននាក់ លើសពីម្នាក់ក្នុងមនុស្ស ៥នាក់ បានស្លាប់ក្នុង "ស្ថ័យប្រល័យពូជ សាសន៍"នេះ។ ប្រជាជនភាគច្រើនបានស្លាប់ដោយការអត់ឃ្លាន ការនឿយហត់ បាក់កម្លាំង និងជំងឺ តែមនុស្ស ប្រហែល ២០០.០០០នាក់ ត្រូវបានប្រហារជីវិតជាប្រព័ន្ធ។ នាយទាហាន និងមន្ត្រី លន់ នល់ ត្រូវបានសម្លាប់ នៅឆ្នាំ១៩៧៥។ នៅឆ្នាំក្រោយៗមកទៀត អ្នកដែលត្រូវបានប្រហារជីវិតដោយការបដិវត្តន៍ គឺជាខ្មែរក្រហមខ្លួន ឯងតែម្តង។

ក្នុងចំណោមកក្តាផ្សេងទៀត ក្រុម ប៉ុល ពត ត្រូវបានអូសទាញដោយបំណងចង់ទាមទារយកដែនដី សណ្តារទន្លេមេគង្គវិញ ដែលបានបាត់បង់ទៅក្នុងការកាន់កាប់របស់វៀតណាមតាំងពីសតវត្សទី១៧។ ការវាយ លុកទៅលើភាគខាងត្បូងវៀតណាម បានសម្លាប់ជនស៊ីវិលរាប់ពាន់នាក់ ទើបនាំអោយវៀតណាមមានការផ្ទុះ សង្គ្រាមតបតនៅខែធ្នូ ឆ្នាំ១៩៧៨។ កម្ពុជាប្រជាធិបតេយ្យ ត្រូវបានជំនួសដោយសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (PRK)វិញ។ មានសមាសភាពដោយអតីតខ្មែរក្រហម ដែលបានរត់ភៀសខ្លួនពីការបោសសំអាត សាធារណរដ្ឋ-ប្រជាមានិតកម្ពុជា បានត្រួតត្រាក្នុងកំឡុងទសវត្សឆ្នាំ៨០។ ដោយមហាអំណាចក្រៅប្រទេសបានគាំទ្រម្ខាងៗ សារជាថ្មីទៀត នោះប្រទេសកម្ពុជាបានវិលត្រឡប់ទៅកាន់សង្គ្រាមស៊ីវិលជាលើកទី២ រវាងរដ្ឋាភិបាលសាធារណ-រដ្ឋប្រជាមានិតកម្ពុជា និងក្រុមសម្ព័ន្ធមិត្តទំពែ ដែលធ្វើប្រតិបត្តិការយោធាខាងក្រៅជំរុំដែនភៀសខ្លួននៅតាមព្រំ ដែនថៃ។ សង្គ្រាមនេះមានប្រពលភាពកម្រិតទាបជាងមុនទេ តែបានធ្វើអោយប្រទេសជាតិខ្សោយយ៉ាងធំធេង។ ជម្លោះនេះបានបន្តក្នុងកំឡុងទសវត្សឆ្នាំ៨០។

រដ្ឋាភិបាលនេះមិនអាចសម្រេចបានការលូតលាស់ ឬការកាត់បន្ថយភាពក្រីក្រជាដុំកំភួនឡើយ (ប្រទេសនេះត្រូវបានកាត់ផ្តាច់ពាណិជ្ជកម្មពីសហគមន៍ក្រៅពីសមាជិកក្រុមប្រឹក្សា សម្រាប់ជំនួយសេដ្ឋកិច្ចទៅ វិញទៅមក(COMECON) និងពីប្រព័ន្ធជំនួយអន្តរជាតិស្ទើរតែទាំងអស់) តែរដ្ឋាភិបាលនេះបានចាត់ចែងធ្វើអោយ

[៥៤] សម្រាប់ទស្សនៈវិស័យផ្សេងទៀត សូមមើលសៀវភៅរបស់ ប៊ឺគ្លែរ(Burgler) ឆ្នាំ១៩៩0, ឆេនដ្លែរ(Chandler) ឆ្នាំ១៩៩0, វិគីរី(Vickery) ឆ្នាំ១៩៨៤, ឃានែន(Kiernan) ឆ្នាំ១៩៩៦

ស្តេរភាពទូរ្ភិក្សមានស្តេរភាពនៅឆ្នាំ១៩៧៩ ហើយបានធ្វើអោយការស្តារឡើងវិញនូវប្រព័ន្ធការសិក្សា និងការ ព្យាបាលជំងឺជាមូលដ្ឋានមានល្បឿនទៅមុខយឺតៗតែជាប្រចាំ។ ប្រជាជនត្រូវបានរៀបចំជា "ក្រុមសាមគ្គី" សមូហភាវូបនីយកម្មថ្នាក់ក្រោមនេះ បានជានាអោយមានសមភាពក្នុងការទទួលបានកម្លាំងពលកម្មបុរស ដែលនៅខ្សត់ និងប្រមូលបានកម្លាំងសត្វអូសទាញនៅឆ្នាំ១៩៧៩-៨០ ប៉ុន្តែនៅពេលសេដ្ឋកិច្ចបានងើបឡើងវិញ ការណ៍នេះត្រូវបានមើលឃើញថា ជាឧបសគ្គដល់កំណើនសេដ្ឋកិច្ចទៅវិញ។ ការរំសាយសមូហភាវូបនីយកម្ម ដែលឥតគ្រោងទុកមានរូបរាងឡើងតាមរយៈសេរីភាវូបនីយកម្ម និងការបែងចែកដីនៅឆ្នាំ១៩៨៩ បានធ្វើអោយ ទិន្នផលទទួលបានប្រសើរឡើង ហើយត្រូវបានស្វាគមន៍ដោយប្រជាជនស្ទើរតែទាំងអស់ ទោះបីក្រុមងាយទទួល រងគ្រោះទាំងឡាយបានបាត់បង់ផ្នែកសំខាន់នៃសន្តិសុខសង្គមក៏ដោយ[៥៥]។

តំណាក់កាលទាំងបីរបស់ប្រទេសកម្ពុជា ក្នុងសម័យអន្តរកាលសន្តិភាព ប្រជាធិបតេយ្យ និងសេដ្ឋកិច្ចទីផ្សារ គឺនៅឆ្នាំ១៩៨៩ វៀតណាមបានដកកងទ័ពរបស់ខ្លួន។ ជម្លោះនេះបានធ្វើអោយស្ថានភាពយោធានៅទ្រឹង និងក្រោយមកត្រូវបានដោះស្រាយដោយកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១។ ការណ៍នេះនាំអោយមានកិច្ចប្រតិបត្តិការរបស់កងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដែលទាមទារ ចំណាយយ៉ាងច្រើន និងវិសាលភាពធំមិនធ្លាប់មានពីមុន ដើម្បីត្រួតពិនិត្យសម័យអន្តរកាលពីរដ្ឋដែលមានប្រព័ន្ធ បក្សតែមួយ និងសង្គ្រាមស៊ីវិលមកជាលទ្ធិប្រជាធិបតេយ្យពហុបក្សប្រកបដោយសន្តិភាពវិញ។ អាជ្ញាធរបណ្តោះ អាសន្នអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា(UNTAC)មានអាណត្តិត្រួតពិនិត្យដកអាវុធ និងការ រំសាយកងទ័ពរៀបចំមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនភៀសខ្លួនចំនួន ៣៥០.០០០នាក់ ពីព្រំដែនថៃ សម្របសម្រួលជំនួយអន្តរជាតិសម្រាប់ការចូលរួមស្តាបនាជាតិឡើងវិញ និងធានាអោយមានលក្ខខ័ណ្ឌសម្រាប់ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌រវាងភាគីក្នុងសង្គ្រាមស៊ីវិល ដែលក្លាយមកជាគណបក្សនយោបាយវិញ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានចាប់ផ្តើមមានទំនាក់ទំនងជាមួយកម្ពុជាវិញ ហើយទីភ្នាក់ងារជំនួយ និងអង្គការ ក្រៅរដ្ឋាភិបាលអន្តរជាតិ ដែលធ្វើការនៅទូទាំងប្រទេសបានកើតឡើងដូចផ្សិត[៥៦]។

តាំងពីឆ្នាំ១៩៩៣ ប្រទេសកម្ពុជាមានកំណើតសេដ្ឋកិច្ចជាមធ្យមខ្ពស់ក្នុងរយៈពេលជាងមួយទសវត្ស ដែលដឹកមុខដោយអនុវិស័យសំណង់ វិស័យទេសចរណ៍ និងចាប់តាំងពីចុងទសវត្សឆ្នាំ៩០ មកការងើបយ៉ាង ឆាប់រហ័សនៃវិស័យកាត់ដេរ ដែលបានទទួលការអនុគ្រោះក្រោមកិច្ចព្រមព្រៀងវាយនភ័ណ្ឌ(MFA) និងកូតា សម្រាប់ផលិតសំលៀកបំពាក់តាមស្តង់ដារការងារ ទទួលស្គាល់ដោយអង្គការពលកម្មអន្តរជាតិ។ ការវិលទៅរក អំពើហិង្សានយោបាយ និងឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុនៅអាស៊ី នៅប្រទេសថៃ និងការដកចេញរបស់អង្គការមូល

[៥៥] សៀវភៅលោក ហ្វ្រីង Frings ឆ្នាំ១៩៩៣

[៥៦] សម្រាប់ការវាយតម្លៃឆ្លាស់ពីផលប៉ះពាល់របស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ នៅប្រទេសកម្ពុជា (UNTAC) សូមអានសៀវភៅអង្គការសហប្រជាជាតិ(UN) ឆ្នាំ១៩៩៥ អ៊ុតទីង(Utting) ឆ្នាំ១៩៩៤ ហ្វឺនឡេ(Fendlay) ឆ្នាំ ១៩៩៥ មីត(Metzl) ឆ្នាំ១៩៩៥ និងហ្វ្រីសុន(Frieson) ឆ្នាំ១៩៩៦

និងរូបិយវត្ថុអន្តរជាតិ ដែលជាកាយវិការតបតទៅនឹងចំណុចខ្សោយក្នុងការគ្រប់គ្រងប្រាក់ចំណូលព្រៃឈើ ដែលចេះតែមានបន្តបានបង្កើតនូវការចុះថយសេដ្ឋកិច្ចក្នុងរយៈពេលខ្លីនៅចុងទសវត្សឆ្នាំ៩០។

ប៉ុន្តែចាប់តាំងពីពេលនោះមក ការងើបឡើងវិញនៃសេដ្ឋកិច្ចមានល្បឿនគួរសម។ ការរីកចម្រើនត្រូវបានពង្រឹងដោយការដួលរលំចុងក្រោយរបស់កុប្បកម្មខ្មែរក្រហមនៅឆ្នាំ១៩៩៩។ ទោះវិស័យកសិកម្មបានបន្តកើនឡើងយ៉ាងយឺតដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួតយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេល ៣ឆ្នាំចុងក្រោយដែលជាទូទៅធ្វើអោយអត្រាទាបនៃផលិតភាព ឬប្រាក់ចំណូលរឹតតែមានសភាពធ្ងន់ធ្ងរជាងមុន មានការរីកដុះដាល់នៃឱកាសរកប្រាក់នៅភ្នំពេញក្រៅពីការដាំដុះ ឬឆ្លងដែនទៅប្រទេសថៃ ដែលនាំអោយមានការកើនឡើងនៃពលកម្មទេសន្តរ-ប្រវេសន៍ ហើយការផ្ញើប្រាក់ទៅផ្ទះជាទិដ្ឋភាពសំខាន់នៃជីវភាព និងការផ្លាស់ប្តូរសង្គម-សេដ្ឋកិច្ចនៅជនបទ។ ប៉ុន្តែស្ថាប័ននយោបាយ និងប្រពៃណីនៃការប្រកួតប្រជែងនយោបាយ ដោយសន្តិវិធីនៅតែមានសភាពអន់ថយនៅឡើយ។

សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់បាតុកម្មប្រឆាំងថៃ កុំអោយចេញផុតពីការគ្រប់គ្រងក្លាយទៅជាចលាចល(និងកិច្ចព្រមព្រៀងសងដែលមានតម្លៃខ្ពស់) នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៣ និងការខកខានរបស់គណបក្សនយោបាយក្នុងការព្រមព្រៀងបង្កើតរដ្ឋាភិបាលចម្រុះអស់រយៈពេលជាង ១ឆ្នាំ បន្ទាប់ពីការបោះឆ្នោត ២០០៣ ដោយសារការជាប់គាំងខាងនយោបាយ បានបញ្ជាក់ថា ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម នឹងអាចទទួលរងការជើរថយក្រោយមួយរយៈ ដែលបណ្តាលអោយមានផលិផលថ្មីរបស់គូប្រជែងនយោបាយ។ លើផ្នែកវិជ្ជាមានការបោះឆ្នោត ឃុំ/សង្កាត់នៅឆ្នាំ២០០២ បានបង្កើតរដ្ឋអំណាចមូលដ្ឋានទូទាំងប្រទេសលើកទី១ ជាមួយនឹងការសន្យាថា នឹងមានផលចំណេញជាបន្តបន្ទាប់ក្នុងការចូលរួម និងការទទួលខុសត្រូវ(សៀវភៅ ហាសែលស្កូក Hasselskog តោ-ឆ្នាំ២០០០ និង ហេក-Nikh and Henke ឆ្នាំ២០០៤[៥៧]។

ដោយសង្ខេបមក ប្រទេសកម្ពុជាបាននឹងកំពុងអនុវត្តគោលការណ៍ទាំងបីក្នុងសម័យអន្តរកាលតាំងពីដើមឆ្នាំ១៩៩០ ។ ទីមួយ ប្រទេសកម្ពុជាបានចេញផុតពីសង្គ្រាមស៊ីវិលមកសន្តិភាព។ ទីពីរ ប្រទេសកម្ពុជាបានអនុវត្តពីនយោបាយបក្សតែមួយមកពហុបក្សនៅក្នុងសម័យអន្តរកាល។ ទីបផុតប្រទេសកម្ពុជាបានរួចផុតពីសេដ្ឋកិច្ចឯកកោ មានកំណើនទាបគ្រប់គ្រងដោយរដ្ឋ និងតម្រង់ទិសដើម្បីគ្រាន់តែរស់ដែលក្នុងនោះ មនុស្សភាគច្រើនស្ថិតក្នុងភាពក្រីក្រដូចគ្នា មករកបែបជាសេដ្ឋកិច្ចទីផ្សារ ដែលបើកចំហរដល់លំហូរមូលធនទំនិញ និងពលកម្មអន្តរជាតិ ដែលក្នុងនោះកំណើនសេដ្ឋកិច្ចបានទាញប្រជាជនមួយចំនួនធំចេញពីបន្ទាត់ភាពក្រីក្រ ប៉ុន្តែវិសមភាពនេះ បានកើតឡើងយ៉ាងលឿនៈ មនុស្សមួយចំនួនធំមិនបានបែងចែកនៅកំណើនសេដ្ឋកិច្ចទេ ហើយអ្នកខ្លះកំពុងទទួលរងការធ្លាក់ចុះនៃកម្រិតជីវភាព។ ក្នុងសម័យអន្តរកាលនេះ ប្រភេទការងារមួយចំនួនត្រូវបានសម្រេចច្រើនជាងចំនួនប្រភេទការងារផ្សេងៗទៀត។ ទន្ទឹមនេះផងដែរ សម័យអន្តរកាលនេះក៏បានផ្តល់នៅទម្រង់នៃការ

[៥៧] រចនាសម្ព័ន្ធរដ្ឋបាលរបស់ប្រទេសកម្ពុជាមានទាំងអស់ ២៤ ខេត្ត/ក្រុង ហើយថ្នាក់ក្រោមពីនេះមានខណ្ឌ/ស្រុក ឃុំ(ឬសង្កាត់សម្រាប់ទីក្រុង) និងភូមិ

ផ្លាស់ប្តូរសង្គមកិច្ច និងសេដ្ឋកិច្ចនូវកំណើនដែលមានឥទ្ធិពលខ្លាំងក្លា ប៉ុន្តែនៅតែមិនត្រូវបានយល់យ៉ាងច្បាស់លាស់នៅឡើយ។ ការផ្តល់និយមន័យដល់ពាក្យ "ក្រោយជម្លោះ" អំពើហិង្សានយោបាយ ដែលមានរយៈពេលយូរជាងការរំពឹងទុកមានផលប៉ះពាល់អវិជ្ជមានយ៉ាងជ្រៅដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃនេះ។ រយៈពេលជិត ៣ទសវត្សនៃជម្លោះផ្ទៃក្នុង ដែលធ្វើអោយរឹតតែមានសភាពអាក្រក់ជាងមុន ដោយសារគូប្រឆាំងក្នុងសង្គ្រាមត្រជាក់មិនគ្រាន់តែសម្លាប់ជីវិតមនុស្សរាប់លាននាក់ប៉ុណ្ណោះទេ ប៉ុន្តែបានធ្វើអោយខូចគ្រឹះច្រើននៃការអភិវឌ្ឍន៍ជាតិផងដែរ[៥៨]។

ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ: កេរ្តិ៍ដំណែលបន្សល់ពីជម្លោះត្រូវបានមើលឃើញច្បាស់លាស់ពីការធ្លាក់ចុះយ៉ាងខ្លាំងនៃមូលធនរូបវន្ត និងមូលធនមនុស្សរបស់ប្រជាជាតិ។ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ហេដ្ឋារចនាសម្ព័ន្ធជឹកជញ្ជូនមិនសមស្រប បានកំហិតតម្លៃ និងការពន្យាពេលធ្វើដំណើរដែលបង្កើនតម្លៃទំនិញនៅទីផ្សារ ឬតម្លៃវត្ថុធាតុដើមសម្រាប់ផលិតកម្ម ព្រមទាំងកំណត់លទ្ធភាពទទួលបានសេវាសុខាភិបាលផ្អែកលើមូលដ្ឋានសម្ភារៈ និងសេវាអប់រំ។ រចនាសម្ព័ន្ធគ្រប់គ្រងទឹកមានលក្ខណៈអន់ថយ ដែលទុកអោយប្រជាជនជាច្រើនទទួលរងគ្រោះដោយសារទឹកជំនន់ ឬគ្រោះរាំងស្ងួត(ជាញឹកញាប់គ្រោះមហន្តរាយទាំងពីរនេះក្នុងឆ្នាំតែមួយ)។ ទោះបីតាំងពីឆ្នាំ១៩៩៣មក សាលារៀន និងមន្ទីពេទ្យជាច្រើនត្រូវបានសាងសង់ ក៏បន្ទប់រៀន និងគ្រែមន្ទីពេទ្យនៅតែមិនគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់ប្រជាជននៅឡើយ។

ការធ្លាក់ចុះយ៉ាងខ្លាំងនៃមូលធនមនុស្ស: ប្រទេសកម្ពុជាមិនគ្រាន់តែបាត់បង់សម្ភារៈរូបវន្តសម្រាប់សកម្មភាពសេដ្ឋកិច្ច និងការផ្តល់សេវាប៉ុណ្ណោះទេ ប៉ុន្តែប្រទេសនេះក៏បានបាត់បង់នៅមូលធនមនុស្សចាំបាច់សម្រាប់ការអភិវឌ្ឍន៍ផងដែរនោះ គឺបញ្ហាវិន្តប្រកបដោយផាសុខភាពល្អ ដែលអាចធ្វើការងារអាជីវកម្មយ៉ាងប្រសើរ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងសេវាសាធារណៈ។ បញ្ហាវិន្តទាំងនោះដែលនៅឆ្នាំ១៩៧៥ ទទួលបានការអប់រំយ៉ាងល្អប្រសើរហាក់ដូចជាត្រូវស្លាប់ក្នុងកម្រិតសមាមាត្រក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ បើពួកគាត់បន្តរស់រានមានជីវិតក្រោយមកពួកគាត់ហាក់ដូចជា អាចនិរទេសខ្លួនក្នុងកម្រិតវិសមាមាត្រដែរ ហើយការសាងជីវិតជាថ្មីនៅបរទេស។ ជាលទ្ធផល ប្រទេសកម្ពុជាបានបាត់បង់មនុស្សពោរពេញដោយសមត្ថភាពខ្ពង់ខ្ពស់ជាច្រើន ហើយត្រូវតែស្តាបនារដ្ឋ និងសេដ្ឋកិច្ចកម្ពុជាឡើងវិញ ជាមួយនឹងវេជ្ជបណ្ឌិត គ្រូបង្រៀន អ្នកសេដ្ឋកិច្ច បញ្ហាវិន្ត ក្បែត្រសាស្ត្រ ឬវិស្វករតែមួយចំនួនតូចប៉ុណ្ណោះ។ គឺជាការលំបាកក្នុងការជំនួសជំនាន់មនុស្សដែលបាត់បង់នេះ។ ក្នុងរយៈពេលមិនដល់ ៤ឆ្នាំ ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ការអប់រំផ្អែកលើមូលដ្ឋានសាលារៀន ត្រូវបានកម្ទេចទាំងស្រុង ហើយនៅពេលដែលក្រោយមកសាធារណរដ្ឋប្រជាមានិតកម្ពុជា(PRK) បានខិតខំយ៉ាងខ្លាំងក្លាក្នុងការកសាងការអប់រំជាមូលដ្ឋានឡើងវិញរបបនេះមានធនធានក្នុងកម្រិតតិចតួចណាស់ដើម្បីធ្វើដូច្នេះ។

[៥៨] ហ៊ូដ Hughes ឆ្នាំ២០០៣

ទីបំផុតមនុស្សជាច្រើនដែលបានរស់រានមានជីវិតក្នុងទសវត្សឆ្នាំ៧០ មានបញ្ហាសុខភាពផ្លូវកាយ និង/ឬចិត្តសាស្ត្រ ដែលមិនអាចត្រូវបានដោះស្រាយយ៉ាងសមស្រប និងដែលកំណត់លទ្ធភាពក្នុងការរកប្រាក់ចិញ្ចឹមជីវិត។ ដោយពេលវេលាចេះតែកន្លងទៅមុខរបួសដោយសារសង្គ្រាម និងគ្រាប់មីននៅតែជាអម្រែកដ៏ធ្ងន់ធ្ងរដល់រដ្ឋាភិបាល ប៉ុន្តែជាញឹកញយរបួសទាំងនេះពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងភាពក្រីក្រយ៉ាងពិតប្រាកដ។ ហើយកង្វះខាតធ្ងន់ធ្ងរខាងផ្នែកអាហារូបត្ថម្ភនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ក៏នៅតែបន្តមានឥទ្ធិពលដែរ ពីព្រោះម្តាយដែលមានសុខភាពមិនល្អដោយសារការបរិភោគអាហារមិនសមស្រប បានបង្កើតទារកមានទំងន់ស្រាលដែលនឹងផ្ទេរភាពមិនអំណោយផលនេះពីជំនាន់មួយទៅជំនាន់មួយទៀត។

មូលធនសង្គមទន់ខ្សោយ និងស្ថាប័នរដ្ឋមិនឆ្លើយតបតាមសំណូមពរៈ ផលប៉ះពាល់ធ្ងន់ធ្ងរទៅលើរាងកាយក៏ដូចជាមូលធនមនុស្ស ការរីករាលដាលអំពើហិង្សានៅក្នុងទសវត្សឆ្នាំ៧០ និងអំពើហិង្សានៅក្នុងទសវត្សឆ្នាំ៨០ ដែលមានកម្រិតទាបជាងមុនតែធ្ងន់ធ្ងរជាងមុន បានប៉ះពាល់យ៉ាងជ្រាលជ្រៅទៅលើស្ថានភាពនៃការចាត់ចែងសង្គមកិច្ច និងសេដ្ឋកិច្ចប្រទេសកម្ពុជាស្ថាប័នរដ្ឋ និងការកំណត់ទំនាក់ទំនងរវាងរដ្ឋ និងសង្គម ព្រមទាំងសេដ្ឋកិច្ច ដែលរដ្ឋគ្រប់គ្រង។ ទិដ្ឋភាពជាច្រើនកេរ្តិ៍តំណែលផ្នែកស្ថាប័នរបស់ទាំងនោះត្រូវបានខូចខាតយ៉ាងដំណំចំពោះលទ្ធភាពវិជ្ជមានសម្រាប់ការអភិវឌ្ឍន៍យូរអង្វែង។ ទោះមិនអាចវាសបានក៏ជាការគួរអោយកត់សម្គាល់បើការទទួលរងអំពើហិង្សា ការបង្អត់មិនអោយមានសម្ភារៈចាំបាច់ ការឃ្លាំមើល និងការខិតខំបំផ្លិចបំផ្លាញរបស់ក្រុមកម្ពុជាប្រជាធិបតេយ្យនូវអត្តសញ្ញាណដែលមានស្រាប់ និងឆ្លាក់ដោយរួមទាំងអត្តសញ្ញាណគ្រួសារមានផលប៉ះពាល់យ៉ាងជ្រៅដល់លទ្ធភាពរបស់អ្នករស់រានមានជីវិត សម្រាប់ជឿទុកចិត្តធ្វើផែនការសម្រាប់រយៈពេលវែង និងបញ្ចេញសកម្មភាពជាសមូហភាព។ ការបង្កើតមូលដ្ឋានស្ថាប័នសម្រាប់សេដ្ឋកិច្ចទីផ្សារទំនើបប្រកបដោយប្រសិទ្ធភាពសម្រួលការចូលទៅកាន់ទីផ្សារសមធម៌ក្នុងការទទួលបានព័ត៌មានស្តីពីការផ្តត់ផ្តង់ និងសេចក្តីត្រូវការសកម្មសិទ្ធិលើទ្រព្យសម្បត្តិ ដែលមានតម្លាភាពសមធម៌ និងស្មោះភាពសមភាពក្នុងការទទួលបម្រើពាណិជ្ជកម្មគ្រប់រូបក្រោមច្បាប់ និងបទប្បញ្ញត្តិពាណិជ្ជកម្ម មិនទាន់ត្រូវបានបំពេញទាំងស្រុងនៅឡើយទេ។

ជាបន្តបន្ទាប់ការនេះឆ្លុះបញ្ចាំងថា បន្ទាប់ពីការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យរដ្ឋាភិបាល "ធម្មតា" មួយត្រូវតែបានបង្កើតឡើងសារជាថ្មី ក្នុងបរិបទនៃទុរ្ភិក្ស ដែលទើបនឹងចាប់ផ្តើមឡើង ការបំផ្លាញជាទ្រង់ទ្រាយធំការខ្វះខាតមូលដ្ឋានធនធានទាំងអស់ និងសង្គ្រាមស៊ីវិល។ រដ្ឋដែលទើបនឹងកើតឡើងមុខតែបារម្ភជាប្រាកដជាលើកដំបូងលើការបន្តរស់ទៅទៀត ហើយយកចិត្តទុកដាក់តិចតួចលើគណនេយ្យភាព ឬការបញ្ចូលគំនិតថ្មី។ ក្នុងវិសាលភាពណាមួយតំណែលនេះបានបន្តធ្វើអោយរចនាសម្ព័ន្ធរដ្ឋមានរូបរាង ព្រមទាំងទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងមន្ត្រីរាជការ។

ពីសន្តិភាពមកការកាត់បន្ថយភាពក្រីក្រៈ តំណែលបន្សល់ទុកដោយជម្លោះនៅតែមានវត្តមាននៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ប្រជាជនកម្ពុជាបច្ចុប្បន្ន។ ប៉ុន្តែរយៈពេល ៦ឆ្នាំបន្ទាប់ពីខ្មែរក្រហមសេសសល់ចុងក្រោយបានវិលមកចូលរួមរស់ក្នុងសង្គមជាតិវិញ និង១២ឆ្នាំ តាំងពីមានដំណោះស្រាយនយោបាយ ដែលនាំអោយ

ភាគីក្នុងជម្លោះសង្គ្រាមស៊ីវិលទាំងអស់ចូលរួមក្នុងប្រព័ន្ធប្រជាធិបតេយ្យ ជាជាងការប្រកួតប្រជែងដោយអាវុធ គឺជាការលំបាកឡើងៗក្នុងការដាក់បន្ទុកបញ្ហាកម្ពុជាទាំងអស់ទៅលើប្រវត្តិសាស្ត្រនៃជម្លោះនេះ តាមរបៀបសាមញ្ញ ឬដោយផ្ទាល់នោះ។ ប្រជាជនកម្ពុជាទាំងអស់ដឹកនាំ និងប្រជាពលរដ្ឋធម្មតា បានផ្តល់ជាកេរ្តិ៍មរតកនូវសង្គមក្រោយជម្លោះមួយ ប៉ុន្តែ១០ឆ្នាំកន្លងទៅ ពួកគាត់ធ្វើការជ្រើសរើស និងបានបញ្ចេញសកម្មភាពដែលបានចាប់ផ្តើមជាសមូហភាពធ្វើអោយជីវិតផ្ទាល់ និងផ្លូវនៃការប្រែប្រួលសង្គមកិច្ច និងសេដ្ឋកិច្ចផ្ទាល់របស់ពួកគាត់មានរូបរាងឡើង។ ៦០% នៃប្រជាជនមានអាយុ ២៤ឆ្នាំ ឬតិចជាងបានកើតក្រោយការដួលរលំរបស់ពួកខ្មែរក្រហមគ្មានការចងចាំពីសម័យកាលកម្ពុជាប្រជាធិបតេយ្យទេ ចំនួន ៥០% នៃប្រជាជនបានកើតក្រោយឆ្នាំ ១៩៨៥។ ហេតុនេះពួកគេមានការចងចាំតិចតួចនូវសម័យកាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬការតស៊ូជាតិដែលជាប្រភពដើមនៃគណបក្សនយោបាយបច្ចុប្បន្នរបស់ខ្លួន[៥៩]។

ឥទ្ធិពលនៃសង្គ្រាមស៊ីវិលក្នុងទសវត្សមុនៗនៅមានបន្ត ប៉ុន្តែឥទ្ធិពលនេះមិនបានទទួលការចាប់អារម្មណ៍ខ្លាំងឡើយ ហើយត្រូវបានមើលឃើញជាសំខាន់ពីស្ថានភាពរបស់ស្ថាប័នសង្គម និងនយោបាយព្រមទាំងទំនាក់ទំនងរវាងស្ថាប័នទាំងនេះ។ ដោយសម័យកាលជម្លោះចេះតែលុបបាត់ជាបន្តបន្ទាប់ពីការចងចាំជាសមូហភាពនោះប្រជាពលរដ្ឋទទួលស្គាល់ និងវាយតម្លៃខ្ពស់ពីភាពខុសគ្នា ដែលសន្តិភាពបាននាំមកអោយជីវិតរបស់ពួកគាត់។

សន្តិភាពបានបើកកាលានុវត្តភាព និងបានបង្កើតលទ្ធភាពនៃជីវិតប្រសើរជាងមុន:[៦០] នៅក្នុងគម្រោងស្រាវជ្រាវសម្រាប់ការសិក្សាស្រាវជ្រាវស្តីពីការចេញពីភាពក្រី អ្នកឆ្លើយក្នុងសម្ភាសន៍បានបញ្ជាក់ថា តើការបញ្ចប់ជម្លោះនយោបាយតាមអាវុធបានសម្រាលអម្រែកនៃការភ័យខ្លាច និងបានបើកកាលានុវត្តភាពជីវភាពយ៉ាងដូចម្តេច? ខ្លឹមសារគម្រោងនេះបានលេចចេញឡើងពីភូមិទាំងអស់ ការពិភាក្សាជាមួយអ្នកដឹកនាំមូលដ្ឋាន ដែលមានជីវភាពរុងរឿង និងអ្នកដែលកាន់តែក្រីក្រទៅៗ និងក្រុមយុវជន-យុវនារី។ ប៉ុន្តែសារៈសំខាន់នៃសន្តិភាពបានលេចចេញយ៉ាងខ្លាំងបំផុតពីភូមិដែលជម្លោះបានបញ្ចប់ក្នុងពេលថ្មីៗកន្លងទៅនេះ (ក្នុងភូមិខ្លះ ខ្មែរក្រហមនៅតែមានសកម្មភាពរហូតចុងទសវត្សឆ្នាំ៩០) និងជាពិសេសក្នុងចំណោមយុវជនក្នុងភូមិមួយចំនួន ដែលឆ្លុះបញ្ចាំងថាក្នុងរយៈពេលនៃទសវត្សឆ្នាមុន៨០ យុវជនទាំងនោះបានចូលបម្រើកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ភូមិខ្សាច់ជីរស់ ខេត្តកំពង់ធំ: មុនពេលកងទ័ព ប៉ុល ពត ចុះចូលជាមួយរដ្ឋាភិបាល អ្នកភូមិស្ទើរតែទាំងអស់មិនហ៊ានសម្រានក្នុងផ្ទះទេ។ ពួកគាត់បានសម្រានផ្ទាល់ដីជិតរណ្តៅសុវត្ថិភាពស្ទើរតែគ្រប់ពេលវេលា។ នៅរាល់ពេលដែលកងទ័ពខ្មែរក្រហម ឬកងទ័ពរដ្ឋាភិបាលចូលមកក្នុងភូមិពួកនេះយកមាន់ និងទារបស់យើង ឬដុតផ្ទះរបស់យើង បើយើងមិនចង់ប្រគល់របស់របរយើងទៅអោយពួកគេ។ នៅឆ្នាំ១៩៩៣ យើងមិនអាចទៅណា

[៥៩] ការពិនិត្យឡើងវិញលើអត្រាចំនួនប្រជាជនពី Neupert 2005

[៦០] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI ឆ្នាំ២០០៦

មកណាដោយសេរីទេ យើងត្រូវតែសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន។ ផ្ទុយទៅវិញនៅឆ្នាំ១៩៩៨ យើងមានសេរីភាពជាងមុនពីព្រោះ យើងអាចទៅទីកន្លែងណាក៏បាន ហើយសហគមន៍យើងមានសុវត្ថិភាពបន្ទាប់ពីសមាហរណកម្មរបស់ខ្មែរក្រហមមក។

ភូមិជាងក្តារ ខេត្តកំពង់ធំ: មុនពេលសមាហរណកម្មខ្មែរក្រហមនៅឆ្នាំ១៩៩៨ សហគមន៍នេះគ្មានសុវត្ថិភាពទេ ព្រោះតំបន់នេះ គឺជាមូលដ្ឋានរឹងមាំរបស់ខ្មែរក្រហម។ នៅពេលនោះស្ថានការណ៍គ្មានស្ថេរភាពទេ ប្រជាជនត្រូវតែរៀបចំអោយបានល្អ ហើយត្រៀមជាស្រេច ដើម្បីរត់គេចេញពីការទម្លាក់គ្រាប់បែក។ ពួកគាត់មានអារម្មណ៍ថា គ្មានសុវត្ថិភាព ហេតុនេះពួកគាត់ដែលខ្វល់ខ្វាយពីការសាងសង់ ឬពីការកែលម្អផ្ទះសម្បែងពួកគាត់ទេ... ដោយហេតុផលនេះហើយទើបយើងតែងតែគិតដល់សន្តិសុខជាដំបូងមុនគេ ហើយយើងមានពេលតិចណាស់សម្រាប់គិតអំពីជីវិតសេដ្ឋកិច្ចរបស់យើង។ នៅពេលនោះខ្ញុំខ្វល់តែពីឆ្នាំង និងចានខ្ញុំជាជាងពីវត្ថុឥតប្រយោជន៍ផ្សេងទៀត នៅពេលដែលមានការប្រយុទ្ធដ៏សាហាវកើតឡើងនៅក្នុងសហគមន៍នេះម្តងៗ។ ខ្ញុំមិនដែលគតិទាល់តែសោះពីការរកប្រាក់ និងពីការកែលម្អកម្រិតជីវភាពរបស់គ្រួសារខ្ញុំព្រោះ ខ្ញុំគ្មានពេលគិតពីរឿងនេះទេ។ ការងារតែមួយដែលខ្ញុំត្រូវធ្វើ គឺរៀនគេចខ្លួនចេញពីការទម្លាក់គ្រាប់បែក។

ភូមិកញ្ជរ ខេត្តក្រចេះ : ភូមិនេះរួចផុតពីជម្លោះអាវុធ បន្ទាប់ពីការចុះចូលរបស់កងទ័ពខ្មែរក្រហមទាំងអស់នៅឆ្នាំ១៩៩៨។ ការទទួលបានសន្តិភាពបានជួយកែលម្អជីវភាពរបស់ប្រជាជននៅក្នុងតំបន់នេះជាច្រើន។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកគាត់កំពុងមើលទៅអនាគតខាងមុខ និងក្តីបារម្ភចំពោះបញ្ហាផ្សេងៗទៀត ពាក់ព័ន្ធនឹងកាលានុវត្តភាពសេដ្ឋកិច្ច ដែលពួកគាត់ និងកូនចៅពួកគាត់ត្រូវប្រឈមមុខ ដូចជា គុណភាពសេវាដែលពួកគាត់ទទួលបានពីរដ្ឋ និងការយល់ឃើញពីវិសមភាពដែលកំពុងរីកធំឡើង និងកំពុងចាក់ឬសយ៉ាងជ្រៅទៅៗពិបាកកែ។

នៅពេលដែលរាជរដ្ឋាភិបាលរិះរកផ្នែរការយល់ឃើញ និងការពិតរបស់ប្រទេសកម្ពុជាពីស្ថានភាពប្រទេសក្រោយជម្លោះទៅជាស្ថានភាពប្រទេសកំពុងអភិវឌ្ឍន៍ "ធម្មតា" វិញដែលប្រជាពលរដ្ឋកម្ពុជាកំពុងបង្កើតសម័យអន្តរកាលនេះដែរ។ ជាផ្នែកមួយនៃអន្តរកាលនេះ ការរំពឹងប្រាថ្នាចង់បានរបស់ពួកគាត់កំពុងកើនឡើង។ ការរំពឹងប្រាថ្នាចង់បានទាំងនេះមានចំពោះបញ្ហានៃដំណើរការ(មានការកើនឡើងនៃការយល់ដឹង និងសារៈសំខាន់ពាក់ព័ន្ធនឹងគោលគំនិតនៃសិទ្ធិឯកត្តជននីតិរដ្ឋ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយក្នុងការប្រើធនធានដោយសុច្ចរិត និងដើម្បីផលប្រយោជន៍សាធារណៈ) និងលទ្ធផលរបស់ការងារ។ ប្រជាពលរដ្ឋចង់ឃើញការរឿនលឿនក្នុងកម្រិតជីវភាព និងក្នុងគុណភាពផ្តល់សេវាសាធារណៈ ដែលពួកគាត់ទទួលបានពីរដ្ឋាភិបាល។ ប្រជាជនកម្ពុជាអាចនឹងមានការរំពឹងប្រាថ្នាទទួចចង់បានវឌ្ឍនភាពសមហេតុផល ព្រមទាំងមានអារម្មណ៍ថា ពួកគាត់អាចអោយអ្នកដឹកនាំ ដែលទទួលសន្លឹកឆ្នោតពីពួកគាត់ទទួលខុសត្រូវដោយមិនគិតថាប្រទេសកម្ពុជាកំពុងតែដោះស្រាយតំណែលក្រោយជម្លោះឡើយ។ ស្តង់ដារកម្រិតខ្ពស់ដូចគ្នាទាំងនេះក៏នឹងត្រូវរំពឹងទុកពីអ្នកធ្វើសកម្មភាពដ៏មានឥទ្ធិពល ដែលប៉ះពាល់ជីវិតរបស់ពួកគាត់រួមទាំងម្ចាស់ជំនួយផងដែរ។

ការវាយតម្លៃការកាត់បន្ថយភាពក្រីក្រក្នុងបរិបទក្រោយជម្លោះ: ជាការពិតប្រទេសកម្ពុជាមានលក្ខណៈមិនធម្មតា ប៉ុន្តែមិនមែនមានតែមួយនោះទេ ក្នុងបទពិសោធន៍ក្រោយជម្លោះនោះ។ នៅពេលដែលខ្លឹមសារនៃសង្គ្រាម និងការបដិវត្តន៍ក្នុងរយៈពេលច្រើនទសវត្សមិនអាចត្រូវបានមើលស្រាលនោះ បទពិសោធន៍អន្តរជាតិផ្តួចផ្តើមគំនិតផ្តល់ឧទាហរណ៍ វិជ្ជមានរបស់ប្រទេសដទៃផ្សេងទៀត ដែលទើបតែចេញផុតថ្មីៗពីជម្លោះ ផ្ទៃក្នុងរយៈពេលច្រើនទសវត្សដូចគ្នា(ឧទាហរណ៍ ប្រទេសម៉ូហ្សំប៊ីក) ឬប្រទេសដែលនៅទទួលរងគ្រោះពីជម្លោះរហូតដល់សព្វថ្ងៃក្នុងផ្នែកយ៉ាងធំនៃបូរណភាពរបស់ខ្លួន(ឧទាហរណ៍ ប្រទេស អ៊ូហ្គានដាបានបង្ហាញពីជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការធ្វើវិភាជន៍ធនធានទាំងប្រាក់ចំណូលក្នុងស្រុក និងជំនួយដើម្បីសម្រេចជោគជ័យគួរកត់សម្គាល់ក្នុងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ធនធានមនុស្ស)។

ការកាត់បន្ថយភាពក្រីក្រក្នុងសង្គមក្រោយជម្លោះមេរៀន ដែលទាញចេញពីបទពិសោធន៍អន្តរជាតិ:[៦១]

ប្រទេសអ៊ូហ្គានដា: បន្ទាប់ពីឯករាជ្យភាពនៅឆ្នាំ១៩៦២ ប្រទេសអ៊ូហ្គានដា បានទទួលរងនូវអស្ថេរភាព និងសង្គ្រាមស៊ីវិលយូរអង្វែងដែលធ្វើអោយប្រទេសនេះកាន់តែក្រីក្រ។ នៅឆ្នាំ១៩៨៦ កងទ័ពតស៊ូជាតិរបស់លោកយូវើរីមូលសឺវើនី(Yoweri MUserveni) បានដណ្តើមយកអំណាច និងបាននាំសន្តិភាពមកអោយដល់តំបន់ភាគច្រើននៃប្រទេសអ៊ូហ្គានដា ទោះបីកុប្បកម្មនៅតែបន្តរហូតដល់សព្វថ្ងៃក៏ដោយ។ ប្រព័ន្ធចលនា "គ្មានបក្ស" នេះបានខិតខំអោយខ្លួនបានក្លាយទៅជាប្រព័ន្ធដែលបញ្ចូលគំនិតទាំងអស់ និងផ្អែកលើការព្រមព្រៀងគ្នាដែលកម្រិតសកម្មភាពរបស់គណបក្សនយោបាយយ៉ាងខ្លាំងដោយលោក មូលសឺវើនី អះអាងថា រាល់សកម្មភាពទាំងនេះមានពាក់ព័ន្ធនឹងការកើនឡើងនៃជម្លោះក្នុងពេលអតីតកាល។ ជាមួយនឹងប្រព័ន្ធនយោបាយនេះលោកមូលសឺវើនី និងចលនារបស់គាត់បានបន្តការកាត់បន្ថយភាពក្រីក្រ ដោយចាត់ទុកថា ជាគម្រោងនយោបាយសម្រាប់កាត់បន្ថយវិសមភាព ដែលធ្វើអោយគ្មានស្ថេរភាព និងលើកកម្ពស់ឯកភាពជាតិ។ ជាលទ្ធផលបន្តបន្ទាប់ការកាត់បន្ថយភាពក្រីក្រក្នុងន័យជាទិសដៅនយោបាយបានក្លាយជាគម្រោងបច្ចេកទេសប្រជាធិបតេយ្យជាតិនៅក្នុងក្រសួងហិរញ្ញវត្ថុ ផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច(MFDED) ដែលបានប្រែក្លាយទស្សនវិស័យនយោបាយទៅជាឧបករណ៍ ដែលគួរជឿទុកចិត្តក្នុងភ្នែករបស់អ្នកចូលរួមគន្លឹះនៅក្រៅប្រទេស។ កត្តាស្នូលនៃក្របខ័ណ្ឌការងារជាយុទ្ធសាស្ត្រ គឺផែនការសកម្មភាពលុបបំបាត់ភាពក្រីក្រ(PEAP) ដោយមានការគាំទ្រពីក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម(MTEF) យុទ្ធសាស្ត្រវិស័យ និងក្រុមការងារមូលនិធិសកម្មភាពក្រីក្រ ដែលការពារចំណាយអាទិភាព ផ្តោតលើភាពក្រីក្រដើម្បីអោយមានការធ្លាក់ចុះនៃថវិកា និងគម្រោងវាយតម្លៃការចូលរួមកាត់បន្ថយភាពក្រីក្រ ដែលបានផ្តល់យោបល់មូលដ្ឋានថ្នាក់ក្រោមដ៏សំខាន់ស្តីពីប្រសិទ្ធភាពនៃគោលនយោបាយដែលអាចលើកឡើងពីបញ្ហាទាំងឡាយដើម្បីដោះស្រាយ។ ដោយពិចារណាលើចំណុចខ្សោយរបស់ខ្លួននៅឆ្នាំ

[៦១] ពីរុន(Piron) និងណូតុន(Norton) ឆ្នាំ២០០៤, ហ្វូស្ទ័រ(Foster) និងមីហ៊ីរុមប៊ី(Mijumbi) ឆ្នាំ២០០៤, មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ឆ្នាំ២០០៣, ធនាគារពិភពលោក(World Bank) ឆ្នាំ២០០៥, គណៈកម្មាធិការសម្រាប់ទ្វីបអាហ្វ្រិក(Commission for Africa) ឆ្នាំ២០០៥, ឌីយ៉ូហ្គោ (Diogo) ឆ្នាំ២០០៥

១៩៨៦ ក្រសួងហិរញ្ញវត្ថុ ផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច បានពង្រីកការសិក្សាពីចំណាយសាធារណៈ និងការកាត់បន្ថយភាពក្រីក្រក្នុងពេលថ្មីៗកន្លងទៅនេះបានសន្និដ្ឋានថា "យើងដឹងថា គ្មានប្រទេសដទៃណាទៀត ដែលបានសម្រេចការផ្លាស់ប្តូរគួរអោយភ្ញាក់ផ្អើលក្នុងរបៀបចំណាយ ដើម្បីជួយជនក្រីក្រក្នុងរយៈពេលដ៏ខ្លីបែបនេះឡើយ"។ កំណើនពិប្រាកដនៃផលិតផលក្នុងស្រុក(GDP) បាននាំអោយភាពក្រីក្រធ្លាក់ចុះពី ៥៦% នៅឆ្នាំ ១៩៩២ មកនៅត្រឹម ៤៤% នៅឆ្នាំ១៩៩៧ និង៣៥% នៅឆ្នាំ២០០០។ ជោគជ័យនៃផែនការសកម្មភាពលុបបំបាត់ភាពក្រីក្រ(PEAP) គឺជាប្រភពយ៉ាងសំខាន់នៃការកើតជាគំនិតសម្រាប់អភិក្រមនៃឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលទទួលការគាំទ្រពីស្ថាប័នហិរញ្ញប្បទានអន្តរជាតិ(IFI) តាំងពីឆ្នាំ១៩៩៩ ក្នុងន័យជាកត្តាស្នូលនៃភាពជាដៃគូរសម្រាប់ជំនួយដ៏មានប្រសិទ្ធភាព។

ប្រទេសម៉ូហ្សាំប៊ីក: សង្គ្រាមស៊ីវិលដ៏យូរអង្វែង ដែលបញ្ឆោះដោយមហាអំណាចបរទេសបានចាប់ផ្តើមឡើងនៅប្រទេសម៉ូហ្សាំប៊ីកនៅឆ្នាំ១៩៧៥ ហើយបានសម្លាប់ប្រជាជនជិត ១លាននាក់ មុនពេលការសម្រេចសន្តិភាពនៅឆ្នាំ១៩៩២ ហើយការបោះឆ្នោតពហុបក្សលើកទី១ ត្រូវធ្វើឡើងនៅឆ្នាំ១៩៩៤។ ចាប់តាំងពីពេលនោះមកកំណើនសេដ្ឋកិច្ចដ៏ខ្លាំង(១២%ក្នុងមួយឆ្នាំ ក្នុងទសវត្សឆ្នាំ៩០) បានស្ថិតនៅជានិរន្តរភាពដោយសារការខិតខំប្រឹងប្រែងយ៉ាងហ្មត់ចង់ ដែលគាំទ្រដោយម្ចាស់ជំនួយ ដើម្បីកែលម្អអភិបាលកិច្ច និងគោលនយោបាយ។ រដ្ឋាភិបាលបានដោះស្រាយជាពិសេស ដើម្បីធ្វើអោយប្រសើរឡើងនូវបរិយាកាសអាជីវកម្ម ដែលអោយមានការកើនឡើងទ្វេដងនូវវិនិយោគឯកជនក្នុងនាមជាចំណែកមួយនៃផលិតផលក្នុងស្រុកសរុប(GDP)រវាងឆ្នាំ១៩៩៨ និងឆ្នាំ២០០៨។ ពីឆ្នាំ១៩៩៦ មានការប្តេជ្ញាចិត្តក្នុងការខិតខំប្រឹងប្រែងដើម្បីកែលម្អការប្រមូលប្រាក់ចំណូលដោយប្រយុទ្ធប្រឆាំងនឹងការគៃលួចបន្លំ និងការគេចពន្ធ ព្រមទាំងការអនុវត្តន៍វិធានការសម្រួលពាណិជ្ជកម្ម។ សព្វថ្ងៃការជម្រះទំនិញបានប្រព្រឹត្តទៅ ៤០ដងលឿនជាងមុនពេលមានការកែទម្រង់។ ក្នុងរយៈពេល២ឆ្នាំ ដំបូងនៃកំណែទម្រង់គយ ការនាំចូលបានធ្លាក់ចុះ ០,២% ប៉ុន្តែប្រាក់ចំណូលគយបានកើនឡើងប្រមាណ ៨,៤%។ កំណើនប្រាក់ចំណូលបាននាំអោយមានចំណាយលើវិស័យសង្គមកិច្ចក្នុងកម្រិតខ្ពស់ជាង និងមានប្រសិទ្ធិភាពជាងមុន។ កម្រិតខ្ពស់នៃជំនួយក្រោមកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ដែលមានសមត្ថភាព ក៏ហាក់ដូចជាបានដើរតួនាទីមួយយ៉ាងសំខាន់ដែរ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្តោតលើភាពក្រីក្រសម្រាប់រយៈពេលមធ្យមរបស់ប្រទេសម៉ូហ្សាំប៊ីក ដែលផ្អែកលើមូលដ្ឋានការស្រាវជ្រាវតម្រង់ទិសគោលនយោបាយ និងការចូលរួមយ៉ាងទូលំទូលាយរបស់សង្គមស៊ីវិល ការដាក់បញ្ចូលមុនគេនូវអភិក្រម ឯកសារជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ(PRSP) នៅថ្នាក់ពិភពលោក។ ម្ចាស់ជំនួយបានទទួលការបញ្ចុះបញ្ចូលដោយអ្នកដឹកនាំប្រទេសម៉ូហ្សាំប៊ីក ពីទស្សនៈវិស័យជាយុទ្ធសាស្ត្រ និងភាពស្មោះត្រង់ក្នុងការប្តេជ្ញាចិត្តធ្វើកំណែទម្រង់។ ហេតុនេះម្ចាស់ជំនួយបានយល់ព្រមសម្រួលទឹកប្រាក់ជំនួយតាមរយៈអភិក្រមទូទាំងវិស័យ។ ជាសំខាន់អត្រាកំណើនសេដ្ឋកិច្ចខ្ពស់មានជានិរន្តរភាពទោះបីនៅពេលអនុបាតជំនួយបានធ្លាក់ចុះយ៉ាងខ្លាំងក៏ដោយ។ ការណ៍នេះផ្តួចផ្តើមគំនិតថា ជំនួយត្រូវបានប្រើប្រាស់ដោយសុភវិនិច្ឆ័យ ដើម្បីសាងសង់គ្រឹះសម្រាប់ការរីកដុះដាលសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ ការផ្តុំកំណើនសេដ្ឋកិច្ច

និងការផ្តល់សេវាដែលកាន់តែប្រសើរឡើងបាននាំអោយទទួលនូវផលចំណេញយ៉ាងទូលំទូលាយ សម្រាប់កម្រិតជីវភាពរស់នៅចន្លោះឆ្នាំ១៩៩៤ និង ២០០២ ការស្លាប់របស់កុមារ ដែលមានអាយុក្រោម ៥ឆ្នាំ បានថយចុះពី ២៧៧ មកនៅត្រឹម ១៣៥ ក្នុងកំណើតកុមារចំនួន ១.០០០។ នៅរវាងឆ្នាំ១៩៩៩ និង ២០០៣ ចំនួនសិក្សានៅបឋមសិក្សា និងធម្យមសិក្សាបានកើនឡើងចំនួនប្រមាណ ៤៣%។ ភាពប្រសើរឡើងទាំងនេះបានឆ្លុះបញ្ចាំងក្នុងអត្រាភាពក្រីក្រដែលធ្លាក់ចុះ ១៤% ក្នុងរយៈពេល ៦ឆ្នាំពី ៦៩% នៅឆ្នាំ១៩៩៧ មកត្រឹម៥៤% នៅឆ្នាំ២០០៣។

ដោយព្យាយាមចម្រាញ់យកមេរៀនពីករណីទាំងនេះ ដែលពាក់ព័ន្ធនឹងប្រព័ន្ធនយោបាយខុសគ្នាឆ្ងាយខ្លឹមសាររួមមួយចំនួនដូចជាហាក់បង្ហាញអោយឃើញថា:

-សារៈសំខាន់នៃការប្តេជ្ញាកាត់បន្ថយភាពក្រីក្រជានិរន្តរភាពក្នុងនាមជាអ្នកដឹកនាំនយោបាយ។

-ការប្រែក្លាយការប្តេជ្ញានេះអោយទៅជាសកម្មភាពសាធារណៈ ប្រកបដោយប្រសិទ្ធភាពតាមរយៈការសមាហរណកម្មការធ្វើផែនការ និងដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

-ក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ សម្រាប់រយៈពេលមធ្យមដែលផ្តោតទៅលើភាពក្រីក្រ ផ្អែកលើមូលដ្ឋានទូលំទូលាយរបស់ជាតិ។

-បង្កើនដោយផ្អែកលើមូលដ្ឋាននៃការវិភាគសង្គមកិច្ច សេដ្ឋកិច្ចពាក់ព័ន្ធនឹងគោលនយោបាយសម្រាប់រកមូលហេតុនៃភាពកក្រីក្រ និងការកាត់បន្ថយភាពក្រីក្រ។

-ព្រមទាំងបង្កើតថ្មី និងតាមដានតាមរយៈយន្តការទាំងឡាយ(ការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអង្គការក្រៅរដ្ឋាភិបាលនៅប្រទេស ម៉ូហ្សាំប៊ីក យន្តការគណនេយ្យភាពមូលដ្ឋាន និងការវាយតម្លៃការចូលរួមកាត់បន្ថយភាពក្រីក្រប្រកបដោយរចនាសម្ព័ន្ធត្រឹមត្រូវនៅប្រទេសអ៊ូហ្គានដា) ដែលត្រូវបានបង្កើតឡើងដើម្បីអូសទាញសង្គមស៊ីវិលអោយរៀបចំ និង/ពង្រឹងការប្តេជ្ញាអនុវត្តគោលនយោបាយជួយជនក្រីក្រ។

ការគ្រប់គ្រងសន្តិភាព និងការអភិវឌ្ឍន៍: ការប្រែប្រួលសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងរយៈពេលក្រោយជម្លោះនៅប្រទេសកម្ពុជា: ពីឆ្នាំ១៩៩៣ រដ្ឋាភិបាលបានចាត់ចែងយ៉ាងសកម្ម ដើម្បីដាក់បញ្ចូលប្រទេសកម្ពុជាឡើងវិញទៅក្នុងទំនាក់ទំនងតំបន់ និងពិភពលោក(ឧទាហរណ៍ តាមរយៈការបន្តសមាជិកភាពសមាគមប្រជាជាតិអាស៊ីប៉ែកអាគ្នេយ៍(ASEAN) និងបន្ទាប់មកទៀតអង្គការពាណិជ្ជកម្មពិភពលោក(WTO) ក្រោយពីភាពឯកកោអស់រយៈពេល២ទសវត្សមក។ ការណ៍នេះកំពុងមានផលប៉ះពាល់ទៅលើសេដ្ឋកិច្ច និងសង្គមកម្ពុជាដែលរាជរដ្ឋាភិបាលកំពុងស្វះស្វែងយល់ និងគ្រប់គ្រង ដើម្បីចង្អុលបង្ហាញផ្លូវនៃការងើបឡើងវិញរបស់ជាតិ និងការអភិវឌ្ឍន៍។

ក្នុងន័យនៃការប្រែប្រួលសេដ្ឋកិច្ច ការធ្វើវិនិយោគ និងពាណិជ្ជកម្ម អន្តរជាតិកំពុងបង្កើតកាលានុវត្តភាពសម្រាប់ការងារ ឬការរកប្រាក់នៅក្នុងប្រទេសកម្ពុជា ឬក៏ក្នុងឋានៈជាពលករទេសន្តរប្រវេសន៍ក្នុងប្រទេសថៃជិតខាង។ នៅពេលជាមួយគ្នានេះ ការប្តូរទៅកាន់សេដ្ឋកិច្ចទីផ្សារបានផ្តល់កម្រៃពាណិជ្ជកម្ម ដែលមិនធ្លាប់មានពីមុនទៅលើដី និងធម្មជាតិ(ជាពិសេសសម្បត្តិព្រៃឈើ និងជលផល)។ ដោយគ្មានស្ថាប័នប្រកបដោយតម្លាភាព ឬ

គណនេយ្យភាពសម្រាប់គ្រប់គ្រងធនធានទាំងនេះ មានការប្រមូលទ្រព្យសម្បត្តិដែលកាន់តែកើនឡើងទៅក្នុងដៃអ្នកមានស្តុកស្តម្ភ។ ជាញឹកញយការប្រមូលផ្តុំធនធានទាំងនេះបានប៉ះពាល់ទៅលើការចំណាយផ្ទាល់របស់សហគមន៍ក្រីក្រនៅមូលដ្ឋាន ដែលពឹងផ្អែកលើលទ្ធភាពទទួលបានផលព្រៃឈើ និងទឹកដើម្បីដោះស្រាយសេចក្តីត្រូវការរបស់គ្រួសារគាត់ផ្ទាល់ ឬដើម្បីរកប្រាក់ចំណូល។ លើសពីនេះទៅទៀត ជាញឹកញយម្ចាស់កម្មសិទ្ធិថ្មីទាំងនេះទទួលបានធនធានដែលទើបត្រូវបានធ្វើឯកជនភាវូបនីយកម្មជាមួយនឹងអប្បហារយ៉ាងច្រើន(ពោលគឺរាជរដ្ឋាភិបាលមិនបានទទួលប្រាក់ចំណូលដែលខ្លួនរំពឹងថា ត្រូវបានហើយដែលសម្រាប់យកមកផ្តល់ហិរញ្ញ-ប្បទាន ដើម្បីធ្វើវិនិយោគក្នុងការអភិវឌ្ឍន៍នោះទេ) និងគ្រប់គ្រងធនធានទាំងនោះដោយផ្តោតលើការទាញយកផលចំណេញតែសម្រាប់រយៈពេលដ៏ខ្លីជាជាងទទួលបានលំហូរនៃផលចំណេញប្រកបដោយនិរន្តរភាព និងការរីករាលដាលទូលំទូលាយសម្រាប់រយៈពេលយូរអង្វែង។

ទំនាក់ទំនងសង្គមតម្លៃ និងការយល់ឃើញក៏កំពុងតែប្រែប្រួលដែរ ដោយមានការគិតគូរដល់ការកាត់បន្ថយភាពក្រីក្រ។ សព្វថ្ងៃការអនុវត្តជាក់ស្តែងនៃកិច្ចសហប្រតិបត្តិការ ឬការដោះដូរទៅវិញទៅមកទៅថ្នាក់ភូមិក្នុងពលកម្ម ឬចិញ្ចឹមសត្វ កំពុងបើកផ្លូវយ៉ាងពេញលេញដល់ការចាត់ចែងធ្វើពាណិជ្ជកម្ម ការប្តូរទៅជាពលកម្មទទួលប្រាក់បៀវត្សអាចនឹងផ្តល់ផលចំណេញដល់ជនក្រីក្រក្នុងរយៈពេលច្រើនឆ្នាំ ប៉ុន្តែក៏អាចបង្កើនភាពងាយរងគ្រោះដែរ។ នៅពេលជាមួយគ្នានេះ ការពឹងផ្អែកលើពលកម្មទេសន្តរប្រវេសន៍ក្នុងរយៈពេលខ្លី ឬវែងជាយុទ្ធសាស្ត្រសម្រាប់បន្តការរស់រានមានជីវិត និងជួនកាលបន្តចាត់ទុកថាជាជោគជ័យកំពុងមានឥទ្ធិពលយ៉ាងជ្រាលជ្រៅទៅលើលទ្ធភាពជំនះទុក្ខព្រួយរបស់រចនាសម្ព័ន្ធគ្រួសារ និងសហគមន៍ ប៉ុន្តែកំពុងតែចាប់ផ្តើមផ្តល់កំណើតលើរបៀបថ្មីនៃការគាំទ្រទៅវិញទៅមក(គណៈកម្មាធិការសេវារបស់មិត្តអាមេរិក AFSC អង្គារមូលនិធិសហប្រជាជាតិដើម្បីកុមារ UNICEF និងមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិប្រទេសកាណាដា IDRC ឆ្នាំ២០០០។

ក្នុងទសវត្សចុងក្រោយ ការកើនឡើងនៃការវែកញែកពីគោលគំនិតនយោបាយថ្មី(ឧទាហរណ៍ សិទ្ធិរបស់បុគ្គល និងការទទួលខុសត្រូវរបស់មន្ត្រីរាជការចំពោះម្ចាស់ឆ្នោត) និងគំរូនៃអង្គការសង្គម(ឧទាហរណ៍ អង្គការក្រៅរដ្ឋាភិបាល និងសហជីព) កំពុងផ្លាស់ប្តូររៀបដែលប្រជាជនកម្ពុជាគិតអំពីទំនាក់ទំនងរបស់ពួកគាត់ជាមួយរដ្ឋាភិបាល។ ការអប់រំ ដែលរីកសាយភាយជាងមុន ការងាយស្រួលច្រើនក្នុងការធ្វើដំណើរតាមដងផ្លូវល្អប្រសើរប្រកបដោយសន្តិសុខ និងការកើនឡើងនៃការផ្សព្វផ្សាយទូរទស្សន៍ក្នុងស្រុក និងបរទេស បទភ្លេង និងព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ កំពុងបង្កើនការយល់ដឹងរបស់ប្រជាជនស្តីពី ពិភពលោកដែលនៅឆ្ងាយពីសហគមន៍របស់ពួកគាត់។ ក្នុងដំណើរនេះឥទ្ធិពលសង្គម និងវប្បធម៌ថ្មីទាំងនេះកំពុងលើកម្ពស់ការរំពឹងប្រាថ្នាចង់បាន និងបង្កើនកម្រិតមនសិការ និងកង្វល់របស់ប្រជាជន ស្តីពីវិសមភាពដែលចេះតែកើនឡើងរវាងអ្នកមានទ្រព្យសម្បត្តិ និងជនក្រីក្រ។

ការវិភាគស្នើរតែទាំងអស់ក្នុងជំពូកនេះផ្តោតជាពិសេសក្នុងរយៈពេលពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០៤ ពីព្រោះឥឡូវយើងមានទិន្នន័យសង្គម-សេដ្ឋកិច្ចគ្រួសារថ្នាក់ជាតិ ដែលដកស្រង់ចេញពីការអង្កេតសង្គមកិច្ច-

សេដ្ឋកិច្ចនៅកម្ពុជា ឆ្នាំ១៩៩៣-៩៤(SESC) និងការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ២០០៤(CSES) សម្រាប់ឆ្នាំទាំងពីរនេះ[៦២]។ ទិន្នន័យនេះអនុញ្ញាតអោយយើងតាមដានការប្រែប្រួលនៃអត្រាភាពក្រីក្រ និងទិដ្ឋភាពក្រីក្រនៅចន្លោះកាលបរិច្ឆេទទាំងនេះ។

ការរកឃើញសំខាន់ពីការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចនៅកម្ពុជា ២០០៤(CSES 2004) និងការប្រៀបធៀបការអង្កេតនេះជាមួយនឹងការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ១៩៩៤(SESC 2004) ត្រូវបានសង្ខេបនៅក្នុងជំពូកទាំងពីរបន្ទាប់ទៅនេះ។ ដោយសារទិន្នន័យឆ្នាំ១៩៩៣-៩៤ នៅមានកម្រិតទិន្នន័យការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចឆ្នាំ២០០៤ និងត្រូវបានយកមកប្រើតាមរបៀបខុសគ្នា ដើម្បីពិនិត្យមើលស្ថានភាពក្រីក្រ និងផ្តល់ស្តង់ដារស៊ែនៅក្នុងឆ្នាំ២០០៤។

ការវិភាគលើទិន្នន័យអង្កេតគំរូដកស្រង់ចេញពីការអង្កេតសង្គម-សេដ្ឋកិច្ចឆ្នាំ១៩៩៣-៩៤ និងឆ្នាំ២០០៤ ត្រូវបានបំពេញបន្ថែមដោយព័ត៌មានបានពីប្រភពជាច្រើនផ្សេងទៀតស្តីពី ស្ថានភាព និងការប្រែប្រួលក្នុងកម្រិតជីវភាពបច្ចុប្បន្ន និងភាពក្រីក្រក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ឬយូរជាងនេះ។ កម្រងទិន្នន័យ ថ្នាក់ជាតិសំខាន់ៗ រួមមានការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០០០ (CDHS) និងការអង្កេតជំរឿនប្រជាជននៅកម្ពុជា(CIPS)។ លើសពីការអង្កេតតំណាងអោយថ្នាក់ជាតិទាំងនេះ របាយការណ៍នេះបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវនូវបរិបទខ្នាតតូចជាច្រើន ជាពិសេសការសិក្សាស្រាវជ្រាវស្តីពីការចាកចេញពីភាពក្រីក្រ(MOPS) ជាស្នាដៃរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍(CDRI)។

ការធានាសន្តិភាព ស្ថេរភាពនយោបាយ និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ គឺជាគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ដែលកើតឡើងដោយសារការបោះឆ្នោតតាំងពីឆ្នាំ១៩៩៣[៦៣]។ សព្វថ្ងៃសន្តិភាពត្រូវចុងក្រោយនេះតំណាងអោយ "ផលចំណេញសន្តិភាព" ដែលមានដោយកម្រនោះ គឺការកើនឡើងដំបូងដ៏ហ៊ាសពីមូលដ្ឋានកម្រិតទាបមែនទែន ពីព្រោះការកសាងសន្តិភាពឡើងវិញ ការទទួលស្គាល់ពីសហគមន៍អន្តរជាតិបានបង្កលទ្ធភាពជាថ្មីម្តងទៀតអោយមានកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្របន្ទាប់ពីជម្លោះក្នុងរយៈពេលជាង ២ទសវត្សមក និងបំពេញបន្ថែម ព្រមទាំងពង្រីកតាមរយៈ "ផលចំណេញគោលនយោបាយ" (ទោះបីសន្តិភាពសំខាន់ជាងសម្រាប់ពេលនេះក៏ដោយ)។ រដ្ឋាភិបាលសក្តិសមទទួលកិត្តិយសក្នុងការធានា និងថែរក្សាសន្តិភាព(ដោយមានការថយក្រោយដ៏ខ្លីក្នុងពេលខ្លះក៏ដោយ)។ រដ្ឋាភិបាលក៏សក្តិសមទទួលកិត្តិយសផងដែរសម្រាប់ការអោយទទួលបានផលចំពេញបន្ថែមទៀត ពីកំណើនសេដ្ឋកិច្ចដែលបានពីផលចំណេញសន្តិភាពតាមរយៈការបន្តយ៉ាងសកម្មនូវសមាហរណកាពនៅក្នុងតំបន់ និងអន្តរជាតិ(ដោយចូលជាសមាជិកសមាគម

[៦២] សម្រាប់ភាពងាយស្រួល(SESC) និងត្រូវាបនយោងទៅលើការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ២៩៩៣-៩៤។ ដូចគ្នាដែរ SESC នឹងត្រូវបានយោងទៅលើការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ២០០៤ ទោះបីតាមការពិតការអង្កេតមានរយៈពេល ១៥ ខែ ដោយចាប់ផ្តើមពីចុងឆ្នាំ២០០៣ រហូតដល់ដើម ឆ្នាំ២០០៥

[៦៣] សូមមើលយុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ១៩៩៨ និងយុទ្ធសាស្ត្រចតុកោណ ឆ្នាំ២០០៤

អាស៊ីអាគ្នេយ៍ ASEAN និងអង្គការពាណិជ្ជកម្មពិភពលោក WTO) តាមរយៈការឆ្លើយតបដ៏មានប្រសិទ្ធភាពទៅនឹងឱកាសដែលផ្តល់ដោយលទ្ធភាពបានទទួលភាពអនុគ្រោះទីផ្សារនៅអាមេរិកខាងជើង និងអឺរ៉ុបសម្រាប់ផលិតផលកាត់ដេរ និងតាមរយៈការត្រួតពិនិត្យវិនិយោគសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាផ្លូវថ្នល់ជាតិ ដែលកំពុងចាប់ផ្តើមតភ្ជាប់លំហសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាង។

ទោះបីយ៉ាងណាការផ្តោតការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្ន និងយ៉ាងមានឥទ្ធិពលទៅលើការកាត់បន្ថយភាពក្រីក្រមិនត្រូវបានប្រកាសយ៉ាងច្បាស់ក្នុងការរៀបរាងគោលនយោបាយទេ: មានអ្វីមួយបានធ្វើអោយខ្សោយនូវការអនុវត្តគោលនយោបាយក្នុងកម្រិតណាមួយ។ ដោយសារឥទ្ធិពលនៃផលចំណេញសន្តិភាពចាប់ផ្តើមចុះខ្សោយទៅប្រទេសកម្ពុជា និងត្រូវការប្រកាន់យកគោលនយោបាយជួយជនក្រីក្រថ្មីស្មុគស្មាញជាងមុន និងប្រុងប្រយ័ត្នជាងមុនបើកម្ពុជាចង់នៅមាននិរន្តរភាព ឬពន្លឿនការលូតលាស់ថ្មីៗនេះក្នុងកំណើតសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ហេតុនេះបញ្ហាប្រឈមសម្រាប់ឆ្នាំខាងមុខ គឺការពង្រឹងសម័យអន្តរកាលនយោបាយ ហើយកសាងលើអន្តរកាលនេះដោយការខិតខំបង្រួបបង្រួមគ្នាជាយុទ្ធសាស្ត្រ និងសហការគ្នាសម្រាប់ការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព។ របាយការណ៍នេះស្វះស្វែងផ្តល់ទស្សនៈជារួមដោយសង្ខេបតែអាចយល់បានពីអ្វីកើឡើងចំពោះភាពក្រីក្រនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ និងពីហេតុផលដើម្បីគាំទ្រដ្ឋាភិបាល និងសង្គមស៊ីវិលកម្ពុជាក្នុងការរៀបចំឡើងជាយុទ្ធសាស្ត្រសម្រាប់ឆ្លើយតបនឹងបញ្ហាភាពក្រីក្រ។

៣.២ និន្នាការនៃភាពក្រីក្រ ឆ្នាំ១៩៩៤-២០០៤

នៅក្នុងតំបន់កណ្តាលនៃប្រទេសកម្ពុជា ដែលត្រូវបានធ្វើការអង្កេតនៅក្នុងឆ្នាំ១៩៩៣-១៩៩៤ និងម្តងទៀតនៅឆ្នាំ២០០៤ (ក្របខ័ណ្ឌធ្វើគំរូតាមភូមិសាស្ត្រ ដែលអាចប្រៀបធៀបបាន) អត្រាភាពក្រីក្របានធ្លាក់ចុះពី៣៩% មកត្រឹម ២៨% ក្នុងអំឡុងពេល ១០ឆ្នាំនេះ។

ទោះបីជាយ៉ាងនេះក៏ដោយ តំបន់ជាច់ស្រយាល និងតំបន់ខ្ពស់រាបផ្សេងទៀត ដែលមិនត្រូវបានធ្វើការអង្កេតនៅឆ្នាំ១៩៩៣-១៩៩៤មក(ហើយនៅតែមាន) ភាពក្រីក្រជាងគេ។ យើងអាចប៉ាន់ប្រមាណបានមកពីអត្រាភាពក្រីកក្រនៅទូទាំងកម្ពុជាឆ្នាំ១៩៩៣-១៩៩៤ ដោយផ្អែកលើនិន្នាការនៅក្នុងក្របខ័ណ្ឌធ្វើគំរូតាមភូមិសាស្ត្រ ដែលអាចប្រៀបធៀបបាន និងអ្វីដែលយើងបានដឹងអំពីប្រជាជន និងភាពក្រីក្រនៅក្នុងតំបន់ជាច់ស្រយាលទាំងនោះ។ ដោយប្រើប្រាស់ព័ត៌មានទាំងនេះ យើងអាចប៉ាន់ប្រមាណថា អត្រាភាពក្រីក្រនៅកម្ពុជាទាំងមូលធ្លាក់ចុះពី៤៧% នៅឆ្នាំ១៩៩៤ (ប៉ាន់ប្រមាណថយក្រោយ) មកត្រឹម ៣៥%(ដែលបានវាស់វែង) នៅឆ្នាំ២០០៤។ ដោយសារមានមន្ទិលពីប៉ារ៉ាម៉ែត្រមួយចំនួន និងភាពមិនល្អិតល្អន់ ក្នុងការទាញយកលទ្ធផលនេះ វាមានសុវត្ថិភាពជាងក្នុងការនិយាយថា អត្រាភាពក្រីក្រនៅកម្ពុជានៅឆ្នាំ១៩៩៤ ស្ថិតនៅចន្លោះ ៤៥ ទៅ

៥០% ។ ដូច្នេះ យើងអាចប៉ាន់ប្រមាណថា រវាងឆ្នាំ១៩៩៤ និង២០០៤ អត្រាភាពក្រីក្រនៅកម្ពុជាធ្លាក់ចុះរវាង ១០ ទៅ ១៥%[៦៤]។

ក្នុងក្របខ័ណ្ឌការធ្វើគំរូតាមកូមិសាស្ត្រ ដែលអាចប្រៀបធៀបបាននេះ អត្រាការប្រើប្រាស់ក្នុងគ្រួសារក្នុងមនុស្សម្នាក់ការងារវាស់ពីសុខុមាលភាព ដែលត្រូវបានយកមកប្រើប្រាស់ក្នុងឯកសារនេះ និងដែលសម្រាប់បញ្ជាក់ពីបន្ទាត់ភាពក្រីក្របានកើតឡើង ៣២% ក្នុងន័យពិត(ពោល គឺដោយគិតទាំងអតិផរណា)។

ភាពប្រសើរឡើងវិញនៃអត្រាការប្រើប្រាស់ក្នុងមនុស្សម្នាក់ និងការធ្លាក់ចុះនៃអត្រាភាពក្រីក្រត្រូវបានពិនិត្យឃើញទាំងក្នុងតំបន់ជនបទ និងក្នុងតំបន់ទីក្រុងព្រមទាំងគ្រប់តំបន់កសិ-អេកូឡូស៊ីទាំងអស់លើកលែងតែតំបន់មួយចេញ។(នៅក្នុងតំបន់ទីប្រាំ គឺតំបន់ភ្នំ និងខ្ពង់រាប) យើងមិនអាចកំណត់ពីនិន្នាការទាំងនោះបានដោយសារតែគំរូរងសម្រាប់តំបន់នេះនៅឆ្នាំ១៩៩៤ មានទំហំតូចពេក ដើម្បីអាចផ្តល់លទ្ធផលការប៉ាន់ប្រមាណចាំបាច់តាមលក្ខណៈស្ថិតិ។

កត្តាកំណត់ក្រៅពីរូបិយវត្ថុនៃសុខុមាលភាព បានផ្តល់រូបភាពជាកស្តុតាងនៃកម្រិតជីវភាពជាមធ្យមដែលកើនឡើង និងអត្រាភាពក្រីក្រដែលធ្លាក់ចុះ។ គុណភាពនៃសម្ភារៈ ផ្ទះសម្បែងសូចនាករនៃការអភិវឌ្ឍន៍ធនធានមនុស្សលទ្ធភាពទទួលបានប្រភពថាមពលទាន់សម័យ និងកម្មសិទ្ធិជាប់លាប់របស់អ្នកប្រើប្រាស់សុទ្ធតែបញ្ជាក់ពីផលចំណេញ ដែលគួរកត់សម្គាល់ រួមទាំងសម្រាប់អ្នកប្រើប្រាស់ផងដែរ។

នៅពេលដែលប្រជាជនបានឆ្លងកាត់ការកាត់បន្ថយភាពក្រីក្រអត្រានៃការកែលម្អមិនដូចគ្នាទេ។ ជីវភាពរស់នៅនៃប្រជាជនជនបទ ដែលបានចាប់ផ្តើមជាមួយនឹងកម្រិតទាបបំផុត នៃការប្រើប្រាស់ពិតជាមធ្យមនៅឆ្នាំ ១៩៩៤ បានកើនឡើងក្នុងអត្រាយឺតបំផុត។ វិសមភាពបានកើនឡើងជាពិសេសក្នុងចំណោមប្រជាជនជនបទ។ ដូច្នេះ នៅពេលដែលជនក្រីក្របំផុតនៅជនបទ មានការលូតលាស់នោះវាមានកម្រិតទាបបំផុតមានន័យដាច់ខាត ហើយពួកគេបន្តធ្លាក់ចុះកាន់តែឆ្ងាយពីក្រោយតាមន័យប្រៀបធៀប នៅពេលដែលកម្រិតជីវភាពនៃក្រុមដទៃទៀតកើនឡើងនៅល្បឿនលឿនជាងនេះ។

ឥឡូវនេះទិន្នន័យនៃការអង្កេតគ្រួសារថ្មីៗ បញ្ជាក់យ៉ាងច្បាស់ថា ភាពក្រីក្របានបន្តធ្លាក់ចុះយ៉ាងខ្លាំងក្នុងទសវត្សចាប់តាំងពីប្រទេសកម្ពុជាងើបឡើងពីដម្លោះ ហើយចាប់ផ្តើមធ្វើដំណើរលើផ្លូវអភិវឌ្ឍន៍ "ធម្មតា" មក។ ដែលរស់ក្នុងគ្រួសារ ដែលតម្លៃការនៃការប្រើប្រាស់ក្នុងមនុស្សម្នាក់ស្ថិតនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រនោះបានធ្លាក់ចុះ។ ការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតពីវិសាលភាពនៃការប្រែប្រួលនេះបង្ហាញថា អត្រាភាពក្រីក្រ គឺចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ផ្អែកលើការប្រើប្រាស់បានធ្លាក់ចុះពី ៤៧% នៅចន្លោះឆ្នាំ ១៩៩៤

[៦៤] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី២៧

មកត្រឹម ៣៥% នៅឆ្នាំ២០០៤[៦៥]។ ដោយគិតពីការសង្ស័យមួយចំនួនអំពីគួលេខពិតប្រាកដនៃការរាប់ប្រជាជន នៅឆ្នាំ១៩៩៤ យើងអាចនិយាយការពារដោយមានការជឿទុកចិត្តថា ភាពក្រីក្រនៅឆ្នាំ១៩៩៤ អាចស្ថិតនៅចន្លោះ ២៥% និង៥0% ។ ផ្អែកលើមូលដ្ឋាននេះ យើងអាចនិយាយបានថា ភាពក្រីក្របានធ្លាក់ចុះប្រមាណពី ១0 ទៅ ១៥% ក្នុងរយៈពេល ១0ឆ្នាំចុងក្រោយនេះ ឬប្រហែល ១% ក្នុងមួយឆ្នាំ។ ការនេះបញ្ជាក់ពីការយល់ខុសចំពោះការចាប់អារម្មណ៍ទូទៅលើកំណើនសេដ្ឋកិច្ចថា មានឥទ្ធិពលតិចតួច ឬក៏គ្មានឥទ្ធិពលលើភាពក្រីក្រសោះនោះ។ នេះគឺជាការចាប់អារម្មណ៍ ដែលកើតឡើងនៅពេលដែលការប៉ាន់ស្មាននានាពីភាពក្រីក្រ ដកស្រង់ចេញពីការអង្កេតក្នុងទសវត្សឆ្នាំ៩0 ត្រូវបានយកមកប្រៀបធៀបទោះតាមការពិតការប៉ាន់ស្មានទាំងនោះមិនអាចប្រៀបធៀបបានទេ។

ឥឡូវនេះ គឺជាលើកទីមួយដែលមានការវិភាគលើទិន្នាការភាពក្រីក្រ: ការអង្កេតគ្រួសារ ដែលមានគំរូធំមួយចំនួនត្រូវបានធ្វើឡើងនៅប្រទេសកម្ពុជាតាំងពីដើមទសវត្សឆ្នាំ៩0។

ការប្រៀបធៀបផ្លែស្វាយជាមួយនឹងចេក: ការរស់ភាពក្រីក្រនៅកម្ពុជាឆ្នាំ១៩៩៤-២00៤ [៦៦]: ជាមួយនឹងការឧបត្ថម្ភពីម្ចាស់ជំនួយវិទ្យាស្ថានជាតិស្ថិតិ នៃរាជរដ្ឋាភិបាលបានរៀបចំការអង្កេតគំរូថ្នាក់ជាតិមួយចំនួនស្តីពីការប្រើប្រាស់ និងស្ថានភាពក្រីក្រ ក្នុងចំណោមគ្រួសារ ប្រជាជនកម្ពុជាចាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ ការអង្កេតទាំងនោះមាន: ១-ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ១៩៩៣-៩៤ SESE សម្រាប់ការងាយស្រួលការអង្កេតនេះត្រូវបានកំណត់ជា SESC ១៩៩៤។ ២-ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជា ឆ្នាំ១៩៩៦ (SES C 1996)។ ៣-ការអង្កេតសេដ្ឋកិច្ចសង្គមនៅឆ្នាំ១៩៩៧ (CSES 1997)។ ៤-ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ១៩៩៩ (CSES1999)។ ៥-ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ២00៤(CSES2004)(ការពិតការអង្កេតនេះត្រូវបានធ្វើឡើងជាង ១៥ខែដោយចាប់ផ្តើមពីចុងឆ្នាំ២00៣ រហូតដល់ឆ្នាំ២00៥ ក៏ប៉ុន្តែវៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ គួលេខដកស្រង់ចេញការអង្កេតនេះនឹងត្រូវបានទាញចេញពីទិន្នន័យ ដែលប្រមូលបានក្នុងរយៈពេល ១២ខែ នៃឆ្នាំ២00៤ តែប៉ុណ្ណោះ)។

ទោះជាយ៉ាងណា ដោយសារបញ្ហាសន្តិសុខនៅពេលនោះ ការអង្កេតសេដ្ឋកិច្ចកម្ពុជាឆ្នាំ២00៣-២00៤ អាចគ្របដណ្តប់តែត្រឹម ៥៦%នៃភូមិនៅជនបទ និង ៦៥%នៃប្រជាជនជនបទ។ ចំពោះតំបន់ "ទីក្រុងផ្សេងទៀត" មានតែ ៨៤% នៃឯកតាគំរូប៉ុណ្ណោះ ដែលត្រូវបានបំពេញ។ តំបន់នានាដែលមិនបានទទួលការអង្កេតនៅឆ្នាំ ១៩៩៣-៩៤ គឺជាតំបន់ដែលខ្មែរក្រហមនៅធ្វើសកម្មភាព និងជាផ្នែកជាច់ស្រយាលខ្លះនៃខេត្តជាច្រើន ដែលធ្វើដំណើរត្រូវជួបនឹងការលំបាកយ៉ាងខ្លាំង។ បើនិយាយអោយទូលំទូលាយទៅតំបន់ទាំងឡាយ ដែលដាច់ចេញពី

---

[៦៥] អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២0១៥?" ខែកុម្ភៈ ឆ្នាំ២00៦ ទំព័រទី២៩

[៦៦] អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២0១៥?" ខែកុម្ភៈ ឆ្នាំ២00៦ ទំព័រទី៣1

ការអង្កេតឆ្នាំ១៩៩៣-៩៤ គឺជាតំបន់ខ្ពស់ដាច់ស្រយាលស្ថិតនៅក្នុងព្រៃជ្រៅតាមព្រំដែនប៉ែកនីរតី បូព៌ា និងឧត្តរនៃប្រទេសដែលនៅទីនោះប្រជាជនតិចតួចរស់នៅក្នុងកម្រិតភាពក្រីក្រខ្លាំងជាងអ្នករស់នៅវាលរាប ក្នុងខេត្តស្នួលនៃការអង្កេតឆ្ងាយណាស់។

ក្នុងការអង្កេតក្រោយមកទៀត វិសាលភាពនៃក្របខ័ណ្ឌការធ្វើគំរូរីកធំជាងមុនដោយជាបន្តបន្ទាប់គ្រប់ដណ្តប់តំបន់ក្រីក្រ និងដាច់ស្រយាលបានច្រើនជាមុន។ ដោយគួបផ្សំជាមួយភាពខុសគ្នាក្នុងទម្រង់ការអង្កេតនិងអនុវត្តក្របខណ្ឌនៃការធ្វើគំរូ ដែលរីកសុះសាយជាងមុន មានន័យថា អត្រាភាពក្រីក្រដែលដកស្រង់ចេញពីការអង្កេតនានាក្នុងទសវត្សឆ្នាំ៩០ មិនអាចយកមកធ្វើការប្រៀបធៀបបានឡើយ និងមិនអាចប្រើប្រាស់សម្រាប់គណនាទិន្នន័យភាពក្រីក្រតាមពេលវេលាបន្តបន្ទាប់បានឡើយ។ ក្នុងការអង្កេតសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ឆ្នាំ ២០០៤(CSEC) គឺជាការអង្កេតលើគ្រួសារកម្ពុជាលើកទី១ ដែលផ្តែកលើក្របខ័ណ្ឌនៃការធ្វើគំរូដោយបញ្ចូលភូមិទាំងអស់(ដែលត្រូវបានប្រើប្រាស់ជាឯកតាគំរូបឋម) សម្រាប់ទូទាំងប្រទេសដោយដកស្រង់ចេញពីជំរឿនប្រជាជនលើកទីមួយរបស់ប្រទេស)។

-ការអង្កេតឆ្នាំ១៩៩៦(1996 SESC) បានប្រមូលព័ត៌មានមានប្រយោជន៍ជាច្រើន ប៉ុន្តែទម្រង់ការប្រើប្រាស់របស់គ្រួសារមានកម្រិតតិចពេក(ទិន្នន័យស្តីពីការប្រើប្រាស់ស្បៀងអាហារមានតែមួយប្រភេទប៉ុណ្ណោះ គឺស្បៀងអាហារទាំងអស់ដែលបរិភោគនៅសប្តាហ៍កន្លងទៅ)។ ជាលទ្ធផលការប្រើប្រាស់របស់គ្រួសារត្រូវបានប៉ាន់ស្មានទាបជ្រុល(ហើយភាពក្រីក្រត្រូវបានប៉ាន់ស្មានខ្ពស់ជ្រុល) បើប្រៀបធៀបជាឧទារណ៍ជាមួយនឹងការអង្កេតឆ្នាំ១៩៩៤។

-ការប្រមូលទិន្នន័យសម្រាប់ការអង្កេតឆ្នាំ១៩៩៧(1997 CSES) បានប្រព្រឹត្តទៅតែមួយដងប៉ុណ្ណោះ (ខែមិថុនា-កក្កដា ១៩៩៧) ជាអកុសលរយៈពេលនេះផ្ងួនគ្នាជាមួយនឹងការធ្លាក់ចុះកាន់តែជ្រៅទៅនៃវិបត្តិនយោបាយ ដែលឈានដល់អំពើហិង្សានយោបាយរវាងដៃគូនៅក្នុងរដ្ឋាភិបាលចម្រុះ។ មានហេតុផលត្រឹមត្រូវដែលត្រូវជឿជាក់ថា គ្រួសារបានកាត់បន្ថយការប្រើប្រាស់មុនពេល តម្លៃចំណាយសម្រាប់ការប្រើប្រាស់ទាប និងអត្រាភាពក្រីក្រខ្ពស់ ដែលត្រូវបានកត់ត្រានៅក្នុងការអង្កេតឆ្នាំ១៩៩៧ មិនឆ្លុះបញ្ចាំងកម្រិតជីវភាពជាក់ស្តែងនៅ៦ខែ ដើមឆ្នាំ១៩៩៧ទេ។ ដោយសារហេតុផលនេះ យើងបានសម្រេចមិនបញ្ចូលទៅក្នុងទិន្នន័យឆ្នាំ១៩៩៧ទេ។

-ជាទីបញ្ចប់ទិន្នន័យប្រមូលបាននៅក្នុងការអង្កេតឆ្នាំ១៩៩៩(1999 CSES) បង្ហាញភាពខុសគ្នាធ្ងាយមិនអាចទទួលយកបានរវាងការអង្កេតទាំងពីរលើក។ មានការព្រមព្រៀងគ្នាថា ស្តង់ដារនៃការបណ្តុះបណ្តាលនិងការត្រួតពិនិត្យនៅលើកទី១ មិនសមស្របដែលនាំអោយតួលេខនៃការប្រើប្រាស់ ត្រូវបានកត់ត្រាក្នុងកម្រិតទាបជ្រុល ហើយភាពក្រីក្រមានកម្រិតខ្ពស់ជ្រុល ចំណែកកម្រិតការប្រើប្រាស់របស់គ្រួសារកត់ត្រានៅលើកទី២ (បន្ទាប់ពីការបណ្តុះបណ្តាលត្រូវបានកែលម្អយ៉ាងច្រើន និងមានការត្រួតពិនិត្យដ៏ត្រឹមត្រូវមក) មានកម្រិតខ្ពស់ជាងមុនច្រើន ហើយការប៉ាន់ស្មានភាពក្រីក្រមានកម្រិតទាបច្រើន។ បន្ទាប់ពីការពិភាក្សាដ៏ច្រើនរបស់អ្នកជំនាញ

ការ និងរដ្ឋាភិបាល មានការព្រមព្រៀងគ្នាថា ទិន្នន័យការប្រើប្រាស់ក្នុងការអង្កេតឆ្នាំ១៩៩៩(1999 CSES)មិនគួរអោយជឿទុកចិត្ត ហើយគ្មានប្រយោជន៍ចំពោះការប្រៀបធៀបអត្រាភាពក្រីក្រក្នុងការអង្កេតផ្សេងទៀតឡើយ។

ការអង្កេតទាំងនេះបានផ្តល់លទ្ធភាពយល់ដឹងតាមកម្រិតខុសៗគ្នា ពីប្រភេទនៃការប្រើប្រាស់ ព្រមទាំងពីចំនួនប្រជាជនដែលតម្លៃនៃការប្រើប្រាស់ស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ។ ប៉ុន្តែរហូតមកដល់ពេលនេះគេមិនអាចវាស់ទិន្នាការភាពក្រីក្រនៅកម្ពុជាបានទេ ពីព្រោះការប៉ាន់ស្មានភាពក្រីក្រដែលដកស្រង់ចេញពីការអង្កេតទាំងនេះមិនអាចប្រៀបធៀបបានឡើយដោយផ្អែកលើហេតុផលខុសៗគ្នាជាច្រើន។

ទីមួយ និងសំខាន់បំផុត គឺគ្មានការអង្កេតណាមួយបានគ្របដណ្តប់ទូទាំងប្រទេស និងប្រជាជនទាំងមូលនៅឡើយ។ ប៉ុន្តែតាមទ្រឹស្តីគេត្រូវតែមានលទ្ធភាពយល់ដឹងបានមួយចំណែកពីន្នាការ នៅក្នុងតំបន់ដែលគ្របដណ្តប់ដោយការអង្កេតលើកទីមួយ ដោយប្រៀបធៀបការវាស់ភាពក្រីក្រដែលបានមកពីការអង្កេតនៅពេលផ្សេងៗគ្នាក្នុងក្របខ័ណ្ឌការធ្វើគំរូតាមភូមិសាស្ត្ររួមមួយ។ អាចនិយាយបានថា ដោយការកំណត់អនុកម្រងនៃគំរូដល់គ្របដណ្តប់នៅក្នុងការអង្កេតលើកក្រោយតាមភូមិសាស្ត្រធំជាងមុន ហើយដែលត្រូវបានទាញយកមកតែពីក្របខ័ណ្ឌគំរូភូមិសាស្ត្រ ដែលបានសិក្សានៅក្នុងការអង្កេតទីមួយនោះ គឺដោយសារការកំណត់ និងអនុវត្តនៅក្របខ័ណ្ឌការធ្វើគំរូតាមភូមិសាស្ត្រ ដែលអាចប្រៀបធៀបបាននៅក្នុង(ឆ្នាំ១៩៩៣-៩៤) ចំពោះទិន្នន័យដែលប្រមូលបានពីការអង្កេតក្រោយមកទៀត គេគួរតែអាចទទួលបាននូវការប៉ាន់ស្មានលើការប្រែប្រួលគួរជឿទុកចិត្តបានក្នុងតំបន់នោះ។ ជាអកុសលរហូតមកដល់ឆ្នាំនេះការកំណត់ក្របខ័ណ្ឌ នៃការធ្វើគំរូដែលត្រូវបានយកមកប្រើសម្រាប់ការអង្កេតលើកទីមួយ ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ១៩៩៤(SESC) ត្រូវបានបាត់បង់ជាអចិន្ត្រៃយ៍ ដែលធ្វើអោយការប្រៀបធៀបជាមួយវង្វាស់គោលមិនអាចធ្វើទៅបាន ទោះបីសម្រាប់តែផ្នែកមួយនៃប្រទេសក៏ដោយ។

ទីពីរ ការប្រែប្រួលនានាក្នុងទម្រង់នៃការអង្កេត និងការអនុវត្តពីការអង្កេតមួយទៅការអង្កេតមួយទៀតមានន័យថា ទិន្នន័យ (ជាពិសេសទិន្នន័យនៃការប្រើប្រាស់សំខាន់ៗ ដែលត្រូវយកមកប្រើប្រាស់សម្រាប់គណនាបន្ទាត់ភាពក្រីក្រ និងអត្រាភាពក្រីក្រ) ត្រូវបានប្រមូលតាមរបៀបខុសៗគ្នា។ ជាលទ្ធផលការរកឃើញពីការអង្កេតមួយមិនអាចប្រៀបធៀបដោយងាយស្រួល ឬទុកចិត្តបានទេ ជាមួយនឹងការរកឃើញពីការអង្កេតមួយផ្សេងទៀតឡើយ សូម្បីតែគេអាចប្រៀបធៀបគំរូតាមភូមិសាស្ត្រដូចគ្នារវាងការអង្កេតទាំងនោះក៏ដោយ។

នៅពាក់កណ្តាលឆ្នាំ២០០៥ ឯកសារលើក្រដាសមួយច្បាប់នៃក្របខ័ណ្ឌការធ្វើគំរូក្នុងការអង្កេតលើកទី១ (ការអង្កេតសេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ១៩៩៤ SECS 1994) ត្រូវបានរកឃើញនៅវិទ្យាស្ថានជាតិស្ថិតិ(NIS)។ ដោយគួបផ្សំជាមួយនឹងភាពស៊ីគ្នារវាងការបង្កើតគំរូការប្រើប្រាស់ ក្នុងការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជា ឆ្នាំ ១៩៩៤ និងឆ្នាំ២០០៤ នោះការនេះបានអនុញ្ញាតអោយគេអាចប្រៀបធៀបការប្រើប្រាស់ក្នុងគ្រួសារ និងភាពក្រីក្រក្នុងតំបន់ភូមិសាស្ត្រដូចគ្នានៅចន្លោះឆ្នាំ១៩៩៤ និងឆ្នាំ២០០៤ ជាលើកទី១។

ការកំណត់បន្ទាត់ភាពក្រីក្រ គឺជាការព្យាយាមកំណត់យ៉ាងជាក់លាក់នូវកម្រិតការប្រើប្រាស់ទំនិញ និងសេវារបស់ឯកត្តជន(ត្រូវបានវាស់តាមរយៈចំណាយទឹកប្រាក់ចំណាយ ឬអ្វីដែលសមមូលនឹងចំណាយ) ចាំបាច់សម្រាប់កម្រិតជីវភាពសមរម្យ។ បើនិយាយតាមបច្ចេកទេសបន្ទាត់ភាពក្រីក្រ គោលរបស់ប្រទេសកម្ពុជារួមមានសំណុំស្បៀងអាហារគោលថ្នាក់ជាតិមួយ និងប្រាក់ឧបត្ថម្ភក្រៅពីស្បៀងប្រចាំតំបន់ចំនួន ៣។ តម្លៃគោលទាំងឡាយត្រូវបានគណនាជាលុយរៀលក្នុងឆ្នាំ១៩៩៣-៩៤ និងសំដៅលើកម្រិតការប្រើប្រាស់ស្បៀងប្រចាំថ្ងៃក្នុងមនុស្សម្នាក់។

បន្ទាត់ភាពក្រីក្រស្បៀងអាហារ ផ្អែកលើតម្លៃចំណាយប៉ាន់ស្មានសម្រាប់ម្ហូបមួយកញ្ជ្រែង ដែលនឹងផ្តល់របបអាហារសម្រាប់ទ្រទ្រង់ជីវិតចំនួន ២.១០០កាឡូរីក្នុងមួយថ្ងៃ។ ការនេះផ្អែកលើបរិមាណនៃប្រភេទអាហារខុសៗគ្នា ដែលបរិភោគដោយមនុស្សក្នុងបញ្ចភាគទី៣ នៃការបែងចែកការប្រើប្រាស់ក្នុងមនុស្សម្នាក់(ដោយសារតែនេះ គឺជាបញ្ចភាគទី១ ក្នុងការអង្កេតនៅឆ្នាំ១៩៩៣-៩៤ SESC 1993-94 ដែលបានបំពេញកម្រិតអប្បបរិមាចំនួន ២.១០០កាឡូរី)។ អ្នកណាម្នាក់ដែលបរិភោគតិចជាងបន្ទាត់ភាពក្រីក្រស្បៀងនោះមិនបានទទួលបរិមាណស្បៀងអប្បបរិមា(កាឡូរី) ចាំបាច់សម្រាប់ទ្រទ្រង់សុខភាពរបស់ខ្លួនឡើយ ហើយបើតាមទ្រឹស្តី គឺគ្មានលទ្ធភាពគ្រប់គ្រាន់បំពេញសេចក្តីត្រូវការនៃការប្រើប្រាស់ក្រៅពីស្បៀងមានដូចជា សំលៀកបំពាក់ ជំរក ការព្យាបាលជំងឺ និងអ្វីៗផ្សេងទៀត។

ការពិតសូម្បីជនក្រីក្រខ្លាំងក៏ត្រូវការប្រើប្រាស់ទំនិញ និងសេវាក្រៅពីស្បៀងអាហារដោអប្បបរិមាដែរ។ ដើម្បីគណនាបន្ទាត់ភាពក្រីក្រ ជារួមប្រាក់ឧបត្ថម្ភក្រៅពីស្បៀងអាហារត្រូវបានទាញចេញពីការប្រើប្រាស់ក្រៅពីស្បៀងអាហាររបស់ប្រជាជនកម្ពុជា ដែលមានការប្រើប្រាស់ទាំងអស់ប្រចាំគ្រួសារក្នុងមនុស្សម្នាក់ស្មើនឹងបន្ទាត់ភាពក្រីក្រស្បៀងអាហារៈ មានន័យថា ប្រាក់ឧបត្ថម្ភក្រៅពីស្បៀងអាហារ គឺជាបរិមាណនៃការប្រើប្រាស់ ដែលឯកត្តជនខ្វះខាតស្បៀងអាហារ និងបង្វែរពីការបរិភោគស្បៀងអាហារទៅជាការប្រើប្រាស់ក្រៅពីស្បៀងអាហារវិញ។

ប្រាក់ឧបត្ថម្ភក្រៅពីស្បៀងអាហារបូកនឹងបន្ទាត់ភាពក្រីក្រស្បៀងអាហារស្មើនឹងបន្ទាត់ភាពក្រីក្ររួម (ឧ+ស=ករ)។

បន្ទាត់ភាពក្រីក្រស្បៀងអាហារបច្ចុប្បន្នប្រាក់ឧបត្ថម្ភក្រៅពីស្បៀងអាហារ និងបន្ទាត់ភាពក្រីក្រទាំងអស់:[៦៧]

ភូមិភាគ	១៩៩៣-៩៤	២០០៤
បន្ទាត់ភាពក្រីក្រស្បៀងអាហារ (ប្រាក់រៀលសព្វថ្ងៃសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ)		
ភ្នំពេញ	១,១៨៥	១,៧៨២
ទីក្រុងផ្សេងទៀត	៩៩៦	១,៥៦៨

[៦៧] SESC 1994, CSES 2004

ជនបទ	៨៨២	១,៣៨៩
ប្រាក់ឧបត្ថម្ភក្រៅពីស្បៀងអាហារ (ប្រាក់រៀលសព្វថ្ងៃសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ)		
ភ្នំពេញ	៣៩៣	៥៦៩
ទីក្រុងផ្សេងទៀត	២៦៩	៣៨៤
ជនបទ	២៣៦	៣៦៤
បន្ទាត់ភាពក្រីក្រទាំងអស់ (ប្រាក់រៀលសព្វថ្ងៃសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ)		
ភ្នំពេញ	១,៥៧៨	២,៣៥១
ទីក្រុងផ្សេងទៀត	១,២៦៥	១,៩៥២
ជនបទ	១,១១៨	១,៧៥៣

ការខាស់តាពក្រីក្រ

នៅពេលបន្ទាត់ភាពក្រីក្រត្រូវបានកំណត់រួចហើយ ការបែងចែកនៃការប្រើប្រាស់ក្នុងគ្រួសារក្នុងមនុស្សម្នាក់ត្រូវបានប្រៀបធៀបជាមួយនឹងបន្ទាត់នេះ ដើម្បីគណនារកវង្វាស់ខុសគ្នានៃភាពក្រីក្រ។

ការវាស់ភាពក្រីក្រៈ អត្រាគម្លាត និងប្រពលភាពៈ

ការអនុវត្តន៍ជាក់ស្តែងជាអន្តរជាតិនូវស្តង់ដារសម្រាប់វាស់ភាពក្រីក្រ ប្រើប្រាស់សន្ទស្សន៍ភាពក្រីក្រ ៣ ដែលមានទាក់ទងគ្នាទៅវិញទៅមកតាមបែបគណិតវិទ្យាដែលលោកហ្វូស្ទ័រ(FOSTER) លោកហ្គ្រៀ(GREER) និងលោក សូប៊ីយ(THORBERCKE) បានលើកបង្ហាញជាលើកដំបូងកាលពីឆ្នាំ១៩៨៤។ វង្វាស់វង្វាល់ភាពក្រីក្រនេះ ដែលត្រូវបានស្គាល់ថា ជាវង្វាស់វង្វាល់ FGT គឺ:

-**សន្ទស្សន៍អត្រាភាពក្រីក្រ(P0)** : ដែលជួនកាលគេហៅថា ជាអត្រាភាពក្រីក្រ។ នេះ គឺជាការវាស់វែងដែលត្រូវបានប្រើជាធម្មតា ហើយដែលងាយយល់ជាងគេបំផុត។ ដោយសាមញ្ញបំផុតសន្ទស្សន៍នេះបញ្ជាក់ពីភាគរយនៃប្រជាជន ដែលមានការប្រើប្រាស់ក្នុងមនុស្សម្នាក់ក្រោមបន្ទាត់ភាពក្រីក្រ។

-**សន្ទស្សន៍គម្លាតភាពក្រីក្រ (P1)** : ដែលជាបរិមាណខុសគ្នាជាមធ្យម ក្នុងចំណោមប្រជាជនទាំងអស់ រវាងការប្រើប្រាស់របស់ឯកត្តជនក្នុងមនុស្សម្នាក់ ដែលកត់ត្រាទុក និងបន្ទាត់ភាពក្រីក្រជាមួយនឹងតម្លៃសូន្យ ដែលបានសន្មតសម្រាប់ប្រជាជនស្ថិតលើបន្ទាត់ភាពក្រីក្រ។

-**សន្ទស្សន៍ប្រពលភាពនៃភាពក្រីក្រ(P2)**: ធ្វើការគណនាដោយដំបូងត្រូវលើកគម្លាតភាពក្រីក្រឯកត្តជនជាការមុននឹងធ្វើមធ្យមភាគតួលេខទាំងនោះ។ ការនេះធ្វើអោយបរិមាណគម្លាតភាពក្រីក្រកើនឡើង និងផ្តល់ការយល់ដឹងពីការបែងចែកតម្លៃចំណាយសម្រាប់ការប្រើប្រាស់ទាបបំផុត(ពោល គឺភាពក្រីក្រជ្រុល)។

អត្រាភាពក្រីក្របានធ្លាក់ចុះនៅតំបន់ជនបទ និងតំបន់ទីក្រុងក្នុងក្របខ័ណ្ឌគំរូតាមភូមិសាស្ត្រ ដែលអាចប្រៀបធៀបបានអត្រាភាពក្រីក្រ(គឺភាគរយនៃប្រជាជនដែលរស់ក្រោមបន្ទាត់ភាពក្រីក្រ) បានធ្លាក់ចុះពី ៣៩% នៅឆ្នាំ១៩៩៤ មកនៅត្រឹម ២៨% នៅឆ្នាំ២០០៤។ នៅពេលអត្រានៃការកាត់បន្ថយភាពក្រីក្រ ដែលត្រូវបានស្គាល់នេះបានផ្គូបផ្សំជាមួយតួលេខប៉ាន់ស្មាននានា នៃការបែងចែកក្នុងចំណោមប្រជាជនទាំងអស់រវាងតំបន់នានាក្នុង និងក្រៅក្របខ័ណ្ឌការធ្វើគំរូឆ្នាំ១៩៩៤ យើងប៉ាន់ស្មានថា ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាទាំងមូលបានធ្លាក់ចុះពី ៤៧% មកនៅត្រឹម ៣៥% ក្នុងចន្លោះពីឆ្នាំ១៩៩៤ និងឆ្នាំ២០០៤។

ចំណោលបកស្រាយនៃការប៉ាន់ស្មានភាពក្រីក្រថ្នាក់ជាតិសម្រាប់ឆ្នាំ១៩៩៤: [៦៨] ទោះបីការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ២០០៤ (CSES 2004) ជាការអង្កេតលើកទី១ ដែលបានគ្របដណ្តប់ទូទាំងប្រទេសក៏យើងអាចសន្មតថា ត្រឹមត្រូវ ដើម្បីប៉ាន់ស្មានការរាស់ភាពក្រីក្រសម្រាប់តំបន់ដែលស្ថិតនៅក្រៅការអង្កេតនៅឆ្នាំ ១៩៩៤ ហើយធ្វើចំណោលក្រោយនូវការរាស់ភាពក្រីក្រសម្រាប់ប្រទេសទាំងមូលក្នុងឆ្នាំ១៩៩៤។ ការធ្វើចំណោលបកស្រាយនេះមានប្រយោជន៍ ពីព្រោះវាផ្តល់នូវការប៉ាន់ស្មានមួយដ៏ល្អប្រសើរបំផុត ស្តីពី ស្ថានភាពក្រីក្រក្នុងប្រទេសទាំងមូលនៅឆ្នាំ១៩៩៤។ ទោះការប៉ាន់ស្មានអាចជាអ្វីក៏ដោយវាអាចអោយមានការពិភាក្សាអំពីថា តើសម្មតិកម្មមួយត្រូវបោះចោល? (ឧទាហរណ៍ ការកាត់បន្ថយភាពក្រីក្រ ថេរតិចតួច ឬលឿន) និងតើការប៉ាន់ស្មានទាំងនោះសមហេតុផលដោយពិចារណាលើស្ថានភាពពេលនោះ និងពេលសព្វថ្ងៃ។ តម្រូវការចាំបាច់សម្រាប់ការងារនេះគឺ ក-ចំណែកប្រជាជននៃតំបន់ស្ថិតក្នុង ឬក្រៅក្របខ័ណ្ឌការធ្វើគំរូដល់ការអង្កេតក្នុង SESC ឆ្នាំ១៩៩៤ ទាំងក្នុងឆ្នាំ១៩៩៤ និង ២០០៤ និង ខ-រង្វាស់ភាពក្រីក្រនៃតំបន់ ដែលបានរាប់បញ្ចូលក្នុងឆ្នាំ ១៩៩៤ និង២០០៤ និងតំបន់ដែលនៅក្រៅក្របខ័ណ្ឌសម្រាប់គំរូដែលអាចប្រៀបធៀបបានក្នុងឆ្នាំ២០០៤។

ដោយផ្តុំក្របខ័ណ្ឌការធ្វើគំរូឆ្នាំ១៩៩៤ និង២០០៤ និងចំណោលប្រជាជនចន្លោះឆ្នាំ១៩៩៣-២០០៤ ដែលត្រូវបានគណនាពីជំរឿនប្រជាជនឆ្នាំ១៩៩៨(Neupert, 1998) យើងបានប៉ាន់ស្មាន ក-ចំណែកប្រជាជននៅតំបន់ក្រៅក្របខ័ណ្ឌការធ្វើគំរូការអង្កេតឆ្នាំ១៩៩៣-៩៤(SESC 1993-94) សម្រាប់ឆ្នាំ១៩៩៤ និងឆ្នាំ២០០៤ និង ខ-ចំណែកនៃប្រជាជននៅតំបន់ក្នុងក្របខ័ណ្ឌការធ្វើគំរូអង្កេតឆ្នាំ១៩៩៣-៩៤(SESC 1993-94) សម្រាប់ឆ្នាំ១៩៩៤ និង២០០៤។ ដោយទាញចេញពីការអង្កេតឆ្នាំ១៩៩៤(SESC 1994) និងការអង្កេតឆ្នាំ២០០៤ យើងអាចប៉ាន់ស្មានអត្រាភាពក្រីក្រសម្រាប់ ក-តំបន់ក្នុងក្របខ័ណ្ឌការធ្វើគំរូរបស់ការអង្កេតឆ្នាំ១៩៩៣-៩៤ សម្រាប់ឆ្នាំ១៩៩៣ និង២០០៤ និង ខ-តំបន់ក្រៅក្របខ័ណ្ឌការធ្វើគំរូរបស់ការអង្កេតឆ្នាំ១៩៩៣-៩៤ សម្រាប់ឆ្នាំ២០០៤។ គេអាចបង្កើតសេណារីយ៉ូពីរបីសម្រាប់អត្រាកាត់បន្ថយភាពក្រីក្រក្នុងតំបន់ក្រៅក្របខ័ណ្ឌ ការធ្វើគំរូរបស់ការអង្កេតឆ្នាំ១៩៩៤។ អត្ថបទសំខាន់បង្ហាញសេណារីយ៉ូតែមួយប៉ុណ្ណោះ ដែលក្នុងនោះអត្រាកាត់បន្ថយ

[៦៨] SESC 1994-93, CSES 2004

ភាពក្រីក្រក្នុងតំបន់ក្រៅក្របខ័ណ្ឌត្រូវបានសន្មតថា ដូចគ្នានឹងអត្រាក្នុងតំបន់ក្នុងក្របខ័ណ្ឌសម្រាប់ប្រភេទដូចគ្នា។

សេណារីយ៉ូទី១ : ការប៉ាន់ស្មានភាពក្រីក្រល្អបំផុតសម្រាប់ប្រជាជនកម្ពុជាទាំងអស់ក្នុងឆ្នាំ១៩៩៣-៩៤

	ចំណែកប្រជាជន %	អត្រាភាពក្រីក្រ %	គម្លាតភាពក្រីក្រ %	ប្រពលភាពនៃភាពក្រីក្រ %
ភ្នំពេញ	០,០៧៥៨	១១,៤	៣,០	១,២
តំបន់ "ក្នុងក្របខ័ណ្ឌ" ក្នុងតំបន់ទីក្រុងផ្សេង	០,០៥៦៧	៣៦,៦	៩,៦	៣,៦
តំបន់ "ក្នុងក្របខ័ណ្ឌ" ក្នុងតំបន់ជនបទ	០,៤៦៧០	៤៣,១	១០,០	៣,៣
តំបន់"ក្រៅក្របខ័ណ្ឌ" ក្នុងតំបន់ទីក្រុងផ្សេង	០,០៤១៤	៦៣,៥	១៤,៥	៤,៩
តំបន់"ក្រៅក្របខ័ណ្ឌ" ក្នុងតំបន់ជនបទ	០,៣៥៩១	៥៩,១	១៦,៧	៦,២
ប្រទេសកម្ពុជា		៤៧,០	១២,០	៤,៣

នេះគឺជាការសន្មតត្រឹមត្រូវប្រសើរជាងគេបំផុត ពីព្រោះគ្មានទិន្នន័យជាឯកសារក្រដាសផ្សេងទៀតទេ (ដូចជា ផលិតផលក្នុងស្រុកសរុបប្រចាំខេត្ត ឬប្រាក់ចំណូលកសិកម្ម) ដើម្បីផ្តួចផ្តើមគំនិតផ្សេងពីនេះ។ ប៉ុន្តែសេណារីយ៉ូផ្សេងទៀតនៃការកាត់បន្ថយភាពក្រីក្រក៏សមហេតុផលដែរ ហើយយើងនឹងបង្ហាញសេណារីយ៉ូពីរផ្សេងទៀតនៅខាងក្រោម។ ទីមួយ ភាពក្រីក្រត្រូវបានសន្មតថានៅថេរ(ពោលគឺ គ្មានការកាត់បន្ថយ) ក្នុងតំបន់ក្រៅក្របខ័ណ្ឌ និងទីពីរ ភាពក្រីក្រតំបន់ក្រៅក្របខ័ណ្ឌ(ជនបទ និងទីក្រុង) ធ្លាក់ចុះក្នុងអត្រាដូចគ្នានឹងក្នុងតំបន់ទីក្រុង ដែលត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌការធ្វើគំរូឆ្នាំ១៩៩៤ ដែរ។

សេណារីយ៉ូឆ្លាស់ពីរនៃការប៉ាន់ស្មានភាពក្រីក្រសម្រាប់ប្រទេសកម្ពុជាទាំងមូលនៅឆ្នាំ១៩៩៣-៩៤

ការសន្មត/សេណារីយ៉ូ	អត្រាភាពក្រីក្រ %	គម្លាតភាពក្រីក្រ %	ប្រភពនៃភាពក្រីក្រ %
១-ក្រីក្រនៅថេរ(គ្មានការកាត់បន្ថយ) ក្នុងតំបន់ក្រៅក្របខ័ណ្ឌទាំងអស់	៤១,១	១០,៥	៣,៨
២-ភាពក្រីក្រនៅតំបន់ជនបទ និងទីក្រុង ក្រៅក្របខ័ណ្ឌបានធ្លាក់ចុះក្នុងអត្រារបស់តំបន់ទីក្រុង	៥៥,២	១៤,០	៤,៩

ជាមួយផលិតផលក្នុងស្រុកសរុប(GDP)ចំនួន ២១១ដុល្លារសម្រាប់មនុស្សម្នាក់ក្នុងទឹកប្រាក់ថៃ ចំនួន ២.០០០ដុល្លារអាមេរិក អត្រាភាពក្រីក្រចំនួន ៤៧% សម្រាប់ប្រទេសកម្ពុជានៅឆ្នាំ១៩៩៤ មិនទំនងថាមិនសមហេតុផលទេ។ នៅប្រទេសជិតខាង ដូចជា ឡាវ អត្រាភាពក្រីក្រនៅឆ្នាំ១៩៩៣ គឺ ៤៦% ជាមួយនឹងផលិតផលក្នុងស្រុកសរុប(GDP)ចំនួន ២៤៧ដុល្លារ សម្រាប់មនុស្សម្នាក់ក្នុងទឹកប្រាក់ថៃចំនួន ២.០០០ដុល្លារអាមេរិក (ធនាគារពិភពលោក ឆ្នាំ២០០៥) ចំណែកនៅប្រទេសវៀតណាមអត្រាភាពក្រីក្រ ត្រូវបានប៉ាន់ស្មានថា មានកម្រិត ៥៦% នៅឆ្នាំ១៩៩៣ ជាមួយនឹងផលិតផលក្នុងស្រុកសរុប(GDP)ចំនួន ២៦៥ដុល្លារ សម្រាប់មនុស្សម្នាក់ក្នុងទឹកប្រាក់ថៃចំនួន ២.០០០ដុល្លារអាមេរិក(ធនាគារពិភពលោកឆ្នាំ១៩៩៩)។ ក្នុងន័យមួយទៀតអត្រាភាពក្រីក្រចំនួនពី៤៥% ទៅ ៥០% នៅឆ្នាំ១៩៩៤ ហាក់ដូចជាគួរអោយជឿបានក្នុងបរិបទនៃផលិតផលក្នុងស្រុកសរុប(GDP)របស់ប្រទេសកម្ពុជាក្នុងពេលនោះ។

ដោយក្រឡេកមើលតែនិន្នាការក្នុងក្របខ័ណ្ឌការធ្វើគំរូ ដែលអាចប្រៀបធៀបបាន(ពោល គឺនិន្នាការដែលផ្ទុយពីអត្រាភាពក្រីក្រ ដែលត្រូវបានធ្វើចំណោលមកក្រោយ) គឺជាការច្បាស់ថាអត្រាភាពក្រីក្របានធ្លាក់ចុះទាំងនៅតំបន់ទីក្រុង និងតំបន់ជនបទ។ ដូចការរំពឹងទុកបរិមាណប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រស្បៀងទាបនិងធ្ងន់ធ្ងរក៏បានធ្លាក់ចុះក្នុងអត្រាប្រហាក់ប្រហែលគ្នាដែរ (យឺតបន្តិចនៅក្នុងតំបន់ទីក្រុងលឿនជាងក្នុងតំបន់ជនបទ)។

ដោយសារអត្រាភាពក្រីក្រ និងភាពក្រីក្រស្បៀងអាហារបានធ្លាក់ចុះ យើងគ្រាន់តែអាចរំពឹងថា ជម្រៅនៃភាពក្រីក្រក៏បានថយចុះដែរ។ ដោយកម្រិតជីវភាពរបស់ជនក្រីក្រ(ដូចត្រូវបានវាស់ដោយការប្រើប្រាស់ពិតក្នុងមនុស្សម្នាក់) មានការប្រសើរឡើងដោយក្នុងករណីមួយចំនួនបានរុញពួកគាត់អោយឆ្ងងផុតពីបន្ទាត់ភាពក្រីក្រ និងក្នុងករណីផ្សេងទៀត បាននាំពួកគាត់អោយឡើងឆ្ពោះមកកាន់បន្ទាត់ភាពក្រីក្រ។ ហេតុនេះគម្លាតភាពក្រីក្រត្រូវបានកាត់បន្ថយ។ ដូចការរំពឹងទុកភាពក្រីក្រមានកម្រិតខ្ពស់ខ្លាំងនៅជនបទ និងទាប់នៅភ្នំពេញ។

គំនូសនៃការបែងចែកសរុបនៃការប្រើប្រាស់ពិតក្នុងសម្រាប់មនុស្សម្នាក់ដោយផ្អែកលើគំរូ ដែលអាចប្រៀបធៀបបានតាមភូមិសាស្ត្រ(ពោល គឺគ្រួសារមកពីភូមិដែលបញ្ចូលក្នុងក្របខ័ណ្ឌ ការធ្វើគំរូសម្រាប់ការអង្កេតឆ្នាំ១៩៩៣-៩៤) ក៏ដូចជាបន្ទាត់ភាពក្រីក្រស្បៀងអាហារ និងបន្ទាត់ភាពក្រីក្រជារួមតាមតម្លៃនៅភ្នំពេញឆ្នាំ១៩៩៣-៩៤។ គំនូសនេះបង្ហាញថា ការប្រើប្រាស់ពិតក្នុងគ្រួសារក្នុងមនុស្សម្នាក់បានកើនឡើងសម្រាប់គ្រប់ចំណែកនៃការបែងចែកប្រជាជននៅចន្លោះឆ្នាំ១៩៩៤ និង២០០៤ ដូចត្រូវបានឃើញយ៉ាងច្បាស់តាមរយៈការប្តូរយ៉ាងច្បាស់ទៅខាងស្តាំក្នុងការបែងចែកសរុប។ លទ្ធផលសំខាន់មួយ គឺអត្រាភាពក្រីក្រត្រូវបានប៉ាន់ស្មានថាបានថយចុះក្នុងរយៈពេល១០នេះ សម្រាប់គ្រប់បន្ទាត់ភាពក្រីក្រ[៦៥]។

[៦៥] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៣៩

ការប្រើប្រាស់បានកើនឡើងពីមូលដ្ឋានទាបមួយទៅជនបទ ក៏ដូចជា នៅទីក្រុងគ្រាន់តែក្នុងបរិមាណមួយតិចជាង។ ក្នុងក្របខ័ណ្ឌដែលអាចប្រៀបធៀបបានតាមភូមិសាស្ត្រការប្រើប្រាស់ពិតប្រាកដ(កំណត់ក្នុងន័យជាការប្រើប្រាស់ប្រចាំគ្រួសារ ក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃជាមធ្យមដោយគណនាជាប្រាក់រៀលនៅឆ្នាំ ១៩៩៣-៩៤) បានកើនឡើង ៣២% (ពី ២.២២៨រៀល ទៅ ២.៩៣២រៀល សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ) ក្នុងប្រទេសទាំងមូល។ ការកើនឡើងយ៉ាងឆាប់រហ័សបំផុត នៃការប្រើប្រាស់ជាមធ្យម ៣៦% ត្រូវបានរកឃើញនៅតំបន់ទីក្រុងក្រៅពីភ្នំពេញ ហើយការកើនឡើងយ៉ាងយឺតបំផុត ២៤% ត្រូវបានរកឃើញនៅតំបន់ជនបទ[៧០]។

ដោយពង្រឹងការចាប់ផ្តើមអារម្មណ៍ពីការកើនឡើងនៃកម្រិតជីវភាព និងការធ្លាក់ចុះនៃភាពក្រីក្រ[៧១] បង្ហាញថា ចំណែកនៃការប្រើប្រាស់ក្រៅពីស្បៀងអាហារបានកើនឡើង នៅគ្រប់ក្រុមបញ្ចាគទាំងអស់នៅរវាងឆ្នាំ១៩៩៣-៩៤ និងឆ្នាំ២០០៤។ ដោយហេតុថា អាទិភាពទី១ នៃការប្រើប្រាស់ប្រចាំគ្រួសារជានិច្ចជាកាល គឺស្បៀងអាហារ និងចំណែកនៃស្បៀងអាហារក្នុងការប្រើប្រាស់ទាំងអស់ គឺទាក់ទងគ្នាទៅវិញទៅមកជាមួយទ្រព្យសម្បត្តិនោះ ការកើនឡើងនូវចំណែកក្រៅពីស្បៀងអាហារ បញ្ជាក់ជាកស្តុតាងពីការធ្លាក់ចុះនៃអត្រាភាពក្រីក្រ។ នេះបញ្ជាក់ថា សព្វថ្ងៃគ្រួសារក្រីក្រ និងមិនក្រីក្រអាចមានលទ្ធភាពចំណាយទៅលើសេចក្តីត្រូវការ ក្រៅពីស្បៀងអាហារបានច្រើនជាងនៅឆ្នាំ១៩៩៤។

ការអង្កេតគ្រួសារនៅកម្ពុជា បានប្រមូលទិន្នន័យពីសូចនាករសង្គម-សេដ្ឋកិច្ចមួយចំនួនធំបន្ថែមពីលើការប្រើប្រាស់របស់គ្រួសារ។ ជាមួយនឹងចំណែកក្រៅពីស្បៀងអាហារ សូចនាករសង្គម-សេដ្ឋកិច្ចទាំងនោះមានសារៈប្រយោជន៍ណាស់ ដើម្បីពិនិត្យថ្លឹងថ្លែងពីប្រាកដភាពនៃរូបភាព ការកាត់បន្ថយភាពក្រីក្រ ដែលបានទទួលបានពីការវាស់បន្ទាត់ភាពក្រីក្រនៃបរិមាណប្រជាជនជម្រៅ និងប្រពលភាព។ ជាការពិតណាស់ ជាញឹកញយសូចនាករសង្គមកិច្ច-សេដ្ឋកិច្ចទាំងនោះត្រូវបានចាត់ទុកថា គួរជឿទុកចិត្តជាងការប្រើប្រាស់ ឬប្រាក់ចំណូលប្រចាំគ្រួសារក្នុងការវាស់វែងទ្រព្យសម្បត្តិពិត។ សូចនាករទាំងនេះក៏ផ្តល់ការយល់ដឹងពីទំហំនៃភាពក្រីក្រក្រៅពីរូបិយវត្ថុ ដូចជាស្ថានភាពការអប់រំ និងសុខាភិបាល ដែលអាចនឹងមិនត្រូវបានកត់ត្រាក្នុងទិន្នន័យការប្រើប្រាស់នោះ។ សូចនាករក្រៅពីប្រាក់ចំណូលផ្សេងទៀត ដូចជា កម្មសិទ្ធិយូរអង្វែងប្រចាំគ្រួសារ គុណភាពផ្ទះសម្បែង និងការប្រើប្រាស់ប្រភពថាមពលទំនើបបញ្ជាក់ថា ស្ថានភាពរស់នៅនៃប្រជាជនទូទៅ និងក្នុងចំណោមជនក្រីក្រមានភាពល្អប្រសើរគួរអោយកត់សម្គាល់រវាងឆ្នាំ១៩៩៣-៩៤ និង២០០៤។ ក្នុងចំណោមបញ្ចាគក្រីក្របំផុតទីប្រាំនៃប្រជាជនកម្មសិទ្ធិ ទូរទស្សន៍បានកើនឡើងទ្វេមួយជាដប់(ពី៣.៤ ទៅ ៣៦%) នៅពេលដែលលទ្ធភាព

[៧០] អាស៊ីបូត៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៣៩

[៧១] អាស៊ីបូត៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៤០

ប្រើប្រាស់ម៉ាស៊ីនភ្លើង ឬភ្លើងអគ្គីសនីប្រើដោយអាគុយកើនឡើងពី ១,៦ ទៅ ២៨%[៧២]។ នៅក្នុងចំណោមបញ្ជាភាគក្រោមបំផុតនេះចំនួនច្រើនជាងមុនមានផ្ទះប្រក់ដោយដំបូលស័ង្កសី ឬអាលុយមីញ៉ូម បើប្រៀបធៀបទៅនឹងដប់ឆ្នាំមុននៅពេលដែលផ្ទះភាគច្រើនប្រក់ដោយដំបូលស្លឹក[៧៣]។

ការផ្តល់សេវាជាមូលដ្ឋានផ្សេងៗត្រូវបានកែលម្អយ៉ាងច្រើន។ ការនេះកំពុងតែចាប់ផ្តើមលេចឡើងក្នុងសូចនាករមួយចំនួននៃលទ្ធផលអភិវឌ្ឍន៍ធនធានមនុស្ស។ នៅចន្លោះឆ្នាំ១៩៩៧ និង២០០៤ អត្រាចូលរៀនពិតនិងអត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សារបស់កុមារបានកើនឡើងជាង ១០% ក្នុងចំណោមកុមារមកពីបញ្ជាភាគក្រីក្របំផុតទីប្រាំនៃប្រជាជន[៧៤]។

នៅពេលការប្រើប្រាស់បានកើនឡើងនៅគ្រប់បញ្ជាភាគទាំងអស់នៅចន្លោះឆ្នាំ១៩៩៤ និង២០០៤ នោះកំណើននេះមិនបានប្រព្រឹត្តទៅដោយស្មើគ្នាឡើយ ដោយតំបន់ជនបទកើនឡើងយ៉ាងយឺតបំផុត និងបានបង្ហាញពីកម្រិតភាពក្រីក្រដែលបន្តឡើងខ្ពស់។ នៅឆ្នាំ២០០៤ ការប្រើប្រាស់ពិតនៅតំបន់ជនបទ គឺ ៦៧% នៃការប្រើប្រាស់ពិតនៅតំបន់ទីក្រុងផ្សេងទៀត: អត្រានេះធ្លាក់ចុះដល់ ៦១% នៅឆ្នាំ២០០៤។

តាមលំនាំដូចគ្នាដែរ កំណើនការប្រើប្រាស់មិនឯកភាពគ្នាទេក្នុងចំណោមក្រុមបញ្ជាភាគប្រើប្រាស់ទាំងឡាយ។ ការប្រើប្រាស់ពិតក្នុងមនុស្សម្នាក់ក្នុងបញ្ជាភាគក្រីក្របំផុតបានកើនឡើងប្រមាណតែ ៨% ប៉ុណ្ណោះ ប៉ុន្តែបានកើនឡើងដល់ទៅ ៤៥% ចំពោះបញ្ជាភាគមានបំផុត។ ជាលទ្ធផលចំណែកការប្រើប្រាស់របស់ជនក្រីក្រក្នុងចំណោមការប្រើប្រាស់ទាំងអស់របស់ប្រទេសបានធ្លាក់ចុះក្នុងចន្លោះពេលឆ្នាំ១៩៩៤ និង ២០០៤។

វឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រក៏មានភាពមិនស្មើគ្នាដែរ ក្នុងចំណោមជនក្រីក្រដូចគ្នា។ ជនក្រីក្រខ្លាំងមានការកើនឡើងក្នុងការប្រើប្រាស់ពិតយឺតជាងជនក្រីក្រ "មធ្យម" យ៉ាងខ្លាំង។ ដោយការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាទាំងពីរលើក(SESC/CSES) មិនមែនមានលក្ខណៈប្រហាក់ប្រហែលគ្នា (ពោល គឺការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ២០០៤ មិនបានប្រើប្រាស់គំរូគ្រួសារនៃការអង្កេតឆ្នាំ១៩៩៤ ឡើងវិញទេ) យើងមិនអាចធ្វើអត្ថាធិប្បាយដោយផ្ទាល់ទៅលើការឈានទៅរក និងចាកចេញពីភាពក្រីក្ររបស់ប្រជាជនបានទេ។ ទោះជាយ៉ាងណាក៏ដោយព័ត៌មាននៃផ្នែកនីមួយៗនៅតែអនុញ្ញាតអោយយើងសន្និដ្ឋានបានថា បរិមាណច្រើនបង្គួរនៃជនក្រីក្រធម្មតា(ពោល គឺជនដែលមានការប្រើប្រាស់ឋិតនៅក្រោមបន្ទាត់ភាពក្រីក្រតិចតួច) បានចាក

[៧២] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៤១

[៧៣] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៤១

[៧៤] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៤២

ចេញពីភាពក្រីក្រ រីឯទំហំនៃភាពខ្វះខាតការប្រើប្រាស់របស់ជនក្រីក្រជ្រុល និងបរិមាណនៃជនក្រីក្រជ្រុលក្នុងចំណោមជនក្រីក្រសរុបក្នុងឆ្នាំ២០០៤ នៅតែមានកម្រិតស្រួចស្រាវដូចឆ្នាំ១៩៩៤ ដដែល[៧៥]។

បែបផែននៃកំណើន និងការកាត់បន្ថយភាពក្រីក្រក៏កំពុងតែបង្កើនភាពខុសគ្នានៃអត្រាភាពក្រីក្រក្នុងផ្នែកផ្សេងៗរបស់ប្រទេស។ ភាពក្រីក្របានធ្លាក់ចុះយ៉ាងលឿននៅទីក្រុងភ្នំពេញ និងនៅតំបន់ឆ្នេរសមុទ្រ ដែលបាននាំមុខយ៉ាងច្រើនជាងនៅតំបន់ទន្លេសាប និងតំបន់ទំនាប[៧៦]។

មេគុណជីនី(GINI) បានផ្តល់ការវាស់វែងវិសមភាពដោយសង្ខេប និងមានប្រយោជន៍ក្នុងការបែងចែកប្រាក់ចំណូល ឬការប្រើប្រាស់: តម្លៃសូន្យមានន័យថា មានភាពស្មើគ្នាល្អឥតខ្ចោះក្នុងការបែងចែកប្រាក់ស្មានមេគុណចំណូលខណៈដែលតម្លៃ១ បានចង្អុលបង្ហាញថាមានវិសមភាពទាំងស្រុង។ ការប៉ាន់ GINI សម្រាប់កម្ពុជាបានបញ្ជាក់ថា វិសមភាពបានកើនឡើងយ៉ាងខ្លាំងនៅតាមតំបន់ដែលអាចប្រៀបធៀបគ្នាបានរវាងឆ្នាំ១៩៩៤ និង២០០៤ ភាពមិនស្មើគ្នាបាននាំមុខជាបឋមនៅតំបន់ជនបទ[៧៧]។ អត្រានៃកំណើនវិសមភាពនៅកម្ពុជាត្រូវបានគេមើលឃើញថា មានល្បឿនលឿនមិនធម្មតា។ ដោយផ្តាច់ចេញពីគ្នានៃការប្រែប្រួលវិសមភាពអោយទៅជាក្រុមៗ និងការប្រែប្រួលក្នុងក្រុមយើងឃើញថា ៨៦% នៃការកើនឡើងវិសមភាពសរុប គឺបណ្តាលមកពីការកើនឡើងនៃវិសមភាពនៅតំបន់ជនបទ ហើយមានតែ ១៤% ប៉ុណ្ណោះដែលបណ្តាលពីការកើនឡើង នៃវិសមភាពរវាងជនបទ និងទីក្រុង។

ការចាប់អារម្មណ៍លើការឡើងយ៉ាងឆាប់រហ័ស នៃវិសមភាពរវាងតំបន់ទីក្រុង និងតំបន់ជនបទ គឺជាអ្វីមួយដែលគេគិតថាជាការពិភាក្សាដ៏មានប្រជាប្រិយភាព ក្នុងនោះរួមទាំងនៅថ្នាក់ភូមិផងដែរ។

ទស្សនៈផ្សេងៗពីវិសមភាពក្នុងចំណោមយុវជននៅជនបទ:[៧៨] បើសិនជាមានការយល់ដឹងពីសន្តិសុខ និងសេរីភាពជាមូលដ្ឋានខ្លាំងជាងមុនក្នុងសហគមន៍ជនបទនោះ ក៏នឹងមានការយល់ដឹងពីវិសមភាពកាន់តែធំឡើង និងកាលានុវត្តភាពសម្រាប់កូនចៅគ្រួសារអ្នកមាន និងអ្នកក្រ។

អ្នកមាន មានម្ហូបអាហារសម្រាប់បរិភោគនៅពេលដែលអ្នកក្រគ្មានអ្វីសោះ។ អ្នកមាន ក្លាហាន និងមានអំណាច ចំណែកអ្នកក្រគ្មានលក្ខណៈទាំងនេះទេ។ កូនអ្នកមានស្លៀកពាក់ខោអាវស្អាត និងល្អណាស់ ចំណែកខ្ញុំដែលជាកូនអ្នកក្រមានតែសំលៀកបំពាក់កខ្វក់(យុវជន)។ តាំងពីឆ្នាំ១៩៩៨ មកសុខមាលភាពរបស់ប្រជាជននៅក្នុងសហគមន៍នេះបានប្រសើរឡើងយ៉ាងខ្លាំង។ អ្នកមានកាន់តែមានទៅចំណែកឯអ្នកក្រនៅជាប់អន្ទាក់ភាពក្រីក្រ ឬធ្លាក់ខ្លួនក្រជាងមុន។ ហេតុផលដែលនាំអោយមានវិសមភាពរវាងប្រជាជនក្នុងសហគមន៍នេះ គឺជាអ្នក

---

[៧៥] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៤៥

[៧៦] ដ-ឯ-ម

[៧៧] ដ-ឯ-ម

[៧៨] MOPS, CDRI 2006

មានលុយច្រើនមានដីប្រកបដោយជីជាតិ និងមានលទ្ធភាពជួលអ្នកក្រ និងអ្នកខ្វះខាតខ្លាំងអោយធ្វើការអោយពួកគេ។ ពួកគេគ្រាន់តែប្រើខួរក្បាល និងលុបដើម្បីរកចំណូលបានខ្ពស់នៅពេលដែលយើងប្រើពលកម្មខ្លាំងតែបានទទួលប្រាក់កម្រៃតិចតួចមកវិញ(យុវនារី)។

អ្នកខ្លះបានកត់សម្គាល់ថា វិសមភាពខាងទ្រព្យសម្បត្តិមានន័យថា អ្នកមាន មានលទ្ធភាពប្រើសេរីភាពយ៉ាងរីករាយ ដែលនេះគ្រាន់តែជាទ្រឹស្តីសម្រាប់អ្នកក្រប៉ុណ្ណោះ។

យើងមានសេរីភាពធ្វើអ្វីដែលយើងចង់ ជាពិសេសរកការងារធ្វើទាំងនៅក្នុង និងក្រៅភូមិ ដើម្បីក្រពះយើងផ្ទាល់ និងរបស់សមាជិកគ្រួសារយើងផ្សេងទៀត។ ប៉ុន្តែអ្នកមានទ្រព្យសម្បត្តិមានសេរីភាពជាងអ្នកក្រ ពីព្រោះពួកគេមានលុយ ហើយអាចកំសាន្តសប្បាយនៅពេលណាពួកគេចង់។ (យុវនារីក្នុងគ្រួសារក្រីក្រ) បើយើងចង់ទៅចូលរួមពិធីក្នុងសហគមន៍នៅពេលយប់យើងត្រូវសុំការអនុញ្ញាតពីឪពុកម្តាយយើងសិន។ ប៉ុន្តែជាធម្មតា យើងមិនអាចទៅទេ ពីព្រោះតាមការពិតយើងគ្មានលុយ យើងត្រូវធ្វើការធ្ងន់នៅពេលព្រឹកទៀត។ បើចង់មានសេរីភាពត្រូវមានបាយគ្រប់គ្រាន់ដើម្បីបរិភោគសិន(យុវនារី)។

តាមការពិតការកើនឡើងនៃវិសមភាព គឺជាប្រការដែលមិនអាចជៀសផុតបានក្នុងអន្តរកាលសេដ្ឋកិច្ចដែលមានផែនការពីថ្នាក់កណ្តាល និងក្រីក្រអោយទៅជាសេដ្ឋកិច្ចមួយដែលឈរលើគោលការណ៍ទីផ្សារ។ ដរាបណា វិសមភាពបានកើនឡើងស្របទៅនឹងការធ្លាក់ចុះនៃភាពក្រីក្រខ្លាំង គេអាចអះអាងថាវិសមភាពតែឯកឯងមានទំនាក់ទំនងខ្លាំងរវាងកម្រិតខ្ពស់នៃវិសមភាព និងភាពយឺតយ៉ាវនៃអត្រាកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ អ្វីដែលជាចំណាប់អារម្មណ៍អំពីសេចក្តីអធិប្បាយរបស់ MOPS គឺជាការគិតថា វិសមភាពកំពុងកើនឡើងមិនត្រឹមតែក្នុងន័យជាសមិទ្ធផលប៉ុណ្ណោះ តែថែមទាំងក្នុងន័យឱកាសថែមទៀត។ មានការយល់ឃើញមួយថា ជនក្រីក្រដែលមានទ្រព្យសម្បត្តិទំនាក់ទំនងសង្គម និងមានកាលានុវត្តភាពតិចតួចសម្រាប់ការអប់រំ ត្រូវបានជាប់គាំងនៅក្នុងកិច្ចការដែលប្រើប្រាស់ជំនាញទាប និងកិច្ចការធ្វើដោយដៃមិនមានលទ្ធភាពប្រកួតប្រជែងក្នុងន័យស្មើភាពគ្នាជាមួយអ្នកមានបានទេ។

ប្រធានបទនេះ នឹងត្រូវបានពន្យល់កាន់តែលម្អិតនៅជំពូកបន្ទាប់ដែលពិភាក្សាពីកម្រិតនៃវិសមភាពក្នុងឆ្នាំ២០០៤។ ប៉ុន្តែសម្រាប់ពេលនេះ គឺយើងគ្រាន់តែកត់សម្គាល់ថា ប្រសិនបើអត្ថប្រយោជន៍នៃកំណើនក្នុងរយៈពេល ១០ឆ្នាំ កន្លងទៅនេះត្រូវបានបែងចែកអោយមានភាពស្មើគ្នាកាន់តែច្រើនរវាងអ្នកមាន និងអ្នកក្រម្ល៉េះ អត្រានៃការកាត់បន្ថយភាពក្រីក្រត្រូវបានកើនឡើងយ៉ាងខ្លាំង។ បទពិសោធន៍នៃបណ្តាប្រទេស(ឧទាហរណ៍ ប្រទេសវៀតណាម) ដែលបានបង្កើតកំណើនដែលមានមូលដ្ឋានទូលំទូលាយ ដែលបានរាប់បញ្ចូលជនក្រីក្របានច្រើនក្នុងកម្រិតមួយនោះបានបញ្ជាក់បង្ហាញថា បែបផែនការចែករំលែកកំណើនបែបនេះ មានស្ថេរភាពជាង(ជាញឹកញាប់ខ្ពស់ជាង) បែបផែនកំណើន(ដូចដែលគេបានឃើញក្នុងប្រទេសកម្ពុជា) ដែលត្រូវបានឈរលើតែវិស័យពីរបីប៉ុណ្ណោះ ហើយក្នុងនោះអត្ថប្រយោជន៍នៃកំណើនបានបូកបន្ថែមតែលើអ្នកដែលមានស្រាប់។

ចំពោះការធ្លាក់ចូល និងចាកចេញពីភាពក្រីក្រតាមការអង្កេតលើគំរូតាមការជ្រើសរើសដោយចៃដន្យ បានអោយដឹងថា ការប្រែប្រួលសរុប ក្នុងភាគរយនៃភាពក្រីក្ររវាងចំណុចពីរបានធ្វើអោយយើងឃើញនូវការប្រែប្រួលរវាងរូបភាពពីរ ប៉ុន្តែគន្លងនៃការប្រែប្រួលពិតប្រាកដរបស់គ្រួសារមានភាពមិនច្បាស់លាស់ក្នុងរយៈពេលនោះ។ ការប្រែប្រួលជាភាគរយអាចលាក់កំបាំងលក្ខណៈចម្រុះផ្សេងៗជាច្រើន ក្នុងបទពិសោធន៍ជាក់ស្តែងរបស់មនុស្សម្នាក់ៗ ឬគ្រួសារ។ ម្យ៉ាងវិញទៀត ការប្រែប្រួលដូចគ្នានៃអត្រាភាពក្រីក្រជាទូទៅ អាចជាផលិតផលនៃភាពប្រសើរឡើងជាទូទៅបន្តិចម្តងៗនូវកម្រិតជីវភាពក្នុងនោះជនមិនមែនក្រីក្រស្ថិតនៅក្រៅភាពក្រីក្រ ហើយជនក្រីក្រមួយចំនួនបានរួចផុតពីភាពក្រីក្រ ឬស្ថានភាពមួយដែលស្ទាហាប់ជាងនេះ គឺថាមនុស្សមួយចំនួនធំរួចផុតពីភាពក្រីក្រ ប៉ុន្តែជនមិនក្រីក្រពីមុនមួយចំនួនធំ បែរជារំកិលបញ្ច្រៀសទិសធ្លាក់ចូលក្នុងភាពក្រីក្រទៅវិញ។ តុល្យភាពរវាងការផ្លាស់ប្តូរទាំងពីរនេះនាំអោយមានការប្រែប្រួលពិតប្រាកដនៃភាគរយ។ ប្រការនេះមានសារៈសំខាន់ពីព្រោះបទពិសោធន៍ក្នុងប្រទេសផ្សេងទៀតបង្ហាញថា ជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រទាមទារ ជាពិសេសនូវការគួបផ្សំដំណាក់កាលនានា ការបង្កើតកាលានុវត្តភាពសម្រាប់ជនក្រីក្រអោយគេផុតពីភាពក្រីក្រ និងសំណាញ់សុវត្ថិភាពដែលទប់ស្កាត់ជនមិនមែនក្រីក្រ កុំអោយធ្លាក់ចូលក្នុងភាពក្រីក្រ ឬជនក្រីក្រកុំអោយធ្លាក់ចូលក្នុងភាពទីទ័លក្រ។ គោលនយោបាយ និងកម្មវិធីដែលចាំបាច់សម្រាប់ដោះស្រាយភាពងាយទទួលរងគ្រោះជាញឹកញាប់ខុសគ្នាពីគោលនយោបាយ និងកម្មវិធីសម្រាប់ជួយជនដែលកំពុងក្រីក្រ។ ដូចគ្នានេះដែរ ជនក្រីក្ររ៉ាំរ៉ៃ ឬយូរអង្វែងតម្រូវអោយមានបែបផែនជំនួយផ្សេងពីគ្នា ដើម្បីជួយពួកគេអោយឆ្លងផុតទៅកាន់ជនក្រីក្ររយៈពេលខ្លី។

ម្យ៉ាងទៀត យើងក៏ចង់ដឹងដែរថា តើប្រភេទជនក្រីក្រ និងជនក្រីក្រមានស្ថេរភាពយ៉ាងដូចម្តេច? ដូច្នេះដើម្បីស៊ើបអង្កេតបញ្ហាដែលមានយូរមកហើយនេះ ការសិក្សាពីការចេញពីភាពក្រីក្រ MOPS ដែលរៀបចំឡើងនិងធ្វើការអង្កេតដោយ CDRI ត្រូវបានធ្វើអង្កេតឡើងវិញ ២០០៤-០៥ នេះបានធ្វើអង្កេតសារជាថ្មីឡើងវិញគ្រួសារជិត ១.០០០ ដែលត្រូវបានអង្កេតរួចពីឆ្នាំ២០០១។ លទ្ធផលនៃការងារនេះមានទម្រង់ការយល់ដឹងពីតុល្យភាពក្នុងរយៈពេល ៣ឆ្នាំ រវាង ក-ជនក្រីក្ររ៉ាំរ៉ៃ(អ្នកដែលនៅក្រីក្រក្នុងរយៈពេល ២ឆ្នាំ) ខ-ជនមិនមែនក្រីក្រ ថេរ គ-អ្នកដែលបានគេចចេញផុតពីភាពក្រីក្រ ឃ-អ្នកដែលបានធ្លាក់ចូលក្នុងភាពក្រីក្រ។

វិសាលភាពនៃការប្រែប្រួលកម្រិតជីវភាពគ្រួសារៈ ដោយសារមានការលំបាកក្នុងការវាស់ប្រើប្រាស់អោយបានត្រឹមត្រូវ ឬលម្អិតនៅក្នុងការអង្កេតគ្រួសារ ដែលធ្វើឡើងក្នុងគោលបំណងច្រើនមានកង្វល់សមហេតុផលមួយថា ការវិភាគដែលគិតតែថា តើគ្រួសារទាំងឡាយបានឆ្លងផុតបន្ទាត់ភាពក្រីក្រប្រាកដមួយ ឬនៅអាចនឹងផ្តល់ការចាប់អារម្មណ៍ខុសស្តីពីភាពប្រាកដនៃការវិភាគ។ ជំនួសអោយការបែងចែកតែជាពីរផ្នែកអ្នកក្រ និងអ្នកមិនក្រ យើងសម្រេចធ្វើការវិភាគដើមលើទិដ្ឋភាពផ្សេងៗ នៃគ្រួសារក្នុងកម្រងទិន្នន័យរបស់ MOPS តាមការបែងចែកសុខមាលភាពគ្រួសារជាបីប្រភេទនៅពេលណាមួយ។ វិធីសាស្ត្រនេះ បែងចែកច្បាស់លាស់រវាងអ្នកក្រ(អ្នកស្ថិតនៅក្រោមដាច់ពីបន្ទាត់ភាពក្រីក្រហៅថា "ជនក្រីក្រខ្លាំង") អ្នកមិនក្រ(អ្នកស្ថិតនៅលើដាច់ពីបន្ទាត់ភាពក្រីក្រ

"អ្នកធូរធារ") និងអ្នកដែលនៅចន្លោះ ២០%ខាងលើ និងខាងក្រោមបន្ទាត់ភាពក្រីក្រហៅថា "ជនក្រីក្រល្មម"។ ផ្នែកលើមូលដ្ឋានចំណាយប្រចាំគ្រួសារក្នុងមនុស្សម្នាក់ដែលបានកត់ត្រានៅក្នុង MOPS គ្រួសារនីមួយៗក្នុងចំណោមគ្រួសារចំនួន ៨៩០ ដែលត្រូវបានអង្កេតនៅឆ្នាំ២០០១ និង២០០០ ត្រូវបែងចែកអោយស្ថិតនៅក្នុងប្រភេទណាមួយក្នុងចំណោម ប្រភេទទាំងបីសម្រាប់ការអង្កេតទាំងពីរឆ្នាំ។ ដោយប្រៀបធៀបស្ថានភាពក្នុងឆ្នាំ ២០០១និង ២០០៤ យើងទទួលបាននូវក្រុមចំនួន ៩ ដូចដែលបង្ហាញក្នុងប្រអប់ចំនួន ៩ ដែលប្រអប់នីមួយៗកំណត់ពីចលនា(ឬអចលនា) របស់គ្រួសារក្នុងរយៈពេល ៣ឆ្នាំ នៅចន្លោះការអង្កេតទាំងពីរ។

តារាងអន្តរកាលនៃគ្រួសារជាក្រុម

		២០០៤		
		ក្រីក្រខ្លាំង	**ក្រីក្រល្មម**	**ធូរធារ**
២០០១	**ក្រីក្រខ្លាំង**	១៤%	១០%	៤%
	ក្រីក្រល្មម	៧%	១៤%	១២%
	ធូរធារ	៣%	១២%	២៤%

មិនថាពួកគេស្ថិតក្នុងក្រុមក្រីក្រណាស់ ក្រីក្រល្មម ឬធូរធារនៅឆ្នាំ២០០១ ពួកគេនៅតែស្ថិតក្នុងក្រុមដដែលនៅឆ្នាំ២០០៤។ អ្នកដែលនៅក្រុមក្រីក្រណាស់ទាំងពីរលើកត្រូវបានហៅថា "ជនក្រីក្ររ៉ាំរ៉ៃ"។ ក្រុមនេះមានប្រមាណ ១៤% នៃគំរូរបស់ MOPS។ ក្រុម "មធ្យមចេះ" ដែលបានចាប់ផ្តើម និងបញ្ចប់ក្នុងប្រភេទ "ក្រីក្រល្មម" មានប្រមាណ ១៤%ដែរ។ ចុងក្រោយ "អ្នកមាន" ដែលនៅតែធូរធារទាំងក្នុងឆ្នាំ២០០១ និង២០០៤ ជាក្រុមដែលធំជាងគេបង្អស់ក្នុងតារាងអន្តរកាលនេះជាមួយនឹងអត្រា ២៤% នៃគំរូ។ រួមបញ្ចូលគ្នាអ្នកដែលមិនមានចលនាទាំងនេះមានប្រមាណ ៥១% នៃគំរូទាំងអស់បញ្ជាក់ថា មានកម្រិតស្ថេរភាពមួយសម្រាប់គ្រួសាររស់នៅជនបទជាច្រើន ដែលយ៉ាងហោចណាស់វាស្ថិតស្ថេរក្នុងរយៈពេលយ៉ាងខ្លីបីឆ្នាំ និងនៅក្នុងក្រុមដ៏ទូលំទូលាយទាំងបីនេះ។

ប៉ុន្តែគ្រួសារនៅសល់ ៤៩% បានប្តូរស្ថានភាពរបស់ខ្លួនឡើងលើ ឬចុះក្រោមមួយ ឬពីរទីតាំង។ គ្រួសារដែលធ្វើចលនាឡើងលើមានបរិមាណច្រើនជាងគ្រួសារដែលមានចលនាចុះក្រោមបន្តិច។ គ្រួសារតិចតួចប៉ុណ្ណោះ(ប្រមាណ៧%)បានប្តូរស្ថានភាពខ្លាំងដែលកំណត់ដោយចលនាឡើងលើ ឬចុះក្រោមឆ្លងដល់ទៅពីរក្រុម(ពោល គឺពីជនក្រីក្រខ្លាំងទៅជាអ្នកធូរធារហៅ "ពីស្នូមទៅជាអ្នកមាន" ឬពីអ្នកមានធូរធារទៅជាជនក្រីក្រខ្លាំងវិញហៅថា "ពីអ្នកមានទៅជាស្នូម")។ ដោយសារតែក្រុមទាំងពីរមានទំហំតូច(មួយៗមានតែ ៣.៥% នៃគំរូភូមិ

ចំនួន ៩ ឬប្រហែល ៣០គ្រួសារ)។ យើងដាក់ក្រុមទាំងពីរបញ្ចូលជាមួយនឹងក្រុមជិតខាងក្នុងបំណងធ្វើការវិភាគនៅពេលក្រោយទៀត[៧៩]។

ម្យ៉ាងទៀត បើយើងពិនិត្យមើលលើការពន្យល់ពីការប្រែប្រួលនៃទ្រព្យធនគ្រួសារ ឃើញថា យុទ្ធសាស្ត្រដោះស្រាយជីវភាព និងវិសាលភាពរបស់យុទ្ធសាស្ត្រទាំងនោះមានលក្ខណៈស្មុគស្មាញ។ ហេតុនេះមិនមែនជាការងាយស្រួលក្នុងការកំណត់ថា តើអ្វីដែលមានសហព័ន្ធ និងការប្រែប្រួលនៃស្ថានភាពគ្រួសារលើសពីការទទួលយកយុទ្ធសាស្ត្រដោះស្រាយដែលលេចចេញពីនេះ។ អាស្រ័យហេតុនេះ នៅដំណាក់កាលនេះយើងបង្ហាញការរៀបរាប់ត្រង់ៗពីការប្រែប្រួលចម្បងនៃលក្ខណៈសម្គាល់គ្រួសារសិន។ ការវិភាគលម្អិតនេះត្រូវបានបញ្ចូលក្នុងការសិក្សាសំយោគរបស់ MOPS ដែលធ្វើឡើងដោយ CDRI ដែលនឹងចេញផ្សាយនៅរវាងឆ្នាំ២០០៦។

ការវិភាគដើមលើកឡើងថា ការកើនឡើងនៃប្រាក់ចំណូលទាំងអស់ បានជួយពង្រឹងទីតាំងរបស់ជនមិនមែនក្រីក្រ។ ទន្ទឹមនឹងនោះជនក្រីក្ររ៉ាំរ៉ៃហាក់ដូចជាជាប់អន្ទាក់ ក្នុងសកម្មភាពដែលផ្តល់ប្រាក់ចំណូលទាប ដែលមិនអាចអោយពួកគេសន្សំប្រាក់ ឬធ្វើវិនិយោគ ដែលអាចនាំអោយចាកចេញផុតពីភាពក្រីក្របាន។ គ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេ គ្រួសារដែលធ្លាប់ចូលក្នុងភាពក្រីក្រ បានឆ្លងកាត់ការធ្លាក់ចុះនៃប្រាក់ចំណូលយ៉ាងច្រើន។ ដូចគ្នានេះដែរ គ្រួសារដែលបានដឹងថា ការប្រើប្រាស់របស់ខ្លួនថយចុះ (ធ្លាក់ចូលក្នុងភាពក្រីក្រ និងភាពក្រីក្រកាន់តែជ្រៅ) មើលឃើញតម្លៃនៃទ្រព្យធនគ្រួសារទាំងអស់ថយចុះដែរ នៅចន្លោះឆ្នាំ២០០១ និងឆ្នាំ ២០០៤ នៅពេលដែលក្រុមផ្សេងទៀតទាំងអស់ដែលមានរួមទាំងជនក្រីក្ររ៉ាំរ៉ៃ បានប្រមូលទ្រព្យធនដែលមានតម្លៃយ៉ាងច្រើន[៨០]។

ទំនាក់ទំនងរវាងវិសាលភាពគ្រួសារ និងការប្រែប្រួលសមាសភាពនៃប្រាក់ចំណូលគួរអោយចាប់អារម្មណ៍ណាស់។ ប្រាក់ចំណូលពីអាជីវកម្មផ្ទាល់ខ្លួនពលកម្ម និងប្រភព "ផ្សេងទៀត" បានក្លាយជាមានសារៈសំខាន់យ៉ាងខ្លាំងដោយពលកម្មហាក់ដូចជាសំខាន់ ជាពិសេសក្នុងការជួយគ្រួសារអោយគេចផុតចេញពីក្រុមក្រីក្រខ្លាំង ចំណែកឯអាជីវកម្មផ្ទាល់ខ្លួនបានជួយគ្រួសារក្រីក្រល្មមអោយចូលទៅក្នុងជួរនៃគ្រួសារអ្នកមានលុយ។ សម្រាប់ជនក្រីក្ររ៉ាំរ៉ៃ ប្រភពសំខាន់បំផុតនៃប្រាក់ចំណូលនៅឆ្នាំ២០០៤ (៣៨% នៃប្រាក់ចំណូលទាំងអស់) គឺប្រាក់កម្រៃបានមកពីការធ្វើការដោយខ្លួនឯងក្នុងពេលដែល ២៣% បានមកពីពលកម្ម និង១៨% ពីធនធានកម្មសិទ្ធិរួម (CPR)[៨១]។ តួលេខនេះបានប្រែប្រួលយ៉ាងខ្លាំងពីឆ្នាំ២០០១ នៅពេលដែលប្រាក់ចំណូលបានមកពី

[៧៩] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៥០

[៨០] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៥១

[៨១] ដ-ឯ-ម

ធនធានកម្មសិទ្ធិរួម គឺកសិកម្ម(២៨%ប្រៀបធៀបនឹង ៣៣%) ហើយពលកម្មបានរួមវិភាគទានតែ ២៨% នៃប្រាក់ចំណូលទាំងអស់។

គ្រួសារដែលធ្លាក់ក្នុងភាពក្រីក្រ ត្រូវបានកំណត់ដោយការធ្លាក់ចុះនៃប្រាក់ចំណូលពីកសិកម្ម និងពីធនធានកម្មសិទ្ធិរួម(CPR) និងការកើនឡើង(ខ្លាំង ឬសមាមាត្រ) នៃប្រាក់ចំណូលបានមកពីអាជីវកម្មផ្ទាល់ខ្លួន និងពលកម្ម។ ការនេះឆ្លុះបញ្ចាំងថា ទឹកជំនន់ និងគ្រោះរាំងស្ងួតជាច្រើនក្នុងឆ្នាំកន្លងទៅថ្មីៗនេះបានប៉ះពាល់ការបង្កបង្កើនផលស្រូវ។ ភូមិជាច្រើនដែល MOPS ធ្វើការសិក្សាក៏បានទទួលរងការថយចុះនៃការរនេសាទយ៉ាងខ្លាំងដែរ។ ទាំងនេះ គឺជាទិន្នាការដែលគ្រួសារជនបទជាច្រើនផ្សេងទៀត បានឆ្លងកាត់ដូចគ្នានៅកម្ពុជា។

ការងារចុះទៅមូលដ្ឋានរបស់ក្រុមការងាររបស់ MOPS ដែលបានសួរសំណួរជាក់លាក់ពីការប្រែប្រួលខ្លាំង ដែលគ្រួសារប្រឈមលើកឡើងថា គ្មានភាពខុសគ្នាជាធំដុំទេ រវាងក្រុមជនក្រីក្រ និងក្រុមអ្នកមាន។ ការណ៍នេះបញ្ជាក់ថា នៅពេលដែលគ្រួសារជនបទភាគច្រើនអាចប្រឈមនឹងទិដ្ឋភាពហានិភ័យដូចគ្នា(និងកម្រិតខ្ពស់ជាង) គ្រួសារអ្នកមានជាងក៏អាចទប់ទល់នឹងការស្តុតរន្ធត់បែបនេះដែរ ដោយមិនចាំបាច់ស្រាវរកទ្រព្យធនផលិតកម្មសំខាន់ៗ ឬរកយុទ្ធសាស្ត្ររស់នៅផ្សេងទៀត ដែលខុសប្លែកពីអ្នកក្រីក្រឡើយ ប្រសើរជាងការធ្លាក់ចុះនៃផលិតភាពដោយសារតែការប្រែប្រួលខ្លាំងបែបនេះ។

៣.៣ ស្ថានភាពក្រីក្រនៅកម្ពុជាចន្លោះឆ្នាំ ២០០៤-២០០៨

អត្រាភាពក្រីក្រនៅឆ្នាំ២០០៤ គឺមានប្រមាណជា ៣៥% មានន័យថា ៣៥% នៃប្រជាជនកម្ពុជាត្រូវបានប៉ាន់ស្មានថារស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ។ ឯភាពក្រីក្រនៅជនបទ(៣៩%) មានកម្រិតខ្ពស់ជាងនៅទីក្រុង(៥% នៅភ្នំពេញ និងនៅតំបន់ទីប្រជុំជនផ្សេងទៀត)។

ភាពក្រីក្រនៅកម្ពុជា គឺជាអកូតហេតុជនបទយ៉ាងលើសលប់មួយ។ នៅឆ្នាំ២០០៤ ប្រហែល ៩១% នៃជនក្រីក្របានរស់នៅក្នុងតំបន់ជនបទ។ តំបន់ជនបទនៅក្នុងភូមិភាគទន្លេសាប និងភូមិភាគភ្នំ/ខ្ពង់រាប បានទទួលរងអត្រាភាពក្រីក្រកម្រិតខ្ពស់បំផុត និងប្រពលភាពនៃភាពក្រីក្រធ្ងន់ធ្ងរបំផុត។ អត្រាភាពក្រីក្រនៅភូមិភាគជនបទទន្លេសាប និងភូមិភាគជនបទភ្នំ/ខ្ពង់រាប គឺ៤៥% និង៤៦% តាមលំដាប់។

បើយើងមើលទៅលើទិដ្ឋភាពមុខរបរតាមគ្រួសារដែលមេគ្រួសារប្រកបមុខរបរកសិកម្ម ឬធ្វើការជាអ្នកបម្រើតាមផ្ទះនោះស្ថិតក្នុងអត្រាភាពក្រីក្រខ្ពស់បំផុត(ជាមធ្យមជាង ៤០%) និងក្នុងប្រពលភាពនៃភាពក្រីក្រធ្ងន់ធ្ងរជាងគេបំផុត។ គ្រួសារដែលមេគ្រួសារប្រកបមុខរបរណាមួយក្នុងចំណោមមុខរបរទាំពីរខាងលើជារួមមានចំនួនជិត ២/៣ នៃជនក្រីក្រទាំងអស់នៅប្រទេសកម្ពុជា។ ក្រុមមុខរបរដែលទទួលបានអត្រាភាពក្រីក្រទាបជាងគេបំផុត គឺក្រុមគ្រួសារដែលមានមេគ្រួសារធ្វើការក្នុងវិស័យសាធារណៈ។

គ្រួសារក្រីក្រមានអម្រែកពឹងផ្អែកពលកម្មកម្រិតខ្ពស់ និងខ្វះខាតធនធានមនុស្ស គឺពួកគាត់ច្រើនតែគ្មានការអប់រំ គ្មានជំនាញ និងគ្មានសុខភាពល្អ។ ជនក្រីក្រ និងជាពិសេសជនក្រីក្រជ្រុលបានប្រមូលផ្តុំនៅក្នុង

តំបន់ជនបទជាច់ស្រយាល ដែលនៅទីនោះលទ្ធភាពទទួលបានផ្លូវថ្នល់ ទីផ្សារ និងសេវាមូលដ្ឋាននៅមានកម្រិត។ ពួកគាត់ក៏គ្មានការធានាក្នុងការបានទទួលកម្មសិទ្ធិកាន់កាប់ដីធ្លីពិតប្រាកដ និងលទ្ធភាពទទួលបានប្រព័ន្ធធានារ៉ាស្ត្រផងដែរ។ បញ្ហាសំខាន់សម្រាប់ជនក្រីកក្រនៅទីក្រុង គឺការធានាក្នុងការបានទទួលកម្មសិទ្ធិកាន់កាប់ផ្ទះ និងកាលានុវត្តភាពសម្រាប់រកប្រាក់ចំណូល ឬការងារប្រកបដោយផលចំណេញ។ លើសពីនេះអ្នករស់នៅក្នុងតំបន់អាណាធិបតេយ្យទាមទារសិទ្ធិរស់នៅជាមួយនឹងសិទ្ធិទទួលបានសេវាក្នុងកម្រិតមួយ ប៉ុន្តែគ្មានសិទ្ធិកាន់កាប់ផ្ទះទេ ព្រមទាំងងាយរងគ្រោះពីការបណ្តេញចេញពីទីនោះគ្រប់ពេលវេលាទៀតផង។

សម្រាប់ជាព័ត៌មានយោង អត្រាភាពក្រីក្រនៅឆ្នាំ២០០៤ បើផ្អែកតាមបន្ទាត់ភាពក្រីក្រអន្តរជាតិ ១ដុល្លារ ១ថ្ងៃ គឺមាន ១៨,៥% ។ ក៏ប៉ុន្តែនៅក្នុងកិច្ចការនេះទាំងមូលភាពក្រីក្រត្រូវបានវិភាគតាមស្តង់ដារទូទៅ គឺផ្អែកលើបន្ទាត់ភាពក្រីក្រជាតិ ដែលបានពិពណ៌នានៅក្នុងអត្ថបទខាងលើ។

ក-ការប្រើប្រាស់បន្ទាត់ភាពក្រីក្រ: ប្រៀបធៀបបន្ទាត់ភាពក្រីក្រ និងបន្ទាត់១ដុល្លារ ១ថ្ងៃ[៨២]

នៅក្នុងមួយទសវត្សកន្លងមកសហគមន៍អន្តរជាតិ បានចាប់អារម្មណ៍ខ្លាំងឡើងៗចំពោះការតាមដានរាល់ទិន្នាការនៃភាពក្រីក្រនៅក្នុងពិភពលោកទាំងមូលជាចម្បង គឺដើម្បីតាមដានពីដំណើរការឆ្ពោះទៅរកការសម្រេចបានគោលបំណងទី១ នៃគោលដៅអភិវឌ្ឍន៍សហវត្ស ដែលទាមទារអោយរដ្ឋាភិបាល និងអង្គការអន្តរជាតិប្តេជ្ញាកាត់បន្ថយភាគរយនៃប្រជាជនក្រីក្រនៅលើពិភពលោកទាំងមូល អោយចុះថយអស់នៅពាក់កណ្តាលពីឆ្នាំ ១៩៩០ ដល់ ២០១៥ ។ ដើម្បីតាមដានមើលភាពក្រីក្រថ្នាក់ពិភពលោក គេចាំបាច់ត្រូវមានវង្វាស់ភាពក្រីក្រជាច់ខាត ដែលមានលក្ខណៈជាបទដ្ឋានរួមអាចប្រៀបធៀបពីប្រទេសមួយទៅប្រទេសមួយ និងពីមួយឆ្នាំទៅមួយឆ្នាំដោយជាក់ស្តែង។ តម្រូវការអោយមានចំណុចសម្រេចជាអន្តរជាតិនេះបានធ្វើអោយគេប្រកាន់យកបន្ទាត់មួយដែលគេហៅថា "១ដុល្លារ ក្នុង១ថ្ងៃ" ដែលកំណត់បន្ទាត់ភាពក្រីក្រផ្អែកលើទំនិញ និងសេវាដែលអាចទិញបានសម្រាប់ ១ដុល្លារ សម្រាប់ម្នាក់ក្នុង ១ថ្ងៃ នៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៣។ ដូច្នេះ ពាក្យពេញនៃបន្ទាត់ភាពក្រីក្រអន្តរជាតិ គឺ ១ដុល្លារ ១នាក់ ក្នុង ១ថ្ងៃ គិតតាមអំណាចទិញខុសៗគ្នាធៀបនឹងឆ្នាំ១៩៩៣។

តាមរយៈការកំណត់ដូចនេះ បន្ទាត់ភាពក្រីក្រអន្តរជាតិសំដៅទូទាត់ការប្រែប្រួលថ្លៃទំនិញ(គឺទូទាត់តាមអតិផរណា) និងទូរទាត់តាមថ្លៃខុសគ្នារវាងប្រទេសនានា (គឺទូរទាត់តាមភាពខុសគ្នានៃចំណាយក្នុងការរស់នៅរវាងសេដ្ឋកិច្ចផ្សេងៗគ្នា)។ ដោយសារថ្លៃទំនិញ និងសេវា(ជាពិសេសថ្លៃអាហារ) នៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំមានកម្រិតទាបជាងនៅសហរដ្ឋអាមេរិក តម្លៃពិតប្រាក់នៃប្រាក់ ១ដុល្លារ គិតតាមអំណាចទំនិញខុសគ្នាធៀបនឹងឆ្នាំ១៩៩៣ នៅប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយនោះមានកម្រិតស្មើនឹង ១.៣៨២រៀល ក្នុង១នាក់ ក្នុង១ថ្ងៃ(ឬ០.៣៤ដុល្លារ គិតតាមថ្លៃនៅឆ្នាំ២០០៤)។ ដូច្នេះ បន្ទាត់ភាពក្រីក្រអន្តរជាតិ ១ដុល្លារ ក្នុង១ថ្ងៃមានតម្លៃជាក់ស្តែងទាបជាងបន្ទាត់ភាពក្រីក្រជាតិ និងដែលត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ គឺមាន

[៨២] Knowles 2005, Deaton 2001; Deaton and Grosh 2000

តម្លៃ ១.៧៥៣រៀល(០.៤៣ដុល្លារ) សម្រាប់១នាក់ក្នុង១ថ្ងៃនៅជនបទ និង ២.៣៥១រៀល (០.៥៨ដុល្លារ) សម្រាប់១នាក់ក្នុង១ថ្ងៃនៅភ្នំពេញ។ ដូច្នេះ ការប្រើប្រាស់បន្ទាត់ភាពក្រីក្រអន្តរជាតិ នាំអោយមានការប៉ាន់ស្មានអត្រាភាពក្រសម្រាប់ឆ្នាំ២០០៤(១៨,៥%) ទាបជាងអត្រាដែលបានមកពីបន្ទាត់ភាពក្រីក្រជាតិ(៣៥%) ទោះបីជាអត្រាទាំងពីរនេះផ្អែកលើទិន្នន័យដូចគ្នាក៏ដោយ(គឺទិន្នន័យស្តីពីការប្រើប្រាស់ក្នុងគ្រួសារគិតក្នុង១នាក់ក្នុង១ថ្ងៃ បានមកពីការសួរអោយអោយគ្រួសាររំលឹកពិការចំណាយកន្លងមកនៅក្នុងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច២០០៤)។

គម្លាតខុសគ្នារវាងបន្ទាត់ភាពក្រីក្រជាតិ ដែលមានលក្ខណៈសព្វជ្រុងជ្រោយ និងបន្ទាត់ភាពក្រីក្រអន្តរជាតិ ដែលមានកម្រិតទាបជាងមិនមែនជារឿងមិនប្រក្រតីនោះទេ។ កម្រិតនៃបន្ទាត់ភាពក្រីក្រសម្រាប់កម្ពុជាមានកម្រិតប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសមានចំណូលទាបភាគច្រើន ដែលមានបន្ទាត់ភាពក្រីក្រជាតិទាបជាងកន្លះដុល្លារក្នុង ១ថ្ងៃ គិតតាមថ្លៃបច្ចុប្បន្ន ប៉ុន្តែកម្រិតនេះវាខ្ពស់ជាងបន្ទាត់ភាពក្រីក្រអន្តរជាតិ ១ដុល្លារ ក្នុង ១ថ្ងៃ (ដែលនាំអោយមានអត្រាភាពក្រីក្រគិតតាមបន្ទាត់ភាពក្រីក្រជាតិខ្ពស់ជាងអត្រាគិតតាមបន្ទាត់ភាពក្រីអន្តរជាតិ)។ ឧទាហរណ៍ នៅវៀតណាមកាលពីឆ្នាំ១៩៩៨ អត្រាភាពក្រីកំណត់ដោយបន្ទាត់អន្តរជាតិ ១ដុល្លារ ១ថ្ងៃ គឺ ១៦,៤% រីឯអត្រាភាពក្រីក្រផ្អែកតាមបន្ទាត់ភាពក្រីក្រជាតិ ៤,៩០០ដុង(០.៣៥ដុល្លារ) សម្រាប់ ១នាក់ ក្នុង១ថ្ងៃ តាមការអង្កេតបទដ្ឋានរស់នៅគឺ ៣៧%។ ស្រដៀងគ្នានេះដែរ នៅប្រទេសឡាវ អត្រាភាពក្រីក្រផ្អែកតាមបន្ទាត់ភាពក្រីក្រអន្តរជាតិ ១ដុល្លារ ១ថ្ងៃ គឺ ២៨,១% នៅឆ្នាំ២០០២ និង ២៥,៨% នៅឆ្នាំ ២០០៣។ ផ្ទុយមកវិញ អត្រាភាពក្រីក្រផ្អែកតាមបន្ទាត់ភាពក្រីក្រជាតិនៅឆ្នាំ២០០២-០៣(៣,០៦៥ គិត ឬ ០.២៦ដុល្លារ សម្រាប់ ១នាក់ ក្នុង១ថ្ងៃ) ដែលបានមកពីការអង្កេតសេដ្ឋកិច្ច និងការប្រើប្រាស់មានកម្រិតខ្ពស់ជាងគេ គឺ ៣០,៧%។

ដូច្នេះ បន្ទាត់ភាពក្រីក្រអន្តរជាតិ ១ដុល្លារ ១ថ្ងៃ ផ្តល់នូវការកំណត់ភាពក្រីក្រ ដែលមានពុំសូវច្បាស់លាស់ដូចបន្ទាត់ភាពក្រីក្រជាតិឡើយ។ វាមានតួនាទីសំខាន់ណាស់ក្នុងការប្រៀបធៀបច្បាលៗរវាងប្រទេសនានា ពី១ឆ្នាំទៅ ១ឆ្នាំ ដើម្បពិនិត្យមើលការឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្ស។ ក៏ប៉ុន្តែសម្រាប់ ការវិភាគថ្នាក់ជាតិ និងការពិភាក្សាគោលនយោបាយគេគួរប្រើប្រាស់បន្ទាត់ភាពក្រីក្រ ដែលគេគណនាដោយផ្អែកលើគោលការណ៍អន្តរជាតិ និងចង្កោមនៃការប្រើប្រាស់ជាក់ស្តែងនៅក្នុងប្រទេស។ ដូច្នេះ របាយការណ៍នេះប្រើប្រាស់បន្ទាត់ភាពក្រីក្រជាតិសម្រាប់គណនាអត្រាភាពក្រីក្រផ្សេងៗ។

តំបន់វាលរាបប៉ែកនិរតីទាំងឡាយមានអត្រាភាពក្រីក្រទាបជាងថ្នាក់ជាតិ(៣២% ចំណែកឯភូមិភាគទន្លេសាបមាន ៤៣% និងភូមិភាគខ្ពស់រាប/ភ្នំ មាន៥៦%) ប៉ុន្តែដោយសារដង់ស៊ីតេប្រជាជននៅទីនោះមានកម្រិតទាបមានប្រជាជនរហូតដល់ទៅ ៤០% នៃជនក្រីក្រទូទាំងប្រទេសបានរស់នៅក្នុងខេត្តវាលរាបប៉ែកនិរតីនោះ។

នៅពេលទិន្នន័យត្រូវបានបែងចែកលម្អិតបន្ត គេឃើញមានភាពខុសគ្នាយ៉ាងច្រើនតាមខេត្តនីមួយៗ ប៉ុន្តែខេត្តក្រីក្រជាងគេបំផុត(ក្នុងន័យអត្រាភាពក្រីក្រ និងសន្ទស្សន៍ប្រពលភាពនៃភាពក្រីក្រ) នៅតែគឺជា ខេត្ត

នៅតំបន់ទន្លេសាប ឬតំបន់ភ្នំ/ខ្ពង់រាបដែល។ ចំណែកឯខេត្តដែលមានភាពក្រីក្រជ្រៅជាងគេបំផុត គឺសៀមរាប កំពង់ស្ពឺ និងកំពង់ធំ[៨៣]។

ជាទូទៅជនក្រីក្រ គឺជាសមាជិកគ្រួសារដែលមេគ្រួសារជានីតិជនពេញកម្លាំងបំផុត គឺទិន្នន័យបង្ហាញអោយឃើញថា អត្រាភាពក្រីក្រខ្ពស់បំផុត និងមហាជនដ៏ច្រើនបំផុតនៃជនក្រីក្រ គឺស្ថិតក្នុងចំណោមមេគ្រួសារដែលមានកម្លាំងខ្លាំង(ក្នុងអាយុពី ៣០ ទៅ ៥០ឆ្នាំ)។ បុគ្គលនៅក្នុងគ្រួសារទាំងនេះតំណាងអោយប្រមាណ ៦០% នៃជនក្រីក្រទាំងមូល។

ខ-យេនឌ័រ និងភាពក្រីក្រនៅកម្ពុជា:[៨៤] តាមការសិក្សាឯកសារសង្គមវិទ្យា និងនរវិទ្យាតែងតែសង្កត់ធ្ងន់លើ "សមភាពប្រៀបធៀប" រវាងបុរស និងស្ត្រីនៅកម្ពុជា ហើយចែងថា ស្ត្រីកម្ពុជាតាមប្រពៃណីកន្លងមកមានឋានៈសង្គម និងឯករាជ្យភាពច្រើនជាងស្ត្រីនៃប្រទេសមួយចំនួនដូចជា ឥណ្ឌា និងចិន (Ledgerwood 2005)។ អាពាហ៍ពិពាហ៍មិនតម្រូវអោយខាងស្រីជូនជំនូនទៅខាងប្រុស ហើយចំណងទាក់ទងសាច់ញាតិរវាងខាងប្រុស និងខាងស្រី និងប្រពៃណីអោយខាងប្រុសទៅជាមួយឪពុកម្តាយខាងស្រីក្រោយពីរៀបការ ផ្តល់នូវការគាំទ្រខាងគ្រួសារដល់ស្ត្រី(UNDP 1998)។ ស្ត្រីចូលរួមយ៉ាងសកម្មនៅក្នុងសេដ្ឋកិច្ច ហើយពលកម្មកសិកម្មអាចបែងចែកតាមប្រភេទការងារសម្រាប់បុរស និងស្ត្រី(កាន់តែធ្វើដូចនេះច្រើនឡើង)។ ភាគច្រើនស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការចាត់ចែងប្រាក់ចំណូលទាំងចំណាយរបស់គ្រួសារ ដោយមានការសម្រេចចិត្តរួមគ្នាលើបញ្ហាសេដ្ឋកិច្ចចម្បងៗ។

ទោះបីជាទំនាក់ទំនងរវាងបុរស និងស្ត្រីនៅកម្ពុជាចាត់ទុកថាមានសមភាពជាងនៅប្រទេសដទៃទៀតក៏ដោយ ក៏នៅមានវិសមភាពយេនឌ័រនៅក្នុងផ្នែកមួយចំនួននៃឆាកជីវិតសង្គម សេដ្ឋកិច្ច និងនយោបាយ។ ជាយូរមកហើយ វិសមភាពយេនឌ័រមានកម្រិតខ្ពស់ក្នុងវិស័យអប់រំ(ការបញ្ជូនកូនស្រីទៅសាលារៀនត្រូវបានយល់ឃើញថា ជាការមិនចាំបាច់ ឬគេមិនអោយតម្លៃតែម្តង) នៅក្នុងអំណាចនយោបាយ (មានស្ត្រីតិចតួចណាស់ដែលកាន់កាប់តំណែង ដែលអាចអោយពួកគេចូលរួមចំណែកក្នុងការងារកសិកម្មផងដែរ។ ជម្រើសការងារត្រូវបានកំណត់ចម្បងទៅតាមយេនឌ័រ ហើយមានស្ត្រីតិចតួចណាស់នៅក្នុងនាទីអ្នកគ្រប់គ្រងនៅក្នុងវិស័យណាក៏ដោយ។

ក្នុងការអនុវត្តន៍ជាក់ស្តែងឧត្តមគតិយេនឌ័រ គឺជាចំណែកមួយនៃកត្តាជាច្រើនដែលកំណត់នូវឋានៈ(ដូចជា អាយុ ទ្រព្យសម្បត្តិ កិត្តិនាម និងអំណាច)។ (ជាឧទាហរណ៍ ស្ត្រីរៀបការ ដែលមានកូនអាចមានសេរីភាពច្រើនជាងក្នុងការនិយាយ និងធ្វើតាមចិត្តខ្លួនច្រើនជាងស្ត្រីក្មេង) ទំនាក់ទំនងយេនឌ័រកំពុងមានការប្រែប្រួលដូច

---

[៨៣] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៦២

[៨៤] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៦៦

គ្នានឹងសង្គមកម្ពុជាដែរ។ ផ្នែកមួយចំនួននៃទំនាក់ទំនងយេនឌ័រ ជាប្រពៃណីកំពុងប្រែប្រួលល្អជាងមុន(ទោះបីជានៅទាមទារអោយមានការយកចិត្តទុកដាក់ថែមទៀតក៏ដោយ)។ គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងអក្ខរកម្មកំពុងថយចុះ ហើយការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយ ចាប់ផ្តើមកើតមានឡើង ហើយទោះបីជាមានកម្រិតតិចតួចក៏ដោយ។ ក៏ប៉ុន្តែជ្រុងខ្លះនៃការប្រែប្រួលសេដ្ឋកិច្ច និងសង្គមកាន់តែធ្វើអោយស្ត្រីអន់ថយថែមទៀត។ ដោយសារមានបុរសច្រើនជាងស្ត្រីបានស្លាប់នៅក្នុងសង្គ្រាមនៃទសវត្សរ៍១៩៧០(និងនៅទសវត្ស ១៩៨០ ផងដែរ) កម្ពុជាមានសមាមាត្រាភេទខុសគ្នាច្រើនក្នុងចំណោមមនុស្សវ័យចំណាស់។ បុរសដែលអាចរៀបការបានមានចំនួនតិចតួចជាងស្ត្រីអាចមានអាកប្បកិរិយាមិនគប្បីជាមួយស្ត្រី ហើយរួចខ្លួនដែលគេមិនអាចអត់ឱនអោយបានកាលពីមុនមក។ ទោះបីសមាមាត្រាភេទសំដៅរកតុល្យភាពក៏ដោយ ក៏នៅមានឥរិយាបថ ដែលបន្សល់ទុកពីមុនមកដែលទំនងជាកត្តាមួយបង្កអោយមានហិង្សាក្នុងគ្រួសារ ដែលមាននៅកម្រិតខ្ពស់ខ្លាំងដដែល។ សង្គ្រាមបានបន្សល់ទុកដោយផ្ទាល់ និងដោយប្រយោលនូវគ្រួសារ ដែលមានស្ត្រីជាអ្នកដឹកនាំ(ដោយសារបុរស ដែលរស់នៅអាចបោះបង់ចោលស្ត្រីម្នាក់ ហើយនៅរៀបការបានដដែល)។ ទោះបីជាការវិភាគទិន្នន័យចំណាយមិនបង្ហាញអោយឃើញថា គ្រួសារដឹកនាំដោយស្ត្រីក្រជាងគ្រួសារដឹកនាំដោយបុរសក៏ដោយ ការសិក្សាតាមមូលដ្ឋានមួយចំនួនបង្ហាញអោយឃើញថា គ្រួសារដែលមានស្ត្រីជាអ្នកអ្នកដឹកនាំ ពិតជាមានកង្វះខាតសមត្ថភាព ផ្នែកសេដ្ឋកិច្ចមួយចំនួន។

ប្រព័ន្ធសុខាភិបាលសាធារណៈ មិនបម្រើអោយស្ត្រីបានល្អ ដែលបណ្តាលអោយមានអត្រាមរណៈមាតាខ្ពស់គួរអោយបារម្ភ(៤៣៧នាក់ ក្នុងចំណោម ១០០.០០០នាក់)។ទំនាក់ទំនង និងតម្លៃយេនឌ័រក៏ជាចំណុចស្នូលផងដែរនៅក្នុងបញ្ហាប្រឈមដ៏ចម្បងបំផុត គឺវីរុសហ៊ីវ និងជំងឺអេដស៍។ ការអនុគ្រោះជាប្រពៃណីចំពោះពេស្យា កម្មបានបង្កជាបញ្ហាប្រឈមដ៏ធំដែលរដ្ឋាភិបាលឆ្លើយតបបានល្អ ប៉ុន្តែនៅខណៈពេលដែលអត្រាឆ្លងបានធ្លាក់ចុះដោយសារការជំរុញអោយប្រើប្រាស់ស្រោមអនាម័យនៅក្នុងសេវាបម្រើផ្លូវភេទ និងការរួមភេទធម្មតានៅមានការលំបាកក្នុងការជំរុញអោយគូស្រករប្រើប្រាស់ស្រោមអនាម័យ ហើយការណ៍នេះធ្វើអោយការឆ្លងពីប្តីទៅប្រពន្ធ និងពីម្តាយទៅកូនមានការកើនឡើង។ ទោះបីជាការអង្កេតរកឃើញថា ការសម្រេចចិត្តក្នុងការធ្វើផែនការគ្រួសារច្រើនតែបានធ្វើឡើងរួមគ្នាក៏ដោយ ក៏ការស្រាវជ្រាវតាមការចូលរួមបង្ហាញអោយឃើញថា ស្ត្រីមានអំណាចតិចតួច ដើម្បីចរចារអោយមានការរួមភេទប្រកបដោយសុវត្ថិភាព និងការប្រើប្រាស់ស្រោមអនាម័យនៅក្នុងការរស់នៅជាប្តីប្រពន្ធ។

ជាចុងបញ្ចប់ស្ត្រីភាគច្រើនក្នុងវិស័យការងារ ដែលមានកម្រៃទាប ហើយទទួលបានប្រាក់តិចជាងបុរសសម្រាប់ការងារដូចគ្នា។ ការរីកចម្រើនឆាប់រហ័សនៅក្នុងវិស័យកាត់ដេរ បានផ្តល់ជាប្រយោជន៍ជាច្រើនដល់ចំនួនប្រហែល២០០.០០០នាក់ (ដែលមានចំនួនលើសពី ៩០% នៅក្នុងកម្លាំងពលកម្មនៅក្នុងវិស័យនេះ) ក៏ប៉ុន្តែនេះ គឺជាមួយភាគរយប៉ុណ្ណោះនៃកម្លាំងពលកម្មសរុបក្នុងប្រទេស។ កម្មករកាត់ដេរ ស្ត្រីក៏មានការពឹងពាក់

ខ្លាំងពីគ្រួសាររបស់គេ ដែលបណ្តាលអោយគេផ្ញើប្រាក់មួយភាគធំទៅអោយក្រុមគ្រួសារ ដែលនាំអោយគេជួបប្រទះនូវកង្វះខាតក្នុងការបរិភោគផ្ទាល់ខ្លួន។

គ-ជនជាតិភាគតិច និងភាពក្រីក្រ:[៨៥] ប្រទេសកម្ពុជាផ្តុំឡើងដោយជនជាតិនានាក្នុងកម្រិតស្មើសាច់គួរសម បើប្រៀបធៀបទៅនឹងរដ្ឋផ្សេងទៀតនៅក្នុងតំបន់អាស៊ីប៉ែកអាគ្នេយ៍: ក្រុមភាគច្រើន គឺជនជាតិខ្មែរ ដែលមានប្រមាណ ៩៦% នៃប្រជាជន។ ៤% នៅសល់ទៀត គឺជាក្រុមជនជាតិចម្រុះដែលមានលក្ខណៈកំណត់ ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចខុសគ្នាឆ្ងាយណាស់ចំពោះទំនាក់ទំនងរបស់ពួកគេជាមួយជនជាតិខ្មែរភាគច្រើន និងចំពោះការអភិវឌ្ឍន៍នៃការបញ្ជ្រាប។ ទំហំតូចនៃប្រជាជនជាតិភាគតិច បើប្រៀបធៀបនឹងក្រុមភាគច្រើនបានធ្វើអោយមានការពិបាកខ្លាំងណាស់ ចំពោះការវិភាគដែលផ្អែកលើការអង្កេត សង្គម-សេដ្ឋកិច្ច នៅកម្ពុជា(CSES) ពីព្រោះគ្រួសារក្រៅពីខ្មែរក្នុងគំរូមានចំនួនតិច ហើយជាពិសេសអត្រាភាពក្រីក្រសម្រាប់ក្រុមតូចៗ ដែលដកស្រង់ចេញពីការអង្កេត(CSES) មានលក្ខណៈមិនមាំទាំតាមការគណនាតាមស្ថិតិ។

ជនជាតិចាម(ឬខ្មែរឥស្លាម) មានចំនួន ២,២% នៃប្រជាជន ហើយរស់នៅជាទូទៅក្នុងភូមិដោយឡែក(ដោយប្រមូលផ្តុំរស់នៅក្នុងខេត្តកំពង់ចាម និងខេត្តជិតខាងផ្សេងទៀត) ឬជិតទីក្រុង។ ពួកគាត់បានបង្ហាញពីការស្លៀកពាក់ និងជំនាញមុខរបរខុសប្លែកខ្លះ ប៉ុន្តែក្រៅពីនេះពួកគាត់រស់នៅតាមរបៀបមួយដូចគ្នាច្រើននឹងខ្មែរភាគច្រើនដែរ។ ដោយពង្រឹងការចាប់អារម្មណ៍នេះការអង្កេតឆ្នាំ២០០៤(CSES 2004) បានបង្ហាញថា ចំពោះការប្រើប្រាស់របស់គ្រួសារក្នុងមនុស្សម្នាក់ៗពួកគាត់បានធ្លាក់ចុះយ៉ាងខ្លាំង(៧៦%) ទៅក្នុងមធ្យមភាគកណ្តាល។

ជាទូទៅជនជាតិចិន(0,២% នៃគំរូការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច មានទ្រព្យសម្បត្តិច្រើនជាងកម្រិតមធ្យមភាគថ្នាក់ជាតិ។ ចំណែកឯជនជាតិវៀតណាម(0,៤%) ក៏មានទ្រព្យសម្បត្តិច្រើនជាងមធ្យមភាគដែរ ប៉ុន្តែក៏មានជនជាតិវៀតណាមក្រុមតូចៗរស់នៅក្នុងស្ថានភាពក្រីក្រដែរ(ក្នុងសមាគមនេសាទនៅទន្លេសាប)។

ជនក្រីក្រជាងគេបំផុត និងជាក្រុមជនជាតិមានចំនួនតិចជាងគេបំផុតនៅប្រទេសកម្ពុជា គឺជាអ្នកភ្នំ(ខ្មែរលើ ជនជាតិ ឬ "ក្រុមកុលសម្ព័ន្ធ") ដែលរស់នៅជាពិសេសក្នុងតំបន់ខ្ពស់ពោរពេញដោយព្រៃឈើក្នុងខេត្តឦសាននៃប្រទេស: រតនគីរី មណ្ឌលគីរី ក្រចេះ និងស្ទឹងត្រែង។ ក្រុមចំនួន ១៧ សំខាន់ដែលក្រុមនីមួយៗមានចំនួនសមាជិកពីរាប់រយនាក់ទៅដល់ ១៩.០០០នាក់ រួមគ្នាទៅមានប្រហែល ១០៤.០០០នាក់ ឬតិចជាង 0,១% នៃប្រជាជនទូទាំងប្រទេស។

តាមកម្រិតខុសៗគ្នាក្រុមទាំងនេះ បញ្ហាប្រឈមជាពិសេស គឺ ក-បញ្ហាភាសា (ដែលរារាំងពួកគាត់មិនអោយទាញយកផលប្រយោជន៍បានក្នុងទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និងរដ្ឋបាល) ជាមួយអ្នកនិយាយភាសាខ្មែរ ខ-ភាពដាច់ស្រយាលជ្រុល(ព្រមទាំងជាថ្មីម្តងទៀត របាំងភាសា និងអតុល្យភាពអំណាច) ដែលធ្វើអោយពួកគាត់លំបាកនឹងទទួលបានសេវាដូចជា ការសិក្សា ឬការព្យាបាលជំងឺ និង គ-ការពឹងផ្អែកយ៉ាងខ្លាំងលើព្រៃឈើ

[៨៥] ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ឆ្នាំ២០០២ វេទិការអង្គការក្រៅរដ្ឋាភិបាល(NGO Forum) ឆ្នាំ២០០៥ ក្រុមសិទ្ធិជនជាតិភាគតិច(Minoritires Rights Group) ឆ្នាំ១៩៩៥

សម្រាប់ផលិតផលឈើ និងផលិតផលក្រៅពីឈើ ព្រមទាំងជាការផ្តត់ផ្តង់ដីសម្រាប់ប្តូរវេន ការធ្វើកសិកម្មគោចរ។ ដោយផលប្រយោជន៍ពាណិជ្ជកម្ម និងផលប្រយោជន៍របស់រដ្ឋ ព្រមទាំងជនជាតិខ្មែរ ដែលមកពីទីកន្លែងផ្សេងនៃប្រទេសកម្ពុជាមកតាំងលំនៅថ្មី កំពុងទាក់ទាញពួកគេយ៉ាងខ្លាំងអោយមកធ្វើអាជីវកម្មលើសក្តានុពលសេដ្ឋកិច្ចរបស់ព្រៃឈើតំបន់ខ្ពស់ នោះជនជាតិភាគិតភ្នំកំពុងទទួលរងហានិភ័យនៃការបាត់បង់លទ្ធភាពទទួលបានព្រៃ-ឈើ និងដី។ កម្រិតអក្ខរកម្មភាសាខ្មែរទាបព្រមទាំងកង្វះខាតតំណាងនៅថ្នាក់មូលដ្ឋាន និងថ្នាក់រដ្ឋបាលជាតិ មានន័យថា គឺជាការលំបាកសម្រាប់ពួកគាត់ក្នុងការអោចយល់ដឹងពីសិទ្ធិ ដែលពួកគាត់ត្រូវមានពីព្រោះ បរិស្ថានផ្លូវច្បាប់មិនទាន់មានលក្ខណៈពេញលេញ ច្បាប់ស្តីពីដីធ្លីឆ្នាំ២០០១ មានចែងពីបទបញ្ញត្តិសម្រាប់អោយសហគមន៍ភាគតិចជនជាតិដើមទាមទារកម្មសិទ្ធិកាន់កាប់ដី ជាកម្មសិទ្ធិឯកត្តជន ឬកម្មសិទ្ធិសហគមន៍ ប៉ុន្តែអនុក្រិត្យ ដែលត្រូវកំណត់លក្ខខ័ណ្ឌផ្លូវច្បាប់សម្រាប់ការទទួលស្គាល់កម្មសិទ្ធិសហគមន៍មិនទាន់ត្រូវបានព្រាងនៅឡើយ។

អាស្រ័យហេតុនេះ ក្រុមទាំងនេះមានទំនោរស្ថិតក្នុងស្ថានភាពគ្មានអំណាច និងមានទីតាំងខ្សត់ខ្សោយក្នុងការចូលរួមការពិភាក្សា និងការចរចារស្តីពីការសកម្មភាពអភិវឌ្ឍន៍ ដែលប៉ះពាល់ជីវភាពរបស់ពួកគាត់។ តាមការអង្កេតតូចៗលើក្រុមទាំងនេះរកឃើញពី ក-កម្រិតខ្ពស់នៃភាពក្រីក្រ ខ-កម្រិតទាបបំផុតនៃការផ្តល់ និងការទទួលយកសេវាសុខាភិបាលទន់ខ្សោយជ្រុលព្រមទាំង គ-ស្ថានភាពអប់រំទាបក្នុងផ្នែកអនក្ខរកម្ម ការឆ្លងជំងឺ និងជំងឺរាគគ្មាន ការថែរក្សាគត៌ និងការខ្វះខាតអាហារូបត្តម្ភសម្រាប់កុមារ។ ក្រុមតូចៗនៃភាពក្រីក្រជ្រៅទាំងនេះដង្ហើយហៅអោយមានការិនិយោគ បែបប្រពលវប្បកម្មលើកម្មវិធី ដែលត្រូវបានរៀបចំដោយប្រុងប្រយ័ត្ន សម្រាប់ការផ្តល់ក្រុម(ជោគជ័យត្រូវបានសម្រេចក្នុងការអប់រំបឋមសិក្សាពីរភាសា) និងការផ្តល់អំណោយដល់មូលដ្ឋាន។ សម្រាប់ក្រុមទាំងនេះដែលហាក់ដូចជានៅមិនបានទទួលផលចំណេញ ពីការបញ្ជ្រាបកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ អង្គការក្រៅរដ្ឋកិបាល និងទីភ្នាក់ងារអង្គការសហប្រជាជាតិបាន ដើរតួនាទីយ៉ាងសំខាន់ ហើយហាក់ដូចជា នឹងបន្តធ្វើដូច្នោះ ទៀតនាពេលអនាគតដ៏សមស្រប[៨៦]។

ឃ-គ្រួសារដែលមានមេគ្រួសារជាកសិករ និងជាអ្នកបម្រើតាមផ្ទះមានទំនងជាក្រីក្រជាងគេច្រើន

អត្រាភាពក្រីក្រមានកម្រិតខ្ពស់បំផុតក្នុងចំណោមកសិករ និងអ្នកបម្រើតាមផ្ទះ។ គ្រួសារដែលមានមេគ្រួសារជាកសិករបង្កបង្កើនផលដោយផ្ទាល់ខ្លួនឯង និងជាអ្នកបម្រើតាមផ្ទះមានចំនួនលំដាប់បន្តបន្ទាប់ ៤៥% និង ១៣% នៃប្រជាជនទាំងអស់។ គ្រួសារដឹកនាំដោយអ្នកបម្រើតាមផ្ទះក៏មានអត្រាភាពក្រីក្រខ្ពស់ជាងគេបំផុតដែរ ក្នុងទិដ្ឋភាពក្រីក្រនៅឆ្នាំ១៩៩៤ ហើយមានចំនួនកើនឡើងក្នុងចំណោមប្រជាជនទាំងអស់(៩% នៅឆ្នាំ ២០០៤)។ អត្រាភាពក្រីក្រប៉ាន់ស្មានទាបជាងគេបំផុត គឺជារបស់គ្រួសារដែលមានមេគ្រួសារជាមន្ត្រីក្នុងវិស័យ

[៨៦] ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ឆ្នាំ២០០២ វេទិការអង្គការក្រៅរដ្ឋាភិបាល(NGO Forum) ឆ្នាំ២០០៥ ក្រុមសិទ្ធិជនជាតិភាគតិច(Minoritires Rights Group) ឆ្នាំ១៩៩៥

សាធារណៈ។ ទម្រង់ទាំងនេះមានតួលេខដូចគ្នាយ៉ាងទូលំទូលាយជាមួយនឹងរបកគំហើញនៃទិដ្ឋភាព ភាពក្រីក្រលើកមុន[៨៧]។

ង-អត្រាភាពក្រីក្រមានកម្រិតខ្ពស់បំផុតនៅតំបន់ជាប់ស្រយាល

លទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច(ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ) និងហេដ្ឋារចនាសម្ព័ន្ធសង្គមកិច្ច(សេវាមូលដ្ឋានរួមមាន ប្រភពថាមពលទំនើប ទឹកស្អាត និងអនាម័យព្រមទាំងសាលារៀន និងសម្ភារៈមូលដ្ឋានសម្រាប់ការព្យាបាលជំងឺ) នៅមានកម្រិតទាបឆ្ងាយសម្រាប់ជនក្រីក្រជាងសម្រាប់ជនមិនមែនក្រីក្រ។ ជនក្រីក្រ និងជាពិសេសជនក្រីក្រខ្លាំង(បញ្ចភាគបាតក្រោម ដែលស្ថិតក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ) មានទំនងជារស់នៅក្នុងតំបន់ជាប់ស្រយាល និងភាពឯកកោជ្រុលដែលនៅទីនោះលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធ ឬសេវាមូលដ្ឋាននៅមានកម្រិត។ គម្លាតជាមធ្យមរបស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមូលដ្ឋានកើនឡើងជាលំដាប់ នៅពេលដែលគេចេញពីក្រុមបញ្ចភាគ ដែលមានការប្រើប្រាស់ខ្ពស់ជាងទៅកាន់ក្រុមទាបជាងមួយទៀត។ ជាពិសេសជនក្រីក្រស្បៀងអាហារស្ថិតនៅឯកកោពីលទ្ធភាពទទួលបានទីផ្សារ និងសម្ភារៈមូលដ្ឋានសម្រាប់ការព្យាបាលជំងឺជាអចិន្ត្រៃយ៍។ នៅពេលទិន្នន័យត្រូវបានបែងចែកតាមខេត្តនោះ ខេត្តប៉ៃលិនក្នុងតំបន់ភ្នំ/ខ្ពង់រាប (ពោល គឺរតនគីរី ស្ទឹងត្រែង ព្រះវិហារ) និងខេត្តសៀមរាប ឯនៅក្នុងតំបន់ទន្លេសាបមានហេដ្ឋារចនាសម្ព័ន្ធខ្សត់ខ្សោយជាងគេ ដែលត្រូវបានវាស់ដោយភាគរយនៃភូមិដែលមានផ្លូវថ្នល់គ្រប់រដូវ ឬភូមិ ដែលមានប្រែងឥន្ធនៈជាប្រភពថាមពល[៨៨]។

ម្យ៉ាងទៀត ជនក្រីក្រទាំងឡាយ ស្ទើរតែមិនបានទទួលនូវប្រភពថាមពលទំនើបព្រមទាំងទឹកស្អាត និងអនាម័យតាមការអង្កេតឃើញថា ជនក្រីក្រពឹងផ្អែកយ៉ាងខ្លាំងលើការអុសដុត សម្រាប់ជំនួយប្រែងឥន្ធនៈ និងប្រែងកាតសម្រាប់ការបំភ្លឺពេលយប់ ចំណែកឯកជនមិនមែនក្រីក្រទទួលបានប្រណិតភាពដោយមានការភ្ជាប់ប្រព័ន្ធឧស្ម័ន និងអគ្គីសនីសម្រាប់ប្រើប្រាស់។ នៅពេលមានគម្លាតស្តីពីប្រភពអគ្គីសនីគួរអោយកត់សម្គាល់រវាងជនក្រីក្រនោះ ការផ្តាច់លទ្ធភាពទទួលបានទឹកស្អាត និងអនាម័យមានសភាពស្រួចស្រាវជាពិសេសក្នុងចំណោមជនក្រីក្រ។ មានតែ ២% នៃគ្រួសារក្រីក្រប៉ុណ្ណោះ មានលទ្ធភាពទទួលបានប្រព័ន្ធទឹកស្អាត ឬទឹកសាធារណៈ ហើយមានតែ ៣,៥% នៃជនក្រីក្របំផុតប៉ុណ្ណោះមានលទ្ធភាពទទួលបានអនាម័យ។ ជាមួយគ្នានេះដែរ ជនក្រីក្របំផុតមួយចំនួនធំនៅតំបន់ជនបទគ្មានលទ្ធភាពទទួលបានដីសម្រាប់បង្កបង្កើនផល ដោយសារប្រទេសកម្ពុជានៅតែមានសេដ្ឋកិច្ចកសិកម្មជាលក្ខណៈគ្រួសារ ដែលមាន៧១% នៃកម្លាំងពលកម្មក្នុងផ្នែកកសិកម្ម និង ៩១% នៃជនក្រីក្រស់នៅតំបនជនបទ នោះទ្រព្យធនសំខាន់បំផុតសម្រាប់ជនក្រីក្រនៅជនបទ គឺពលកម្ម និងដី។

---

[៨៧] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៦៩

[៨៨] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៧០

ដោយសារមូលធនមនុស្សមានកម្រិត និងកង្វះជំនាញ ដែលជាហេតុធ្វើអោយជនក្រីក្រ និងជនក្រីក្រខ្លាំងមានលទ្ធភាពតិចតួចធ្វើអោយកម្លាំងពលកម្មរបស់ពួកគាត់មានប្រយោជន៍ចំពោះកាលនុវត្តភាពការងារ ក្រៅពីការបង្កបង្កើនផលកសិកម្ម។ ហេតុនេះដីក្លាយជាទ្រព្យធនសំខាន់បំផុតសម្រាប់ជនក្រីក្រនៅជនបទ។

ភាពគ្មានដីធ្លី ដែលសំដៅលើភាគរយនៃគ្រួសារនៅជនបទ គ្មានដីធ្វើកសិកម្មបានកើនឡើងពី ១២,៦% ក្នុងការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច ឆ្នាំ១៩៩៧(CSES 1997) មកដល់ ១៥,៨% ក្នុងការអង្កេតឆ្នាំ១៩៩៩ (CSES 1999) និងដល់ ១៩,៨% ក្នុងការអង្កេតឆ្នាំ (CSES 2004)។ គ្រួសារទាំងនេះគ្មានដីមិនបាន ខ្វីដី ឬ មិនបានជួលដី និងមិនអាចប្រើដីសហគមន៍ទេ។ នៅឆ្នាំ២០០៤ ប្រមាណ ១៥% នៃជនក្រីក្រខ្លាំង និង១៣% នៃក្រុមក្រីក្របន្ទាប់គ្មានដីនៅតំបន់ជនបទទេឡើយ។

ក្នុងចំណោមអ្នកដែលមានដីសម្រាប់បង្កបង្កើនផលក្រុមក្រីក្រខ្លាំង និងក្រុមអ្នកក្រីក្រហាក់ដូចជា អាចទទួលបានកម្មសិទ្ធិកាន់កាប់ដីតិចតួចជាងក្រុមមិនមែនក្រីក្រ។ ការទទួលបានកម្មសិទ្ធិកាន់កាប់ដីហាក់ដូចជាកើនឡើងតាមប្រាក់ចំណូល។ ប្រព័ន្ធសិទ្ធិកាន់កាប់ដីប្រកបដោយការធានា និងការគ្រប់គ្រងដីប្រកបដោយប្រសិទ្ធភាពមានសារៈសំខាន់បំផុតរបស់កំណើតកសិកម្ម និងសម្រាប់សម្រួលការចាកចេញពីវិស័យនេះ។ ផលប្រយោជន៍នៃសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ និងច្រងក្រងជាឯកសារច្បាស់លាស់នៅក្នុងការស្រាវជ្រាវអន្តរជាតិ។

ច-ជនក្រីក្រនៅទីក្រុងចេះតែកើនឡើងមែន ឬទេ?

ស្ថិតិភាពក្រីក្រគណនាចេញពីការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច(CSES) អាចតំណាងអោយជនក្រីក្រនៅទីក្រុងមិនសព្វពេញលេញដោយហេតុផលប្លែកៗ។ ទី១ ជនក្រីក្របំផុតនៅទីក្រុងជាច្រើន(ជាពិសេសនៅភ្នំពេញ) ដេកតាមផ្លូវ និងអាចត្រូវបានមើលរំលងដោយក្របខ័ណ្ឌការធ្វើគំរូការអង្កេត(CSES) ដែលផ្អែកលើតែលំនៅឋាន/និវេសនដ្ឋាន។ ស្ទើរតែទាំងអស់នៃស្រទាប់សង្គមបន្ទាប់មក(ក្រីក្រ ប៉ុន្តែមិនមែនទ័លក្រ) រស់នៅក្នុងតំបន់សំណង់អនាធិបតេយ្យ។ នៅពេលការតាំងលំនៅក្រៅផ្លូវការកើតមានឡើងនៅឆ្នាំ១៩៩៨ ត្រូវបានបញ្ចូលទៅក្នុងជំនឿន(ដែលបានផ្តល់ក្របខ័ណ្ឌការធ្វើគំរូសម្រាប់ការអង្កេតឆ្នាំ២០០៤) ការតាំងទីលំនៅទាំងនេះបានកើនឡើងយ៉ាងហ៊ាសពីពេលនោះមក ដោយសារអន្តោប្រវេសន៍ពីតំបន់ជនបទទាំងឡាយ។ អង្គការក្រៅរដ្ឋាភិបាលនានាប៉ាន់ស្មានថា ចំនួនគ្រួសារក្រីក្រក្នុងតំបន់សំណង់អនាធិបតេយ្យ បានកើនឡើងពីរដងនៅចន្លោះឆ្នាំ ១៩៩៧ និងឆ្នាំ២០០៣។ ហេតុនេះ ទើបមានគ្រួសារក្នុងតំបន់សំណង់អនាធិបតេយ្យមួយចំនួន មិនត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌការធ្វើគំរូការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច។

ទោះបីប្រជាជនក្នុងតំបន់សំណង់អនាធិបតេយ្យមិនក្រីក្រទាំងអស់ ក៏ភាគច្រើនជាជនក្រីក្រ។ ដូច្នេះ ជាការពិតដែលប្រទេសកម្ពុជាមានភាពក្រីក្រ ហើយនឹងនៅតែក្រីក្រក្នុងរយៈពេលច្រើនឆ្នាំទៅខាងមុខទៀត យ៉ាងលើសលប់នៅតំបន់ជនបទ ចំណែកឯភាពក្រីក្រនៅភ្នំពេញ និងទីក្រុងផ្សេងទៀតប្រាកដជាមានកម្រិតខ្ពស់ជាងព័ត៌មានក្នុងការអង្កេតសង្គកិច្ច-សេដ្ឋកិច្ច(CSES)។ ភាពក្រីក្រនៅទីក្រុងហាក់ដូចជា កាន់តែកើនឡើងតាម

ពេលវេលាពីព្រោះ ជនក្រីក្រចេះតែចូលមកទីក្រុងនានា ដើម្បីស្វែងរកជីវភាពប្រសើរ។ ក្នុងទសវត្សចុងក្រោយនេះ ការប្តូរទីលំនៅពីជនបទមកទីក្រុងហាក់ដូចជា នឹងកើនឡើងជាពិសេស ពីព្រោះទម្រង់នៃកំណើនសេដ្ឋកិច្ចនៅតែមិនស្មើភាពគ្នាយ៉ាងខ្លាំង ដោយផ្តៀងមករកឧស្សាហកម្ម និងសេវានៅទីក្រុង ហើយទុកអោយកសិកម្ម និងសេដ្ឋកិច្ចជនបទអោយយឺតយ៉ាវខាងក្រោយ។ ដោយសារភាពគ្មានដីបង្កបង្កើនផលកើនឡើង ហើយលទ្ធភាពទទួលបានធនធានទ្រព្យសម្បត្តិរួម ឬផលិតភាពធនធានទ្រព្យសម្បត្តិថយចុះ ទេសន្តរប្រវេសន៍ពីជនបទមកទីក្រុងអាចត្រូវបានរំពឹងថាកើនឡើង។ ដោយបញ្ហាអ្នកក្រីក្រនៅទីក្រុងមានការខុសគ្នាពីអ្នកក្រីក្រនៅជនបទ ហើយភាពក្រីក្រនៅទីក្រុងត្រូវដោះស្រាយតាមបរិបទការធ្វើផែនការទីក្រុងសាំញ៉ាំ (ទាំងសេដ្ឋកិច្ច និងទីផ្សារ) រដ្ឋាភិបាលត្រូវតែមានគោលនយោបាយ និងកម្មវិធីសង្គ្រោះជាក់លាក់សម្រាប់អ្នកក្រជនបទ ដែលខុសពីគោលនយោបាយសម្រាប់អ្នកក្រីក្រនៅទីក្រុង។

ការអង្កេតលើភាពក្រីក្រនៅទីក្រុងមួយចំនួន ជាពិសេសទីក្រុងភ្នំពេញត្រូវបានធ្វើឡើងដោយអង្គការសហប្រជាជាតិសម្រាប់លំនៅឋាន(UN-Habitat) និងអង្គការក្រៅរដ្ឋាភិបាល។ ការអង្កេតធ្វើដោយមជ្ឈមណ្ឌលធនធានទីក្រុង(URC) បង្ហាញថា ដូចបានរំពឹងគិតទុកមុនអញ្ចឹង អ្នកដែលរស់នៅក្នុងតំបន់សំណង់អនាធិបតេយ្យស្ទើរតែទាំងអស់ប្រកបការងារក្រៅផ្លូវការជាអ្នករត់ម៉ូតូឌុប កម្មករសំណង់ អ្នកបម្រើតាមផ្ទះ ឬអ្នកលក់ដូរតូចតាចតាមផ្លូវចំណែកមួយភាគតូចទៀត ធ្វើការជាអចិន្ត្រៃយ៍ (ឬយ៉ាងហោចណាស់មិនម្តងម្កាលទាំងស្រុងពេក) ជាកម្មករនិយោជិកក្នុងឧស្សាហកម្មកាត់ដេរ (ជាពិសេសនារី) ឬក្នុងភោជនីយដ្ឋាន ឬជាអ្នកសំអាតផ្ទះ (ប្រភេទដែលរកឃើញក្នុងការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច ឆ្នាំ២០០៤(CSES 2004) ដែលមានអត្រាភាពក្រីក្រខ្ពស់បំផុត ៤៩% ហើយមានចំនួនតិចតែមានការកើនឡើងជាលំដាប់ក្នុងចំណោមប្រជាជនក្រីក្រ និងជនក្រីក្រ។

ដូចនៅជនបទដែរ ការអង្កេតនានានៅតំបន់ទីក្រុងរកឃើញថា កុមារបានធ្វើវិភាគទានយ៉ាងធំក្នុងការរកប្រាក់ចំណូលជួយដល់គ្រួសារក្រីក្រដោយរកបានប្រហែល ៤.០០០រៀល ក្នុងមួយថ្ងៃ ដោយធ្វើការងារជាអ្នករើសសំរាម អ្នកខាតស្បែកជើង អ្នកសុំទាន ឬក៏នៅផ្ទះមើលបងប្អូនតូចៗនៅពេលឪពុកម្តាយចេញទៅធ្វើការខាងក្រៅ។ បញ្ហារបស់ជនក្រីក្រនៅទីក្រុងខុសប្លែកពីបញ្ហារបស់ជនក្រីក្រនៅជនបទ។ ជាទូទៅប្រជាជនប្រកបដោយសុខភាពល្អនៅជនបទអាចរកសម្ភារៈសំណង ឬទឹកបានយ៉ាងស្រួល ប៉ុន្តែនៅទីក្រុងគេត្រូវតែទិញវត្ថុទាំងអស់នេះ ហើយនៅពេលតំបន់គ្រួសារមានទ្រព្យសម្បត្តិអាចតភ្ជាប់ទទួលសេវាពីក្រុងបាន តំបន់ក្រីក្រជាទូទៅគ្មានលទ្ធភាពដូចនេះទេ ហើយត្រូវទិញទឹកពីអ្នកលក់ឯកជនក្នុងតម្លៃខ្ពស់ជាងច្រើន។ ជាទូទៅ ប្រាក់ចំណូលនៅទីកក្រុងបានខ្ពស់ជាងនៅតំបន់ជនបទ ប៉ុន្តែតម្លៃទំនិញក៏ថ្លៃដែរ។ ជនក្រីក្រនៅទីក្រុងជាច្រើនពឹងផ្អែកលើពលកម្មមិនទៀងទាត់ សម្រាប់រកប្រាក់ចំណូល ដែលជាហេតុនាំអោយពិបាកសន្សំ។ បើបញ្ហាប្រឈមសម្រាប់ជនក្រីក្រនៅទីក្រុង គឺការតស៊ូរកប្រាក់ចំណូលអោយបានគ្រប់គ្រាន់នោះ ការគំរាមកំហែសំខាន់ជាងអ្វីទាំងអស់ចំពោះជីវភាពរស់នៅ និងសុខមាលភាពរបស់ពួកគាត់ គឺការធានានៃការទទួលបាននូវសិទ្ធិរស់នៅក្នុងផ្ទះ។ នៅពេលច្បាប់ដីធ្លីផ្តល់សិទ្ធិមួយចំនួនដល់អ្នកកំពុងរស់នៅ សិទ្ធិទាំងនោះមានតិចតួចសម្រាប់ អ្នកដែលបានតាំងទីលំនៅលើអ្វី

ដែលត្រូវបានកំណត់ថា ជាដីសាធារណៈរបស់រដ្ឋ(ផ្ទុយពីដីឯកជនរបស់រដ្ឋ) ហើយសូម្បីតែអ្នកមានសិទ្ធិកាន់កាប់មិនទាន់ពេញលេញក៏ងាយទទួលរងគ្រោះនឹងការខិតខំព្យាយាមផ្លាស់ប្តូរ ទីលំនៅរបស់ពួកគាត់ដែរ ក្នុងបរិបទនៃការឡើងថ្លៃដីយ៉ាងឆាប់រហ័សបែបនេះ។ ជនក្រីក្រច្រើនមានអារម្មណ៍ថា ជីវិតរបស់ពួកគាត់មានភាពប្រសើរឡើង តាំងពីបានចាកចេញពីជនបទមកនៅទីក្រុង គឺជាការផ្លាស់ប្តូរដែលនាំពួកគាត់អោយទទួលបានកាលានុវត្តភាពការងារប្រសើរជាងមុន ប្រាក់ចំណូលច្រើនជាងមុន ព្រមទាំងសេវាសុខភាព និងការអប់រំប្រសើរជាងមុន។ ដូច្នេះហើយ ទើបពួកគេមិនសូវចាប់អារម្មណ៍ចំពោះការផ្តល់ដីនៅក្រៅទីក្រុងឡើយ។ ជនក្រីក្រជាច្រើននៅក្នុងតំបន់សំណាងអនាធិបតេយ្យរាយការណ៍ថា ពួកគាត់មានលទ្ធភាពកែលម្អផ្ទះសម្បែងនៅពេលទើបមកដល់ភ្លាម។ ប៉ុន្តែការបណ្តេញដោយបង្ខំ(សាលាក្រុងបានបណ្តេញ ១១.០០០គ្រួសារពីកណ្តាលទីក្រុងនៅចន្លោះឆ្នាំ១៩៩៨ និង ២០០៣) អាចទាញពួកគាត់អោយចុះមកដល់កម្រិតស្មើ ឬអាក្រក់ជាងពីអ្វីដែលពួកគាត់បានឆ្លងកាត់មុនពេលមកដល់ទីក្រុងទៅទៀត[៨៥]។

ការតាំងទីលំនៅដ៏កុហករលើដីតូច ក៏ងាយទទួលរងគ្រោះប៉ះពាល់យ៉ាងទូលំទូលាយដល់សហគមន៍ទាំងមូល ដោយសារមហន្តរាយដូចជា ទឹកជំនន់ ឬអគ្គីភ័យ ដែលអាចធ្វើអោយគ្រួសាររាប់ពាន់ក្លាយជាទីទ័លក្រក្នុងពេលតែមួយយប់។ ចំពោះឯកភាពសង្គម និងមូលដ្ឋានសហគមន៍សម្រាប់សកម្មភាពជាសមូហភាពជនក្រីក្រនៅទីក្រុងមានសមត្ថភាពគ្រាន់បើជាជាងជនក្រក្រីនៅទីជនបទសម្រាប់ចំណុចមួយចំនួន និងអន់ជាងជនក្រីក្រនៅជនបទសម្រាប់ចំណុចមួយចំនួនផ្សេងទៀត។ ម្យ៉ាងដោយមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល សហគមន៍ក្រីក្របានរៀបចំស្នើសុំការផ្តល់សេវា ឬប្រឆាំងនឹងការបណ្តេញចេញ។ ម្យ៉ាងទៀត ជនក្រីក្របំផុតក្នុងចំណោមជនក្រីក្រនៅក្នុងទីក្រុងគ្រួសារដែលរស់នៅពីការរើសអេតចាយនៅកន្លែងចាក់សំរាមរបស់ទីក្រុង កុមារ ឬជនពិការគ្មានគ្រួសារ ដែលរស់នៅតាមផ្លូវ អ្នករកស៊ីផ្លូវភេទ អាចទទួលរងការឈឺចាប់កម្រិតខ្ពស់បំផុត ដោយសារការផាត់ចេញពីសង្គម និងភាពងាយទទួលរងគ្រោះ។ ប៉ុន្តែសូម្បីតែក្នុងចំណោមក្រុមទាំងនេះមានភស្តុតាង មួយចំនួនបញ្ជាក់ពីការបង្កើតជាក្រុមជុំវិញកន្លែងធ្វើការ ឬបញ្ហាការផ្តល់សេវា។

ផ្នែកសំខាន់មួយក្នុងចំណោមផ្នែកសំខាន់ផ្សេងទៀត ដែលខ្វះខាតព័ត៌មាន គឺស្ថានភាពនៃការប្រែប្រួលសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងមជ្ឈមណ្ឌលបន្ទាប់បន្សំនានាក្នុងទីក្រុង។ ទោះបីការរៀបចំក្រុងរបស់ប្រទេសកម្ពុជាយកគំរូដូចទីក្រុងជំនាន់ចាស់ៗយ៉ាងច្រើន(មានទីក្រុងធំ ២-៣ក្រៅពីភ្នំពេញ ដែលមានប្រជាជន ៦ដង នៃប្រជាជនទីក្រុងធំជាងគេលំដាប់ទី២ នៅឆ្នាំ១៩៩៨) ក៏បទពិសោធន៍ក្នុងប្រទេសផ្សេងទៀតផ្តួចផ្តើមគំនិតថា ទីរួមខេត្តអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍តំបន់ជនបទរបស់ខ្លួនសម្រាប់ការបង្កើតឧស្សាហកម្ម ការកែច្នៃ និងបន្ថែមតម្លៃដល់ផលិតផលកសិកម្ម ព្រមទាំងអាចទាញយកពលកម្មជនបទ ដែលត្រូវបានកែលម្អលទ្ធភាពជីក្នុងមនុស្សម្នាក់ៗ និងធ្វើអោយមាននិរន្តរភាពប្រាក់កម្រៃកសិកម្ម និងតម្លៃផលិតផល។

[៨៥] ការិយាល័យរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស UNOHCHR ឆ្នាំ២០០៤ មជ្ឈមណ្ឌលធនធានទីក្រុង URC ឆ្នាំ២០០៤

គួអោយចាប់អារម្មណ៍នោះ គឺករណីសេដ្ឋកិច្ចដែលមានវិសមភាពតិច ស្តែងឡើងជាក់ច្បាស់ពីបទពិសោធន៍នៅប្រទេសជិតខាងរបស់កម្ពុជា។ កំណើនខ្ពស់នៅក្នុងខ្លាំងអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ាមានភាពពិសេសកន្លងមកក៏ដូចជាបច្ចុប្បន្ននៅត្រង់កម្រិតវិសមភាពទាប បើប្រៀបធៀបនឹងប្រទេសមានចំណូលមធ្យមនៅអាមេរិកឡាទីន(ដែលមានកំណើតមធ្យមទាបជាងអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា) ឬបើប្រៀបធៀបនឹងប្រទេសមានចំណូលទាបនៅអនុតំបន់សាហារ(ដែលប្រទេសមួយចំនួនធំមានកំណើនសេដ្ឋកិច្ចទាប ឬអវិជ្ជមានស្ទើរហូតមកក្នុងពីរទសវត្សកន្លមក)។ នៅក្នុងការព្យាយាមពន្យល់ថា តើអ្វីទៅធ្វើអោយប្រទេស កូរ៉េ តៃវ៉ាន់ ថៃ ឥណ្ឌូនេស៊ី ឬក្រោយមក ចិន ហើយ (គួរអោយកត់សម្គាល់ជាគេបំផុត) វៀតណាមរីកលូតលាស់ឆាប់រហ័សក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមក នេះអ្នកវិភាគមួយចំនួនបានលើកឡើងថា កត្តាមួយចំនួន គឺមកពីវិសមភាពមានកម្រិតទាបនៅក្នុងដំណាក់កាលដំបូង(ជាពិសេសក្នុងការកាន់កាប់ដី ព្រមទាំងកម្រិតអប់រំ និងអក្ខរកម្ម)។

ការនេះមិនមែននិយាយថា គេអាចសម្រេចបានសមភាពទាំងស្រុង ឬក៏ថាសមភាពគួរតែជាគោលដៅនៃគោលនយោបាយដ៏ចាំបាច់នោះទេ។ ប៉ុន្តែចំណុចសំខាន់នោះ គឺកម្រិតវិសមភាពគួរត្រូវបានចាត់ទុកយ៉ាងហ្មត់ចត់ថា ជាកត្តាផលប៉ះពាល់ជាវិជ្ជមានដល់កម្រិតនៃការកាត់បន្ថយភាពក្រីក្រផង និងដល់កំណើនសេដ្ឋកិច្ចផង។ យ៉ាងហោចណាស់អ្នកកាត់តែងគោលនយោបាយ ដែលចង់បានកំណើនសេដ្ឋកិច្ចចីរភាព និងស្ថេរភាពសង្គម និងនយោបាយគួរតែយកចិត្តទុកដាក់តាមដានវិសមភាព ដែលកើនឡើងឆាប់រហ័ស(ឬមិនកើនឡើងតែមានកម្រិតខ្ពស់)។ ការពិនិត្យមើលកស្តុតាងអន្តរជាតិអោយសព្វជ្រុងជ្រោយមួយបានអះអាងថា ការប្រើប្រាស់សកម្មភាពសាធារណៈដ៏ហ្មត់ចត់ ដើម្បីបញ្ចៀសកុំអោយវិសមភាពកើនឡើងកម្រិតខ្ពស់នោះ គឺជាគោលនយោបាយសេដ្ឋកិច្ចដ៏សមស្រប ហើយបន្ថែមថាផ្ទុយពីគតិបណ្ឌិតដែលគេឯកភាពក្នុងទសវត្សមុនៗ មានគោលនយោបាយមួយចំនួន ដែលគេអាចប្រើប្រាស់ដើម្បីជំរុញអោយមានសមភាព ដែលមិនខូចខាតដល់កំណើនសេដ្ឋកិច្ចទេ តែធ្វើអោយកាន់តែមានកំណើនខ្ពស់ និងស្ថេរភាពនយោបាយទៀតផង (Killick 2002)។ គោលនយោបាយទាំងនេះមិនរាប់បញ្ចូលនូវការបែងចែកឡើងវិញដាច់ខាតនូវទ្រព្យសម្បត្តិ ឬចំណូល ដែលពិបាកអនុវត្តតាមផ្លូវនយោបាយនេះឡើយ។ ការវិនិយោគនៅក្នុងការអប់រំទូទៅប្រកបដោយគុណភាព ដើម្បីជំរុញអោយកូនអ្នកក្រ មានលទ្ធភាពចូលរួមស្មើគ្នាសម្រាប់រកការងារ និងកាលានុវត្តភាព ឬការវិនិយោគនៅក្នុងវិធានការការពារសង្គម(ដូចជា សេវាសុខភាពតម្លៃទាប) ដែលនឹងជួយការលើកទឹកចិត្តកាត់បន្ថយហានិភ័យមានកម្រិតសមរម្យសម្រាប់គ្រួសារក្រីក្រសុទ្ធ តែអាចជួយបន្ថយកំណើនវិសមភាព និងបង្កើនសកម្មភាពសេដ្ឋកិច្ចផ្សេងៗ។

ការបញ្ចុះអត្រានៃការកាត់បន្ថយភាពក្រីក្របានប្រមាណពី ១០% ទៅដល់ ១៥% កក្នុងរយៈពេលចន្លោះឆ្នាំ១៩៩៣-៩៤ ដល់ឆ្នាំ២០០៤ គឺជាជោគជ័យដ៏សម្បើមមួយ។ ប៉ុន្តែការបកស្រាយប្រកបដោយគុណភាពពីរបត់នេះទាមទារអោយគិតដល់កត្តាបរិបទមួយចំនួន។ ទី១ គឺថាដូចមានចែងក្នុងជំពូក១ អញ្ចឹងក្នុងរយៈកាលនេះ ប្រទេសកម្ពុជាបានទទួលដោយរីករាយនូវកត្តាប្រវត្តិសាស្ត្រ ពិសេសមួយចំនួនដែលបានជួយប្រទេសនេះអោយកាត់បន្ថយភាពក្រីក្រ។ ភាពប្រសើរឡើងមានលក្ខណៈងាយស្រួយគួរសម នៅពេលចាប់ផ្តើម

ពីមូលដ្ឋានទាបបំផុតមួយ ដែលត្រូវបានបន្ថែមដោយផលចំណេញនៃរបបកូតាលើកទី១ ដែលរហូតដល់ឥឡូវនេះរក្សាការពារនាំចេញផលិតផលកាត់ដេររបស់ប្រទេសកម្ពុជាទៀត។ ដោយឥទ្ធិពលពេញលេញនៃការជំរុញកំណើនសេដ្ឋកិច្ចដែលមានតែម្តង ហើយដោយកម្រចេះតែចុះខ្សោយទៅៗ នោះប្រទេសកម្ពុជានឹងត្រូវស្វែងរកប្រភពនៃកំណើនសេដ្ឋកិច្ចថ្មីៗ និងរបៀបរបបថ្មីៗដើម្បីដោះស្រាយការកាត់បន្ថយភាពក្រីក្រ។ កត្តាទី២ ដែលធ្វើអោយការបកស្រាយលើរបត់ភាពក្រីក្រេនះមានសុទិដ្ឋិនិយមតិច គឺថានៅពេលដែលប្រជាជនជាច្រើនបានគេចចេញពីភាពក្រីក្រមួយផ្នែកធំនៃជនមិនមែនក្រីក្រនៅតែទទួរងហានិភ័យ ដែលអាចរុញពួកគាត់អោយវិលចូលទៅភាពក្រីក្រវិញដដែល។ របៀបនៃការឆ្លុះបញ្ចាំងរឿងនេះតាមភូមិសាស្ត្រ គឺដោយមើលការបែងចែកនៃការប្រើប្រាស់របស់គ្រួសារសម្រាប់មនុស្សម្នាក់ៗ។ យើងអាចមើលឃើញថា បរិមាណដ៏សម្បើមនៃប្រជាជនប្រមូលផ្តុំយ៉ាងកុះករ ឬមួយក្រោម ឬមួយលើបន្តិចជុំវិញបន្ទាត់ភាពក្រីក្រ។ ម្យ៉ាងនេះ គឺជាដំណឹងល្អដែលបញ្ជាក់ថា ជនក្រីក្រជាច្រើនទាមទារការកើនឡើងថេរ នៃការប្រើប្រាស់តែបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីលើកពួកគាត់ជាបន្តបន្ទាប់ផុតពីភាពក្រីក្រ។ ប៉ុន្តែរូបភាពនេះក៏បានបញ្ជាក់តាមរបៀបផ្ទុយទៅវិញដែរថា ក្នុងឆ្នាំ២០០៤ ការប្រើប្រាស់សម្ភារៈសម្រាបមនុស្សម្នាក់ៗត្រូវបានកត់ត្រាទុក ដែលដាក់ពួកគាត់អោយនៅត្រឹមបន្ទាត់ភាពក្រីក្របន្តិចប៉ុណ្ណោះ។ នៅពេលដែលការនេះមានន័យថា ពួកគាត់ត្រូវបានបែងចែកអោយស្ថិតក្នុងប្រភេទមិនមែនក្រីក្រសម្រាប់ពេលនេះ នោះការធ្លាក់ចុះកម្រិតជីវភាពរបស់ក្រុមនេះ តែបន្តិចប៉ុណ្ណោះនឹងនាំអោយពួកគាត់វិលត្រឡប់ចុះទៅនៅពីក្រោមបន្ទាត់ភាពក្រីក្រវិញហើយ។ ជិត ៧% នៃគ្រួសារស្ថិតនៅចន្លោះ១០% លើបន្ទាត់ភាពក្រីក្រពោលគឺ បើការប្រើប្រាស់របស់គ្រួសារទាំងនេះសម្រាប់តែមនុស្សម្នាក់ៗគ្រាន់តែថយចុះប្រមាណ ១០% អត្រាភាពក្រីក្រនឹងកើនប្រមាណ ៧% ពី ៣៥% មកដល់ ៤០%[៥០] ។

ឆ-ប្រភពនៃភាពងាយទទួលរងគ្រោះ

គ្រួសារក្នុងប្រទេសកម្ពុជាប្រឈមនឹងហានិយភ័យប្លែកៗ ជាឯកត្តជន ឬជាសមូហភាពដែលអាចរុញច្រាន សូម្បីតែគ្រួសារមានទ្រព្យសម្បត្តិគួរសមអោយធ្លាក់ចូលក្នុងភាពក្រីក្របាន ហើយគ្រួសារក្រីក្រអោយធ្លាក់ចូលក្នុងភាពទីទ័លក្រ[៥១]។ ការស្តុតរន្ធត់រួម(នោះ គឺការស្តុតរន្ធត់ដែលប៉ះពាល់គ្រួសារជាច្រើននៅពេលតែមួយ និងហាក់ដូចជាប៉ះពាល់យ៉ាងលើសលប់ចំពោះយុទ្ធសាស្ត្រដោះស្រាយសង្គម ផ្អែកលើការគាំទ្រក្នុងគ្រួសារ និងសហគមន៍)រួមមាន: ទឹកជំនន់ និងគ្រោះរាំងស្ងួតយ៉ាងធ្ងន់ធ្ងរ: ទឹកជំនន់ក្នុងឆ្នាំ២០០ បានប៉ះពាល់ប្រជាជនប្រមាណ ៣.៤០០.០០០នាក់បណ្តាលអោយខូចខាតផលដំណាំ និងធ្វើអោយខូចខាតសម្ភារៈសាធារណៈក្នុងទម្រង់ជាហេដ្ឋារចនាសម្ព័ន្ធ និងធ្វើអោយមានជំងឺរីករាលដាល។ គ្រោះរាំងស្ងួតឆ្នាំ២០០២ និង ២០០៤ ក៏ប៉ះពាល់ប្រជាជនរាប់លាននាក់ដែរ។

---

[៥០] អាស៊ីបូព៌ា និងប៉ាស៊ីហ្វីក "កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេ នាឆ្នាំ២០១៥?" ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រទី៧៩

[៥១] ធនាគារពិភពលោក ឆ្នាំ២០០៥

-ការប្រែប្រួលពាណិជ្ជកម្មអន្តរជាតិ ដែលប៉ះពាល់ដល់អំណោយផលរបស់ទំនិញ និងសេវារបស់កម្ពុជា។ វិស័យកាត់ដេរហាក់ដូចជាអាចបន្តសកម្មភាពទៅមុខទៀត ទោះបីមិនបានពង្រីកក៏ដោយបន្ទាប់ពីការបញ្ចប់កិច្ចព្រមព្រៀងវាយនភ័ណ្ឌ(MFA) ដោយមានការអនុគ្រោះបន្ថែមពីសហព័ន្ធអឺរ៉ុប និងកិច្ចការពាររបស់សហរដ្ឋអាមេរិកទល់នឹងការនាំចេញរបស់ប្រទេសចិន។ ប៉ុន្តែការអនុគ្រោះទាំងនេះនឹងត្រូវផុតកំណត់នៅឆ្នាំ២០០៨ : បើសិនមិនត្រូវបានជំនួសវិញទេ នោះនិយោជិក កម្មករជាច្រើនក្នុងវិស័យកាត់ដេរនឹងប្រឈមនឹងនិកម្មភាព(ភាពអត់ការងារធ្វើ)។ វិស័យទេសចរណ៍ និងសំណាង ងាយទទួលរងគ្រោះដោយសារការភ័យខ្លាចជំងឺសារស៍(SARS) គ្រុនផ្តាសាយបក្សី អស្ថេរភាពនយោបាយ និងភេរវកម្ម។ ការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ប្រទេសថៃ ឬការផ្លាស់ប្តូរបញ្ញត្តិស្តីពី ទេសន្តរប្រវេសន៍ពលកម្មខ្មែរនឹងធ្វើអោយប្រជាជនជាច្រើនគ្មានលទ្ធភាពទទួលបាននូវការងារឆ្លងដែនដូរយកប្រាកកម្រៃ និងផ្តល់ផលចំណេញតិចដល់អ្នកផ្សេងទៀត។

ចំពោះសហគមន៍ជនក្រីក្រស់នៅក្នុងតំបន់សំណង់អនាធិបតេយ្យនៅទីក្រុងការបណ្តេញចេញ ឬអគ្គីភ័យដែលរីករាយយ៉ាងរហ័ស គឺជាការស្តុតរន្ធត់របស់សហគមន៍ទាំងមូល។

ការស្តុតរន្ធត់ ឬហានិភ័យចំឡែកនោះ គឺការស្តុតរន្ធត់ ឬហានិភ័យ ដែលប៉ះពាល់តែគ្រួសារមួយដោយមិនប៉ះពាល់អ្នកជិតខាងឡើយរួមមាន: ១-ជំងឺដែលត្រូវបានរកឃើញថា ជាកត្តាសំខាន់ក្នុងការឈានទៅដល់ការបាត់បង់ជី។ ដោយប្រព័ន្ធសុខាភិបាលសាធារណៈគ្មានគុណភាពខ្ពស់ មិនផ្តល់លទ្ធភាពអោយទទួលបានការព្យាបាល មិនអនុញ្ញាតអោយអ្នកជំងឺក្រមានលទ្ធភាពបង់ប្រាក់គ្រប់ជំងឺ ជាពិសេសជំងឺ ឬរបួសសង្គ្រោះបន្ទាន់អាចទាមទារ ការបង់ប្រាក់យ៉ាងច្រើនសម្បើមទាំងតម្លៃព្យាបាល និងបាត់បង់ពលកម្មរបស់អ្នកជំងឺ។ ២-ការខកខានប្រមូលផលដំណាំ(ដោយសារទឹកជំនន់ ឬគ្រោះរាំងស្ងួតនៅមូលដ្ឋាន ឬការខូចខាតបំផ្លាញដោយសត្វល្អិត) ឬជំងឺ ឬការងាយសត្វ៣ហន:។ ៣-ការលួច ឬអំពើហិង្សារួមទាំង អំពើហិង្សាក្នុងគ្រួសារ ព្រមទាំងព្រឹត្តិការណ៍ជីវិតក្នុងវដ្តសង្សា ដូចជា អាពាហ៍ពិពាហ៍ មរណភាព ឬកំណើតដែលពិធីនីមួយៗទាក់ទិននឹងការចំណាយការខាត់បង់សក្តានុពលប្រាក់ចំណូល និងសេចក្តីត្រូវការក្នុងការប្រើប្រាស់ ដែលកើនឡើង។ ការចំណាយមួយចំនួនអាចត្រូវបានប៉ាន់ស្មានមុន យ៉ាងហោចណាស់ក៏មួយផ្នែកដែរ ដែលជាការងាយស្រួលក្នុងការកាត់បន្ថយ ឬដោះស្រាយផលប៉ះពាល់ ប៉ុន្តែការចំណាយមួយចំនួនទៀតមិនអាចត្រូវបានប៉ាន់ស្មានមុនបានទេ។

ដូច្នេះយើងឃើញថា ភាពងាយស្រួលទទួលរងការស្តុតរន្ធត់ទាំងនេះ គឺរឹតតែធ្ងន់ធ្ងរទៅទៀតដោយសារ ១-មូលដ្ឋានទ្រព្យធន និងការសន្សំរបស់គ្រួសារក្រីក្រមានកម្រិត។ ២-ការអភិវឌ្ឍន៍អន់ថយនៃទីផ្សារហិរញ្ញវត្ថុសម្រាប់ការសន្សំ ការខ្ចីប្រាក់ ឬការធានារ៉ាប់រង។ ៣-កង្វះខាតពហុកម្មមុខរបរក្នុងគ្រួសារ(និងសហគមន៍) ៤-ការពឹងផ្អែកយ៉ាងខ្លាំងលើប្រភពទ្រព្យសម្បត្តិរួមជាផ្នែកមួយនៃយុទ្ធសាស្ត្រជីវភាពរស់នៅធម្មតា ឬជាប្រព័ន្ធសុវត្ថិភាពនៅពេលលទ្ធភាពទទួលបាន ឬកម្រិតផលិតភាពរបស់ធនធានទាំងនេះធ្លាក់ចុះ និង ៥-កង្វះខាតនីតិរដ្ឋ និងកង្វះខាតលទ្ធភាពទទួលបានយុត្តិធម៌ក្នុងជម្លោះរវាងជនក្រីក្រ និងអ្នកមានទ្រព្យសម្បត្តិ ឬអ្នកមានអំណាច។

ជំពូកទី៤
វិភាគលើមូលហេតុនៃភាពក្រីក្រនៅកម្ពុជា

៤.១ មូលហេតុនៃភាពក្រីក្រ

៤.១.១ មូលហេតុនៃនយោបាយ

បើយើងពិនិត្យពីប្រវត្តិសាស្ត្រខ្មែរ យើងឃើញថា ភាពសុខសាន្តក្នុងសង្គមមានតិចតួចណាស់ គឺជួបតែសង្គ្រាម ដែលជៀតជ្រែកពីបរទេសផង សង្គ្រាមដណ្តើមអំណាចផ្ទៃក្នុងប្រទេសផង។ សង្គ្រាមរ៉ាំរ៉ៃហែកហួរសម្លាប់ខ្មែរគ្នាឯងយ៉ាងសាហាវ រហូតមកដល់សព្វថ្ងៃស្ទើរតែរលាយប្រទេសបាត់ពីផែនទីពិភពលោកនេះទៅហើយ។ ក្នុងប្រវត្តិសាស្ត្រ ខ្មែរបានកត់ត្រាទុកស្ទើរតែមិនអស់នូវសង្គ្រាមចំបាំងរាំងជល ដែលកើតមានឡើងដោយសារតែការដណ្តើមអំណាច បែងចែកអំណាច និងទ្រព្យសម្បត្តិមិនស្មើគ្នា។ អ្នកដែលត្រូវទទួលបានអំណាចតិចតួច ឬទ្រព្យសម្បត្តិមិនសមនឹងចិត្តលោភលន់របស់ខ្លួនតាំងក្រេវក្រោធកើតទុក្ខមិនសុខចិត្ត ចេញតស៊ូដេកក្នុងព្រៃបញ្ចុះបញ្ចូលប្រមែប្រមូលបង្កើតជាកងទ័ព បង្កជាភ្លើងសង្គ្រាមក្នុងស្រុកដោយគ្មានគិតពីសេចក្តីស្លាប់ និងទុក្ខលំបាកវេទនារបស់ប្រជាពលរដ្ឋឡើយ។ ការប្រយុទ្ធគ្នារវាងខ្មែរនិងខ្មែរនេះ បណ្តាលអោយប្រទេសជាតិចុះខ្សោយស្ទើរខ្សោះឈាម និងធ្លាក់ចូលក្នុងមហន្តរាយយ៉ាងអាណោចអាធមជាទីបំផុត។

ក្នុងឱកាសដែលប្រទេសជាតិចុះខ្សោយ និងមានវិបត្តិក្នុងប្រទេស បារាំងបានឆ្លៀតឱកាសនេះចូលមកត្រួតត្រា(ដាក់អាណានិគម) តាំងពីឆ្នាំ១៨៦៣ ជិតមួយសតវត្ស កម្ពុជានៅក្រោមអំណាចបារាំងពេលនោះ កិច្ចការក្រៅប្រទេស(នយោបាយក្រៅប្រទេស) ការទាក់ទងនឹងបរទេសទូទៅ និងកិច្ចការរដ្ឋាភិបាលក្នុងប្រទេសស្ថិតនៅក្នុងកណ្តាប់ដៃបារាំងទាំងអស់[៥២]។ របបគ្រប់គ្រងដោយបារាំងបានបង្កើតអោយមានឧបសគ្គដល់ការលូតលាស់នៃផលិតកម្មជាតិនៅកម្ពុជា ដោយហេតុថា ទីផ្សារក្នុងប្រទេសបានត្រូវបើកចំហរដល់ការនាំចូលដោយសេរី "គឺមិនយកពន្ធដារ" នូវគ្រឿងផលិតកម្ម ឧស្សាហកម្មទាំងឡាយពីក្រៅប្រទេស[៥៣]។ ជំងឺខ្វះអធិបតេយ្យភាព ភាពក្រលំបាករបស់ប្រជាពលរដ្ឋខ្មែរ បានកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃកាន់តែខ្លាំងឡើងៗ។

មេដឹកនាំខ្មែរមិនសូវឈឺចាប់ជាតិនិយម ស្នេហាជាតិតែសំបកក្រៅ គឺធ្វើយ៉ាងណាអោយតែសម្រេចបាននូវមហិច្ឆតា និងល្បែងនយោបាយរបស់ខ្លួនដោយយកប្រទេសជាតិ ធ្វើជាបទពិសោធន៍នយោបាយរបស់ខ្លួន។ ដោយចរិកអ្នកដឹកនាំបែបនេះហើយ បានជាប្រទេសជាតិគ្មានការអភិវឌ្ឍន៍រីកលូតលាស់ដោយមិនបានថែរក្សាធនធាន និងបង្កើតធនធានសម្រាប់បម្រើអោយវិស័យអភិវឌ្ឍន៍សង្គមឡើយ។ ពាក់ព័ន្ធនឹងបញ្ហាធនធានដូចជាធនធានមនុស្ស កូនខ្មែរដែលរៀនចេញដឹងប្រកបដោយចំណេះវិទ្យាសាស្ត្រខ្លាំងពូកែ និងជ្រៅជ្រះដែលធាតុផ្សំ

---

[៥២] ហេង ហុង "ឱ! លោកធំខ្មែរ" ទំព័រទី១៩

[៥៣] Ibid. Page 22.

សម្រាប់ការអភិវឌ្ឍន៍សង្គមជាតិនោះ បែរគ្មានការយកចិត្តទុកដាក់ និងផ្តល់ឱកាសអោយកូនខ្មែរណាម្នាក់យកចំណេះដឹងវិទ្យាសាស្ត្រមកសាបព្រោះលើកូនខ្មែរដទៃទៀត ដើម្បីជាកម្លាំងច្រើនងាយស្រួលក្នុងការកសាងជាតិឡើយ។ កូនខ្មែរដែលបានបញ្ចប់ការសិក្សានៅបរទេសប្រកបដោយចំណេះដឹងវិទ្យាសាស្ត្រខ្ពស់ៗ បន្ទាប់ពីបញ្ចប់ការសិក្សាបានត្រឡប់មកស្រុកវិញក្នុងសេចក្តីសង្ឃឹម និងយកចំណេះដឹងទាំងប៉ុន្មានមកចូលរួមចំណែកកសាងប្រទេសជាតិ ប្រកបដោយឆន្ទៈខ្ពស់របស់ខ្លួន។ តែគួរអោយអនិច្ចារណាស់ ពេលមកដល់មាតុភូមិត្រូវបានសង្គមធ្វើមិនដឹង មិនឮ ព្រមទាំងបញ្ជាអោយអាមុីអាថៅធ្វើការតាមដានការអ្នកទាំងនោះ ក្លាចក្រែងពួកនេះមានគំនិតជឿនលឿនជាងខ្លួន និងហ៊ានរិះគន់ប្រឆាំងនឹងគំនិតរបស់ខ្លួន ពិសេសក្លាចពួកនេះមានប្រជាប្រិយ៍ភាពជាង(នេះ គឺចំពោះអ្នកដែលគ្មានទេពកោសល្យ ខាងអែបអបរណប ឱនលំទោន និងមិនបានបំពេញនូវមហិច្ឆតារបស់ពួកគេ)។

ដោយអ្នកដឹកនាំមានគំនិតបែបនេះ ធ្វើអោយប្រទេសជាតិទាំងមូលគ្រាន់តែរស់មិនអាចលូតលាស់បានព្រោះខ្វះអ្នកចេះដឹងខ្ពស់ៗចូលរួមប្រកបទៅដោយឆន្ទៈរបស់គេ។ មិនតែប៉ុណ្ណោះដោយសារអំពើនេះបណ្តាលអោយនិស្សិតបញ្ញាវន្ត អ្នកចេះដឹងខ្ពស់ៗដកសេចក្តីទុកចិត្តពីអ្នកដឹកនាំទៀតផងហើយក៏ជាកត្តាមួយធ្វើអោយពួកនេះលេចដុះចេញជាគំនិតចង់កែប្រែរបបសង្គមឡើង ធ្វើអោយមានទំនាស់ខ្វែងគំនិតគ្នាបង្កើតអស្ថេរភាពសង្គម និងអស្ថេរភាពនយោបាយ។ ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗទៀតដូចជាភាពក្រីក្រនៅក្នុងសង្គមជាតិកម្ពុជាមានមូលហេតុជាច្រើន ប៉ុន្តែមូលហេតុចម្បងដែលសំខាន់ជាងគេ ដែលធ្វើអោយមានវិនាសសកម្មបង្កើតនូវវិបត្តិនយោបាយ និងភាពកក្រើក្រហូតដល់បច្ចុប្បន្ន គឺដោយសារសង្គ្រាម ដែលបណ្តាលមកពីការលោភលន់អំណាចលុយកាត់ និងបុណ្យសក្តិបានជំរុញអោយជនជំពូកខ្លះ ដែលខ្វះមនុស្សធម៌ ខ្វះចំណេះដឹង ចូលចិត្តចិញ្ចឹមនូវអំពើហិង្សា ឃោរឃៅ និងការជួញដូរសង្គ្រាម (អាជីវកម្មសង្គ្រាម)។ ជនឱកាសនិយមនៃជំពូកខាងលើតែងរមែងយល់ឃើញថា ការប្រព្រឹត្តនូវអំពើហិង្សាឃោរឃៅ និងការជួញដូរ សង្គ្រាមអាចនាំអោយគេក្លាយទៅជាអ្នកមានអំណាច មានទ្រព្យសម្បត្តិលើញើសឈាមនៃទុក្ខវេទនារបស់អ្នកដទៃបាន។ ម្យ៉ាងវិញទៀត ជនខាងលើនេះក្រៅអំពីការលោភអំណាចទ្រព្យសម្បត្តិធ្វើសង្គ្រាមបានរំលោភលើច្បាប់ ដែលជាសកម្មភាពបំផ្លាញជាតិ ដោយមិនដឹងខ្លួនពុំមានគំនិតអ្វីសម្រាប់កសាង និងស្ថាបនាជាតិ ដើម្បីបម្រើផលប្រយោជន៍ប្រជាជនអោយមានជីវភាពធូរធារឡើយ។ គេមិនដែលបានគិតថា សង្គ្រាមជាប្រភពមូលដ្ឋាននៃវិបត្តិសង្គម និងភាពក្រីក្រឡើយ។ មិនតែប៉ុណ្ណោះ សង្គ្រាមបំផ្លាញនូវវប្បធម៌ជាតិ និងធនធានធម្មជាតិ ដែលធ្វើអោយប្រជាជនរស់នៅក្នុងភាពក្រគោកយ៉ាក និងពុំមានពេលក្រេបជញ្ជក់នូវចំណេះដឹងបានទៀតផង។

ជាក់ស្តែងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧០-១៩៩៨ បានផ្លាស់ប្តូររបបគ្រប់គ្រងរហូតដល់ **៦** របប[៥៤] ដែលមាន:

[៥៤] HISTORY OF PHNOM PENH CITY, First Edition-March 1998.

-១៩៧០-១៩៧៥ របបសាធារណរដ្ឋខ្មែរ

-១៩៧៥-១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យ

-១៩៧៩-១៩៨៩ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

-១៩៨៩-១៩៩២ របបរដ្ឋកម្ពុជា

-១៩៩២-១៩៩៣ UNTAC

-១៩៩៣-បច្ចុប្បន្ន របបព្រះរាជាណាចក្រកម្ពុជា

សង្គ្រាម និងការផ្លាស់ប្តូរបបនយោបាយនៃការគ្រប់គ្រងញឹកញាប់ធ្វើអោយប្រទេសគ្មានលំនឹងស្ថេរភាពនយោបាយ កើមានវិបត្តិនយោបាយរ៉ាំរ៉ៃ។ សង្គ្រាមបានបំផ្លាញសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យរបស់ជាតិអោយធ្លាក់ដុនដាប ប្រជាជនរស់នៅគ្មានសេចក្តីសុខ ផ្លាស់ប្តូរទីលំនៅជាញឹកញាប់ទៅរកកន្លែងដែលមានសុវត្ថិភាព បាត់បង់ពេលវេលាបង្កបង្កើនផង ការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គម ហើយជាពិសេសនៅចន្លោះថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩ ដែលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យ(ប៉ុល ពត) គឺសាហាវឃោរឃៅបំផ្លិចបំផ្លាញជាងពេលមានសង្គ្រាមថែមទៀត។ វិបត្តិកើតមានផ្ទួនៗសម្រាប់កម្ពុជា ធ្វើអោយមានការខ្វះស្បៀងអាហារ ដែលនាំអោយសុខមាលភាពប្រជាជនចុះដុនដាបពោល គឺជីវិតរស់នៅមានរយៈពេលខ្លី។ សង្គ្រាមបានបន្សល់ទុក្ខនូវភាពក្រីក្រ ជនអនាថា ជនពិការ និងស្ត្រីមេម៉ាយដែលធ្វើអោយបាត់បង់នូវប្រពលភាព និងភាពងាយទទួលរងគ្រោះ។ សង្គ្រាមបានគំរាមកំហែង និងបន្សល់ទុក្ខនូវគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះជាច្រើននៅលើដី ដែលប្រជាជនត្រូវការបង្កបង្កើនផល។ យោងតាមទិន្នន័យព័ត៌មានដែលស្រាវជ្រាវដោយស៊ីម៉ាក ដែលទើបតែបញ្ចប់ជាស្ថាពរនៅខែមេសា ឆ្នាំ២០០២ បានបង្ហាញនូវលទ្ធភាពឃើញថា មានភូមិចំនួន ៦៤២២ភូមិ ប្រមាណជា ៤៦.២%នៃភូមិទូទាំងប្រទេស ត្រូវរងនូវការគំរាមកំហែងដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបានបន្សល់ទុក្ខដោយសារតែសង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សកន្លងមក ចំណុចដែលបង្កប់ទៅដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ១១១.២៨៧កន្លែង។ ដី ដែលសង្ស័យថា មានគ្រាប់មីននោះទំហំ ៤.៤៦៦គីឡូម៉ែត្រក្រឡា ដែលដីភាគច្រើនជាកន្លែងរស់នៅរបស់ប្រជាពលរដ្ឋ។ មានប្រជា-ពលរដ្ឋ ដែលរងនូវការគំរាមកំហែងពីមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ៥.១៨៦.៧៧១នាក់ ត្រូជា ៤៥,៣% នៃប្រជាពលរដ្ឋទូទាំងប្រទេស[៥៥]។ ទោះបីកម្ពុជាបានទទួលសន្តិភាព ១០០% ក៏ដោយក៏គ្រាប់មីនដែលនៅសេសសល់ពីសង្គ្រាមយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងព្រៃ និងស្រែចំការបានបង្ករគ្រោះថ្នាក់ជារៀងរាល់ថ្ងៃដល់ប្រជាជនស្លូតត្រង់ជាពិសេសអ្នករស់នៅតំបន់ជាច់ស្រយាល បណ្តាលអោយពួកគេក្លាយទៅជាជនពិការអស់មួយជីវិត ឬស្លាប់បាត់បង់ជីវិតយ៉ាងអាណោចអាធមជាទីបំផុត។ សង្គ្រាមនេះ គឺបានបន្សល់ទុក្ខនូវអនុស្សាវរីយ៍មួយរយ

[៥៥] ការសែតស្មើកម្ពុជា ឆ្នាំទី១១ លេខ៣០៩៤ ទំព័រ ក២

ជំពូកដ៏សែនជូរចត់បំផុតដល់កូនខ្មែរជំនាន់ក្រោយ ក៏ដូចជាសង្គមខ្មែរទាំងមូល។ ព្រោះតែសង្គ្រាមធ្វើអោយប្រជាពលរដ្ឋខ្មែរយើងធ្វើការកាប់សម្លាប់គ្នាឯង ដើម្បីអោយតែឈ្នះតាមចិត្តមានៈនៃមហិច្ឆិតានោះ។

កេរ្តិ៍មរតកដ៏អាក្រក់ ដែលបង្កដោយសង្គ្រាមជំនាន់សតវត្សទី២០ បានបន្សល់ទុក្ខអោយកូនខ្មែរជំនាន់ក្រោយ គឺៈ ១-ខ្វះអ្នកមានសមត្ថភាពនៅគ្រប់ស្ថាប័នរដ្ឋ ព្រោះតែសង្គ្រាមបានបំផ្លាញប្រភពធនធានមនុស្ស (សម្លាប់អ្នកចេះចោល)។ ២-រចនាសម្ព័ន្ធសង្គមធ្លាក់ក្រោមសូន្យ ផ្លូវគមនាគមន៍ ស្ពាន ត្រូវខ្ទេចខ្ទីដោយសារមីន និងបំផ្លាញតាមរូបភាពផ្សេងៗ ដែលជាយុទ្ធសាស្ត្រសង្គ្រាមរបស់ពួកគេដើម្បីឈ្នះ។ ៣-ប្រទេសទាំងមូលនៅសល់តែដី ហើយដីកន្លែងខ្លះស្ទើរ ឬប្រើការលែងកើតទៀតផង។ ព្រោះដីទាំងនោះត្រូវក្លាយជាចំការមីន ដែលពួកគេបានកប់ក្នុងសម័យសង្គ្រាមដណ្តើមអំណាចគ្នា និងកន្លែងខ្លះទៀតបានក្លាយជាវាលរណ្តៅគ្រាប់។ មីនរាប់លានគ្រាប់ត្រូវបានកប់ក្នុងដីរហូតដល់សព្វថ្ងៃ ដែលជាឧបសគ្គដ៏ធ្ងន់ធ្ងរដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ៤-ធ្វើអោយកូនខ្មែរបាត់អស់សុជីវធម៌ជាខ្មែរ ដែលធ្លាប់តែមានប្រពៃណីសាមគ្គីគ្នា ស្រឡាញ់គ្នា ជួយគ្នា ឧស្សាហ៍ ព្យាយាម និងខំកសាងប្រទេសខ្លួន។ ឥឡូវទៅជាឃោរឃៅព្រៃផ្សៃសម្លាប់គ្នាយ៉ាងសាហាវនៅក្នុងសង្គម។ ៥-សម្បត្តិវប្បធម៌មានទាំងរូបចម្លាក់នៅតាមប្រាសាទនានា ជាពិសេសប្រាសាទនៅខេត្តសៀមរាប ត្រូវបានបាក់បែក ដោយសារសង្គ្រាមមួយផ្នែក និងមួយផ្នែកត្រូវបាត់បង់ពីប្រទេសខ្មែរទៅនៅឯបរទេស។ ៦-ភាពបាក់ស្អាត និងការលែងទុកចិត្តគ្នាទៅវិញទៅមករវាងខ្មែរ និងខ្មែរ។ ប្រាកដណាស់មកដល់ថ្ងៃនេះបានធ្វើអោយស្មារតីខ្មែរស្ថិតក្នុងសភាពភ័យខ្លាចមិនហ៊ានបញ្ចេញមតិ ដែលផុសចេញពីក្រអៅបេះដូរបស់ខ្លួនទេ។ ៧-ស្ត្រីមេម៉ាយរាប់ពាន់ រាប់ម៉ឺននាក់រស់នៅដោយវេទនា ភាពក្រីក្រទុរគត របស់ប្រជាជនខ្មែរគ្រប់បែបយ៉ាង និងជាពិសេសកុមារគ្របដណ្តប់ដោយជំងឺគ្រប់ប្រភេទ។ ជនពិការរាប់ពាន់ រាប់ម៉ឺននាក់ មានតាំងពីបាក់ដៃ បាក់ជើង របួសសសុះខ្លួន និងមានជំងឺពុំរ៉ៃដែលជាបន្ទុករបស់សង្គមត្រូវតែចិញ្ចឹមពួកគេ។ ជាពិសេសជំងឺខួរក្បាល ដែលជាការលំបាកបំផុត ព្រោះក្នុងរបបគ្រប់គ្រងនីមួយៗគេអប់រំកូនខ្មែរគេគាបសង្កត់ បង្ខំអោយកូនខ្មែរទទួលយកគំនិតនៃបុគ្គលមួយក្តាប់តូច ដើម្បីបម្រើមហិច្ឆតារបស់ក្រុមខ្លួនក្នុងបំណងកេងប្រវ័ញ្ចអំណាចប៉ុណ្ណោះ។

ជាការពិតណាស់សង្គ្រាមបានបន្សល់ទុក្ខនូវវិបត្តិសង្គម ប្រជាពលរដ្ឋបាត់បង់សមត្ថភាពស្ថិតនៅក្នុងភាពក្រីក្រ។ បញ្ហានេះជាការប្រឈមចំពោះមុខមួយយ៉ាងធ្ងន់ធ្ងរដល់សង្គម ដែលត្រូវការដោះស្រាយ។ ដូច្នេះសង្គ្រាមជាមូលហេតុសំខាន់ណាស់ ដែលបណ្តាលអោយមានភាពក្រីក្រនៅកម្ពុជា។ ដោយមានពិសោធន៍សង្គ្រាម ធ្វើអោយមានមហន្តរាយដល់សង្គម និងបន្សល់ទុក្ខតែភាពក្រីក្រយ៉ាងដូច្នេះ គួរតែយើងគ្រប់គ្នាបង្កើតគំនិតបញ្ចៀសពីបទពិសោធន៍ខាងលើនេះហើយ យើងទាំងអស់គ្នា ជាពិសេរដ្ឋាភិបាលត្រូវមានគោលបំណងពិតប្រាកដក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងការកាត់បន្ថយភាពក្រីក្រ ដោយមានជំហរគោលនយោបាយដូចជា ការផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋអាចរកប្រាក់ចំណូលបានក្នុងក្របខ័ណ្ឌនៃច្បាប់ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យអោយបានត្រឹមត្រូវ ហើយរដ្ឋាភិបាលត្រូវមានតួនាទីត្រឹមត្រូវក្នុងការគ្រប់គ្រងតាមគោលការណ៍នៃអភិបាលកិច្ចល្អ។

ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗទៀត ដូចជា គណបក្សនយោបាយៈ បន្ទាប់ពីសង្គ្រាមបង្ហូរឈាម ដណ្តើមអំណាច និងការផ្លាស់ប្តូររបបនយោបាយជាបន្តបន្ទាប់នៅក្នុងប្រទេសកើតមានវិបត្តិនយោបាយរ៉ាំរ៉ៃអស់រយៈពេលជាងបីទសវត្សកន្លងមក។ ប្រទេសកម្ពុជា ក៏ជួបនូវវិបត្តិដណ្តើមអំណាចបែបប្រជាធិបតេយ្យតាមរយៈការបង្កើតគណបក្សនយោបាយប្រកួតប្រជែង ដើម្បីអំណាចតាមរយៈការគាំទ្រពីប្រជាពលរដ្ឋ។ ការរៀបចំអំណាចតាមរបៀបខាងលើ គឺក្នុងគោលបំណងអភិវឌ្ឍន៍ និងកសាងនីតិរដ្ឋប្រកបដោយលក្ខណៈប្រជាធិបតេយ្យស្របតាមមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣[៥៦]។ ប្រព័ន្ធនយោបាយការរៀបចំអភិវឌ្ឍន៍ និងកសាងនីតិរដ្ឋជាលក្ខណៈប្រជាធិបតេយ្យជាការប្រពៃណាស់ព្រោះប្រទេសអភិវឌ្ឍន៍ជាច្រើននៅលើពិភពលោកមានការគាំទ្រ និងពេញនិយមនូវប្រព័ន្ធនយោបាយនេះ។ ប្រព័ន្ធនយោបាយនេះធ្វើអោយប្រជាពលរដ្ឋមានឱកាសក្នុងការចូលរួមចំណែកយ៉ាងសកម្មតាមរយៈតំណាងរបស់ខ្លួន នៅក្នុងសកម្មភាពនយោបាយការសម្រេចចិត្តរាល់កិច្ចការសង្គម។

ប្រព័ន្ធបោះឆ្នោតជ្រើសរើសតំណាងរបស់ប្រជាពលរដ្ឋនៅកម្ពុជាតាមប្រព័ន្ធសមាមាត្រ វាផ្ទុយពីលទ្ធិប្រជាធិបតេយ្យ គឺប្រគល់សិទ្ធិសេរីភាពអោយប្រជាពលរដ្ឋជាអ្នកជ្រើសរើសតំណាងរបស់ខ្លួនដោយផ្ទាល់។ ដូច្នេះ ប្រជាពលរដ្ឋ ដែលជាអ្នកបោះឆ្នោតនៅកម្ពុជា ហាក់ដូចជាផ្ទេរសិទ្ធិរបស់ខ្លួនទាំងស្រុងទៅអោយមេគណៈ-បក្ស ដែលជាអ្នកចាត់ចែងទាំងអស់ក្នុងករណីនេះអធិបតេយ្យភាពរបស់ប្រជាពលរដ្ឋហាក់ដូចជាអស់រលីង។ ចំណែកឯបេក្ខជន ដែលបានជ្រើសតាំងដោយមេគណបក្សអោយឈរជាតំណាងរបស់ប្រជាពលរដ្ឋនោះ ហាក់ដូចជាបានមកដោយសារមេគណបក្ស ដែលជាអ្នកផ្តល់សិទ្ធិអំណាចអោយគេ ហើយគេខិតខំយកចិត្តទុកដាក់តែមេគណបក្សពុំសូវរវល់នឹងប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត(ម្ចាស់អំណាច) ប៉ុន្មានទេ រីឯប្រជាធិបតេយ្យដែលថាប្រជាពលរដ្ឋជាម្ចាស់អំណាចក្នុងមាត្រា៥១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នោះមានន័យតែតាមផ្លូវច្បាប់ តែការពិតជាក់ស្តែងពុំមានន័យឡើយ ព្រោះអំណាចពិតប្រាកដស្ថិតក្នុងកណ្តាប់ដៃនៃមេគណបក្ស រីឯប្រជាពលរដ្ឋជាម្ចាស់អំណាចបាត់បង់នូវការទំនុកបម្រុងនិងឧបត្ថម្ភពីតំណាងរបស់ខ្លួន ធ្វើអោយការរស់នៅក្នុងភាពក្រីក្រគ្មានទីបញ្ចប់។

អំណាចមេគណបក្សគ្រប់ដណ្តប់ទៅលើឆន្ទៈរបស់ប្រជាពលរដ្ឋនោះ បានធ្វើអោយជនដែលបានអំណាចពីមេគណបក្សមួយចំនួនជាច់ខាតត្រូវតែស្មោះត្រង់នឹងបក្សក្នុងភាពងងឹតងងល់ ដោយគេបម្រើបក្សច្រើនជាងបម្រើប្រយោជន៍សាធារណៈ។ ការជ្រើសរើសបុគ្គលិកធ្វើការនៅក្នុងស្ថាប័នរដ្ឋឈរលើជំហរបក្សអោយកាន់អំណាចច្រើនជាងឈរលើជំហរសមត្ថភាព និងបទពិសោធន៍។ ពួកគេពង្រឹងបក្សនៅក្នុងប្រព័ន្ធរដ្ឋបាល ហើយរដ្ឋបាលដែលបម្រើអោយបក្សនោះមិនអាចមានភាពអព្យាក្រឹត្យ ក្នុងការបម្រើផលប្រយោជន៍សាធារណៈដោយប្រសិទ្ធិភាពបានទេ ជាគ្រោះថ្នាក់ចំពោះវាសនាប្រទេសជាតិក្នុងការកសាងសន្តិភាពបង្រួបបង្រួម និងអភិវឌ្ឍន៍

[៥៦] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ទំព័រទី១៣

ជាតិ។ ការប្រកាន់បក្សពួកនៅក្នុងប្រព័ន្ធរដ្ឋបាល ឬការគ្រប់គ្រងអំណាចរដ្ឋវាចិញ្ចឹមនូវគំនិតគុំគួនជាប្រចាំ ដែលធ្វើអោយសាមគ្គីជាតិមានភាពទន់ខ្សោយ គ្មានការឯកភាពជាតិជាមូល ដែលនាំអោយកើតមានវិបត្តិជាអចិន្ត្រៃយ៍នៅក្នុងសង្គមជាតិ ដែលនាំអោយប្រជាពលរដ្ឋរស់នៅក្នុងសង្គមមួយភ័យខ្លាច និងក្នុងភាពក្រីក្រ។

នៅប្រទេសដែលមានការរីកចម្រើនគេច្រើនយកផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈធំ។ នៅប្រទេសដែលការដឹកនាំឈរលើប្រយោជន៍បុគ្គល គ្រួសារ និងគបក្សជាធំសម្រាប់ប្រទេសនោះវាជាគ្រោះថ្នាក់បំផុតចំពោះសង្គម និងប្រទេសជាតិទាំងមូល។ ប្រជាជនបាត់ភាពកក់ក្តៅអស់ជំនឿក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍សង្គម មិនតែប៉ុណ្ណោះទុក្ខវេទនារបស់ប្រជាជនភាគច្រើនអាចនាំអោយមានវិបត្តិសង្គម។ ដូច្នេះសកម្មភាព ឬទស្សនៈអ្នកដឹកនាំដែលមានដូចខាងលើ គួរតែកាត់បន្ថយ ឬបំបាត់ចោលជាបន្ទាន់ ទើបចូលរួមកាត់បន្ថយបាននូវភាពក្រីក្រ និងជំរុញអភិវឌ្ឍន៍ប្រទេសជាតិមានការរីកចម្រើនទៅមុខបាន។

ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗទៀត ដូចជា: អន្តោប្រវេសន៍ចូលមកកម្ពុជា: ការលំហូរចូលនៃជនចំណាកស្រុកក្រៅ(អន្តោប្រវេសន៍)មកកម្ពុជាច្រើន ប្រទេសកម្ពុជាមានស្ថានភាពដូចជាអន្តរការីមួយនៅក្នុងទីផ្សារពលកម្មក្នុងតំបន់ គឺទទួលពលករចំណាកស្រុកក្រៅមក និងមានពលកររបស់ខ្លួនផ្ទាល់ទៅកាន់ប្រទេសក្រៅ(ប្រទេសថៃ)។ លំហូរចូលពលករទាំងនេះភាគច្រើនមិនស្របច្បាប់។

បើពិនិត្យជាក់ស្តែងក្នុងស្ថានភាពកម្ពុជាបច្ចុប្បន្ន ជនជាតិវៀតណាមសឹងតែទាំងអស់ដែលបានរស់នៅកម្ពុជាជាច្រើនជំនាន់មក ហើយត្រូវបានជន្លៀសទៅវៀតណាមវិញនៅក្រោយពេលដែល លន់ នល់ ដណ្តើមក្នុងអំឡុងឆ្នាំ១៩៧០ និងនៅក្រោមរបបខ្មែរក្រហមជាបន្តមកទៀត។ នៅទសវត្ស ១៩៨០ ប្រជាជនវៀតណាមទាំងនេះបានត្រឡប់មកកម្ពុជាវិញជាបណ្តើរៗជាមួយនឹងមិត្តភក្តិ បងប្អូន កងទ័ព និងជំនាញការវៀតណាម។ នៅពេលកងទ័ពវៀតណាមដកចេញពីកម្ពុជាជាបន្តបន្ទាប់នោះមានកងទ័ព និងបងប្អូនមិត្តភក្តីគេមួយចំនួនមិនបានវិលត្រឡប់ទៅវៀតណាមវិញទេ។ បើតាមការវាយតម្លៃជាមធ្យមហាក់ដូចជាមានភាពគួរអោយទុកចិត្តនៅឆ្នាំ ១៩៨៧ សហគមន៍នៃជនអន្តោប្រវេសន៍មានប្រហែល ១០% នៃចំនួនប្រជាជនសរុបរបស់ប្រទេស[៥៧]។ នៅក្នុងទសវត្ស ១៩៩០ ជនអន្តោប្រវេសន៍វៀតណាមបានចូលមកកម្ពុជាមួយលើកទៀតដោយកម្លាំងទាក់ទាញនៃឱកាសងាយស្រួលរកស៊ីនៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី ដែលកំពុងរីកលូតលាស់[៥៨]។

ចំពោះទំហំនៃអន្តោប្រវេសន៍ខាងលើ យើងពិបាកធ្វើការប៉ាន់ស្មានកំណើនណាស់រវាងចន្លោះពីទសវត្ស ៩០ រហូតដល់បច្ចុប្បន្ន។ ចំណាក់ស្រុករបស់ពួកគេមានមូលហេតុខាងសេដ្ឋកិច្ចជាចម្បងបំផុត ព្រោះសេដ្ឋកិច្ច

[៥៧] NICOLAS REGAUD: "កម្ពុជាក្នុងព្យុះសង្ឃរា" ទំព័រទី១៣៨

[៥៨] CDRI "ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតម្រូវចំពោះវិបត្តិ"បោះពុម្ពខែតុលា ឆ្នាំ២០០១ ទំព័រទី២៩

ទីផ្សារសេរី កម្ពុជាជាឱកាសមួយល្អណាស់សម្រាប់ពួកគេ។ ផ្នែកតម្រូវការកង្វះពលករជំនាញក្នុងស្រុកបានផ្តល់ឱកាសល្អយ៉ាងច្រើនចំពោះមេការសំណង់ ជាងកែច្នៃឈើ អ្នកជួសជុលម៉ាស៊ីនអាជីវកររំដែលជាអន្តោប្រវេសន៍[៥៥]។

នៅខាងផ្នែកច្បាប់ ផ្នែកផ្តត់ផ្តង់ការត្រួតពិនិត្យទន់ខ្សោយ ចំពោះអន្តោប្រវេសន៍ចូលមកកម្ពុជា ដែលជាកត្តាជួយសម្រួលដល់លំហូរចូលនៃជនខាងលើ។ លំហូរចូលនៃជនអន្តប្រវេសន៍អតិបរមាជាកត្តាធ្វើអោយមានអតិផរណាទីផ្សារពលកម្មក្នុងស្រុកធ្វើអោយមានការចែករំលែក និងបាត់បង់ចំណូលប្រជាជន និងពលករក្នុងស្រុកមិនមែនតែប៉ុណ្ណោះវាធ្វើអោយបាត់បង់សក្តានុពលផ្នែកច្បាប់ទៀតផង។

ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗទៀតដូចជា: បញ្ហាវិបត្តិដីធ្លី: បញ្ហាដីធ្លី គឺជាទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ប្រជាពលរដ្ឋ ហើយវាជាមធ្យោបាយផលិតកម្មាននិរន្តរភាព ផ្នែកសេដ្ឋកិច្ច។ ការបាត់បង់ដីធ្លីរបស់ប្រជាពលរដ្ឋមានន័យថា ប្រទេសមានការបាត់បង់កម្លាំង និងការផ្តល់ឱកាសចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៍។ ពាក់ព័ន្ធទៅនឹងការកាត់បន្ថយភាពក្រីក្រដីធ្លី ជាមូលដ្ឋានដ៏សំខាន់នៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។

ដីជាអចលនទ្រព្យយ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជានៅតំបន់ជនបទ ទោះបីនោះវាមិនអាចភ្ជួររាស់បានក៏ដោយ ក៏កម្មសិទ្ធិត្រូវបានបែងចែកមិនស្មើគ្នាដោយមានប្រជាជនមួយចំនួនបានកាន់កាប់ដីដ៏ច្រើន និងក្នុងរយៈពេលមិនច្បាស់លាស់[900]។ តាមការធ្វើអង្កេតសហគមន៍គ្រួសារអ្នកមានជាងគេ(ចំណូលសល់ពីតម្រូវការប្រចាំថ្ងៃលើសលប់) ១0% បានកាន់កាប់ដីធ្លីដល់ទៅ ៤0% ក្នុងពេលដែលគ្រួសារអ្នកក្រជាងគេ (ចំណូលមិនបានបំពេញតម្រូវការជីវភាពប្រចាំថ្ងៃមានការខ្វីបុលបន្ថែម) ចំនួន៤0% បានកាន់កាប់ដីតែ ១២% ប៉ុណ្ណោះ។ ដីកសិកម្ម ដែលមិនប្រើប្រាស់បាននៅតែមានចំនួនច្រើនដោយសារការបន្សល់ទុកគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។ ប្រជាជនម្នាក់មានដីតែ 0.៣៣ហិកតាប៉ុណ្ណោះ ហើយ១៤,៤% នៃគ្រួសាររស់នៅជនបទគ្មានកម្មសិទ្ធិ ដីដែលក្នុងនោះ ៨,៦% នៅតំបន់ឆ្នេរសមុទ្រ និង ១៧,៣% នៅតំបន់ទន្លេសាប(ទិន្នន័យឆ្នាំ១៩៩៧ របស់ក្រសួងផែនការ)។ នៅចន្លោះឆ្នាំ១៩៩0 ដល់ឆ្នាំ ១៩៩៩ ដីធ្វើកសិកម្មសម្រាប់មនុស្សម្នាក់មកត្រឹម 0,២១ហិកតា /មនុស្សម្នាក់ គឺបានថយចុះជិត៣0%[909]។ ការកើនឡើងនៃផលធៀបសម្ពាធដី និងប្រជាជន គឺបណ្តាលមកពីការកើតឡើងនៃការចាប់កំណើនមនុស្សធ្វើអោយមានការកើនឡើងនូវប្រជាជនដែលគ្មានដីធ្លី។ នៅតាមតំបន់ខ្លះមានដីធំសម្រាប់មនុស្សម្នាក់ៗធ្វើកសិកម្មតែដីទាំងនោះគ្មានដីជាតិគ្មានប្រភពទឹក។ដោយកត្តាខាងលើធ្វើអោយការធានានូវកម្មសិទ្ធិដីធ្លី គឺជាវិបត្តិមួយដែលតែងតែទាស់ទែងគ្នាពីភាពជាម្ចាស់ និងការប្រើប្រាស់ដី និងវិបត្តិមួយទៀតដោយកម្លាំងពលកម្មធ្វើអន្តោប្រវេសន៍ចូលតំបន់ទីក្រុង ដែលកំណើនប្រជាជន កើនឡើងលើសលប់នៅទីក្រុងថ្លៃដី និងផ្ទះបានកើនឡើង ហើយអ្នកក្រីក្រមិនអាចទទួលបានជំរកសមរម្យ។

---

[៥៥] Ibid (CDRI) ទំព័រទី២៩

[900] រាជរដ្ឋាភិបាល "ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំ លើកទី២(២00១-២00៥)" ទំព័រទី១៥៨

[909] Ibide ទំព័រទី១៥៨ ឬ(ដ.ឯ.ម ទំព័រទី១៥៨)

នៅជនបទគ្រួសារនីមួយៗប្រើប្រាស់ដីធ្លីជាសំខាន់ ដើម្បីធ្វើកសិកម្មសម្រាប់ដោះស្រាយការហូបចុករបស់ខ្លួនឯងផ្ទាល់ និងសម្រាប់ដោះដូរបន្តិបន្តួច គឺពុំមែនសម្រាប់ទីផ្សារធំទូលាយនោះទេ។ ម្យ៉ាងវិញទៀត ដីអាចដាំដុះបានជាច្រើនមិនត្រូវបានគេប្រើប្រាស់ទេ ដោយសារមានការរឹតរក្នុងសង្គម។ ចាប់ពីចុងទសវត្ស ៨០ នៅពេលមានការបន្ធូរច្បាប់គ្រប់គ្រងលើចលនាផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន និងការបើកចំហចំពោះសេដ្ឋកិច្ចទីផ្សារសេរី និងការប្រាស្រ័យទាក់ទងជាមួយអន្តរជាតិលំនាំនៃការប្រើប្រាស់ដីមានការប្រែប្រួលយ៉ាងខ្លាំងនៅតំបន់នានាតាមដងផ្លូវសំខាន់ៗ និងនៅក្បែរទីប្រជុំជន។ ការផ្លាស់ប្តូរបបនយោបាយមានការប្រែប្រួលក្នុងការប្រើប្រាស់ដីធ្លីជាក់ស្តែង គឺបណ្តាលមកពីកំណើនតម្រូវការធនធានដីធ្លី ប្រភពខាងក្រៅសហគមន៍មានជាអាទិ៍បុគ្គល ក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋ។ ការផ្លាស់ប្តូរនិន្នាការប្រើប្រាស់ដីធ្លីធ្វើអោយមានការផ្លាស់ប្តូរទស្សនៈរបស់ប្រជាជនពីរឿងសិទ្ធិខាងដីធ្លី។ តែជាទូទៅនៅទីជនបទក្នុងលក្ខខ័ណ្ឌនៃការដាំដុះជីវចម្រុះ ព្រឹត្តិការណ៍គ្រប់គ្រងដីធ្លីពឹងផ្អែកជាសំខាន់លើការប្រើប្រាស់ដី ជាក់ស្តែងដីបម្រើផលិតកម្មគេធ្វើស្របតាមប្រពៃណី ទំនៀម-ទម្លាប់នៅមូលដ្ឋាន ដោយមិនសូវមានឯកសារជាផ្លូវការ។ ដោយទីផ្សារដីធ្លីមានតម្រូវការខ្ពស់ធ្វើអោយមានការរំលោភពីបុគ្គល ឬក្រុមហ៊ុនមកពីក្រៅសហគមន៍ ឬខាងយោធា ដែលមានធនធាន និងអំណាច។ មួយផ្នែកទៀតប្រជាពលរដ្ឋដែលជាម្ចាស់ដីបានលក់ដីធ្លី ដែលខ្លួនបង្កបង្កើនផល ហើយធ្វើចំណាក់ស្រុកផ្លាស់ប្តូរទីលំនៅនៅទីកន្លែងផ្សេងដោយជួលដីគេធ្វើកសិកម្ម ឬក៏ចូលមកទីក្រុង។ កត្តាទាំងនេះធ្វើអោយបាត់បង់ទិន្នផល កសិផលដែលប្រមូលបានពីដីទាំងនោះ។

ម្យ៉ាងវិញទៀត ស្ថានភាពតួនាទីបុរស-ស្ត្រី ពុំមានលក្ខណៈល្អទេក្នុងការប្រើប្រាស់ដី និងកម្មសិទ្ធិដីធ្លី។ វិសមភាពរវាងបុរស និងស្ត្រីនៅក្នុងលទ្ធភាពមានដី និងមានកម្មសិទ្ធិដីធ្លីកំពុងកើនឡើងគម្លាតរវាងគ្រួសារបុរសមេគ្រួសារ និងគ្រួសារស្ត្រីមេគ្រួសារ។ គ្រួសារ ស្ត្រីមេគ្រួសារគ្រប់គ្រងដីកសិកម្មតូចជាងគ្រួសារបុរសជាមេគ្រួសារ ទោះបីជាកាលដំបូងគ្រួសារទាំងពីរប្រភេទបានទទួលដីពីរដ្ឋក្នុងទំហំដូចគ្នាក្តី។ ក្រោយពេលបែងចែកដីធ្លីនៅចុងទសវត្សរ៍៨០ គ្រួសារស្ត្រីមេគ្រួសារមិនអាចពង្រីកដីកសិកម្មរបស់ខ្លួនដូចគ្រួសារបុរសមេគ្រួសារទេ ដោយសារខ្វះកម្លាំងពលកម្ម និងសត្វអូសទាញ។ ជាទូទៅគ្រួសារស្ត្រីមេគ្រួសារច្រើនងាយរងគ្រោះក្លាយជាអ្នកគ្មានដីធ្លីជាងគ្រួសារបុរសមេគ្រួសារ[១០២]។

បញ្ហាវិបត្តិដីធ្លី និងកើតមានទ្វេថែមទៀតក្នុងករណីគ្មានវិធានការពង្រឹងផ្នែកច្បាប់ និងមន្ត្រីពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន។ ការរៀនសូត្របានតិចតួចរបស់ប្រជាពលរដ្ឋមានចំណែកយ៉ាងធំក្នុងរឿងនេះ និងងាយរងគ្រោះក្លាយជាអ្នកគ្មានដី។ ព្រោះកំណើនប្រជាជនពីមួយថ្ងៃទៅមួយថ្ងៃកាន់តែកើនឡើង និងពួកអ្នកពាក់ព័ន្ធនឹងដីធ្លីនេះក៏កាន់តែមានសកម្មភាពរស់រវើក និងមានរូបភាពខុសៗគ្នាទៅតាមតំបន់ផ្សេងៗ នៃប្រទេសកម្ពុជា។ ដោយតម្រូវការទីផ្សារផលប្រយោជន៍ខាងពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលជំរុញអ្នកជំនួញពួកមន្ត្រីយោធា

[១០២] CDRI "ការវាយតម្លៃបញ្ហាសង្គមកិច្ចពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា" ខែមីនា ឆ្នាំ២០០២ ទំព័រទី២៦"

និងអាជ្ញាធរស៊ីវិល ដែលមានអំណាចខាងហិរញ្ញវត្ថុ និងនយោបាយ ហើយដែលយកចិត្តទុកដាក់ក្នុងការបង្កើនទ្រព្យធនតាមរយៈការរំលោភ និងទិញលក់កេញ្ចកចំណេញ ក៏ដូចជា ការប្រើប្រាស់ដីធ្លីក្នុងលក្ខណៈពាណិជ្ជកម្ម និងជនចំណាកស្រុកជនមាតុភូមិនិវត្តន៍ និងប្រជាជនដាច់ឬសគល់ ដែលផ្លាស់ទីចុះឡើងក្នុងប្រទេសដើម្បីស្វែងរកន្លែងជ្រកកោន និងចិញ្ចឹមជីវិត។ ក្រុមនេះមានកម្លាំងហិរញ្ញវត្ថុ និងនយោបាយតិចតួច ប៉ុន្តែវត្តមានរបស់ពួកគេក៏មានទម្ងន់គួរអោយកត់សម្គាល់ដែរ(ដូចជាសំណង់អនាធិបតេយ្យជាច្រើននៅក្រុងភ្នំពេញ និងតាមទីប្រជុំជនផ្សេងៗទៀត)។

ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗជាច្រើនទៀតដូចជា: អំពើពុករលួយ និងអភិបាលកិច្ចទន់ខ្សោយ បញ្ហាពុករលួយជាបញ្ហាសកលលោកទាំងប្រទេសនោះជាប្រទេសរីកចម្រើន ឬក៏ជាប្រទេសក្រីក្រក៏ដោយ។ ដូចជា ប្រទេសកម្ពុជាបាននឹងកំពុងប្រឈមមុននឹងបញ្ហាដ៏លំបាក ក្នុងការសម្រេចអោយបានជោគជ័យលើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម ដោយសារអំពើពុករលួយជ្រៀតចូល និងចាក់ឬសត្រាំត្រែង ដែលជារបាំងមួយយ៉ាងក្រាស់រារាំងដល់ដំណើរការនេះ។

តាមទស្សនៈទូទៅបានយល់ឃើញថា អំពើពុករលួយ គឺមិនគ្រាន់តែជាការគំរាមកំហែងដល់ស្ថាប័នប្រជាធិបតេយ្យ និងការគោរពសិទ្ធិសារវ័ន្ត និងសេរីភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កអោយមានភាពអន្តរាយដល់ការអភិវឌ្ឍន្តសេដ្ឋកិច្ចសង្គម និងធ្វើអោយប្រជាជនរាប់លាននាក់នៅលើពិភពលោក ក៏ដូចជានៅក្នុងប្រទេសកម្ពុជាដែរកាន់តែក្រទៅៗ។ អំពើពុករលួយអាចនាំអោយមានការសម្រេចចិត្តមិនសមហេតុផល និងរាំងស្ទះដល់ការអភិវឌ្ឍន៍សាធារណៈ និងផ្នែកឯកជន និងមិនអំណោយផលដល់បរិយាកាសសង្គមសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

អំពើពុករលួយ ជាបញ្ហាសំខាន់ដែលមានឥទ្ធិពលអាក្រក់ដល់អ្នកក្រីក្រ ទាំងការជះឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចដោយចីរភាព ចំណូលរបស់រដ្ឋាភិបាល និងទាំងការចំណាយផ្ទាល់ដែលតម្រូវលើគ្រួសារ។ ការស្វែងរកសេវាកម្មអប់រំ សុខាភិបាល និងសេវាសាធារណៈផ្សេងទៀត ដែលមានទម្រង់បង់ថ្លៃឈ្នួលមិនស្របច្បាប់ គឺជាបន្ទុកយ៉ាងធ្ងន់របស់អ្នកក្រីក្រ។ មិនតែប៉ុណ្ណោះអំពើពុករលួយជះឥទ្ធិពលអាក្រក់លើជាតិ និងសង្គមបង្កអោយមានភាពអនាធិបតេយ្យរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និងជារបាំងឧបសគ្គដល់ដំណើរការកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម។

អំពើពុករលួយនាំអោយមានការខាតបង់នូវចំណូលសម្រាប់ថវិកាជាតិ។ ការខ្វះខាតថវិកាជាតិនេះវាបានប៉ះពាល់ទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប៉ះពាល់ទៅលើការរស់នៅរបស់មន្ត្រីរាជការមានកម្រិតទាប ព្រោះការខ្វះខាតថវិកាជាតិពុំអាចជម្រុអោយប្រាក់បៀវត្សប្រចាំខែរបស់មន្ត្រីរាជការកើនឡើងបានទេ។ ម្យ៉ាងទៀតកង្វះថវិកាជាតិនេះ នាំអោយស្ថាប័ន និងក្រសួងបម្រើផលប្រយោជន៍សាធារណៈជនមិនពេញលេញ(សេវាកម្មសាធារណៈទន់ខ្សោយ) មិនបានបំពេញទៅតាមតម្រូវការនៃគោលការណ៍ជារដ្ឋ ដែលមានកាតព្វកិច្ចបម្រើប្រយោជន៍ប្រជាពលរដ្ឋជាធំ។ បច្ច័យអាក្រក់ផ្សេងទៀតទៅលើសង្គមជាតិ គឺអំពើពុករលួយ

ជម្រុញអោយអ្នកមានលុយ អំណាចរំលោភលើច្បាប់រដ្ឋ ដោយបង្កើតនូវប្រព័ន្ធបម្រើនូវវប្បធម៌ខ្មៅកខ្វក់ដូចជា បនល្បែងពាលាអាវ៉ាសែ បនស្រីពេស្យា បនលក់គ្រឿងញៀន ដែលជាសកម្មភាពបំផ្លាញអារ្យធម៌ជាតិ។ ភាពងាយស្រួលក្នុងការរកចំណូលដោយប្រព្រឹត្តអំពើពុករលួយនេះធ្វើអោយជៈឥទ្ធិពលអាក្រក់ដល់ប្រព័ន្ធអប់រំ យុវនិស្សិតខ្មែរយល់ថា ចាំបាច់រៀនធ្វើអ្វីមានចំណេះក៏មិនដឹងយកទៅបម្រើការងារធ្វើអ្វីដែរ បើអ្នកពុករលួយ កិបកេងប្រវ័ញ្ចរកតែមួយម៉ោង ឬមួយថ្ងៃ ប្រហែលអ្នកធម្មតាធ្វើការរយៈពេលមួយជីវិត។ ភាពអយុត្តិធម៌ក្នុងសង្គម ដែលមានមូលហេតុមកពីអំពើពុករលួយនេះហើយ ដែលនាំអោយមានវិបត្តិសង្គមដោយក្នុងខួរក្បាលរបស់ពួកគេគ្មានទេធន្ធៈគ្មានទេផលប្រយោជន៍ជាតិ គឺគេធ្វើយ៉ាងណាអោយតែបំពេញបាននូវមហិច្ឆិតារបស់ខ្លួន។ ហើយក៏មិនអាចអោយសង្គមជាតិយើងមានការលូតលាស់ទៅមុខបានដែរ ដោយអំពើពុករលួយអាចបង្វែរជំនួយ អន្តរជាតិអោយខុសគោលដៅ ដែលបានកំណត់ទុកដោយកាត់បន្ថយប្រសិទ្ធិភាពនៃជំនួយនេះទៀតផង។ អំពើពុករលួយជាប្រព័ន្ធមួយ ដែលអាចជម្រុញអោយកម្រិតជំនួយអន្តរជាតិធ្លាក់ចុះជាពិសេសនៅកន្លែងណាដែលអំពើពុករលួយមានកម្រិតខ្ពស់ប្រទេស និងអង្គការជំនួយកាន់តែចង់កាត់បន្ថយជំនួយ ឬក៏កាត់ជំនួយទាំងស្រុង[១០៣] ដែលជាហេតុកាន់តែធ្វើអោយកិច្ចប្រឹងប្រែងក្នុងការអភិវឌ្ឍន៍សង្គមត្រូវអន្តរាយ។

អំពើពុករលួយ គឺជាការបោកបញ្ឆោត ដែលវាយប្រហារគុណភាពអភិបាលកិច្ច និងស្ថេរភាពជាតិ ដោយធ្វើអោយនីត្យានុកូលភាពនៃដំណើរការនយោបាយដួលរលំ។ អំពើនេះតែតែលើស្ងួយអោយមានការមាក់ងាយដល់សេវាសាធារណៈ និងនាំអោយមានការគិតមិនល្អអំពីជីវភាពនយោបាយ។ អំពើពុករលួយធ្វើអោយប៉ះពាល់ទៅលើកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសជាតិ និងធ្វើអោយខូចខាតដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពអំពើពុករលួយធ្វើអោយមានការគេចពន្ធ និងការបាត់បង់ប្រាក់ចំណូលយ៉ាងច្រើនសម្រាប់រដ្ឋ។ ផ្សំគ្នាជាមួយនឹងចំណាយសាធារណៈខ្ជះខ្ជាយកត្តានេះនាំអោយមានគុណភាពកាន់តែទាប នៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈក្នុងរយៈពេលខ្លី និងផលវិបាកថវិកា និងរូបិយវត្ថុមិនល្អក្នុងរយៈពេលវែង។ អំពើពុករលួយអាចប្រែត្រឡប់ការចំណាយ និងអាទិភាពរបស់រដ្ឋាភិបាល ដើម្បីអោយការចិញ្ចឹមប្រព័ន្ធនេះក្លាយទៅជាអាទិភាពខ្ពស់ជាងប្រយោជន៍សាធារណៈ[១០៤]។ ចំពោះផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច(ពាណិជ្ជកម្ម) យើងឃើញថា នៅទីណាមានអំពើពុករលួយកាន់តែខ្ពស់ តម្លៃដើមទុន និងការវិនិយោគកាន់តែខ្ពស់ធ្វើអោយបាត់បង់ភាពយុត្តិធម៌ ក្នុងការប្រកួតប្រជែងទីផ្សារ ទាំងក្នុងស្រុក និងក្រៅស្រុក។ ការប្រកួតប្រជែងតាមបែបពុករលួយ សំណូកប៉ាន់ធ្វើអោយសាធារណៈជន ឬធុរៈជនបាត់បង់សមត្ថភាព និងអត្ថប្រយោជន៍នៃការប្រកួតប្រជែងទីផ្សារ។ អំពើពុករលួយធ្វើអោយមានការយឺតយ៉ាវដល់វិនិយោគផ្ទាល់ពីបរទេស ឬវិនិយោគផ្ទាល់ក្នុងស្រុក ព្រោះគេបានគិតថា ការចំណាយ

[១០៣] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម: "ការត្រួតពិនិត្យអំពើពុករលួយ" សៀវភៅសម្រាប់សមាជិកសភា (June 2000) ទំព័រទី១៦
[១០៤] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម: "ការត្រួតពិនិត្យអំពើពុករលួយ" សៀវភៅសម្រាប់សមាជិកសភា (June 2000) ទំព័រទី១៦

ទៅលើអំពើពុករលួយ (សូកប៉ាន់) វាជាទម្រង់មួយដូចចំណាយបង់ពន្ធដារដែរ។ ហេតុនេះការវិនិយោគដែលកើតមាន ប្រាកដអាចតម្រង់ខុសទិសដៅសេដ្ឋកិច្ចដោយផលប្រយោជន៍អំពើពុករលួយនេះ។

ចំពោះផលប៉ះពាល់សង្គម គឺវប្បធម៌នៃអំពើពុករលួយធ្វើអោយប្រជាជនរបស់ប្រទេស ខ្វះសីលធម៌ដែលបង្កអោយមានការមិនជឿទុកចិត្តលើរដ្ឋ និងស្ថាប័នរដ្ឋនានា និងនៅក្នុងស្ថានភាពដ៏ធ្ងន់ធ្ងរបំផុត គឺធ្វើអោយរដ្ឋដួលរលំតែម្តង។ អំពើពុករលួយរំលោភលើជំនឿទុកចិត្តរបស់សាធារណៈជន និងធ្វើអោយរិចរិលមូលធនសង្គម។ អំពើនេះបំផ្លិចបំផ្លាញច្បាប់ និងបទបញ្ញានានាដែលប្រើប្រាស់សម្រាប់គោលបំណងសង្គម[១០៥]។ អ្នកក្រខ្វះមធ្យោបាយចូលរួមអោយមានប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការ និងផលប្រយោជន៍ជាសាធារណៈដែលជិតដាបដោយអំពើពុករលួយ។ នៅទីណាដែលកម្មវិធីបានផ្តល់ផលប្រយោជន៍ ដល់ពួកគេត្រូវគ្រប់គ្រងតាមរបៀបពុករលួយអ្នកទទួលផលដែលជាជនក្រីក្របំផុតនឹងគ្មានលទ្ធភាពទទួលបាននូវសេវាសាធារណៈនោះឡើយ។ ចំពោះឥទ្ធិពលនៃអំពើពុករលួយលើផ្នត់គំនិតខ្មែរ គឺភាពអយុត្តិធម៌ក្នុងការបែងចែកធនធាន ដោយមូលហេតុពុករលួយនេះហើយដែលធ្វើអោយភាពក្រីក្រនៅប្រទេសយើងកាន់តែរីករាលដាលបន្តក្នុងសង្គមជាលំដាប់។ ឥទ្ធិពលនៃអំពើពុករលួយនេះបានជិតជាប់ទៅក្នុងគំនិតខ្មែរស្ទើរតែគ្រប់រូបទៅហើយធ្វើអោយខ្មែរបាត់បង់នូវឆន្ទៈ និងមនសិការជាតិ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួនជាធំ។ ហេតុអ្វី? មនុស្សរាល់រូបដែលចាប់កំណើតនៅលើលោកមែងទទួលឥទ្ធិពល ពីការអប់រំ និងបណ្តុះបណ្តាលពីគ្រួសារពីសាលារៀន និងពីសង្គមនីមួយៗ ដែលគេរស់នៅលក្ខណៈទាំងបីនេះ វាពង្រឹងទស្សនៈពង្រឹងអាកប្បកិរិយា និងពង្រឹងចរិតមនុស្សជាបន្តបន្ទាប់នៅក្នុងការរស់នៅក្នុងសង្គម។ តាមទ្រឹស្តីចិត្តវិទ្យា និងសង្គមវិទ្យាផ្នត់គំនិត និងទម្លាប់រស់នៅរបស់មនុស្សរាល់រូបមានការលំបាកនឹងកែប្រែនៅពេលដែលអាយុរបស់បុគ្គលនោះ ចេះតែឈានទៅមុខជាលំដាប់។ យ៉ាងណាមិញទម្លាប់ និងឥទ្ធិពលដែលពួកគេទទួលបានពីសង្គម ដែលមានអំពើពុករលួយនេះធ្វើអោយពួកគេហ៊ានប្រព្រឹត្តអ្វីៗទាំងអស់ដោយមិនគិតពីតម្លៃនៃសីលធម៌ និងកត្តិយសរបស់ខ្លួនឡើយ ដូចមន្ត្រីរាជការបម្រើការងារសាធារណៈ បច្ចុប្បន្នភ្លេចអស់ពីគុណភាពសមត្ថភាពរបស់ខ្លួនក្នុងការអនុវត្តន៍ការងារដោយឥទ្ធិពលនៃអំពើពុករលួយ ធ្វើអោយពួកគេចេះដោយគ្មានត្រូវនូវការគោរពឱនលំទោន សង្គមលុតក្រាប សង្គមអែបអរ ដើម្បបុណ្យស័ក្តិ។ កត្តាខាងលើនេះបានជិតដាមស្ទើរពេញខួរក្បាលកូនខ្មែរ។ ប្រជាពលរដ្ឋខ្មែរស្ទើរក្លាយទៅជាពលរដ្ឋលុតក្រាប ដើម្បីកាន់កិច្ចការអ្វីមួយ ដោយគ្មានគិតពីសមត្ថភាពរបស់ខ្លួន។ ប្រទេសកម្ពុជា បានធ្លាក់ចុះដុនដាបវេទនាដល់សព្វថ្ងៃ ព្រោះតែមនុស្សគ្មានសមត្ថភាពនេះធ្វើការគ្មានស្គាល់កិច្ចការដែលខ្លួនត្រូវធ្វើ គឺចេះតែការឱនលំទោនផ្គាប់ផ្គន់បំពេញមុខថ្នាក់លើ ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ សកម្មភាពរបស់គេ គឺធ្វើការបម្រើថ្នាក់លើជាបុគ្គលមិនមែនបម្រើប្រជាពលរដ្ឋទេ។

---

[១០៥] ដ.ឯ.ម ទំព័រទី១៧

មូលហេតុដែលបណ្តាលអោយប្រទេសកម្ពុជា ស្ថិតនៅក្នុងភាពក្រីក្រមានកត្តាជាច្រើន ដូចបានលើកឡើងខាងលើ តែកត្តាទាំងនោះយើងអាចធ្វើការកែច្នៃក្នុងករណីយើងមានឆន្ទៈមនសិការ និងធនធានគ្រប់គ្រាន់។ រីឯធម៌អំពើពុករលួយជាបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរដល់ដំណើរការអភិវឌ្ឍន៍សង្គម ព្រោះថា បើយើងមានធនធានគ្រប់គ្រាន់ក៏ធនធានទាំងនោះមិនបានធ្លាក់ទៅដល់ដំណើរការ និងកម្មវិធីអភិវឌ្ឍន៍ទាំងស្រុងដែរ ដោយសារការសឹករិចរិល និងចំណាយទៅលើអំពើពុករលួយក្នុងករណីយើងទាំងអស់គ្នាគ្មានឆន្ទៈគ្មានមនសិការ និងខ្វះការចូលរួមនោះ។ អំពើពុករលួយ ជាមូលហេតុយ៉ាងសំខាន់ ដែលបង្កអោយភាពក្រីក្រក្នុងសង្គមកាន់តែធ្ងន់ធ្ងរឡើងៗ ហើយក៏ជាឧបសគ្គយ៉ាងសំខាន់ណាស់ដល់ដំណើរការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម។

របាំងឧបសគ្គទាំងឡាយ ដែលកើតមាននៅក្នុងសង្គមកម្ពុជាខាងលើនេះ គឺបណ្តាលមកពីមេរោគសង្គមដ៏សាហាវ គឺអំពើពុករលួយក្នុងសង្គម។ អំពើពុករលួយវាមិនត្រឹមតែធ្វើអោយមានភាពអយុត្តិធម៌នៅក្នុងសង្គមប៉ុណ្ណោះទេ វាបង្កអោយមានអភិបាលកិច្ចមិនសមស្រប និងរំខានដល់ការអភិវឌ្ឍន៍របស់ផ្នែកឯកជន និងសង្គមជាតិ។ អំពើពុករលួយទោះមានទំហំធំក្តី តូចក្តីវាចោទជាបញ្ហាគំរាមកំហែងមិនមែនចំពោះតែស្ថាប័នប្រជាធិបតេយ្យ និងសិទ្ធិជាមូលដ្ឋាន ឬសេរីភាពទូលំទូលាយនោះទេ ប៉ុន្តែវាកំពុងជីកឬសជីកគល់នៃការអភិវឌ្ឍន៍ និងធ្វើអោយមានភាពក្រីក្រកាន់តែធ្លាក់ជ្រៅទៅៗសម្រាប់មនុស្សរស់នៅក្នុងសង្គមទាំងមូល។

ដូចនេះ ដើម្បីអោយដំណើការអភិវឌ្ឍន៍ និងកាត់បន្ថយបាននូវភាពក្រីក្រនៅក្នុងសង្គមកម្ពុជា យើងគួរតែលុបបំបាត់ប្រឆាំងនឹងអំពើពុករលួយនៅក្នុងសង្គមដោយយើងបង្កើតនូវគំនិតជាតិនិយម។ គំនិតជាតិនិយមយ៉ាងដូចម្តេច? រដ្ឋាភិបាល និងប្រជាពលរដ្ឋត្រូវការចូលរួមដោយយកគំនិតជាតិជាធំដោយគិតពីបញ្ហាសង្គមបញ្ហាសេដ្ឋកិច្ច ដែលត្រូវដោះស្រាយទៅថ្ងៃមុខ។ យើងត្រូវពិចារណា និងអនុវត្តនយោបាយសេដ្ឋកិច្ចរបៀបណាដើម្បីអោយប្រជាពលរដ្ឋមានជីវភាពគ្រប់គ្រាន់ និងធ្វើអោយប្រទេសជាតិឆាប់រុងរឿង និងរៀបចំនយោបាយសង្គមបែបណា ដើម្បីអោយប្រជាពលរដ្ឋមានការងារធ្វើ និងកុំអោយមានភាពអនាធិបតេយ្យ លុបបំបាត់នូវការិយាល័យនិយម ដែលជាឫសគល់នៃអំពើពុករលួយ។ នេះហើយគំនិតជាតិនិយម ក្នុងការកសាងប្រទេសជាតិ។

វិបត្តិសេដ្ឋកិច្ច និងអំពើពុករលួយជាវិបត្តិសង្គមមួយយ៉ាងធ្ងន់ធ្ងរ ដែលធ្វើអោយបាត់បង់ភាពម្ចាស់ការដូចជា វិបត្តិខាងលើនេះបានធ្វើអោយកម្ពុជាធ្លាក់ចុះចូលទៅក្នុងស្ថានភាពក្រីក្ររហូតដល់បច្ចុប្បន្ន។ ទុក្ខវេទនារបស់ប្រជាពលរដ្ឋជាបន្តបន្ទាប់ដោយសារវិបត្តិនេះធ្វើអោយប្រជាជន និងសង្គមស្ថិតនៅក្នុងភាពក្រីក្រ។ បញ្ហាសង្គមបានកើតមានឡើងដោយជនមានអំណាច និងបុណ្យស័ក្តិមួយចំនួនបានឆ្លៀតឱកាសពេលសង្គមជួបនូវវិបត្តិបានប្រព្រឹត្តអំពើកេងប្រវ័ញ្ចពុករលួយ បង្កភាពអនាធិបតេយ្យ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន បក្សពួកខ្លួន។ មិនតែប៉ុណ្ណោះ ដូចជា វិបត្តិអត់ការងារធ្វើបានកើតឡើង សង្គមជួបប្រទះនូវវិបត្តិដ៏ធ្ងន់ធ្ងរមួយនៃការធ្លាក់ចុះកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងប្រទេស។ មនុស្ស ដែលរស់នៅក្នុងកម្រិតជីវភាពមិនគ្រប់គ្រាន់ងាយទទួលរងនូវហានិយភ័យកម្រិតខ្ពស់ដូចជា បញ្ហាសុខភាព និងការអូសទាញផ្សេងៗទាំងផ្លូវល្អ និងផ្លូវអាក្រក់ ដែលជាហេតុធ្វើអោយមានការប្រាស់ចាកពីក្រមសីលធម៌សង្គម។ ភាពក្រីក្រ និងការស្រេកឃ្លានជាប្រចាំនោះបង្កអោយមានអ

ស្តេរភាពសង្គមតាមរយៈការបង្ខំចិត្តអោយមនុស្សប្រព្រឹត្តនូវអំពើពេស្យាចារ អំពើពុករលួយទាំងកម្រិតទាប និងកម្រិតខ្ពស់ និងអំពើចោរកម្ម(លួច ឆក់ ប្លន់ កាប់សម្លាប់មនុស្សដូចជាសត្វធាតុ)ជាដើម។

ដូច្នេះ ឥទ្ធិពលនៃវិបត្តិខាងលើនេះ ធ្វើអោយសង្គមជាតិមានភាពច្របូកច្របល់ បង្កអស្ថេរភាព រាំងស្ទះដល់ដំណើរប្រព្រឹត្តទៅរបស់សង្គម។ ដើម្បីស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិអោយមានភាពរុងរឿងថ្កុំថ្កើន និងបញ្ចៀស ឬប្រឆាំងនឹងវិបត្តិខាងលើនេះ ដើម្បីចូលរួមកាត់បន្ថយនូវភាពក្រីក្រ ហើយទាំងអស់គ្នា ដែលជាប្រជាពលរដ្ឋ និងជាពិសេសអ្នកដឹកនាំរដ្ឋាភិបាលត្រូវបង្កើតអោយមានឆន្ទៈ និងមនសិការជាតិធំជាងប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួករបស់ខ្លួន។

៤.១.២ មូលហេតុនៃសង្គម

បញ្ហាអភិរក្សនិយមសង្គមខ្មែរយើងឃើញថា ទោះបីជាមានដំណើរប្រែប្រួលជាប្រវត្តិសាស្ត្រយ៉ាងណាក៏ដោយ ក៏សង្គមខ្មែរហាក់ដូចជាមិនសូវកម្រើកខ្លួនសោះតាំងពីច្រើនសតវត្សមកហើយ។ រួចតម្លាក់អប្សរ ដែលញញឹមនៅអង្គរ និងភាពរួសរាយរបស់ស្ត្រីកសិករសព្វថ្ងៃ បើគិតពីទម្រង់លក្ខណៈដែលមាន គឺនៅតែមានសភាពដូចយ៉ាងច្រើន។ ព្រះពុទ្ធសាសនា ដែលតាំអោយមានឡើងជាច្រើនសតវត្សមកហើយនោះនៅតែជាសាសនារបស់ជាតិដដែល ហើយអារក្សអ្នកតាមបានរក្សាតួនាទីដ៏ប្រសើរមួយដូចពីដើម។ ភាសាខ្មែរនៅតែជាភាសាជាផ្លូវការ ការធ្វើស្រែចំការបានរួមបង្កជាសកម្មភាពដ៏សំខាន់បំផុតរបស់ប្រជាជនភាគច្រើន។ ប្រជាជននៅតែមានជំនឿពឹងពាក់ទៅលើព្រះមហាក្សត្រ ដែលជាប្រមុខរដ្ឋ ដើម្បីជួយរកយុត្តិធម៌ និងគ្រប់គ្រងរបស់ពួកគេថែមទៀត។ ការគោរពខ្លាចក្រែងបុគ្គលមន្ត្រីរាជការតាមឋានានុក្រមបុណ្យស័ក្តិបានកើតមាននៅគ្រប់ទីកន្លែង។ ការចូលចិត្តរៀបឬកភាពសម្បើម ដែលជាចរិកលក្ខណៈរបស់មន្ត្រី ឬអ្នកមានអំណាចទាំងឡាយសព្វថ្ងៃនេះបានស្ថិតនៅក្នុងចំណោមបុគ្គលជាច្រើនជាពិសេសពួកអ្នកទីក្រុងផងដែរ ដែលខ្វល់ខ្វាយតែពីរឿងបង្កើតទ្រព្យសម្បត្តិរបស់ពួកគេជានិច្ច ហើយគិតយ៉ាងម៉េចអោយតែលើសអ្នកជិតខាងរបស់ខ្លួន។

ពិតហើយចំណែកឯប្រជាកសិករនៅតាមជនបទ ស្រែចំការពួកគេខ្វាយខ្វល់តែពីបញ្ហាអាកាសធាតុ ដូចជាការបន់ស្រន់អារក្សអ្នកតា ឬរកព្រះមហាក្សត្រអោយជួយធ្វើពីធីបួងសួង និងពិភាល់ថាអ្វីៗ និងរៀបរយស្រួលបួលទៅតាមដំណើររបស់វាតែប៉ុណ្ណោះ។ ព្រោះថាភាពមិនទៀងទាត់នៃអាកាសធាតុបានរំខាងដល់ការប្រមូលផលដំណាំរបស់ពួកគេ។ ពួកគេបានបណ្តោយខ្លួនក្នុងការរស់នៅ ដោយរស់នៅតាមរបៀបរកមួយថ្ងៃស៊ី-មួយថ្ងៃ ប្រជាកសិករទាំងឡាយពេញចិត្ត និងធ្វើស្រែតែមួយរដូវតែប៉ុណ្ណោះក្នុងមួយឆ្នាំ ដោយទុកពេលវេលាសម្រាប់កំសាន្តសប្បាយយ៉ាងច្រើន។ ការងារដែលនឿយហត់ជាងគេរបស់គាត់ គឺធ្វើដោយដៃដូចជា ការធ្វើស្រែចំការ ភ្ជួររាស់ សាបព្រោះ ដកស្ទូង ជម្រះស្មៅ និងច្រូតកាត់ ដែលជាទម្លាប់របស់ពួកគាត់។

ពួកគាត់មិនសូវមានគំនិតច្នៃប្រឌិតខ្ពស់អោយមានលក្ខណៈវិទ្យាសាស្ត្រប៉ុន្មានទេ ព្រោះកេមានជំនឿតៗគ្នាពីដូនតារបស់ពួកគេមក។ គេមិនសូវអោយតម្លៃទៅលើការអប់រំក្នុងសម័យទំនើប ដែលមានលក្ខណៈវិទ្យា-

សាស្ត្រ កូនចៅមិនសូវរៀនសូត្របានចេះដឹងជ្រៅជ្រះទេ ព្រោះថាកូនចៅអោយរៀនចេះដឹងជ្រៅជ្រះជាកត្តាដែលធ្វើអោយពួកគាត់ពិបាកធ្វើការប្រៀនប្រដៅ។ ជំងឺឈឺថ្កាត់គេមានជំនឿទៅលើអារក្សអ្នកតា គ្រូម៉ៅបុរាណ អបិយជំនឿ និងការសែនប្រេន មិនសូវមានជំនឿទៅលើវិធីព្យាបាលដែលមានលក្ខណៈវិទ្យាសាស្ត្រទេ។ មិនតែប៉ុណ្ណោះ ពាក្យសុភាសិតខ្មែរ "នំមិនធំជាងនាល" នៅតែមានប្រជាប្រិយភាពនៅឡើយ គេច្រើនប្រើអំណាចផ្តាច់ការទៅតាមចំណង់ចំណូលចិត្តឪពុកម្តាយភាគច្រើនមិនបានទុកអោយកូនចៅធ្វើការពិចារណា ដើម្បីការរស់នៅ និងកសាងអនាគតដោយខ្លួនគេទេ គេច្រើនមានគំនិតកេរ្តិ៍ដំណែលពីឪពុកម្តាយ ឬពីដូនតា។ កត្តានេះមានលក្ខណៈល្អប្រសើរ ម្យ៉ាងដែរដែលពួកគាត់រក្សាបាននូវទំនៀមទម្លាប់ប្រពៃណីរបស់ពួកគាត់ តែបើប្រៀបធៀបមកសម័យវិទ្យាសាស្ត្រជឿនលឿននាបច្ចុប្បន្នឃើញថា ទង្វើនេះមានលក្ខណៈអន់ថយខ្វះភាពអ្វីដែលថ្មី ហើយប្លែកមានលក្ខណៈវិទ្យាសាស្ត្រសម្រាប់អភិវឌ្ឍន៍ដំណើរជីវិត និងសង្គមបានឡើយ។

ការអប់រំកូនចៅនៅក្នុងសង្គមគ្រួសាររបស់ខ្មែរច្រើននិយាយថា ការសន្សំសុខប្រសើរជាការសន្សំរឿង ពាក្យនេះ បើយើងធ្វើការពិចារណាទៅឃើញថា ល្អណាស់សម្រាប់ពូជពង្សខ្មែរដែលមានអរិយធម៌ខ្ពង់ខ្ពស់ គឺនេះជាគំនិតបង្កើតសន្តិភាព។ ម្យ៉ាងទៀតការអប់រំដែលបង្ខិតបង្ខំកូនខ្មែរអោយបំបាត់ចោលនូវការសម្រេចចិត្តរបស់យុវជនរួមទាំងគំនិតផ្តួចផ្តើមទាំងអស់។ អាកប្បកិរិយា និងទម្លាប់ផ្សេងៗ ដែលមាននៅក្នុងសង្គមរបស់យើងដែលកំពុងបំផ្លិចបំផ្លាញបុគ្គលម្នាក់ៗ និងកិនកំទេចគំនិតផ្តួចផ្តើមនោះបានបណ្តាលអោយមានជាអចិន្ត្រៃយ៍នូវរោគភ័យខ្លាចមួយ ការខ្វះជំនឿទុកចិត្តលើខ្លួនឯង និងការគេចជៀសមួយនៅមុខការទទួលខុសត្រូវផ្សេងៗ។ ពួកគេបានត្រូវជម្រុញអោយធ្វើតាមប្រតិកម្មរហ័សដូចសត្វខ្យងហៀន ដែលស្ថិតនៅត្រង់ថា ម្នាក់ៗត្រូវចេះសម្ងំនៅក្នុងសម្បករបស់ខ្លួនដូចសត្វខ្យង ដែលវាលឺបខ្លួននៅក្នុងសម្បករបស់វាដៃរសម្រាប់ហេតុផលសន្តិសុខ និងហេតុផលផ្សេងៗទៀត។ ភាគច្រើនគេមិនបានពន្យល់ហេតុផលអ្វីទាំងអស់ប្រាប់ក្មេងទេ បើសិនជាវាប្រព្រឹត្តកំហុសអ្វីមួយវាច្បាស់ជាទទួលការវាយគូថនឹងរំពាត់។ អ្វីដែលជាចិត្តសាស្ត្រ គឺពុំសូវមាននៅក្នុងគំនិតរបស់ប្រជាជនខ្មែរឡើយ ដូចជាម្តាយម្នាក់មិនខំប្រឹងស្វែងយល់ពីបញ្ហាផ្សេងៗនៅខាងក្នុងផ្លូវចិត្តដែលមានភាពជាដើមហេតុធ្វើអោយក្មេងប្រព្រឹត្តអំពើអ្វីមួយទេ ប៉ុន្តែបែរជាយល់ថា គឺហេតុផលផ្សេងផ្នែកខាងក្រៅវិញ ដែលអាចបង្កអោយវាប្រព្រឹត្តការទម្លាប់ទាំងនេះដែលជ្រួលជ្រាបយ៉ាងជ្រៅ និងដែលរីករាលដាលនៅក្នុងព្រំដែនយ៉ាងធំមួយបានបង្ហាញអោយឃើញពីការខ្វះមតិរិះគន់ ដែលជាលក្ខណៈពិសេសបំផុតនៅប្រទេសកម្ពុជា រួមទាំងនៅក្នុងមជ្ឈដ្ឋានបញ្ញាវ័ន្តណាមួយដែលតាំងពីពួកខាងលិចបានស្គាល់របាំងនេះមក។ ការគួរសម ការញញឹមរាក់ទាញ ដែលយើងអោយតម្លៃយ៉ាងត្រឹមត្រូវថា ជាការទាក់ទាញនោះ គឺវាពុំទាក់ទងនឹងការបើកទ្វារមួយឡើយ។ ការអៀនប្រៀននការលាក់គំនិតពុំមែនជាសញ្ញានៃភាពទន់ភ្លន់ និងមានសុជីវធម៌នោះទេវាជាប្រការមួយដែលបានអូសទាញអោយការអភិវឌ្ឍន៍ដើរថយក្រោយមិនដឹងខ្លួន។

សង្គមកម្ពុជាបានឆ្លងកាត់មួយជំហានបន្ថែមទៀត សង្គមនោះបានឆ្លៀតយកប្រយោជន៍អំពីព្រះពុទ្ធសាសនា ដើម្បីធ្វើអោយឧត្តមភាពក្នុងឋានៈជាមន្ត្រីតែតែរឹងប៉ឹងឡើង ដោយហេតុថា តាមប្រជាជនខ្មែរយល់ថា

តង្វាយទាំងឡាយនឹងនាំអោយអ្នកធ្វើអំណោយបាននូវកុសលផលបុណ្យផ្សេងៗ ដែលសមស្របទៅនឹងសារៈសំខាន់របស់វា។ ប្រការនេះបានធ្វើអោយព្រះពុទ្ធសាសនាប្រាស់ចាកពីការពិតហើយ។

សម្រាប់ការរស់នៅរបស់ប្រជាជនខ្មែរបានពឹងផ្អែកទៅលើកម្លាំងអធិជំនឿ និងកម្លាំងដែលមើលមិនឃើញដូចជា អារក្ស-អ្នកតាជានិច្ចព្រោះពួកគេយល់ថា ភូតបិសាចទាំងនោះជាអ្នកដឹកនាំការប្រព្រឹត្តរបស់ពួកគេ ហើយគេមានជំនឿក្នុងចំណោមអារក្ស-អ្នកតា ដែលចូលចិត្តធ្វើល្អ ឬធ្វើអាក្រក់ គឺអាចជាក់ទណ្ឌកម្មមនុស្សទាំងអស់បើសិនជាគេមិនគោរពបូជា។ ដោយហេតុនេះនៅក្នុងផ្នត់គំនិតប្រជាជនខ្មែរ នៅតែយកចិត្តទុកជាក់មិនធ្វើអោយភូតបិសាចទាំងនោះខឹងសម្បាឡើយ។ ពួកគេត្រូវចែករំលែកម្ហូបអាហាររបស់ខ្លួនសែនអារក្ស-អ្នកតា មុននឹងពួកគេចាប់ផ្តើមការងារធ្វើស្រែ ឬមុនពួកគេចូលព្រៃ។ ពួកគេត្រូវលៀងអារក្ស-អ្នកតា ដែលទទួលខុសត្រូវជំងឺខ្លះៗជារៀងរាល់ឆ្នាំ ព្រោះពួកគេយល់ថា ជំងឺឈឺថ្កាត់របស់ខ្លួនដោយសារការមិនគោរពបូជាអារក្ស-អ្នកតាទាំងនោះ។

តួនាទីរបស់ហោរាសាស្ត្រ នៅតែមានឥទ្ធិពលនៅទីក្រុងភ្នំពេញ ក៏ដូចជានៅតាមជនបទផ្ទាយៗដែរ។ ដូចជា ក្នុងរឿងប្រវត្តិសាស្ត្រមួយចំនួន ព្រះរាជវង្សានុវង្សតែងតែសាកសួរយោបល់ពួកហោរាព្រះបរមរាជវាំងជានិច្ចមុននឹងប្រតិបត្តិការងារអ្វីមួយ ឬមុននឹងយាងទៅណាមកណាម្តងៗ។ មិនខុសអ្វីពីប្រជាជនខ្មែរដែលមានជំនឿភាគច្រើនបច្ចុប្បន្ននោះទេ គឺពួកគេមុននឹងចេញដំណើរទៅណាមកណាទៅចាំរើសថ្ងៃមាននក្ខត្តឫក្សល្អ ព្យាករណ៍ដោយហោរាសាស្ត្រជាដរាប។

សរុបសេចក្តីទៅ ជំនឿមើលមិនឃើញទាំងនេះជាអភិរក្សមួយ ដែលមានលក្ខណៈអន់ថយជាទីបំផុតសម្រាប់សង្គម និងសម្រាប់ជីវភាពរស់នៅរបស់ប្រជាជនខ្មែរ។ ជំនឿអរូបីយ៍ទាំងនេះ ជាកត្តាធ្វើអោយមានការចំណាយធនធាន និងខាតបង់ពេលវេលា។

ការជិះជាន់ផ្នែកសេដ្ឋកិច្ច និងតម្រូវការលុយដែលមិនផ្លាស់ប្តូរបានលើកឡើងព្រមគ្នាជាមួយការបានមកនូវអំណាចមួយទ្រព្យសម្បត្តិមួយ ដែលនៅលោកខាងលិចគេអោយតម្លៃតិចតួចបំផុត។

ការចំណាយយ៉ាងច្រើនរបស់ព្រះមហាក្សត្រ ដើម្បីធ្វើអោយកិត្យានុភាពរបស់ព្រះអង្គមានជាស្តាពរតទៅ ការគ្មានប្រជាប្រិយ និងការប្រព្រឹត្តអបាយមុខរបស់ព្រះអង្គម្ចាស់ទាំងឡាយ ដែលរស់នៅដោយសារតង្វាយ ការឆ្លៀតធ្វើអាជីវកម្មលើប្រជាពលរដ្ឋដោយពួកមន្ត្រីធំៗ (សំដីរបស់លោក អែម៉ូនីញ៉ា(E.Aymonnier) ជាអ្នកខ្មែរនិយមដ៏ល្បីល្បាញនៅឆ្នាំ១៨៧៤)[១០៦]។ នៅឆ្នាំ១៨៧៥ អ្នកប្រវត្តិវិទ្យាម៉ូរ៉ា(J.Moura) ដែលជាអ្នកស្រឡាញ់ខ្មែរបានកត់សម្គាល់ថា "នៅពេលនេះអ្វីៗដែលនាំអោយបង់ខាតសម្រាប់ប្រទេស គឺបរិមាណមន្ត្រីរាជការយ៉ាងច្រើនឥតគណនា ឬពួកមន្ត្រីដែលមានតែឋានៈ ប៉ុន្តែពុំមានមុខតំណែងពិតប្រាកដហើយដែលទាញយកផលប្រយោជន៍ពីប្រជាជនដោយរបៀបមួយដែលអាស្រូវយ៉ាងខ្លាំង។ ចំនួនអ្នកបម្រើការងារត្រូវតែកាត់បន្ថយទៅតាម

[១០៦] MARIE ALEXANDRINE MARTIN: "ជំងឺកម្ពុជា" ទំព័រទី២០ ("LE MAL CAMBODGIEN" HISTOIRE D'UNE SOCIETE TRANDITIONNELLE FACEASES LEADERS POLITIQUE 1946-1987) Page 20.

ភាពចាំបាច់ប្រាកដប្រជាពួកគេនឹងត្រូវអោយប្រាក់ឈ្នួល ហើយច្បាប់ថ្មីៗនេះនឹងត្រូវរៀបចំឡើង ដើម្បីលុបបំបាត់ការកែបន្លំ[១០៧]។

នាហ្នឹនជាន់ខ្ពស់នៃរដ្ឋបាលខ្មែរ ក្នុងរបបគ្រប់គ្រងដោយបារាំងជាច្រើនពឹងផ្អែកលើអំណាច និងកិត្យានុភាពបារាំងបានបិទភ្នែកចំពោះសកម្មភាពរបស់បារាំងដែលគាបសង្កត់មកលើប្រជាពលរដ្ឋខ្មែរ ហើយពួកគេចាប់ផ្តើមប្រព្រឹត្តអំពើទាំងឡាយទាក់ទងនឹងការសំណូកសូកប៉ាន់ ដែលបានក្លាយទៅជាជំងឺសង្គមដ៏ធ្ងន់ធ្ងរក្នុងប្រទេស។ ពួកនាហ្នឹនពុករលួយក្នុងសម័យនោះមិនគ្រាន់តែស៊ីសំណូកសូកប៉ាន់ ដើម្បីធ្វើអ្វីមួយនោះគ្រាន់តែសុំបោះត្រាលើឯកសារ ឬសំណុំរឿងក៏ទាមទារអោយបង់កម្រៃដែរ[១០៨] នេះជាអំពើពុករលួយសង្កត់កប្រជាពលរដ្ឋខ្មែរនាសម័យនោះ ហើយនេះជាទម្លាប់របស់ប្រទេសមានអំណាច ដែលបានជាក់អាណានិគមលើប្រទេសទន់ខ្សោយ។

"ប្រាក់ទឹកតែ" គឺជាច្បាប់ទម្លាប់មួយនៅក្នុងប្រទេសកម្ពុជាដូចជា ពាក្យទំនៀមមួយរបស់ខ្មែរបានដៅអោយយើញពីរឿងនេះដែរ "មាត់ហោប៉ៅអាវតែងតែឡើងលើជានិច្ច មិនដែលមានអ្នកណាដេរហោប៉ៅចុះក្រោមទេ" ម្នាក់ៗគេសង្ឃឹមទទួលបានអ្វីមួយជាដរាបក្នុងករណីផ្សេងៗ ដែលគេជួយសម្រួលអោយបានសម្រេចដែលជាប្រាក់រង្វាន់មួយសម្រាប់ជាគុណប្រយោជន៍ផ្ទាល់របស់ខ្លួន ដូចជា ការប្រាក់ដែលបានមកពីមូលនិធិធនាគារដែលគេយកទៅធ្វើការចងការបន្តទៅទៀត។

វាគ្មានអ្វីគួរអោយភ្ញាក់ផ្អើលឡើយ ដែលគេបង្កេតឃើញនៅសម័យទំនើបនេះទំនាក់ទំនងផ្សេងៗរបស់ប្រជាជនខ្មែរជាមួយនឹងរដ្ឋ គឺពោរពេញទៅដោយលក្ខណៈបក្ខពួកនិយម។ លក្ខណៈបក្ខពួកនិយម ដែលមានសភាពក្រាសឃ្មឹកនេះហើយដែលធ្វើអោយស្រអាប់ដល់សកម្មភាពផ្នែករដ្ឋបាល និងសង្គមកិច្ចរបស់កម្ពុជាគ្រប់លំដាប់ថ្នាក់ និងគ្រប់សម័យកាល។

អំពើពុករលួយ ជាបញ្ហាសំខាន់ដែលមានឥទ្ធិពលអាក្រក់អ្នកក្រ ទាំងការជះឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចដោយចីរភាពចំណូលរបស់រាជរដ្ឋាភិបាល និងទាំងការចំណាយផ្ទាល់ដែលតម្រូវលើគ្រួសារ។ ការស្វែងរកសេវាកម្មអប់រំ និងសុខាភិបាល ដែលមានទម្រង់ថ្លៃឈ្នួលមិនសមស្រប(តម្លៃថ្លៃ) គឺជាបន្ទុកយ៉ាងធ្ងន់ធ្ងររបស់អ្នកក្រ។ អ្នកក្រក៏ជាអ្នករងគ្រោះពីការធ្វើអាជីវកម្មឈើខុសច្បាប់ ដែលបំផ្លាញព្រៃឈើជាធនធានរបស់សហគមន៍ និងរងគ្រោះពីការបែងចែកប្រភពធនធានដលផលដោយអត្តនោម័ត និងទាញយកផលប្រយោជន៍ដល់អាជីវកម្ម។ ការទទួលអារម្មណ៍ថា អ្នកក្រគ្មានសិទ្ធិអំណាច គឺកើតមាននៅពេលដែលសង្គមមិនបានផ្តោតការយកចិត្តទុកដាក់ទៅលើគនេះឯង។ គុណភាពរដ្ឋបាលសាធារណៈមានកម្រិតទាបពិសេសនៅថ្នាក់

---

[១០៧] Ibid Page 21.

[១០៨] ហេង ហុង "ឱ! លោកធំខ្មែរ" ទំព័រទី២២

ខេត្ត ដែលត្រូវផ្តល់សេវាកម្មមូលដ្ឋានសម្រាប់អ្នកក្រ ហើយជាថ្មីទៀតអ្នកក្របានឃើញពីតួនាទីគ្មានតម្លៃរបស់គេដោយខ្លួនគេផ្ទាល់។

អំពើពុករលួយនេះ ជាជំងឺមហារីរបស់សង្គម។ ជំងឺនេះវាធ្វើអោយមានការបាត់បង់នូវថវិការដ្ឋ ដែលជាកត្តាសំខាន់ខាងផ្នែកហិរញ្ញវត្ថុសម្រាប់ការស្តារ និងកសាងប្រទេសអោយមានការរីកចម្រើនទៅមុខក្នុងការលើកកម្ពស់ជីវភាពរបស់ប្រជាជន។ នៅក្នុងសង្គមជាតិមួយដែលប្រជាពលរដ្ឋ ក៏ដូចជាមន្ត្រីរាជការមានចំណូលកម្រិតទាប ដែលមិនបំពេញបានតាមតម្រូវការជីវភាពប្រចាំថ្ងៃ និងអ្នកមានអំណាចនិយមប្រើអំណាចជាងការអនុវត្តន៍ច្បាប់ អំពើពុករលួយបានក្លាយទៅជាសកម្មភាពមួយធម្មតារបស់ពួកគេ។ អំពើពុករលួយនាំអោយមានការខាតបង់នូវចំណូលថវិកាជាតិ នេះហើយដែលធ្វើអោយមានផលប៉ះពាល់ទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ ពិសេសទៅលើជីវភាពការរស់នៅរបស់មន្ត្រីរាជការកម្រិតទាប។ មានភាពអយុត្តិធម៌ក្នុងការបែងចែកធនធានដោយមូលហេតុពុករលួយនោះ ហើយដែលធ្វើអោយភាពក្រីក្រនៅប្រទេសយើងកាន់តែរីករាលដាលក្នុងសង្គមជាលំដាប់ រហូតមកដល់បច្ចុប្បន្ន។ សកម្មភាព និងទម្លាប់អំពើពុករលួយនេះជាប្រភពជំងឺមួយយ៉ាងធ្ងន់ធ្ងរដែលជាហេតុធ្វើអោយជំងឺនៃភាពក្រីក្រធ្លាក់ដុនដាប់កាន់តែខ្លាំងឡើងៗនៅក្នុងប្រទេសកម្ពុជាយើង។

ប្រការគួរអោយពិចារណាប្រជាពលរដ្ឋកម្ពុជាសម័យនេះត្រូវតែនាំគ្នាគិតគូរធ្វើយ៉ាងណា ដើម្បីកុំអោយប្រវត្តិសាស្ត្រនិយាយតែពីរឿងអ្នកដឹកនាំខ្មែរ ដណ្តើមតែអំណាចគ្នាប្រាប់កូនចៅជំនាន់ក្រោយៗតទៅទៀត ព្រោះវាគ្មានបានចំណេញអ្វីបន្តិចណាសោះសម្រាប់ប្រជាជាតិរបស់ខ្លួន។ បញ្ហាដែលគួរអោយចាប់អារម្មណ៍ គឺភាពមិនត្រឹមត្រូវមួយ ដែលជាគំរូអាក្រក់នានានៃជំនាន់អវិជ្ជាទាំងឡាយ មិនត្រូវបានលើកយកមកនិយាយអោយមនុស្សជំនាន់នោះដឹងឮនោះ។ ជាការពិតបញ្ហានេះត្រូវបានគេប្រើប្រាស់ច្រើនរបបមកហើយ និងបច្ចុប្បន្នក៏នៅតែប្រើវិធីនេះទៀត ដើម្បីបង្ហាញថាខ្លួនគ្រាន់បើជាងគេ។ ទម្លាប់ចោទជាក់គ្នាពីមួយទៅមួយនៅតែមានបន្តមិនចេះចប់ ដូចជា ជំនាន់សាធារណៈរដ្ឋខ្មែររបស់ លន់ នល់ គេបានចោទសម្តេចព្រះនរោត្តម សីហនុ លក់ដីអោយយួនខាងជើង[១០៥]។ ពេលក្រុមខ្មែរក្រហមឡើងកាន់អំណាចក្រោយពេលធ្វើសង្គ្រាម ៥ឆ្នាំ បានបន្ទោសរបបសក្តិភូមិនិងមូលធននិយមខ្មែរក្រហមជារបបដែលខ្មែរគ្រប់រូបបានថ្កោលទោសថា ជារបបប្រល័យពូជសាសន៍កាប់សម្លាប់ប្រជាជាតិខ្លួនមិនរើសមុខ[១១០]។ សម្រាប់ខ្មែរពីរបបមួយទៅរបបមួយមិនបានធ្វើការស្ថាបនាអភិវឌ្ឍន៍សង្គមជាតិទេដូចជា ការជិះជាន់ដែលអ្នកមានអំណាច និងអ្នកមានទ្រព្យធននៅតែមានអំពើអយុត្តិធម៌ក្នុងសង្គមនៅតែមិនអាចកែកុនអ្វីកើអំពើពុករលួយនៅតែបន្តចាក់គ្រឹះក្នុងសង្គម និងយ៉ាងចេញមុខថែមទៀត។ ជារួមប្រជាកសិករ និងកម្មករខ្មែរនៅតែក្រីក្រ ដែលនឹងកាន់តែយ៉ាប់យឺនថែមទៀ។

[១០៥] ការសែតកោះសន្តិភាព អត្ថបទ "គំនិតដដែលៗ" លេខ៤៨០៥ ថ្ងៃពុធ ទី០៧ ខែឧសភា ឆ្នាំ២០០៣ ទំព័រទី២

[១១០] Ibid Page 2.

ក្នុងប្រវត្តិសាស្ត្រមានចំណុចល្អ និងចំណុចមិនល្អតែរាល់សកម្មភាព និងទម្លាប់របស់អ្នកនយោបាយខ្មែរ កម្រទទួលស្គាល់ចំណុចល្អនៃប្រវត្តិសាស្ត្រណាស់ ផ្ទុយទៅវិញបែរជានាំគ្នាបំផ្លើសលើចំណុចមិនល្អបន្ថែមទៀត ធ្វើអោយកាន់តែមើលឃើញភាពខ្មៅងងឹត ប៉ុន្តែអ្វីដែលអ្នកជំនាន់ក្រោយអួតអាងថា អ្នកជំនាន់មុនមានកំហុសបែបនេះ ឬបែបនោះបែរជាមិនលុបបំបាត់តែបានដើរជាន់ជានចាស់ដដែល បំភ្លេចអស់ពីកំហុសដែលនាំអោយកើតមានវិបត្តិក្នុងសង្គម។

សរុបមក ទម្លាប់នៃការទម្លាក់កំហុសដាក់គ្នា ដើម្បីយកប្រៀបខ្លាំង និងប្រៀបឈ្នះនោះមិនគួរប្រព្រឹត្តតទៅទៀតនោះទេ ហើយការបង្ហាញអោយឃើញនូវសកម្មភាពជណ្តើមអំណាចគ្នាកាន់តែមិនគប្បីប្រព្រឹត្តតទៅទៀតដែរ។ គួរតែយើងទាំងអស់គ្នាបង្កើនូវគំនិតជាតិនិយមួយឈរលើស្មារតីចូលរួមយ៉ាងសកម្មទិទៀន រិះគន់ក្នុងន័យស្ថាបនាកសាងអភិវឌ្ឍ ដើម្បីភាពរុងរឿង និងជឿនលឿនសម្រាប់សង្គមជាតិយើង។

ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗទៀត ដូចជាការស្ថិតនៅក្រៅសង្គម គឺជារបាំងដែលរារាំងអ្នកក្រីក្រមិនអោយចូលរួមពេញលេញនៅក្នុងចរន្តរបស់សង្គម ដោយសារកត្តាអវិជ្ជាគ្មានលទ្ធភាពចូលរួមក្នុងការសម្រេចិត្តនានា និងច្បាប់រើសអើងដោយឈរលើមូលដ្ឋាននៃយេនឌ័រ ជាតិសាសន៍ និងអំពើពុករលួយជាដើម។

អនក្ខរកម្ម ជារបាំងមួយចំពោះអ្នកក្រីក្រធ្វើអោយជីវិតរបស់ពួកគេ ស្ថិតនៅក្រៅដំណើការអភិវឌ្ឍន៍ទាំងចេតនា ឬអចេតនា។ អនក្ខរជនត្រូវបានគេមើលងាយយ៉ាងខ្លាំងក្នុងសង្គមកម្ពុជា ហើយខ្លួនឯងមានអារម្មណ៍ថាជាអ្នកស្ថិតនៅក្រៅសង្គមដោយខ្លួនឯង។ អនក្ខរជនងាយរងនូវហានិយភ័យខ្ពស់ ដូចជា ការអូសទាញផ្សេងៗ ទាំងផ្លូវល្អ និងផ្លូវអាក្រក់ ដែលជាហេតុធ្វើអោយមានការប្រាស់ចាកពីក្រមសីលធម៌សង្គមធ្វើអោយមានភាពច្របូកច្របល់បង្កអស្ថេរភាពរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សង្គម។

ស្ត្រីក្នុងប្រទេសកម្ពុជាមិនបានសប្បាយ និងការទទួលបានស្មើរភាពគ្នាចំពោះការសិក្សា ការងារដែលមានប្រាក់បៀវត្សសិទ្ធិកាន់កាប់ដីធ្លី និងសិទ្ធិទ្រព្យសម្បត្តិផ្សេងៗ។ ស្ត្រីក៏ទទួលរងនូវសេវាកម្មសុខភាពបន្តពូជតិចតួចផងដែរ។ ពួកគេជាទូទៅស្ថិតនៅក្នុងការចាញ់ប្រៀបនៃគ្រួសារ និងសង្គម។ បញ្ហានេះបានសិក្សា និងបង្ហាញនៅក្នុងផ្នែកភាពក្រីក្រពីបញ្ហាយេនឌ័រ។

ជនជាតិភាគតិចច្រើនស្ថិតនៅក្នុងគុណវិបត្តិនៃដំណើរការអភិវឌ្ឍន៍ ដោយសារតែកង្វះអ្នកតំណាងក្នុងកម្រិតគ្រប់គ្រង និងបញ្ញត្តិ។ ពួកគេក៏ជាក្រុមបាត់បង់ផលប្រយោជន៍ និងក្រុមបន្ទាប់បន្សំដោយសារតែឧបសគ្គនៃភាសាផ្លូវការរបស់ពួកគេមានកម្រិត។

អស់រយៈពេលមួយទសវត្សកន្លងមកហើយ បញ្ហាហ៊ីវ/អេដស៍(HIV/AIDS) បានធ្វើអោយជនរងគ្រោះបាត់បង់នូវសេចក្តីសង្ឃឹមទៅថ្ងៃអនាគតរបស់ពួកគេ ហើយនឹងលទ្ធភាពស្មើសិទ្ធិដូចពលរដ្ឋធម្មតា[១១១]។

[១១១] យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ(២០០២-២០០៥)(២០/១២/២០០២) ទំព័រទី២២ និង២៣

កត្តាខាងលើនេះ បានជម្រុញអោយអ្នកទាំងនោះមានការឃ្លាតឆ្ងាយពីសង្គមដោយអចេតនា ជាហេតុធ្វើអោយខ្វះការចូលរួមដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងបង្កើនបន្ថែមនូវបន្ទុក ដែលជាវិបត្តិដល់សង្គមដែលត្រូវដោះស្រាយ។

ចំពោះភាពអសមត្ថភាពតែងតែរារាំងដល់អ្នកក្រ ក្នុងការខិតខំប្រឹងប្រែងរបស់ពួកគេអោយរួចផុតពីភាពក្រីក្រ។ ភាពអសមត្ថភាពនេះវាក៏កើតឡើងផងដែរ ពីកង្វះសមត្ថភាពដូចជា នៅប្រទេសកម្ពុជាយើងកង្វះសមត្ថភាពបណ្តាលមកពីបញ្ហាសុខភាព អាហារូបត្ថម្ភ អត្រាមរណៈភាព អត្រានៃការចូលរៀន និងខ្វះជំនាញវិជ្ជាជីវៈផ្ទាល់ខ្លួនជាដើម។ បើយើងពិនិត្យជាទូទៅប្រទេសយើងនៅអន់ជាងគេបើប្រៀបធៀបទៅនឹងប្រទេសមួយចំនួននៅក្នុងតំបន់(តាមរយៈទិដ្ឋភាពរស់នៅជាក់ស្តែងក្នុងសង្គម)។ ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗទៀតដូចជា បញ្ហាសុខភាព គឺនៅពៃលមានការធ្លាក់ខ្លួនឈឺមានទំនាក់ទំនងជាច្រើនដែលអាចបណ្តាលអោយមានភាពក្រីក្រ។ សុខភាពខ្សោយ គឺបណ្តាលអោយធ្លាក់ខ្លួនក្រដោយបាត់បង់ពលកម្មក្នុងការរកចំណូលសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃបន្តិចម្តងៗ។ អ្នកក្រជានិច្ចកាលតែងតែមានសុខភាពពុំល្អប្រជាជនកម្ពុជា ដែលក្រមានបន្ទុកយ៉ាងធ្ងន់ធ្ងរនៃជំងឺ។ អ្នកក្រហាក់ដូចជាពុំសូវបានយល់ដឹងពីសុខភាព និងអនាម័យ ដូចជា កង្វះអនាម័យ ទឹកស្អាត ការបង្ការជំងឺ ការជ្រើសរើសម្ហូបអាហារជាដើម។ ជាពិសេសនៅកម្ពុជា ជំងឺ ដែលអាចការពារបានតែបែជាមិនបានបង្ការធ្វើអោយជំងឺគំរាមកំហែងជីវិតជាញឹកញាប់ដែលភាគច្រើន អ្នកក្របាននឹងកំពុងប្រឈមមុនរួមមាន: ជំងឺគ្រុនចាញ់ រោគរបេង ជំងឺគ្រុនឈាម និងហ៊ីវ/អេដស៍។

ចំពោះបញ្ហាកង្វះអាហារូបត្ថម្ភ ជាបន្ទុកយ៉ាងធ្ងន់មួយសម្រាប់ប្រទេសកម្ពុជាធ្លាក់ទៅក្នុងភាពក្រីក្រ ព្រោះថាកង្វះអាហារូបត្ថម្ភ គឺជាគ្រោះអាសន្នយ៉ាងស្ងប់ស្ងាត់មួយ ដែលអាចបណ្តាលអោយបាត់បង់ផ្នែកសេដ្ឋកិច្ចគ្រួសារ និងការបាត់បង់ជីវិត។ ជាទូទៅកូនក្មេងដែលរស់នៅកក្នុងគ្រួសារដែលក្រនៅជនបទ គឺមានសភាពស្គមខុសប្រក្រតី។ ការខ្វះអាហារូបត្ថម្ភចាប់ផ្តើមភ្លាមក្នុងជីវិតវាជាប់ទាក់ទងនឹងចិត្តវិទ្យា និងការរីកលូតលាស់ខួរក្បាលនិងរាងកាយរបស់មនុស្ស។ កង្វះអាហារូបត្ថម្ភរារាំងពួកគេពីការលូតលាស់ដ៏ល្អបំផុត ហើយរួមទាំងសមត្ថភាពរបស់ពួកគេក្នុងការប្រយុទ្ធប្រឆាំងនៃភាពក្រីក្រ។ ការហូបមិនបានគ្រប់គ្រាន់ គឺជាកត្តាមួយដែលបាត់បង់ចំណេះដឹងយ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជាយើងជាដើម។ ទន្ទឹមគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងសំខាន់ផ្សេងៗទៀតដូចជា កង្វះការអប់រំ និងជំនាញពោល គឺជនក្រីក្រនៅកម្ពុជាបច្ចុប្បន្នភាគច្រើនមានមេគ្រួសារដែលទទួលបានការអប់រំតិចជាងកម្រិតមធ្យម។ ពួកគេបាត់បង់ឱកាសក្នុងការសិក្សាដោយសារសង្គ្រាមអស្ថេរភាពនយោបាយ និងរបបកម្ពុជាប្រជាធិបតេយ្យក៏ជាចំណែកមួយដែរ ហើយមួយចំណែកទៀត ពាក់ព័ន្ធនឹងជីវភាពគ្រួសារ និងសេវាអប់រំមិនបានបំពេញតាមតម្រូវការរបស់ពួកគេ។

កត្តាមូលដ្ឋាននៃភាពក្រីក្រ ក៏អាចបណ្តាលមកពីកម្រិតយល់ដឹងរបស់ប្រជាជនយើងក្នុងការចូលរួមចំណែកជួយកសាងសេដ្ឋកិច្ចប្រទេសជាតិអោយមានការរីកចម្រើន។ ប្រជាជនយើងដែលរស់នៅក្នុងបរិស្ថានមិន

ចេះអក្សរមាននិន្នាការសំដៅឆ្ពោះទៅរកអ្វីដែលជាមូលដ្ឋាន នៃការនៅក្រៅសង្គមទាំងមូលខ្វះការពិចារណា និងងាយទទួលរងគ្រោះថ្នាក់បំផុត។

ដោយឡែកដែលយើងអាចធ្វើការកត់សម្គាល់ផ្សេងៗទៀត ដូចជា ភាពក្រីក្រមកពីបញ្ហាយេនឌ័រដែលបច្ចុប្បន្នស្ត្រីកម្ពុជាមិនទាន់បានទទួលធនធាន និងផលប្រយោជន៍ពីការអភិវឌ្ឍន៍ក្នុងភាពស្មើគ្នានៅឡើយទេ។ ស្ត្រីគ្មានឧត្តមភាពដូចបុរសដោយពុំទទួលបានសេវាសុខភាពគ្រប់គ្រាន់ ពីព្រោះគ្រោះថ្នាក់នៃសុខភាពមានការទាក់ទងទៅនឹងការមានផ្ទៃពោះ និងភាពជាម្តាយរបស់ស្ត្រី។ ស្ត្រីបានទទួលសេវាអប់រំតិចតួចការចូលសិក្សាកម្រិតឧត្តមបានទទួលចំណូលតិចពីការងារ ពិសេសការងារដែលតម្រូវកម្រិតជំនាញខ្ពស់ទទួលបានសិទ្ធិតិចតួចក្នុងការកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិនានា ដោយមកពីទំនៀមទម្លាប់ពីបុរាណ និងមានឱកាសតិចតួចក្នុងការបង្ហាញទស្សនៈរបស់ខ្លួនក្នុងសកម្មភាពនយោបាយ។ ក្នុងស្ថានភាពបែបនេះស្ត្រីងាយធ្លាក់ខ្លួនរងគ្រោះចូលក្នុងភាពក្រីក្រ ហើយនឹងត្រូវរារាំងមិនអោយបានចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងសង្គមស៊ីវិលថែមទៀតផង។

សង្គ្រាម និងចលនាអន្តោប្រវេសន៍ជាបន្តបន្ទាប់បាននាំមកនូវភាពពុំប្រក្រតីក្នុងសមាមាត្រខ្ពស់របស់ស្ត្រីជាមេគ្រួសារ និងបានបង្កើតបន្ទុកក្នុងគ្រួសារ ដែលកើតឡើងដោយសារកង្វះខាតជាញឹកញាប់នូវសកម្មភាពបុរសសម្រាប់ការងារសេដ្ឋកិច្ច។ បន្ថែមលើការទទួលខុសត្រូវ ការទទួលបានធនធានផលិតកម្មរបស់ស្ត្រីនៅតែប្រទះឧបសគ្គអំពីទំនៀមទម្លាប់ និងបន្ទុកពេលវេលាដ៏ធ្ងន់ធ្ងរ ដែលកើតឡើងដើម្បីតុល្យការក្នុងការផលិតឡើងវិញសម្រាប់សង្គម និងតួនាទីផលិតកម្មសេដ្ឋកិច្ច។ ជាញឹកញាប់ស្ត្រីស្ថិតក្នុងការផ្តល់ប្រាក់កម្រៃការងារទាបធ្វើការតាមមុខងារមានសមត្ថភាពជំនាញនៅទាប និងអាចងាយរងគ្រោះតាមទ្រង់ទ្រាយនានាក្នុងការធ្វើអាជីវកម្មតាមកន្លែងធ្វើការងារ។ ស្ត្រីទោរទន់ទៅរកការទទួលខុសត្រូវជាបឋមនូវការងារអាជីវកកម្មនៅតាមផ្ទះ ដែលអនុញ្ញាតអោយគេបំពេញតុល្យភាពដោយការទទួលថែទាំងកូន និងការងារផ្ទះសម្បែងរួមទាំងក្នុងសកម្មភាពសេដ្ឋកិច្ចរបស់គេ[១១២]។

ការសិក្សាអប់រំផ្លូវការរបស់ស្ត្រីមានកម្រិតទាបជាងបុរស ដែលជាហេតុធ្វើអោយគម្លាតយេនឌ័រនេះបានកើតមានឡើងជារហូត។ អត្រាមានកូន និងអត្រាស្លាប់របស់មាតានៅកម្ពុជាមានកម្រិតខ្ពស់ជាងគេក្នុងតំបន់ហើយនឹងខ្ពស់ជាងកម្រិតនៃបណ្តាលប្រទេស ដែលមានកម្រិតចំណូលប្រហាក់ប្រហែលគ្នា[១១៣]។ ស្ត្រីវ័យក្មេងៗបានងាកទៅរកឧស្សាហកម្មផ្លូវភេទយ៉ាងច្រើន ដោយពួកគេមិនបានសិក្សាអប់រំខ្វះការពិចារណា និងមានជម្រើសតិចបំផុតសម្រាប់ពួកគេ។ ភាពក្រីក្ររបស់សង្គមមានភាពចលាចលរចនាសម្ព័ន្ធស្របច្បាប់មិនបានរីកលូតលាស់ និងភាពខ្សោយ នៃអនុភាពរបស់ច្បាប់នោះសុទ្ធតែបានចូលរួមធ្វើអោយឧស្សាហម្មផ្លូវភេទកើនឡើងយ៉ាងរហ័ស។

---

[១១២] រាជរដ្ឋាភិបាល: ផែការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំ លើកទី២(២០០១-២០០៥) ទំព័រទី៣៧

[១១៣] រាជរដ្ឋាភិបាល: ផែការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំ លើកទី២(២០០១-២០០៥) ទំព័រទី៣៧

អំពើហិង្សាតាមគ្រួសារនៅតែបន្តការគំរាមកំហែងលើស្ត្រីកម្ពុជា។ ការទទួលបានភាពមិនស្មើគ្នានូវភោគទ្រព្យ និងរបស់របរការរសាយចិត្តដោយការប្រកួតប្រជែងសេដ្ឋកិច្ច សំពាធលើការចង់បានចំណូលខ្ពស់ និងចលនាអន្តោប្រវេសន៍ដោយអន្ទោកអន្ទោងនោះសុទ្ធតែចូលរួមក្នុងកត្តានៃហិង្សាគ្រួសារ។ ភាពក្រីក្រ ភាពមានកម្រិតនៃមុខរបរដែលអាចធ្វើបាន និងការកើនឡើងនូវតម្លៃទំនិញ និងសេវាកម្មមូលដ្ឋាននោះបានកំណត់ថា ជាការប្រឈមជាបន្ថែមលើការប្រឈមក្នុងគ្រួសារ និងហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានស្រាប់[១១៤]។

ប្រពៃណីពីបុរាណទម្លាប់ និងរបៀបរបបរស់នៅដែលមានដ៏យូរលង់មកហើយនោះបានបង្កើតឡើងនូវឥរិយាបថរើសអើងប្រឆាំងនឹងស្ត្រី។ ប្រពៃណីខ្មែរបានបង្ហាត់អោយនារីត្រូវតែចេះអត់ទ្រាំចំពោះប្តីរបស់ខ្លួន ទោះបីជានារីនោះជាមនុស្សសំខាន់ក្នុងការរកស៊ីចិញ្ចឹមគ្រួសារក៏ដោយ។ គ្រួសារកម្ពុជា ជាច្រើននៅតែចាត់ទុកកូនស្រីថា ជាកម្លាំងធ្វើការងារចាំបាច់ក្នុងគ្រួសារ។ ការងារក្រៅផ្ទះដូចជាការពាក់ព័ន្ធក្នុងនយោបាយសកម្មភាពសង្គម និងវប្បធម៌នោះមិនបានផ្តល់ការលើកទឹកចិត្តដល់ស្ត្រីឡើយ។ ប្រពៃណី និងជំនឿទាំងនេះនៅតែមានភាពខ្លាំងក្លានៅក្នុងសង្គមខ្មែរនៅឡើយ។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលជីវភាពរបស់ប្រជាពលរដ្ឋភាគច្រើនរស់នៅក្នុងភាពក្រីក្រ។ ភាពអនាធិបតេយ្យនៃសុខាភិបាលបាននឹងកំពុងជម្រុញអោយប្រជាពលរដ្ឋកាន់តែក្រីក្រទៅៗ ហើយក៏ជាបន្ទុកមួយសម្រាប់ថវិកាសាធារណៈ។ ភាពអនាធិបតេយ្យលើវិស័យសុខាភិបាលមាន: ការប្រើប្រាស់ថ្នាំ បច្ចេកវិជ្ជានៃជីវៈពេទ្យ និងការព្យាបាលជំងឺដោយយកបញ្ហាបក្សពួក និងលុយជាធំ។

ថ្នាំពេទ្យ និងការប្រើប្រាស់នៅកម្ពុជាសព្វថ្ងៃភាគច្រើន ថ្នាំក្លែងក្លាយ ថ្នាំហួសកំណត់ការប្រើប្រាស់ អ្នកលក់ដោយគ្មានអនាម័យត្រូវបានគេដាក់លក់ដោយសេរី អ្នកលក់គ្មានអនាម័យក្នុងការវេចខ្ចប់ចំពោះថ្នាំគ្មាន សំបកដែលអាចនាំអោយមានជំងឺឆ្លងទៅលើអ្នកប្រើប្រាស់។ ថ្នាំពេទ្យមួយចំនួនទៀត ត្រូវគេដាក់លក់ច្របូកប្របល់និងទំនិញផ្សេងៗទៀត។ អ្នកលក់ថ្នាំពេទ្យភាគច្រើនគ្មានជំនាញពេទ្យជាមូលដ្ឋាន ការលក់ទៅអោយអ្នកប្រើប្រាស់ជាទូទៅមិនបានពន្យល់ពីវិធីប្រើប្រាស់ ធ្វើអោយអ្នកប្រើប្រាស់មិនអាចព្យាបាលជំងឺបានតាមលក្ខណៈវិទ្យាសាស្ត្រ ដែលនាំអោយប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។ ភាពអនាធិបតេយ្យក្នុងការលក់ថ្នាំបុរាណ និងការផ្សព្វផ្សាយពាណិជ្ជកម្មស្តីពី ការព្យាបាលអោយជាសះស្បើយ ដូចជា ជំងឺអេដស៍ ជាការបោកបញ្ឆោតធ្វើអោយប្រជាពលរដ្ឋមួយចំនួនខ្វះការពិចារណា គ្មានការប្រុងប្រយ័ត្នដល់ការការពារឆ្លងជំងឺអេដស៍។

ការខ្វះខាតផ្នែកសម្ភារៈ និងសីលធម៌នៃវិជ្ជាជីវៈគ្រូពេទ្យ ធ្វើអោយប្រជាពលរដ្ឋខ្មែរពុំទាន់មានជំនឿពេញលេញទៅលើគ្រូពេទ្យខ្មែរ។ ការមានទស្សនៈយកលុយជាធំធ្វើអោយគ្រូពេទ្យភ្លេចមនសិការវិជ្ជាជីវៈពេទ្យ ដែលមានតួនាទីជាអ្នកជួយសង្គ្រោះជីវិតមនុស្សជាទូទៅ។ បច្ចុប្បន្នគ្រូពេទ្យខ្លះទាមទារអោយមានការទូទាត់លុយមុននឹងធ្វើការព្យាបាល។ដោយការខ្វះខាតលុយកាក់ក្នុងការព្យាបាលប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកទៅលើគ្រូបុរាណ។

[១១៤] Ibid ទំព័រទី៣៨

បើមានតម្រូវការចាំបាច់ដល់ការព្យាបាលជំងឺធ្ងន់ធ្ងរ ធ្វើអោយប្រជាពលរដ្ឋបង្ខំចិត្តលក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដើម្បីដោះស្រាយបញ្ហា។

ការបង់ថ្លៃឈ្នួលព្យាបាលសុខភាពបានបន្តភាពមិនអនុគ្រោះចំពោះប្រជាជនក្រីក្រ។ ថ្លៃឈ្នួលព្យាបាលសម្រាប់អ្នកក្រីក្រនោះជាឧបសគ្គរបស់អ្នកក្រ ក្នុងការទទួលបានូវសេវានេះដោយហេតុថា ជាទូទៅមន្ទីពេទ្យមិនបានលើកលែងអោយអ្នកក្រីក្រដែលមិនមានលទ្ធភាពបង់ប្រាក់នោះឡើយ។

ការប្រព្រឹត្តទៅនៃសេវាសុខាភិបាលសម្រាប់អ្នកក្រីក្រ និងអ្នករស់នៅក្នុងជនបទមិនសូវបានដំណើរការល្អពីព្រោះ ទាំងគ្រឿងសម្ភារៈប្រើប្រាស់ និងអ្នកផ្តល់សេវាពេទ្យផ្តោតតែលើប្រជាជនរស់នៅទីក្រុង ពុំបានយកចិត្តទុកដាក់ដល់តំបន់ជនបទដាច់ស្រយាល។ "កស្តុតាងទាំងឡាយបញ្ជាក់ថា ថវិកាដ៏មានកម្រិតរបស់ក្រសួងសុខាភិបាលត្រូវប្រើប្រាស់សម្រាប់ឧបត្ថម្ភសេវា ដែលការប្រើប្រាស់បានភាគច្រើនដោយអ្នកមានចំណូលមធ្យមនិងខ្ពស់មិនមែនសម្រាប់បង្កើនគុណភាពនៃសេវាសម្រាប់អ្នកក្រីក្រ ឬការលើកទឹកចិត្តដល់អ្នកក្រីក្រដើម្បីទទួលបាននូវការព្យាបាលដ៏សមស្របនៅតាមមន្ទីពេទ្យរដ្ឋទេ។ ការបែងចែកតាមទីតាំងភូមិសាស្ត្រនៃថវិកាសម្រាប់ដំណើការរបស់ក្រសួងសុខាភិបាល ភាគច្រើនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់មិនមែនសម្រាប់មូលដ្ឋានបំបាត់ភាពក្រីក្រ ដូចដែលបានប៉ាន់ស្មាន ឬតម្រូវការផ្នែកសុខាភិបាលនោះទេ" [១១៥]។

យោងតាមមាត្រា៦ នៃលក្ខន្តិកៈហិរញ្ញប្បទាន ស្តីពីប្រព័ន្ធគាំទ្រសម្ភារៈបរិក្ខាសុខាភិបាលជាតិគាំទ្រសម្ភារៈបរិក្ខាបានតម្រូវអោយបង្កើតនីតិវិធី ដើម្បីលើកលែងរាល់ការចំណាយ ថ្លៃឈ្នួលប្រើប្រាស់ដល់អ្នកក្រីក្រ[១១៦] ដូចនេះ ជាគោលការណ៍យ៉ាងហោចណាស់អ្នកក្រីក្រក៏ត្រូវបានរួចពីការចំណាយលើសេវាកម្មថែទាំសុខភាពទាំងនៅមណ្ឌលសុខភាព និងទាំងនៅមន្ទីពេទ្យ។ តែផ្ទុយទៅវិញក្រៅពីចំនួនតិចតួចដែលបានទទួលការលើកលែងបង់ថ្លៃឈ្នួលសេវាប្រព័ន្ធមុខងារនេះមិនទាន់មានប្រសិទ្ធិភាពក្នុងការបម្រើអ្នកក្រីក្រឡើយ។ កត្តាផ្សេងទៀតដែលអ្នកក្រមានការរារែកក្នុងការប្រើប្រាស់សេវាសុខាភិបាល គឺគេមិនដឹងមុនថា តើគេត្រូវបង់ថ្លៃឈ្នួល ឬក៏មិនត្រូវបង់ ហើយអ្នកក្រថែទាំងមានការរួញរាក្នុងការសុំរួចថ្លៃឈ្នួលសេវាកម្ម។ មិនតែប៉ុណ្ណោះនៅប្រទេសកម្ពុជាអ្នកក្រីក្រមានលទ្ធភាពតិចតួច ដើម្បីទទួលនូវសេវាកម្មសង្គម បើប្រៀបធៀបជាមួយនឹងអ្នកមានទ្រព្យសម្បត្តិ ហើយប្រជាជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ក្រីក្រជាងគេចំនួន ២១% ត្រូវធ្វើដំណើរជាង ៥គីឡូម៉ែត្រ ដើម្បីទៅដល់មណ្ឌលសុខភាព[១១៧]។

ភាពអនាធិបតេយ្យ និងគ្មានតម្លាភាពលើសេវាសុខាភិបាលនេះ រដ្ឋាភិបាលគួរមានវិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពវិជ្ជាជីវៈ និងពង្រឹងផ្នែកនេះអោយមានសុក្រិត្យភាពខ្ពស់ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការស្វែងរកសេវាសុខភាពរបស់អ្នកក្រីក្រ និងប្រកបទៅដោយគុណភាពខ្ពស់ ពីព្រោះគោលដៅគន្លឹះក្នុងការកាត់

---

[១១៥] រាជរដ្ឋាភិបាល: ផែការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំ លើកទី២(២០០១-២០០៥) ទំព័រទី១៣២

[១១៦] រាជរដ្ឋាភិបាល: ផែការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំ លើកទី២(២០០១-២០០៥) ទំព័រទី១៣២

[១១៧] យុទ្ធសាស្ត្រជាតិ កាត់បន្ថយភាពក្រីក្រ(២០០៣-២០០៥) ទំព័រទី២២

បន្តយ ឬលុបបំបាត់ភាពក្រីក្រ គឺការផ្តល់ភាពងាយស្រួលសេវាសុខាភិបាល ដែលមានគុណភាពល្អដល់អ្នកក្រីក្រ និងកាត់បន្តយការចំណាយមិនចាំបាច់នានារបស់ប្រជាពលរដ្ឋ។ កត្តាចម្បងនៃគ្រប់យុទ្ធសាស្ត្រកាត់បន្តយភាពក្រីក្រ គឺការធ្វើអោយមានកំណើនសេដ្ឋកិច្ចលឿនជាងមុន ដោយចាប់ផ្តើមពីសេដ្ឋកិច្ចគ្រួសារទៅពីព្រោះ កំណើននេះហើយ ដែលបង្កើតអោយមានកាលានុវត្តភាព ស្វែងរកចំណូល និងបង្កើនធនធានសម្រាប់ធ្វើហិរញ្ញប្បទានដល់សកម្មភាពនានា ដែលបម្រើអោយការកាត់បន្តយភាពក្រីក្របានឆាប់រហ័ស។

ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងផ្សេងៗទៀត ដូចជា កង្វះសេវាអប់រំ និងមុខជំនាញ: ប្រទេសកម្ពុជាជាប្រទេសក្រីក្រក្នុងចំណោមប្រទេសក្រីក្រក្នុងសកលលោក។ កត្តាមូលដ្ឋាននៃភាពក្រីក្ររបស់កម្ពុជាមានអត្រាខ្ពស់បណ្តាលមកពីកម្រិតយល់ដឹងរបស់ប្រជាជនយើងក្នុងការចូលរួមចំណែកជួយកសាងសេដ្ឋកិច្ចប្រទេសជាតិអោយមានការរីកចម្រើន។ បណ្តាប្រទេសអភិវឌ្ឍន៍នានាលើពិភពលោក ដូចជា ប្រទេសជប៉ុន និងប្រទេសសឹង្ហបូរី ដែលមានការរីកចម្រើនក៏ដោយ ការរួមចំណែកប្រជាជនរបស់គេមានកម្រិតយល់ដឹងខ្ពស់។ ចំណេះវិជ្ជាមានតួនាទីសំខាន់ក្នុងការរួមចំណែកកសាងប្រទេសកម្ពុជាអោយមានការរីកចម្រើនទៅមុខ តែជាអកុសលប្រជាពលរដ្ឋកម្ពុជាភាគច្រើននៅតែមានចំណេះដឹង និងបទពិសោធន៍ ដែលមានកម្រិតទាបនៅឡើយ។ ប្រជាពលរដ្ឋភាគតិចប៉ុណ្ណោះ ដែលភ្ជាប់ចំណេះដឹង និងបទពិសោធន៍ទៅនឹងភាពសម្បូណ៌រុងរឿងផ្នែកសេដ្ឋកិច្ច ឬទៅនឹងសន្តិភាព និងស្ថេរភាព។

ប្រជាពលរដ្ឋក្រីក្រនៅកម្ពុជា ភាគច្រើនមានមេគ្រួសារ ដែលទទួលបាននូវការអប់រំតិចតួចជាមធ្យម។ អត្រានៃភាពក្រីក្រមានកម្រិតខ្ពស់នៅក្នុងគ្រួសារទាំងឡាយ ដែលមេគ្រួសារពុំបានរៀនសូត្រនៅសាលា ឬក៏បានរៀនត្រឹមតែបឋមសិក្សា។ ប្រភេទធំទាំងពីរនេះមានសមាមាត្រស្មើនឹង៧៧% នៃជនក្រីក្រ។ អត្រានៃភាពក្រីក្រនៅក្នុងសង្គមគ្រួសារ ដែលមេគ្រួសារបានបញ្ចប់មធ្យមសិក្សាកម្រិតពីរ គឺ ២៤% នៅក្នុងគ្រួសារដែលមេគ្រួសារ រៀនចប់ថ្នាក់ឧត្តមសិក្សានោះ អត្រានៃភាពក្រីក្រមានត្រឹម ៧% ប៉ុណ្ណោះ[១១៨]។

នៅតំបន់ជនបទលំដាប់អ្នកក្រីក្របំផុត បានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាមានអត្រា ៥០% នៃកុមារនៅជនបទ ដែលមានអាយុពី ១២-១៧ឆ្នាំ ក្នុងលំដាប់ថ្នាក់អ្នកក្របំផុតបានចុះឈ្មោះចូលរៀននៅសាលាអនុវិទ្យាល័យមានកម្រិតទាបជាង បើប្រៀបធៀបក្នុងលំដាប់ថ្នាក់អ្នកមានបំផុត គឺ ២៥%។ ការចុះឈ្មោះចូលរៀននៅទាប និងការសម្រេចិត្តរបស់កុមារក្រីក្រនៅដំណាក់កាលនេះបានបង្ហាញថា ភាពក្រីក្រនឹងឆ្លងកាត់រយៈពេលវែងពីការកើនឡើងប្រាក់ចំណូលទៅថ្ងៃអនាគត[១១៩]។

បញ្ហាដែលជាឧបសគ្គ បានកើតឡើងដល់ការចុះឈ្មោះចូលរៀន និងសម្រេចចិត្តរបស់កុមារក្រីក្រ ត្រូវប្រឈមមុននឹងបញ្ហាជាច្រើន។ ការបាត់បង់ឱកាសក្នុងការបង្កើនពុទ្ធិរបស់ពួកគេដោយសារមានកម្រិតទាបទាំង

---

[១១៨] យុទ្ធសាស្ត្រជាតិ កាត់បន្តយភាពក្រីក្រ(២០០៣-២០០៥) ទំព័រទី២០

[១១៩] Ibide Page 20.

ធនធានសាធារណៈ និងឯកជន ឬគ្រួសារ មិនតែប៉ុណ្ណោះវាក៏បណ្តាលមកពីស្ថេរភាពនយោបាយ និងសង្គ្រាម។ បញ្ហាផ្សេងទៀត គឺដោយសារពួកគេស្ថិតនៅក្នុងស្ថានភាពក្រីក្រខ្វះសមត្ថភាពក្នុងការចំណាយ និងតម្រូវការអោយពួកគេរកប្រាក់ចំណូល ដើម្បីទ្រទ្រង់គ្រួសារ និងជីវិតរស់នៅរបស់ពួកគេ។ មិនតែប៉ុណ្ណោះជាច្រើនទៀត ដែលជារបាំងដល់ពួកគេ ដូចជាភាពក្រីក្ររបស់ឪពុកម្តាយ សេចក្តីត្រូវការនៅផ្ទះ ការបង្រៀនខ្សត់ខ្សោយ ចំងាយផ្លូវទៅសាលាឆ្ងាយ ការរៀនសូត្រ គេយល់ឃើញថាពុំមានប្រយោជន៍ និងការរៀនសូត្ររបស់ពួកគេមិនបានរៃងឆ្ងាយ ដោយសារស្ថានភាពជីវភាពក្នុងគ្រួសារមានភាពក្រីក្រ កង្វះខាតការជម្រុញពីសង្គម ការបង្រៀនខ្សត់ខ្សោយ (អ្នកបង្រៀន និងអ្នកទៅរកស្ថិតក្នុងស្ថានភាពក្រីក្រ)។ ម្យ៉ាងទៀត កុមារត្រូវការពេលវេលារៀនសូត្រ និងលំហែរ និងត្រូវការជំរុញបង្ហាញអោយបានច្រើនថែមទៀតពីសង្គមគ្រួសាររបស់គេ។ ដោយសារកង្វះជីវភាព និងការជម្រុញទឹកចិត្តដល់ពួកគេនេះ ដែលធ្វើអោយពួកគេឃ្លាតឆ្ងាយពីសាលារៀន និងពីសង្គម។ កត្តាទាំងអស់នេះធ្វើអោយសង្គមជួបបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរក្នុងពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគតដល់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម។

ភាពក្រីក្របានបង្កអោយមានភាពឯកោ និងភាពដាច់ឆ្ងាយពីសង្គមរបស់ក្រុមប្រជាជនមួយចំនួន ដែលមិនទាន់ទទួលបានពីសេវាបម្រើសាធារណៈផ្សេងៗ ព្រោះតែលក្ខណៈភូមិសាស្ត្រពិបាក និងដាច់ស្រយាលពេក។ តំបន់ជនបទក្រីក្រ និងតំបន់ជនជាតិភាគតិចទទួលរងគ្រោះ ដោយសារមិនមានសាលារៀនគ្រប់គ្រាន់ ចំងាយផ្លូវពីផ្ទះទៅកាន់សាលារៀឆ្ងាយពេក និងលក្ខខ័ណ្ឌបន្ទប់រៀនមិនសមស្រប ព្រមទាំងសាលារៀនមិនគ្រប់កម្រិតថ្នាក់ សម្រាប់កម្រិតអប់រំមូលដ្ឋាន។ កត្តាទាំងអស់នេះគួបផ្សំជាមួយប្រាក់បៀវត្ស ដែលមិនមានលក្ខណៈជួយលើកទឹកចិត្តផងនោះធ្វើអោយគុណភាពអប់រំនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលទាំងអស់មានភាពមិនច្បាស់លាស់ ហើយថែមទាំងជួបការលំបាក ក្នុងការទាក់ទាញគ្រូបង្រៀនបានទៅបម្រើការងារនៅតំបន់ទាំងនោះផងដែរ។ ម្យ៉ាងទៀត ស្ថានភាពនេះក៏ជះឥទ្ធិពលមកពីពុំបានផ្តល់ឱកាសអោយបានគ្រប់គ្រាន់សម្រាប់ចូលរៀនក្នុងប្រព័ន្ធឡើងវិញ ហើយនិងកង្វះខាងកម្មវិធីអក្ខរកម្មប្រព័ន្ធអប់រំក្រៅប្រព័ន្ធនៅតាមតំបន់ ដែលការបោះបង់ចោលការសិក្សារបស់សិក្សមានកម្រិតខ្ពស់។

ដើម្បីទទួលបានជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមមានចីរភាព នោះយើងទាំងអស់គ្នាត្រូវចូលរួមពិសេស រដ្ឋាភិបាលជាតួអង្គសំខាន់ដល់ការពង្រឹង និងពង្រីកបន្ថែមគ្រប់ហេដ្ឋារចនាសម្ព័ន្ធអោយមានលក្ខណៈល្អប្រសើរដល់សេវាអប់រំបណ្តុះបណ្តាលជំនាញ ដល់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ដោយផ្តល់ និងលើកទឹកចិត្ត ទ្រទ្រង់ជីវភាពអោយបានគ្រប់គ្រាន់ដល់គ្រូបង្រៀន ជម្រុញបង្កើតអង្គការសង្គមស៊ីវិល និងជួយប្រជាពលរដ្ឋអោយទទួលបានផងដែរ នូវឱកាសយល់ដឹងអំពីលក្ខណៈចំណេះដឹងអត្ថ-ប្រយោជន៍ ដែលទទួលបានពីចំណេះដឹងទៅថ្ងៃអនាគត ពិសេសការអភិវឌ្ឍន៍ធនធានមនុស្ស។ មិនតែប៉ុណ្ណោះធ្វើអោយគេមានការយល់ដឹងដល់កាតព្វកិច្ច និងសិទ្ធិរបស់ពួកគេនៅក្នុងសង្គម និងមានទំនាក់ទំនងជិត ស្និតជាមួយនឹងរដ្ឋាភិបាល ឬរដ្ឋបាលមូលដ្ឋានរបស់ពួកគេ។ ការអប់រំប្រជាពលរដ្ឋតាមរយៈអង្គការសង្គមស៊ីវិល

ដោយការលើកទឹកចិត្តដល់ការចាប់អារម្មណ៍ក្នុងការប្រើសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ដែលទទួលបានចំណេះដឹងពីការអប់រំ និងចំណេះដឹងនេះផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ដល់ប្រទេសជាតិ និងប្រជាពលរដ្ឋ និងជម្រុញអោយមានការចូលរួមនៅក្នុងអង្គការសង្គមស៊ីវិល ដើម្បីទទួលបាននូវតម្រូវការចាំបាច់ដល់ការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ។

ការទទួលបានលទ្ធភាពនៃការសិក្សាអប់រំ និងការបណ្តុះបណ្តាល គឺជាប្រការសំខាន់សម្រាប់ផលិតភាពរបស់ប្រជាកសិករ និងក្រុមអ្នកទីទ័លក្រដទៃទៀត។

ម្យ៉ាងទៀត ការប្រឈមនឹងកំណើនប្រជាជនមានការកើនឡើងខ្ពស់ជាឧប្បត្តិហេតុ នៃភាពក្រីក្រមានជាប់ទាក់ទងទៅនឹងអត្រាកំណើនប្រជាជនខ្ពស់ អត្រាមរណៈខ្ពស់ និងអត្រាមានជំងឺខ្ពស់។ កម្ពុជាមានអត្រាកំណើនខ្ពស់ជាងគេក្នុងចំណោមបណ្តាប្រទេសអាស៊ានលើកលែងតែប្រទេសឡាវ អត្រាកំណើនប្រជាជនប្រចាំឆ្នាំជាមធ្យម ២,៤៩% ដែលចំនួនប្រជាជនសរុប ១១.៤ លាននាក់ ហើយតាមការធ្វើចំណោលប្រជាជនកម្ពុជានឹងកើនឡើងស្ទើរតែទ្វេដង គឺដល់ ២០.៣លាននាក់ក្នុងឆ្នាំ២០២១[១២០]។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ មានការកើនឡើងច្រើនជាហេតុធ្វើអោយចំនួនមនុស្សដែលមានអាយុ ២០ឆ្នាំ ឬក្រោមនេះមានចំនួនច្រើនគឺមានប្រហែលនឹង ៥៥% នៃចំនួនប្រជាជនសរុបនាពេលបច្ចុប្បន្ននេះ[១២១] ។

កម្ពុជាត្រូវប្រឈមនឹងក្រុមជំនាន់អាយុពី ១៥-២៤ឆ្នាំ ដែលមានចំនួនយ៉ាងច្រើន ហើយពួកគេកំពុងឈានដល់វ័យបន្តពូជជាបន្តបន្ទាប់។ ក្រុមនេះហើយ ជាក្រុមដែលមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ធ្វើអោយមានកំណើនប្រជាជនច្រើនទស្សវត្ស។ នៅពេលអនាគតបង្កើតជាបន្ទុកយ៉ាងធ្ងន់ធ្ងរដល់ការផ្តល់សេវាកម្មអប់រំ (សាលារៀន) សេវាកម្មសុខភាពជីធ្លី និងសេចក្តីត្រូវការសំខាន់ៗដ៏ទៃទៀតសម្រាប់ជីវិត។ តាមការសិក្សាស្រាវជ្រាវបានប៉ាន់ស្មានប្រជាជនកម្ពុជាមានប្រហែល ១/៣ នៃចំនួនប្រជាជនសរុបរស់នៅក្នុងភាពក្រីក្រ[១២២]។ ផលប៉ះពាល់នៃកំណើនប្រជាជនដល់ភាពក្រីក្រ គឺជាក់ស្តែងចំពោះគ្រួសារក្រីក្រជាពិសេសស្ត្រី និងក្រុមបន្ទាប់បន្សំផ្សេងៗទៀត ដែលមានចំនួនកូនច្រើន ហើយមានធនធានតិចតួចស្ទួចស្តើង ជាអ្នកទទួលផលវិបាកច្រើនជាងគេបំផុតពីកំណើនប្រជាជនខ្ពស់នេះ។ ភាពក្រីក្រនេះជម្រុញអោយពួកគេរស់នៅក្នុងលក្ខខ័ណ្ឌខ្សត់ខ្សោយ ដូចជាទីកន្លែងរស់នៅខ្វះអនាម័យ ទឹកស្អាត ខ្វះម្ហូបអាហារ មានឥទ្ធិពលមិនល្អដល់ការទទួលកាឡូរីមិនគ្រប់គ្រាន់ និងបង្កើតកង្វះខាតអាហារូបត្ថម្ភ និងនៅក្នុងគ្រួសារក្រីក្រ ដែលទាំងអស់នោះជាការចូលរួមធ្វើអោយមានជំងឺផ្សេងៗ។ បញ្ហាទាំងនេះបានធ្វើអោយកើនឡើងស្រឹតៗនៃភាពក្រីក្រ និងធ្វើអោយស្ថានភាពគ្រួសារកាន់តែយ៉ាប់យឺនឡើងៗថែមទៀត។ កំណើនប្រជាជនកើនលឿនពេក ក៏ចូលរួមចំណែកធ្វើអោយបរិស្ថានកខ្វក់ និងការបំផ្លាញដល់ធនធានធម្មជាតិផងដែរ។ អត្រាកំណើនប្រជាជនកាន់តែខ្ពស់ធ្វើអោយប៉ះពាល់ដល់រចនាសម្ព័ន្ធតាមអាយុ

[១២០] ការសែតកោះសន្តិភាព លេខ៤៨៥៨ ថ្ងៃអង្គារ៍ ទី០៨ ខែកក្កដា ឆ្នាំ២០០៣ ទំព័រទី៧

[១២១] Ibid ទំព័រទី៧

[១២២] Idem ទំព័រទី៧

ហើយចូលរួមចំណែកបង្កើនចំនួនអ្នកនៅក្នុងបន្ទុកកាន់តែច្រើនឡើង ដែលប្រជាជននៅក្នុងបន្ទុកមានវ័យក្មេង អាចធ្វើអោយរាំងស្ទះដល់ការរីកលូតលាស់ខាងសេដ្ឋកិច្ចក្នុងសង្គមគ្រួសារ។

ផលប៉ះពាល់ដែលបណ្តាលមកពីកំណើនប្រជាជន នៅតែបន្តកើនខ្ពស់ ធ្វើអោយរាំងស្ទះដល់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ព្រោះសេដ្ឋកិច្ចសង្គមមិនបានបំពេញតាមតម្រូវការរបស់ពួកគេ មិនតែប៉ុណ្ណោះការអភិវឌ្ឍន៍ធនធានមនុស្សមានកម្រិតទាប ការចេះអានអក្សរនៅមានកម្រិតទាប អត្រាកំណើនសេដ្ឋកិច្ចក្នុងគ្រួសារទាប។ បញ្ហានេះធ្វើអោយការខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងការធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវិតក្នុងការរស់នៅរបស់ប្រជាជនកម្ពុជា និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពមានការលំបាកយ៉ាងខ្លាំង។

ដូច្នេះ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងស្ថានភាពពន្យាកំណើនប្រជាជន រដ្ឋាភិបាលនិងយើងទាំងអស់គ្នាត្រូវមានការចូលរួមដោយពង្រឹង និងពង្រីកសេវាកម្មសាធារណៈ ពិសេសវេកម្មពន្យាកំណើតដល់គូស្វាមី និងភរិយា ដែលទើបនឹងរៀបការថ្មីៗអោយបានទូលំទូលាយទូទាំងប្រទេស ជាពិសេតំបន់ដែលមានត្រូវការចំបាច់ដែលមិនបានបំពេញខ្ពស់ ហើយធ្វើអោយតម្រូវការនេះមានចីរភាពសម្រាប់អ្នកដែលបានឈានចូលដល់អាយុបន្តពូជថ្មី។

ជាមួយគ្នានេះដែរ យើងអាចធ្វើការកត់សម្គាល់លើរឿងសំខាន់ៗផ្សេងទៀត ដូចជា: បញ្ហាប្រវត្តិសាស្ត្រ នយោបាយ និងសេដ្ឋកិច្ចនៅកម្ពុជា។ ការរាលដាលនៃសង្គ្រាមក្នុងប្រទេសវៀតណាមចូលមកប្រទេសកម្ពុជាបានបង្កឡើងនូវអស្ថេរភាព និងវិបត្តិសេដ្ឋកិច្ចកលយុគយ៉ាងធ្ងន់ធ្ងរ ទន្ទឹមគ្នានឹងភាពប្រទូស្សរាយផ្នែកសង្គម និងនយោបាយ។ រដ្ឋភិបាល ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី **សម្តេចនរោត្តម សីហនុ** ត្រូវបានគេផ្តួលរំលំកាលពីឆ្នាំ ១៩៧០ ហើយរដ្ឋាភិបាលថ្មីក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ លន់ នល់ ត្រូវបានគេបន្តុបឡើង។ ក្រៅពីការពឹងផ្អែកផ្នែកនយោបាយ និងយោធារដ្ឋាភិបាលនេះ បានពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើជំនួយរបស់សហរដ្ឋអាមេរិកក្នុងការធ្វើហិរញ្ញប្បទាន ចំពោះឱនភាពជញ្ជីងទូទាត់ ការឧត្តម្ភសម្ភារៈចាំបាច់រួមទាំងស្បៀងអាហារ និងការរក្សាហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាមូលដ្ឋាន។ ដោយរដ្ឋាភិបាលត្រួតពិនិត្យជនបទបានបន្តិចបន្តួច និងដោយមិនអាចទាក់ទាញ ការជឿជាក់បានសមត្ថភាពរដ្ឋាភិបាលក្នុងការស្វែងរកចំណូលស្ថិតនៅកម្រិតទាបបំផុត[១២៣]។ អំពើពុករលួយបានស៊ីរួងជ្រៅ ហើយបង្កឡើងនូវការបាត់បង់សេចក្តីជឿទុកចិត្តរបស់ប្រជាជនទៅលើស្ថាប័នរដ្ឋ។ អតិផរណាមានកម្រិតខ្ពស់ទោះបីជាមានជំនួយឧបត្ថមពីសហរដ្ឋអាមេរិកក៏ដោយ។ រយៈពេលនោះ គឺជាដំណាក់កាលលើកដំបូង ហើយនៃវិបត្តិ ឬការដួលរលំសេដ្ឋកិច្ចកម្ពុជា ដែលមានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ប្រព័ន្ធនៃការដឹកនាំ ជាពិសេស ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងស្ថាប័នសេដ្ឋកិច្ច ដែលដឹកនាំ ឬគាំទ្រដោយរដ្ឋ។

[១២៣] CDRI: ការកែទម្រង់សេដ្ឋកិច្ចការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍នៅកម្ពុជា(១៩៩៧) ទំព័រទី៥-៨

អស្ថេរភាព និងការបំផ្លិចបំផ្លាញនៃប្រព័ន្ធសេដ្ឋកិច្ចទាំងមូល កើតមានឡើងនៅក្នុងរបបខ្មែរក្រហម (កម្ពុជាប្រជាធិបតេយ្យ) នាឆ្នាំ១៩៧៥-១៩៧៩។ ដោយសារភាពពុំដែលមាន និងសារធាតុព្រៃផ្សៃនៃការផ្លាស់ប្តូរសង្គមរបស់ខ្មែរក្រហម នោះប្រព័ន្ធសេដ្ឋកិច្ចក្នុងសម័យនោះបានធ្លាក់ចូលទៅក្រោមការបំផ្លិចបំផ្លាញយ៉ាងដំណាំ។ រូបិយប័ណ្ណត្រូវបានលុបបំបាត់ចោលជាមួយគ្នានឹងស្ថាប័នហិរញ្ញវត្ថុ និងការទិញ/លក់គ្រប់ប្រភេទ កម្មសិទ្ធិឯកជនត្រូវបិទចោល ហើយដីធ្លីទាំងអស់ត្រូវដាក់ក្រោមការត្រួតពិនិត្យរបស់រដ្ឋ កសិកម្មត្រូវដាក់បញ្ចូលជាសមូហភាព ហើយប្រព័ន្ធឧស្សាហកម្មដ៏ស្តួចស្តើងនោះត្រូវបានពន្លិចចោល រីឯអ្វីដែលនៅសេសសល់ នោះត្រូវដាក់ក្រោមការត្រួតពិនិត្យរបស់រដ្ឋសម្រាប់ផលិតកម្មចាំបាច់។ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចត្រូវបានបិទចោល។ ស្ថាប័នសិក្សា-ធិការលើកលែងតែសាលាបឋមសិក្សា ត្រូវបានបន្តដំណើរមុខងាររបស់ខ្លួន ដូចជាវិស័យសុខាភិបាលដែរ គឺមានតែការថែរក្សាសុខភាពកម្រិតទាបបំផុត។ ការគាំទ្រខាងក្រៅត្រូវបានផ្លាស់ប្តូរ ក៏ប៉ុន្តែការពឹងផ្អែកនៅតែមានទោះបីជាកម្ពុជាបានផ្តាច់ខ្លួនចេញពីប្រទេសនានាលើពិភពលោកក៏ដោយ។ អ្វីដែលបានកើតឡើងនៅក្នុងរបបនោះបានបន្សល់ទុកនូវភាពគ្រាំគ្រាស្មុគស្មាញដល់ការគ្រប់គ្រង និងការអភិវឌ្ឍន៍សេដ្ឋកិច្ច នៅកម្ពុជា។

ការផ្តួលរលំរបបខ្មែរក្រហម និងការបង្កើតរដ្ឋាភិបាលថ្មីនៅឆ្នាំ១៩៧៩ មានការរីកដុះដាលក្នុងការស្តារសេដ្ឋកិច្ច-សង្គមកិច្ចឡើងវិញដ៏ដោយ ក៏កម្រិតនៃសមិទ្ធិផលទាំងអស់នោះ នៅតែជាគ្រឹះដំបូងហើយមានចំនួនតិចតួចនៅឡើយ គឺមានការពឹងផ្អែកទៅខាងក្រៅនៃសេដ្ឋកិច្ចដែរ។ និន្នាការនៅពេលនោះ គឺឆ្ពោះទៅរកក្រុមប្រទេសសង្គមនិយមសំខាន់ គឺសហភាពសូវៀតតែម្តង។ ការពឹងផ្អែកទាំងស្រុងបែបនេះ គឺការជំរុញដោយនយោបាយអន្តរជាតិនៃសង្គ្រាមត្រជាក់ និងមកពីការដាក់របបថ្មីនេះអោយឯកកោ ដោយប្រទេសលោកខាងលិច និងបក្សពួករបស់គេ។ ពាណិជ្ជកម្មក្រៅប្រទេស គឺធ្វើឡើងក្នុងវង្វង់ប្រទេសសមាជិកសង្គមនិយមតែប៉ុណ្ណោះ ហើយឱនភាពថវិកាត្រូវបានធ្វើហិរញ្ញប្បទានដោយជំនួយពីសហភាពសូវៀត។ ទោះបីជារបបថ្មីខំប្រមែប្រមូលកម្លាំងរបស់ខ្លួន ដើម្បីស្តារសេដ្ឋកិច្ចក៏ដោយ ក៏ការលំបាកនៅមានច្រើន ដោយសារតែការដាក់អោយឯកកោដោយប្រទេសលោកខាងលិច និងដោយសារតែសង្គ្រាមនៅអូសបន្លាយជាមួយខ្មែរក្រហម និងកម្លាំងតស៊ូផ្សេងទៀត។ បញ្ហានេះដែលនាំអោយមានការរង្គោះរង្គើខ្លាំងនៅក្នុងការចំណាយរបស់រដ្ឋាភិបាល ព្រោះថា ជាពាក់កណ្តាលនៃចំណូលត្រូវបានបែងចែកទៅលើវិស័យសន្តិសុខ និងការពារប្រទេស។ ដូច្នេះ ហើយ ទើបចាប់តាំងពីដំណាក់កាលដំបូងនៃការស្តារប្រទេសម្ល៉េះ ម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសត្រូវរង្គោះរង្គើរដោយសារកត្តា ដែលរបបនេះមិនអាចគ្រប់គ្រងបាន។ របបថ្មីនេះបានចាប់ផ្តើមដំណើរការផលិតកម្ម ឧស្សាហកម្មឡើងវិញ ការដាក់អោយប្រើប្រាស់រូបិយប័ណ្ណ និងធនាគារនៅក្នុងសេដ្ឋកិច្ចសង្គមនិយម ការស្តារឡើងវិញនូវប្រព័ន្ធអប់រំ និងអ្នករងទុក្ខដើម្បីអោយពួកគេបានទទួលស្បៀងអាហារ និងការងារ ប៉ុន្តែការគាំពារ និងការផ្តត់ផ្តង់របស់គេនោះ បំពេញមិនបានតាមតម្រូវការដល់ការខ្វះខាតរបស់ពួកគេឡើយ។ ផ្ទៃក្នុងប្រទេសមានការខ្វះខាតកើនឡើងជារៀងរាល់ឆ្នាំ ការចំណាយសង្គមត្រូវកាត់បន្ថយ ដែលបណ្តាលអោយមានផលវិបាកជាវិជ្ជមានលើការអភិវឌ្ឍន៍ធនធានមនុស្ស និងភាពក្រីក្រធ្វើអោយកើតមាននូវការប្រព្រឹត្តខុសឆ្គងពីសំណាក់រដ្ឋអំណាច និងការបាត់បង់ជំនឿលើរដ្ឋ។ ទង្វើ

ទាំងនេះនៅតែមានវិបត្តិសេដ្ឋកិច្ច និងភាពអត់ឃ្លាននៅក្នុងសង្គម ដែលទទួលរងខ្ទេចខ្ទាំ និងអស្ថេរភាពក្នុងសង្គម ដោយការប្រើប្រាស់ច្រើននូវធនធានដ៏ស្តួចស្តើងនៅក្នុងសង្គមទៅលើសង្គ្រាមស៊ីវិល។

វិបត្តិម៉ាក្រូសេដ្ឋកិច្ចក្នុងដំណាក់កាលកន្លងទៅនេះ គឺទាក់ទងផ្ទាល់ទៅនឹងសភាពការណ៍អន្តរជាតិ ដែលជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ សញ្ញានៃការបញ្ចប់សង្គ្រាមត្រជាក់ចាប់តាំងពីពាក់កណ្តាលទសវត្សទី៨០ និងការដួលរលំនៃសហភាពសូវៀត ជាឧបករណ៍មួយដែលជម្រុញដំណើរការសន្តិភាពនៅកម្ពុជា ដោយបាននាំមកនូវសន្ធិសញ្ញាសន្តិភាពនៅទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ក៏ប៉ុន្តែការបញ្ឈប់ជំនួយពីសហភាពសូវៀតក្នុងអំឡុងឆ្នាំ១៩៨៩ និងការចាប់ផ្តើមដំណើរការសន្តិភាពស្ទើរតែនាំមកនូវគ្រោះមហន្តរាយដល់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ពីព្រោះ គ្មានជំនួយបរទេសមកបំពេញកង្វះខាតដ៏ធំទំរាំដល់ពេលរដ្ឋាភិបាលថ្មីបានបង្កើតដោយការបោះឆ្នោតនៅពាក់កណ្តាលឆ្នាំ១៩៩៣។ លើសពីនេះទៀត ស្ថាប័នគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចត្រូវបានតម្រូវអោយកែប្រែយ៉ាងធាប់រហ័ស ដែលនាំអោយមានការលំបាកខ្លាំងក្នុងការសិក្សាអោយបានគ្រប់គ្រាន់ដើម្បីប្រកាន់យកនៅតួនាទីថ្មីនៅក្នុងសេដ្ឋកិច្ចទីផ្សារ។

ក្នុងរយៈពេលនៃកំណែទម្រង់សេដ្ឋកិច្ចឆ្នាំ១៩៨៩-១៩៩៣ បានស្តែងជារយៈកាលមួយយ៉ាងស្មុគស្មាញបំផុតក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ច ដែលជាមួយគ្នានឹងការបញ្ឈប់ជំនួយបរទេស ពីអតីតជាប្រទេសសមាជិកសង្គមនិយម ជាពិសេសពីសហភាពសូវៀត។ វិបត្តិនយោបាយកើតឡើងពីការដួលរលំនៃសហភាពសូវៀត ដែលនាំទៅដល់ការបោះបង់មនោគមវិជ្ជាសង្គមនិយមចោល។ កត្តានេះស្ទើរតែធ្វើអោយការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសក្រឡាប់ធ្លាក់ចុះពីផ្លូវតែម្តង។ ក្នុងការធ្វើកែទម្រង់ឆ្ពោះទៅរកទីផ្សារត្រូវបានផ្តួចផ្តើម និងកំណត់ជាយុទ្ធសាស្ត្រនយោបាយ និងការគ្រប់គ្រងសេដ្ឋកិច្ច ទន្ទឹមនឹងគ្នានោះ កំណែទម្រង់សារពើពន្ធត្រូវបានចាប់ផ្តើមដែរ។ ប៉ុន្តែការលុបបំបាត់ចោលវិភាគទានស្នេហាជាតិ "ពីវិស័យកសិកម្មធ្វើអោយសមត្ថភាពរបស់រដ្ឋក្នុងការផ្តល់ការឧបត្ថម្ភធនចំពោះបុគ្គលិក និងផ្តល់ស្បៀងដល់ក្រុមទុគតជនត្រូវបានស្រុតចុះយ៉ាងខ្លាំង។ ការលុបបំបាត់ "ក្រុមសាមគ្គី" (ប្រភេទក្រុមក្នុងប្រព័ន្ធកសិកម្ម) ត្រូវបានបន្តដោយការប្រកាសឡើងវិញនូវកម្មសិទ្ធិឯកជនក្នុងវិស័យកសិម្មពេលនោះ ធ្វើអោយមានកង្វះខាតមធ្យោបាយផលិតកម្មកសិកម្ម ដល់គ្រួសារជាច្រើននៅជនបទ។

រយៈកាលនេះដែរ សេដ្ឋកិច្ចប្រទេសបានបែរឆ្ពោះទៅរកទីផ្សារឯកជនភាវូបនីយកម្ម និងការបន្តយអន្តរាគមន៍របស់រដ្ឋទៅលើសកម្មភាពសេដ្ឋកិច្ច។ វិនិយោគបរទេសត្រូវបានស្វាគមន៍ទៅលើការផលិតទំនិញ និងសេវាស្ទើរតែគ្រប់ប្រភេទ។ ទីផ្សារបើកចំហមិនប្រកាន់និន្នាការនយោបាយ រាល់ការធ្វើពាណិជ្ជកម្មអន្តរជាតិ ត្រូវបានអនុញ្ញាតចំពោះក្រុមហ៊ុនជាតិ និងបរទេស ហើយពន្ធគយត្រូវបានកាត់បន្ថយ។ ចំណែកវិស័យសេវាសាធារណៈមួយចំនួនដូចជា អគ្គីសនី ទូរគមនាគមន៍ ផ្លូវដែក សុខាភិបាល អប់រំ ជាដើម រដ្ឋបន្តគាំទ្រដោយសេវាកម្រិតទាបដែលជាកត្តាមិនសមស្របទៅនឹងតម្រូវការសង្គម ជាពិសេសវិស័យសុខាភិបាល និងអប់រំ ដែលជួបប្រទះនូវការខ្វះខាតធនធានយ៉ាងខ្លាំង។

រយៈពេលនោះរហូតមកដល់បច្ចុប្បន្នទីផ្សារទាំងអស់ គឺជាទីផ្សារសេរី "ទំនិញលើទីផ្សារដំណើរការលើមូលដ្ឋានតម្រូវការ និងការផ្គត់ផ្គង់"[១២៤] (មិនកំហិតនូវតម្រូវការ និងការផ្គត់ផ្គង់វាប្រែប្រួលអាស្រ័យទៅលើបរិមាណ និងទីផ្សារពាណិជ្ជកម្មសេរី)។ ដោយសារការផ្លាស់ប្តូរ និងធ្វើការកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ច និងការគ្រប់គ្រងមានល្បឿនយ៉ាងគំហុកបែបនេះ ដែលធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើរចនាសម្ព័ន្ធសង្គម។ កំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយទាំងនេះហាក់ដូចជា មាននៅត្រឹមតែក្នុងជួរដៀកិបាល កង្វះការសម្របសម្រួលរវាងផ្នែកសាធារណៈ និងផ្នែកឯកជន។ បញ្ហានេះ ជាការប្រឈមមួយយ៉ាងស្រួចស្រាវដល់ការមិនស៊ីសង្វាក់គ្នារវាងផ្នែកទាំងពីរខាងលើ។ លើសពីនេះទៅទៀត ធ្វើអោយមានការជួបលំបាកដល់ផ្នែកឯកជន និងវិនិយោគក្នុងទីផ្សារប្រគួតប្រជែង ដែលជាហេតុធ្វើអោយមានភាពច្របូកច្របល់ក្នុងរចនាសម្ព័ន្ធកំណែទម្រង់បង្កអោយមានការអនុវត្តន៍ច្បាប់នៅមានភាពទន់ខ្សោយ។

សកម្មភាពពាណិជ្ជកម្ម គឺបម្រើតម្រូវការសេដ្ឋកិច្ចជួយជម្រុញសេដ្ឋកិច្ចជាតិ អោយមានការរីកលូតលាស់។ តែដោយឡែកសម្រាប់ការធ្វើពាណិជ្ជកម្មនៅកម្ពុជាបច្ចុប្បន្ន មិនបានបម្រើនូវតម្រូវការដល់ការរីកលូតលាស់សេដ្ឋកិច្ចសង្គមទេ ដោយគ្មានការគោរពច្បាប់អោយបានត្រឹមត្រូវ។ ចំពោះរាល់ទំនិញដែលនាំចេញនាំចូលគ្មានការត្រួតពិនិត្យត្រឹមត្រូវអ្នកប្រកបរបបជំនួញនាំចេញនាំចូលភាគច្រើន ឬក៏សឹងតែទាំងអស់មិនបានទទួលការបណ្តុះបណ្តាលអំពីបែបបទ ដែលត្រូវបំពេញទៅតាមច្បាប់ ដែលមានជាធរមាននៅក្នុងប្រទេសយើងទេ។ ទីផ្សារពាណិជ្ជកម្មនៅកម្ពុជា គឺអ្នកនាំចេញ នាំចូលទំនិញគិតតែពីប្រាក់ចំណេញ មិនគិតពីផលប៉ះពាល់បរិស្ថាន ឬក៏សុខភាពអ្នកប្រើប្រាស់ និងសុខុមាលភាពសង្គមឡើយ។ ប្រព័ន្ធច្បាប់ទន់ខ្សោយមិនបានយកមកអនុវត្តន៍អោយបានត្រឹមត្រូវទេ ដោយសារឥទ្ធិពលនៃអំពើពុករលួយ។ ផលប៉ះពាល់ដល់ចំណូលពន្ធរដ្ឋដោយឥទ្ធិពលអ្នកមានអំណាចក្នុងជួរមន្ត្រីរាជការ ដែលមានតួនាទីនៅក្នុងស្ថាប័នរដ្ឋប្រកបមុខរបរជាពាណិជ្ជករដោយផ្ទាល់ ឬដោយប្រយោល។

ទំនិញមួយចំនួនដែលត្រូវនាំចូលផ្តាច់មុខ ដោយក្រុមហ៊ុនមួយក្តាប់តូច ជាការរំលោភបំពានទៅលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ ក្នុងការប្រកួតប្រជែងធ្វើអោយមានអតិបរមានថ្លៃ ដែលជាផលប៉ះពាល់ចំណាយខ្ពស់ដល់អ្នកប្រើប្រាស់។ ម្យ៉ាងវិញទៀត ការនាំចេញក៏ដូច្នោះដែរ ការផ្តាច់មុខធ្វើអោយអប្បរមាថ្លៃចំពោះផលិតផលដែលត្រូវនាំចេញ(កសិផល និងផលិតផលកែច្នៃពីធនធានក្នុងស្រុកផ្សេងទៀត)។ បញ្ហានេះកំពុងតែបំផ្លិចបំផ្លាញផលប្រយោជន៍ផលិតករខ្មែរដោយមិនដឹងខ្លួន។ ទំនិញនាំចូល ដែលបានដាក់លក់នៅលើទីផ្សារនៅកម្ពុជាបច្ចុប្បន្នមិនបានធ្វើការត្រួតពិនិត្យទៅលើគុណភាពអោយបានត្រឹមត្រូវទៃដូចជា គ្រឿងបរិភោគ បរិភោគ និងទំនិញមួយចំនួនទៀត។ កង្វះខាតនេះនាំអោយមានផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ និងចំណាយគ្មានប្រសិទ្ធភាពរបស់ប្រជាពលរដ្ឋ។ លំហូរចូលនៃទំនិញក្លែងបន្លំ គ្មានគុណភាព ខ្វះបរិមាណ ឱសថហួសអាយុប្រើ

[១២៤] មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រៈ សេដ្ឋកិច្ចវិទ្យា(១៩៩៧)

ប្រាស់ ការវិចខ្ចប់មិនបានត្រឹមត្រូវជាដើម។ បញ្ហានេះបង្កអោយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកប្រើប្រាស់ បាត់បង់សុខមាលភាពសេដ្ឋកិច្ចសង្គម និងជាឧបសគ្គដល់ដំណើរការអភិវឌ្ឍន៍ ពិសេសជាឧបសគ្គដល់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ ការគ្មានការតែបណ្តឹង ឬរាំងខ្ចប់នូវបណ្តាទំនិញមួយចំនួនដែលកម្ពុជាផលិតបានអាចប្រើប្រាស់ជំនួយអោយគ្នាបាននោះឡើយ។ កត្តានេះធ្វើអោយបាត់បង់ទីផ្សារផលិតផលក្នុងស្រុក និងមានការបាក់ទឹកចិត្តដល់ផលិតករក្នុងស្រុក និងបាត់បង់លទ្ធភាពផលិត ដែលជាហេតុជំរុញអោយអត្រាការងារក្នុងស្រុកមានកម្រិតទាប។

ដើម្បីជានាបាននូវប្រសិទ្ធភាព និងជម្រុញអោយសកម្មភាពពាណិជ្ជកម្មចូលរួមដល់ដំណើរការអភិវឌ្ឍន៍រីកលូតលាស់ដល់សេដ្ឋកិច្ច និងសង្គមនោះ រដ្ឋាភិបាលគួរតែទទួលយកការផ្តត់ផ្តង់ និងជានូវមូលដ្ឋានច្បាប់ និងសេវាកម្មសំខាន់ៗដទៃទៀត ដែលជាគ្រឹះនៃប្រសិទ្ធិភាពក្នុងការរៀបចំមូលដ្ឋាននៃប្រព័ន្ធទីផ្សារសេរី។ មូលដ្ឋានច្បាប់ចំបាច់សម្រាប់ជាវិធានការមួយចំនួន ដូចជា ការផ្តល់នូវច្បាប់ដល់ពាណិជ្ជករ កំណត់នូវច្បាប់លើកម្មសិទ្ធិឯកជន ច្បាប់ការងារ ច្បាប់វិនិយោគ និងច្បាប់ផ្សេងៗទៀតសម្រាប់ជានាដល់ការអនុវត្តន៍កិច្ចព្រមព្រៀងផ្សេងៗ។ មូលដ្ឋាននៃច្បាប់រដ្ឋាភិបាលទទួលបានលទ្ធភាពសម្រាប់បំពេញតួនាទីជាអាជ្ញាកណ្តាលនៅក្នុងរង្វង់ នៃទំនាក់-ទំនងសេដ្ឋកិច្ច វែកមុខនូវករណីនៃភាពអយុត្តិធម៌ក្នុងការអនុវត្តន៍របស់ភ្នាក់ងារសេដ្ឋកិច្ច។ ព្រោះផ្អែកលើមូលដ្ឋាននៃច្បាប់រដ្ឋ មិនអនុញ្ញាអោយមានការលក់ដូរទំនិញក្លែងក្លាយបន្លំ ខូចគុណភាព ខ្វះបរិមាណ និងហួសការកំណត់ប្រើប្រាស់ ព្រមទាំងទាមទារនូវការវិចខ្ចប់អោយបានត្រឹមត្រូវជាដើម ក្នុងគោលបំណងធានាអោយបាននូវសុខុមាលភាព និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក៏ដូចជាសង្គមជាតិទាំងមូល។

ប្រទេសកម្ពុជា ជាប្រទេសដែលរងទុក្ខដោយសង្គ្រាម ដែលបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាតិ ជាពិសេស ជាបន្ទុកមួយដ៏ធ្ងន់ធ្ងរបំផុតចំពោះថវិកាជាតិ។ អំពើពុករលួយនៅក្នុងស្ថាប័នរដ្ឋមួយចំនួនបានធ្វើអោយមានការចាយវាយមិនច្បាស់លាស់នៃថវិកាជាតិ ដែលការចំណាយផ្នែកតម្រូវការសាធារណៈ ច្រើនខ្ពស់ជាងចំណូលដែលរដ្ឋប្រមូលបាន[១២៥]។ ការចំណាយទៅលើផ្នែកយោធា សន្តិសុខ និងចំណាយលើមុខងារសាធារណៈ (ប្រាក់ខែមន្ត្រីរាជការ ដែលមានចំនួនច្រើនលើសពីតម្រូវការនៃបែបបទរដ្ឋ) មានកម្រិតខ្ពស់ជាងចំណាយផ្នែកសង្គម ជាពិសេសផ្នែក អប់រំ ផ្នែកសុខភាព និងផ្នែកអភិវឌ្ឍកសិកម្ម និងជនបទ។ មូលហេតុដែលនាំអោយមានការខ្ជះខ្ជាយចំណាយលើតម្រូវការសាធារណៈមានកម្រិតខ្ពស់បណ្តាលមកពីសង្គ្រាម អសន្តិសុខសង្គម និងបរិមាណនៃចំនួនមន្ត្រីរាជការមានកម្រិតខ្ពស់។ ការចំណាយថវិកាជាតិលើផ្នែកយោធា និងស្ថាប័នកំពូលៗមួយចំនួន ដូចជា គណៈរដ្ឋមន្ត្រី សភាជាតិ និងព្រះបរមរាជវាំង នៅតែមានចំណែកដ៏ធំ នៃចំណាយសរុបបានជំរុញអោយភាពក្រីក្រនៅកម្ពុជានៅតែមានភាពថែរ ហើយកត្តានេះ ជាហេតុផលមួយដែលរដ្ឋាភិបាលមិនអាចផ្តល់

[១២៥] សុក ហាច និង Sarthi Acharya "របាយការណ៍ប្រចាំឆ្នាំ ស្តីពីសេដ្ឋកិច្ចកម្ពុជា ២០០២" ទំព័រទី៣៧

ថវិកាថែមទៀតសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីចូលរួមដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាបានឡើយ[១២៦]។

យើងពុំអាចយកថវិកាជាតិផ្នែកការពារជាតិ សន្តិសុខ និងចំណាយទៅលើស្ថាប័នមួយចំនួនទៀតនោះទេបម្រើផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចបានឡើយ ក្នុងករណីដែលរាជរដ្ឋាភិបាលពុំមានទិសដៅនយោបាយសេដ្ឋកិច្ចជាតិអោយបានត្រឹមត្រូវ។ ការចំណាយផ្នែកការពារជាតិ និងសន្តិសុខ ដើម្បីសន្តិភាព និងស្ថាប័នមួយចំនួនដូចបានលើកឡើងខាងលើនេះ ជាទង្វើរ និងទស្សន:មួយសមស្របទៅនឹងសភាពការណ៍ពិតនៃប្រទេសកម្ពុជា តែវាជាទង្វើរនិងទស្សន:មួយខុសពីទ្រឹស្តីក្នុងការកសាងសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ប្រទេស ដែលកំពុងស្ថិតនៅក្នុងភាពក្រីក្រ។ រហូតមកដល់ឆ្នាំ២០០១ ការចំណាយផ្នែកការពារជាតិ និងសន្តិសុខនៅតែមានកម្រិតខ្ពស់ជាងការចំណាយផ្នែកសង្គមនៅឡើយ[១២៧]។

ថវិកាជាតិ គឺជាដង្ហើម និងសរសៃឈាមសម្រាប់ទ្រទ្រង់អាយុជីវិត និងសុខុមាលភាពសង្គមជាតិ។ ប្រទេសកម្ពុជាជាប្រទេសមួយស្ថិតនៅក្នុងភាពក្រីក្រ ចំណូលថវិកាភាគច្រើនបានមកពីចំណូលពន្ធ ដែលមានជាង ៧០%[១២៨] នៃចំណូលសរុបកក្នុងស្រុក។

ពន្ធ ជាប្រភពចំណូលមួយយ៉ាងសំខាន់សម្រាប់ថវិការដ្ឋ ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដោយថវិកានេះជាធនធានសម្រាប់ធ្វើការវិនិយោគសាធារណៈ។ តែសម្រាប់កម្ពុជាការអនុវត្តន៍ច្បាប់ និងវប្បធម៌ពន្ធដារនៅមានភាពទន់ខ្សោយ ដោយចំណូលពន្ធដារមានការបាត់បង់បង្កឡើងដោយអភិបាលកិច្ចទន់ខ្សោយ អំពើពុករលួយការគេវេសពន្ធភាគច្រើន គឺពន្ធគយសំដៅទៅលើទំនិញនាំចូលច្រើនជាងទំនិញនាំចេញ[១២៩] នៅតាមមាត់ច្រកព្រំដែន។ ការបាត់បង់ចំណូលពន្ធនេះ ក៏បណ្តាលមកពីសមត្ថភាពរដ្ឋបាលពន្ធខ្សោយទាំងសមត្ថភាពកម្រិតទាំងរដ្ឋបាលពន្ធដារ និងរដ្ឋបាលពន្ធគយ។

សមត្ថភាពរដ្ឋបាលគយនៅមានកម្រិតក្នុងការបង្ក្រាប និងទប់ស្កាត់ការនាំចេញ-ចូល ដោយខុសច្បាប់នៅទីកន្លែងដែលមានការត់គេពន្ធគយ។ ទំនិញ ដែលត្រូវបានរត់គេចពន្ធគយ នៅតាមព្រំដែនច្រើនធ្វើឡើងនៅតាមមាត់ច្រករបៀងតូចៗ ដែលពុំដែលមានសមត្ថកិច្ចចុះទៅដល់ គឺច្រកព្រំដែនមិនអនុញ្ញាតអោយធ្វើការឆ្លងកាត់ពុំមែនជាច្រកព្រំដែនអន្តរជាតិ។ ហើយប្រភេទទំនិញ ដែលរត់គេចពន្ធគយនេះភាគច្រើនប្រភេទទំនិញដែលជាប់អត្រាពន្ធកម្រិតខ្ពស់ដូចជា ប្រេងឥន្ធនៈ បារី កេសដ្ធៈ រថយន្ត ម៉ូតូ និងប្រភេទទំនិញប្រណិតផ្សេងៗ ទៀតពេលខ្លះក៏មានទំនិញ ដែលជាប់អត្រាពន្ធកម្រិតទាបរត់គេចពន្ធគយផងដែរ។

---

[១២៦] ជ.ឯ.ម

[១២៧] Ibid ទំព័រទី៤០(តារាង៣.១១ ថវិកាតាមរយៈរតនាគារជាតិ)

[១២៨] Idem ទំព័រទី៣៩(តារាង៣.១០ ចំណូលថវិកាក្នុងស្រុកនៅឆ្នាំ២០០០ និង២០០១

[១២៩] តារាងពន្ធគយកម្ពុជា (CUSTOMS TARIFF OF CAMBODIA) ឆ្នាំ២០០១(ទំនិញនាំចេញភាគច្រើនត្រូវបានលើកលែងពន្ធ)

រដ្ឋបាលពន្ធដារក៏នៅមានចម្លោះប្រហោងខ្លះៗ ជុំវិញការធ្វើសវនាកម្មក្រុមហ៊ុន ដែលបន្លំ ហើយគេចវេសមិនព្រមបង់ពន្ធ។ ចន្លោះខ្វះខាតរបស់រដ្ឋបាលពន្ធដារទុកឱកាសឆកល្វែងអោយក្រុមហ៊ុន និងសហគ្រាសទាំងឡាយ ដែលជាប់ពន្ធក្នុងការលាក់ទុកឯកសារ ការកសាងកំណត់ត្រាឯកសារ និងរបាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗក្នុងបំណងបំប៉ោងចំណាយ ហើយបន្ទាប់ចំណូលដើម្បីបង់ពន្ធតិចជាងការតម្រូវនៃច្បាប់ពន្ធ។ វាមិនត្រឹមតែមានឥទ្ធិពលដល់ការបាត់បង់ចំណូលថវិកាជាតិប៉ុណ្ណោះទេ ថែមទាំងមានឥទ្ធិពលដល់កម្រិតស្មោះត្រង់នៃការបង់ពន្ធផងដែរ។

ការគេចវេសពន្ធត្រូវបានគេដឹងថា កើតមានជាច្រើននៅតាមក្រុមហ៊ុន និងសហគ្រាសនានា ដែលមួយចំនួន ត្រូវបានគេរកឃើញថា មានការបន្លំពន្ធដារ។ ដូចជាក្នុងឆ្នាំ២០០០ ការធ្វើសវនកម្មលើលិខិតស្នាម និងសវនកម្មដល់សហគ្រាសចំនួន ២៨០ បានរកឃើញថា ១៨០ សហគ្រាសបានដាក់លិខិតប្រកាសប្រចាំឆ្នាំដែលមានលទ្ធផលខាត។ ប៉ុន្តែក្រោយពីធ្វើសវនកម្មហើយ រដ្ឋរកឃើញមាន ៩២ សហគ្រាសមានលទ្ធផលចំណេញ និងកំណត់អោយមានការបង់ពន្ធឡើងវិញ ប្រាក់បន្ទចំនួន ២០ពាន់លានរៀ ស្មើប្រមាណ ៥.១លានដុល្លារអាមេរិក[១៣០]។

ការខាតបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន ភាពអនាធិបតេយ្យក្នុងការគ្រប់គ្រងស្លាកលេខយានយន្ត (រថយន្ត ម៉ូតូ កប៉ាល់...) ជាការខាតបង់ប្រាក់ចំណូលរបស់រដ្ឋ។ មិនតែប៉ុណ្ណោះ ភាពអនាធិបតេយ្យនេះធ្វើអោយប៉ះពាល់ដល់បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមទៀតផង។ អ្នកមានអំណាច និងបក្សពួកខ្លួនមួយចំនួនបានបំពានលើច្បាប់ដោយយកមធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូនផ្ទាល់ខ្លួនដាក់ស្លាកលេខរាជការ រដ្ឋសភា ន.ប ខ.ម ជាដើម បង្វៀងគេវេសពន្ធដារ ដោយប្រើប្រាស់មធ្យោបាយទាំងនោះបំពានលើច្បាប់ចរាចរ បង្កអោយមានភាពអសន្តិសុខក្នុងសង្គម។

ការខាតបង់ពន្ធលើប្រាក់ខែ: ការកម្រិតក្នុងការបង់ពន្ធលើប្រាក់ខែមានភាពមិនយុត្តិធម៌ដោយមន្ត្រីរាជការដែលមានតួនាទី និងអំណាចមិនសូវចាប់អារម្មណ៍ក្នុងការបង់ពន្ធជូនរដ្ឋទេ។ ទង្វើដ៏អាក្រក់នេះធ្វើអោយថវិកាជាតិមានការបាត់បង់ជាប្រចាំ។ ច្បាប់ពន្ធដារ ជាច្បាប់មួយមានសមភាពដល់ការអនុវត្តន៍រវាងអ្នកតូច និងអ្នកធំ អ្នកក្រនិងអ្នកមាន។ តែផ្ទុយទៅវិញ ត្រូវបានគេបំពានដោយមានការគៀបសង្កត់លើតែប្រាក់ខែអ្នកតូច និងអ្នកទន់ខ្សោយធ្វើអោយអ្នកមានកាន់តែមានឡើង ហើយចំណែកអ្នកក្រកាន់តែក្រទៅៗ។ ការមិនប្រកាសប្រាក់ខែជាទៀងទាត់ធ្វើអោយមានការលំបាកក្នុងការកំណត់អំពីអត្រាបង់ពន្ធរបស់បុគ្គល។

ការបាត់បង់ពន្ធដោយក្រុមហ៊ុនពាណិជ្ជកម្ម ដែលបង្កើតនៅប្រទេសកម្ពុជាច្រើនមានភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលរបស់មន្ត្រីរាជការដែលមានអំណាច។ ការយកឥទ្ធិពលនៃអំណាចនេះទៅប្រើប្រាស់ធ្វើអោយរដ្ឋខាតបង់ចំណូលថវិកាផ្នែកពន្ធដារយ៉ាងធ្ងន់ធ្ងរ ហើយការយកអំណាចនេះទៅប្រើប្រាស់ប្រកបរបប

---

[១៣០] រស្មីកម្ពុជា: ថ្ងៃទី២៣-២៤ ខែមេសា ឆ្នាំ២០០១: "ការធ្វើសវនកម្មលើក្រុមហ៊ុនរកឃើញថា មានការបន្លំពន្ធដារខ្លាំងណាស់" (ទំព័រ ក.២)

អាជីវកម្មផ្តាច់មុខ ដែលប្រឆាំងនឹងការប្រកួតប្រជែងនៃរបបសេដ្ឋកិច្ចទីផ្សារ។ ម្យ៉ាងទៀត ក្រុមហ៊ុនពាណិជ្ជកម្ម ភាគច្រើន ពុំសូវមានប្រព័ន្ធគណនីត្រឹមត្រូវ ដែលនាំអោយមានការលំបាកចំពោះរដ្ឋក្នុងការកំណត់ពន្ធ។ ភាព ច្របូកច្របល់នេះ ហើយដែលធ្វើអោយប៉ះពាល់ដល់ចំណូលពន្ធដារ និងផលប្រយោជន៍ជាតិខ្មែរទាំងមូល។ នេះជាករណីខុសឆ្គងធ្ងន់ធ្ងរបំផុត ដែលមិនអោយប្រទេសជាតិកសាងនីតិរដ្ឋ និងអភិវឌ្ឍន៍រីកចម្រើនទៅមុខបាន។

ការបាត់បង់ចំណូលថវិកាជាតិដោយអំពើពុករលួយ នយោបាយ អាជីវកម្មរបស់ពាណិជ្ជករ និងមន្ត្រីរាជការ មួយចំនួន បាននឹងកំពុងតែរួមផ្សំគំនិត និងសកម្មភាពរបស់ខ្លួនបំផ្លិចបំផ្លាញសេដ្ឋកិច្ចជាតិ និងសុខមាលភាព សង្គមពាណិជ្ជករខ្លះហ៊ានបន្លំឯកសារលើប្រភេទទំនិញដែលនាំចូល ដើម្បីជៀសវាងការបង់ពន្ធខ្ពស់ដោយធ្វើការ នាំចូលនូវប្រភេទទំនិញ ដែលមានអត្រាពន្ធខ្ពស់ និងទំនិញខ្លះហួសកំណត់ពេលប្រើប្រាស់គ្មានគុណភាពដូចជា ទំនិញដែលជាកាកសំណល់ រថយន្ត ម៉ូតូចាស់ៗ និងទំនិញផ្សេងទៀត ដែលនាំចូលបង្កើតនូវអត្រាជាតិពុលក្នុង បរិស្ថាន និងប៉ះពាល់ដល់សុខភាពប្រជាជន។ ម្យ៉ាងវិញទៀត ការរត់ពន្ធប្រេង និងទំនិញផ្សេងៗទៀតដោយសារ អំពើពុករលួយនៃមន្ត្រីរាជការបានធ្វើអោយខាតបង់ប្រាក់ចំណូលនៃថវិកាជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់។

អំពើពុករលួយធ្វើអោយបាត់បង់សមត្ថភាពប្រមូលចំណូលទាំងពន្ធដារ និងមិនមែនពន្ធដារ ដូចជា ចំណូលពីព្រៃឈើ និងកាប់ឈើនៅមានកម្រិតខ្សោយ។

ការលើកលែងពន្ធដែលបានផ្តល់អោយតាមច្បាប់វិនិយោគ បានកាត់បន្ថយអស់យ៉ាងច្រើននូវមូលដ្ឋាន ត្រូវគិតពន្ធ។ ផលប៉ះពាល់មិនល្អចំពោះហិរញ្ញវត្ថុសាធារណៈ ពិសេសចំពោះចំណូលថវិកាជាតិ ដោយការចូល អាស៊ាន និង AFTA[១៣១] របស់កម្ពុជា។ ហេតុផល គឺកន្លងមកចំពោះចំណូលពន្ធដារ រដ្ឋាភិបាលតែងពឹងផ្អែក យ៉ាងធ្ងន់ធ្ងរលើចំណូលពន្ធគយ(ពន្ធលើទំនិញនាំចូល និងនាំចេញ)។ ប៉ុន្តែការចូល AFTA តម្រូវអោយប្រទេស កម្ពុជាកាត់បន្ថយអត្រាពន្ធនាំចូល ហើយនឹងរបាំងពាណិជ្ជកម្មផ្សេងៗទៀត។ កម្ពុជាក៏ត្រូវធ្វើការកាត់បន្ថយ អត្រាពន្ធគយតាមគម្រោង CEPT[១៣២] ដែលជាការប្រឈមមុខនឹងកង្វះខាតប្រាក់ចំណូល ដែលនឹងត្រូវជួបប្រទះ។ ក្នុងពេលជាមួយគ្នា ដើម្បីធានា និងកាត់បន្ថយនៃការខាតបង់ចំណូលថវិកានេះ រដ្ឋាភិបាលគួរតែធ្វើការកែទម្រង់ ពន្ធដារដោយបង្កើនសមត្ថភាពប្រមូលចំណូលក្នុងស្រុកត្រូវពង្រឹង និងពង្រីកមូលដ្ឋានគិតពន្ធបន្ថែមទៀត និង ពង្រឹងអភិបាលកិច្ចអោយបានសមស្របប្រកបដោយតម្លាភាព។

ការបាត់បង់នូវចំណូលថវិកាជាតិនេះ ទំនងកើតមានឡើងអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ។ បើសិនទំនោរនេះនៅតែកើតឡើងនោះ ចំណូលពន្ធសម្រាប់ថវិកាជាតិក៏នៅតែបន្តបាត់បង់រហូត។ ថ្វីបើការ បាត់បង់ចំណូលថវិកានេះគ្មានតួលេខដែលគួរអោយជឿជាក់ ដើម្បីបញ្ជាក់ពីទំហំរបស់វាក៏ដោយ ក៏ការបាត់បង់ នេះមានរួចទៅហើយ។ បញ្ហាដែលកើតឡើងក្នុងស្ថានភាពដូចនេះ បើពុំមានវិធានការទប់ស្កាត់អាចជាឱកាសធ្វើ

---

[១៣១] AFTA = ASEAN Free Trade Area. (តំបន់ពាណិជ្ជកម្មសេរីអាស៊ាន)

[១៣២] CEPT = Common Effective Preferential Triffs. (គម្រោងអនុគ្រោះពន្ធគយរួម)

អោយពូជនៃអំពើពុករលួយគេវេសពន្ធដុះពន្លក ហើយវប្បធម៌ពន្ធដារត្រូវធ្វើអោយសឹករិចរិល។ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ និងពង្រឹងផ្នែកប្រមូលចំណូលថវិកានេះ ព្រោះថា បើយើងពិនិត្យតាមបរិបទអន្តរជាតិ ចំណូលថវិកាកម្ពុជានៅទាប បើធៀបនឹងប្រទេសជិតខាង។ ដូចជាប្រទេសថៃ ប្រជាជនម្នាក់ផ្តល់ថវិកាអោយប្រហែល ៦០០ដុល្លារ ធៀបនឹងប្រទេសកម្ពុជា ដែលប្រជាជនផ្តល់អោយថវិការដ្ឋតែ ៣០ ដុល្លារក្នុងមួយនាក់[១៣៣]។ មូលហេតុនៃគម្លាតនេះ គឺនៅក្នុងប្រទេសកម្ពុជា ចំណូលជាតិមានកម្រិតទាប ហើយប្រព័ន្ធសារពើពន្ធក៏នៅភាពទន់ខ្សោយនៅឡើយ។

ដូច្នេះ វិធានការដាក់ទោសពិន័យតាមច្បាប់ចំពោះបុគ្គល ឬក្រុមហ៊ុនដែលប្រព្រឹត្តអំពើពុករលួយ និងគេចវេសពន្ធ គឺជាវិធានការមួយដ៏ល្អបំផុតសម្រាប់បង្កើតចំណូលថវិកាជាតិ និងចូលរួមបង្កើតនូវឥទ្ធិពលល្អដល់វប្បធម៌ពន្ធដារបស់សង្គមកម្ពុជាយើង។

៤.២ ករណីសិក្សានៅស្រុកជុំគីរី ខេត្តកំពត

៤.២.១ ស្ថានភាពភូមិសាស្ត្ររបស់ស្រុកជុំគីរី

ស្រុក គឺជាថ្នាក់គ្រប់គ្រងរដ្ឋបាលដែនដី ដែលមានសារៈសំខាន់មួយក្នុងចំណោមថ្នាក់គ្រប់គ្រងរដ្ឋបាលនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លក្ខណៈសំខាន់របស់ថ្នាក់ស្រុក គឺជាថ្នាក់គ្រប់គ្រងក្រោមគេបង្អស់ក្នុងការផ្តល់សេវាកម្មបច្ចេកទេសរបស់ក្រសួងស្ថាប័នជំនាញនានា។ ហេតុនេះ ថ្នាក់ស្រុកជាថ្នាក់ដែលមានលក្ខណៈសមស្រប និងមានភាពងាយស្រួលជាងគេក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋានពិសេសប្រជាពលរដ្ឋក្រីក្រ។ ម្យ៉ាងវិញទៀត ថ្នាក់ស្រុក គឺជាថ្នាក់ដែលមានលក្ខណៈសមស្របបំផុតក្នុងការកំណត់ និងដោះស្រាយបញ្ហាអន្តរឃុំ/សង្កាត់ ដើម្បីធានាភាពរលូននៃការសហការគ្នា និងផ្សារភ្ជាប់រវាងឃុំ/សង្កាត់នីមួយៗក្នុងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន។

បច្ចុប្បន្ននេះ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ស្រុក/ខណ្ឌ មិនទាន់ធានាបានក្នុងការអនុវត្តតួនាទីដើម្បីសម្របសម្រួល និងចូលរួមក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន ហើយសាលាស្រុក/ខណ្ឌ និងការិយាល័យជំនាញជុំវិញស្រុក/ខណ្ឌ មិនទាន់មានភាពសកម្ម និងស៊ីសង្វាក់គ្នាក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅឡើយ។

ស្រុកជុំគីរី មានទីតាំងស្ថិតនៅប៉ែកឦសាននៃទីរួមខេត្តកំពត មានចំងាយ ៥៥គ.ម ពីទីរួមខេត្ត ដែលមានព្រំប្រទល់:

-ខាងជើងទល់នឹង ស្រុកបសែធ ខេត្តកំពង់ស្ពឺ និងស្រុកត្រាំកក់ ខេត្តតាកែវ

-ខាងត្បូងទល់នឹង ស្រុកឈូក

-ខាងកើតទល់នឹង ស្រុកត្រាំកក់ ខេត្តតាកែវ

-ខាងលិចទល់នឹង ឃុំតាកែន ស្រុកឈូក

[១៣៣] សុក ហាច និង Sarthi Acharya "របាយការណ៍ប្រចាំឆ្នាំ ស្តីពីសេដ្ឋកិច្ចកម្ពុជា ២០០២" ទំព័រទី៣៨

នៅក្នុងស្រុកជុំគីរីត្រូវបានបែងចែកជា ០៧ឃុំ មានចំនួន ៣៧ភូមិ មានសាលាមត្តេយ្យ០៥កន្លែង បឋមសិក្សា២៥កន្លែង អនុវិទ្យាល័យ០៥កន្លែង វិទ្យាល័យ០១កន្លែង មណ្ឌលសុខភាព០៤កន្លែង មានប្រជាពលរដ្ឋសរុប៤៧.៥១៩នាក់ ស្រី២៤.៣២៥នាក់ ចំនួនគ្រួសារសរុប១០.១៤៧គ្រួសារ អាយុ១៨ឆ្នាំឡើង២៥.៩០១នាក់ ស្រី១៤.៤០០នាក់ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋ១៤៣នាក់ ក្នុង១គីឡូម៉ែត្រការ៉េ[១៣៤]។ បើប្រៀបធៀបក្នុងឆ្នាំ ២០០២ ប្រជាពលរដ្ឋមានការកើនឡើង ៤.៤២២នាក់ គិតជាមធ្យមប្រមាណជា ១,០៧០ភាគរយ ក្នុងមួយឆ្នាំ។

ចំនួនប្រជាពលរដ្ឋតាមឃុំ ឆ្នាំ២០០៩

ល.រ	ឈ្មោះឃុំ	ចំនួនភូមិ	ចំនួនគ្រួសារ	ប្រជាពលរដ្ឋ
១	ច្រេស	៤	១.៣៥៦	៦.១៨៥
២	ស្រែសំរោង	៥	៩៥៣	៤.៤៩៩
៣	ស្រែក្នុង	៦	១.២១៥	៦.២០៦
៤	ស្រែចែង	៦	២.១៩២	៩.៥៧៤
៥	ស្នាយអញ្ជិត	៥	១.២១៨	៥.៦១៦
៦	ត្រពាំងរាំង	៥	១.៤៥៥	៧.២៤៩
៧	ជំពូវន្ត	៦	១.៧៥៨	៨.១៩០

យើងមានមណ្ឌលសុខភាពចំនួន ០៤ ក្នុងមណ្ឌលមានប្រជាពលរដ្ឋចាប់ពី ១ម៉ឺននាក់ ឡើងក្នុងមណ្ឌលនីមួយៗធ្វើការជូនប្រជាពលរដ្ឋប្រចាំពិនិត្យស្ត្រីមានផ្ទៃពោះចុះចាក់ថ្នាំបង្ការជំងឺ ៦មុខ ដល់ស្ត្រី និងកុមារ។ បំផុសចលនាអោយស្ត្រីមានផ្ទៃពោះទៅសម្រាលកូននៅមណ្ឌលសុខភាព ជៀសវាងគ្រោះថ្នាក់ដល់ម្តាយ។

ក្រៅពីនេះទៀតហើយ មានអ្នកស្ម័គ្រចិត្តភូមិ គ្រប់ភូមិទូទាំងស្រុក ដើម្បីជួយផ្សព្វផ្សាយជំងឺផ្តាសាយ បក្សីអប់រំសុខភាពចេះអនាម័យដល់គ្រួសារតាមផ្ទះ ជៀសវាង និងបង្ការជំងឺឆ្លងផ្សេងៗ។ ក្នុងមណ្ឌលសុខភាពមានបុគ្គលិកចំនួន ៥នាក់ទៅ៧នាក់។

តារាងស្ថិតិការងារវិស័យកសិកម្មឆ្នាំ១៩៩៣-២០០៨

ល.រ	ឈ្មោះឃុំ	ចំនួនគ្រួសារ	ចំនួនប្រជាពលរដ្ឋ (នាក់)	ផ្ទៃដីបង្ករបង្កើនផល (ហ.ត)	ផ្ទៃដីស្រែពិត (ហ.ត)	ផ្ទៃដីចំការ (ហ.ត)
១	ច្រេស	១.៣៥៦	៦.១៨៥	៣.១៧៨	១.៨៧៨	១៥៥
២	ស្រែសំរោង	៩៥៣	៤.៤៩៩	៩៦៩	៩៤៩	៩០

[១៣៤] របាយការណ៍បូកសរុប ការងារស្រុកជុំគីរី រយៈពេល ០៩ខែ ដើមឆ្នាំ២០០៩

៣	ស្រែក្នុង	១.២១៥	៦.២០៦	១.៥៩៦	១.៣៩៦	១២៧
៤	ស្រែចែង	២.១៩២	៩.៥៧៤	២.៨៦៦	២.៤៣៦	១៧១
៥	ស្នាយអញ្ជិត	១.២១៨	៥.៦១៦	១.០៣៥	១.០១៥	៩៥
៦	ត្រពាំងរាំង	១.៤៥៥	៧.២៤៩	១.៤០០	១.៣៤០	១១០
៧	ជំពូវន្ត	១.៧៥៨	៨.១៩០	១.៥៦៧	១.៤៩១	១៤៥
		១០.១៤៧	៤៧.៥១៩	១២.៦០៥	១០.៥០៥	៨៩៣

ប្រភព: របាយការណ៍បូកសរុប ការងារស្រុកជុំគីរី រយៈពេល ០៩ ខែដើមឆ្នាំ២០០៩

តារាងស្ថិតសត្វពាហនៈ និងសត្វស្លាប ឆ្នាំ២០០៩

ល.រ	ឈ្មោះ ឃុំ	ចំនួនគោបា	ចំនួនគោ				គោសរុប	កម្លាំងអូសទាញសរុប	ចំនួនក្របី				ក្របីសរុប	កម្លាំងអូសទាញសរុប
			គោ ៣ឆ្នាំឡើង		គោ ៣ឆ្នាំចុះ				ក្របី ៣ឆ្នាំឡើង		ក្របី ៣ឆ្នាំចុះ			
			ឈ្មោល	ញី	ឈ្មោល	ញី			ឈ្មោល	ញី	ឈ្មោល	ញី		
១	ជំពូវែន្ត	១៦	១៨៨០	២៣១០	៦៥០	៧៨៥	៥២១០	៣៨០៦	៩៩០	៨២០	២៥១	១៩៩	២២៦១	១៨១០
២	ត្រពាំងរាំង	១៤	១១០៧	១៤០២	៥៧៩	៥៣០	៣៦៣២	២៥២៣	១៣៥	៣២៤	៨៥	១៥៨	៧០២	៤៥៩
៣	ស្វាយអញ្ជិត	១២	១២៨២	៩៩២	៤៥៩	៥៩៥	៣២៤០	២២៨៦	៥០	១៧៦	៥២	៦១	៣៣៩	២២៦
៤	ស្រែងចែង	១៤	១៦៤០	២២៨០	៩៦៨	១០៣០	៥៩៣២	៣៩៣៤	១៤	១៦	៨	៦	៤៤	៣០
៥	ស្រែក្នុង	៨	១០៣៦	៤៥៩	៤៤៨	៤១០	២៤០១	១៥៤៣	៥៨	៤៥	៣៤	៤៦	១៨៧	១០៧
៦	ស្រែសំរោង	១០	៥០៩	១១០១	៣៤៨	៤១៩	២៧៨៧	២០២០	០	៤	២	១	៧	៤
៧	ច្រេស	១០	១១៩៤	១៤៨៦	៣៧២	៣១២	៣៣៧៤	២៦៩០	៣៨	៣៩	១៤	១០	១០១	៧៧
សរុប	៧ឃុំ	៨៤	៨៦៤៨	១០០៧០	៣៨២៤	៤០៤១	២៦៥៦៧	១៨៨០២	១២៨៥	១៤២៨	៤៤៧	៤៨១	៣៦៤១	២៧១៣

ប្រភព: ការិយាល័យកសិកម្មស្រុកជុំគីរី ផ្នែកផលិតកម្ម និងបសុព្យាបាលស្រុក ជុំគីរី,ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ លេខ០៤២ ផបសជគរ ២០០៩

តារាងស្ថិតសត្វពាហនៈ និងសត្វស្លាប ឆ្នាំ២០០៩

ល.រ	ឈ្មោះឃុំ	ចំនួនសេះ				សេះសរុប	ចំនួនជ្រូក				ជ្រូក សរុប	ចំនួនមាន់	ចំនួនទា	ចំនួនក្ងាន	ចំនួនទាកាប៉ា	ចំនួនពពែ
		៣ ឆ្នាំឡើង		៣ ឆ្នាំចុះ												
		ឈ្មោល	ញី	ឈ្មោល	ញី		បា	មេ	សាច់	កូន						
១	ជំពូវែន្ត	០	០	០	០	០	២៥	៤២៧	៨៧៨	៨៨៩	២២១៩	១៨៩៨៣	៦៦១៩	១០	៣៤	៤
២	ត្រពាំងរាំង	០	០	០	០	០	១៩	២២៥	១៥៨៩	៩៤១	២៧៧៤	២១៤៣៥	៦៣២៥	១២	៥២	២៥
៣	ស្វាយអញ្ជិត	០	០	០	០	០	២០	៣១០	៩៩៨	៧២៩	២០៥៧	១៥៩២៨	២៧៧៩	១០	៤៨	០
៤	ស្រែងចែង	១	២	១	១	៥	២៩	២៧០	១៤៨០	៧៤៨	២៥២៧	១៤១៨០	៥៤២៣	២៤	៩៨	៦
៥	ស្រែក្នុង	១	១	០	០	២	១០	៨៩	៨៤២	១៩៨	១១៣៩	១០១៩៥	៦៩៨	១៨	១០២	០
៦	ស្រែសំរោង	០	០	០	០	០	២០	២៧៩	៩៥២	៤២៥	១៧១៦	១២០៨៩	៣៦៤២	១០	៩៤	០
៧	ច្រេស	០	០	០	០	០	១៤	១០២	១១៤០	២៤០	១៤៩៦	១៥២៣០	៤៧៨០	១៤	៥២	៨
សរុប	៧ឃុំ	២	៣	១	១	៧	១៣៧	១៧០២	៧៩១៩	៤១៧០	១៣៩២៨	១០៨០៤០	៣០២៦៦	៩៨	៥២០	៤៣

ប្រភព: ការិយាល័យកសិកម្មស្រុកជុំគីរី ផ្នែកផលិតកម្ម និងបសុព្យាបាលស្រុក ជុំគីរី,ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ លេខ០៤២ ផបសជគរ ២០០៩

តារាងស្ថិតិប្រជាពលរដ្ឋ និងចំនួនសត្វពាហនៈ សត្វស្លាប ឆ្នាំ២០០៨

ឈ្មោះ ឃុំ	ចំនួនគ្រួសារ	ចំនួនប្រជាពលរដ្ឋ		សរុប (នាក់)	ចំនួនប្រជាពលរដ្ឋចាប់ពី១៨ឆ្នាំឡើង		សរុប	ចំនួនគោបា	ចំនួនសត្វគោ				កម្លាំងអូសទាញ	គោសរុប	ចំនួនសត្វក្របី				កម្លាំងអូសទាញ	ក្របីសរុប
									ពង្រាំឡើង		ពង្រាំចុះ				ពង្រាំឡើង		ពង្រាំចុះ			
		ប្រុស	ស្រី		ប្រុស	ស្រី			ឈ្មោល	ញី	ឈ្មោល	ញី			ឈ្មោល	ញី	ឈ្មោល	ញី		
ជំពូវន្ត	១៧២៩	៣៦៥៦	៤០២៥	៧៦៨១	១៩៣០	២១៧១	៤១០១	១៦	១៤៧៣	២៣០៩	៦៤៤	៧៤០	៣៧៨២	៥១៨២	៩៩០	៨១៤	២៤៩	១៩៤	១៨០៤	២២៤៧
ត្រពាំងរាំង	១៣២៤	៣០៥២	២៥៧៨	៥៦៧០	១៩២៩	១៧៩០	៣៧១៥	១៧	១១០៧	១៣៩៨	៥៦២	៥២៦	២៥០៥	៣៦១០	១៣១	៣១៩	៨០	១៥៣	៣៨០	៦៨៩
ស្វាយអញ្ជិត	១១៦៤	២៦៣៣	២៧៩០	៥៤២៣	១៣១៩	១៤៥៩	២៧៧៨	១១	១២៨២	៩៨៩	៤៥៤	៥៩៣	២១៧១	៣៣២៩	៤២	១៧០	៤៧	៦៧	២១២	៣២៦
ស្រែងចែង	១៦១៤	៤២៥៩	៤៥៦៥	៨៨២៤	២១៩០	២៤៧២	៤៦៦២	១៣	១៦៣៩	២២៧១	៩៦២	១០២៥	៣១៦០	៥៩១០	១៣	១២	៥	៤	១៨	២៧
ស្រែក្នុង	១២០៤	២៨២២	៣១១១	៥៩៣៣	១៤២៣	១៧០៣	៣១២៦	១០	១០៣២	៤៩៣	៤៤៣	៤០៦	១៥៣៥	២៣៨០	៥៨	៤៣	៣០	៤២	១០១	១៧៣
ស្រែសំរោង	៣១៩	២០៣៣	២៣៨៩	៤៤២២	១១២៩	១៣៦១	២៤៩០	១០	៩០៩	១០៥៧	៣៤២	៤១៥	២០០៦	២៧៧៣	០	២	១	០	២	៣
ប្រែស	១៣២១	៣០១៩	៣២៨៦	៦៣០៥	១៩៦៦	២១៧៨	៤១៤៤	៩	១១៩២	១៤៨២	៣៦៩	៣០៩	២៦៧៤	៣៣៦១	៣១	៣៣	១៣	៥	៦៤	៨២
សរុប ៧ឃុំ	៩១៧៥	២១៥១៤	២២៧៤៤	៤៤២៥៣	១១៨៨៦	១៣១៣៤	២៥០១៦	៨៦	៨៦៣៤	១០០៣៩	៣៧៧៦	៤០១៤	១៨៦៧៣	២៦៤៦៣	១២៥៨	១៣៩៣	៤៣១	៤៦៥	២៥៨១	៣៥៤៧

ប្រភព: ការិយាល័យកសិកម្មស្រុកជុំគីរី ផ្នែកផលិតកម្ម និងបសុព្យាបាលស្រុក ជុំគីរី,ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ លេខ០៤២ ផបសជគរ ២០០៩

៤.២.២ ស្ថានភាពកសិកម្មនៅស្រុកជុំគីរី

បញ្ហាបង្កបង្កើនផលក្នុងឆ្នាំបន្តបន្ទាប់កន្លងមកមានជួបការលំបាកខ្លះៗ និងការងាយស្រួលខ្លះអាស្រ័យដោយលក្ខខ័ណ្ឌធម្មជាតិ និងអាកាសធាតុប្រែប្រួលមិនទៀងទាត់។ ជាក់ស្តែង ទូទាំងស្រុកមានផ្ទៃដីបង្កបង្កើនផលចំនួន ១១.៥០៥ហិកតា សម្រាប់ផលិតផលស្រូវធ្ងន់ ស្រូវស្រាល ស្រូវកណ្តាល និងស្រូវចំការ។ ក្នុងឆ្នាំកន្លងមក យើអនុវត្តន៍បានជាលទ្ធផលល្អបង្គួរ លើការងារបង្កបង្កើនផលរបស់ប្រជាពលរដ្ឋ ជាក់ស្តែងចាប់ពីខែឧសភា ឆ្នាំ២០០៦ ដោយសារអាកាសធាតុមានលក្ខណៈអំណោយផល មានទឹកភ្លៀងធ្លាក់ដើមឆ្នាំគ្រប់គ្រាន់ បានធ្លាក់ចុះជាបន្តបន្ទាប់ពាសពេញគ្រប់ទីកន្លែងបានល្អទូទាំងស្រុក បង្កលក្ខណៈងាយស្រួលដល់ប្រជាកសិករក្នុងការភ្ជួររាស់ដាស់ដីស្រែ និងក្នុងការអនុវត្តន៍ការងារសោបព្រោះបានចាត់តាំងពីដើមរដូវ និងបានឈានដល់ការបញ្ចប់រួចរាល់ដាស់ដីស្រែ និងក្នុងការអនុវត្តន៍ការងារសោបព្រោះបានចាត់តាំងពីដើមរដូវ និងបានឈានដល់ការបញ្ចប់រួចរាល់ជាស្ថាពរលើការងារសោបព្រោះនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦ នេះជាការងារស្រូវវស្សា យើងអនុវត្តបានលើផ្ទៃដីសរុបចំនួន ១១.២៧៤.៥០ហិកតា ស្មើនឹង៩៨ភាគរយ នៃផ្ទៃដីសរុប ១១.៥០៥ហិកតា ក្នុងតំណាក់កាលនេះដែរ ដំណាំរួមផ្សំ និងបន្លែបង្គារ ដែលប្រជាកសិករបានដាំនាដើមរដូវវស្សានេះមាន សភាពដុះលូតលាស់បានល្អប្រសើរ។ គួរអោយកត់សម្គាល់ផងដែរចាប់ពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦ មានការកើនឡើងនៅសត្វមមាចស្មោតស៊ីបំផ្លាញដំណាំស្រូវ នៅលើសំណាប និងសន្ធូង ដែលបានស្ងួងរួចហើយធ្វើអោយផ្ទៃដីប៉ះពាល់បំផ្លាញចំនួន ៧៧.២៥ហិកតា ផ្ទៃដីខូចខាតចំនួន២.៧៥ហិកតា ម្យ៉ាងទៀតផលប៉ះពាល់ និងការខូចខាតសន្ធូងដោយសារការខ្វះខាតទឹកនៅចុងរដូវវស្សាឆ្នាម២០០៦ គិតត្រឹមថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៦ នេះនៅក្នុងបណ្តាឃុំទាំង០៧ នៃស្រុកជុំគីរី។ ប៉ុន្តែដោយសារមានការចុះជួយអន្តរាគមន៍របស់មន្ទីកសិកម្មខេត្ត អាជ្ញាធរមូលដ្ឋានមន្ត្រីជំនាញក្សេត្រសាស្ត្រ និងប្រជាពលរដ្ឋ ដែលជាម្ចាស់ស្រែបានរួមសហការធ្វើការទប់ស្កាត់នៅសត្វល្អិតមមាច-ស្មោតនេះបានទាន់ពេលវេលា ធ្វើអោយការរាតត្បាតរបស់វាមានសភាពស្ងប់ស្ងាត់ទៅវិញ។ ក្នុងឆ្នាំ២០០៧ កន្លងមកនេះដោយអាកាសធាតុមានលក្ខណៈអំណោយផលល្អចាប់តាំងពីដើមរដូវ និងបានបង្កលក្ខណៈងាយស្រួលដល់ប្រជាកសិករទូទាំងស្រុក ការងារបង្កបង្កើនផលស្រូវរដូវវស្សា និងបានបញ្ចប់ការងារដកស្ងួងរួចរាល់ជាស្ថាពរនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ លើផ្ទៃដីសរុបចំនួន ១១.៥០៥ហិកតា ផ្ទៃដីអនុវត្តបាន ១១.២១២ហិកតា ស្មើនឹង៩៧,៤៦%។ ជាមួយនេះដែរ ការងារដំណាំរួមផ្សំគ្រប់មុខមានលក្ខណៈល្អប្រសើរ បើគិតមកដល់ខែមីនា ឆ្នាំ២០០៧ នេះការងារប្រមូលផលស្រូវរដូវប្រាំងអនុវត្តបាន ៩០០ហិកតា ទិន្នផល២.៨០០តោនក្នុងមួយហិកតា បរិមាណផល ២.៥២០តោន។ ក្នុងនោះសម្រាប់ស្រូវប្រាំងភ្ជួរដីបាន៣៣៤ហិកតា សាបបាន៤៧ហិកតា ស្ងួងបាន១៩៦.៥ហិកតា ដំណាំរួមផ្សំនៅរដូវប្រាំងអនុវត្តបាន១០៦ហិកតា។ ប៉ុន្តែដោយសារកក្នុងឆ្នាំ២០០៧នេះបានកើតឡើងនៅសត្វមមាចស្មោតជាថ្មីម្តងទៀត បានធ្វើអោយដំណាំស្រូវវស្សាត្រូវទទួលរងនូវការបំផ្លាញ ដោយសត្វមមាចស្មោតយ៉ាងធ្ងន់ធ្ងរ។ តែដោយមានការជួយអន្តរាគមន៍ទាន់ពេលវេលារបស់មន្ទីរខេត្ត និងការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងពីអភិបាលស្រុក និងការិយាល័យកសិកម្មស្រុក បានសហការណ៍ជាមួយអាជ្ញាធរភូមិ ឃុំ

និងប្រជាពលរដ្ឋធ្វើយុទ្ធនាការចុះកំចាត់មមាចស្មោតតាមរយៈដាក់ថ្នាំពុលធម្មជាតិ ដាក់អំពូលនៅពេលយប់ និងដាក់ប្រេងខ្មៅ ធ្វើអោយដំណាំស្រូវរបស់ប្រពលរដ្ឋបានគេចផុតពីការខូចខាតបាន។ នៅក្នុងឆ្នាំ២០០៨ កន្លងមកនេះដែរ ដោយសារលក្ខណៈធម្មជាតិអំណោយផលល្អ មានភ្លៀងធ្លាក់ចាប់ពីដើមរដូវ បានបង្កលក្ខណៈងាយស្រួលដល់ប្រជាកសិករទូទាំងស្រុក ធ្វើការភ្ជួររាស់ដាស់ដីស្រែ និងការអនុវត្តន៍លើការងារសាបព្រោះដោយបានរួចរាល់ជាស្ថាពរនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៨ ការងារបង្កបង្កើនផលស្រូវរដូវវស្សា យើងអនុវត្តបានលើផ្ទៃដីសរុប ១១.៥៩៨ហិកតា ស្មើនឹង១០០,៨១ភាគរយ នៃផ្ទៃដីសរុប១១.៥០៥ហិកតា។

លទ្ធផលបង្កបង្កើនផលគិតមកដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ នេះអនុវត្តបានស្រូវប្រាំងសាបបាន ៤៧.៥ហិកតា ស្ទួងបាន១៩៦.៥ហិកតា ស្មើនឹង១៧,៨៦ភាគរយ នៃផែនការស្រូវវស្សាសាបអនុវត្តបាន២៧១ ហិកតា ស្ទួងបាន១០៨០ហិកតា ស្រូវកណ្តាលអនុវត្តសាបបាន១២៩ហិកតា ស្ទួងបាន២២៩៣ហិកតា ស្រូវចំ-ការអនុវត្តបាន១៣ហិកតា ក្នុងនោះដំណាំរួមផ្សំមាន: ពោត=៧៥.៥ហិកតា ដំឡូងមី=៣៩ហិកតា ដំឡូងជ្វា=៣២.៥ហិកតា សណ្តែកបាយ=៤៦.៥ហិកតា សណ្តែកគ្រប់មុខ=៥៩.៥ហិកតា បន្លែគ្រប់មុខ=២១ហិកតា និងដំណាំឧស្សាហកម្មរយៈពេលខ្លីរួមមាន: សណ្តែកដី=២៧.៥ហិកតា អំពៅ=៤៣ហិកតា។

ស្រុកជុំគីរី ជាស្រុកមួយ ដែលមានធនធានមច្ឆាជាតិនៅក្នុងស្ទឹង បឹង ទំនប់ ប្រឡាយនានា ប៉ុន្តែបច្ចុប្បន្ននេះដោយសារមានការប្រែប្រួលបរិស្ថានធម្មជាតិ និងកំណើនប្រជាជនជាបន្តបន្ទាប់បានធ្វើអោយតម្រូវការត្រីកាន់តែមានការកើនឡើងជាលំដាប់ ហើយបរិមាណផលត្រីក្នុងធម្មជាតិ មិនអាចផ្គត់ផ្គង់បានតាមតម្រូវការ។ ទន្ទឹមនឹងនេះដែរ រដ្ឋបាលជលផលស្រុកបាននឹងកំពុងយកចិត្តទុកដាក់ផ្សព្វផ្សាយដល់កសិកររយើងនូវវិធីសាស្ត្រគ្រប់គ្រងធនធានជលផលអោយមានប្រសិទ្ធភាពនៅតាមតំបន់ ដែលមានទឹកធម្មជាតិនៅក្នុងស្រុក ដោយជួយរៀបចំបង្កើតអោយមានសហគមន៍គ្រប់គ្រងនៅតាមមូលដ្ឋាន ដើម្បីអោយប្រជាកសិករបានយល់ច្បាស់ពីតួនាទី និងភារកិច្ចក្នុងការគ្រប់ក្រងជលផលក្នុងតំបន់របស់ខ្លួន។ ក្រៅពីនេះផ្នែកជលផលស្រុកបានសហការជាមួយគម្រោងនានាអនុវត្តការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងគោលបំណង ដើម្បីជានាការផ្គត់ផ្គង់ម្ហូបអាហារនៅគ្រប់តំបន់ ដែលប្រជាកសិករកំពុងទទួលការខ្វះខាតសាច់ត្រីទទួលទាន។ បច្ចុប្បន្នមានកសិករជាច្រើនគ្រួសារបានទទួលការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីពីមន្ត្រីជំនាញជលផលសហការជាមួយបណ្តាអង្គការនានា និងដោយមានការចូលរួមផ្សព្វផ្សាយពីកសិករផង ទាំងនេះបានធ្វើអោយពួកគាត់កំពុងមានសកម្មភាពចិញ្ចឹមត្រី និងឈានទៅរកការផលិតកូនត្រីពូជនៅតាមតំបន់របស់ខ្លួនទៀតផង។ ក្នុងនោះមន្ទីរការងារស្រុកក៏បានធ្វើពិធីលែងកូនត្រីចំនួន ៥០.០០០កូន(នៅទំបន់ព្រៃផ្តៅ) និងបំផុសប្រជាពលរដ្ឋអោយចិញ្ចឹមកូនត្រីតាមលក្ខណៈគ្រួសារថែមទាំងបានចុះទៅបើកវគ្គបណ្តុះបណ្តាលនៅតាមបណ្តាឃុំនីមួយៗជាក់ស្តែងនៅក្នុងឃុំស្រែក្នុងបានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីបានចំនួន ៣០វគ្គ ស្មើនឹង ០៦ភូមិ ក្នុងនោះមានការចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារចំនួន ១៥កន្លែង។ នៅឃុំស្រែចែង បានបើកវគ្គបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារបានចំនួន ០២វគ្គ។ ដោយឡែកនៅក្នុងឃុំច្រេសវិញ បានបើកវគ្គបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារបាន

ចំនួន ០២វគ្គ។ ដោយឡែកនៅក្នុងឃុំប្រេសវិញ បានបើកវគ្គបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារបានចំនួន ០២វគ្គ។ ចំណែកនៅក្នុងឃុំស្រែក្នុងវិញ បានបើកវគ្គបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារបានចំនួន ០៤វគ្គ ស្មើនឹង ០៤ភូមិ និងបានធ្វើបទបង្ហាញ០១វគ្គនៅភូមិតាទែន។

៤.២.៣ ស្ថានភាពក្រីក្ររបស់ប្រជាពលរដ្ឋស្រុកជុំគីរី

ភាពក្រីក្រជាកត្តាចម្បងបំផុត ដែលប្រទេសនីមួយៗបានជួបប្រទះរួចមកហើយ និងកំពុងជួបប្រទះជាក់ជាមិនខានក្នុងពេលអនាគត ជាពិសេសនៅក្នុងប្រទេសកម្ពុជាយើង ដែលជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់កំពុងអភិវឌ្ឍន៍បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមអស់ជាងពីរទសវត្សកន្លងមក។ រាល់ហេដ្ឋារចនាសម្ព័ន្ធត្រូវបំផ្លាញដល់កម្រិតសូន្យ។ សង្គ្រាមបានជន្លៀសប្រជាជនអោយវិនាសព្រាត់ប្រាស់គ្រួសារ ឃ្លាតលំនៅឋាន និងបានបន្សល់ទុកនូវស្ត្រីមេម៉ាយ ជនពិការ កុមារកំព្រា មនុស្សចាស់ជរា ជនងាយរងគ្រោះបាត់បង់នូវកម្លាំងពលកម្ម ដែលជាបន្ទុកដ៏ធ្ងន់ធ្ងររបស់រាជរដ្ឋាភិបាលក្នុងការរែកពន់។ ដោយឡែកនៅស្រុកជុំគីរី ជាស្រុកមួយនៃខេត្តកំពត ដែលព័ទ្ធជុំវិញដោយតំបន់ព្រៃភ្នំ សំបូរទៅដោយធនធានធម្មជាតិសព្វបែបយ៉ាង ដីមានជីជាតិល្អ មានអាងទឹក ទំនប់ប្រឡាយ ដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពរដ្ឋក្នុងការប្រកបមុខរបរដាំដុះរបស់ពួកគាត់។ តែដោយសារការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកជុំគីរីទាំងមូលនៅតាមបទពិសោធន៍ កម្រិតទាបនៅឡើយ និងការឆ្លងកាត់នូវសង្គ្រាមជាងពីរទសវត្ស កន្លងមកធ្វើអោយជីវភាពរស់នៅរបស់ពួកគាត់ជួបប្រទះនូវភាពក្រីក្រ ដែលជាបញ្ហាប្រឈម។ លើសពីនេះទៀត ភាគច្រើនពុំបានចូលរៀនគ្រប់ៗគ្នា ហើយកុមារមិនបានចូលរៀនសុទ្ធសឹងជាកុមារ ដែលឪពុកម្តាយ និងអាណាព្យាបាលទីទ័លក្រជួបការលំបាកលំបិនបំផុតក្នុងបញ្ហាជីវភាពរបស់ពួកគាត់។ តាមការស្រង់ស្ថិតិប្រជាពលរដ្ឋក្រីក្រនៅស្រុកជុំគីរី ឆ្នាំ២០០៧ ដែលមានប្រជាពលរដ្ឋសរុបចំនួន ៩.៣៣៧ គ្រួសារ មានគ្រួសារក្រីក្រចំនួន ៣៩៤គ្រួសារ[១៣៥]។ ដូច្នេះ យើងអាចអោយនិយមន័យនៃភាពក្រីក្រថា ជាកង្វះខាតនៅប្រាក់ចំណូល ឬការប្រើប្រាស់ និងការគ្មានកាលានុវត្តភាព ខ្វះការអប់រំ ការគ្មានសិទ្ធិអំណាច និងការរើសអើងប្រឆាំងស្ត្រី។ ម្យ៉ាងទៀត អ្នកខ្លះធ្លាក់ក្នុងភាពក្រីក្រនៅក្នុងខណៈពេលដែលអ្នកខ្លះរួចផុតពីភាពក្រីក្រ។ យោងតាមការអង្កេត ការរកឃើញទាំងលាយអំពើការវិភាគបរិមាណ នៃភាពក្រីក្រ ដែលបានធ្វើពីមុនមកបានបន្ថែម និងជូនព័ត៌មានជាទូលាយដោយលទ្ធផលនៃការវាយតម្លៃនៃភាពក្រីក្រ ដោយមានការចូលរួម ដែលបានធ្វើឡើងនៅកក្នុងទ្រុងទ្រាយទូទាំងប្រទេសពីចុងខែតុលា ដល់ពាក់កណ្តាលខែធ្នូ ឆ្នាំ២០០៧ ដោយបានធ្វើការវាយតម្លៃភាពក្រីក្រពីកត្តាដូចជា: អ្នកកក្រខ្វះខាតសន្តិសុខស្បៀង អ្នកខ្លះមានវិបត្តិជីវិតជម្រុញអោយមានការចូលរួមពីអ្នកក្រីក្រ ដែលបណ្តាលមកពីមនុស្សក្រីតែក្រថែមទៀត។ រីឯអ្នកក្រខ្លះខ្វះខាតនូវការទទួលយកធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម ហើយនឹងសេវាកម្មជាមូលដ្ឋាននានា។ ហើយអ្នកក្រជាអ្នក

---

[១៣៥] របាយការណ៍ស្តីពី សន្និបាតបូកសរុបលទ្ធផលការងារគ្រប់វិស័យទូទាំងស្រុកជុំគីរី ឆ្នាំ២០០៧ ទំព័រទី១-១៥

គ្មានអំណាចមានអារម្មណ៍គ្មានសង្ឃឹមលើជីវិតរបស់ខ្លួន និងកូនចៅរបស់ខ្លួន និងជួបតែការបាត់បង់ក្នុងគ្រួសារ និងការទំនាក់ទំនងក្នុងសហគមន៍។ ពេលខ្លះអ្នកក្រខ្វះខាតទំនុកចិត្តលើរដ្ឋបាលភូមិ ឃុំ ស្រុក និងខេត្ត[១៣៦]។

ដោយឡែកនៅស្រុកជុំគីរី ភាពក្រីក្រជាបញ្ហាប្រឈម ដែលមានអត្រាខ្ពស់បំផុតនៅក្នុងស្រុក ចំពោះក្រុមគ្រួសារប្រកបរបរដោយពឹងផ្អែកលើកសិកម្មទាំងស្រុង និងមានលក្ខណៈមួយចំនួនទៀតនៃអន្តរកាលរបស់កម្ពុជាក្រោយសង្គ្រាម គឺហេតុការណ៍ពិតជាក់ស្តែងអំពីកង្វះធនធានមនុស្សគ្រប់កម្រិត ពិសេសប្រជាពលរដ្ឋរស់នៅស្រុកជុំគីរី ការយល់ដឹងរបស់ពួកគាត់នៅមានកម្រិតទាបនៅឡើយ ដែលធ្វើអោយជីវភាបរស់នៅរបស់ពួកគាត់មានការលំបាកលំបិនសព្វបែបយ៉ាងទាំងផ្នែកសេដ្ឋកិច្ច ក៏ដូចជា អប់រំក្នុងការទទួលបានព័ត៌មានផ្សេងៗពីសង្គមរបស់ខ្លួន។ ដូចនេះ ឃើញថាផលវិបាកទាំងនេះ គឺជារបាំងដែលរារាំងអ្នកក្រីក្រមិនអោយចូលរួមពេញលេញនៅក្នុងចរន្តរបស់សង្គមដោយសារកត្តាទាំងឡាយដូចជា: ភាពអវិជ្ជា គ្មានលទ្ធភាពចូលរួមក្នុងការសម្រេចចិត្តនានា និងបានទទួលនូវការរើសអើង និងកង្វះសមត្ថភាព និងលទ្ធភាព[១៣៧]។ តាមការអង្កេតរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានសហការជាមួយនឹងអង្គការយូណេស្កូបានធ្វើការសន្និដ្ឋានថា **អ្នកក្រីក្រ និងអ្នកអវិជ្ជា គឺជាក្រុមមនុស្សតែមួយ**។

ក-ផែនការកាត់បន្ថយភាពក្រីក្រស្រុកជុំគីរី តាមវិស័យកសិកម្ម(១៩៩៦-២០០៣)

យោងតាមគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា បានលើកយកនូវគោលការណ៍កាត់បន្ថយភាពក្រីក្រក្នុងការធានានូវសន្តិសុខស្បៀងបង្កើនកំណើនកសិកម្មប្រកបដោយប្រសិទ្ធភាព ដោយរក្សាបាននូវបរិស្ថានធម្មជាតិ ជម្រុញការប្រណាំងប្រជែង និងគោរពនូវគោលការណ៍អភិវឌ្ឍន៍ប្រកបដោយសមធម៌ យុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មបានផ្តោតលើចំណុចសំខាន់ៗដូចតទៅ:

១.រក្សាបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសមស្រប និងគោលនយោបាយលើកទឹកចិត្ត និងបរិស្ថាន ដែលមានភាពអនុគ្រោះ។

២.ពន្លឿនការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រប្រកបដោយចីរភាព រួមទាំងធានាដល់កសិករអាចគ្រប់គ្រងទឹកបានយ៉ាងខ្លាំងឡើងៗ។

៣.អភិវឌ្ឍន៍ការដាំដុះមានផលិតភាពខ្ពស់ និងឈរលើមូលដ្ឋានដាំដំណាំច្រើនមុខ។

៤.អនុវត្តន៍អោយបានធាប់រហ័សនូវការចេញកម្មសិទ្ធិ និងការបែងចែកដីកសិកម្ម ដែលទទួលបានពីការដោះមីន។

---

[១៣៦] ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ៥ឆ្នាំ លើកទី២ ឆ្នាំ២០០១-២០០៥ ទំព័រទី៣៦

[១៣៧] យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០០ ទំព័រទី១០-១១

៥.រកទីផ្សារនាំស្រូវចេញ និងកសិផលផ្សេងទៀត ទន្ទឹមនឹងការពង្រឹងការកែច្នៃកសិផល និងប្រព័ន្ធគ្រប់គ្រងគុណភាពកសិផល។

៦.ពង្រឹងសេវា និងការគ្រប់គ្រងវិស័យកសិកម្មសំខាន់ៗរួមមាន ការផ្សព្វផ្សាយកសិកម្ម ការស្រាវជ្រាវ ការអភិវឌ្ឍន៍ផ្នែកទីផ្សារ ឥណទាន និងមានការបែងចែកវត្ថុធាតុដើមកសិកម្ម។

៧.ពង្រឹងការចិញ្ចឹមសត្វ ផ្តោតលើការថែរក្សាសុខភាពសត្វ អាហារសត្វ ការគ្រប់គ្រងកសិដ្ឋានក្នុងការចិញ្ចឹមមាន់ ការចិញ្ចឹមជ្រូក និងការផលិតចំណីសត្វ។

៨.ការពង្រឹងការគ្រប់គ្រង និងការដាក់អោយប្រើប្រាស់បច្ចេកទេសវិទ្យាសាស្ត្រសមស្រប សម្រាប់ចិញ្ចឹមសត្វតាមវាលស្រែ និងការចិញ្ចឹមសត្វទូទៅ។

៩.ការពង្រឹងសមត្ថភាពរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧត្តុនិយម ទាំងនូវថ្នាក់កណ្តាល និងខេត្ត/ក្រុង។

លទ្ធផលអនុវត្តន៍របស់ស្រុកជុំគីរី ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវយុទ្ធសាស្ត្របន្តបន្ទាប់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋអាជ្ញាធរស្រុកជុំគីរី ក៏ដូចជាប្រជាពលរដ្ឋស្រុកជុំគីរីផងដែរ បានខិតខំប្រឹងប្រែងនូវការប្រើប្រាស់ដីធ្លី និងធនធានទឹក ដែលមានកង្វះខាតសម្រាប់ឧបសគ្គពិសេសពេលជួបបាតុភូតធម្មជាតិ ទឹកជំនន់ ភាពរាំងស្ងួត ខ្យល់ព្យុះ និងសត្វល្អិត ដែលបានបំផ្លាញស្រូវវស្សា។ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដោយមានការចូលរួមឧបត្ថម្ភពីអង្គការនានាដូចជា អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងការខិតខំប្រឹងបែងរបស់ស្ថាប័នរដ្ឋ ក៏ដូចជាអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាកង្វះខាតរបស់ប្រជាពលរដ្ឋស្រុកជុំគីរី ពិសេសផ្តោតទៅលើប្រជាពលរដ្ឋរស់នៅតាមបណ្តាឃុំចំនួន បី ក្នុងចំណោម ប្រាំពីរឃុំ គឺឃុំច្រេស ឃុំស្រែក្នុង និងឃុំស្រែចែង ដែលប្រជាពលរដ្ឋកំពុងរស់នៅទីនោះតែងតែជួបការលំបាកនៅក្នុងជីវភាព ហើយពួកគាត់បានប្រឹងប្រែងធ្វើអោយបានល្អប្រសើរឡើងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋយើង។

យោងតាមរបាយការណ៍របស់វិស័យកសិកម្មនៅស្រុកជុំគីរី ដែលបានអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងឆ្នាំ២០០២ ដែលរួមមានការបង្កបង្កើនផលស្រូវប្រាំងដើមរដូវ និងស្រូវវស្សា និងដំណាំរួមផ្សំអនុវបាន: ១-ស្រូវប្រាំងអនុវបាន ៩០៧ហិកតា ទិន្នផល ២.៥តោនក្នុង១ហិកតា។ ២-ស្រូវចំការ ១៥ហិកតា។ ៣-ស្រូវដើមរដូវ ១១០៦ហិកតា ស្រូវធ្ងន់១១ហិកតា ស្រូវអ៊ីអារ ១៩ហិកតា សរុប១១៣៦ហិកតា។ ៤-បញ្ចប់ការស្ទងសរុបបាន១០៥៦១ហិកតា។ ៥-ស្រូវវស្សា ៦៧៨៥ ហិកតា។ ៦-ដំណាំរួមផ្សំសរុប១០៤០ហិកតា រួមមានដំឡូងមី១៨៣ហិកតា ដំឡូងជ្វា១៥៣ហិកតា ពោត ២០០ហិកតា បន្លែគ្រប់មុខ១៧៧.៥០ហិកតា សណ្តែកគ្រប់មុខ១០៣ហិកតា ក្នុងនោះសណ្តែកបាយ ១២៩.៥០ហិកតា សណ្តែកដី៤៤ហិកតា អំពៅ៥០ហិកតា។

ទិន្នផលបង្កបង្កើនផលស្រូវរដូវវស្សាគិតពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០៣ របស់ស្រុកជុំគីរី

ឆ្នាំ	ផែនការស្នូង (ហ.ត)	ផែនការអនុវត្តមាន(ហ.ត)	ភាគរយ (%)
១៩៩៩	១៣.០០០	១២.៦៣៦	៩៧,២
២០០០	១៣.០០០	១២.៥២០	៩៦,៣០
២០០១	១៣.០០០	១០.៦២២	៨១,៧០
២០០២	១៣.០០០	១០.៥៦១	៨១,២៣
២០០៣	១៣.០០០	១០.៥៥៤.៥០	៨១,១៩

ប្រភព: របាយការណ៍បូកសរុប ការងារស្រុកជុំគីរី ឆ្នាំ២០០៣

ចំណែកការគ្រប់គ្រងធនធានធម្មជាតិរបស់ស្រុកជុំគីរី ក្រោយពីរងការបំផ្លិចបំផ្លាញដោយសង្គ្រាមជាងពីរទសវត្ស និងការកាប់ទន្ទ្រានបំផ្លាញព្រៃឈើជាបន្តបន្ទាប់កន្លងមក ដោយការមើលឃើញពីតថភាពបាត់បង់ធនធានធម្មជាតិបែបនេះ រាជរដ្ឋាភិបាលកម្ពុជាយើងបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ និងបានចាត់វិធានការចាំបាច់យ៉ាងម៉ឺងម៉ាត់សំដៅប្រយុទ្ធប្រឆាំងនឹងបទល្មើសព្រៃឈើ។ ពិសេសក្នុងអាណត្តិទី២ របស់រាជរដ្ឋាភិបាល បានចេញសេចក្តីសម្រេចលុបចោលនៅកិច្ចសន្យា ព្រៃសម្បទានដែលបានធ្វើឡើងក្នុងជំនាន់រាជរដ្ឋាភិបាលអាណត្តិទី១ ចំនួន ១៥ក្រុមហ៊ុន គិតជាផ្ទៃដីសរុប ៣លានហិកតា ដែលក្នុងនោះរាជរដ្ឋាភិបាលបានប្រកាសដាក់ជាតំបន់ការពារ និងអភិរក្សព្រៃឈើវិញប្រមាណ ១លាន ៣សែនហិកតា។ លើសពីនេះទៀតសោត រាជរដ្ឋាភិបាលកម្ពុជាយើង បានចាត់ទុកកំណែទម្រង់ព្រៃឈើថា ជាអាយុជីវិតនយោបាយរបស់ខ្លួន ថែមទាំងបានបង្កើតនៅទិវាពលកម្មដាំដើមឈើជាប្រពៃណីជាតិនេះ គឺជាការអនុវត្តចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការពារធនធានធម្មជាតិ ពិសេសក្នុងគោលដៅគាំទ្រដល់សកម្មភាពថែរក្សាការពារព្រៃឈើ សត្វព្រៃ និងដាំដើមឈើគ្រប់ប្រភេទឡើងវិញពីព្រោះថា (ព្រៃឈើ ជាសរសៃឈាមក្នុងវិស័យកសិកម្ម ជាអាយុជីវិតរបស់ប្រជាកសិករ និងជាប្រភពនៃកំណើនសេដ្ឋកិច្ច ដូច្នេះ យើងត្រូវរួបរួមគ្នាថែរក្សាការពារព្រៃឈើ និងដាំដើមឈើអោយបានគ្រប់ៗគ្នា)[១៣៨]។ ដោយសារសង្គ្រាម និងទំនាស់ផ្ទៃក្នុងអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ បានបំផ្លិចបំផ្លាញ និងបន្សល់ទុកអោយយើងនូវផលវិបាកយ៉ាងធ្ងន់ធ្ងរច្រើនរាប់មិនអស់ ពិសេសគឺភាពក្រីក្រ។ សង្គ្រាម និងភាពក្រីក្រ បានដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរទៅលើធនធានធម្មជាតិ ពិសេស ព្រៃឈើ និងសត្វព្រៃ ដែលក្នុងនោះតំបន់ព្រៃឈើនៅស្រុកជុំគីរី ក៏ទទួលរងគ្រោះនូវការបំផ្លិតបំផ្លាញ ការកាប់ឆ្ការទន្ទ្រានរុករានព្រៃឈើ និងការបរបាញ់សត្វយ៉ាងរង្គាលផងដែរ។

---

[១៣៨] សន្ទរកថា របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ថ្លែងក្នុងពិធីបុណ្យ "វុក្ខទិវា" នៅតំបន់ដីជំរាលក្បាលឆាយ ក្រុងព្រះសីហនុ នៅថ្ងៃទី០៩ កក្កដា ឆ្នាំ២០០៣

ក្រោយពីបានអនុវត្តតាមគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហាព្រៃឈើអាជ្ញាធរស្រុកជុំគីរី បានខិតខំបង្ក្រាបរាស់បទល្មើស និងសត្វព្រៃ ដោយបានយកចិត្តទុកដាក់ ការដាំដើមឈើឡើងវិញ ជាលក្ខណៈចម្ការ គ្រួសារ ដោយមានការដាំនៅតាមភូមិឋាន តាមវត្តអារាម តាមទីសាធារណៈ តាមប្រព័ន្ធទំនប់ប្រឡាយ និងនៅតាមដងវិថីនានា ដែលជាឧត្តមប្រយោជន៍ដ៏មានសារៈសំខាន់ក្នុងការលើកស្ទួយដល់បរិស្ថានធម្មជាតិ។ ដើម្បីឆ្លើយតបតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី២ ជាក់ស្តែងនៅស្រុកជុំគីរី បានបង្កើតនូវសមាគមព្រៃឈើមួយនៅក្នុងឃុំស្រែក្នុង ដោយបានពង្រឹងការណែនាំអោយប្រជាពលរដ្ឋបានយល់ច្បាស់ពីសារៈសំខាន់នៃព្រៃឈើ និងបានអប់រំរៀនសូត្រអោយប្រជាពលរដ្ឋចេះថែទាំសម្បត្តិធម្មជាតិ ដូចសត្វព្រៃ ថែមទាំងលុបបំបាត់រាល់បទល្មើសបរិស្ថានធម្មជាតិ និងបានពង្រីកការដាំកូនឈើបន្ថែមទៀត ក្នុងភូមិសាស្ត្រជាបន្តបន្ទាប់។

ខ-ការកាត់បន្ថយភាពក្រីក្រស្រុកជុំគីរី តាមវិស័យកសិកម្ម(២០០៤-២០០៨)

ទន្ទឹមនឹងការធានាជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ សម្រាប់ដោះស្រាយការងារជូនប្រជាពលរដ្ឋ កម្ពុជាប្រកបដោយសមធម៌ និងយុត្តិធម៌សង្គម តាមរយៈផែនការសកម្មភាពអភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងការធានារក្សានូវប្រសិទ្ធភាពការងារ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តន៍កម្មវិធីកំណែទម្រង់គ្រប់ផ្នែក គ្រប់វិស័យសំដៅដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ របៀបរៈគោលនយោបាយដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលអាណត្តិទី៣ នៃរដ្ឋសភាកន្លងមកបានអនុវត្តន៍គោលនយោបាយ ផ្តោតសំខាន់ទៅលើវិស័យកសិកម្មអាត្តិភាពចម្បងបំផុតទទួលបាននូវសក្តានុពលលទ្ធផលជាផ្លែផ្កាជោគជ័យយ៉ាងធំធេង ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ដើម្បីឈានដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ យ៉ាងណាក៏ដោយ កំណើននេះនៅមានកម្រិតទាបនៅឡើយ ជាពិសេសប្រជាពលរដ្ឋនៅតាមទីជនបទ ដែលប្រកបរបរកសិកម្មជាំដុះនៅតែងាយទទួលរងគ្រោះដោយសារអស្ថេរភាពវិបត្តិផ្សេងៗពីខាងក្រៅ និងការងាយរងគ្រោះពីធម្មជាតិជាដើម។ ដូច្នេះ បញ្ហានេះយើងចាំបាច់ត្រូវតែពង្រឹងនូវកំណើនសេដ្ឋកិច្ចជាតិ ដោយប្រើអោយអស់នូវសក្តានុពលសេដ្ឋកិច្ចក្នុងការពង្រីកនូវវិសាលភាព សេដ្ឋកិច្ចទៅលើវិស័យផ្សេងៗទៀតអោយបានកាន់តែច្រើនពិសេស គឺវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដែលមានសក្តានុពលធ្វើអោយមានកំណើនថែមទៀត និងអាចផ្តល់ផលជាវិជ្ជមានបានយ៉ាងរហ័ស ដើម្បីរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទទៀតផង។

គោលនយោបាយកសិកកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់ផលិតភាពកសិកម្ម អោយក្លាយទៅជាវិស័យនាំមុខមួយ ដែលអាចផ្តល់ជីវភាពបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីកក្រ។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលបានបន្តផ្តល់អាទិភាពខ្ពស់ទៅលើការលើកកម្ពស់ផលិតភាព និងការធ្វើពិភាវូបនីយកម្មកសិកម្ម ព្រមទាំងបន្តជម្រុញកសិ-ពាណិជ្ជកម្ម។ រាជរដ្ឋាភិបាលនឹង

បង្កើនការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់អនុវត្តន៍ពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដើម្បីធានាបាន និរន្តរភាពនៃកំណើនសេដ្ឋកិច្ចជាតិ បង្កើនការងារ និងបង្កើនប្រាក់ចំនូលនៅជនបទព្រមទាំងធានានូវសន្តិសុខ ស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើអោយប្រសើរឡើងនូវអាហារូបត្ថម្ភ និងការនាំចេញកសិផលក្នុងន័យនេះ ការបង្វែរទិសពីការអភិវឌ្ឍន៍បែប "**បើកទូលាយ**" ឬតាមបែប "**វិបុលកម្ម** ទៅកាន់ការអភិវឌ្ឍន៍តាមបែប"**ស៊ីជម្រៅ**" ឬតាមបែប "**ប្រពលកម្ម**" ពោលគឺ ការពង្រឹងសមត្ថភាពចិញ្ចឹមលើផ្ទៃដី ដែលមានស្រាប់តាមរយៈប្រពលវប្បកម្ម បានក្លាយទៅជាអាទិភាពដ៏ខ្ពស់បំផុតមួយរបស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាល និងជម្រុញបង្កើតបរិយាកាសល្អសម្រាប់ការចូលរួមរបស់ផ្នែកឯកជន ដើម្បីការលូតលាស់ នៃវិស័យកសិកម្ម តាមរយៈការប្រឹងប្រែងពន្លឿន ការផ្តល់កម្មសិទ្ធិដីធ្លីនៅតាមតំបន់ជនបទក្នុងទិសដៅពង្រឹង សុវត្ថិភាព នៃការកាន់កាប់ដីធ្លីសម្រាប់កសិកម្ម ការពង្រីក និងការបែងចែកដីធ្លីកសិកម្មក្នុងក្របខ័ណ្ឌដីសម្បទាន សង្គមកិច្ច ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រងធនធានទឹកដោយយកចិត្តទុកដាក់ផងដែរ ដល់ ការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់នៅប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់បន្តការស្តារបន្ថែម និងពង្រឹងគុណ ភាពសហគមន៍អ្នកប្រើប្រាស់ទឹក ព្រមទាំងការកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និងការពឹងផ្អែក ទាំងស្រុងលើលក្ខខ័ណ្ឌធម្មជាតិ។ល។

ក្នុងទិសដៅជម្រុញផលិតភាពកសិកម្មរាជរដ្ឋាភិបាល និងយកចិត្តទុកដាក់បន្ថែមទៀត ចំពោះការពង្រីក សេវាកម្មគាំទ្រដល់វិស័យនេះ ដូចជា ការងារស្រាវជ្រាវ និងផ្សព្វផ្សាយការអភិវឌ្ឍន៍ទីផ្សារកសិកម្ម ការបែងចែក សម្ភារៈ ពូជ ជី និងការផ្តល់ឥណទានជនបទ។ល។ ក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាព ជាពិសេសទៅលើការតម្រង់ទិសកិច្ចការវិនិយោគសាធារណៈ និងការលើកទឹកចិត្តវិនិយោគឯកជនអោយឆ្ពោះ ទៅរកវិស័យកសិកម្មសំដៅរកការលើកកម្ពស់កំណើនកសិផល និងធានាគុណភាពកសិផលកម្ពុជាអោយបាន ឆ្លើយតបទៅនឹងតម្រូវការនៃស្តង់ការដាអន្តរជាតិ។

រាជរដ្ឋាភិបាល បន្តផ្តល់អាទិភាពទៅលើកិច្ចការអភិវឌ្ឍន៍តំបន់ព្រំដែន និងតំបន់ទីជនបទដាច់ស្រយាល ដើម្បីទប់ស្កាត់នៅការចំណាកស្រុកតាមការរៀបចំ និងកសាងតំបន់ទីប្រជុំជនមួយចំនួន ដែលមានបណ្តាញ ហេដ្ឋារចនាសម្ព័ន្ធសមស្របសម្របសម្រួលដល់ជីវភាពរស់នៅ និងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជា ពលរដ្ឋនៅទីនោះ។

រាជរដ្ឋាភិបាល បានបន្តជម្រុញចលនា "**ភូមិមួយ-ផលិតផលមួយ**" ដើម្បីលើកស្ទួយគំនិតច្នៃប្រឌិត និង ជំនឿលើខ្លួនឯងរបស់ប្រជាំពលរដ្ឋនៅតាមជនបទ ដោយឈរលើគោលការណ៍សំខាន់ៗបួនយ៉ាងគឺ: ១-ការរិះរក វិធីផលិត ដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃបរិស្ថានភូមិឋាន និងសមស្របទៅតាមសេចក្តីត្រូវការ របស់ទីផ្សារ។ ២-ការបង្កលក្ខណៈងាយស្រួល និងការផ្តល់ការលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការផលិត ដូចជា ការស្វែងរកទីផ្សារផ្តល់ឥណទាន ការផ្ទេកបច្ចេកវិទ្យា និងការផ្តល់ពូជ។ ៣-ការជួយបណ្តុះបណ្តាលសមត្ថភាព

គ្រប់គ្រង និងធនធានមនុស្ស។ ៤-បង្កលក្ខណៈងាយស្រួលអោយប្រជាពលរដ្ឋបង្កើតសហគមន៍កសិកម្មក្នុងទិសដៅធានាតម្លៃផលិតផល។

ដី និងទឹក គឺជាធនធានធម្មជាតិដ៏សំខាន់បំផុតសម្រាប់ទ្រទ្រង់ជីវិតរាល់សកម្មភាពទាំងអស់ និងការរីកចម្រើនរបស់មនុស្ស ដែលបានប្រព្រឹត្តនៅលើផែនដីនេះ ដែលមានមូលដ្ឋានពីរសម្រាប់យកមកប្រើប្រាស់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចដល់ការកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតាមជនបទ។ ដោយបន្តអនុវត្តន៍ច្បាប់ភូមិបាល និងគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលផ្តុំចាត់វិធានការពង្រឹងការគ្រប់គ្រងបែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយចីរភាព និងសមធម៌ ដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី និងការបែងចែកដីធ្លី ការធានាសុវត្ថិភាព វិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រើមិនធ្វើផលិតកម្ម ឬអាជីវកម្ម។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលបានពិនិត្យឡើងវិញនូវដីទំនេរបស់រដ្ឋ ឬដីរដ្ឋ ដែលឯកជនកាន់កាប់ដោយមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក រាជរដ្ឋាភិបាលបាននឹងបន្តផ្តល់អាទិភាពដល់ការពង្រឹងសិទ្ធិ កាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋដែលត្រូវការដីធ្លីសម្រាប់សាងសង់លំនៅឋាន និងធ្វើអាជីវកម្មកសិកម្មជាគ្រួសារក្នុងក្របខ័ណ្ឌដីសម្បទាន ដើម្បីគោលដៅសង្គមកិច្ចដោយឈរលើគោលការណ៍ជួយគ្រួសារក្រីក្រ និងជនងាយរងគ្រោះ។

រាជរដ្ឋាភិបាល ក៏បានផ្តោតការយកចិត្តទុកដាក់ទៅលើ ការបោសសំអាតមីន ដែលបញ្ហានេះមិនត្រឹមតែធានាអោយមានសន្តិសុខមួយមុខនោះទេ តែវាជាបញ្ហាសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ជារួមជាពិសេសដីសម្រាប់ប្រកបរបរកសិកម្ម ក៏ដូចជា ការផ្តល់នូវសុវត្ថិភាពក្នុងការធ្វើអាជីវកម្មរបស់ប្រជាពលរដ្ឋយើង នៅតាមទីជនបទជាច់ស្រយាល ដែលតែងតែរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

ដោយឡែកនៅស្រុកជុំគីរី ដែលជាកោសិកាមួយ នៃសង្គមស្ថិតនៅតំបន់ជនបទជាច់ស្រយាលពីក្រុង ក្រោយពីបានអនុវត្តតាមគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលអាណត្តិទី៣ នៃរដ្ឋសភាតាមគោលនយោបាយស្តីពីការកាត់បន្ថយភាពក្រីក្រតាមបែបបច្ចេកវិទ្យាស៊ីជម្រៅ ដើម្បីកែប្រែជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយបានល្អប្រសើរឡើង និងការចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រអោយបានឆាប់នោះអាជ្ញាធរដែនដីស្រុកជុំគីរី បានចូលរួមយ៉ាងសកម្មអនុវត្តន៍សម្រេចភារកិច្ចបានយ៉ាងធំធេងនានា ដើម្បីចូលរួមចំណែក ការស្ថារនិងអភិវឌ្ឍន៍ប្រទេសជាតិសំដៅធ្វើយ៉ាងណាគោរពអនុវត្តន៍អោយបាននូវផែនការបទបញ្ជាទិសដៅក៏ដូចជា ការពិនិត្យសម្របសម្រួល និងជំរុញដល់សកម្មភាពមូលដ្ឋានភូមិ ឃុំ ឆ្ពោះទៅកាន់ជោគជ័យជាក់ស្តែងកក្នុងឆ្នាំ ២០០៧ កន្លងមកនេះអាជ្ញាធរ ស្រុកជុំគីរីអនុវត្តន៍ការងាររបស់ខ្លួនដោយបានទទួលនៅលទ្ធផលគួរជាទីមោទនៈដូចខាងក្រោម:

ផ្នែកទី១- ការបង្កបង្កើនផល និងការប្រមូលផលស្រូវវស្សាឆ្នាំ២០០៧-២០០៨ អនុវត្តបាន:

ក-ស្រូវស្រាលអនុវត្តបាន: ៦៨៣.៥ហិកតា ទិន្នផល ៣.៤១១គោន/១ហិកតា បរិមាណផល ២៣៣១.៨០៩គោន។

ខ-ស្រូវកណ្តាលអនុវត្តបាន: ៨.៣០៩ហិកតា ទិន្នផល ៣.២៣៧តោន/១ហិកតា បរិមាណផលសរុប ២៦៩០២.៦៦៦តោន។

គ-ស្រូវធ្ងន់អនុវត្តបាន: ២១៩៦ហិកតា ទិន្នផល ៣.៧០៣តោន/១ហិកតា បរិមាណផលសរុប ៨.១៣៣តោន។

ឃ-ការងារប្រមូលផលស្រូវរដូវប្រាំឆ្នាំ២០០៧: អនុវត្តបាន ៩០០ហិកតា ទិន្នផល ២.៨០០តោន/១ហិកតា បរិមាណផល ២៥២០តោន។

គិតមកដល់ខែមីនា ឆ្នាំ២០០៨ នេះការបង្កបង្កើនផលស្រូវប្រាំងទូទាំងស្រុកអនុវត្តបានក្នុងនោះ ភ្ជួរបាន ៣៣៤ហិកតា សាបបាន៤៧ហិកតា ស្ទូងបាន១៩៦.៥ហិកតា ផ្សំជីធម្មជាតិបាន១៦៣តោន ដំណាំរួមផ្សំនូវរដូវប្រាំងអនុវត្តបាន១០៦ហិកតា។

ការងារដំណាំរួមរដូវវស្សាឆ្នាំ២០០៧ ក្រៅពីការបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០០៧ ប្រជាពលរដ្ឋ យើងក៏បានយកចិត្តទុកដាក់ប្រកបដោយដំណាំរួមផ្សំបន្ថែមទៀត ដែលលទ្ធផលជាក់ស្តែងយើងសម្រេចបានទូទាំងស្រុករួមមាន:

-ពោត : ៩៣ហិកតា

-ដំឡូងមី : ៦០ហិកតា

-ដំឡូងជ្វា : ៤០ហិកតា

-បន្លែងគ្រប់មុខ : ៨១.៥ហិកតា

-សណ្តែកបាយ : ២៣.៥ហិកតា

+ដំណាំឧស្សាហកម្មអនុវត្តបាន:

-សណ្តែកដី : ៥១ហិកតា

-អំពៅ : ៥១ហិកតា

-សរុប :១០២ហិកតា

+ការងារបណ្តុះបណ្តាលដំណាំស្រូវ:

-ការអនុវត្តបណ្តុះបណ្តាលដំណាំស្រូវជំហ៊ានទី២ ចំនួន១០វគ្គ ស្មើ១០ភូមិ ក្នុង ៥ឃុំ មានកសិករចូលរួម ៣០០នាក់ ស្រី២០០នាក់។

-ចុះពិនិត្យតាមដានជាប្រចាំនៅពេលកសិកររធ្វើស្រែ។

គួររំលឹកបង្ហាញផងដែរថា: នៅរដូវវស្សាឆ្នាំ២០០៧ កន្លងមកនេះដំណាំស្រូវវស្សាត្រូវទទួលរងនូវការបំផ្លាញដោយសត្វមមាតស្នោតយ៉ាងធ្ងន់ធ្ងរនៅលើសំណាប និងសន្ធូងរួចនៅតាមបណ្តាភូមិ ឃុំ ទូទាំងស្រុកជុំគីរី។ ប៉ុន្តែដោយមានការអន្តរាគមន៍ទាន់ពេលវេលារបស់មន្ទីកសិកម្មខេត្ត និងការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងពីអភិបាលស្រុក និងការិយាល័យកសិកម្មសហការជាមួយអាជ្ញាធរភូមិ ឃុំ និងប្រជាពលរដ្ឋធ្វើយុទ្ធនាការចុះកម្ចាត់

សត្វមមាចត្នោត តាមរយៈដាក់ថ្នាំពុលធម្មជាតិ ដាក់អំពូលមែត្រនៅពេលយប់ និងដាក់ប្រេងខ្មៅធ្វើអោយដំណាំស្រូវរបស់ប្រជាពលរដ្ឋរួចផុតពីការខូចខាតទាំងស្រុង។ ដែលទោះបីយ៉ាងនេះក្តី ក៏នៅតែមានផលប៉ះពាល់ខ្លះៗមួយចំនួនផងដែរ។

បើគិតនៅក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០០៨ ស្រុកអនុវត្តបានស្រូវប្រាំងសាបបានចំនួន ៣៧ហិកតា ស្នងបានចំនួន ១៩៦.៥តោន ស្មើនឹង១៧,៨៦% នៃផែនការ រីឯទិន្នផលបានចំនួន ២.៥៩៣តោន ក្នុង១ហិកតា បរិមាណសរុបស្មើ ៥០៩.៥៥តោន បន្លែគ្រប់មុខ១០៦ហិកតា ពោត២៨ហិកតា និងការបង្កបង្កើនផលស្រូវរដូវវស្សាសាបអនុវត្តបាន២៧១ហិកតា ស្នងបានចំនួន១០៨០ហិកតា ទិន្នផលសរុប៣.៥៨៣តោន[១៣៩]។ ស្រូវ-កណ្តាលអនុវត្តបានសាបបាន១.២៩៣ហិកតា ស្នងបាន៨.២១២ហិកតា ស្រូវធ្ងន់អនុវត្តបានសាបបាន៣៩៨ ហិកតា ស្នងបាន២២៩៣ហិកតា ស្រូវចំការអនុវត្តបានចំនួន១៣ហិកតា ក្នុងនោះដំណាមរួមផ្សំមានពោតមានចំនួន៧៥.៥ហិកតា ដំឡូងមី ៣ហិកតា ដំឡូងជ្វា៣២.៥ហិកតា សណ្តែកបាយ៤៥.៥ហិកតា សណ្តែកគ្រប់មុខ ៥៩.៥ហិកតា បន្លែគ្រប់មុខ២១ហិកតា និងដំណាំឧស្សាហកម្មរយៈពេលខ្លីរួមមាន សណ្តែកដី២៧.៥ហិកតា អំពៅចំនួន៤៣ហិកតា។

លទ្ធផលបង្កបង្កើនផលស្រូវរដូវវស្សាគិតពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០០៨ របស់ស្រុកជុំគីរី

ឆ្នាំ	ផែនការស្នង	ផ្ទៃដីអនុវត្តមាន(ហ.ត)	ភាគរយ (%)
២00៤	១១.៥0៥	១0.២២៧	៨៨.៨៩
២00៥	១១.៥0៥	១0.៧0២	៩៣,0២
២00៦	១១.៥0៥	១១.២៧៤.៥0	៩៨
២00៧	១១.៥0៥	១១.២១២.៤៦	៩៧,៤៦
២00៨	១១.៥0៥	១១.៥៩៨	១00,៨១

លទ្ធផលទាំងអស់ខាងលើនេះដែរបានបង្ហាញអោយឃើញថា ក្រោយពីបានអនុវត្តន៍តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល យើងបានទទួលជោគជ័យជាបន្តបន្ទាប់យ៉ាងល្អប្រសើរពិសេសក្នុងឆ្នាំ២០០៨ នេះមានការកើនឡើងគួរអោយកត់សម្គាល់។

[១៣៩] សាលាស្រុកជុំគីរី: របាយការណ៍បូកសរុបលទ្ធផលការងារយៈពេល ០៩ខែ ដើមឆ្នាំ២០០៨ និងទិសដៅអភិវឌ្ឍន៍បន្ត លេខ៣០៨

ផ្នែកទី២-សមិទ្ធិផល "**ភូមិ១ ផលិតផល១**"

លើសពីនេះទៀតនៅក្នុងស្រុកជុំគីរីបានបង្កើតនូវចលនា "**ភូមិ១ ផលិតផល១**" គឺជាផ្នែកមួយដ៏សំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សំដៅការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ គណៈកម្មាធិការជាតិជំរុញចលនា "**ភូមិ១ ផលិតផល១**" ត្រូវបានបង្កើតឡើងដែលមាន:

១. សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាប្រធាន

២. ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ជាអនុប្រធាន

៣. ឯកឧត្តម សុន គន្ធរ អគ្គលេខាធិការ

ចលនា "**ភូមិ១ ផលិតផល១**" នឹងផ្តល់ឱកាសជូនដល់ប្រជាកសិករនូវ: ១-បង្កើនមុខរបរថ្មីបន្ថែមដល់ស្ត្រីគ្មានការងារធ្វើ។ ២-បង្កើនប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅសម្រាប់គ្រួសារនីមួយៗ។ ៣-បន្តប្រពៃណីពីដូនតា។ ៤-លើកកម្ពស់តម្លៃសូត្រខ្មែរ។ ៥-ផ្សារភ្ជាប់ផលិតផលក្នុងស្រុកទៅនឹងទីផ្សារក្នុងប្រទេស ទីផ្សារក្នុងតំបន់ និងទីផ្សារអន្តរជាតិ។ ៦-រួមចំណែកធ្វើអោយអត្រានៃភាពក្រីក្រធ្លាក់ក្នុងកម្រិតទាប។ ៧-ធ្វើអោយប្រសើរឡើងនូវការផ្តល់អំណាចចាត់ចែងគ្រប់គ្រងដល់សហគមន៍។ ៨-បង្កើនកម្រិតនៃជំនឿជឿជាក់លើរដ្ឋាភិបាលនៅពេលអនាគត។ ៩-កាត់បន្ថយជាតិអតិបរមានូវការធ្វើចំណាកស្រុក។ ១០-បំពេញបន្ថែមកង្វះខាតស្បៀងប្រចាំខែដល់ប្រជាកសិករ។

ការផ្តល់នូវគោលនយោបាយក្នុងការអនុគ្រោះធានាដល់ការអភិវឌ្ឍន៍ ដោយក្រុមហ៊ុនឯកទេសរបស់ក្រុមសហគ្រាស **ហុងមេដា** ខេត្តធុងឈីង ប្រទេសចិន ដែលជាក្រុមហ៊ុនមានបច្ចេកទេស និងឯកទេសកម្រិតខ្ពស់មួយលើវិស័យឧស្សាហកម្មសំពត់សូត្រ ដែលធ្វើអាជីវកម្ម កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ហើយផ្តល់សេវាកម្មមានគុណភាពល្អរហូតដល់ក្រុមហ៊ុនទទួលបានកិត្តិនាមល្អប្រសើរក្នុងតំបន់ និងអន្តរជាតិ។ សហគ្រាសមានអ្នកគ្រប់គ្រង អ្នកបច្ចេកទេសវិស្វកម្ម និងអ្នកលក់ដូរដ៏ស្ទាត់ជំនាញ ព្រមទាំងមានកម្លាំងបច្ចេកទេសច្រើនបរិបូរណ៍។ ផលិតផល ដែលសម្រេចបានម៉ាករឈ្មោះ WINTUS បានលក់ដូរដល់បណ្តាប្រទេសជាច្រើននៅក្នុងទ្វីបអឺរ៉ុបទ្វីបអាមេរិកខាងជើង និងខាងត្បូងប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង និងប្រទេសឥណ្ឌាជាដើម។ ក្រុមសហគ្រាស **ហុងមាដា** បានចាត់ទុកប្រទេសកម្ពុជាជាតំបន់ថ្មី ដើម្បីពង្រីកអាជីវកម្មផលិតសូត្រ ហើយក្រុមហ៊ុនគ្រោងនឹងបង្កើននូវមូលដ្ឋានដាំដើមមន និងចិញ្ចឹមដង្កូវនាងក្នុងដំណាក់កាលទី១ ក្នុងឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ នៅលើផ្ទៃដីទំហំ ៣.០០០ហិកតា ដល់ ៥.០០០ហិកតា និងដំណាក់កាលទី២ ចាប់ផ្តើមពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១១ នៅផ្ទៃដីទំហំ ៣.០០០ ហិកតាដល់ ៥.០០០ហិកតា បន្ថែមទៀត។

ក្រោយពីបញ្ចប់ការកសាងខាងលើរួចក្រុមសហគ្រាស និងដាក់ទុនវិនិយោគកសាងរោងចក្រផលិតពត់សូត្រ ដែលអាចកែច្នៃសូត្រ ១.០០០តោន ក្នុង១ឆ្នាំ នៅប្រទេសកម្ពុជា ដល់ពេលនោះតម្លៃផលិតផលនាំចេញក្នុង ១ឆ្នាំៗ នឹងកើនលើសពី២៥លាន ដល់ ៣០លានដុល្លារអាមេរិក។ លើសពីនេះក្រុមហ៊ុនក៏បានធានាផ្តល់នូវបច្ចេកទេសការបណ្តុះបណ្តាល និងព្យល់ណែនាំដោយឥតបង់ថ្លៃដូចជា:

១. ក្រុមហ៊ុននឹងផ្តល់ប្រភេទដើមមនល្អជាងគេក្នុងប្រទេសចិន ដោយឥតបង់ថ្លៃ

២. ក្រុមហ៊ុននឹងផ្តល់ពូជដង្កូវនាងល្អជាងគេបំផុតនៅប្រទេសចិន

៣. ក្រុមហ៊ុននឹងផ្តល់សម្ភារៈល្អជាងគេក្នុងប្រទេសចិន សម្រាប់ចិញ្ចឹមដង្កូវនាង

៤. ក្រុមហ៊ុននឹងផ្សព្វផ្សាយបច្ចេកទេសល្អជាងគេនៅក្នុងប្រទេសចិន

៥. ក្រុមហ៊ុននឹងចាត់តាំងអ្នកបច្ចេកទេសជាំដើមមន និងចិញ្ចឹមដង្កូវនាងពីប្រទេសចិនមកដល់ប្រទេសកម្ពុជា ហើយស្នាក់នៅជាប្រចាំក្នុងប្រទេសកម្ពុជា ដើម្បីជួយពន្យល់ណែនាំ។

៦. ក្រុមហ៊ុននឹងផ្តល់ការបណ្តុះបណ្តាល និងណែនាំអំពីបច្ចេកទេសជាំមន និងចិញ្ចឹមដង្កូវនាងឥតបង់ថ្លៃ។

៧. ក្រុមហ៊ុននឹងផ្តល់ដង្កូវនាងតូវ។ ដែលមានគុណភាពល្អ និងមានចំនួនគ្រប់គ្រាន់។ ចំពោះការភ្ញាស់ដង្កូវនាង ការចិញ្ចឹមដង្កូវនាងតូច។(អាយុ ៣សម័យ ១ថ្ងៃ) ដែលដំណើរការជាគន្លឹះ គឺត្រូវការបច្ចេកទេស និងឯកទេសខ្ពស់សុទ្ធតែចិញ្ចឹមផ្តាច់មុខដោយក្រុមហ៊ុន។ ក្រោយពីអាយុ ៣សម័យ ក្នុង១ថ្ងៃ ទើបក្រុមហ៊ុនលក់អោយកសិករយកទៅចិញ្ចឹម ដូច្នេះ កសិករមានការងាយស្រួលបំផុតគ្រាន់តែទទួលសម្ភារៈចិញ្ចឹមដង្កូវនាងធំស្រាប់រាប់ទាំងមធ្យោបាយចិញ្ចឹមផងដែរ។

ដោយយោងទៅលើមូលហេតុសំខាន់ៗខាងលើនេះហើយ ទើបបានជាក្រុមហ៊ុនហ៊ានធានា និងព្យាករណ៍ច្បាស់ថា កសិករ ដែលទទួលយកនៅកិច្ចសន្យាជាំមន និងចិញ្ចឹមដង្កូវនាងពិតជាអាចមានលទ្ធភាពប្រកបមុខរបរនេះ ហើយអនាគតដ៏ខ្លីខាងមុខ ពិតជាបានទទួលប្រាក់ចំណូលខ្ពស់រៀងរាល់ខែ ដើម្បីលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃកាន់តែល្អប្រសើរ[១៤០]។

ដូច្នេះ ចលនាភូមិមួយផលិតផលមួយ នៅស្រុកជុំគីរី បានបង្ហាញអោយឃើញថា បានចាប់ផ្តើមដំណើរការតាំងពីអំឡុងឆ្នាំ២០០៧ មកម្ល៉េះ ប្រជាកសិករចំនួនពីរស្រុក គឺស្រុកដងទង់ និងស្រុកជុំគីរី ក្នុងខេត្តកំពត បាននាំគ្នាជាំដើមមន ដើម្បីចិញ្ចឹមនាងយកសំបុកនាងលក់ទៅអោយក្រុមហ៊ុន **ហុងមេជា** របស់ចិន ដែលបានបំផុសអោយប្រជាកសិករទាំងពីរស្រុកនេះមានមុខរបរថ្មីមួយបន្ថែមទៀត លើមុខរបរធ្វើស្រែ ដែលពុំសូវបានផលល្អប៉ុន្មាននោះពួកគាត់សុទ្ធតែបង្ហាញនៅសេចក្តីសប្បាយរីករាយ ដោយសារតែមុខរបរបន្ថែមថ្មីនេះប្រើប្រាស់រយៈពេលខ្លី ប៉ុន្តែទទួលបានប្រាក់កម្រៃយ៉ាងគួរសម។ ជារួមការចិញ្ចឹមដង្កូវនាង គឺមានរយៈពេលតែ ១៥-២០ថ្ងៃប៉ុណ្ណោះ។ អាចប្រមូលផលសំបុកនាងសម្រាប់លក់បានហើយ ហើយក្នុងរយៈពេលនោះការងាររវល់ខ្លាំងមានតែ ៣ ទៅ៥ថ្ងៃប៉ុណ្ណោះ។

ផ្នែកទី៣-យុទ្ធនាការរបស់សាលាស្រុកជុំគីរី

ក-បើវគ្គចិញ្ចឹមជ្រូកដល់កសិករចំនួន ៧វគ្គ ស្មើ ៧ភូមិ កសិករចូលរួម ២១នាក់ ស្រី១៣៣នាក់។

ខ-ការងារធារាសាស្ត្រៈ

---

[១៤០] ផ្តួចផ្តើមរៀបចំឡើងដោយឯកឧកត្តម នីម ច័ន្ទតារា អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានក្រុមការងារចុះជួយស្រុកជុំគីរី និងស្រុកដងទង់ ខេត្តកំពត

-ការជួលជុល និងកែលម្អប្រព័ន្ធស្រោចស្រព

-ជួសជុល និងស្តារប្រព័ន្ធស្រោចស្រពបានចំនួន ៣គម្រោង ក្នុងនោះរួមាន

-ជួសជុលទំនប់ស្ទឹងដូនកេ នៅឃុំស្រែចែង ដោយប្រើថវិកាអស់ទឹកប្រាក់ចំនួន ៦៥.០០០ដុល្លារ

-ស្តារប្រឡាយមេ ចេញពីទំនប់ស្ទឹងដូនកេ នៅឃុំស្នាយអញ្ចិត បាន១ខ្សែ(អង្គរពលកម្ម)

-ជួសជុល និងដាក់លូ ជ្រុងបិទបើក ទំនប់ភូមិអូរ ឃុំត្រពាំងរាំងបានមួយកន្លែង

-ស្តារប្រឡាយចេញពីទំនប់ម្លេចនៅឃុំច្រេសបានចំនួន ២ខ្សែ ដោយប្រើអង្គរពលកម្មអស់ចំនួន ២តោន ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**។

-សក្តានុពលទំនប់ទាំងបីនេះ អាចស្រោចស្រពនៅរដូវវស្សាលើផ្ទៃដីចំនួន ៧.៧០៦ហិកតា និង នៅរដូវប្រាំបានចំនួន ២.៥៦៩ហិកតា។

គ-ការងារបសុព្យាបាល:

ក្នុងឆ្នាំ២០០៧នេះ ការងារចាក់ថ្នាំការពារ និងព្យាបាលសត្វពាហនៈទូទាំងស្រុកសម្រេចបាន:

-ការចាក់ថ្នាំការពារជំងឺសាទឹកដល់គោ ២.៣២១ក្បាល ក្របី២២១ក្បាល

-ការចាក់ថ្នាំការពារជំងឺអុតក្តាមគោចំនួន ៦៣០ក្បាល ក្របី៣១ក្បាល

-ការចាក់ថ្នាំការពារជំងឺសាទឹកសត្វជ្រូក ១១៧៥ក្បាល

-ការចាក់ថ្នាំការពារជំងឺប៉េសជ្រូក ១១៥៧ក្បាល

-ការចាក់ថ្នាំការពារជំងឺរាគរូសជ្រូក ១១៥៥ក្បាល

ឃ-ការពិនិត្យ និងព្យាបាលសត្វពាហនៈ:

-ចាក់ថ្នាំព្យាបាលសត្វគោចំនួន ៤២៤ក្បាល ជាសះស្បើយ៤១៧ក្បាល

-ចាក់ថ្នាំព្យាបាលក្របីចំនួន១១៥ក្បាល ជាសះស្បើយ១១១ក្បាល

-ចាក់ថ្នាំព្យាបាលសត្វជ្រូកចំនួន ១៩៣២ក្បាល ជាសះស្បើយ១៥៧០ក្បាល

ង-ការងារសុរិយោដី:

គិតមកដល់ខែមីនា ឆ្នាំ២០០៨ នេះការងារវាស់វែងដីជាលក្ខណៈប្រព័ន្ធជូនប្រជាពលរដ្ឋទូទាំងស្រុកអនុវត្តបាន:

-ប្រមូលទិន្នផលសម្រេចបាន =៣៣.២៥៩ក្បាលដី

-បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ =៣២.៦៨២ក្បាលដី

-គូសក្រាហ្វិចក្នុងកុំព្យូទ័រ =២៨.៩៤០ក្បាលដី

-វាស់ដោយម៉ាស៊ីន =៧.០៥៤ក្បាលដី

-បិទផ្សាយទិន្នន័យសាធារណៈ =២៣.៥៦០ក្បាលដី

-ប័ណ្ណចុះហត្ថលេខារួច =២០.៤៤៦ប័ណ្ណ

-ប័ណ្ណចែករួច =១៧.០៣៨ប័ណ្ណ

-ប័ណ្ណនៅសល់ =៣.៤០៨ប័ណ្ណ

ច-ការងារសាធារណៈការ និងដឹកជញ្ជូន:

-ការងារជួសជុល និងថែទាំផ្លូវ

-ជួសជុលផ្លូវអភិវឌ្ឍន៍ជុំគីរី-ឈូក ដោយចាក់ដីលុបសំបុកមាន់ និងកាប់ឆ្ការព្រៃនៅតាមដងផ្លូវអភិវឌ្ឍន៍នានាក្នុងបានល្អប្រសើរ។

-ធ្វើផ្លូវជាតិលេខ៤១ ដោយកម្លាំងគ្រឿងចាក់របស់កងវិស្វកម្ម ក្នុងភូមិសាស្ត្រស្រុកជុំគីរី ប្រវែង ២៩គីឡូម៉ែត្រ។

-ក្រាលគ្រួសក្រហមរួចបានប្រវែង ១៨គីឡូម៉ែត្រ។

ផ្នែកទី៤-ការងារគ្រប់គ្រងព្រៃឈើ

ប្រទេសកម្ពុជាយើង ជាប្រទេសមួយសម្បូរណ៍ទៅដោយធនធានធម្មជាតិសម្រុះ ចំពោះធនធានព្រៃឈើវិញ នៅកម្ពុជាយើងមានតំបន់ការពារធម្មជាតិ ២៣កន្លែង ដែលគ្រប់ដណ្តប់លើផ្ទៃដីជាង ៣.៣លានហិកតា[១៤១] ព្រមទាំងតំបន់ការពារព្រៃឈើ និងសត្វព្រៃ ដែលត្រូវបានលើកកម្ពស់យកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល។ តំបន់ការពារធនធានធម្មជាតិនៅកម្ពុជាយើង គឺជាឃ្លាំងស្តុកធនធានសេនេទិកនិងប្រព័ន្ធជីវចម្រុះ ដែលមានសក្តានុពលសម្រាប់កសិកម្ម វប្បធម៌ ប្រវត្តិសាស្ត្រ និងទេសចរណ៍ធម្មជាតិមិនចេះរីងស្ងួត។

ជាមួយនេះដែរបញ្ហាព្រៃឈើ ក៏នៅតែជាគោលដៅយុទ្ធសាស្ត្រចម្បង របស់រាជរដ្ឋាភិបាលនៅក្នុងវិស័យព្រៃឈើ ដើម្បីធានាអោយបាននូវការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយបានឈរលើមូលដ្ឋាននៃសេចក្តីប្រកាសបីសំខាន់ៗគឺ:

១.គោលនយោបាយគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយមានការត្រួតពិនិត្យអាជីវកម្មព្រៃឈើយ៉ាងម៉ឺងម៉ាត់ និងសមស្របតាមនិយាមនៃការគ្រប់គ្រងព្រៃឈើអន្តរជាតិ ដែលតម្រូវអោយមានទំហំព្រៃឈើបម្រុងទុកគ្រប់គ្រាន់សម្រាប់ទប់ទល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ និងសម្រាប់ការពារភាពរាំងស្ងួត ទឹកជំនន់ ព្រមទាំងមានព្រៃលិចទឹកសម្រាប់ទុកជាជម្រកមច្ឆជាតិ។

២.ការពារប្រព័ន្ធធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចម្រុះ និងប្រភេទសត្វកម្រ។

៣.ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើមួយ ដែលរឹងមាំ មានតម្លាភាព និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងតំបន់នោះ។ ជាមួយនេះដែរ រាជរដ្ឋាភិបាលអាណត្តិទី៣ បានបន្តនៅការខិតខំប្រឹងប្រែងចាត់វិធានការផ្អាក និងពិនិត្យអាជីវកម្មព្រៃឈើសម្បទាន ដែលនៅសេសសល់ ដើម្បីឈានដល់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងបន្តជម្រុញគោលនយោបាយកក្នុងការដាំដុះព្រៃឈើឡើងវិញ។ ទន្ទឹមនឹង

[១៤១] យោងទស្សនាវដ្តី ព្រៃឈើ-សត្វព្រៃ លេខ៣២ ឆ្នាំ២០០៥

ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៣នេះដែរ ក្នុងការពង្រឹងការដាំដុះឡើងវិញ លើបញ្ហាព្រៃឈើ ដែលត្រូវបានបំផ្លិចបំផ្លាញ ដោយសារសង្គ្រាមដ៏រ៉ាំរ៉ៃជាពីរទសវត្សកន្លងមក និងការរងនៅការកាប់ទន្ទ្រានពីសំណាក់ជនខិលខូចមួយចំនួន ដោយមានការយកចិត្តទុកដាក់បន្តអនុវត្តពីរាជរដ្ឋាភិបាល អាជ្ញាធរស្រុកជុំគីរី បាននឹងខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់អនុវត្តបានជោគជ័យជាបន្តបន្ទាប់ ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងស្រុកជុំគីរី។ ស្របតាមគោលនយោបាយខាងលើនេះដែរ អាជ្ញាធរស្រុកជុំគីរី បានអនុវត្តបន្ត និងជម្រុញអោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងឃុំ ក្នុងការចូលរួមថែរក្សា និងការដាំកូនឈើឡើងវិញ ដើម្បីការពារធនធានធម្មជាតិក្នុងស្រុកជាអាទិ៍ ព្រៃឈើ ស្ទឹងមច្ឆជាតិ សត្វព្រៃ កំពុងរងនូវការគំរាមកំហែងដោយសកម្មភាពរបស់មនុស្សនេះ ជាបញ្ហាគួរអោយចាប់អារម្មណ៍បំផុត។ ចំពោះការធ្វើអាជីវកម្មអនាធិបតេយ្យទៅលើធនធានធម្មជាតិទាំងនេះ អាជ្ញាធរស្រុកបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើធ្វើអុស និងឆ្ងាការរុករានព្រៃធ្វើស្រែចំការ ដែលជាហេតុនាំអោយព្រៃឈើឈានទៅរកការបាត់បង់។ ជាក់ស្តែងស្រុកជុំគីរី បានបង្កើតសមាគមន៍ព្រៃឈើមួយកន្លែងនៅឃុំច្រេស ដែលមាននៅក្នុងភូមិពីរ គឺភូមិច្រេស និងភូមិឈើទាល មានឈ្មោះថា (ដំណាក់រលួសបវេច្ចធំ) ដើម្បីធ្វើការទប់ស្កាត់ និងការថែរក្សាការពារធនធានធម្មជាតិទាំងនោះ ក្នុងការរួមចំណែកធ្វើអោយប្រសើរឡើងដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងស្រុកជុំគីរីទាំងមូល។

៤.២.៤ ផែនការសកម្មភាពរយៈពេល៥ឆ្នាំ(២០០៩-២០១៣)របស់ស្រុកជុំគីរី

ក-ចក្ខុវិស័យ

រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភាបានដាក់ចេញនូវ "យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព និងយុទ្ធសាស្ត្រសំខាន់បំផុតសម្រាប់ទ្រទ្រង់ដល់ការអនុវត្តន៍ កម្មវិធីនយោបាយរបស់ខ្លួនតាមរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដែលមានអភិបាលកិច្ចល្អជាស្នូល និងផ្តោតទៅលើកម្មវិធីកំណែទម្រង់ទាំង៤យ៉ាង។ ស្រុកជុំគីរីមានចក្ខុវិស័យដូចចែងជាបន្តបន្ទាប់: ១-ពង្រឹងធានា សន្តិភាព សន្តិសុខ និងស្ថេរភាពសណ្តាប់ធ្នាប់សាធារណៈសង្គម និងស្ថេរភាពនយោបាយ។ ២-ពង្រឹងយុទ្ធសាស្ត្រ នៃការអភិវឌ្ឍន៍ស្រុកដើម្បីកាត់បន្ថយភាពក្រីក្រ។ ៣-ពង្រឹងការងារអភិបាលកិច្ចល្អ ប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់រឹមដ្ឋការ និងវិសហមដ្ឋការ។ ៤-ខិតខំធានាសុវត្ថិភាពស្បៀង កាត់បន្ថយភាពក្រីក្រអោយនៅកម្រិតទាបបំផុតនៅក្នុងមូលដ្ឋាន។ ៥-ខិតខំទាក់ទងស្តារ កសាងហេដ្ឋារចនាសម័ន្ធ និងថែរទាំអោយមាននិរន្តរភាព។ ៦-ធ្វើអោយមានលំនឹងកាត់បន្ថយនូវការទំនាស់ដីធ្លីដោយការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ និងជាដុំ។ ៧-លើកស្ទួយកម្រិតជីវភាពរស់នៅស្ត្រី និងកុមារ ដោយទំនាក់ទំនងជាមួយអង្គការសហគមន៍ ឬក្រុមហ៊ុនអភិវឌ្ឍន៍កសិកម្ម និងកសិ-ឧស្សាហកម្មនានា ដើម្បីកាត់បន្ថយការចំណាកស្រុករបស់ប្រជាពលរដ្ឋ។ ៨-លុបបំបាត់គ្រោះអវិជ្ជា តាមផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាដល់ឆ្នាំ២០១២ មានមួយអនុវិទ្យាល័យនៅក្នុងមួយឃុំ។ ៩-រក្សាការពារខឿនវប្បធម៌

សាសនា បាវចនាជាតិ។ ១០-កំចាត់ជំងឺគ្រុនអោយអស់ក្នុងស្រុក និងកាត់បន្ថយរាល់ជម្ងឺនានា។ ១១-ពង្រឹងការងាររដ្ឋបាលមូលដ្ឋាន និងទំនាក់ទំនងជាមួយអង្គភាពស្ថាប័នពាក់ព័ន្ធ និងចុះបង្កើនការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជម្រុញក្នុងការប្រមូលពន្ធ និងចុះបញ្ជីអត្រានុកូលដ្ឋាន និង១២-ជម្រុញការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយទប់ស្កាត់អោយខាងតែបានរាល់ការជ្រៀតចូលក្នុងភូមិសាស្ត្រភូមិ ឃុំ ស្រុក ឬលួចដាំកញ្ឆា អាភៀនជាដើម។ល។

ខ-យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ស្រុក ដើម្បីកាត់បន្ថយភាពក្រីក្រ

១-ពង្រឹង និងថែរក្សាសណ្តាប់ធ្នាប់សាធារណៈរបស់ប្រជាពលរដ្ឋជាពិសេស ចំពោះសន្តិសុខ នៃគ្រួសារនីមួយៗ កាត់បន្ថយអោយបានជាអតិបរមានូវបទល្មើសគ្រប់ប្រភេទតាមមូលដ្ឋាន។

២-សក្តានុពលរបស់ស្រុកជុំគីរី មុខរបរសំខាន់របស់ប្រជាពលរដ្ឋ គឺធ្វើកសិកម្ម ដូច្នេះ ត្រូវធានាអោយបានពូជទឹកដី។

៣-ពង្រឹងសកម្មភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា ដែលមានស្រាប់នៅក្នុងស្រុក និងបន្តសហការជាមួយអង្គការជាតិ និងអន្តរជាតិនានា។

គ-អំពីការងារអភិបាលកិច្ចល្អជាអាទិភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ

ស្រុកបានខិតខំប្រឹងប្រែងបន្ថែមទៀត ចំពោះមន្ត្រីរាជការស៊ីវិលរក្សាបានអព្យាក្រិត្យភាពពិតប្រាកដនៅក្នុងអនុវត្តន៍មុខងារសាធារណៈ ដោយកែលម្អសេវាសាធារណៈអោយរំកិលគៀកកិតជិតមូលដ្ឋាន និងប្រជាជន ព្រមទាំងអនុវត្តអោយបានល្អតាមតួនាទីរបស់ខ្លួន និងចាត់អោយមានវគ្គបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល តាមគ្រប់រូបភាព ដូចជា វគ្គរៀនសូត្រផ្សព្វផ្សាយខ្លី។ សំដៅអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់ការទ្រទ្រង់ដល់ការអនុវត្តភារៈកិច្ចចំពោះមុខ និងអនាគត។

ឃ-អំពីការងាររដ្ឋបាលមូលដ្ឋាន

បន្តគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីលើកកម្ពស់សមត្ថភាពជានាអនុវត្តបានត្រឹមត្រូវនូវរាល់ភារកិច្ចដែលច្បាប់បានកំណត់ រួមចំណែកកាន់តែមានប្រសិទ្ធភាពថែមទៀតក្នុងការធានាស្ថេរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គមការអនុវត្តន៍ដោយចីរភាព ការគោរពគោលជៅប្រជាធិបតេយ្យសេរីពហុបក្សនៅមូលដ្ឋាន និងការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋកាន់តែមានប្រសិទ្ធិភាពល្អប្រសើរ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ត្រៀមរាល់លក្ខណៈសម្បត្តិសម្រាប់ការផ្ទេររាល់ភារកិច្ច ធនធាន និងមន្ត្រីបុគ្គលិក។ល។ ពីអាជ្ញាធរបច្ចុប្បន្នទៅអោយអាជ្ញាថ្មី ដែលនឹងបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ខេត្ត ស្រុក នាពេលខាងមុខដើម្បីធានាបាននិរន្តរភាព នៃការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ និងអោយបានស្របតាមច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធនានា។

ចំពោះការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ រក្សាអោយខាងតែបាននៅសំបុត្រដែលបានចុះក្នុងសារពើភ័ណ្ឌ និងបន្តការងារពន្ធដារតាមការណែនាំរបស់ក្រសួង។

រីឯការងារអត្រានុកូលដ្ឋាន និងលិខិតបទដ្ឋានសិក្សាការស្រាវជ្រាវកំណត់ឡើងវិញនូវនីតិវិធី និងបែបបទនៃការតម្កល់ទុកសៀវភៅអត្រាអនុកូលដ្ឋានគ្រប់ប្រភេទ ដែលបានកត់ត្រាចប់សព្វគ្រប់នូវឃុំ សង្កាត់។

ត្រៀមសហការជាមួយការិយាល័យអប់រំ និងកីឡា ទាក់ទងនឹងការប្រើប្រាស់សំបុត្រអត្រានុកូលដ្ឋានកំណើត។

បញ្ជាក់កំណើត សេចក្តីចំលងសំបុត្រកំណើត ឬបញ្ជាក់ពីកំណើតសម្រាប់សិស្សចូលរៀន ឬប្រឡងនានា និងការងារអត្រានុកូលដ្ឋានក្នុងកម្មវិធីសិក្សា។

ខ-អំពីការងារនគរបាល កងរាជអាវុធហត្ថ និងផ្នែកសឹករងស្រុក

ដើម្បីសម្រេចរាល់កិច្ចធានានូវសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថេរភាពនយោបាយ បន្តអនុវត្តគោលការណ៍ដែលមានចែងក្នុងសៀវភៅ "ស" របស់កងយោធពលខេមរភូមិន្ទ ដោយជំរុញជួយឧបត្ថម្ភសមភូមិមុខ ការខិតខំប្រឹងប្រែងត្រៀមកម្លាំងជួយប្តូរផ្លាស់នៅសមភូមិមុខ និងផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ អនុវត្តតាមបទបញ្ជារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** បំបាត់ទាំងស្រុងនៅកុងត្រូលជជុះ ល្បែងស៊ីសងគ្រប់ប្រភេទ អោយបានម៉ឺងម៉ាត់ជាទីបំផុត។ បន្តពង្រឹងកម្លាំងកងរាជអាវុធហត្ថ និងកម្លាំងនគរបាលជាតិទៅជាកម្លាំងមានវិជ្ជាជីវៈជំនាញ និងបច្ចេកវិទ្យាទំនើបមានស្មារតីទទួលខុសត្រូវគោរពប្រតិបត្តិច្បាប់យ៉ាងម៉ឺងម៉ាត់ គោរពសិទ្ធិមនុស្ស បម្រើដល់ប្រជាពលរដ្ឋដោយស្មោះត្រង់ មានសមត្ថភាពសម្រេចបានល្អនូវភារកិច្ចគ្រប់គ្រង និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ព្រមទាំងរក្សាបាននូវសុខដុមរម្យនានៅក្នុងសង្គមជាតិ។

សន្តិភាព ស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម គឺជាលក្ខខ័ណ្ឌមិនអាចខ្វះបានសម្រាប់ការពង្រឹងស្ថេរភាពមីក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៍ក្នុងស្រុកប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រក្នុងការបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគ និងអ្នកទេសចរណ៍ក៏ដូចជា ក្នុងការបង្ករលក្ខណៈអោយប្រជាពលរដ្ឋអាចរស់នៅប្រកបដោយអាជីវកម្មធម្មតា និងការចូលរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងសកម្មតាមសមត្ថភាពរៀងខ្លួន។

ច-អំពីការងារអភិវឌ្ឍន៍គ្រប់វិស័យ

ក-ការងារកសិកម្ម

ដើម្បីអោយសម្រេចបាននូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញទិសដៅរបស់ក្រសួង ក៏ដូចជា ការណែនាំចង្អុលបង្ហាញពីថ្នាក់ដឹកនាំមន្ទីរ។ ក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម

សម្រាប់លើកស្ទួយជីវភាពគ្រួសារក្រីក្រនៅតាមជនបទ ដើម្បីធានានូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ត្រូវមានផែនការអនុវត្តន៍វិស័យកសិកម្មអោយបានសម្រេចតាមដំណាក់កាលនីមួយៗ រួមមាន:

១-វិស័យសម្រាប់ឆ្នាំ២០០៩-២០១៣

ជំរុញលើកម្ពស់ផលិតផលកសិករ ការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់អនុវត្តប្រពលវប្បកម្មបង្កើនទិន្នផលដើម្បីធានានិរន្តរភាព សន្តិសុខស្បៀងក្នុងគ្រួសារ ប្រាក់ចំណូល និងកំណើនសេដ្ឋកិច្ចជាតិ។ អនុវត្តនូវបច្ចេកទេសថ្មីៗ ប្រើពេលវេលាខ្លីចំណាយទុនតិច ហើយទទួលបានផលច្រើនដូចជា ប្រើពូជថ្មី អាយុកាលថ្មី ប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ(ស្ងួងស្រូវមួយដើម) ដំណាំឆ្លាស់ប្រព័ន្ធកសិកម្មជាចម្រុះ កែប្រែគុណភាពដី ជីកំប៉ុស្ត។

បំផុតពង្រឹងការចិញ្ចឹមសត្វគ្រប់ប្រភេទជាលក្ខណៈគ្រួសារ ឯកជនកសិដ្ឋាននានាសម្រាប់ចិញ្ចឹមផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងការនាំចេញ ព្រមទាំងធ្វើអោយប្រសើរឡើងនូវអាហារូបត្ថម្ភ តាមជនបទ ដោយអនុវត្តតាមការប្រើប្រាស់ធនធានក្នុងស្រុក ដែលមានថ្លៃដើមទាប ហើយទទួលកម្រៃខ្ពស់។

ផ្តល់បច្ចេកទេសជំនាញ និងបទពិសោធន៍នានាក្នុងការចិញ្ចឹមសត្វផ្តល់វិធានការការពារជំងឺ ដូចជាការចាក់ថ្នាំការពារជាដើម។ល។

ពង្រឹងពង្រីកវារីវប្បកម្ម ជំរុញការចិញ្ចឹមជាលក្ខណៈគ្រួសារតាមរយៈការចិញ្ចឹមក្នុងស្រះ ត្រពាំងស្រែ ឬថង់ប្លាស្ទិច។ យកចិត្តទុកដាក់ដល់អ្នកមានគោលបំណងចិញ្ចឹមត្រីដោយបង្កលក្ខណៈងាយស្រួលទាំងវិធីសាស្ត្របច្ចេកទេស និងឯកសារនានា។

ក-ការងារអប់រំយុវជន និងកីឡា

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានផែនការដូចខាងក្រោម:

ក-១-ផ្នែកចំណេះដឹងទូទៅ គឺបានរៀបចំកែលម្អពិនិត្យផែនទីសិក្សាឡើងវិញ ដើម្បីប្រមូលកុមារដល់វិស័យសិក្សាអោយចូលរៀនបានគ្រប់គ្នា ហើយជួយអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន និងនាយកសាលា ដើម្បីលើកកម្ពស់គុណភាពបង្រៀន និងរៀន។ ពង្រឹងការអប់រំសុខភាព និងអនាម័យដល់សិក្សានុសិស្សអំពីការហូបស្អាត ផឹកស្អាត និងរស់នៅស្អាត ទាំងមត្តេយ្យ និងមធ្យមសិក្សា។ លើកទឹកចិត្តពង្រឹងការចូលរួមសហគមន៍ និងមាតាបិតាសិស្ស ដើម្បីលើកកម្ពស់ការអប់រំអោយមានគុណភាពខ្ពស់។ បើកថ្នាក់មត្តេយ្យក្នុងបឋមអោយបាន ២០សាលាក្នុងចំណោម ២៦សាលា។ បន្តត្រៀមបើកសាលារៀនបឋមសិក្សាថ្មី ចំនួន ២កន្លែងទៀត ដើម្បីធានាដល់ការប្រមូលកុមារគ្រប់អាយុអោយចូលរៀនបានគ្រប់ៗគ្នា។ មិនតែប៉ុណ្ណោះត្រៀមបើកអនុវិទ្យាល័យមួយកន្លែងទៀត ដើម្បីបង្កលក្ខណៈងាយស្រួលដល់កុមារ ដែលបានរៀនចប់ថ្នាក់ទី៦ បានបន្តការសិក្សាចប់កម្រិតអប់រំមូលដ្ឋាន ជាពិសេសកុមារា កុមារី និងកុមារមកពីគ្រួសារក្រីក្រ។

ក-២-ផ្នែកអប់រំក្រៅប្រព័ន្ធ បានជម្រុញអោយមានការបានត្រៀមបើកវិទ្យាល័យនៅក្នុងទីតាំងអនុវិទ្យាល័យឃុំស្រែចែង ដើម្បីបង្កលក្ខណៈអោយសិក្សាបានរៀនចប់ថ្នាក់ទី៩ បានបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និងបានរៀនបន្តទៅឧត្តមសិក្សាជាពិសេសសិស្សស្រី។ លើសពីនេះបានត្រៀមបើកមជ្ឈមណ្ឌលសិក្សាសហគមន៍អោយបានគ្រប់ឃុំក្នុងស្រុក ដើម្បីផ្តល់ការអប់រំ និងវិជ្ជាជីវៈមូលដ្ឋានរបស់មនុស្សពេញវ័យអោយមានជំនាញសម្រាប់រកប្រាក់ចំណូល ជាពិសេសគឺផ្តល់ចំណេះដឹង និងបំណិនផ្នែកកសិកម្ម និងសិប្បកម្ម ហើយក៏បានយកចិត្តទុកដាក់ធ្វើការប្រមូលកុមារ ដែលបោះបង់ការសិក្សាក្រោមរយៈពេល បីឆ្នាំអោយចូលរៀនឡើងវិញ។ ចំពោះផ្នែកយុវជនស្រុកបានពង្រឹងក្រុមសិក្សាយុវជន និងកុមារ ដែលមានស្រាប់អោយមានសកម្មភាព និងប្រកបដោយគុណភាព ពិសេសលើការងារប្រឡងប្រណាំងកុមារបីល្អ យុវជន បីល្អ និងបានបន្តកសាងក្រុម-ប្រឹក្សាកុមារ និងយុវជនអោយមាននិរន្តរភាពនៅគ្រប់សាលា។

ខ-សុខាភិបាល ផែនការឆ្នាំ២០០៩-២០១៣

ខ-១-កាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក:

បុគ្គលិកមណ្ឌលសុខភាពទាំងអស់ បានចុះអប់រំសុខភាពតាមភូមិស្តីពីការកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក ស្ត្រីវ័យបន្តពូជត្រូវការចាក់ថ្នាំការពារជម្ងឺតេតាណុសអោយបាន៥ដង ដើម្បីបង្ការការពារជំងឺតេតាណុសដល់ម្តាយ និងទារកក្រោយពេលសម្រាល។

ស្ត្រីមានផ្ទៃពោះត្រូវមកពិនិត្យផ្ទៃពោះអោយបាន ៥ដង មុនពេលសម្រាល និងទទួលថ្នាំគ្រាប់ជាតិដែកអោយបាន ៩០គ្រាប់។ ពេលសម្រាលកូនត្រូវមែកសម្រាលនៅមណ្ឌលសុខភាព។ តាមដានក្រោយពេលសម្រាលរហូតដល់៦ខែ ការផ្តល់ថ្នាំជាតិដែក និងថ្នាំជីវជាតិអា ថ្នាំទម្លាក់ព្រូន។ ចំពោះទារកកើតភ្លាមត្រូវផ្តល់ថ្នាំបង្ការជំងឺរបេង រលាកថ្លើម ប្រភេទបេ។ បន្តតាមដានការលូតលាស់ដល់កុមារអាយុក្រោម ៥ឆ្នាំ ជារៀងរាល់ខែ និងផ្តល់ថ្នាំគ្រាប់ជីវជាតិអា និងថ្នាំទម្លាក់ព្រូនអោយបានទៀងទាត់ដោយមានកិច្ចសហការរបស់ស្រុក និងមានការឧបត្ថម្ភថវិការដោយក្រសួងសុខាងភិបាលថែមទៀត។

ខ-២-ផែនការផ្តល់ថ្នាំបង្ការដល់កុមារអាយុក្រោម ១ឆ្នាំអោយបាន ១០០% និងបង្កើនអត្រាគ្របដណ្តប់អោយបាន១០០%

ការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកស្ម័គ្រចិត្តកូនពេលកើតមកត្រូវអោយមកចាក់ថ្នាំបង្ការនៅមណ្ឌលសុខភាពអោយបាន ៥ដង មុនអាយុ ១ឆ្នាំ។ បុគ្គលិកមណ្ឌលសុខភាព ធ្វើផែនការចុះចាញ់ថ្នាំបង្ការតាមភូមិជារៀងរាល់ខែ និងអប់រំសុខភាពតាមបណ្តាគ្រប់ភូមិ។

ខ-៣-កាត់បន្ថយភាពចម្លងជំងឺអេដស៍ដល់សហគមន៍អោយនៅកម្រិតទាបបំផុត

សហការជាមួយអាជ្ញាធរមូលដ្ឋានអោយប្រជាពលរដ្ឋមុនពេលរៀបការ និងមុនពេលបួសជាសង្ឃ។ អ្នកដែលដៃគូរស្នេហារច្រើនត្រូវមកធ្វើតេស្តឈាមរកមេរោគអេដស៍នៅមណ្ឌលសុខភាព។

ខ-៤-ស្រាវជ្រាវ និងកាត់បន្ថយការឆ្លងរីករាលដាលនៃជំងឺរបេងនៅសហគមន៍

សហការជាមួយមូលដ្ឋានចុះអប់រំសុខភាពតាមសហគមន៍តាមវត្តអារាម។ ទីប្រជុំជននានាចំពោះអ្នកក្អកលើសពី២១ថ្ងៃ ត្រូវមកពិនិត្យរកមេរោគរបេងនៅមណ្ឌលសុខភាព ព្យាបាលជំងឺរបេងដោយមិនគិតថ្លៃ ហើយជាសះស្បើយ ១០០%។ មានការពិនិត្យស្រាវជ្រាវយ៉ាងច្បាស់លាស់ និងផ្តល់ស្បៀងអោយថែមទៀត។

ខ-៥-កាត់បន្ថយការឈឺស្លាប់របស់ជំងឺគ្រុនចាញ់ គ្រុនឈាម

សហការជាមួយអាជ្ញាធរមូលដ្ឋាន និងបុគ្គលិកមណ្ឌលសុខភាពទាំងអស់ចុះអប់រំសុខភាពតាមសាលារៀនវត្តអារាម និងចុះផ្ទាល់ដល់ក្រុមគ្រួសារ ដែលនៅចុងកាត់មាត់ព្រៃកជិតព្រៃភ្នំ។ ការចែកចាយមុងអោយបាន ១០០% មុនរដូវភ្លៀងធ្លាក់ដោយចាំបាច់ត្រូវអោយសម្រាកក្នុងមុងពេលយប់ និងថ្ងៃអោយបាន ១០០% ហើយពេលជំងឺត្រូវមកព្យាបាលនៅមណ្ឌលសុខភាព។

ខ-៦-ទប់ស្កាត់ និងការពារឆ្លងនៃជំងឺផ្តាសាយបក្សី

សហការជាមួយអាជ្ញាធរមូលដ្ឋាននៅពេលមានសត្វឈឺ ឬងាប់ច្រើនត្រូវរាយការណ៍ជូនមណ្ឌលសុខភាពពេទ្យសត្វជាបន្ទាន់។ បន្តអប់រំ ដល់សហគមន៍កុំអោយប៉ះពាល់សត្វឈឺ ឬងាប់។ មន្ត្រីមណ្ឌលសុខភាពត្រូវចុះអប់រំសុខភាពដល់សហគមន៍ស្តីពីការហូបស្អាត ផឹកស្អាត រស់នៅស្អាត ដោយអប់រំអោយប្រជាពលរដ្ឋពេលមានជំងឺចូលមកព្យាបាលនៅមណ្ឌលសុខភាព ឬមន្ទីពេទ្យ។

គ-ផែនការឆ្នាំ២០០៩-២០១៣ របស់អង្គការអភិវឌ្ឍន៍ជនបទស្រុក

ដើម្បីឆ្លើយតបយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ការិយាល័យអភិវឌ្ឍន៍មានផែនការបើកវគ្គបណ្តុះបណ្តាលបុគ្គលិកចំនួន១០វគ្គ។ ឯការងារផ្សេងៗទៀតដូចជា:

១-ការងារជួសជុល និងសាងសង់អាគារការិយាល័យ

បង្កើនការងារសណ្តាប់ធ្នាប់ការិយាល័យតាមរយៈ

+ធ្វើរបងព័ទ្ធជុំវិញការិយាល័យស្រុក

+ការជួសជុលអាគារ

+បំពាក់គ្រឿងសង្ហារឹម

+ចាក់ដីបំពេញទីធ្លា

២-ការងារអនាម័យជនបទ

ទិសដៅឆ្នាំ២០០៩-២០១៣ ប្រជាពលរដ្ឋទាំង៣៧ភូមិ និងមានអនាម័យល្អតាមរយៈ

+ការសាងសង់បង្គន់អនាម័យចំនួន១៨៥០បង្គន់

+សាងសង់អណ្តូងទឹកស្អាតចំនួន១១២អណ្តូង

+ការជួសជុលអណ្តូងទឹកស្អាត ចំនួន ៩៥អណ្តូង

៣-ការងារអភិវឌ្ឍន៍សហគមន៍

គណៈកម្មការអភិវឌ្ឍន៍ភូមិទាំង៣៧ និងមានជំនាញក្នុងការដឹកនាំប្រជាពលរដ្ឋឆ្ពោះទៅរកភាពរីកចម្រើនតាមរយៈការ

+បើកវគ្គពង្រឹងសមត្ថភាព គ.អ.ក ចំនួន១២វគ្គ សម្រាប់សិក្ខាកាម ៣៦០នាក់

+បន្តការគាំទ្រសកម្មភាពសហគមន៍ទាំង៣៧ភូមិក្នុងស្រុក

+ផ្តល់ប្រាក់កម្ចី តាមរយៈការធ្វើឥណទានផលសហគមន៍ ទាំង ៣៧ភូមិ

+ផ្តល់ដើមទុនដល់គ្រួសារ ទីទ័លក្រសម្រាប់បង្កើតមុខរបរបន្ថែមផ្សេងៗទាំង៣៧ភូមិ ចំនួន៩២៥គ្រួសារ។

៤-ការងារផ្លូវលំជនបទ

+បើកវគ្គពង្រីកសមត្ថភាព គណៈកម្មការថែទាំទាំងផ្លូវលំ ទាំង៣៧ភូមិ ចំនួន ៤៣វគ្គ មានសិក្ខាកាម២៥៩នាក់។

+ការជួសជុលផ្លូវលំ

+ការសាងសង់ផ្លូវលំ

ឃ-ទិសដៅឆ្នាំ២០០៩-២០១៣របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី

ជំរុញធ្វើការកំណត់ព្រំប្រទល់រដ្ឋបាលខេត្តអោយបានច្បាស់លាស់រវាងខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ដោយខេត្តទាំងពីរនេះមានព្រំប្រទល់ជាប់នឹង ភូមិខ្ទបរុន ក្នុងឃុំស្រែចែង ស្រុកជុំគីរី ។ ការសិក្សារៀបចំតំបន់ទីប្រជុំជនអោយមានសណ្តាប់ធ្នាប់ល្អ។ សិក្សារៀបចំប្រព័ន្ធលូជុំវិញទីផ្សារ ដើម្បីលើកកម្ពស់សុខុមាលភាព និងការការពារបរិស្ថានសាធារណៈ។

ចំពោះការងារគណៈកម្មការសុរិយោដី បានបើកគម្រោងស្នើសុំបើកវគ្គបណ្តុះបណ្តាលលើផ្នែកការងារគណៈកម្មការសុរិយោដីបន្ត។ យើងថែមទាំងបានជួយពង្រីក និងផ្សព្វផ្សាយបន្ថែមលើការងាររបស់គណៈកម្មការសុរិយោដី។

រីឯការងារសំណង់បានធ្វើការផ្សព្វផ្សាយបន្ថែមដល់អាជ្ញាធរដែនដីអោយបានច្បាស់លាស់មុនពេលសាងសង់សំណង់ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់។ ផ្សព្វផ្សាយអោយក្រុមការងារមកចុះឈ្មោះសុំធ្វើអាជីវកម្ម។ ចំពោះការងារសុរិយោដីតម្រូវរៀបចំបើកវគ្គបណ្តុះបណ្តាលច្បាប់ភូមិបាល និងលិខិតបទដ្ឋាន អនុវត្តច្បាប់ភូមិបាលនៅសាលាស្រុកជុំគីរីចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ សិក្ខាកាមអញ្ជើញចូលរួមពីថ្នាក់ស្រុក ការិយាល័យជុំវិញស្រុកចំនួន១៨នាក់ និងក្រុមប្រឹក្សាចំនួន២១នាក់ សរុបចំនួន៣៩នាក់។ ធ្វើការផ្សព្វផ្សាយអោយប្រជាពលរដ្ឋបានយល់ច្បាស់ក្នុងការចុះបញ្ជីបំពេញបន្ថែម និងចុះបញ្ជីបន្ត។ ធ្វើការស្នើសុំអោយមានគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធចម្រុះ បញ្ជីបន្ថែមនៅក្នុងស្រុកជុំគីរីមួយ ភូមិមួយទៀត គឺភូមិខ្ទបរុន ឃុំស្រែចែង។

ង-ផែនការឆ្នាំ២០០៩-២០១៣ របស់ការិយាល័យសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

១-ផ្នែកសេវាកម្មសុខមាលភាពសង្គមសម្រាប់ជនក្រីក្រងាយរងគ្រោះ

-ពង្រឹងកម្មវិធីសង្គ្រោះបន្ទាន់ ដើម្បីជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះ

-កសាងបណ្តាញសង្គមកិច្ចនៅគ្រប់ឃុំ

-លើកកម្ពស់ការយល់ដឹងរបស់សហគមន៍

-ទប់ស្កាត់ការជួញដូរមនុស្ស

-ផ្តល់សេវាកម្មសង្គមកិច្ច និងថែទាំដល់កុមារ និងគ្រួសាររងគ្រោះដោយសារមេរោគអេដស៍

-ជំរុញការការពារ និងលើកកម្ពស់សិទ្ធិកុមារ។

២-ផ្នែកសេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម

-រៀបចំ និងប្រមូលទិន្នន័យជនពិការ ដើម្បីកំណត់តម្រូវការ និងផ្តល់សេវាកម្មជូនជនពិការ

-សម្របសម្រួលជាមួយអង្គការដៃគូ ដើម្បីផ្តល់មុខរបរខ្នាតតូចជូនជនពិការ។

៣-ផ្នែកសន្តិសុខសង្គម សុខមាលភាពមនុស្សចាស់ និងប្រជាកសិករទូទៅ

-ជួយសម្រួលជីវភាពរស់នៅអតីតមន្ត្រីរាជការស៊ីវិល និងគ្រួសារអតីតរាជការស៊ីវិល

-បង្កើតសហគមន៍ អតីតមន្ត្រីរាជការ

-ចុះពិនិត្យ និងសិក្សាស្រាវជ្រាវអំពីស្ថានភាពមនុស្សចាស់តាមសហគមន៍។

៤-ផ្នែកអតីតយុទ្ធជន

-បង្កើតគណៈកម្មការ និងអភិវឌ្ឍន៍អតីតយុទ្ធជននៅថ្នាក់ឃុំ

-ពិនិត្យអតីតយុទ្ធជនគ្មានដីធ្លី គ្មានមុខរបរដើម្បីទទួលការគាំទ្រ

-បំផុសចលនារបស់អតីតយុទ្ធជន។

ច-រួមចំណែកយ៉ាងសកម្មសម្រាប់ឆ្នាំ២០០៩-២០១៣ របស់អធិការដ្ឋាននគរបាលស្រុកមានគោលដៅយុទ្ធសាស្ត្រ ដើម្បីដាក់ចេញនូវវិធានការ:

រួមចំណែកយ៉ាងសកម្មរក្សារឹងមាំ សន្តិភាព ឯកភាពជាតិ និងបូរភាពទឹកដីក្នុងមូលដ្ឋានរបស់ខ្លួន។ រក្សាសន្តិភាពអោយនូវតែស្ថិតក្នុងលក្ខណៈពេញបរិបូរណ៍ ដែលនឹងផ្តល់ឱកាសអោយការអភិវឌ្ឍន៍ភូមិ ឃុំ របស់ខ្លួនបានកាន់តែប្រសើរ។ បានសហការជុំវិញការបំផុសឃោសនាអប់រំជាប្រចាំ ចំពោះប្រជាពលរដ្ឋគ្រប់ស្រទាប់មន្ត្រីរាជការគ្រប់ថ្នាក់អោយយល់ពីតម្លៃមិនអាចកាត់ថ្លៃបាន នៃសុខសន្តិភាពអោយបានគង់វង្សស្ថិតស្ថេរ។

ការពារដាច់ខាតសន្តិសុខជាតិ បង្ការទប់ស្កាត់អំពើភេរវកម្ម និងឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលចូលក្នុងស្រុកយើង។ ក្តាប់អោយជាប់សភាពការណ៍ប្រែប្រួលនៃកម្មភាពភេរវកម្មអន្តរជាតិ ក្តាប់ឧបាយកល និងអង្គការចាត់តាំងរបស់ភេរវកម្មនៅក្នុងភូមិសាស្ត្រ ដើម្បីគ្រប់គ្រងបង្ការទប់ស្កាត់អំពើភេរវកម្មអោយកាន់តែមានប្រសិទ្ធភាពខ្ពស់។

កាត់បន្ថយបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ និងផ្តល់សេវាឆ្លើយតបមានប្រសិទ្ធភាពចំពោះបទល្មើសដែលកើតឡើង ដើម្បីបង្កើនភាពជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើកងកម្លាំងមន្ត្រីរាជការតាមទិសដៅសហគមន៍ភូមិ ឃុំ មានសុវត្ថិភាព។ បំផុសអោយមាននូវចលនាប្រជាពលរដ្ឋចូលរួមសកម្មបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ត្រូវបានលេចឡើងជារូបភាពផុសផុលនៅសហគមន៍គ្រប់មូលដ្ឋានមើលឃើញ និងទទួលអំពីសារសំខាន់នៃការចូលរួមចំណែករបស់ខ្លួនជាមួយកម្លាំងសមត្ថកិច្ច និងមានការសប្បាយរីករាយនៅគ្រប់សហគមន៍ភូមិឃុំ។

លើកកម្ពស់ការចូលរួមរបស់មហាជន ក្នុងការប្រឆាំងបទល្មើសព្រហ្មទណ្ឌដោយត្រូវធ្វើយ៉ាងណាអោយប្រជាពលរដ្ឋមានជំនឿទុកចិត្ត ពិសេសប៉ុស្តិ៍រដ្ឋបាលមូលដ្ឋាន ហើយហ៊ានរាយការណ៍ ផ្តល់ដំណឹងជនសង្ស័យ ឬព័ត៌មានបទល្មើស ដើម្បីស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបបទល្មើស។

ទប់ស្កាត់មិនអោយប្រភពគ្រឿងញៀន និងកាត់បន្ថយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅក្នុងភូមិសាស្ត្រ។ សហការយ៉ាងជិតស្និតជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរមូលដ្ឋាន និងបង្កើនការឃោសនាអប់រំ។ លើកកម្ពស់ការយល់ដឹងអំពីគ្រោះមហន្តរាយ នៃការប្រើប្រាស់គ្រឿងញៀន ជាពិសេសយុវជនសិស្សសាលា ដែលបានបោះបង់ការរៀនសូត្រ។

កាត់បន្ថយអំពើធ្វើអាជីវកម្មលើកម្លាំងពលកម្ម អាជីវកម្មផ្លូវភេទ លើស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ ដើម្បីលើកកម្ពស់កិត្តិយស និងកិត្យានុភាពជាតិ។

ធ្វើអោយមានសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោកមានលក្ខណៈល្អប្រសើរ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងការកាត់បន្ថយការប្រើប្រាស់ទ្រូងថ្នល់ និងចិញ្ចើមថ្នល់អនាធិបតេយ្យ។ ហើយធ្វើយ៉ាងណា ជំរុញការងារគ្រប់គ្រងរដ្ឋបាលអោយក្លាយជាកិច្ចការជំនាញ ដែលអាចបម្រើអោយការស្រាវជ្រាវស៊ើបអង្កេតបទល្មើស មានរបៀបរៀបរាយសណ្តាប់ធ្នាប់សាធារណៈ អោយមានការរីកចម្រើនស្របតាមគំនិតឈានឡើងថ្មីរបស់ប្រទេសជាតិ។ ចូលរួមកាត់បន្ថយការគ្រោះថ្នាក់និងមហន្តរាយនានា ដែលបណ្តាលមកពីអាវុធជាតិផ្ទុះ។

បង្កើតអោយមានកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ការគ្រប់គ្រងអាវុធជាតិផ្ទុះអោយបានជ្រួតជ្រាបយ៉ាងទូលំទូលាយក្នុងស្រទាប់មហាជនប្រជាជនគ្រប់លំដាប់ថ្នាក់ដោយសារអាវុធ និងការផ្តន្ទាទោសការប្រើប្រាស់អាវុធជាតិផ្ទុះខុសច្បាប់។ ព្រមទាំងខិតខំកសាងកម្លាំងប្រកបដោយសមត្ថភាពវិជ្ជាជីវៈ សីលធម៌ និងទទួលការគាំទ្រពីប្រជាពលរដ្ឋ។

បង្កើន និងពង្រឹងសមត្ថភាពកងកម្លាំងមន្ត្រីរាជការគ្រប់ថ្នាក់អោយទៅជាកម្លាំងមានវិជ្ជាជីវៈជំនាញមានស្មារតីទទួលខុសត្រូវការគោរពប្រតិបត្តិច្បាប់ គោរពសិទ្ធិមនុស្ស និងបម្រើប្រជាពលរដ្ឋដោយស្មោះត្រង់តាមរយៈការបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

សរុបមក ចក្ខុវិស័យការកសាងផែនការដោយុទ្ធសាស្ត្រ ៥ឆ្នាំ គឺជាការផ្តើមចេញពីទស្សនៈរបស់ថ្នាក់ដឹកនាំ ដែលបានគិតគូរទុកជាមុន នូវអ្វីដែលបម្រុងអនុវត្តន៍នៅពេលខាងមុខ ដោយមានការពិចារណាយ៉ាងល្អិត

ល្អន់ពីនិរន្តរភាពចីរភាពសម្រាប់អភិវឌ្ឍន៍ភូមិ ឃុំ ស្រុក ពិសេសការអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់ការទី២របស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជាជាប្រមុខ និងជាត្រីវិស័យសម្រាប់ចង្អុលទិសក្នុងការអនុវត្តរយៈពេល ៥ឆ្នាំ តាមការ អភិវឌ្ឍន៍បែបប្រជាធិបតេយ្យការផ្តល់សេវាអោយដល់មូលដ្ឋាន ដើម្បីភាពរីកចម្រើនលើគ្រប់វិស័យទៅថ្ងៃអនាគត។

៤.៣ យុទ្ធវិធីកាត់បន្ថយភាពក្រីក្រសម្រាប់កសិករនៅកម្ពុជា

៤.៣.១ ពង្រីកវិស័យកសិកម្ម ដែលជាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ

ប្រសិទ្ធភាពនៃការកាត់បន្ថយភាពក្រីក្រទាមទារអោយមានការខិតខំប្រឹងប្រែង និងផ្តោតទៅលើការយក ចិត្តទុកដាក់ពីស្ថេរភាពអ្នកក្រីក្រនៅតាមជនបទ និងសក្តានុពលអភិវឌ្ឍន៍កសិកម្ម ក៏ដូចជាការខិតខំប្រឹងពង្រឹង និងកែលម្អ ដើម្បីបន្ថយវិសមភាពយេនឌ័រ។ ក្នុងចំណោមប្រជាជនរស់នៅជនបទ ដែលមានរបរកសិកម្ម ជា ប្រភពចំណូលចម្បង គឺមាន ៩០% នៃប្រជាជននៅជនបទហើយ ៨០% នៃចំនួននេះរស់ជាមួយនឹងកសិកម្ម។ វិស័យកសិកម្មបានយកសមាមាត្រប្រមាណជា៤០% នៃផលិតផលសរុបក្នុងស្រុក។ រាជរដ្ឋាភិបាលទទួលស្គាល់ថា កំណើនកសិកម្មមានសារៈសំខាន់ធំធេងដល់ការកាត់បន្ថយភាពក្រីក្រ ពីព្រោះ: ១-កសិកម្មជាប្រភពចំណូលបឋម ផ្ទាល់នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។ ២-ការជះឥទ្ធិពលជាពហុបែបរបស់កសិកម្ម អាចជាសក្តានុពល ដែលជះឥទ្ធិពលខ្លាំងក្លាលើការពង្រឹងផ្នែកនានារបស់សេដ្ឋកិច្ច និងការអភិវឌ្ឍន៍ប្រភពចំណូលពីកសិកម្ម។ ៣-កសិកម្មបានចូលរួមជាមួយនឹងការប្រែប្រួលដ៏ធំធេងតាមរដូវកាល ក្នុងសុខមាលភាពរបស់ប្រជាជនក្រីក្រ ដែល រស់នៅជនបទ។

ការធ្វើអោយវិស័យកសិកម្មកាន់តែប្រសើរឡើងនោះ គឺជាគន្លឹះសម្រាប់ពង្រីកកំណើនសេដ្ឋកិច្ច និងកាត់ បន្ថយភាពក្រីក្រ ក៏ដូចជាការគិតពីសក្តានុពលជាច្រើនសម្រាប់ការលើកកម្ពស់។ ក្នុងបណ្តាឆ្នាំកន្លងថ្មីៗនេះ កសិកម្មបានបង្ហាញពីភាពលំនឹងខ្លាំង ដែលធ្វើអោយមានកំណើនទូទៅរបស់សេដ្ឋកិច្ច ថ្វីបើមានបញ្ហាសំខាន់អំពី សក្តានុពលរបស់វិស័យនេះក៏ដោយ។ បញ្ហានេះអំពាវនាវអោយមានអភិក្រមថ្មីមួយសម្រាប់វិស័យកសិកម្ម ដែលជាមួយនោះការធ្វើអន្តរាគមន៍របស់រាជរដ្ឋាភិបាលមានការចាប់អារម្មណ៍ លើបញ្ហានានាផ្ទាល់របស់កសិកម្ម។ រាជរដ្ឋាភិបាល មានបំនងបង្កើនបរិយាកាសនយោបាយគាំទ្រកសិកម្ម ដោយរួមមានដល់ការផ្តត់ផ្តង់អោយផ្នែក សេដ្ឋកិច្ចចម្រុង ហេដ្ឋារចនាសមព័ន្ធសង្គម និងសេវាសង្គមនានា ដែលអនុញ្ញាតអោយកសិករទាំងឡាយធ្វើសេចក្តី សម្រេចចិត្តក្នុងផលិតកម្ម និងវិនិយោគទុនផ្ទាល់ខ្លួនរបស់ពួកគេ។ វិស័យកសិកម្មអាចផ្តល់កំណើនប្រពលភាព ការងារ ដែលនាំអោយមានចំណូលខ្ពស់សម្រាប់អ្នកក្រខ្សត់ជាច្រើន។ យ៉ាងណាក៏ដោយផលិតកម្មកសិកម្មច្រើន អាចធ្វើការស្រោចស្រង់ ប្រជាជនចេញពីភាពក្រីក្របាននៅពេលណាបណ្តាវិធានការ ដែលយកមកប្រើនោះមាន អំណោយផលដល់អ្នកក្រីក្រ និងក្នុងស្ថានភាពដែលធនធានធម្មជាតិត្រូវបានប្រើប្រាស់ដោយចីរភាព។ ប្រជាជន ជិត ៩០% រស់នៅជនបទដូចនេះ យុទ្ធសាស្ត្រសម្រាប់កាត់បន្ថយភាពក្រីក្រ ត្រូវផ្តោតសំខាន់លើកម្មវិធីអភិវឌ្ឍន៍

ជនបទចម្រុះ ជាពិសេស ការបង្កើនយន្តការផលិតភាពកសិកម្ម តាមរយៈការប្រើប្រាស់ពូជដែលផ្តល់នូវទិន្នផលខ្ពស់ ការសិក្សាស្រាវជ្រាវលើដំណាំស្រូវ និងដំណាំកសិ-ឧស្សាហកម្ម ការកសាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារា-សាស្ត្រ និងការអនុវត្តន៍អោយបានខ្ជាប់ខ្ជួននូវនយោបាយទឹក ការរៀបចំកម្មសិទ្ធិដីធ្លីមានស្ថេរភាព និងសុវត្ថិភាពការប្រើប្រាស់ដីអោយមានសណ្តាប់ធ្នាប់ រួមទាំងកិច្ចការការពារបរិស្ថានធម្មជាតិទៀតផង។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលបានផ្តល់អាទិភាព ដល់ការពង្រឹងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច និងបង្កើតការងារនៅទីជនបទ។ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយសម្រួលជារូបវន្តនានា រួមមាន បណ្តាញផ្លូវគមនាគមន៍ បណ្តាញធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹក និងចែកចាយទឹក បណ្តាញអគ្គីសនី។ បណ្តាញទាំងនេះជើរតួនាទីជាមូលដ្ឋានគ្រឹះ និងជាកត្តាកំណត់ដ៏សំខាន់នូវកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ។

គោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះវិស័យកសិកម្ម គឺផ្តោតទៅលើការលើកស្ទួយតួនាទី ផ្នែកកសិកម្មអោយក្លាយទៅជាផ្នែកនាំមុខ ដែលអាចផ្តល់នូវថាមពលបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមជាវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលនឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដើម្បីធានានូវនិរន្តរភាពនៃកំណើនសកម្មភាព សេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាធ្វើអោយប្រសើរឡើងនូវការបង្កើនការនាំចេញកសិផល។ ក្នុងន័យនេះ ការបង្វែរទិសពីការអភិវឌ្ឍន៍តាមបែប "វិបុលវប្បកម្ម" ទៅកាន់ការអភិវឌ្ឍន៍តាមបែប "ប្រពលវប្បកម្ម" ពោលគឺ ពង្រឹងសមត្ថភាពការចិញ្ចឹមលើផ្ទៃដី ដែលមានស្រាប់អោយបានខ្ពស់បំផុត។

រាជរដ្ឋាភិបាល នឹងជម្រុញបង្កើតបរិយាកាសល្អសម្រាប់ការចូលរួមរបស់ផ្នែកឯកជន ដើម្បីការលូតលាស់នៃវិស័យកសិកម្ម តាមរយៈការប្រឹងប្រែងផ្តល់កម្មសិទ្ធិដីធ្លី នៅតាមតំបន់ជនបទអោយបានលឿនបំផុតក្នុងទិសដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីកសិកម្ម ការពង្រីក និងការបែងចែកដីធ្លីកសិកម្ម ក្នុងក្របខ័ណ្ឌ ដី-សម្បទានសង្គមកិច្ច។ ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពផ្ទៃដី ការគ្រប់គ្រងធនធានទឹក និងយកចិត្តទុកដាក់ផងដែរ ដល់ការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់។ ការបន្តបង្កើត និងពង្រឹងគុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក ព្រមទាំងការកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និងការពឹងផ្អែកទាំងស្រុងលើលក្ខខ័ណ្ឌធម្មជាតិ។ល។ ក្នុងគោលបំណងជួយដល់ការចែករំលែកនូវបន្ទុករបស់គ្រួសារកសិករក្រីក្រ។ រាជរដ្ឋាភិបាល នឹងបន្តអនុវត្តគោលនយោបាយ មិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលបង្កបង្កើនផលក្នុងលក្ខណៈជាគ្រួសារ។ ក្នុងទិសដៅជម្រុញផលិតភាពកសិកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បន្ថែមទៀតចំពោះ ការពង្រីសេវាកម្ម គាំទ្រវិស័យកសិកម្មនេះ ដូចជា ការងារស្រាវជ្រាវ និងផ្សព្វផ្សាយការអភិវឌ្ឍន៍នូវផ្សារកសិម្ម ការបែងចែកសម្ភារៈ ពូជ ជី និងការផ្តល់ឥណទានជនបទ ដោយមានអត្រាការប្រាក់ទាប។ល។ ផ្អែកលើមូលដ្ឋាននៃការអនុវត្តគោលនយោបាយវិមជ្ឈការ។

រាជរដ្ឋាភិបាលនឹងរំលែកតួនាទីនេះជាដំហានៗទៅលើក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលនឹងទទួលបាននូវការពង្រឹងសមត្ថភាពអោយក្លាយទៅជាអាជ្ញាធរអភិវឌ្ឍន៍ ជាអ្នកផ្តេរចំណេះដឹងអោយដល់កសិករនៅតាមមូលដ្ឋានរបស់ខ្លួន។ នៅក្នុងក្របខ័ណ្ឌនេះដែរ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពបង្កើតសាលាបច្ចេកទេសកសិកម្មនៅតាមខេត្តមួយចំនួនសម្រាប់ផ្តល់ឱកាសសិក្សាជូនយុវជន និងយុវនារីនៅតាមជនបទ ដើម្បីពួកគេអាចបង្កើនសមត្ថភាពជំនាញរបស់ខ្លួន ហើយកទៅប្រើប្រាស់ក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនវិញ។ រាជរដ្ឋាភិបាលក៏ពិនិត្យផងដែរនូវលទ្ធភាពបង្កើតមណ្ឌលអភិវឌ្ឍន៍កសិកម្ម និងកសិដ្ឋានគំរូនៅតាមស្រុកមួយចំនួនផង ដើម្បីបង្ហាញផ្សព្វផ្សាយ និងបណ្តុះបណ្តាលជូនកសិករអំពីបច្ចេកទេសកសិកម្ម បច្ចេកទេសវារីវប្បកម្ម និងបសុវប្បកម្ម ដែលអាចផ្តល់ទិន្នផលខ្ពស់អំពីការធ្វើកសិដ្ឋានចម្រុះ និងអំពីព័ត៌មានទីផ្សារ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពពិសេសទៅលើការតម្រង់ទិសកិច្ចការវិនិយោគសាធារណៈ និងការលើកទឹកចិត្តវិនិយោគឯកជនអោយឆ្ពោះទៅរកវិស័យកសិកម្ម សំដៅលើកកម្ពស់កំណើនកសិផល និងធានាគុណភាពកសិផលកម្ពុជាអោយឆ្លើយតបទៅនឹងតម្រូវការនៃស្តង់ដារអន្តរជាតិ។ រាជរដ្ឋាភិបាលបានបន្តជំរុញចលនា "**ភូមិ១ ផលិតផល១**" ដើម្បីលើកស្ទួយគំនិតច្នៃប្រឌិតខ្ពស់ និងជំនឿលើខ្លួនឯងរបស់ប្រជាពលរដ្ឋនៅតាមទីជនបទដោយឈរលើគោលការណ៍សំខាន់ៗបីយ៉ាងគឺ: ១-ការរិះរកវិធីផលិត ដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃបរិស្ថានភូមិឋាន និងសមស្របទៅតាមសេចក្តីត្រូវការរបស់ទីផ្សារ។ ២-ការបង្កលក្ខណៈងាយស្រួល និងការផ្តល់ការលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការផលិត ក៏ដូចជាការស្វែងរកទីផ្សារ ការផ្តល់ឥណទាន ការផ្ទេរបច្ចេកវិទ្យា និងការផ្តល់ពូជ។ ៣-ការជួយបណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រងធនធានមនុស្ស។ ការបង្កលក្ខណៈងាយស្រួលអោយប្រជាពលរដ្ឋ បង្កើតសហគមន៍កសិកម្ម ក្នុងទិសដៅធានាតម្លៃផលិតផល។

ដី និងទឹក គឺជាធនធានធម្មជាតិពីរយ៉ាង ដែលជាមូលដ្ឋានសំខាន់ អាចយកមកប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្ម និងកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ។ ដោយបន្តអនុវត្តច្បាប់ភូមិបាល និងគោលនយោបាយដីធ្លី។ រាជរដ្ឋាភិបាលបានប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែក និងប្រើប្រាស់ដីធ្លីប្រកបទៅដោយសមធម៌ និងធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី និងការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកមិនប្រើប្រាស់ មិនធ្វើផលិតកម្ម ឬអាជីវកម្មៗល។ រាជរដ្ឋាភិបាលបានពិនិត្យឡើងវិញនូវដីទំនេររបស់រដ្ឋ ឬដីរដ្ឋ ដែលឯកជនកាន់កាប់ដោយមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនិតិវិធី ដែលបានកំណត់កន្លងមក។ រាជរដ្ឋាភិបាល បាននឹងបន្តផ្តល់អាទិភាពដល់ការពង្រឹងសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ដែលត្រូវការដីសម្រាប់សង់លំនៅឋាន និងធ្វើអាជីវកម្មកសិកម្ម គ្រួសារក្នុងក្របខ័ណ្ឌដីសម្បទាន ដើម្បីគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្ម ដោយឈរលើគោលការណ៍ជួយគ្រួសារកសិករក្រីក្រ ដែលរស់នៅទីជនបទដាច់ស្រយាល និងផ្តល់សុវត្ថិភាពក្នុងការប្រកបអាជីវកម្ម។

មច្ឆាជាតិមានសារៈសំខាន់សម្រាប់ប្រជាជនគ្រប់រូបដោយផ្តល់ជាអាហារ និងជាចំណូលក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ គួបផ្សំនឹងអង្ករ ត្រី ក៏ជាផ្នែកមួយសំខាន់ដែរ នៃសន្តិសុខស្បៀង ហេតុនេះហើយរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអភិវឌ្ឍន៍វិស័យជលផល ប្រកបដោយដោយចីរភាព និងមានសមធម៌ ដោយប្រគល់សិទ្ធិអំណាចទៅអោយសហគមន៍ជនបទ ដើម្បីអោយប្រជាកសិករអាចចូលរួមបានយ៉ាងសកម្មក្នុងការរៀបចំផែនការ និងកម្មវិធីនានា ដើម្បីទទួលខុសត្រូវគ្រប់គ្រងធនធានជលផលដោយខ្លួនឯង។ រាជរដ្ឋាភិបាលនឹងបង្វែរឡូត៏នេសាទចប់កិច្ចសន្យាមួយចំនួនទុកជាកន្លែងសម្រាប់អភិរក្សពូជត្រី និងបង្កើនផលស្តុកធម្មជាតិទុករក្សា ពូជត្រីដែលស្ទើរផុតពូជអោយកើតមានសម្បូរណ៌ឡើងវិញ ព្រមទាំងបង្កើនទំហំដែននេសាទជូនប្រជាពលរដ្ឋ និងជម្រុញការអភិវឌ្ឍន៍ផ្នែកវារីវប្បកម្ម ដើម្បីឆ្លើយតបទៅនឹងកំណើននៃតម្រូវការសាច់ត្រី ព្រមទាំងបន្តយសម្ភាធលើធនធានជលផល និងធនធានធម្មជាតិផងដែរ។

គោលដៅជាយុទ្ធសាស្ត្រនៅក្នុងវិស័យព្រៃឈើ គឺការធានាអោយបាននូវការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងដោយឈរលើមូលដ្ឋានសំខាន់ៗ ដូចជា:

-គោលនយោបាយគ្រប់គ្រងព្រៃឈើ ដោយមានការត្រួតពិនិត្យអាជីកម្មព្រៃឈើយ៉ាងម៉ឺងម៉ាត់ និងសមស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងព្រៃឈើ ដែលតម្រូវអោយមានទំហំព្រៃឈើបម្រុងទុកគ្រប់គ្រង សម្រាប់ទប់ទល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ ដើម្បីការពារភាពរាំងស្ងួត និងទឹកជំនន់ ព្រមទាំងមានព្រៃលិចទឹកសម្រាប់ទុកជាជម្រកមច្ឆាជាតិ។

-ប្រព័ន្ធការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចម្រុះ និងប្រភេទសត្វដែលកម្រ។

-ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើមួយ ដែលរឹងមាំមានតម្លាភាព និងមានការគ្រប់គ្រងដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងតំបន់នោះ ហើយទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលបាននឹងបន្តជំរុញគោលនយោបាយដាំដុះព្រៃឈើឡើងវិញ។

កម្ពុជា ជាប្រទេសកសិកម្ម ដែលសំបូរដោយធនធានធម្មជាតិ មានអំណោយផលល្អសម្រាប់ការងារបង្ករបង្កើនផល ហើយប្រជាពលរដ្ឋប្រមាណ ៨០% រស់នៅដោយពឹងផ្អែកលើវិស័យនេះ។ ផលទុនជាតិ ដែលបានមកពីវិស័យកសិកម្មក្នុងរយៈពេលកន្លងមកមានពី ៤០% ទៅ ៥០%។ កសិកម្មនៅក្នុងកម្ពុជាបែងចែកជាច្រើនផ្នែកដូចជា: ផ្នែកដាំដុះ ផ្នែកចិញ្ចឹមសត្វ ផ្នែកព្រៃឈើ និងផ្នែកជលផល។

ការធ្វើអាជីវកម្មផលិតកម្ម ការគ្រប់គ្រង ព្រមទាំងលទ្ធផលទោះបីមានភាពលំបាក ងាយស្រួល ដែលមានលក្ខណៈខុសគ្នាក្តី ក៏មានលក្ខណៈរួមគ្នាដែរ។ ទម្រង់ផលិតកម្មអាជីវកម្មក្នុងវិស័យកសិកម្ម ជាទូទៅលើគ្រប់ផ្នែកទាំងអស់មានបែបផែនផលិតកម្ម អាជីវកម្មពីរបែបគឺ:

-បែបផែនខ្នាតតូច ឬមធ្យម ដែលមានលក្ខណៈជាអាជីវកម្មគ្រួសារ និងមានលក្ខណៈវិនិយោគទុនកម្រិតទាប។

-បែបផែនផលិតកម្មជាលក្ខណៈកសិ-ឧស្សាហកម្ម តាមរបៀបវិនិយោគទុនខ្នាតធំ។

យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក៏ដូចជា ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ គឺជំរុញការអភិវឌ្ឍន៍កសិកម្ម ដោយផ្តែកទៅលើបែបផែនទាំងពីរបែបនោះ។

១-បែបផែនផលិតកម្មខ្នាតតូច និងមធ្យម ដែលអនុវត្តន៍ដោយកសិករភាគច្រើនរយៈពេលកន្លងមកមានសភាពអន់ថយមានបច្ចេកវិជ្ជាទាបទុនវិនិយោគតិចខ្វះទីផ្សារ។ ប៉ុន្តែបច្ចុប្បន្នវាមានតួនាទីសំខាន់ណាស់ព្រោះផលិតផលកសិកម្មស្ទើរតែទាំងស្រុងចេញពីប្រភពនេះ។

២-បែបផែនកសិ-ឧស្សាហកម្មតាមរយៈវិនិយោគទុនខ្នាតធំ គឺសំដៅបង្កើតផលិតផលដែលមានគុណភាពខ្ពស់បង្កើតការងារថ្មីសម្រាប់ប្រជាពលរដ្ឋ និងនាំមកនូវបច្ចេកវិជ្ជាទំនើបៗ។ ហើយជាមួយគ្នានេះដែរ ក្រុមហ៊ុនវិនិយោគអាចមានលទ្ធភាពរកទីផ្សារដោយខ្លួនឯង ព្រមទាំងជាទីផ្សារទទួលបាននូវវត្ថុធាតុដើម ជាកសិផលដែលមានប្រភពពីផលិតករខ្នាតតូចយកទៅកែច្នៃទៀតផង។

៤.៣.២ ការអភិវឌ្ឍន៍កសិកម្ម គន្លឹះនៃការកាត់បន្ថយភាពក្រីក្រ

វិស័យកសិកម្មពឹងផ្អែកសំខាន់លើកំណើនផលិតផលស្បៀងប្រចាំឆ្នាំនៅតំបន់វាលទំនាប។ តំបន់ទាំងនេះតែងតែរងគ្រោះដោយទឹកជំនន់ជាញឹកញាប់ធ្វើអោយផលិតស្បៀង និងការចិញ្ចឹមសត្វត្រូវបាត់បង់យ៉ាងច្រើនជារៀងរាល់ឆ្នាំ។ ដីជាំដុះ ដំណាំ ឈើហូបផ្លែក្នុងតំបន់គ្មានទឹកលិចមានប្រមាណទាបជាង ៥% នៃផ្ទៃដីជាំដុះសរុប។

ប្រទេសកម្ពុជាមានផ្ទៃដីសម្រាប់កសិកម្មសរុបប្រមាណ ១៨.១៥លានហិកតា ក្នុងនោះមួយភាគបីស្មើនឹង ៤.៦លានហិកតា ជាដីមានអំណោយផលសម្រាប់វិស័យកសិកម្ម។ បច្ចុប្បន្ន ដីដែលប្រើប្រាស់សម្រាប់កសិកម្មមានប្រហែល ២.៧លានហិកតា និងមានផ្ទៃដីប្រមាណ ៣.៧លានហិកតាទៀត ជាដីថ្មីអាចធ្វើកសិកម្មបាន។ មានផ្ទៃដី១.២លានហិកតា នៃដីកសិកម្មបច្ចុប្បន្ននៅមិនទាន់ប្រើប្រាស់ និងប្រហែល ២.៥លានហិកតាទៀត ជាដីព្រៃគម្លោត ហើយភាគច្រើនជាដីមានជីវជាតិទាប មិនសមស្របទៅនឹងដំណាំកសិកម្ម។ ក្រោមសម្ពាធដ៏ធ្ងន់ធ្ងរពីប្រជាសាស្ត្រ និងទីផ្សារបានទាមទារអោយកែច្នៃដីទាំងនោះ អោយក្លាយទៅជាដីប្រើប្រាស់សម្រាប់កសិកម្ម ហើយរាជរដ្ឋាភិបាលត្រូវតែប្រកាន់យកជំហរអោយរឹងមាំ ដើម្បីទទួលបាននូវផលល្អ និងប្រកបដោយសមធម៌។

ប្រព័ន្ធកសិកម្មបានផ្តោតសំខាន់លើដំណាំស្រូវក្រោមរបបទឹកភ្លៀង នៅតាមតំបន់មួយចំនួនទទួលបានការស្រោចស្រពដោយមានកំណត់។ ដោយសារតែកសិផលពឹងផ្អែកទាំងស្រុងលើទឹកភ្លៀងសម្រាប់ការស្រោចស្រពនេះហើយ ដែលនាំអោយទិន្នផលម្តងទាបម្តងខ្ពស់។ ផលស្រូវដែលបានពីរបបទឹកភ្លៀងតិចជាងផលដំណាំផ្សេងៗទៀតប្រចាំឆ្នាំ។ ការវិនិយោគបន្ថែមលើដំណាំស្រូវក្នុងរដូវវស្សា មិនអាចបង្កើនចំណូលកសិកម្មអោយបានច្រើនឡើយ។ ទោះជាយ៉ាងណាក៏មូលដ្ឋានសម្រាប់បង្កើនកសិផលច្រើនប្រភេទមានទំហំតូចនិងតិចជាង ៥% នៃផ្ទៃដី ដែលបច្ចុប្បន្នកំពុងដាំដំណាំប្រចាំឆ្នាំផ្សេងៗ ហើយដើម្បីពង្រីកដំណាំកសិផលច្រើនប្រភេទនោះ ទីផ្សារក្នុងស្រុកបានក្លាយជាឧបសគ្គដល់ផលិតកម្ម។ កសិករជាទូទៅ ភាគច្រើនទទួលបានភោគផលត្រឹមតែ ២លានរៀលប៉ុណ្ណោះ ក្នុងមួយឆ្នាំ ដែលជាផលដកនៃតម្លៃលក់ និងតម្លៃទុនផលិត ហើយកម្លាំងពល

កម្មគ្រួសារមិនត្រូវបានចំណាយ។ បរិមាណនេះមានពី ៣០% ទៅ ៦០% នៃចំណូល ដែលជាតម្រូវការចាំបាច់របស់គ្រួសារ។ ផលិតផលបន្ថែអាចសម្រេចតម្លៃលក់ប្រហែល ៤លានរៀល ប្រចាំឆ្នាំសម្រាប់កម្លាំងពលកម្មខ្ពស់ជាធម្មតាកសិករដាំបន្ថែពីរដងទៅបីដងក្នុងមួយឆ្នាំ។

តម្លៃលក់ទាបនៅតាមចំការ ត្រូវបានចាត់ទុកថា ជាផលដ៏សំខាន់សម្រាប់គ្រួសារកសិករក្នុងការញើតប្រើបច្ចេកវិទ្យាទំនើប ដែលតម្រូវអោយចាយប្រាក់ដើម្បីទិញគ្រាប់ពូជ ជី និងថ្នាំសម្លាប់សត្វល្អិត។ ថ្លៃលក់ទាបរឹងតម្លៃដឹកជញ្ជូនខ្ពស់កង្វះខាតការប្រកួតប្រជែងទីផ្សារ និងកង្វះខាតជាទូទៅនូវសម្ភារៈបរិក្ខាកែច្នៃកសិផលប្រសិទ្ធភាពនៃការសម្រួលដល់ការកែច្នៃកសិផលអាចបន្ថែមតម្លៃនៅកសិដ្ឋាន និងអនុញ្ញាតអោយអ្នកទិញផ្តល់ថ្លៃសមរម្យចំពោះកសិផល ដែលកសិករបានធ្វើការផលិត។ ការខាតបង់ទិន្នផលដ៏ច្រើនក្រោយពេលរដូវច្រូតកាត់អាចបណ្តាលមកពីការទុកដាក់មិនបានល្អ និងការពន្យាពេលបញ្ចេញផលិតផលទៅទីផ្សារដំណើរការនេះប្រព្រឹត្តទៅមិនបានល្អ ព្រោះខ្វះប្រព័ន្ធគមនាគមន៍ ដើម្បីធ្វើចរាចរទំនិញជាទូទៅ គឺខ្វះខាតនៅប្រព័ន្ធព័ត៌មានពីទីផ្សារ។ ដំណោះស្រាយមានប្រសិទ្ធភាពបំផុត គឺបង្កើនប្រព័ន្ធគមនាគមន៍ងាយស្រួលក្នុងការដឹកជញ្ជូន និងជំរុញអោយកសិករយល់ដឹងពីទីផ្សារ។

អាស្រ័យដោយធនធានដ៏សំបូរបែបនេះ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ប្រទេសកម្ពុជាមានលទ្ធ-ភាពសម្រាប់រក្សាស្ថេរភាពកំណើនកសិកម្ម។ ទាំងអស់នេះ ជាកាលានុវត្តភាពដែលអាចយកមកប្រើប្រាស់ ដើម្បីលើកទឹកចិត្តដល់កសិកម្មតូចតាចធ្វើអោយមានភាពភ្លៀវភ្លាឡើងវិញ តាមរយៈការអនុវត្តន៍គោលនយោបាយកសិកម្មមួយសមស្រប និងមានកម្មវិធីអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ ការលំបាកនានាចាំបាច់ជាច្រើនដែលត្រូវធ្វើការសិក្សាអោយបានស៊ីជម្រៅ ក្នុងបរិបទនៃគម្រោងការអនុវត្តន៍សម្រាប់កំណើនកសិកម្មមួយជាក់លាក់។

ចំពោះផលិតកម្មស្រូវ និងដំណាំផ្សេងៗមានសក្តានុពលល្អសម្រាប់រយៈពេលខ្លី និងមធ្យម ដើម្បីបង្កើនទិន្នផលស្រូវបង្កើនការដាំដុះបែបប្រពលវប្បកម្ម និងបង្កើនផ្ទៃដីមួយឯកតាក្នុងប្រព័ន្ធដីរៈស្រូវខុសៗគ្នា។ អាចសម្រេចជោគជ័យបាន ក្នុងសក្តានុពលផលិតភាពអតិបរិមាដោយធ្វើការអភិវឌ្ឍន៍មធ្យោបាយស្រោចស្រពត្រឹមត្រូវសម្រាប់បង្កើនផលិតកម្មពីរដងលើផ្ទៃដី ទំនាប និងប្រើប្រាស់ពូជ ដែលមានគុណភាពល្អទៅតាមលទ្ធភាពជាមូលដ្ឋានរបស់សហគមន៍កសិដ្ឋាន និងបង្កើតទីផ្សារសម្រាប់នាំស្រូវចេញ។ ផ្នែកធារាសាស្ត្រដូចជា ការប្រើប្រាស់អណ្តូងលូរាក់ និងស្នប់បូមទឹកធុនតូចបង្កើនផលស្រូវ និងដាំដុះបែបប្រពលវប្បកម្មបានដែរ ពិសេសចំពោះតំបន់ដីមានផលិតភាពពីមធ្យមទៅខ្ពស់ ដែលផលប្រចាមឆ្នាំសរុប ៥.៤តោន ក្នុងមួយហិកតា ខ្ពស់ជាងកម្រិតផលិតភាពកន្លងមកពីរដង ហើយនេះគេអាចធ្វើបាន។ តាមការប៉ាន់ស្មាន ១០០.០០០ហិកតា ដែលកើនឡើងក្នុងផ្ទៃដីបានស្រោចស្រពជាដីមានផលិតភាពពីមធ្យមទៅខ្ពស់នោះ បរិមាណស្រូវអាចកើនឡើងដល់ ៣០០.០០០តោន សូម្បីតែតំបន់ដី ដែលមានផលិតភាពទាប ក៏កម្រិតទិន្នផលអាចពង្រីកបានប្រហាក់ប្រហែលនឹង ២៥០.០០តោនដែរ ហើយបរិមាណនេះកើនឡើងដល់ ៧,២% និង ៨,៧% តាមប្រភេទនីមួយៗនៃ

ផលិតកម្មស្រូវប្រចាំឆ្នាំ។ ជាមួយនឹងសក្តានុពលសម្រាប់អោយមានផលលើសនោះ លទ្ធភាពនៃការនាំស្រូវចេញ ក្នុងបរិមាណសមរម្យមិនប្រើពេលវេលាយូរឡើយ។

បច្ចុប្បន្នប្រទេសកម្ពុជា ដូចជា មានភាពជឿនលឿនខ្លះក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាងនៅអាស៊ានអំពីផលិតផល ពោត សណ្តែកសៀង សណ្តែកបាយ ។ល។ ជាមួយការស្រោចស្រព និងការកែលម្អបច្ចេកវិទ្យាផលិតនោះ អាចប្រកួតប្រជែងនៃផលិតកម្មដំណាំផ្សេងៗដូចជា ដំឡូងមី ដំឡូងជ្វា និងបន្លែ។ ទោះជាដូច្នេះក្តី កម្ពុជាបាននាំចេញគ្រឿងផ្សំចំណីសត្វសម្រាប់ផលិតកម្មចិញ្ចឹមមាន ម្សៅត្រី កន្ទក់ ចុងអង្ករ ទៅបណ្តាប្រទេសមួយចំនួននៅអាស៊ាន ដោយធ្វើការបង្កើនប្រសិទ្ធភាពផលិតកម្មជាមួយនឹងការបង្កើនវិនិយោគក្នុងអាជីវ-កម្មផលិតកម្មរបស់អ្នកវិនិយោគក្នុងស្រុក និងបរទេស។

រីឯដំណាំកសិ-ឧស្សាហកម្ម ដូចជា កៅស៊ូ ជាផលិតផល ដែលកម្ពុជាបាននាំចេញ ជាប្រពៃណីមួយយូរយារមកហើយ។ កៅស៊ូ នៅតែជាផលិតផលមួយក្នុងចំណោមផលិតផល ដែលកម្ពុជាទទួលផលប្រយោជន៍។ ប៉ុន្តែនៅមានខ្វះចន្លោះធ្វើការកែលម្អក្នុងលក្ខខ័ណ្ឌបច្ចេកទេសប្រមូលផល និងគុណភាពដំណើរការផលិតកម្ម។ ផលិតផល អាចកើនឡើងក្នុងរយៈពេលមធ្យម និងរយៈពេលវែងដោយពង្រីកផ្ទៃដីដាំដុះ បង្កើនដង់ស៊ីតេដើមកៅស៊ូ និងធ្វើអោយផលិតភាពនៃដើមកៅស៊ូ នីមួយៗប្រសើរឡើង។

ផលិតផលកសិកម្មមួយផ្នែកធំ ត្រូវបានធ្វើការនាំចេញជាវត្ថុធាតុដើម និងមួយផ្នែកទៀត ជាផលិតផលកែច្នៃ ដែលមានកម្រិតគុណភាពទាប ជាហេតុធ្វើអោយផលិតផលទាំងនោះលក់ក្នុងតម្លៃទាប។ ហេតុនេះហើយ រាជរដ្ឋាភិបាលបានចាត់ទុកការអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្មជាទិសដៅអាទិភាព ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបង្កើតកំណើនសេដ្ឋកិច្ចតាមរយៈ ១-ការបង្កើនប្រាក់ចំណូល ដែលបានមកពីការកែច្នៃផលិតផលកសិកម្ម និងម្ហូបអាហារ។ ២-ការបង្កើតការងារជូនប្រជាពលរដ្ឋនៅតាមបណ្តាកសិដ្ឋានកសិកម្ម និងសហគ្រាសកែច្នៃ។ ៣-ការផ្លាស់ប្តូរការនាំចេញនូវវត្ថុធាតុ ដើម្បីអោយទៅជាការនាំចេញនូវផលិតផលសម្រេច។

មានលទ្ធភាពប្រហាក់ប្រហែលគ្នានេះដែរ ក្នុងការបង្កើនផលិតកម្មស្វាយចន្ទី ដូង សម្រាប់នាំចេញ ហើយនឹងផលិតផលកាហ្វេ សម្រាប់ជំនួសអោយការនាំចូល ព្រោះកាលពីឆ្នាំ១៩៦០ ប្រទេសកម្ពុជាធ្លាប់បាននាំចេញនូវផលិតផលកាហ្វេ ប៉ុន្តែបច្ចុប្បន្នផលិតផលនេះពុំទាន់មាននៅឡើយទេ។ លក្ខខ័ណ្ឌអាកាសធាតុសម្រាប់កសិកម្មានសមស្របជាពិសេសទៅនឹងដំណាំដូង ដែលបច្ចុប្បន្នបានផលិតសម្រាប់ការប្រើប្រាស់ផ្លែដូងខ្ចីតែប៉ុណ្ណោះ។

ចំពោះវិស័យជលផល និងព្រៃឈើវិញ យើងដឹងហើយថា ប្រជាជនកម្ពុជាភាគច្រើនជាប្រជាជន ដែលរស់នៅតាមជនបទពឹងផ្អែកលើវិស័យជនផលសម្រាប់ផ្គត់ផ្គង់ជីវភាព។ ត្រីបានដើរតួជាប្រភពផ្តល់ប្រូតេអ៊ីនយ៉ាងសំខាន់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតាមជនបទក៏ដូចជា នៅទីក្រុង។ គេបានរកឃើញនៅតំបន់ខ្សត់ត្រីប្រភពប្រូតេអ៊ីនប្រមាណ ៤០% ទៅ ៦០% ដោយផ្តល់ត្រី និងនៅតំបន់សំបូរត្រី ជាពិសេស ប្រជាជននៅតាមតំបន់ជុំវិញបឹងទន្លេសាប ដងទន្លេ ស្ទឹង ព្រែក និងវាលទំនាបលិចទឹកនានា ប្រមាណពី៧០%ទៅ ៧៥%

នៃប្រូតេអ៊ីន ដែលបានមកពីត្រី។ តាមការប៉ាន់ស្មានតម្រូវការ និងការផ្គត់ផ្គង់នៅតាមគម្លាតឆ្ងាយពីគ្នានៅឡើយ ជាទូទៅ ទទួលបានត្រឹមតែ ១០-១៣គ.ក្រ ម្នាក់ៗក្នុងមួយឆ្នាំ គឺទាបជាងចំនួនអប្បបរមានៃតម្រូវការ ប្រូតែអ៊ីន ដែលមានចំនួន២១.៥គ.ក្រម្នាក់ៗក្នុងមួយឆ្នាំ។ ក្នុងចន្លោះឆ្នាំ១៩៩៥-៩៦ ការធ្វើស្ថិតិតាមផ្ទះនៅក្នុងស្រុកដែលប្រកបដោយរបរជានេសាទ នៅក្នុងខេត្តចំនួន៨ បានបង្ហាញពីការហូបត្រីមានចំនួន៧៦គ.ក្រម្នាក់ៗក្នុងមួយឆ្នាំ។ សម្រាប់ប្រជាជន ៤.២លាននាក់ ត្រូវការបរិមាណត្រីប្រមាណ ២៨០.០០០តោនក្នុងមួយឆ្នាំ។

ក្រៅពីការផ្តល់ម្ហូបអាហារដល់ប្រជាជន វិស័យជលផលក៏បានផ្តល់ការងារយ៉ាងច្រើនដល់ប្រជាកសិករខ្មែរយើងដែរ។ ក្នុងចំណោមប្រជាជនជាំង ១១.៤លាននាក់ មានអ្នកនេសាទប្រមាណ ២៥០.០០០នាក់ ដែលត្រូវជា ២.២% នៃប្រជាពលរដ្ឋសរុប។ ក្រៅពីនេះប្រជាជនប្រមាណ ៨០% ជាអ្នកនេសាទផង និងជាកសិករផងដែរ។ វិស័យជលផលនៅកម្ពុជាមានចំណែក ៣.៤%-៤,៥% ក្នុងផលទុនជាតិសរុប ដោយគិតទាំងការនេសាទគ្រួសារផងដែរ។

បទពិសោធន៍នៃការគ្រប់គ្រងវិស័យជលផលកន្លងមក បណ្តាលអោយមានបាតុភាពទំនាស់ជាច្រើនរាប់មិនអស់ ដែលកើតមានឡើងមកអំពីសិទ្ធិពុំស្មើគ្នា ក្នុងការទទួលអត្ថប្រយោជន៍ពីជលផល។ មានន័យថា អត្ថ-ប្រយោជន៍ដ៏លើសលប់បានមកពីវិស័យជលផល ត្រូវបានផ្តល់ទៅអោយមនុស្សមួយចំនួនតូច ដែលមានលទ្ធភាពគ្រប់គ្រាន់ដូចជា ម្ចាស់ឡូត៍នេសាទជាដើម ហើយអ្នកទាំងនោះពុំមែនជាអ្នករស់នៅក្នុងសហគមន៍នេសាទទេ ចំណែកប្រជានេសាទក្រីក្រភាគច្រើន ដែលរស់នៅក្នុងសហគមន៍នេសាទផ្ទាល់ ទទួលបានអត្ថប្រយោជន៍តិចតួចប៉ុណ្ណោះ។ ដោយសារហេតុផលខាងលើគួបផ្សំជាមួយនឹងការកើនឡើងនូវចំនួនប្រជាជនពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើអោយទំនាស់បានកើតឡើងស្ទើរគ្រប់ទីកន្លែង ហើយម្យ៉ាងវិញទៀតដើម្បីរស់ធ្វើអោយប្រជានេសាទអ្នកក្រីក្រទាំងនោះបង្ខំចិត្តមិនគោរពច្បាប់ ហើយបានប្រព្រឹត្តអំពើល្មើសផ្សេងៗ នាំទៅដល់ការបំផ្លិចបំផ្លាញធនធានជាតិ។ យល់ឃើញនូវហេតុផលទាំងនេះ រដ្ឋាភិបាលក្នុងពេលថ្មីៗនេះ បានដាក់ចេញជាថ្មីនូវគោលនយោបាយកំណែទម្រង់ជលផលក្នុងទិសដៅចម្បងពីរ គឺការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងលើកកម្ពស់ជីវភាពរបស់ប្រជានេសាទ។

ក្នុងទិសដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ក្នុងគោលបំណងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនដែលរស់នៅតាមជនបទ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅចម្បងៗដូចជា: ការកែសម្រួលច្បាប់ជលផលអោយបានចប់សព្វគ្រប់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនៅក្នុងឆ្នាំ២០០២ ការបង្កើតសហគមន៍នេសាទ និងការបង្កើនការចិញ្ចឹមត្រីនៅតាមតំបន់ដែលគ្មានដែននេសាទ។

ចំពោះការបង្កើតសហគមន៍នេសាទថ្មីៗនេះ រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់វិស័យជលផលក្នុងនោះ រាជរដ្ឋាភិបាលបានកាត់បន្ថយផ្ទៃឡូត៍នេសាទ និងលុបឡូត៍នេសាទប្រមាណ ៥៦% ទុកសម្រាប់អោយប្រជា-ពលរដ្ឋប្រកបរបរនេសាទជាលក្ខណៈគ្រួសារ។ ស្របជាមួយនេះដែរ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយអនុញ្ញាតអោយរៀបចំគ្រប់គ្រង តាមរយៈការបង្កើតសហគមន៍នេសាទ គឺបានប្រែក្លាយរូបភាពនៃការ

គ្រប់គ្រងវិស័យដលផលពីការគ្រប់គ្រងដោយរដ្ឋដោយប្រើច្បាប់ជាមូលដ្ឋាន មកជាការគ្រប់គ្រងបែបសហ-គ្រប់គ្រង មានន័យថា ការគ្រប់គ្រងធនធានដលផលដោយផ្អែកលើសហគមន៍ គឺជាប្រព័ន្ធគ្រប់គ្រងមួយដែលរដ្ឋអំណាច ចែករំលែកអំណាចមួយចំនួនអោយទៅប្រជាពលរដ្ឋធ្វើការគ្រប់គ្រងអភិរក្ស និងប្រើប្រាស់ធនធានដលផលអោយមាននិរន្តរភាពនៅតាមមូលដ្ឋានរបស់ពួកគេ។ ការគ្រប់គ្រងធនធានដលផលបែបនេះ ធានាបាននូវសុវត្ថិភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយហេតុថា ពួកគេទាំងនោះមានសិទ្ធិប្រើប្រាស់ និងគ្រប់គ្រងលើធនធានសំខាន់ៗនោះ ហើយពួកគាត់នឹងមានឱកាសល្អប្រសើរមួយ ដើម្បីឆ្លើយតបនឹងតម្រូវការជាមូលដ្ឋានរបស់ខ្លួន និងការកែលម្អ ជីវភាពរស់នៅ។

ជាមួយគ្នានេះដែរ ការងារបំផុស និងផ្សព្វផ្សាយការចិញ្ចឹមត្រីតាមស្រះ និងតាមវាស្រែក៏ជាទិសដៅសំខាន់មួយដែរ ក្នុងការចូលរួមចំណែកលើកស្ទួយដល់ជីវភាពប្រជាពលរដ្ឋ ដែលរស់នៅតាមតំបន់ឆ្ងាយពីដែននេសាទ។ កន្លងមកកាងារនេះទទួលបានលទ្ធផលគួរអោយកត់សម្គាល់តាមរយៈសកម្មភាពនិងជួយឧបត្ថម្ភរបស់អង្គការអន្តរជាតិនានាដូចជា: AIT, MRC/DANIDA, PADEC, SAO and AFO ដោយបានផ្សព្វផ្សាយ និងបង្រៀនដល់កសិករអោយចេះចិញ្ចឹមត្រីតាមស្រែ និងស្រះ ដូចជា នៅខេត្តកណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវជាដើម។ ទិសដៅបន្តក្រសួងកសិកម្មនឹងពង្រឹងបន្តការងារនេះនៅខេត្តមួយចំនួនទៀតដូចជា នៅខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគីរី រតនគីរី ជាដើម។

តាមស្ថិតិផ្លូវការ ផលិតផលត្រីក្នុងតំបន់ស្រែទំនាបបានបង្ហាញពីកម្រិតផលត្រីប្រចាំឆ្នាំយ៉ាងតិចបំផុត ២៥គ.ក្រ ក្នុងមួយហិកតា។ ទម្លាប់ចិញ្ចឹមត្រីតាមស្រែមានអន្លង់សម្រាប់ចាប់ ត្រូវការវិនិយោគតិចតួច ដូចជា ជីកស្រះ ប្រឡាយ ទិញកូនត្រី និងចំណីខ្លះប៉ុណ្ណោះ ហើយចំណូលបានមកពីត្រី និងបូកបន្ថែមលើចំណូលបានមកពីស្រូវ ឬយ៉ាងហោចណាស់ត្រីបានផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ប្រជាកសិករដែរ។

ព្រៃឈើមានតួនាទីយ៉ាងសំខាន់ណាស់ក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិ ក្នុងវិស័យកសិកម្មសេដ្ឋកិច្ច បរិស្ថានរបស់ប្រទេសកម្ពុជា ជាពិសេសសម្រាប់ការចិញ្ចឹមជីវិតរបស់សហគមន៍ជនបទ។ ម្យ៉ាងវិញទៀត ព្រៃឈើជាប្រភពថាមពល និងវត្ថុធាតុដើមសម្រាប់បម្រើនៅសេចក្តីត្រូវការក្នុងស្រុក និងធ្វើការនាំចេញទៅបរទេស។ ក្របខ័ណ្ឌគោលនយោបាយព្រៃឈើ ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងអោយបានគ្រប់គ្រាន់ផងដែរទៅលើសុវត្ថិភាពស្បៀង និងការកាត់បន្ថយភាពក្រីក្រ។

គោលនយោបាយ ដើម្បីនិរន្តរភាពផលិតកម្មឈើមានប្រសិទ្ធភាព ត្រូវតែមានគោលដៅធ្វើអោយមានសុទិដ្ឋិនិយមលើផលប្រយោជន៍របស់សហគមន៍ជនបទ តាមរយៈសហគន៍ដែលមានព្រៃឈើជាមូលដ្ឋាន និងការពារផលប៉ះពាល់ជាអវិជ្ជមានដល់ព្រៃឈើតាមលំហូរនទីក។

មិនតែប៉ុណ្ណោះការងារផលិតកម្ម និងបសុព្យាបាល មានលទ្ធភាពច្បាស់លាស់សម្រាប់ការបង្កើនផលិត-ភាព និងគុណភាពផលិតកម្មដោយសង្កត់ធ្ងន់លើយុទ្ធសាស្ត្រ ៥ចំណុច កាត់បន្ថយអត្រាសត្វឈឺ ស្លាប់ បង្កើន

ផលិតកម្ម និងគុណភាពចំណីសត្វ អភិវឌ្ឍន៍ផលិតកម្មសត្វ និងកែច្នៃលាមសត្វកែលម្អ និងកែប្រែពូជសត្វ និងទីផ្សារ។

ដើម្បីអោយបានសម្រេចនូវគោលបំណងតម្រូវអោយមានសកម្មភាពជាច្រើនដូចជា កែសម្រួល និងកសាងច្បាប់លិខិតបទដ្ឋាន ផ្នែកផលិតកម្មសត្វ និងបសុព្យាបាល ការអភិវឌ្ឍន៍ចាត់ចែងធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញបច្ចេកទេស ការផ្សព្វផ្សាយបច្ចេទេសផលិតកម្មសត្វ និងបសុព្យាបាលដល់ស្រទាប់ប្រជា-កសិករ ការពង្រឹងពង្រីសេវាកម្មបសុពេទ្យដោយជ្រើសរើស និងបន្តជ្រើសរើសភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីជួយពិនិត្យព្យាបាល និងការពារសុខភាពសត្វកក្នុងមូលដ្ឋានរបស់ខ្លួន ពង្រីកសកម្មភាពរោគវិនិច្ឆ័យជំងឺសត្វ ការស្រាវជ្រាវជំងឺសត្វ ការត្រួតពិនិត្យជំងឺសត្វ ការចាក់ថ្នាំការពារ ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ការពង្រីកប្រព័ន្ធព័ត៌មាន ផ្នែកផលិតកម្ម និងបសុព្យាបាល នាំចូលពូជដំណាំចំណីសត្វ ដែលផ្តល់ទិន្នផលខ្ពស់ផ្សព្វផ្សាយពូជ ដំណាំ ចំណីសត្វ អោយកសិករដាំ បង្កើតមន្ទីរពិសោធន៍វិភាគចំណីសត្វ លើកទឹកចិត្តអ្នកវិនិយោគសត្វបង្កើតអោយមានឡជីវឧស្ម័ននៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីសត្តឃាតសម្រាប់យកថាមពលប្រើប្រាស់នៅក្នុងផ្ទះបាយដុតបំភ្លឺ ដើម្បីរួមចំណែកក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយការកាប់ព្រៃឈើ និងការចូលរួមការការពារបរិស្ថាន និងសុខមាលភាពសង្គម។ ម្យ៉ាងវិញទៀត កាកសំណល់ចេញពីឡជីវឧស្ម័នប្រើប្រាស់ជាជីកំប៉ុស្តិ៍ជាក់ដំណាំកសិកម្មមានប្រសិទ្ធភាពខ្ពស់ នាំចូលពូជសត្វថ្មីដែលមានទិន្នផលខ្ពស់បង្កាត់ និងផ្សព្វផ្សាយពូជពង្រឹង និងពង្រីកស្ថានីយ៍ផ្សព្វផ្សាយពូជសត្វធ្វើការអង្កេតវិភាគទិន្នន័យតម្រូវការតម្លៃសត្វ និងផលិតផលមានដើមកំណើតពីសត្វក្នុងស្រុក និងក្រៅស្រុក។

ក្នុងផ្នែកនេះដែរ ហេតុផលក្នុងការបង្កើនផលិតកម្មសត្វអោយមានសន្ទុះកើនឡើងជាលំដាប់ គឺដើម្បីរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខ និងសុវត្ថិភាពស្បៀង ដែលនឹងឆ្លើយតបទៅនឹងកំណើនប្រជាជនដែលបានកើនឡើងគួរអោយបារម្ភ។ ការបង្កើនផលិតកម្មចិញ្ចឹមសត្វចតុបាទដោយមិនមែនគ្រាន់តែផ្តល់ជាសាច់ និងទឹកដោះសម្រាប់ធ្វើម្ហូបអាហារប៉ុណ្ណោះទេ តែត្រូវបានបំពេញកាតព្វកិច្ចដ៏សំខាន់ដែលមិនអាចខ្វះបាន សម្រាប់ជាកម្លាំងអូសទាញ និងផ្តល់ជាលាមកសម្រាប់ធ្វើជាជីធម្មជាតិ ក្នុងការជំរុញបង្កើនផលិតភាពកសិកម្មទៀតផង។

សរុបមក មូលហេតុចម្បងនៃភាពក្រីក្រ គឺទាក់ទងទៅនឹងការខ្វះមធ្យោបាយផលិតកម្ម ខ្វះភាពជោគជ័យក្នុងការបង្កើតលក្ខខ័ណ្ឌផលិតផលកសិកម្ម។ ប្រព័ន្ធធារាសាស្ត្រមិនគ្រប់គ្រាន់ ធ្វើអោយផ្ទៃដីដាំដុះភាគច្រើនអាចដាំដុះបានតែម្តងប៉ុណ្ណោះ ក្នុងមួយឆ្នាំ ហើយដីទាំងនោះតែងតែរងគ្រោះធម្មជាតិធ្ងន់ធ្ងរ ដែលកើតឡើងជាប្រចាំ។ ខ្វះធនធានមនុស្ស ការអប់រំស្ថិតនៅកម្រិតទាប ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទន់ខ្សោយ បណ្តាញទីផ្សារគ្មានភាពប្រកួតប្រជែងច្បាប់កម្មសិទ្ធិដីធ្លីមិនទាន់រឹងមាំ កង្វះខាតការវិនិយោគសាធារណៈសេវាកម្មនានា និងភាពមិនទាន់រីកចម្រើនផ្នែកប្រព័ន្ធហិរញ្ញវត្ថុជនបទទាំងនេះបានបង្ហាញឡើងជាឧបសគ្គដ៏ធំមួយដល់ការបង្កើនប្រពលភាពកសិកម្មការរក្សាសុខភាព និងភាពស្វាហាប់របស់សង្គមជនបទ។

ដោយប្រជាជន ៩០% ជាជនក្រីក្រស៊ៅនៅជនបទ ដែលពឹងផ្អែកជាបឋមលើវិស័យកសិកម្មសម្រាប់ជីវភាពរស់នៅនោះកិច្ចខិតខំប្រឹងប្រែងចម្បង ក្នុងការចាប់ផ្តើមអភិវឌ្ឍន៍ទីផ្សារ ដែលមានទិសដៅឆ្ពោះទៅរកវិស័យកសិកកម្ម និងផ្តោតជាសំខាន់លើការបង្កើនទិន្នផលការបង្កើនផលចំណេញ ដែលចេញពីដីធ្លី គឺជាលក្ខខ័ណ្ឌដ៏សំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ។ ការងារលំបាកមួយចំនួន ដែលត្រូវពុះពារក្នុងគម្រោងអភិវឌ្ឍន៍នេះ គឺជាការផ្តល់ប្រព័ន្ធចែកចាយទឹកអោយគ្រប់គ្រាន់ និងគ្រប់ទីកន្លែងដែលមានដីកសិកម្ម។ បើកចំហរទីផ្សារសម្រាប់ផលិតកម្មកសិកម្ម និងសម្ភារៈប្រើប្រាស់សម្រាប់កសិកម្មធានាកម្មសិទ្ធិដីធ្លីពន្យល់ណែនាំ និងផ្សព្វផ្សាយចំណេះដឹងស្តីពីបច្ចេកវិទ្យាទំនើប ដែលពាក់ព័ន្ធទៅនឹងកសិកម្មបង្កើតអក្ខរភាពដល់កសិករ។

ចំពោះមុខដើម្បីរួមចំណែក អនុវត្តគោលនយោបាយអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលក៏ដូចជា គោលនយោបាយអភិវឌ្ឍន៍កសិកម្មក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញនូវទិសដៅ និងការៈកិច្ចគឺៈ ផ្តល់អាទិភាពលើការចំណាយវិនិយោគចំណាយសេវាកម្មផ្សេងៗក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម កសិកម្មការងារស្រាវជ្រាវពិសោធន៍ផ្សព្វផ្សាយបំពាក់បំប៉នបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យាផលិតកម្ម។ ត្រូវមានគោលនយោបាយយុទ្ធសាស្ត្រមួយគាំទ្រកសិផលក្នុងស្រុក សម្រាប់ទីផ្សារក្នុងស្រុកដោយកម្រិតការនាំចូលចំពោះផលិតផល ដែលអាចផលិតក្នុងស្រុកបាន។ មានវិធានការអន្តរាមន៍ដល់ការគាំទ្រនូវផលិតកម្មក្នុងស្រុក ដើម្បីលើកម្ពស់ជីវភាពរស់នៅ និងប្រាក់ចំណូលប្រចាំថ្ងៃអោយល្អប្រសើរឡើង។

៤.៣.៣ បទឱ្កីតយន្តការចាំបាច់បន្ថានដ់ចូលរួមកាត់បន្ថយការលំបាករបស់កសិករ

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមប្រតិបត្តិការការងាររបស់ខ្លួនទៅលើមាគ៌ាឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អ ដែលជាបញ្ហាអាទិភាព។ បន្ទាប់ពីការបោះឆ្នោតជាសកលឆ្នាំ១៩៩៣។ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុម័តនូវយុទ្ធសាស្ត្រជាលើកដំបូង ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺកម្មវិធីជាតិ ដើម្បីស្តារ និងការអភិវឌ្ឍន៍កម្ពុជា។ កម្មវិធីទាំងនេះបានគ្របដណ្តប់ទៅលើបញ្ហាទាំងនេះមុខជាច្រើន និងបានកំណត់នូវគំនិតផ្តួចផ្តើមជាអាទិភាពមួយចំនួន ដូចជា ការធ្វើផែនការ ៥ឆ្នាំ លើកទី១ នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមត្រូវបានអនុម័ត ហើយរៀបចំឡើងដោយមានការពិគ្រោះយល់យ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធ។ បន្ទាប់ការបោះឆ្នោតជាទូទៅឆ្នាំ១៩៩៨ ប្រមុខរាជរដ្ឋាភិបាល សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានថ្លែងនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជ-រដ្ឋាភិបាលថ្មី ហើយកម្មវិធីទាំងនេះ គឺបានទាមទារអោយមានការចូលរួមពីគ្រប់ភាគី ដើម្បីជម្រុញអោយមានការខិតខំប្រឹងប្រែងនាំយកសន្តិភាព ស្ថេរភាព សន្តិសុខ នីតិរដ្ឋ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលជាគ្រឹះនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់យុត្តិធម៌សង្គម។ ផ្តើមចេញពីនេះរាជរដ្ឋាភិបាលសម្រេចបានលទ្ធផលជាសារវន្ត ទោះបីជាមិនអាចសម្រេចបានគ្រប់ជ្រុងជ្រោយយ៉ាងណាក៏ដោយក៏អាចចាត់ទុកជាការឈានទៅរកការអភិវឌ្ឍន៍ជាបណ្តើរៗ។ សន្តិភាព សន្តិសុខ និងស្ថេរភាពនយោបាយត្រូវ

បានរៀបចំអោយប្រសើរឡើងវិញ រីឯហិរញ្ញវត្ថុត្រូវបានរៀបំអោយមានសណ្តាប់ធ្នាប់ផងដែរ ទោះជាមានការលំបាកខ្លះៗយ៉ាងណាក៏ដោយ ជាសក្ខីភាពរាជរដ្ឋាភិបាលរក្សាបាននូវលំនឹងអតិផរណានៃប្រាក់ និងកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើតអោយបានប្រសើរឡើងនូវសេដ្ឋកិច្ចទីផ្សារ ដោយបានធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងតំបន់ និងពិភពលោក។

ក្នុងឆន្ទៈនេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានតាក់តែងនូវសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រ កាត់បន្ថយភាពក្រីក្របណ្តោះអាសន្ន និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២ ដែលដឹកនាំដោយក្រសួងផែនការ ដោយផ្តោតទៅលើសកម្មភាពរួមក្រោយទស្សនៈវិស័យ និងយុទ្ធសាស្ត្ររួមគ្នា។ ជាងនេះទៀត ជៀសវាងទំនាស់ទៅលើយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីឈានទៅសម្រេចនូវគោលបំណងតែមួយ គឺការលុបបំបាត់គ្រោះទុគត៌ និងការកាត់បន្ថយភាពក្រីក្រ។ ការសម្រេចបានូវយុទ្ធសាស្ត្ររួមនេះ គឺជាសមិទ្ធិផលនៃការពិគ្រោះយោបល់ដ៏ទូលំទូលាយមួយដែលបានធ្វើឡើងដោយមានការជួយឧបត្ថម្ភគាំទ្រពីដៃគូពីរ គឺធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី។

ក.១-ការបង្កើតសមត្ថភាព និងការត្រួតពិនិត្យភាពក្រីក្រ

ការកសាងសមត្ថភាព និងការពង្រឹងស្ថាប័ន គឺជាប្រការដ៏សំខាន់សម្រាប់កាត់បន្ថយការលំបាក់ក្នុងការអភិវឌ្ឍន៍ ហើយធានានូវការថែរក្សា និងពង្រឹងមូលដ្ឋានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងអត្រាកំណើនសេដ្ឋកិច្ច។ បច្ចុប្បន្នហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច នៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ ហើយសមត្ថភាពជំរុញរបស់រាជរដ្ឋាភិបាល យើងនៅមានកម្រិតប្រព័ន្ធធនាគារនៅពុំទាន់មានប្រសិទ្ធភាពលិខិតបទដ្ឋានគ្រប់គ្រង និងការប្រតិបត្តិការនានានៅពុំទាន់បានកំណត់អោយបានច្បាស់លាស់ ហើយការជម្រុញការអនុវត្តន៍គោលការណ៍ទាំងអស់ពុំទាន់សមស្របនៅឡើយ។ ម្យ៉ាងទៀត ជោគជ័យនៃការអនុវត្តន៍ផ្នែកសេដ្ឋកិច្ចកន្លងបានផ្អែកយ៉ាងខ្លាំងទៅលើប្រភពជំនួយពីក្រៅប្រទេស ហើយជំនួយឧបត្ថម្ភទាំងនេះមានសារៈសំខាន់ សម្រាប់ជួយសម្រួលដល់ការកំណែទម្រង់រចនាសម្ព័ន្ធ និងកាត់បន្ថយតម្លៃនៃកំណែទម្រង់ តែពុំអាចយកមកជំនួយក្នុងការស្វែករកប្រភពធនធានតាមការប្រកួតប្រជែងទីផ្សារក្នុងស្រុក និងអន្តរជាតិ ដើម្បីជំរុញដំណើរការអភិវឌ្ឍន៍បានឡើយ[១៤២]។

យើងគួរយល់ថា ប្រទេសកម្ពុជាយើងជាប្រទេសមួយមានធនធាននៅមានកម្រិត ដែលមិនអាចធ្វើអោយយើងសម្រេចបាននូវគោលដៅផ្នែកសង្គមដ៏មានមហិច្ឆតារបស់ខ្លួនបាននោះទេ។ ដូច្នេះ កត្តាចាំបាច់យើងត្រូវអោយមានការពិគ្រោះយោបល់ ការសម្របសម្រួល និងសហការក្នុងគោលបំណងធ្វើអោយបានប្រសើរឡើងនូវការប្រើប្រាស់ធនធានដែលមាន ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាលត្រូវបានកែលម្អដោយមានការចូលរួមយ៉ាងសកម្ម ពីភាគីពាក់ព័ន្ធទាំងអស់។ ផែនការនេះ គឺជាផែនការដែលត្រូវធ្វើសម្បទានជានិរន្តរ៍នូវតម្រូវការជាក់ស្តែងរបស់ជាតិ និងផែនការដែលគ្របណ្តប់លើគ្រប់វិស័យ ដើម្បីជាមធ្យោបាយសម្រេចបាននូវសកម្មភាពការងារជាបន្តបន្ទាប់ថែមទៀតក្នុងបុព្វហេតុអភិបាលកិច្ចល្អ។

---

[១៤២] ព្រះរាជាណាចក្រកម្ពុជា កម្មវិធីវិនិយោគសាធារណៈ ២០០០-២០០២ ទំព័រទី៤

ជាសក្ខីភាព ប្រមុខរាជរដ្ឋាភិបាលបានធ្វើការណែនាំដល់គណៈរដ្ឋមន្ត្រីរបស់ខ្លួន ក្នុងការជំរុញលើការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត ដែលអាចធ្វើបានដើម្បីសម្រួលដល់ការធ្វើកំណែទម្រង់នេះ។ បច្ចុប្បន្នរាជរដ្ឋាភិបាលបាននឹងកំពុងបញ្ចូលបន្ថែមទៀតផងដែរ នូវសកម្មភាពមួយចំនួននៅក្នុងកម្មវិធីនិងយុទ្ធសាស្ត្រ ដែលមានស្រាប់ដោយផ្អែកលើសេចក្តីព្រាងជាយុទ្ធសាស្ត្រ ដែលបានចូលរួមផ្សព្វផ្សាយកន្លងមក។

ការងារជោគជាច្រើនបាននឹងកំពុងបន្ត ដើម្បីបញ្ចប់នៅច្បាប់មួយចំនួនរបស់ជាតិជាបន្តបន្ទាប់ ជាពិសេស គឺក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានដាក់អោយអន្តរក្រសួងពិនិត្យ និងផ្តល់យោបល់ជាមុន និងដាក់ជូនគណៈរដ្ឋមន្ត្រីសម្រេច។ ច្បាប់ និងលិខិតបទដ្ឋានសំខាន់ថ្មីមួយចំនួនទៀត ជាពិសេស គឺច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងច្បាប់ដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ ដូចជា ដីធ្លី រុក្ខប្រមាញ់ និងនេសាទ សត្វព្រៃជាដើម ដែលជាក្របខ័ណ្ឌមួយសមស្រប ដែលត្រូវផ្តល់ដល់ផ្នែកឯកជន និងសេដ្ឋកិច្ចទីផ្សារត្រូវបានអនុម័តដាក់អោយប្រើប្រាស់រួចហើយ ឬមួយចំនួនទៀតកំពុងតែរៀបចំសេចក្តីព្រាង អោយបានចប់សព្វគ្រប់ជាមុនសិន ដែលនៅក្នុងករណីនីមួយៗយើងបានដាក់អោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ។

ចំពោះការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ចាំបាច់ត្រូវតែជំរុញអោយមានការខិតខំប្រឹងប្រែងទាំងអស់គ្នា។ ហើយដើម្បីសម្រេចបាននូវគោលដៅនេះសំខាន់បំផុតនោះ គឺយើងត្រូវធ្វើយ៉ាងណាអោយបៀវត្សមន្ត្រីរាជការទទួលបានសមស្របអាចទទួលយកបានជាពិសេសប្រាក់បៀវត្សរបស់មន្ត្រី ដែលទទួលខុសត្រូវផ្នែកច្បាប់ទម្លាប់ យើងត្រូវពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ហើយបន្ថែមលើសពីនេះទៅទៀតនោះ គឺថា យើងត្រូវធ្វើការរួមគ្នាដោយភាពស្មោះត្រង់អោយកាន់តែប្រសើរឡើង។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដោយគិតរាប់ទាំងរាជរដ្ឋាភិបាលអាណត្តិទី២ រាជរដ្ឋាភិបាលបានធ្វើអោយមានវឌ្ឍនភាពដោយអនុវត្តតាមគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់ខ្លួនសំដៅបង្កើតសេដ្ឋកិច្ចលំនឹងម៉ាក្រូសេដ្ឋកិច្ច និងស្ថាបនាមូលដ្ឋានគ្រឹះមួយយ៉ាងរឹងមាំសម្រាប់កំណើនសេដ្ឋកិច្ចយូរអង្វែង ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។

ខាងក្រោមនេះ គឺជាសមិទ្ធិផលសំខាន់ៗ ដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមក:

ទី១-រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់រដ្ឋបាល និងប្រព័ន្ធយុត្តិធម៌ ទាំងការបង្កើតនៅប្រព័ន្ធច្បាប់ដែលចាំបាច់សម្រាប់អភិបាលកិច្ចល្អ។ ប្រព័ន្ធច្បាប់នេះបានផ្តល់លទ្ធភាពអោយស្ថាប័ននានាពង្រឹងនីតិរដ្ឋ និងការពង្រឹងសមត្ថភាព។ ជាមួយគ្នានេះដែរ សង្គមស៊ីវិល និងសារព័ត៌មានកម្ពុជាមានលក្ខណៈកាន់តែរស់រវើកជាងមុន ហើយវិស័យឯកជនប្រែក្លាយជាយន្តការជម្រុញកំណើនសេដ្ឋកិច្ច។

ទី២-រាជរដ្ឋាភិបាលចាប់ផ្តើមបង្កើតផែនការ និងយុទ្ធសាស្ត្រជាតិ មានដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមមានរយៈពេល ៥ឆ្នាំ លើកទី២ ផែនការវិនិយោគសាធារណៈ និងផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ យើងចាត់ទុកថា ផែនការទាំងនេះជាកត្តាជំរុញបន្ថែមទៀតក្នុងការកាត់បន្ថយភាពក្រីក្រ ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួមពីបណ្តាក្រសួងពាក់ព័ន្ធនានាជាច្រើន។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល

៥ឆ្នាំ គឺជាគម្រោងមួយដែលបានបង្កើតឡើងដោយមានការវិភាគ និងសកម្មភាពស្នើឡើង ហើយបានអនុវត្ត ទន្ទឹមនឹងពេលដែលផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដើម្បីដើរតួនាទីជាឧបករណ៍សម្រាប់ពិនិត្យឡើងវិញអោយស៊ីជម្រៅលើសមិទ្ធិផល និងការកែសម្រួលគោលនយោបាយចាំបាច់ជាប្រចាំ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបង្ហាញអោយឃើញថា រាជរដ្ឋាភិបាល បានបង្វែងការយកចិត្តទុកដាក់របស់ខ្លួន ចំពោះគោលនយោបាយសម្រាប់រយៈពេលមធ្យមទៅរយៈពេលវែង ហើយទទួលស្គាល់កម្មវិធីកំណែទម្រង់របស់ខ្លួន គឺផ្តោតសំខាន់លើការកាត់បន្ថយភាពក្រីក្រ។

ទី៣-រាជរដ្ឋាភិបាលបានបង្កើតក្រុមអភិវឌ្ឍន៍សង្គម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ ដោយមានការចូលរួមពីភ្នាក់ងារមួយចំនួន និងសង្គមស៊ីវិល។ ក្រុមប្រឹក្សានេះនឹងក្លាយទៅជាស្ថាប័នកម្រិតខ្ពស់បំផុតមួយរបស់រាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ និងសម្របសម្រួល លើកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសក្នុងគោលបំណងប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ការធានាអោយមានសមភាព និងយុត្តិធម៌សង្គម។

ទី៤-រាជរដ្ឋាភិបាលបានអភិវឌ្ឍន៍របៀបវារៈនយោបាយសង្គមថ្មីមួយ គឺនយោបាយធ្វើជំនួយ ដើម្បីគាំទ្រដល់ជនក្រីក្រ និងអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ។ នយោបាយនេះនឹងផ្តល់នូវមូលដ្ឋានគ្រឹះមួយសម្រាប់ការកែចម្រើនសមត្ថភាព និងវឌ្ឍនភាពពេលអនាគត ដែលជាការចាំបាច់ និងអាទិភាពចំពោះផែនការ និងយុទ្ធសាស្ត្រដែលត្រូវបានប្រើប្រាស់ក្នុងការចំណាយដោយឡែក និងការចំណាយជាក់ស្តែងនៃធនធានខាងក្នុង និងខាងក្រៅសម្រាប់ផ្នែកសង្គម។

ទី៥-រាជរដ្ឋាភិបាលបានប្តេជ្ញាជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស ចាប់តាំងពីឆ្នាំ១៩៩៨ មក ហើយបន្តដល់បច្ចុប្បន្ន បាននឹងកំពុងជំរុញបង្កើតគណៈកម្មការភូមិ ឃុំ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងតាមបែបប្រជា-ធិបតេយ្យ ដែលគាំទ្រដោយក្រសួងអភិវឌ្ឍន៍ជនបទ។ គណៈកម្មការនេះត្រូវបានគេអោយតម្លៃថា ជាមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទចាប់តាំងពីថ្នាក់ក្រោមទៅថ្នាក់លើ និងជាមូលដ្ឋានដើម្បីឈានទៅរកការចូលរួមនិងការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព[១៤៣]។ គណៈកម្មការនេះបានដំណើរការនៅក្នុងឃុំ និងភូមិនៅព្រះរាជាណាចក្រកម្ពុជា ហើយដើរតួនាទីជាយន្តការដ៏សំខាន់សម្រាប់ការធានាដល់ការទាក់ទិនដោយផ្ទាល់របស់គ្រួសារក្រីក្រនៅតាមជនបទ។ ក្នុងការស្វែងរកសេចក្តីត្រូវការបន្ទាន់បំផុតនៅតាមភូមិ ឃុំ ក្នុងការសម្រេចធ្វើគម្រោងដំណើរគម្រោង និងគាំទ្រគម្រោងព្រមទាំងក្នុងការផ្តល់កម្លាំង និងសម្ភារៈសម្រាប់អនុវត្តគម្រោង។

ក្នុងឆន្ទៈនេះដែរ រាជរដ្ឋាភិបាលនឹងកំពុងបន្តគោលនយោបាយវិមជ្ឈការជាងមួយអាណត្តិកន្លងមក ហើយដើម្បីអោយអាជ្ញាធរភូមិ ឃុំ មានសិទ្ធិសម្រេចបានច្រើនជាងមុនក្នុងការអភិវឌ្ឍន៍ភូមិ ឃុំ របស់ពួកគេ។

ទី៦-ក្នុងការប្រឈមនឹងភាពក្រីក្រ ភាពគ្មានដី ការបាត់បង់ដីធ្លី និងបណ្តាកាន់កាប់ដីធ្លី ដែលជាបញ្ហាដ៏ស្មុគស្មាញមួយ។ ដោយមើលឃើញនៅបញ្ហានេះ ទើបរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ភូមិបានថ្មីមួយ

---

[១៤៣] វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ការអភិវឌ្ឍន៍ដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចនៅកម្ពុជា ឆ្នាំ២០០២ ទំព័រទី២២២

ដោយផ្តោតចិត្តទុកដាក់ដល់ការវិនិយោគ តាមរយៈផ្តល់កម្មសិទ្ធិស្របច្បាប់លើដីធ្លីជាបញ្ហាមួយយ៉ាងសំខាន់សម្រាប់រាល់គ្រួសារទាំងឡាយ។ ច្បាប់ភូមិបាលថ្មីនេះអាចនឹងមានលទ្ធភាពជាវិជ្ជមានក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ទន្ទឹមនឹងពេលដែលការចុះបញ្ជីកម្មសិទ្ធិដីធ្លី និងលទ្ធភាពប្រើប្រាស់ដីធ្លីនៅតែជាបញ្ហាសំខាន់សម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍ ការការពារធនធានធម្មជាតិដែលមានស្រាប់ និងការធានានិរន្តរភាពនៃការប្រើប្រាស់ធនធានទាំងនេះ។ ដូច្នេះ រាជរដ្ឋាភិបាលបាននឹងកំពុងបោះជំហានយ៉ាងត្រឹមត្រូវក្នុងបញ្ហានេះក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋទូទាំងប្រទេស។

ទី៧- នយោបាយរដ្ឋាភិបាលកម្ពុជា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក បានធ្វើការអភិវឌ្ឍន៍ដោយបានកសាងផ្លូវលំតាមជនបទ ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ និងការផ្តល់ប្រភពទឹកក្នុងការចូលរួមចំណែក ដើម្បីបង្កើនលទ្ធភាពរបស់ប្រជាពលរដ្ឋ ការប្រើប្រាស់ទីផ្សារ និងសេវាសាធារណៈ និងបានចូលរួមចំណែកផងដែរ ក្នុងការលើកតម្កើនសុខភាពសាធារណៈ។ ជាងនេះទៅទៀត ផ្នែកសន្តិសុខ សន្តិភាព និងការអភិវឌ្ឍន៍តាមតំបន់ព្រំដែន គឺមានសារៈសំខាន់ចាំបាច់ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ដាច់ស្រយាល ហើយក៏ជាការចូលរួមចំណែកមួយសម្រាប់ប្រទេសជាតិ គឺការពារបូរណភាពទឹកដីស្របតាមរដ្ឋធម្មនុញ្ញដែលបានចែង។

សរុបសេចក្តីមក ចំណុចទាំងប៉ុន្មានដែលបានការរៀបរាប់ខាងលើ អាចសន្និដ្ឋានបានថា រាជរដ្ឋាភិបាលបានកំពុងបោះជំហានទៅមុខយ៉ាងត្រឹមត្រូវសំដៅលើការចំណាយសម្រាប់ផ្នែកសេដ្ឋកិច្ច និងសង្គមសម្រាប់លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការស្តារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធតាមជនបទ និងសេវាសាធារណៈ។ ហើយការលើកកម្ពស់សមត្ថភាពរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ផែនការ និងយុទ្ធសាស្ត្រនៅក្នុងផែនការសង្គមកិច្ច គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅនឹងសន្តិភាព សន្តិសុខ និងស្ថេរភាព នយោបាយនៅទូទាំងប្រទេសផងដែរ។

ក.២-ការរៀបចំអភិវឌ្ឍន៍ផែនការកាត់បន្ថយភាពក្រីក្រ

ផែនការកាត់បន្ថយភាពក្រីក្រ គឺជាទិសដៅយ៉ាងសំខាន់ និងត្រូវអភិវឌ្ឍន៍ក្នុងរយៈពេលវែងមួយសម្រាប់រាជរដ្ឋាភិបាល។ ក្នុងការកាត់បន្ថយភាពក្រីក្រនេះ គឺជាបញ្ហាស្មុលផងដែរ នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងកម្មវិធីវិនិយោគសាធារណៈ ហើយជាសកម្មភាពដែលបានកំណត់ទៅវិស័យនានានៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយផ្តោតយកចិត្តទុកដាក់ពិសេសនៅជនបទ។ បើតាមការសិក្សាស្រាវជ្រាវបានអោយដឹងថា ការកើនឡើងខ្ពស់នៃភាពក្រីក្រត្រូវបានរកឃើញនៅតាមតំបន់ដាច់ស្រយាល។ ដូច្នេះ ដើម្បីកាត់បន្ថយភាពក្រីក្រនោះ គឺត្រូវបង្កើនល្បឿន ការអភិវឌ្ឍន៍នៅជនបទប្រកបដោយចីរភាព គឺជាបញ្ហាសំខាន់ហើយយុទ្ធសាស្ត្រអភិវឌ្ឍន៍នៅជនបទរបស់រាជរដ្ឋាភិបាលត្រូវផ្តោតទៅលើ: ១-ជាពិសេសផ្តោតទៅលើក្រុមនុស្សខ្សត់ និងអ្នកពនេចរ។ ២-ពង្រីក និងបង្កើនកិច្ចដំណើរការចូលរួមសម្រាប់ស្វែងយល់ក្នុងការបង្កើតដំណោះស្រាយផ្សេងៗ ដោយមានការចូលរួមផ្ទាល់ពីប្រជាជនលើសកម្មភាពកែលម្អ និងអភិវឌ្ឍន៍របស់គាត់ផ្ទាល់។ ៣-ការបញ្ចូលគ្នាទាំងសេដ្ឋកិច្ច

និងសង្គមកិច្ចនៅក្នុងទម្រង់សមាហរណកម្មមួយ ដែលមានទីតាំងគ្របដណ្តប់ និងពហុវិស័យ ការចូលរួមពិចារណាកសាងផែនការពីក្រោមឡើងមកលើជាមួយ និងវិឆ្ជការរូបនីយកម្មនៃការរៀបចំ និងការខិតខំប្រឹងប្រែងគ្រប់គ្រងការអភិវឌ្ឍន៍។

ទិសដៅនៃគោលនយោបាយរាជរដ្ឋាភិបាល គឺបង្កើនល្បឿន និងណែនាំការអភិវឌ្ឍន៍ជនបទដោយធានាអោយគ្រប់ស្ថាប័នជាតិ និងអន្តរជាតិបានចូលរួមយ៉ាងជិតស្និទ្ធទាំងអស់គ្នាក្នុងការអភិវឌ្ឍន៍នៅជនបទបង្កើនចំនួនមនុស្សដែលមានការណែនាំ យើងបានបញ្ចូលវិធីសាស្ត្រទៅក្នុងការអភិវឌ្ឍន៍ជនបទ។ ហើយចំណុចសំខាន់នៃយុទ្ធសាស្ត្រ គឺត្រូវតម្រង់ទិសដៅទៅរកការសម្រាលបញ្ហាសេដ្ឋកិច្ច និងសន្តិភាពនៅគ្រប់ទីកន្លែង។ ប៉ុន្តែដោយសារកង្វះខាតប្រភពធនធាននោះបានតម្រូវផ្តល់អាទិភាពជាចម្បង ទៅលើចំណុចគោលដៅមួយចំនួនដែលបានជ្រើសរើសដោយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ។ វិស័យកសិកម្ម ដែលបានរៀបចំនៅក្នុងឯកសារកម្មវិធីវិនិយោគសាធារណៈ "ក.វ.ស" នេះបានបង្ហាញពីផែនការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតផ្នែកហិរញ្ញវត្ថុមួយ ដែលមានប្រសិទ្ធភាព និងគាំទ្រអភិវឌ្ឍន៍ជនបទ។ បន្ថែមពីលើសកម្មភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងអង្គការក្រៅរដ្ឋាភិបាលនោះ មូលនិធិសង្គមក៏ជាប្រភពមួយយ៉ាងសំខាន់នៃហិរញ្ញប្បទានជនបទ។ មូលនិធិសង្គម បានយកចិត្តទុកដាក់លើការស្តារហេដ្ឋារចនាសម្ព័ន្ធតាមជនបទ ដែលកំពុងធ្វើអោយសមត្ថភាពអនុវត្តន៍របស់មូលដ្ឋាននៅខ្សោយ។ មូលនិធិនេះបានទ្រទ្រង់ដល់ការស្តារហេដ្ឋារចនាសម្ព័ន្ធជនបទសំខាន់ៗតាមរយៈការស្តារកក្នុងកម្រិតតិចតួចឆាប់រហ័សខិតខំកសាងឡើងវិញ តាមការសន្មត់ដោយផ្តោតទៅរកការការងារនៅជនបទ ហើយនឹងអនុវត្តដោយសហគមន៍ផ្ទាល់។ មូលនិធិសង្គម គឺជាការចំណាយហិរញ្ញវត្ថុ និងឧបត្ថម្ភបច្ចេកទេសអោយដល់គម្រោងកម្រិតតូចដោយអនុម័តដោយសហគមន៍នៅជនបទសម្រាប់កសាងសាលាបឋមសិក្សា សាលាក្រោយមធ្យមសិក្សា និងសម្រាប់សេវាកម្ម សុខភាពជនបទ។ អាទិភាពក្នុង "ក.វ.ស" សម្រាប់ការអភិវឌ្ឍន៍ជនបទ គឺជាវិនិយោគផ្លូវថ្នល់ផ្គត់ផ្គង់ទឹកស្អាត អប់រំ សុខាភិបាល បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ ឥណទានជនបទ និងការកសាងសមត្ថភាព។

ការសម្របសម្រួល និងរៀបចំហេដ្ឋរចនាសម្ព័ន្ធគ្រប់គ្រងការអភិវឌ្ឍន៍ជនបទ ស្ថិតក្នុងសមត្ថកិច្ចក្រសួងអភិវឌ្ឍន៍ ខេត្ត ស្រុក ឃុំ ភូមិ គឺជាហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ ដែលរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ នោះត្រូវបានបញ្ចូលជាមួយនឹងគោលដៅជំរុញការអនុវត្តតាមបែបវិមជ្ឈការ ក្នុងការកសាងផែនការអភិវឌ្ឍន៍ជនបទ ការងារហិរញ្ញវត្ថុ ទាំងផែនការអនុវត្តន៍។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទភូមិប្រមាណជា ៧៥០០ភូមិ ដែលគ្របដណ្តប់ ៦៩% នៃភូមិទាំងអស់នឹងត្រូវបានបង្កើតឡើងនាចុងឆ្នាំ២០០០ ដោយផ្តល់ធនធាន(ទុន) ដោយការបណ្តុះបណ្តាលប្រជាជននៅក្នុងមូលដ្ឋាននោះហើយ និងសម្រាប់ពង្រឹកកម្លាំងពលកម្មដើម្បីទ្រទ្រង់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទភូមិ។ សព្វថ្ងៃគណៈកម្មការអភិវឌ្ឍន៍ខេត្ត និងឃុំត្រូវបានតែងតាំងដើម្បីអនុវត្តការងារជាមួយកិច្ចការរដ្ឋអំណាចមូលដ្ឋាន។ ប៉ុន្តែគណៈកម្មាធិការអភិវឌ្ឍន៍ភូមិត្រូវបានបោះឆ្នោតជ្រើសរើសជាលក្ខណៈប្រជាធិបតេយ្យ តាមរយៈប្រជាជនរស់នៅក្នុងភូមិនោះ ដែលនេះ គឺជាការងារបង្កើតការ

ចូលរួមថ្មីនៃហេដ្ឋារចនាសម្ព័ន្ធក្នុងការអភិវឌ្ឍន៍ជនបទ និងជាមូលដ្ឋានសម្រាប់សម្រេចជោគជ័យដោយនិរន្តរ-ភាពនៃដំណើរការអភិវឌ្ឍន៍។ សកម្មភាពរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ គឺធានាអោយមានការចូលរួមដោយផ្ទាល់ពីក្រុមគ្រួសារនៅជនបទក្នុងការស្វែងយល់ពីសេចក្តីត្រូវការរបស់ភូមិ សម្រាប់ការងាររៀបចំគម្រោងការចូលរួម ពលកម្មសំភារៈសម្រាប់អនុវត្តគម្រោង ហើយនឹងដំណើរការថែទាំងសមិទ្ធផលវិនិយោគសាធារណៈបន្ទាប់ពីបានបញ្ចប់ការងារ។ ទំនាក់ទំនងជាគន្លឹះរបស់បណ្តាស្ថាប័ន៣ក់ព័ន្ធ ដែលរួមមានក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កសិកម្មក្នុងការសម្របសម្រួលការប្រមូលទិន្នន័យ និងការធ្វើការវិភាគនោះបានផ្តល់ការប្រជុំមួយសម្រាប់ដោះស្រាយបញ្ហា និងកំណត់អាទិភាពហើយ និងសម្រួលការអនុវត្តន៍គម្រោងនៅក្នុងបញ្ហាគន្លឹះទាំងពីរនេះ។ ភ្ជាប់ជាមួយនឹងក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កសិកម្មជនបទនោះ គណៈកម្មការឥណទានអភិវឌ្ឍន៍ជនបទ ដែលបានយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើការអភិវឌ្ឍន៍ការគ្រប់គ្រង និងសម្របសម្រួលសកម្មភាព ឥណទានជនបទជាមួយ និងការសម្របសម្រួលដែលកំពុងអនុវត្តន៍ដោយគណៈកម្មការដឹកនាំការងារសិលា។

ក.៣-ដំណើរសកម្មភាពចូលរួមកាត់បន្ថយភាពក្រីក្រ

ការកត់បន្ថយភាពក្រីក្រ គឺត្រូវឈរលើការអភិវឌ្ឍន៍ជាពហុវិស័យរួមាន:

ក.៣.១-សេវាកម្មសហគមន៍ និងសង្គមកិច្ច យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលចំពោះក្រុមការងាររងគ្រោះ គឺការបែងចែកការចំណាយរបស់រដ្ឋឡើងវិញទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច ពិសេសក្នុងតំបន់ជនបទ ដោយរួមជាមួយការទ្រទ្រង់យ៉ាងសកម្មដល់ការបង្កើតការងារអោយធ្វើ និងបណ្តុះបណ្តាលមុខរបរ។ មូលហេតុ ដោយសារពើរពន្ធសម្រាប់ការទ្រទ្រង់សេវាកម្មសង្គមមាននៅមានកម្រិត នោះរដ្ឋាភិបាលអនុវត្តយុទ្ធសាស្ត្រអំពាវនាវអោយមានការចូលរួមពីអង្គការក្នុងស្រុក និងអន្តរជាតិ។ គួបផ្សំជាមួយនឹងជំនួយពីបរទេស រដ្ឋាភិបាលបានបន្តធ្វើការកែលម្អសមត្ថភាពរបស់ខ្លួន ដើម្បីស្វែងយល់ និងការរៀបចំយន្តការផ្តល់កិច្ចការពារក្រុមការងាររងគ្រោះ។ ការថយចុះនៃភាពគ្មានការងារធ្វើ គឺមានសារៈសំខាន់នៃការកាត់បន្ថយភាពក្រីក្រ ដែលក្នុងនេះផែនការដែលបានបង្កើតឡើង ដោយមានសមត្ថភាពផ្តល់អត្ថប្រយោជន៍ដល់ប្រព័ន្ធឥណទានជនបទអោយមានប្រសិទ្ធភាព និងនិរន្តរភាព ដែលនាំអោយមានសារៈសំខាន់ក្នុងការសម្របសម្រួល ដល់ការចាប់បង្កើតលទ្ធភាពមានការងារធ្វើអ្វីដែលអាចស្រូបយកពលករ ដែលគ្មានការងារធ្វើបន្ថែមទៀតពីមួយឆ្នាំទៅមួយឆ្នាំ។ ម្យ៉ាងវិញទៀត ធនធានបន្ថែមរបស់រដ្ឋាភិបាលសម្រាប់ចំណាយឧបត្ថម្ភ និងជំនួយដល់ផ្នែកសង្គមកិច្ចនឹងបានស្នើឡើងសម្រាប់ពេលខ្លះ ហើយធនធានទាំងនេះនឹងត្រូវបានប្រើប្រាស់យ៉ាងប្រុងប្រយ័ត្នក្នុងការធានាតម្រូវការសង្គមជាមូលដ្ឋាន ដែលភាគច្រើនសំដៅលើជនងាយរងគ្រោះ និងសមាជិកក្រីក្រក្នុងសង្គម។ គ្រួសារក្រីក្រ កុមារកំព្រា ក្មេង ដែលគេបោះបង់ចោល និងជនពេនចរនឹងត្រូវទទួលការយកចិត្តទុកដាក់ពិសេស។ អន្តរគមន៍ក្នុងការកសាងសមត្ថភាពរបស់បណ្តាក្រសួង និងស្ថាប័នទទួលខុសត្រូវចំពោះសង្គម និងសេវាកម្មសហគមន៍នឹងត្រូវបានរៀបចំឡើង ដើម្បីអោយការប្រើប្រាស់ជំនួយកាន់តែមានប្រសិទ្ធភាព ដល់ក្រុមជនងាយរងគ្រោះក្នុងទស្សនៈកាត់បន្ថយភាពងាយរងគ្រោះដល់ពួកគេ និងបង្កើតការចូលរួមរបស់ពួកគេក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ ដើម្បីសម្រួលដល់គំនិតផ្តើមលើគោលដៅ

កាត់បន្ថយភាពក្រីក្រ រដ្ឋាភិបាលបានអនុវត្តប្រព័ន្ធអង្កេតគ្រួសារចម្រុះជាបន្តបន្ទាប់ក្នុងន័យត្រួតពិនិត្យសន្ទស្សន៍ភាពក្រីក្រ និងផ្តល់ទិន្នន័យជាមូលដ្ឋានសម្រាប់បង្កើត និងអនុវត្តគោលនយោបាយប្រឆាំងភាពក្រីក្រ។ រដ្ឋាភិបាលបានប្តេជ្ញារក្សាយកការតាមដានពិនិត្យពីភាពក្រីក្រដោយទៀងទាត់ តាមរយៈអង្កេតគ្រួសារជាពហុគោលចម្បង។ បញ្ហាដែលទាក់ទងទៅនឹងកិច្ចការនេះដែរ គឺការកសាងស្ថាប័នអោយបានល្អប្រសើរសម្រាប់ភ្ជាប់ការវិភាគពីភាពក្រីក្រទៅនឹងការរៀបចំគោលនយោបាយ និងកំណត់អាទិភាពចំណាយសាធារណៈ។

ក.៣.២-ការដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បញ្ហាគ្រាប់មីនត្រូវបានគេរាប់បញ្ចូលជាអាទិភាពខ្ពស់បំផុតមួយនៅក្នុងការងារស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ពិសេសនៅក្នុងការឈានទៅរកសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រនៅជនបទ។ ផ្ទៃដីច្រើនលើសលប់ ដែលប៉ះពាល់ដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលជាឧបសគ្គយ៉ាងធំមួយរារាំងដល់កិច្ចអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងវិស័យដទៃទៀត។

ដូច្នេះ សកម្មភាពប្រឆាំងនឹងគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បានចូលរួមចំណែកយ៉ាងសំខាន់ និងយ៉ាងជាក់ស្តែងទៅនឹងការកាត់បន្ថយភាពក្រីក្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានផ្តល់នូវៈ ទី១-ការកាត់បន្ថយអត្រាគ្រោះថ្នាក់ ដែលដៈឥទ្ធិពលជាអវិជ្ជមាន ជាពិសេសដល់គ្រួសារជនរងគ្រោះ ទី២-ផ្តល់សហគមន៍ដែលរងនូវផលប៉ះពាល់ខ្លាំងមានលទ្ធភាពប្រើប្រាស់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ដូចជា ធនធានទឹក សាលារៀន មន្ទីរពេទ្យ និងផ្លូវថ្នល់... ទី៣-បែងចែកដីមានសុវត្ថិភាពសម្រាប់ការតាំងទីលំនៅ និងធ្វើស្រែចំការដើម្បីរួមចំណែកក្នុងការធ្វើសមាហរណកម្ម ក្នុងវិស័យសេដ្ឋកិច្ចជូនប្រជាជន ដែលខ្វះខាតដីនៅទីជនបទ ទី៤-ដាក់ផ្លាកសញ្ញាសម្គាល់ និងអប់រំប្រជាពលរដ្ឋនៅត្រង់តំបន់សង្ស័យថា មានមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ទី៥-កំណត់អាទិភាព និងបែងចែកដី ដែលដោះមីន ហើយដោយមានការចូលរួមចំណែកសមស្រប ប្រកបដោយសមធម៌ និងមានការគាំទ្រដល់ជនក្រីក្រនៅថ្នាក់មូលដ្ឋាន និងទី៦-ផ្តល់ការជ្រោមជ្រែងដល់ការធ្វើសមាហរណកម្ម និងការស្តារនីតិសម្បទាឡើងវិញ នៃជនពិការដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅសហគមន៍របស់ពួកគាត់។

ក.៣.៣-ការអភិវឌ្ឍន៍ធនធានមនុស្ស: ការចំណាយសរុបសម្រាប់ការបណ្តុះបណ្តាល និងការអប់រំ មានកម្រិតទាបជាងតម្រូវការចាំបាច់ក្នុងការស្តារ និងទំនើបភាវូបនីយកម្ម ការសិក្សារៀនសូត្រ និងបង្កើតអោយមានឯកទេសកម្មផ្នែកបច្ចេកទេសក្នុងការសិក្សា។ រីឯការបណ្តុះបណ្តាលទាំងនៅក្នុង និងក្រៅប្រទេស គឺបានជួយលើកកម្ពស់សមត្ថភាពជំនាញខាងគ្រប់គ្រងប្រព័ន្ធទីផ្សារសេរីនៅកម្ពុជា ជាពិសេសទៅលើផ្នែកអាជីវកម្ម និងសេដ្ឋកិច្ច និងលើវិស័យអភិវឌ្ឍន៍ផ្សេងៗទៀត ដើម្បីជាមូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រជាមួយគ្នានេះដែរ ការគៀងគរជំនួយពីបរទេសបានជួយផ្តល់នូវការពិគ្រោះយោបល់ក្នុងការរៀបចំគោលនយោបាយរបស់ក្រសួង ស្ថាប័នសំខាន់ ជាពិសេសស្ថាប័នសេដ្ឋកិច្ចក្នុងការបណ្តុះបណ្តាលដល់មន្ត្រីរាជការ នៃបណ្តាក្រសួងស្ថាប័នទាំងនោះ។ យ៉ាងណាមិញ កសាងសមត្ថភាព គឺជាការទាមទារអោយមានការបន្តធ្វើវិនិយោគ និងមានតួនាទីធ្វើអោយកំណើនសេដ្ឋកិច្ចមានលក្ខណៈរឹងមាំយូរអង្វែង ហើយការងារដំបូងបង្អស់នៃការអភិវឌ្ឍន៍ធនធានមនុស្ស គឺបង្កើនសមត្ថភាពជំនាញផ្នែកគ្រប់គ្រង ដើម្បីពង្រឹងការរៀបចំរចនាសម្ព័ន្ធសហគ្រាសឡើងវិញលើជំនាញ ខាង

ផ្នែកបូជា គណនេយ្យ សនវកម្ម ម៉ាយីតធីង សហគ្រិនឯកជន និងគ្រប់គ្រងសហគ្រាសសាធារណៈ។ល។ ការងារមួយទៀត ដែលមានសារៈសំខាន់ដែរនោះ គឺជាការលើកស្ទួយផលិតភាពពលកម្មតាមរយៈការកែលម្អគុណភាព និងលទ្ធភាពប្រើប្រាស់សេវាអប់រំ និងសុខភាពសាធារណៈ ដែលរដ្ឋាភិបាលចាំបាច់ត្រូវការចំណាយជាក់ស្តែងការកែលម្អលើវិស័យទាំងនោះដោយផ្តោតជាពិសេសនៅក្នុងខេត្ត និងស្រុក។

ក.៣.៤-ការកាត់បន្ថយកងទ័ព: ចំណាយលើការការពារជាតិ និងសន្តិសុខនឹងត្រូវកាត់បន្ថយ។ ជំនួយនឹងត្រូវបានអំពាវនាវរកដើម្បីទ្រទ្រង់ដល់ការកាត់បន្ថយកងទ័ពជាបន្ទាន់ ហើយនិងប្រើប្រាស់អតីតយោធិនដើម្បីជួយដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឡើងវិញ។ ទាំងកំណែទម្រង់ស៊ីវិល និងការកាត់បន្ថយកងទ័ពនឹងជួយសម្រាល់បន្ទុកដ៏ធ្ងន់ដល់ការចំណាយជាប្រចាំ ព្រមទាំងបង្កលក្ខណៈអោយមានការផ្ទេរសមាសភាគក្នុងការចំណាយថវិកាជាតិទៅអោយវិស័យសុខាភិបាល និងអប់រំបានច្រើនជាងមុនសំដៅធ្វើអោយចំណាយរបស់វិស័យទាំងពីរនេះមានកម្រិតប្រហាក់ប្រហែលនឹងបណ្តាលប្រទេសក្នុងតំបន់។

ក.៣.៥-ការកែទម្រង់ប្រព័ន្ធច្បាប់: រាជរដ្ឋាភិបាលបានយល់ច្បាស់ពីសារៈសំខាន់របស់ប្រព័ន្ធច្បាប់ និងតម្រូវការក្នុងការងាររបស់ស្ថាប័នានា។ តាមរយៈវិធានការថ្មីៗនេះរាជរដ្ឋាភិបាលនឹងបំពេញបន្ថែមពីលើសមិទ្ធិផលគតិយុត្ត ដែលសម្រេចបានកន្លងមក ដោយមានបញ្ចូលកម្មវិធីតាក់តែងច្បាប់ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធនៃស្ថាប័នដែលកំពុងអនុវត្តអោយមានប្រសិទ្ធភាព និងយកចិត្តទុកដាក់ជាចម្បងលើកិច្ចការអនុវត្តន៍។ ចំពោះបញ្ហានេះអន្តរាគមន៍ចម្បងរបស់រដ្ឋាភិបាលគឺផ្តោតលើការយកចិត្តទុកដាក់តាក់តែងនិងអនុវត្តច្បាប់ ពង្រឹងសមត្ថភាពដោះ-ស្រាយវិវាទដោយមានប្រសិទ្ធភាព ព្រមទាំងសង្កត់ធ្ងន់លើការសម្របសម្រួលអោយមានចំណាយចិតបំផុតកក្នុងចម្លងការនានា តាមរយៈការកែលម្អដោយផ្អែកលើប្រភពព័ត៌មាន ដែលអាចរកបាន។ ការគួបផ្សំកំណែទម្រង់ច្បាប់ លិខិតបទដ្ឋាន ទៅនឹងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជា ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ គន្លឹះ និងជួយជំរុញដល់ការអភិវឌ្ឍន៍របស់ផ្នែកឯកជន។ ក្រោមការកែទម្រង់តុលាការ នោះមានការចាប់ផ្តើមសំខាន់ៗ ដែលរួមមាន ការបំពេញក្របខ័ណ្ឌ ច្បាប់ស្តារសាលាកាត់ក្តី ពង្រឹងយន្តការ និងលើកទឹកចិត្ត ដល់បុគ្គលិក។ លើសពីនេះទៀត ត្រូវពង្រីកព័ត៌មានតុលាការកែលម្អហេដ្ឋារចនាម្ព័ន្ធ និងសម្ភារៈបន្ថែមទៀត។

ក.៣.៦- កំណែទម្រង់សារពើពន្ធ: ការកែលម្អស្ថានភាពថវិកាអាចនឹងសម្រេចទៅបានតាមរយៈវិធានការរួមមួយដែលក្នុងនោះមាន ការពង្រឹងការងារត្រួតពិនិត្យលើកម្រិតចំណាយរបស់រាជរដ្ឋាភិបាល និងវិធានការនានា ដើម្បីបង្កើនចំណូលដូចជាពន្ធលើតម្លៃបន្ថែមដែលបានចាប់ផ្តើមអនុវត្តនៅខែមករា ឆ្នាំ១៩៩៩មក។ ក្នុងការរកចំណូលបន្ថែមរាជរដ្ឋាភិបាលនឹងបន្តអនុវត្តវិធានការទាំងឡាយ ដែលនឹងត្រូវបានកំណត់ឡើង ដើម្បីឈានទៅបង្កើតអោយបាននូវមូលដ្ឋានចំណូលមួយដែលមានលំនឹង និងមានចីរភាពជាងមុន។ ការពឹងផ្អែកលើពន្ធនាំចូលនឹងត្រូវបានកាត់បន្ថយជាជំហានៗ ដើម្បីលើកទឹកចិត្តដល់ការពង្រីពាណិជ្ជកម្មទំនាក់ទំនងក្នុងតំបន់ដែលជាផ្នែមួយនៃកំណែតម្រូវរចនាសម្ព័ន្ធ និងអោយសមជាសមាជិកមួយរបស់អាស៊ាន ដែលកម្ពុជាបានចូលក្នុងឆ្នាំ១៩៩៩។ ការធ្លាក់ចុះនៃចំណូលមកពីប្រភពខាងលើនេះ នឹងត្រូវទូទាត់បំពេញវិញដោយវិធានការសំខាន់ៗ

ធម្មជាតិ ដែលមានប្រសិទ្ធភាពជាងមុន ពិសេសលើធនធានព្រៃឈើ ធ្វើអោយចំណូលជាតិមានភាពល្អប្រសើរឡើង ដូចជា ការកើនឡើងនៃចំណូលថវិកាដែលប្រមូលបានមកពីការធ្វើអាជីវកម្ម ធនធានធម្មជាតិនានា ប្រកបដោយមានលក្ខណៈចីរភាព។

ក្នុងការរៀបចំរចនាសម្ព័ន្ធចំណាយថវិកាជាតិឡើងវិញ រាជរដ្ឋាភិបាលយល់ច្បាស់ពីភាពចាំបាច់នៃការកាត់បន្ថយនូវការចំណាយរបស់វិស័យទាំងឡាយ ដែលមិនបង្កគ្រោះថ្នាក់ដល់សមត្ថភាពផ្នែកសេដ្ឋកិច្ចជាតិ។ រដ្ឋាភិបាលនឹងធានាធ្វើអោយការថែទាំ និងការពង្រីហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមកិច្ច ស្ថិតក្នុងកម្រិតមួយដែលអាចទទួលយកបាន ក៏ដូចជាអោយសមស្របទៅនឹងសមត្ថភាពគ្រប់គ្រងដំណើរការកែទម្រង់របស់បណ្តាក្រសួង/ស្ថាប័នគន្លឹះ។ ក្នុងបញ្ហានេះ រាជរដ្ឋាភិបាលនឹងបង្កើនឡើងនូវគម្រោងការរកតម្លៃចំណាយមកវិញ និងគម្រោងការចូលរួមផ្នែកហិរញ្ញវត្ថុ ដើម្បីបំពេញអោយបានទាំងស្រុង ឬមួយផ្នែកណានោះ នៃចំណាយរបស់សេវាកម្មសាធារណៈនានា។ បន្ថែមពីលើនេះការសន្សំក្នុងកម្រិតមួយសមរម្យនឹងអាចធ្វើបានតាមរយៈនៃការបញ្ចប់ជោគជ័យ នៃការកាត់បន្ថយកងទ័ព និងកំណែទម្រង់រដ្ឋបាលស៊ីវិល។ ទោះជាយ៉ាងណាក៏ដោយសម្រាប់រយៈពេលខ្លី ការសន្សំអាចធ្វើបានដោយមានកម្រិតពីព្រោះ រដ្ឋបានត្រូវចំណាយប្រាក់បំណាច់ ដែលត្រូវបានទទួលក្រោយពេលឈប់ធ្វើការ និងត្រូវចំណាយលើការបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល ក៏ដូចជាយោធិនវិសាយ។

ក.៣.៧-កំណែទម្រង់សហគ្រាសសាធារណៈ : ឯកជនភាវូបនីយកម្ម និងការកែលម្អកិច្ចដំណើរការរបស់សហគ្រាសរដ្ឋនៅតែជាការងារមួយជាអាទិភាពរបស់រាជរដ្ឋាភិបាល។ សហគ្រាសរដ្ឋ ដែលកំពុងដំណើរការ និងមិនត្រូវបានកំណត់អោយបង់ចំណូលថវិកាជាតិទៀតទេ ហើយក៏គ្មានការដាក់កម្រិតលើចំនួនឥណទា ដែលត្រូវខ្ចីពីធនាគារពាណិជ្ជកម្មដែរ។ ប៉ុន្តែការកែលម្អកិច្ចដំណើរការ និងការជួយសម្រួលអោយមានលទ្ធភាពប្រើប្រាស់មូលធនក្នុង និងក្រៅប្រទេស នោះមានសារៈសំខាន់សម្រាប់កំណែទម្រង់ផ្នែកសហគ្រាសសាធារណៈ។ តទៅថ្ងៃមុខរាជរដ្ឋាភិបាលនឹងធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ដែលនៅសល់ ហើយគ្រោងនឹងធ្វើឯកជនភាវូបនីយកម្មចំការកៅស៊ូរដ្ឋជាដំហានដំបូងនៅក្នុងឆ្នាំ២០០៩។ ការងារទាំងនេះនឹងបង្កលក្ខណៈអោយមានការសន្សំក្នុងសកម្មភាពផលិតកម្មលុបបំបាត់ឧបសគ្គនានា ដែលរារាំងមិនអោយមនាទីផ្សារ ដែលមានលក្ខណៈប្រណាំងប្រជែង ការទាក់ទាញវិនិយោគ ព្រមទាំងការលើកទឹកចិត្តអោយមានកិច្ចដំណើរការប្រកបដោយប្រសិទ្ធភាពទីផ្សារ។

ក.៣.៨-កំណែទម្រង់ផ្នែកហិរញ្ញវត្ថុ: គោលដៅចម្បងបំផុតនៃកំណែទម្រង់នេះ គឺត្រូវតែពង្រឹងនៅធនាគារជាតិបន្ថែមទៀតដោយត្រូវធ្វើអោយកាន់តែប្រសើរឡើងវិញ នូវការគ្រប់គ្រងកិច្ចដំណើរការរបស់ធនាគារពាណិជ្ជកម្ម ដើម្បីបង្កលក្ខណៈអោយការសន្សំ និងការវិនិយោគក្នុងស្ថានភាពមួយ ដែលអាជីវកម្មមានលក្ខណៈប្រណាំងប្រជែង។ ការកែលម្អកិច្ចដំណើរការប្រព័ន្ធធនាគារពាណិជ្ជកម្ម គឺមានសារៈសំខាន់សម្រាប់បង្កើនបរិយាកាសអោយមានកំណើនសេដ្ឋកិច្ច ដែលនាំមុខដោយផ្នែកឯកជនពិសេស គឺការវិនិយោគបរទេសផ្ទាល់។ រដ្ឋាភិបាលនឹងបង្កើតអោយមានច្បាប់ និងអនុវត្តច្បាប់ស្តីពីការធ្វើធនាគារ និងស្ថាប័នហិរញ្ញវត្ថុ។ ទន្ទឹមនេះ រាជ-រដ្ឋាភិបាលនឹងស្វែងរកជំនួយបន្ថែមទៀត ដើម្បីពង្រឹងដល់ការគ្រប់គ្រងត្រួតពិនិត្យរបស់ធនាគារជាតិលើធនាគារ

ពាណិជ្ជកម្ម ដើម្បីកែលម្អបែបបទនៃការអោយខ្ចីប្រាក់ ក៏ដូចជា វិភាគអំពីកម្រិតគ្រោះថ្នាក់របស់ឥណទាន និងការសងបំណុល។ ធនាគារជាតិនឹងសម្រេចបាននូវការដកខ្លួនចេញពីការងារធនាគារពាណិជ្ជកម្មជាមួយនឹងការធ្វើឯកជនភាវូបនីយកម្ម ធនាគារពាណិជ្ជកម្មក្រៅប្រទេស។ ការប្រុងប្រយ័ត្ននឹងត្រូវផ្តល់អោយទៅការចាប់ផ្តើមប្រើប្រាស់ឧបករណ៍អន្តរការីផ្នែកហិរញ្ញវត្ថុថ្មី ដើម្បីជំរុញលើកទឹកចិត្តអោយមានការសន្សំជាតិ។ ដើម្បីបន្តជំរុញការអនុវត្ត "បដិដុល្លារូបនីយកម្ម" ក្នុងសេដ្ឋកិច្ចរាជរដ្ឋាភិបាល និងបន្តអនុវត្តគ្រប់វិធានការ ដើម្បីលើកកម្ពស់ផ្តល់ជំនឿទុកចិត្តលើប្រាក់រៀលដូចជា ការពង្រឹងបង្កលក្ខណៈអោយមានការកើនឡើងនូវការប្រើប្រាស់ប្រាក់រៀលផងដែរ។

ក.៣.៩-ការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍន៍ជានិរន្តរភាព: ការអភិវឌ្ឍន៍សកម្មភាពតាមរយៈការពង្រឹងស្ថាប័នរៀបចំរចនាសម្ព័ន្ធឡើងវិញ ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ការងារ គឺជាការងារយ៉ាងសំខាន់។ ក្រោមកិច្ចអភិវឌ្ឍន៍រដ្ឋបាល ដែលកំពុងដំណើរការនោះការកំណត់ផែនការសកម្មភាពដែលផ្តោតទៅលើការបោះឆ្នោតក្រុមប្រឹក្សាឃុំដែលនឹងត្រូវអនុវត្តនៅកំឡុង ក.វ.ស នេះ គឺជាការពង្រឹងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម។ ការចំណាយសម្រាប់ដំណើរការបោះឆ្នោត និងការបណ្តុះបណ្តាលលេខាធិការដ្ឋបាលឃុំមានតម្លៃប៉ាន់ស្មានប្រមាណជា ២០.៥លានដុល្លារ ដែលក្នុងនោះ ០.៥លានដុល្លារសម្រាប់បណ្តុះបណ្តាលមន្ត្រីផ្លូវការ។ ទុនវិនិយោគអាទិភាពខ្ពស់មួយចំនួនត្រូវបានកំណត់ ក្នុងកម្មវិធីសម្របសម្រួលជំនួយជំនឿនប្រជាជនសេវាកម្មពន្ធនៅតាមខេត្ត ការអភិវឌ្ឍន៍ផែនការស្តង់ដារសាងសង់ និងដីធ្លី និងការគ្រប់គ្រងទីក្រុង។ បន្ទាប់មកត្រូវបង្កើតការគ្រប់ដណ្តប់ដោយគោលនយោបាយអភិវឌ្ឍន៍ដីធ្លី និងការការពារទីតាំងធម្មជាតិ ដែលគម្រោមកំហែង ដោយភាពអនាធិបតេយ្យ។ ក្នុងទីក្រុងការរៀបចំផែនការសម្រាប់អភិវឌ្ឍន៍រាជធានីភ្នំពេញ ក្រុងព្រះសីហនុ ក្រុងសៀមរាប បង្កើតសេវាកម្មកត់ត្រាទ្រព្យសម្បត្តិ និងបញ្ហាសិទ្ធិដីធ្លី។ ដូចគ្នានេះដែរ ត្រូវបង្កើតសេវាកម្មផ្តល់ព័ត៌មានប្រព័ន្ធធរណីវិទ្យា និងឋានលេខាសាស្ត្រនៃផែនទី។

ក.៣.១០-សមាហរណកម្មតំបន់ និងពិភពលោក: ឬសគល់សេដ្ឋកិច្ចសម្រាប់តំបន់ទាំងមូលសម្រាប់សហប្រតិបត្តិការទូទៅ ហើយនឹងសមាហរណកម្មនោះជាមូលដ្ឋាន គឺមកពីកត្តា៤យ៉ាង: ទី១-ទីផ្សារកម្ពុជាតូចខ្លាំងអំណោយផល់ដល់ដំណើរការងារសកម្មភាពកក្នុងស្រុក ដែលអាចលុបបំបាត់ភាពក្រីក្រ។ ទី២-ប្រទេសកម្ពុជាមិនមានធនធានហិរញ្ញវត្ថុ ឬអ្នកជំនាញគ្រប់គ្រងទូទៅគ្រប់គ្រាន់ ដើម្បីប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួនប្រកបដោយភាពសុទិដ្ឋិនិយម។ ទី៣-ប្រទេសកម្ពុជាមានតម្រូវការបញ្ចូលបច្ចេកវិទ្យាទំនើប ដែលជំរុញអោយមានប្រសិទ្ធភាពការងារកើនឡើង និងជាឱកាសដ៏ទូលំទូលាយក្នុងជម្រើសរបស់អ្នកប្រើប្រាស់។ ទី៤-គ្មានប្រទេសណាមួយអាចផលិតបានគ្រប់មុខទំនិញ ដើម្បីទាញយកឧត្តមភាពបាននោះទេ តែគ្រប់ប្រទេសនឹងអាចទទួលបានផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការ និងការធ្វើពាណិជ្ជកម្មទៅវិញទៅមក។ ប្រទេសកម្ពុជាសមាជិកសកម្មមួយក្នុងសហប្រតិបត្តិការអនុតំបន់ទន្លេមេគង្គជាសមាជិកអាស៊ាន ហើយនិងបានចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហេតុនេះការងារដែលកំពុងយកចិត្តទុកដាក់ គឺអនុវត្តការកសាងសមត្ថភាព

ជាតិអោយស្របទៅនឹងសេដ្ឋកិច្ចត្រូវការ ហើយភាគច្រើនដែលត្រូវធ្វើក្នុងកំឡុងពេល ក.វ.ស នេះ គឺកែសម្រួលច្បាប់ក្នុងស្រុក និងនីតិវិធីពាណិជ្ជកម្ម ដើម្បីភ្ជាប់ខ្លួនទៅក្នុងបន្ទាត់ទូទៅកក្នុងអាស៊ាន។

ក.៣.១១-យុទ្ធសាស្ត្រសំខាន់នៃកម្មវិធីវិនិយោគសាធារណៈ រាជរដ្ឋាភិបាលទទួលស្គាល់ថា ការកំណត់នៅអាទិភាព និងការបែងចែកទុន ព្រមទាំងដំណើរការនៃការកំណត់ការវិភាគការងារ គឺជាផ្នែកទូទៅដ៏សំខាន់នៃដំណើរការកម្មវិធីវិនិយោគសាធារណៈ និងពិតជាជួយរួមចំណែកក្នុងនយោបាយកំណែទម្រង់រចនាសម្ព័ន្ធ ដែលកំពុងតែអនុវត្ត និងដែលបានគ្រោងទុក។ បើសិនជាគ្មានការបែងចែកទុកដ៏មានប្រសិទ្ធភាព និងអនុវត្តបណ្តាគម្រោងអាទិភាពរបស់កម្មវិធីវិនិយោគសាធារណៈទាន់ពេលវេលានោះទេ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចសំខាន់ៗនឹងត្រូវគាំងដំណើរការ។ បើកំណើនសេដ្ឋកិច្ចត្រូវធ្លាក់ចុះនោះតម្លៃនៃអន្តរកាល ដែលពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់ដែលកំពុងដំណើរការ និងដែលបានគ្រោងទុកនឹងមានកម្រិតខ្ពស់ជាមុន ហើយនឹងមានផលមិនល្អ ជាពិសេសចំពោះអ្នកក្រីក្រនៅទីជនបទ។ រាជរដ្ឋាភិបាលនឹងថែរក្សាហើយពង្រឹង ដំណើរការកម្មវិធីវិនិយោគសាធារណៈ ដើម្បីអោយការងារនេះនៅតែជាកម្លាំងជំនួយ និងចាំបាច់មួយនៃកម្មវិធីរួមរបស់កំណែទម្រង់។

ខ-យន្តការចាំបាច់ទី២ នៃការកាត់បន្ថយភាពក្រីក្រ

ការរីករាលដាលនៃភាពក្រីក្ររបស់កម្ពុជាកក្នុងបរិបទនៃសង្គ្រាមស៊ីវិលជាងពីរទសវត្ស និងទុក្ខវេទនា គឺជាបញ្ហាប្រឈមគន្លឹះមួយរបស់រាជរដ្ឋាភិបាល ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច គឺបានចាប់ផ្តើមជាមួយនឹងដំណើរការសន្មត់យ៉ាងមុតមាំថា "ការលុបបំបាត់ភាពក្រីក្រ" គឺជាទិសដៅតែមួយគត់ និងយូរអង្វែងរបស់រាជរដ្ឋាភិបាល ហើយការកាត់បន្ថយភាពក្រីក្រនេះទៀតសោត គឺជាការនាំមុខ និងជាស្នូលនៃផែនការអភិវឌ្ឍន៍នៅឆ្នាំបន្តបន្ទាប់ទៀត"។ ហេតុនេះ ដើម្បីលើកទិសដៅយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រទទួលបានជោគជ័យ គឺត្រូវឈរលើគោលការណ៍មួយចំនួនដូចតទៅ:

ការបង្កើតកាលានុវត្តភាព និងសន្តិសុខសង្គម: តាមរយៈការពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការពន្លឿនកំណើនសេដ្ឋកិច្ច ការជំរុញការអភិវឌ្ឍន៍វិស័យឯកជន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងផ្នែកថាមពល ការធានានូវការអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវវិស័យកសិកម្ម ការកែលម្អការគ្រប់គ្រងធនធានទឹក ការជំរុញការអភិវឌ្ឍន៍ជនបទមិជ្ឈការ ការធានានូវការគ្រប់គ្រងធនធានធម្មជាតិអោយបានល្អ ការលើកទឹកចិត្តបណ្តាសកម្មភាព ដែលបង្កើតប្រាក់ចំណូល ការអនុវត្តន៍គោលនយោបាយដីធ្លី និងការបង្កើនសេវាមីក្រូហិរញ្ញវត្ថុសម្រាប់ប្រជាជនក្រីក្រ។ ទោះបីជាបណ្តាកម្មវិធី ដែលាមនគោលដៅច្បាស់លាស់សម្រាប់តំបន់នៅជនបទអាចអោយផលយ៉ាងឆាប់រហ័ស ចំពោះប្រជាជនតាមជនបទក៏ដោយ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការអភិវឌ្ឍន៍នៃវិស័យឧស្សាហកម្ម និងសេវាកម្មផងដែរ។ យុទ្ធសាស្ត្ររបស់យើងគឺមិនត្រឹមតែធ្វើទំនើបការបូនីយកម្មប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវជំរុញការអភិវឌ្ឍន៍វិស័យសំខាន់ៗដទៃទៀត ដែលអាច

ក្លាយទៅជាក្បាលរទេះភ្លើងដ៏មានថាមពល ដើម្បីអូសទាញនាវាកម្ពុជាពីច្រវាក់ខ្នោះឃ្នាងនៃភាពក្រីក្រតោកយ៉ាកនេះ។

កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចដ៏ល្អប្រសើរ និងបានកាត់បន្ថយភាពក្រីក្រគួរអោយកត់សម្គាល់បំផុត។ សេដ្ឋកិច្ចមានកំណើនយ៉ាងខ្លាំងក្លានៅក្នុងទសវត្សកន្លងមកនេះ ជាពិសេសក្នុងរយៈកាលបួនឆ្នាំចុងក្រោយនេះ ដែលកំណើនស្ថិតក្នុងកម្រិត ១០% ជារៀងរាល់ឆ្នាំ។ ការអនុវត្តសេដ្ឋកិច្ចក្នុងឆ្នាំ២០០៧ បានប៉ាន់ស្មានថា មានកំណើន ៩,៦% ទោះបីជាកំណើននេះទាបជាងកំណើនក្នុងឆ្នាំ ២០០៥-២០០៦ក៏ដោយ ក៏កំណើននេះនៅតែមានភាពល្អប្រសើរ ដោយសារបង្ហាញថា សេដ្ឋកិច្ចយើងកាន់តែរឹងមាំឡើង ហើយការអនុវត្តន៍សេដ្ឋកិច្ចក្នុងឆ្នាំ ២០០៦-២០០៧ មិនមែនជារឿងហេងស៊ីយចៃដន្យទេ នេះឆ្លុះបញ្ចាំងជាមូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសមានភាពល្អប្រសើរ[១៤៤]។ដោយសារតែនិរន្តរភាពនៃកំណើនសេដ្ឋកិច្ចជាមួយនឹងការអភិវឌ្ឍន៍វិស័យកសិកម្មកាន់តែល្អ ភាពក្រីក្រអាចនឹងធ្លាក់ចុះយ៉ាងខ្លាំងពីអត្រា ៤% ចុងឆ្នាំ២០០៤។ ចាប់តាំងពីឆ្នាំ២០០៤មក គឺមិនទាន់មានការធ្វើអង្កេតទៀតទេ ប៉ុន្តែគេអាចប៉ាន់ប្រមាណបានថា អត្រានៃភាពក្រីក្រថយចុះ១១% ក្នុងមួយឆ្នាំ។ សម្រាប់ទសវត្សគិតត្រឹមឆ្នាំ២០០៧នេះ ផ.ស.ស ក្នុងមនុស្សបានកើតទ្វេដល់៥៨៩ដុល្លារ ហើយគួលេខនេះរំពឹងថានឹងឡើងដល់ ១០០ដុល្លារក្នុងឆ្នាំ២០១៥ ឬអាចលឿនជាងនេះផងនៅពេលដែលការផលិតប្រេងឧស្ម័នចាប់ផ្តើមដំណើរការ[១៤៥]។

យុទ្ធសាស្ត្រជាបឋម គឺការបន្ត និងពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយភាពប្រុងប្រយ័ត្នគួបផ្សំជាមួយនឹងការបើកចំហរសេដ្ឋកិច្ច និងការតម្រង់ទិសទៅរកទីផ្សារ។ កម្ពុជាត្រូវបន្តដំណើររបស់ខ្លួនក្នុងការធ្វើសមាហរណកម្មស៊ីជម្រៅជាមួយសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក និងបន្តមាគ៌ាសេដ្ឋកិច្ច ដែលផ្តោតលើការពង្រីកទំនាក់ទំនងសេដ្ឋកិច្ច ជាមួយក្រៅប្រទេស ព្រមទាំងបន្តអនុវត្តគោលនយោបាយសេដ្ឋកិច្ចហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលឈរលើមូលដ្ឋានទីផ្សារ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវគោលនយោបាយអត្រាប្តូរប្រាក់ ដែលផ្អែកលើទីផ្សារ និងប្រព័ន្ធអត្រាការប្តូរប្រាក់សេរី។ យើងនឹងបន្តការកែទម្រង់ពាណិជ្ជកម្មនៅក្នុងបរិការណ៍ នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។ រាជរដ្ឋាភិបាលផ្តោតកិច្ចខិតខំប្រឹងប្រែងជាសំខាន់លើការពង្រឹងស្ថាប័ន ដើម្បីធានាបរិស្ថានម៉ាក្រូសេដ្ឋកិច្ចមួយ ដែលមានស្ថេរភាពក្នុងគោលដៅបង្កើនសេដ្ឋកិច្ច។

គោលដៅសេដ្ឋកិច្ចរបស់ខ្លួន រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនកំណើនសេដ្ឋកិច្ចាប់ពី ៦% ទៅ ៧% ក្នុងរយៈពេលមធ្យមដោយរក្សាអតិផរណាក្នុងកម្រិតក្រោម ៤% រក្សាឱនភាពគណនីចរន្តក្រៅប្រទេសក្នុងកម្រិតមួយ ដែលមានចីរភាព និងទៅលើការគ្រប់គ្រងដោយហ្មត់ចង់នូវបំណុលក្រៅប្រទេស។ ដើម្បីសម្រេចអោយបាននូវគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តកំណែទម្រង់សារពើពន្ធជាមូលដ្ឋាន ដែលសំដៅ

[១៤៤] សុន្ទរកថា សម្តេចតេជោ ហ៊ុន សែន នៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ សណ្ឋាគារភ្នំពេញ ២៨ កុម្ភៈ ២០០៨

[១៤៥] សុន្ទរកថា សម្តេចតេជោ ហ៊ុន សែន នៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ សណ្ឋាគារភ្នំពេញ ២៨ កុម្ភៈ ២០០៨

បង្កើនចំណូលការកែលម្អនៅបែបផែន និងប្រសិទ្ធភាពនៃចំណាយថវិកា។ ចំណុចសំខាន់ៗនៃកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធ គឺពង្រឹងការគ្រប់គ្រងធនធានសាធារណៈ និងព្រៃឈើ កែលម្អរដ្ឋបាលពន្ធដារអនុវត្តកំណែទម្រង់រដ្ឋបាល និងយោធា ជំរុញការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការអភិវឌ្ឍន៍ផ្នែកឯកជន និងកំណែទម្រង់ពាណិជ្ជកម្ម រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តក្នុងការពិនិត្យឡើងវិញ នូវក្របខ័ណ្ឌគោលនយោបាយសារពើពន្ធក្នុងគោលដៅបង្កើនចំណូលថវិកាពង្រឹងការប្រមូលពន្ធ និងធានាបាននូវសមធម៌ និងលុបបំបាត់នូវឧបសគ្គ ដែលបន្ទុចបង្អងាក់ការវិនិយោគឯកជន។ ប្រការនេះទាមទារអោយមានការអភិវឌ្ឍន៍នូវក្របខ័ណ្ឌពន្ធដារមួយដ៏ទំនើប និងនីតិវិធីប្រកបដោយតម្លាភាពសម្រាប់គ្រប់គ្រងការធ្វើសម្បទានធនធានធម្មជាតិ ដោយរួមមានការដីកយកវ៉ែប្រែងកាត និងការធ្វើអាជីវកម្មព្រៃឈើ ដើម្បីកែលម្អ និងធានានូវការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ចីរភាព និងគណនេយ្យភាពបង្កើនចំណូលថវិកា។

ជាការពិតក្នុងរយៈពេលកន្លងមកនេះ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រយ័ត្នប្រយែង ពិសេស គឺ គោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ននឹងគោលនយោបាយថវិកា (ទាំងខាងចំណូល ទាំងខាងចំណាយ) ដែលផ្តោតទៅលើការដោះស្រាយភាពក្រីក្រជំរុញផលិតកម្ម និងកំណើនដែលក្នុងនោះវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ គឺជាអាទិភាពខ្ពស់បំផុតមួយ។ ក៏ប៉ុន្តែស្ថានភាពសេដ្ឋកិច្ចពិភពលោក និងតំបន់ និងកំណើនដ៏លឿន(ក្នុងតួលេខ ២ខ្ទង់) ក្នុងរយៈពេល ៤ឆ្នាំ ចុងក្រោយនេះបានបណ្តាលអោយមានសីតុណ្ហភាពនៃសេដ្ឋកិច្ចជាតិមានការកើនឡើង។

វិធានការជាក់ស្តែង ដែលបានដាក់ចេញកន្លងមកនៅក្នុងទិសដៅជានាកុំអោយកំដៅនៃសេដ្ឋកិច្ចជាតិកើនឡើង ហួសកម្រិតក្រៅពីគោលនយោបាយគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ន ដូចបានគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាក់ស្តែងជាបន្តបន្ទាប់ សំដៅលើកស្ទួយជីវភាពរបស់ប្រជាជននិងកាត់បន្ថយល្បឿនអតិផរណាជាពិសេសការឡើងថ្លៃទំនិញប្រើប្រាស់ជាមូលដ្ឋានមួយចំនួនដូចជាប្រេងឥន្ធនៈ ថាមពលអគ្គីសនី និងម្ហូបអាហារជាដើម។ វិធានការទាំងនោះរួមមាន:

-តម្លើងបៀវត្សមូលដ្ឋាន ២០% នៅក្នុងឆ្នាម២០០៨ ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិវត្តន៍ជន។

-តម្លើងប្រាក់ឧបត្ថម្ភប្រចាំខែ ១០០% ជូនប្រពន្ធ/ប្តី និងកូនរបស់មន្ត្រីរាជការស៊ីវិល កងយោធពល-ខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តន៍ជន មន្ត្រីបាត់បង់សមត្ថភាព និងយុទ្ធជនពិការ និងតម្លើងប្រាក់បំណាច់មុខងារបង្រៀនរបស់គ្រូបង្រៀនចំនួន ១០% ចាប់ពីខែមេសា ឆ្នាំ២០០៨ទៅ។

-រាជរដ្ឋាភិបាលបានរៀបចំសម្រួលលំហូរសាច់ប្រាក់ជូនវិនិយោគិននៅក្នុងវិស័យកាត់ដេរ តាមរយៈការព្យួរការអនុវត្តន៍ពន្ធអប្បបរមា ១% រយៈពេល ៣ឆ្នាំ ពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១០ ដើម្បីតម្លើងប្រាក់ខែជូនដល់កម្មកររនៅក្នុងវិស័យកាត់ដេរចំនួន ៦ដុល្លារអាមេរិក បន្ថែមទៀតលើប្រាក់ខែ អប្បបរមា ៥០ដុល្លារអាមេរិកក្នុងមួយខែ។

-រាជរដ្ឋាភិបាលបានផ្តល់ការឧបត្ថម្ភធនយ៉ាងស្ងៀមស្ងាត់ទៅលើការនាំចូលប្រេងឥន្ធនៈ ដោយឈរលើតម្លៃមូលដ្ឋានគិតពន្ធដារ។ តាមរយៈនេះដែរ រាជរដ្ឋាភិបាលបានឧបត្ថម្ភធនចំនួន ជិត ១៨០លានដុល្លារអាមេរិក នៅឆ្នាំ២០០៧ កន្លងទៅ ហើយបានឧបត្ថម្ភធនប្រមាណជាង ២០លានដុល្លារអាមេរិកក្នុងមួយខែនៅដើមឆ្នាំ ២០០៨នេះ។ គ្រាន់តែនៅត្រីមាសទីមួយឆ្នាំ២០០៨នេះ ទំហំនៃការឧបត្ថម្ភនេះបានឡើងដល់ជិត ៧០លានដុល្លារអាមេរិកទៅហើយ។ ប្រការនេះបានធ្វើអោយថ្លៃ ប្រេងឥន្ធនៈនៅកម្ពុជាមានកំណើនទាបជាងកំណើនថ្លៃប្រេងឥន្ធនៈនៅប្រទេសជិតខាង និងទៅលើទីផ្សារអន្តរជាតិ។ ជាក់ស្តែងឆ្នាំ ២០០៧ ថ្លៃប្រេងសាំងលក់រាយនៅកម្ពុជាបានកើនឡើងដល់ ១០,១% ទន្ទឹមនឹងថ្លៃប្រេងសាំងលក់រាយនៅវៀតណាមបានកើនឡើង ៤៣% ហើយថ្លៃប្រេងសាំងលក់រាយនៅប្រទេសថៃបានកើនឡើង ២៣,១%។ បច្ចុប្បន្នថ្លៃប្រេងសាំងលក់រាយនៅប្រទេសជិតខាងបានកើនឡើងជិតស្មើនឹងថ្លៃប្រេងសាំងលក់រាយនៅកម្ពុជាយើងដែរ។

-រាជរដ្ឋាភិបាលបានផ្តល់ការឧបត្ថម្ភធន **បណ្តោះអាសន្ន និងក្នុងរយៈពេលខ្លី** ដល់អគ្គីសនីកម្ពុជា លើការនាំចូលវត្ថុធាតុដើមប្រេងឥន្ធនៈ និងពន្ធលើតម្លៃបន្ថែម។ ការឧបត្ថម្ភនេះត្រូវបានធ្វើឡើងក្នុងគោលបំណងធ្វើអោយតម្លៃអគ្គីសនីនៅភ្នំពេញស្ថិតក្នុងកម្រិតទាប ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជន និងសម្រួលដល់ការងារផលិតកម្ម។ នៅក្នុងឆ្នាំ១៩៩៩-២០០៧ នេះដែរ រាជរដ្ឋាភិបាលបានផ្តល់ការឧបត្ថម្ភនេះសរុបចំនួន ៣៨លានដុល្លារអាមេរិក គឺជិត ៥លានដុល្លារក្នុងមួយឆ្នាំ។ ដោយឡែកនៅឆ្នាំ២០០៨ នេះរាជរដ្ឋាភិបាលបានគ្រោងថវិកាជាតិចំនួន ៤១លានដុល្លារ អាមេរិកសម្រាប់ផ្តល់ឧបត្ថម្ភធនដល់វិស័យនេះ។

-រាជរដ្ឋាភិបាលបានណែនាំទៅគ្រប់ក្រសួង និងស្ថាប័នសាធារណៈទាំងអស់អនុវត្តការសន្សំសំចៃខ្ពស់ក្នុងការប្រើសប្រាស់ប្រេងឥន្ធនៈ និងថាមពលអគ្គីសនី។ នៅក្នុងឆ្នាំ២០០៨ ការប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់ដំណើរការរដ្ឋបាល គឺត្រូវបានកំណត់ត្រឹមឥណទាន ដែលបានចែងក្នុងច្បាប់ថវិកាតែប៉ុណ្ណោះ។ នៅឆ្នាំ២០០៧ ថវិកាសម្រាប់ប្រេងឥន្ធនៈមានចំនួន ១០៧.៨៣ន់លាន ឬប្រមាណ ២,២% នៃចំណាយថវិកាសរុប និងសម្រាប់ច្បាប់ថវិកាឆ្នាំ ២០០៨ ថវិកាសម្រាប់ប្រេងឥន្ធនៈចំនួន ១២២.៣៣ន់លានរៀល ឬប្រមាណ ២,១% នៃចំណាយថវិកាសរុប។

កំណើនសេដ្ឋកិច្ចមានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ព្រោះវាផ្តល់នូវកាលានុវត្តភាពក្នុងការបង្កើននៅចំណូល និងធនធាន ដើម្បីជាទុនសម្រាប់ផ្តល់ហិរញ្ញប្បទានដល់យន្តការកាត់បន្ថយភាពក្រីក្របានឆាប់រហ័ស។ ការបន្តអនុវត្តន៍កម្មវិធីកំណែទម្រង់បច្ចុប្បន្ន នឹងជួយបង្កើតលក្ខខ័ណ្ឌសម្រាប់បង្កើនប្រាក់សន្សំក្នុងស្រុក និងបង្កើនសកម្មភាពវិនិយោគឯកជនក្នុងស្រុក និងពីបរទេស ដើម្បីសម្រេចបាននូវគោលដៅ នៃកំណើន៧% ក្នុងទសវត្សខាងមុខ។ ប្រការនេះទាមទារអោយមានការរក្សានូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការបន្តកំណែទម្រង់ទីផ្សារ និងការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ច និងតម្រង់ទិសឆ្ពោះទៅខាងក្រៅប្រទេស។ វាក៏ទាមទារផងដែរ នូវការអភិវឌ្ឍន៍ស្ថាប័នសេដ្ឋកិច្ចសង្គម និងគោលនយោបាយអោយកាន់តែប្រសើរឡើង ដើម្បីទទួលបាននូវអភិបាលកិច្ចកាន់តែល្អថែមទៀតនៅកម្ពុជា។ បើតាមស្ថិតិនៃភាពក្រីក្រនៅកម្ពុជាក្នុងឆ្នាំ១៩៩៩

ប្រសិនបើយើងសម្រេចធ្វើបានអត្រាកំណើនពី ៦%ទៅ៧% ក្នុងមួយឆ្នាំ និងប្រសិនបើកំណើននោះត្រូវបានបែងចែកអោយសមធម៌នៅក្នុងចំណោមអ្នកក្រីក្រនោះ យើងត្រូវការពេលមិនដល់ប្រាំឆ្នាំឡើយសម្រាប់ទាញជនក្រីក្រជាមធ្យមអោយចាក់ផុតពីភាពក្រីក្រគោកយ៉ាក។ ប៉ុន្តែដើម្បីអោយជីវិតពលរដ្ឋក្រីក្របំផុត ដែលស្ថិតនៅក្រោមបន្ទាត់ក្រីក្រស្បៀងអាចចាកចេញពីភាពក្រីក្របាន គឺមានរយៈពេលលើសពី ១៥ឆ្នាំ ប្រសិនបើយើងសម្រេចបាននូវកំណើនក្នុងអាត្រា ៣% ក្នុងមួយឆ្នាំជាបន្តបន្ទាប់។ ដូច្នេះ យើងត្រូវដាក់ចេញនូវកម្មវិធីដែលមានគោលដៅអោយបានច្បាស់លាស់ ដើម្បីផ្តល់ផលចំណេញអោយជនកក្រីក្រនៅក្នុងទម្រង់នៃការពង្រឹងធនធានមនុស្ស និងធនធានរូបវន្ត និងតាមរយៈការធ្វើអន្តរាគមន៍ផ្សេងៗ(ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ) ដែលជួយបង្កើនផលចំណូលដែលគេទទួលបានពីធនធានទាំងនោះ។

ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្លាំង និងគោលនយោបាយសារពើពន្ធដោយឈរលើមូលដ្ឋានដ៏ទូលាយដែរ នោះបណ្តាលអោយសង្គមកិច្ចមានការកើនឡើងខ្លាំងជាពិសេសផ្នែកសុខាភិបាល និងផ្នែកអប់រំ។ ការអង្កេតប្រជារាស្ត្រ និងសុខភាពថ្នាក់ជាតិថ្មីបំផុតរកឃើញថា អត្រាស្លាប់របស់កុមារអាយុក្រោម ៥ឆ្នាំ បានធ្លាក់ចុះ ៣០% ក្នុងរវាងឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៤។ លើសពីនេះទៅទៀត កុមារខ្វះជីវជាតិអាយុក្រោម ៥ឆ្នាំ បានធ្លាក់ចាក់កណ្តាលក្នុងរយៈពេលដូចគ្នានោះ។ វឌ្ឍនភាពនេះត្រូវបានវាយតម្លៃថាល្អប្រសើរ បើប្រៀបធៀបទៅនឹងលទ្ធផលដែលប្រទេសកំពុងអភិវឌ្ឍន៍ជុំវិញពិភពលោកសម្រេចបាន។ នៅក្នុងវិស័យអប់រំវិញអត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតបឋមសិក្សាបានកើនឡើងយ៉ាងខ្លាំងពី ៦៥% ក្នុងមួយឆ្នាំ ២០០០ ដល់ ៦៧% ក្នុងឆ្នាំ២០០៤ និងលើសពី ៩០% ក្នុងឆ្នាំថ្មីៗនេះ។ អត្រាចូលរៀនពិតនៅកម្រិតមធ្យមសិក្សាបឋមភូមិ បានកើនឡើងទ្វេដងចាប់ពីឆ្នាំ១៩៩៧ គឺកើនពី៧,៦% ដល់ ១៦,៤% នៅឆ្នាំ២០០៤ និងរហូតដល់ជាង ៣០% ក្នុងកំឡុងពេល បីឆ្នាំចុងក្រោយនេះ[១៤៦]។ បន្ថែមពីនេះទៅទៀតសូចនាករសំខាន់ៗខ្លះដូចជា អក្ខរភាព អត្រាត្រួតថ្នាក់ និងចំនួនឆ្នាំកុមារបានចូលរៀនបានកើនឡើងជាវិជ្ជមានបន្ថែមទៀត។ នេះមានន័យថា ការកសាងប្រព័ន្ធអប់រំជាតិ កំពុងចាក់ឫសហើយ។

ជាពិសេស យើងបានសំឡឹងទៅមុខលើទស្សនវិស័យសេដ្ឋកិច្ច បានបន្តស្ថិតក្នុងស្ថានភាពល្អប្រសើរក្នុងឆ្នាំ២០០៨នេះ។ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថា អាចនឹងសម្រេចបានក្នុងអត្រា ៧,៣% សម្រាប់ឆ្នាំ ២០០៨។ គំនិតផ្តួចផ្តើមពីវិស័យឯកជន មានសកម្មភាពចូលរួមវឌ្ឍនភាពក្នុងការធ្វើកំណែទម្រង់ ចេះតែបន្តទៅមុខ ហើយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ជាមួយនឹងនិរន្តរភាពនៃការវិនិយោគផ្ទាល់ពីបរទេស។ ក្នុងរយៈពេលមធ្យមសេដ្ឋកិច្ចនឹងស្ថិតក្នុងសុខភាពល្អ ពិពិធកម្មសេដ្ឋកិច្ចក្នុងវិស័យក្រៅពីកសិកម្មមានការកើនឡើងដោយកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំ និងស្ថិតក្នុងរវាង ៦% ទៅ ៧%។ ការនាំចេញសម្លៀកបំពាក់សកម្មភាពសំណង់ និងវិស័យទេសចរណ៍នឹងបន្តជាកម្លាំងជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី។ លើសពីនេះទៀត វិស័យ

[១៤៦] សុន្ទរកថា សម្តេចតេជោ ហ៊ុន សែន នៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៨ សណ្ឋាគារភ្នំពេញ ២៨ កុម្ភៈ ២០០៨

កសិកម្មនឹងនៅបន្តមានការអភិវឌ្ឍន៍ល្អដោយមានវឌ្ឍនភាពពិពិធកម្មប្រភេទដំណាំ និងការពង្រីកកសិ-ឧស្សាហកម្ម និងកសិ-អាជីវកម្ម។ គោលនយោបាយកំណែទម្រង់ទីជនបទជាពិសេសពង្រីកប្រព័ន្ធធារាសាស្ត្រ និងការបែងចែកដីធ្លី អាចនាំឈានទៅសម្រេចបានវឌ្ឍនភាព និងពិពិធកម្មវិស័យកសិកម្មក្នុងរយៈពេលមធ្យម។

រាជរដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការអភិវឌ្ឍន៍ពង្រឹងក្របខ័ណ្ឌច្បាប់ បទបញ្ញត្តិ និងសមត្ថភាពស្ថាប័ន ក្នុងការសម្របសម្រួលដល់សកម្មភាពធុរៈកិច្ច ការវិនិយោគឯកជននៅកម្ពុជា។ រាជរដ្ឋាភិបាល បានចាត់ទុកវិស័យឯកជន ជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។ វិស័យឯកជន ដែលមានការលូតលាស់ល្អ អាចបំពេញតួនាទីជំនួសការវិនិយោគសាធារណៈនៅក្នុងវិស័យសង្គមកិច្ច តាមរយៈការស្រូបយកកម្លាំងពលកម្មដ៏លើសលប់នៃវិស័យសាធារណៈ និងការផ្តល់នូវធនធានចាំបាច់ ដើម្បីស្រូបយកតម្រូវការការងារ ដែលចេះតែកើនឡើង។ ប៉ុន្តែការអភិវឌ្ឍន៍វិស័យឯកជន ត្រូវបានជួបនៅការលំបាកដោយសារកង្វះខាតនូវច្បាប់ស្ថាប័ន នីយ័តកម្ម និងប្រភពហិរញ្ញប្បទាននៅមានកម្រិត។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងកែលម្អនូវបរិយាកាសសម្រាប់ធុរៈកិច្ច ដោយជានាអោយបាននូវប្រព្រឹត្តកម្មស្មើភាពមួយសម្រាប់វិស័យឯកជណ រួមមានការធ្វើអោយស៊ីសង្វាក់គ្នារវាងបណ្តាច្បាប់ និងលិខិតបទដ្ឋាន ការអនុម័តក្រមពាណិជ្ជកម្មដ៏ទូលំទូលាយមួយ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ ការរក្សាភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងតំបន់ និងការបង្កើនគុណភាពនៃប្រព័ន្ធតុលាការ។ ក្នុងនោះច្បាប់មួយចំនួននៃក្រមពាណិជ្ជកម្មថ្មីត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីរួចហើយដើម្បីពិនិត្យ និងសម្រេច។

ជាមួយគ្នានេះដែរ ការអភិវឌ្ឍន៍ផ្នែកធនធានមនុស្ស ប្រកបដោយនិរន្តរភាពជាការចាំបាច់សំខាន់ណាស់ ក្នុងការបង្កើតនៅផលិតភាព និងភាពប្រកួតប្រជែងរបស់ប្រទេស។ ដោយយើងសង្កេតឃើញនៅមានគម្លាតដ៏ធំរវាងតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់វិស័យឯកជន។

គម្លាតនេះរួមមានគុណភាពប្រភេទ និងអាជីពរបស់កម្លាំងពលកម្ម។ ការបង្កើនគុណភាពកម្រិតឧត្តមសិក្សាជាពិសេស ផ្នែកវិទ្យាសាស្ត្រ ការបង្កើនការបណ្តុះបណ្តាល់វិជ្ជាជីវៈ និងជំរុញអោយមានការបណ្តុះបណ្តាលពីវិស័យឯកជនខ្លួនឯងអាចដោះស្រាយបញ្ហានេះបានមួយចំនួនធំ។

រាជរដ្ឋាភិបាល បានទទួលស្គាល់ថា និរន្តរភាពពីកំណើនរបស់ប្រទេសកម្ពុជានាពេលអនាគត អាស្រ័យទៅលើសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកកាលានុវត្តភាព និងមូលដ្ឋានកំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះ ការពង្រឹងអភិបាលកិច្ចល្អជាតម្រូវការចាំបាច់បំផុត ដើម្បីទាក់ទាញវិនិយោគអោយច្រើនថែមទៀត និងការជានាភាពប្រកួតប្រជែងរបស់យើងជាមួយប្រទេសជិតខាងនោះ ជាពិសេសក្នុងវិស័យសក្តានុពលរបស់យើងដូចជាកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មអតិពលកម្ម និងកែច្នៃ វិស័យទេសចរណ៍ កម្មន្តសាល និងវិស័យសេវាកម្ម។

រាជរដ្ឋាភិបាលយល់ឃើញយ៉ាងច្បាស់ថា វិស័យឯកជនអាចជួយជំរុញដល់កំណើនសេដ្ឋកិច្ច ដែលក្នុងនោះ រាជរដ្ឋាភិបាលបានដើរតួជាអ្នកយុទ្ធវិទូ បង្កើតបរិស្ថាន អាជីវកម្មសម្រាប់វិស័យឯកជន និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍន៍។ ដំណើរប្រព្រឹត្តទៅល្អរបស់វិស័យឯកជន ជាគន្លឹះក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចអោយខ្លាំងរឹងមាំ ដូច្នេះ រាជរដ្ឋាភិបាល ត្រូវតែជានាអោយអនុវត្តនៅក្របខ័ណ្ឌច្បាប់ សម្រាប់ការប្រកួតប្រជែងដោយយុត្តិធម៌ តម្លាភាព

គណនេយ្យភាព និងការទំនាក់ទំនងល្អជាមួយវិស័យសាធារណៈ។ បរិស្ថានសម្រាប់សហគ្រាសលូតលាស់អាចពង្រឹងបានតាមរយៈអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ធនធានមនុស្ស ហើយផ្នែកសាធារណៈត្រូវតែខ្លាំង និងរឹងមាំដើម្បីកែសម្រួលទីផ្សារសំដៅធ្វើយ៉ាងណាអោយការកែចម្រើនខាងវិស័យឯកជន ផ្តល់ផលដល់ប្រជាជនក្រីក្រ និងអ្នកដែលគ្មានឱកាស។

រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា យើងត្រូវតែធ្វើការពិចារណាស្វែងរកវិធានការជាក់លាក់ ដើម្បីអោយកំណែទម្រង់ជាប្រព័ន្ធអោយកាន់តែស៊ីជម្រៅ ដើម្បីសម្របសម្រួលដល់ការអភិវឌ្ឍន៍វិស័យឯកជន និងកែលម្អបរិស្ថានសម្រាប់ការវិនិយោគពាណិជ្ជកម្ម និងសហគ្រាសនៅកម្ពុជា។ ដើម្បីបង្កើតឱកាសេដ្ឋកិច្ចអោយបានច្រើនថែមទៀត សម្រាប់វិស័យឯកជន យើងត្រូវតែលើកតម្កើងកេរ្តិ៍ឈ្មោះ និងរូបភាពរបស់កម្ពុជានៅក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោក។ ដំណើរការកំណែទម្រង់ឆ្ពោះទៅប្រព័ន្ធបញ្ជារតែមួយ នឹងបន្តជួយកាត់បន្ថយទម្រង់ការសម្រាប់ការនាំចេញ នាំចូល ក៏ដូចជាការអនុម័តគម្រោងវិស័យវិនិយោគនឹងបន្តធ្វើថែមទៀត។

កត្តាដែលសំខាន់បំផុត គឺជោគជ័យក្នុងការអភិវឌ្ឍន៍វិស័យឯកជននៅប្រទេសកម្ពុជា អាស្រ័យចម្បងទៅលើការអភិវឌ្ឍន៍ឧស្សាហកម្មធុនតូច និងមធ្យម។ ដោយសារតែឧស្សាហកម្មនៅកម្ពុជាភាគច្រើនមានទ្រង់ទ្រាយតូច និងមធ្យម រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យយុទ្ធសាស្ត្រ និងផែនការសកម្មភាពយ៉ាងច្បាស់លាស់សម្រាប់ការអភិវឌ្ឍន៍ឧស្សាហកម្មធុនតូច និងមធ្យម។ ដើម្បីឈានទៅសម្រេចអោយបានទិសដៅដែលបានកំណត់ រាជរដ្ឋាភិបាលកម្ពុជាកំពុងគិតគូរពិចារណាយ៉ាងខ្លាំងក្លា អំពីការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ការលូតលាស់របស់ឧស្សាហកម្មធុនតូច និងមធ្យម និងបង្កើនូវក្របខ័ណ្ឌស្ថាប័នក្នុងរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលគោលនយោបាយឧស្សាហកម្មធុនតូច និងមធ្យម ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធ។

តាមការសិក្សាស្រាវជ្រាវបានអោយដឹងផងដែរថា បញ្ហាប្រឈមមុខនៃការអភិវឌ្ឍន៍ផ្នែកឯកជននៅកម្ពុជាគឺហេដ្ឋារចនាសម្ព័ន្ធមិនទាន់លូតលាស់ល្អ បញ្ហាសន្តិសុខសម្រាប់វិនិយោគិននៅទីចុងកាត់មាត់ញកមានភាពចន្លោះប្រហោងនៃប្រព័ន្ធគតិយុត្តការប្រាក់ខ្ពស់ ការលំបាក់រកឥណទាន ព័ត៌មានមិនគ្រប់គ្រាន់ ស្តីពីតម្រូវការលើទីផ្សារ កង្វះខាតពលករមានជំនាញ និងអ្នកគ្រប់គ្រងដែលមានជំនាញខ្ពស់[១៤៧]។ កង្វះខាត និង/ឬ គុណភាពផ្លូវមិនសូវល្អ ដែលរារាំងដល់ច្រកចូលទីផ្សារ និងវត្ថុធាតុដើម គុណភាពនៃកំពង់ផែ ការផ្គត់ផ្គង់ចរន្តអគ្គីសនី និងទឹកអោយបានទៀងទាត់នៅតាមខេត្ត គឺជាបញ្ហាដែលសហគ្រិននានាបានលើកឡើង។ បញ្ហាសន្តិសុខផ្ទាល់ខ្លួននៅក្នុងទីជនបទ គឺជាកត្តាមួយដែលរារាំងធុរៈជនទាំងក្នុងស្រុកទាំងពីបរទេសមិនអោយវិនិយោគ មកពីវិនិយោគរបស់គេឆ្ងាយពីទីក្រុងភ្នំពេញ។ សហគ្រាសតូច និងមធ្យមបានលើកឡើងនូវចន្លោះប្រហោងនៃបទបញ្ញត្តិស្តីពីការកាន់កាប់ដី ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍ធុរៈកិច្ចធុនតូច។

[១៤៧] យុទ្ធសាស្ត្រក្នុងការផ្តល់ជំនួយដល់កម្ពុជា: ការកសាងមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ធនាគារពិភពលោក ឆ្នាំ២០០០

ការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច គឺជាគោលនយោបាយមួយទៀត ដែលអាចកាត់បន្ថយរបាំង ដែលរារាំងពលរដ្ឋក្រីក្រមិនអោយចូលរួមក្នុងវិស័យសេដ្ឋកិច្ចបាន។ ហេដ្ឋារចនាសម្ព័ន្ធមិនត្រឹមតែជះឥទ្ធិពលដល់បែបផែននៃកំណើនប៉ុណ្ណោះទេ ក៏ប៉ុន្តែការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ នឹងធ្វើអោយស្ថាភាពក្រីក្រកាន់តែមានកម្រិតធ្ងន់ធ្ងរឡើងថែមទៀត ពីព្រោះ វារាំងខ្ទប់មិនអោយពលរដ្ឋក្រីក្រទទួលបាននូវសេវាសុខភាព ការអប់រំ ហើយថែមទាំងបង្កើនបន្ទុកការងាររបស់ស្ត្រីថែមទៀតផង។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធវាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងបរិការណ៍នៃការបន្តការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម ដោយវាបង្កលក្ខណៈអោយប្រជាពលរដ្ឋក្រីក្រងាយស្រួលទទួលបាននូវលទ្ធភាចូលទៅកាន់ទីផ្សារកាន់តែងាយស្រួល ដោយសារមានផ្លូវគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ទំនិញ។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធគួបផ្សំនឹងការធានាអោយប្រជាពលរដ្ឋក្រីក្រទទួលបានឥណទាន សេវាអប់រំ និងសុខភាព និងការធានាអនុវត្តន៍គោលនយោបាយទីផ្សារបើចំហនឹងមិនជួបឧបសគ្គ ដែលបណ្តាលមកពីពលរដ្ឋក្រីក្រមិនបានចូលរួមចំណែកនៅក្នុងដំណើរការនៃការអភិវឌ្ឍន៍នោះឡើយ។ អាទិភាពជាគន្លឹះក្នុងការគ្រប់គ្រងផ្នែកហេដ្ឋារចនាសម្ព័ន្ធរួមមាន ការបង្កើតវិស័យថាមពលប្រកបដោយប្រសិទ្ធភាព អគ្គីសនីភាវូបនីយកម្មនៅជនបទ ការជួសជុល និងថែរក្សាប្រព័ន្ធផ្លូវថ្នល់ ការកែលម្អ ការផ្គត់ផ្គង់ទឹក និង អនាម័យ ការពង្រឹងប្រព័ន្ធទូរគមនាគមន៍ ការបង្កើតឡើងនូវផែនការសម្រាប់ខេត្ត/ក្រុង ការរៀបចំផែនទីភូមិសាស្ត្រ រដ្ឋបាលតាមដំនាញ និងការកសាងលំនៅឋាននៅទីជនបទ។ ហេដ្ឋារចនាសម្ព័ន្ធកសិកម្មដូចជា ផ្លូវ ប្រព័ន្ធធារា-សាស្ត្រ និងការរកទីផ្សារក៏មានសារៈសំខាន់ដែរ ក្នុងការកាត់បន្ថយភាពក្រីក្រ។ ការកសាងសមត្ថភាព ដើម្បីកែលម្អសេវាគាំទ្រ និងការងារកសិកម្មសំខាន់ៗដូចជា ការស្រាវជ្រាវកសិកម្ម ការរៀបចំផែនការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ ការផ្តល់ធាតុចូលកសិកម្ម និងការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងខាងឧស្សាហកម្មទៅអោយកសិករត្រូវតែអនុវត្តអោយស្របគ្នាជាមួយនឹងការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធ។

យោងតាមទិន្នន័យនៃការធ្វើអង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងឆ្នាំ១៩៩៩ មានគ្រួសារប្រហែល ១៧% មានអគ្គីសនីប្រើប្រាស់។ នៅជនបទមានតែគ្រួសារចំនួន ២% ប៉ុណ្ណោះមានអគ្គីសនីរដ្ឋប្រើប្រាស់ ក្នុងខណៈដែល ៥,៤% ទៀតប្រើប្រាស់អគ្គីសនីឯកជន។ កង្វះអគ្គីសនី បានធ្វើអោយគុណភាពនៃការអប់រំ និងការថែរក្សាឧុសភាពនៅទីជនបទធ្លាក់ចុះ ដែលជាមូលហេតុ ធ្វើអោយស្ថានភាពក្រីក្រនៅតំបន់ជនបទនៅតែបន្តមានអត្ថិភាពទៅទៀត។ ដូចនេះ អគ្គីសនីភាវូបនីយកម្មនៅតំបន់ជនបទនឹងមិនត្រឹមតែអាចកែលម្អសេវាសង្គមសម្រាប់បម្រើអោយពលរដ្ឋក្រីក្រនៅក្នុងរយៈពេលមធ្យម និងវែងប៉ុណ្ណោះទេ តែថែមទាំងនឹងលើកស្ទួយផលិតភាពការងារនៅក្នុងវិស័យកសិកម្មទៀតផង។ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមនៃការអភិវឌ្ឍន៍វិស័យថាមពលដ៏រឹងមាំនៅកម្ពុជា គឺជាការចំណាយខ្ពស់ក្នុងការផលិតថាមពលអគ្គីសនី។ ការកសាងស្ថានីយ៍វារីអគ្គីសនីទោះបីជាអាចបណ្តាលអោយមានការចិចរិលបរិស្ថានក៏ដោយ តែវាអាចនឹងជួយដោះស្រាយបញ្ហាប្រឈមទាំងនោះបាន។ ក៏ប៉ុន្តែប្រទេសជាអ្នកផ្តល់ជំនួយមាននិន្នាការផ្តល់អាទិភាពដល់វិស័យដទៃទៀត ដែលអាចផ្តល់ផលភ្លាមៗដល់ជីវភាព

របស់ប្រជាពលរដ្ឋ។ នាចុងខែធ្នូ ឆ្នាំ២០០០ រដ្ឋសភាជាតិនឹងអនុម័តច្បាប់អគ្គីសនី ដែលនឹងដាក់ចេញនូវ ក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងលើវិស័យថាមពល។

ចំណែកឯបរិស្ថានក្នុងវិស័យរ៉ែ គួរតែទទួលនូវការយកចិត្តទុកដាក់ខ្ពស់ផងដែរ។ ប្រទេសកម្ពុជាយើង មានមេរៀនរាប់មិនអស់ ដែលអាចដកស្រង់ពីប្រទេសដទៃ ក្នុងការគ្រប់គ្រងរធនធានរ៉ែរ។ វិស័យរ៉ែរបស់យើងនៅ ដំណាក់កាលក្មេងខ្ចីនៅឡើយ ហើយរំពឹងថានឹងបន្តការរីកចម្រើនយឺតៗ។ ទោះបីជាយើងមានច្បាប់សម្រាប់ គ្រប់គ្រង ធ្វើអាជីវកម្មរ៉ែ ព្រមនឹងច្បាប់សម្រាប់ការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ តែការអនុវត្តន៍ ច្បាប់នៅតែជាបញ្ហាមួយ នៃការគ្រប់គ្រងបរិស្ថានអោយបានល្អត្រឹមត្រូវក្នុងឧស្សាហកម្មរ៉ែ។

ការលើកស្ទួយវិស័យកសិម្ម គឺជាមុំទីមួយរបស់យុទ្ធសាស្ត្រចតុកោណនៃរដ្ឋាភិបាលកម្ពុជា។ ការលើក ស្ទួយវិស័យកសិកម្មអាចដំណើរទៅបាន គឺឈរលើមុំទាំងបួននៃវិស័យនេះរួមមាន ការលើកស្ទួយផលិតភាព កសិកម្ម និងពិពិធកម្មកសិកម្ម ក្នុងន័យនេះ យើងមានសេចក្តីត្រូវការចាំបាច់ក្នុងការពង្រឹង និងពង្រីកមូលដ្ឋាន កំណើនសេដ្ឋកិច្ចជាតិ ដោយប្រើសក្តានុពលភាពសេដ្ឋកិច្ច លើវិស័យផ្សេងៗទៀតបានកាន់តែច្រើន ជាពិសេស លើវិស័យកសិកម្ម និងឧស្សហកម្ម ដែលមានសក្តានុពលភាពកំណើនយ៉ាងធំធេង ដែលអាចជះឥទ្ធិពលជា វិជ្ជមានយ៉ាងរហ័សក្នុងការខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅតំបន់ជនបទ។

ដោយសារ ៨៥% នៃប្រជាជនរស់នៅក្នុងសហគមន៍ជនបទ និង៧៥% នៃពលរដ្ឋក្រីក្រ គឺជាគ្រួសារ ដែលមានមេគ្រួសារជាកសិករ គន្លឹះសម្រាប់បង្កើតកំណើតសេដ្ឋកិច្ចប្រកបដោយចីរភាពសម្រាប់ការកាត់បន្ថយ ភាពក្រីក្រ និងសម្រាប់ការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជនបទ គឺការពន្លឿនការអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយ ចីរភាព។ សក្តានុពលកសិកម្មអាចសម្រេចបានតាមរយៈទី១-ពន្លឿនការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រឯកជន តូចធំ អោយមានប្រសិទ្ធភាព និងអាចដំណើរការបានភ្លាមៗដូចជា អណ្តូងស្នប់រាក់ៗ និងប្រព័ន្ធម៉ាស៊ីបូមទឹកតូច ទី២-បង្កើនផលិតភាពស្រូវ ទី៣-កែលម្អប្រព័ន្ធដាំដុះ និងប្រព័ន្ធវប្បកម្ម ទី៤-ពង្រីក និងកែលម្អការចិញ្ចឹមសត្វ ទី៥-ពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់បច្ចេកវិទ្យាសមស្របក្នុងការចិញ្ចឹមត្រីក្នុងស្រែ និងការចិញ្ចឹមត្រី ទូទៅ និងទី៦-អភិវឌ្ឍន៍វិស័យកសិ-រុក្ខាសហគមន៍។ ប្រព័ន្ធធារាសាស្ត្រតូចៗ ដែលគ្រប់គ្រងដោយកសិករផ្ទាល់ គឺជា កាលានុវត្តភាពដ៏ល្អប្រសើរបំផុត ដោយសារប្រទេសកម្ពុជាមានផ្ទៃដីដាំដុះចំនួន ៤.៨លានហិកតា ដែលមានទឹក ក្រោមដី ឬដែលមានទន្លេ ស្ទឹង ហូរកាត់ខ្វាត់ខ្វែង។ ក៏ប៉ុន្តែការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រត្រូវតែធ្វើឡើងអោយ បានទន្ទឹងមគ្នា និងការកែលម្អនូវសេវា និងការងារគាំទ្រ ផ្នែកធារាសាស្ត្រកសិកម្មសំខាន់ៗ ដូចជា គម្រោង សាកល្បងស្តីពីកម្មវិធីវិសេស ដើម្បីជានានៅសន្តិសុខស្បៀង ដែលឧបត្ថម្ភដោយអង្គការនានា ក្នុងគោលដៅទាក់ ទាញយកផលប្រយោជន៍ជាអតិបរមាពីការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រជាដើម។ ជាមួយគ្នានេះ យើងនឹងមាន សក្តានុពលដ៏ប្រសើរក្នុងរយៈពេលខ្លី និងក្នុងរយៈពេលវែង ដើម្បីបង្កើនទិន្នផលស្រូវ និងបង្កើតប្រព័ន្ធវប្បកម្ម ដំណាំដុះផ្សេងៗ។ ដំណាំស្រូវលើដីមានទិន្នផលមធ្យម និងខ្ពស់អាចអនុញ្ញាតអោយប្រមូលផលបានរហូតដល់ ៥.៥តោន ក្នុងមួយហិកតាក្នុងមួយឆ្នាំ(ដូច្នេះ វាបង្កើនទិន្នផលស្រូវទ្វេរដងពីរ បើប្រៀបធៀបនឹងកម្រិតសព្វថ្ងៃ

នេះ)។ ម្យ៉ាងវិញទៀត យើងមានកាលានុវត្តភាពដ៏ប្រសើរផងដែរ ក្នុងការកែលម្អប្រព័ន្ធដាំដុះ។ យើងក៏អាចកែលម្អការចិញ្ចឹមសត្វ ដើម្បីអោយប្រជាពលរដ្ឋក្រីក្រជាច្រើន ដែលរស់នៅតាមទីជនបទអាចទទួលបាននូវផលប្រយោជន៍យ៉ាងពេញលេញ។ ក្នុងន័យនេះ យុទ្ធសាស្ត្រនេះត្រូវផ្តោតជាសំខាន់ទៅលើការចិញ្ចឹមមាន់ ទា និងជ្រូក តាមផ្ទះការអភិវឌ្ឍន៍រោងចក្រផលិតចំណីសត្វ និងការចិញ្ចឹមសត្វក្នុងទ្រង់ទ្រាយធំ ដោយប្រើប្រាស់នូវដីដែលនៅទំនេរ។ កាលានុវត្តភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងវិស័យជលផល គឺជាការចិញ្ចឹមត្រីនៅក្នុងស្រែ និងចិញ្ចឹមត្រីជាទូទៅ។

ក្នុងឆន្ទៈនេះដែរ រាជរដ្ឋាភិបាលបន្តជំរុញចលនា"**ភូមិ១ ផលិតផល១**" ដើម្បីលើកស្ទួយនៅគំនិតច្នៃប្រឌិត និងមានជំនឿលើខ្លួនឯងរបស់ប្រជាពលរដ្ឋនៅតាមទីជនបទដោយឈរលើគោលការណ៍សំខាន់ៗបួនយ៉ាង គឺ: ទី១-ការិះរកវិធីដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃបរិស្ថានភូមិឋាន និងសមស្របទៅតាមសេចក្តីស្រូវការរបស់ទីផ្សារ ទី២-ការបង្កើតលក្ខណៈងាយស្រួល និងការផ្តល់ការលើកទឹកចិត្តប្រជាពលរដ្ឋ ក្នុងការផលិតដូចជាការស្វែងរកទីផ្សារ ការផ្តល់ឥណទាន ការផ្ទេរបច្ចេកវិជ្ជា និងផ្តល់ពូជ ទី៣-ការជួយបណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រង និងធនធានមនុស្ស និងទី៤-ការបង្កលក្ខណៈងាយស្រួលអោយប្រជាពលរដ្ឋបង្កើនសហគមន៍កសិកម្មក្នុងទិសដៅជានាតម្លៃផលិតផល[១៤៨]។

ការធ្វើកំណែទម្រង់ដីធ្លី និងការបោសសំអាតមីន។ ទឹក និងដី គឺជាធនធានធម្មជាតិយ៉ាងសំខាន់ ដែលអាចយកមកប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ។ ការបន្តអនុវត្តន៍ច្បាប់ភូមិបាល និងគោលនយោបាយដីធ្លី ដោយរាជរដ្ឋាភិបាលបានប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ ដោយធានានូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិលើដីធ្លី និងការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីធ្លីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្របមួយ ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រាស់មិនធ្វើផលិតកម្ម ឬអាជីវកម្ម។ល។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបាននឹងបន្តផ្តល់អាទិភាពដល់ការពង្រឹងប្រសិទ្ធភាព កាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ដែលត្រូវការដីសម្រាប់សាងសង់លំនៅឋាន និងធ្វើអាជីវកម្មកសិកម្មជាលក្ខណៈគ្រួសារក្នុងក្របខ័ណ្ឌដីសម្បទាន ដើម្បីគោលដៅសង្គមកិច្ច ដោយឈរលើគោលការណ៍ជួយគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ។

ពាក់ព័ន្ធនឹងបញ្ហាដីធ្លីនេះដែរ ការបោសសំអាតមីនមិនគ្រាន់តែជាបញ្ហាសន្តិសុខមួយមុខប៉ុណ្ណោះទេ ប៉ុន្តែវាពាក់ព័ន្ធបញ្ហាសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ជារួមជាពិសេស បញ្ហាផ្គត់ផ្គង់ដីធ្លី និងការផ្គត់ផ្គង់សុវត្ថិភាពក្នុងការប្រកបអាជីវកម្មនៃគ្រួសារកសិករក្រីក្រនៅជនបទដាច់ស្រយាល។

[១៤៨] រាជរដ្ឋាភិបាលកម្ពុជា "យុទ្ធសាស្ត្រចតុកោណ" ឆ្នាំ២០០៤ ទំព័រទី៣៣

ការធ្វើកំណែទម្រង់លើវិស័យនេសាទ និងជលផលសម្រាប់ប្រជនជនកម្ពុជារាប់លានអ្នកដោយបានផ្តល់ជាស្បៀងអាហារជាចំណូល និងការរស់នៅ ហើយគួបផ្សំនឹងអង្ករ ត្រី ដែលជាផ្នែកមួយយ៉ាងសំខាន់នៃសន្តិសុខស្បៀង បានផ្តល់ប្រូតេអ៊ីនចំនួន បីភាគបួន ដល់ប្រជាជនចំនួន ពីរលាននាក់។ ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការអភិវឌ្ឍន៍វិស័យជលផលប្រកបដោយចីរភាព និងសមធម៌ដោយប្រគល់អំណាចដល់សហគមន៍ជនបទ ដើម្បីអោយប្រជាកសិករអាចចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការ និងកម្មវិធីនានាដោយទទួលខុសត្រូវគ្រប់គ្រងធនធានជលផលដោយខ្លួនឯង។

ការធ្វើកំណែទម្រង់ព្រៃឈើ ក្នុងវិស័យព្រៃឈើ គឺជាគោលដៅយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាល ដែលត្រូវធានាអោយបាននៅគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយការត្រួតពិនិត្យអាជីវកម្មព្រៃឈើយ៉ាងម៉ឺងម៉ាត់ និងសមស្របតាមនិយមន័យ ការគ្រប់គ្រងព្រៃឈើជាអន្តរជាតិ ដោយតម្រូវអោយមានព្រៃឈើបម្រុងទុកគ្រប់គ្រាន់សម្រាប់ទប់ទល់របស់ប្រជាពលរដ្ឋ និងសម្រាប់ការពារគ្រោះរាំងស្ងួត និងទឹកជំនន់ ព្រមទាំងមានព្រៃលិចទឹកសម្រាប់ទុកជាជម្រកមច្ឆជាតិ។ ទី២-ប្រព័ន្ធការពារធនធានធម្មជាតិ ដោយធ្វើការអភិរក្សជីវសាស្ត្រចម្រុះ និងប្រភេទសត្វដែលកម្រ។ ទី៣-ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើមួយដែលរឹងមាំ មានតម្លាភាព និងគ្រប់គ្រងដោយផ្ទាល់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់នោះ។

បន្ថែមលើគោលការណ៍ទាំងបីនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្អាក និងពិនិត្យអាជីវកម្មព្រៃឈើសម្បទានដែលសេសសល់ទាំងអស់នោះឡើងវិញ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពដោយសំដៅលើការគ្រប់គ្រងអោយមានប្រសិទ្ធភាព និងបន្តជំរុញគោលនយោបាយដាំដុះព្រៃឈើឡើងវិញ។

ការអភិវឌ្ឍន៍វិស័យនេះនៅមានការជួបប្រទះនឹងការលំបាកដោយសារ តែយើងនៅមិនទាន់មានក្នុងក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ និងផែនការសកម្មភាពក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម។ ទីផ្សារនាំចេញអង្ករ និងដំណាំដទៃទៀត មិនទាន់បានស្រាវជ្រាវអោយបានច្បាស់លាស់ ហើយយើងត្រូវប្រឈមមុខនឹងរបាំងជាច្រើន ដែលរារាំងដល់កំណើននៃការនាំចេញក្នុងនោះគុណភាពនៅមានកម្រិតទាប កង្វះខាតនូវព័ត៌មានស្តីពីពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រនៅអន់ថយ កង្វះខាតឧបករណ៍សម្ភារៈសម្រាប់ពេលច្រូតកាត់ និងក្រោយពេលច្រូតកាត់ សមត្ថភាពស្ថាប័ននៅខ្សោយ ទិន្នផលនៅទាប សេវាកម្មកសិកម្មមិនទាន់គ្រប់គ្រាន់ ប្រព័ន្ធធារាសាស្ត្រមិនគ្រប់គ្រាន់ ហើមានផលិតភាពទាប កសិករគ្មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទទួលបាននូវធនធានសម្រាប់ផលិតកម្ម និងការខ្វះខាតសមត្ថភាពស្ថាប័នក្នុងការធ្វើផែនការ អនុវត្តសកម្មភាពអភិវឌ្ឍន៍សម្រាប់កសិកម្ម។

រាជរដ្ឋាភិបាលបានចាត់ទុកវិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីបង្កើនចីរភាពនៃធនធានព្រៃឈើ។ វិធានការទាំងនេះរួមមាន ការអនុវត្តន៍ប្រកបដោយជោគជ័យនូវគោលនយោបាយក្នុងការបង្ការឧក្រិដ្ឋកម្មនោះ ការចាប់បានការកំចាត់ និងការត្រួតពិនិត្យសកម្មភាពខុសច្បាប់នានា។ រាជរដ្ឋាភិបាលបានបង្កើតឡើងអង្គភាពសម្រាប់ផ្តល់របាយការណ៍ និងត្រួតពិនិត្យបទឧក្រិដ្ឋនៃព្រៃឈើនៅក្នុងនាយកដ្ឋានរុក្ខប្រមាញ់នៃក្រសួងកសិកម្ម និងនៅក្នុង

ក្រសួងបរិស្ថាន និងបង្កើតឡើងនៅចំណុចប្រមូលផ្តុំមួយនៅទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ធ្វើការត្រួតពិនិត្យរបាយការណ៍ទាំងនេះ។

បញ្ហាជាអាទិភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល គឺបង្កើតការផ្គត់ផ្គង់ទឹក និងហេដ្ឋារចនាសម្ព័ន្ធទាំងនៅទីក្រុង ទាំងនៅជនបទ ក្នុងគោលដៅ ការដោះស្រាយដើមហេតុចម្បងនៃភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាព សន្តិសុខស្បៀង និងសុខភាពរបស់ប្រជាជន។ យើងនឹងប្រើប្រាស់អោយមានប្រសិទ្ធភាពខ្ពស់នៅទឹកនៅក្រោមដីទាំងរាក់ ទាំងជ្រៅក្នុងគោលដៅធារាសាស្ត្រ និងគោលដៅនៃការផ្គត់ផ្គង់ទឹកតាមទីលំនៅឋាន។ ក្នុងករណីដែលលក្ខខ័ណ្ឌបច្ចេកទេស និងសេដ្ឋកិច្ចអនុញ្ញាតរាជរដ្ឋាភិបាលមានវិធានការស្តារឡើងវិញនៅមូលដ្ឋានធារាសាស្ត្រ ដែលមានស្រាប់ ដើម្បីធានានូវសមធម៌ក្នុងការប្រើប្រាស់ទឹក និងដើម្បីលើកកម្ពស់ផលិត កសិកម្ម និងសន្តិសុខស្បៀង។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម គឺលើកទឹកចិត្តដល់ផ្នែកឯកជន និងកសិកម្មក្នុងការអនុវត្តកម្មវិធីជីកអណ្តូងរាក់ៗ និងម៉ាស៊ីនបូមទឹកតូចៗ។ បន្ទាប់ពីសមត្ថភាព ស្ថាប័នទាំងនៅមជ្ឈឹមទាំងនៅខេត្តក្នុងការរៀបចំការគ្រប់គ្រង និងដំណើរការប្រព័ន្ធធារាសាស្ត្រត្រូវបានពង្រឹងរួច ហើយរាជរដ្ឋាភិបាលនឹងដាក់ចេញនូវយុទ្ធសាស្ត្របន្ថែមក្នុងការពង្រីកប្រព័ន្ធធារាសាស្ត្រធំៗទៀត។

គោលដៅនៃគោលនយោបាយទឹករបស់រាជរដ្ឋាភិបាល គឺពង្រីកតំបន់ស្រោចស្រពពេញលេញពី ១៦ ដល់ ២០% នៃតំបន់ដាំស្រូវទាំងអស់នៅកំឡុងពេល ៥ឆ្នាំ ដល់ ២០០៣ និងនាំបន្តបន្ទាប់ទៀត តាមរយៈការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រសមស្របការបង្កើតការត្រួតពិនិត្យ និងភាពជាម្ចាស់នៅតាមមូលដ្ឋានការជម្រុញការចូលរួមរបស់ផ្នែកឯកជនក្នុងការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងពង្រឹងសមត្ថភាពរបស់អង្គការរដ្ឋ និងសហគមន៍អ្នកប្រើប្រាស់ទឹកក្នុងកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ។

ជាក់ស្តែងនៅឆ្នាំ២០០៦ តាមរយការសហការយ៉ាងជិតស្និទក្នុងចំណោមរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា លើយុទ្ធសាស្ត្រសម្រាប់កសិកម្ម និងធនធានទឹក គឺផ្តោតការយកចិត្តទុកដាក់លើផែនការរបស់អនុវិស័យទាំងអស់នៅក្នុងវិស័យនេះ និងនៅក្នុងចំណោមការងារផ្សេងៗទៀត ដោយបញ្ចូលនូវការវិភាគដោះស្រាយ និងធ្វើជាយុទ្ធសាស្ត្រការងារមួយចំនួនដូចជា:

-ការគ្រប់គ្រងដីកសិកម្ម ចំណុចខ្លាំង ចំណុចខ្សោយ របស់សេដ្ឋកិច្ចមាគ្រាដ្ឋាន ទំហំ និងកត្តាផ្នែកសង្គមដែលទាក់ទងនឹងដីកសិកម្មតូចៗ សហករណ៍ កសិកម្ម ការងារកសិដ្ឋាន ដោយមានកិច្ចសន្យាការធ្វើសម្បទានដីទ្រង់ទ្រាយធំ ដែលទាំងអស់នេះ គឺនៅក្នុងបរិបទនៃការបង្កើនផលកសិកម្ម និងផលិតភាព ពិពិធកម្មការជានាសមត្ថភាព និងយុត្តិធម៌សង្គម។

-ផលិកម្មពូជដែលមានទិន្នផលខ្ពស់ ជាពិសេសស្រូវត្រូវបានបង្កើតឡើងនៅកន្លែងផ្សេង ជាពិសេសនៅក្នុងប្រទេសជិតខាង ដែលមានលក្ខណៈអាកាសធាតុកសិកម្មប្រហាក់ប្រហែលគ្នាធៀបការវិនិយោគទ្រង់ទ្រាយធំក្នុងការស្រាវជ្រាវធំផ្នែកសិកម្ម ដើម្បីបង្កើតពូជថ្មីនៅកម្ពុជា។

-ការបង្កើនផលិតកម្មស្រូវសម្រាប់ការនាំចេញទៅតាមចំណង់ចំណូលចិត្ត ឬបន្ថែមពីលើផលិតកម្មដំណាំដែលមានតម្លៃ និងតួនាទីពិសេស។ ការបង្កើនផលិតកម្មដំណាំដូចជា ផ្លែឈើ និងបន្លែ ដែលបច្ចុប្បន្ននេះកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើការនាំចូល។

•ការមានគោលដៅច្បាស់លាស់ ចំណុចដៅ និងចំណូមពរជាក់ស្តែងដើម្បីសម្រេចបានបង្កើតផលិតកម្មដំណាំតាមរយៈប្រព័ន្ធដាំដុះ ដែលអាចប្រើប្រាស់បានប្រសើរបំផុតនូវប្រភពធនធានទឹក ដែលមានកម្រិត និងកាត់បន្ថយហានិយភ័យចំពោះកសិករ ពីការប្រែប្រួលមិនទៀងទាត់ដោយសារបាតុភូតធម្មជាតិ ដែលកើតមានឡើងពីមួយឆ្នាំទៅមួយឆ្នាំ និងតាមរយៈដំណាំល្អៗបំផុត ដែលត្រូវដាំដុះគ្រប់រដូវដោយផ្តោតការយកចិត្តទុកដាក់លើលក្ខខ័ណ្ឌដី និងកត្តាផ្សេងៗទៀត លើសក្តានុពលនៃការនាំចេញ និងការកែលម្អប្រព័ន្ធធារា-សាស្ត្រ។ល។ ជាមួយគ្នានេះដែរ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដែលជាផ្នែកមួយនៃការងារអភិវឌ្ឍន៍ជនបទ ដែលត្រូវបានក្រសួងអភិវឌ្ឍន៍ជនបទបានដាក់បញ្ចូលក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន និងកម្មវិធីវិនិយោគសាធារណៈរបស់រដ្ឋាភិបាល។ ក្នុងរយៈពេល ៤ឆ្នាំ នៃកិច្ចសហការជាមួយដៃគូរអភិវឌ្ឍន៍ក្រសួងអភិវឌ្ឍន៍ជនបទបានសម្រេចបាននូវសមិទ្ធិផលមួយចំនួនដូចជា បានសាងសង់ទំនប់ទឹកថ្មីបានប្រវែង ២៧គ.ម ជួសជុលទំនប់ទឹកបានប្រវែង ១៩គ.ម សាងសង់ប្រឡាយស្រោចស្រពបានប្រវែង ៦៩គ.ម ជួសជុលប្រឡាយស្រោចស្រពបានប្រវែង ២៤១គ.ម និងសាងសង់ទ្វារទឹកបានចំនួន ៦កន្លែង[១៤៩]។

● ដោយឈរលើគោលនយោបាយធនធានទឹករបស់រដ្ឋាភិបាល គឺការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រតាមរយៈការប្រមើលមើលជាមុន និងដោះស្រាយរាល់បញ្ហា ដែលស្ថាប័នបំពេញការងារក្នុងវិស័យប្រឈមមុខក្នុងអំឡុងពេល ២០ឆ្នាំ ខាងមុខដែលអាចជួយអោយវិស័យនេះអោយប្រកាន់យកវិធានការសមស្រប ដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះ។ ក្នុងឆន្ទៈនេះរាជរដ្ឋាភិបាលនឹងផ្តោតយកចិត្តទុកដាក់លើទី១-ការផ្តល់អោយពលរដ្ឋគ្រប់រូបនៅទឹក ដែលមានសុវត្ថិភាព និងប្រកបដោយអនាម័យ ទី២-ការផ្តល់សេរីភាពដល់ពលរដ្ឋគ្រប់រូបដោយបញ្ចៀសការគម្រាមកំហែងបាត់បង់ជីវិត លក្ខខ័ណ្ឌជីវិតដែលបណ្តាលមកពីភាពចៃដន្យដែលទាក់ទងនឹងទឹក ទី៣-ការផ្តល់ទឹកគ្រប់គ្រាន់ដល់កន្លែងណាដែលត្រូវការ ដើម្បីធានាបានសន្តិសុខស្បៀងការរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាពសេដ្ឋកិច្ច ទី៤-ការធានាបរិស្ថានទឹកដែលគ្មានជាតិពុល និងការទ្រទ្រង់ជីវិតមច្ឆាជាតិ និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងទឹក[១៥០]។

បន្ថែមលើនេះទៅទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ក្នុងការបង្កើតនៅប្រព័ន្ធគ្រប់គ្រងព័ត៌មានជលផលសាស្ត្រពាក់ព័ន្ធនឹងប្រភពទឹកទាំងអស់ទាំងទឹកផ្ទៃលើទាំងទឹកក្រោមដី (អាងទឹកទន្លេអាងទឹកក្រោម) អោយមានចីរភាព និងដែលគួរអោយជឿទុកចិត្តបាន ដែលនឹងផ្តល់ព័ត៌មានជាមូលដ្ឋាន ដើម្បីជួយដល់ការធ្វើ

[១៤៩] ក្រសួងអភិវឌ្ឍន៍ជនបទ: សមិទ្ធផលការងារឆ្នាំ២០០៤-២០០៧ និងទិសដៅបន្តខែឧសភា-មិថុនា ឆ្នាំ២០០៨ ទំព័រទី២២

[១៥០] រាជរដ្ឋាភិបាលកម្ពុជា "យុទ្ធសាស្ត្រចតុកោណ" ឆ្នាំ២០០៤ ទំព័រទី៣៦

ផែនការយុទ្ធសាស្ត្រ និងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយចីរភាព និងដើម្បីរក្សាបាននូវបរិស្ថានសម្រាប់បម្រើអោយគោលដៅផ្សេងៗដូចជា ធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកបរិភោគ ថាមពលវារីអគ្គីសនី ការដឹកជញ្ជូនជលផល ការគ្រប់គ្រងទឹកជំនន់ និងកិច្ចការពារធនធានបរិស្ថានជាដើម។ ចំពោះផែនការនេះ រាជរដ្ឋាភិបាលមានវិធានការនឹង ១-រៀបចំទិន្នន័យលម្អិតនៃវិស័យទឹក ២-រៀបរូបមន្តសម្រាប់យុទ្ធសាស្ត្រវិនិយោគទុន ៣-បង្កើត ក្របខ័ណ្ឌស្ថាប័នសម្រាប់ការធ្វើប្រតិបត្តិ និងថែរក្សាប្រព័ន្ធធារាសាស្ត្រ ៤-រៀបចំផែនការសកម្មភាពស្តីពី គោលនយោបាយអភិវឌ្ឍន៍ធនធានទឹកថ្នាក់ជាតិ និង ៥-ពង្រឹងការធ្វើផែនការគម្រោង និងសកម្មភាពអនុវត្តគម្រោងក្នុងគ្រប់កម្រិតទាំងអស់។

រឿងសំខាន់មួយទៀត ការបន្តការអភិវឌ្ឍន៍វិស័យថាមពល និងបណ្តាញអគ្គីសនី ដែលជាផ្នែកសំខាន់មួយក្នុងចំណោមគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការកើនឡើងនៃតម្រូវការប្រើប្រាស់អគ្គីសនី ដោយឈរលើចក្ខុវិស័យរយៈពេលរបស់ខ្លួន រាជរដ្ឋាភិបាលចាំបាច់ត្រូវធ្វើយ៉ាងណា ដើម្បីធានាអោយមានសន្តិសុខថាមពលនៅទូទាំងប្រទេស។ ក្នុងបរិការណ៍នេះរាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ទៅលើការទាក់ទាញអោយមានការចូលរួមរបស់ផ្នែកឯកជនក្នុងការផលិត និងផ្គត់ផ្គង់អគ្គីសនី ជាពិសេសនៅតាមបណ្តាទីរួមខេត្ត និងទីប្រជុំជនសំខាន់ៗ។ ការអភិវឌ្ឍន៍គម្រោងអគ្គីសនីការបនីយកម្មតំបន់ជនបទប្រកបដោយគុណភាព និងមានតម្លៃសមរម្យ ព្រមទាំងអនុវត្តន៍គម្រោងតភ្ជាប់ខ្សែបញ្ជូលថាមពលពីប្រទេសជិតខាង។

យ៉ាងណាមិញប្រព័ន្ធផលិតកម្មប្រព័ន្ធបញ្ជូល និងប្រព័ន្ធចែកចាយថាមពលក្នុងស្រុក និងត្រូវបានដាក់អោយដំណើរការបណ្តើរៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នៅតាមទីប្រជុំជន និងជនបទ និងបំពេញតម្រូវការ ការផ្គត់ផ្គង់ទៅលើផ្នែកសេដ្ឋកិច្ច(ផលិតកម្ម) ដែលកំពុងរីកចម្រើន។ យុទ្ធសាស្ត្រវិស័យថាមពលរបស់កម្ពុជារយៈពេល ១៥ឆ្នាំ(២០០៦-២០២០) កំពុងបានរៀបចំជាបណ្តើរៗ ដោយស្នើឡើង ដើម្បីអោយមានភាពជាម្ចាស់ការក្នុងវិស័យថាមពលតាមរយៈពាណិជ្ជកម្មថាមពលអគ្គីសនី និងការផ្លាស់ប្តូរថាមពលអគ្គីសនី និងការធ្វើអោយអគ្គីសនីមាននៅក្នុងវិស័យផ្សេងៗទៀត ជាពិសេសប្រជាពលរដ្ឋក្រីក្រអាចមានលទ្ធភាពប្រើប្រាស់ក្នុងការផលិត និងប្រើប្រាស់។ តាមរយៈនេះដែរ យើងនឹងអាចទាក់ទាញវិនិយោគ និងជំរុញអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ច។

ដោយឈរលើយុទ្ធសាស្ត្រក្នុងរយៈពេលមធ្យមមួយ រាជរដ្ឋាភិបាលគួរតែ:

-បន្តធ្វើការជួសជុល និងសាងសង់រោងចក្រថាមពលក្នុងស្រុក

-ខិតខំបញ្ឈៀសការប្រើប្រាស់ប្រភពថាមពល ដែលមានតម្លៃខ្ពស់ ហើយយកចិត្តជំរុញការអភិវឌ្ឍន៍ប្រភពថាមពល ដែលមានតម្លៃទាប។

-ទិញថាមពលអគ្គីសនីនៅក្នុងតម្លៃសមស្របពីប្រទេសជិតខាង តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ដែលនឹងត្រូវពិនិត្យ និងត្រូវពង្រីកប្រព័ន្ធបញ្ជូន និងចែកចាយថាមពលអគ្គីសនីក្នុងកម្រិតជាតិ។

-ពង្រីកការធ្វើអគ្គីសនីការបូបនីយកម្មនៅតំបន់ជនបទ សំដៅលើកស្ទួយដល់ជីវភាពរស់នៅដល់អ្នកក្រីក្រ។

ចំពោះការជំរុញអោយមានការផលិតប្រេង និងឧស្ម័ន ក៏ជាផ្នែកអាទិភាពផងដែរ តាមរយៈការផ្តល់លទ្ធ-ភាពខ្ពស់ក្នុងការរុករកធនធាននេះ តាមរូបភាពមួយល្អបំផុតសំដៅចេញយកផលប្រយោជន៍សំរាប់ប្រទេសជាតិ និងប្រជាពលរដ្ឋ ពិសេស អ្នកក្រីក្រនៅក្នុងរយៈពេលមធ្យម និងរយៈពេលវែងដើម្បីអោយធនធានប្រេង និងឧស្ម័ន ដ៏មានតម្លៃនេះត្រូវបានយកទៅប្រើប្រាស់ជាប្រយោជន៍សាធារណៈទៅតាមលទ្ធភាព ដែលអាចធ្វើទៅបាន។

រីឯការលើកកម្ពស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ឃើញថា ចក្ខុវិស័យលើវិស័យនេះ គឺទាមទារ អោយមានវិនិយោគខ្ពស់ និងរយៈពេលវែងមួយ ដើម្បីកសាងមូលដ្ឋាននៃហេដ្ឋារចនាសម្ព័ន្ធ នៃប្រព័ន្ធ ទូរគមនាគមន៍ទាំងឡាយ ជាពិសេសខ្សែកាបអុបទិច ដែលអាចប្រើប្រាស់បានល្បឿនខ្ពស់ ក្នុងការរៀបចំប្រព័ន្ធ គមនាគមន៍ ទាំងឡាយនៅជនបទ។ បញ្ហាប្រឈមមុខបន្ទាន់ គឺការបញ្ចុះថ្លៃបច្ចុប្បន្នវិស័យគមនាគមន៍ និង ព័ត៌មានវិទ្យាត្រូវដាក់អោយដំណើរការ សម្រាប់ធ្វើអោយប្រសើរឡើងនៃស្ថានភាពរស់នៅរបស់អ្នកក្រីក្រ តាមរយៈ ការបន្ទាបតម្លៃសេវាកម្មទូរគមនាគមន៍អោយបានឆាប់រហ័ស ការពង្រីបណ្តាញទាំងឡាយនៅក្នុងតំបន់ទីប្រជុំជន ធំៗ តូចៗ និងជនបទ ការពង្រឹងសេវាប្រៃសណីយ៍ តំបន់ទីក្រុង ទីប្រជុំជនដល់តំបន់ជនបទ ប្រកបដោយគុណ ភាពមានតម្លៃថោកសមរម្យ និងពង្រីកសមត្ថភាពស្ថាប័នគ្រប់គ្រងការពង្រីក និងធ្វើអោយប្រសើរឡើងនូវវិសាល ភាពប្រសិទ្ធភាព និងតុល្យភាពនៃការផ្សព្វផ្សាយរបស់រដ្ឋមានវិទ្យុ ទូរទស្សន៍ និងភ្នាក់ងារសារព័ត៌មាន ដែលផ្នែក ទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាដំណឹងការអប់រំ ព្រឹត្តិការណ៍សំខាន់ដែលបានកើតឡើងនៅក្នុង ប្រទេស និងលើពិភពលោក។ ហើយបន្តអនុវត្តគោលនយោបាយបើកទូលាយ ក្នុងការជំរុញការចូលរួមផ្នែកឯកជន។ ទាក់ទងនឹងវិស័យនេះដែរ គ្រប់ក្រសួង និងស្ថាប័នទាំងអស់ត្រូវជំរុញអោយមានការបង្កើតគេហទំព័រផ្ទាល់ខ្លួន ហើយកែលម្អអោយទាន់ពេលវេលាក្នុង ៦ខែម្តង ឬញឹកញាប់ទៅតាមតម្រូវការចាំបាច់។ គេហទំព័រនេះ និងមាន ផ្ទុកនូវទិន្នន័យ និងព័ត៌មានទាំងអស់ដែលមានការទាក់ទងទៅនឹងក្រសួង និងស្ថាប័នទាំងនោះ។

ចំពោះការអភិវឌ្ឍន៍ជនបទ និងវិមជ្ឈការអាចធ្វើទៅបានផ្អែកលើការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលបានយល់ឃើញយ៉ាងច្បាស់ថា កិច្ចការពង្រឹងសមត្ថភាពរបស់ស្ថាប័ន គឺជាគន្លឹះនៃការអភិវឌ្ឍន៍។ រដ្ឋបាលសាធារណៈត្រូវមានលក្ខណៈអព្យាក្រិត្យ តម្លាភាព និងការទទួលខុសត្រូវខ្ពស់។ មូលដ្ឋាននៃគោលដៅ នេះ រាជរដ្ឋាភិបាល និងការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋប្រកបដោយ គុណភាព និងប្រសិទ្ធភាពលើសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់រដ្ឋ(ឧទាហរណ៍: ការផ្តល់អត្រានុកូលដ្ឋាន ប័ណ្ណកម្មសិទ្ធិលើដីធ្លី និងលិខិតអនុញ្ញាតផ្សេងៗ) សេវាកម្មពាក់ព័ន្ធនឹងការវិនិយោគសេវាមូលដ្ឋាន និងសៀវភៅ ពាក់ព័ន្ធ និងចំណូលចំណាយរបស់រដ្ឋ។ រាជរដ្ឋាភិបាលបានចាត់ទុកការអនុវត្តន៍កម្មវិធីវិមជ្ឈការថ្នាក់ ឃុំ/សង្កាត់ ថា ជាគន្លឹះសម្រាប់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានលើកកម្ពស់គុណភាពសេវាសាធារណៈ និងជំរុញកិច្ចការ អភិវឌ្ឍន៍គ្រប់ផ្នែកនៅមូលដ្ឋាន ដោយមានការចូលរួមពីសំណាក់មូលដ្ឋានខ្លួនឯងផ្ទាល់។ អាទិភាពចម្បងក្នុងវិស័យ នេះ គឺជាការកសាងសមត្ថភាពគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន និងការផ្តល់ប្រភពធនធានហិរញ្ញវត្ថុសមស្រប ព្រម

ទាំងការលើកស្ទួយវប្បធម៌ចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចការទាំងនោះ។ រាជរដ្ឋាភិបាលបានលើកឡើងនូវយុទ្ធសាស្ត្រខាងលើនេះដោយឈរលើមូលដ្ឋាននៃការអភិវឌ្ឍន៍ជនបទពីក្រោមឡើងចម្រុះ ដោយមានការចូលរួមយ៉ាងទូលំទូលាយ និងដោយឈរលើគោលការណ៍វិមជ្ឈការ។ គោលដៅសំខាន់ គឺត្រូវពង្រឹកចំនួនគណៈកម្មការអភិវឌ្ឍន៍ភូមិ ដែលត្រូវបានបោះឆ្នោតជ្រើសរើស ដើម្បីជាតំណាងភូមិជំនួសមុខអោយរាជរដ្ឋាភិបាល អង្គការ-អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ភូមិ[១៥១]។ ប្រការនេះនឹងអនុញ្ញាតអោយសហគមន៍ចូលរួមយ៉ាងសកម្មនៅក្នុងស្ថាប័នមូលដ្ឋាន និងបង្កើនភាពជាម្ចាស់នៃគម្រោងការអភិវឌ្ឍន៍ដោយផ្តល់អោយបុគ្គលម្នាក់ៗគ្រួសារ និងសហគន៍នីមួយៗនូវសិទ្ធិក្នុងការធ្វើសេចក្តីសម្រេច និងដោយធានានូវគណនេយ្យភាព។ ការកែទម្រង់ស្ថាប័ន និងគោលនយោបាយកំពុងតែទទួលបានការគាំទ្រដោយការវិនិយោគសាធារណៈជាយុទ្ធសាស្ត្រ ដោយរួមបញ្ចូលនូវការផ្តង់ផ្តង់ដល់ភូមិ និងផ្លូវលំជនបទ ដើម្បីគាំទ្រដល់ការស្ថាបនាឡើងវិញ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធជនបទដ៏មានសារៈសំខាន់នេះ និងដើម្បីបង្កើតការងារនៅជនបទ។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពទៅលើការបង្កើនចំណូលជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីរក្សានូវសន្តេប្រវេសន៍ប្រជាជនពីជនបទទៅទីក្រុងអោយស្ថិតនៅត្រឹមកម្រិតមួយ ដែលអាចគ្រប់គ្រងបាន។

ចំណុចសំខាន់មួយទៀត គឺការអនុវត្តន៍គោលនយោបាយដីធ្លី យើងទាំងអស់គ្នាសុទ្ធតែបានដឹងហើយថា គោលនយោបាយដីធ្លីនឹងផ្តោតទៅលើការបែងចែកដីធ្លី ការរៀបចំដីធ្លី និងរដ្ឋបាលដីធ្លី។ កម្មវិធីស្នូលនៃគោលនយោបាយដីធ្លីរួមមាន ការអភិវឌ្ឍន៍គោលនយោបាយដីធ្លីជាតិមួយ ការកែលម្អការគ្រប់គ្រងដីរបស់រដ្ឋ ការចាប់ផ្តើមចុះបញ្ជីដីធ្លីជាប្រព័ន្ធ កាបង្កើតប្រកខ័ណ្ឌគតិយុត្ត ដើម្បីពង្រឹងសិទ្ធិលើទ្រព្យសម្បត្តិ ការបង្កើតនូវផែនការប្លង់មេ និងការកំណត់តំបន់សម្រាប់ថ្នាក់ខេត្ត/ក្រុង និងថ្នាក់ជាតិ និងអភិវឌ្ឍន៍លំនៅឋានជនបទ។ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង រាជរដ្ឋាភិបាលកម្ពុជានឹងដោះស្រាយបញ្ហាទាំងនេះតាមរយៈការអនុម័ត និងការអនុវត្តន៍ច្បាប់ភូមិបាលថ្មី ក៏ជាការអនុវត្តន៍ការងារចុះបញ្ជីដីធ្លីជាប្រព័ន្ធក្នុងកម្រិតជាតិ និងការការពារសម្បត្តិរដ្ឋ។ ចាត់ថ្នាក់ការប្រើប្រាស់ដីធ្លីមានសារៈសំខាន់សម្រាប់ធ្វើការកំណត់ព្រំប្រទល់ប្រភេទដីផ្សេងៗដូចជា ដីព្រៃ ទ្រព្យរដ្ឋដាអចិន្ត្រៃយ៍ ទ្បូតិ៍នេសាទ និងដីកសិកម្មផ្សេងទៀត ដែលអាចជួយអោយជនក្រីក្រអាចទទួលបានដីធ្លី និងកែលម្អការកាន់កាប់ដីធ្លី និងនេសាទជាប្រពៃណី។

សិក្ខាសាលាស្តីពីការគ្មានដីធ្លីត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងខែសីហា ឆ្នាំ២០០កន្លងទៅនេះ ដើម្បីកំណត់ចំនួនប្រជាជនដែលគ្មានដីធ្លី និងមូលហេតុដែលបណ្តាលអោយបាត់បង់ដីធ្លី និងបានរៀបចំគោលនយោបាយដែលពាក់ព័ន្ធនឹងបញ្ហាដ៏សំខាន់នេះ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវវិធានការដូចខាងក្រោម ដើម្បីស្វែងរកនូវដំណោះស្រាយចំពោះបញ្ហាស្មុគស្មាញនេះ : ១-ធ្វើការសិក្សាស្រាវជ្រាវអោយបានហ្មត់ចត់អំពីលទ្ធភាពចូលទៅកាន់កាប់ដីធ្លី ភាពក្រីក្រ

[១៥១] ក្រសួងផែនការៈ របាយការណ៍ឆ្នាំ១៩៩៩ ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា "សេដ្ឋកិច្ចភូមិ និងការអភិវឌ្ឍន"

និងភាពងាយទទួលរងគ្រោះ ដើម្បីមានមូលដ្ឋានធ្វើកំណែទម្រង់គោលនយោបាយ។ ២-កំណត់នូវក្រុមដែលគ្មានដី និងក្រុមដែលមានដីគ្រប់គ្រាន់នៅថ្នាក់ស្រុក និងខេត្ត ដើម្បីធ្វើអោយពួកគេអាចទទួលការយកចិត្តទុកដាក់កាន់តែមានប្រសិទ្ធភាព។ ៣-ហ្វឹកហ្វឺនអាជ្ញាធរខេត្ត និងមូលដ្ឋាន ដើម្បីរៀបចំផែនទីធនធានដី និងឯកសារនៃការរៀបចំផែនការផ្សេងៗទៀត ដែលអាចផ្តល់ទិន្នន័យសំខាន់ៗដល់ការគ្រប់គ្រងធនធានដីនៅក្នុងតំបន់នីមួយៗអោយកាន់តែមានប្រសិទ្ធភាពខ្ពស់ និងផ្តល់លទ្ធភាពអោយមានការត្រួតពិនិត្យជាប្រព័ន្ធនូវសភាពការដីធ្លី និងស្ថានភាពដីធ្លីរបស់ពលរដ្ឋក្រីក្រ និងដែលងាយរងគ្រោះ។ ៤-ចាត់វិធានការ ដើម្បីធានាថា សហគមន៍ដែលបានបង្កើតឡើងនៅមូលដ្ឋានអាចប្រើប្រាស់ទៅតាមទម្លាប់របស់គេនូវធនធានដែលជាសម្បត្តិរួម(ដីធ្លី ព្រៃឈើ និងផ្លូវទឹក) និងមិនត្រូវបានដណ្តើមដោយក្រុមថ្មីទៀត។ ៥-ពិនិត្យឡើងវិញនូវគោលនយោបាយផ្តល់ដីធ្លីដែលបានដោះមីនហើយ ដោយផ្តល់អាទិភាពចំពោះជនភៀសសឹក អតីតយុទ្ធជន និងក្រុមក្រីក្រដទៃទៀត។ ៦-ធានាសុវត្ថិភាព នៃការកាន់កាប់ដីចំពោះកសិករ តាមរយៈការលម្អការកែចំណុចខ្សោយបច្ចុប្បន្ននៃការចាត់ចែងដីធ្លី និងលើច្បាប់ភូមិបាល។ ៧-ចាប់ផ្តើមកម្មវិធី ដែលមានគោលដៅបង្កើតលទ្ធភាពចូលទៅកាន់កាប់ដីធ្លី និងបង្កើតការផ្តល់ប័ណ្ណដីធ្លីដល់ម្ចាស់ដី និងអ្នកកាន់កាប់ដីតូចតាច។ ៨-ពិនិត្យឡើងវិញ នូវកម្មវិធីជួយចំពោះជនភៀសសឹក និងអ្នកធ្វើមាតុភូមិនិវត្តន៍ ដើម្បីរៀនសូត្រជាបទពិសោធន៍នាពេលកន្លងទៅ ជាពិសេស ពាក់ព័ន្ធទៅនឹងការបែងចែក និងការផ្តល់នូវដីធ្លី។ ៩-ការកែលម្អលទ្ធភាពអាចមាន និងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងៗទៀតសម្រាប់ក្រុមជនងាយរងគ្រោះនៅភ្នំពេញ និងទីក្រុងផ្សេងៗទៀត ដោយផ្តល់អាទិភាពដល់តំបន់តោកយ៉ាកនៃសំណង់បណ្តោះអាសន្ន។ ១០-ធ្វើការសិក្សាត្រួតពិនិត្យ ដើម្បីកំណត់ថា បញ្ហាភេទអាចប៉ះពាល់ដូចម្តេចខ្លះ នៅក្នុងគោលនយោបាយដីធ្លី និងប្រព័ន្ធចុះបញ្ជីដីធ្លី ការទទួលមរតកដីធ្លី ភាពជាម្ចាស់ដីធ្លី ដែលកើតឡើងពីអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិដីធ្លី ដែលជាលទ្ធផលនៃជម្លោះរវាងប្តី និងប្រព័ន្ធ។

៤.៣.៤ បណ្តុះឆន្ទៈអោយមានការចងក្រងជាសហគមន៍កសិករ និងការអភិវឌ្ឍន៍

ការចងក្រងជាសហគមន៍ គឺជាដំណើរការមួយដែលត្រូវបានរៀបចំឡើងដោយសមាជិក នៅក្នុងសហគមន៍ ហើយការបង្កើតជាសហគមន៍នេះសោតមិនត្រឹមតែជាដំណើរការ ដែលអាចផ្តល់អោយប្រជាជនក្នុងសហគមន៍ទទួលបានការងារប្រាក់ចំណូល ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តប៉ុណ្ណោះទេ ថែមទាំងជួយអោយសហគន៍មានមូលដ្ឋានគ្រឹះក្នុងការគ្រប់គ្រងធនធានរបស់ខ្លួនទៅនឹងការផ្លាស់ប្តូរបរិស្ថានទៀតផង។

ដើម្បីទទួលបាននូវផែលប្រយោជន៍ដ៏ជាក់លាក់ពីការអភិវឌ្ឍន៍សហគមន៍ វាទាមទារអោយមានការចូលរួម និងសហការគ្នាពីសមាជិកក្នុងសហគមន៍នោះផ្ទាល់ ដូចជា ការចេះផ្លាស់ប្តូរអត្តចរិករបស់ខ្លួន ការធ្វើបន្ទាស់ប្តូរជំនាញដែលមានស្រាប់ ការលើកកម្ពស់បណ្តាញការងារ ការស្វែងរកវិធីសាស្ត្រផ្សេងៗ ដើម្បីដោះស្រាយបញ្ហា និងការចេះប្រើប្រាស់អចលនទ្រព្យក្នុងសហគមន៍ប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តគោលការណ៍ខាងលើនេះអាចធ្វើអោយការអភិវឌ្ឍន៍សហគន៍ កាន់តែមានភាពរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ច និងមានមុខងាររឹងមាំ។

សហគមន៍សំដៅទៅលើក្រុមមនុស្ស ដែលមានអត្តសញ្ញាណដូចគ្នា ឬក៏ប្រហាក់ប្រហែលគ្នា។ ដូច្នេះ ហើយបានជាការអភិវឌ្ឍន៍សហគមន៍ត្រូវតែពឹងផ្អែកទៅលើការទំនាក់ទំនងរវាងមនុស្ស និងការចូលរួមសកម្មភាពរបស់មនុស្ស ដែលជាសមាជិកក្នុងសហគមន៍។ ការចងក្រងជាសហគមន៍ គឺជាដំណើរដែលអាចធ្វើអោយគេបង្កើតនូវជម្រើសក្នុងជីវិត។ នៅទីនេះខ្ញុំចង់និយាយថា ជាជម្រើសថ្មីមួយ ក្នុងការផ្តល់នូវភាពសំបូរបែប ការគិតរកនូវវិធីសាស្ត្រផ្សេងៗក្នុងការដោះស្រាយបញ្ហាជាក់ស្តែង និងការយល់ដឹងនៅពេលខាងមុខ ដើម្បីធ្វើការផ្លាស់ប្តូរទម្លាប់ចាស់ បង្កើតទម្លាប់ថ្មី ដែលផ្តល់អត្ថប្រយោជន៍ច្រើនដល់ជីវិតសមាជិកសហគមន៍ទាំងអស់។

ការចងក្រងជាសហគមន៍ និងការអភិវឌ្ឍន៍វាទាក់ទងទៅនឹងការផ្លាស់ប្តូរការធ្វើអោយរីកចម្រើន ហើយនឹងសមត្ថភាព ដែលអាចធ្វើអោយជីវភាពនៃការរស់នៅ ប្រកបដោយនិរន្តរភាពតាមរយៈការខិតខំប្រឹងប្រែងដោយផ្ទាល់ ដើម្បីលើកកម្ពស់អោយមានការចូលរួម ការចេះបត់បែនតាមកាលៈទេសៈសមត្ថភាពក្នុងសង្គម អត្តចរិតប្រពៃពីមុខងាររបស់ស្ថាប័នផ្សេងៗ និងគុណភាពនៃជីវិត។ និយាយអោយខ្លីទៅ គឺជាការបង្កើតនូវទ្រព្យសម្បត្តិក្នុងន័យនេះសំដៅទៅលើរបស់អ្វីដែលមនុស្សអោយតម្លៃ។

ខាងក្រោមនេះ ជានិយមន័យផ្សេងៗដែលកំណត់ដោយអ្នកសិក្សាផ្សេងៗគ្នា:

-ការអភិវឌ្ឍន៍សហគមន៍ កើតឡើងនៅពេលណាដែលក្រុមមនុស្សក្នុងសហគមន៍ មានការជឿជាក់នៅក្នុងការធ្វើការងាររួមគ្នា ដែលអាចអោយពួកគេទទួលបាននូវជម្រើសផ្សេងៗ និងអាចរៀបចំចាត់ចែងនូវអ្វីដែលជាតម្រូវការរួមរបស់ពួកគេ(ទស្សនៈរបស់ Flora, 1992)។

-ការអភិវឌ្ឍន៍សហគមន៍ សំដៅទៅលើក្រុមមនុស្សក្នុងសហគមន៍ ដែលអាចឈានទៅដល់ការធ្វើសេចក្តីសម្រេចចិត្តដំបូងទៅលើដំណើរការសកម្មភាពសង្គម ដើម្បីផ្លាស់ប្តូរនៅស្ថានភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ដែលគេរស់នៅ(ទស្សនៈរបស់ Christenson, 1989)។

-ការអភិវឌ្ឍន៍សហគមន៍ គឺជាដំណើរការបង្កើនជម្រើសច្រើន(ទស្សនៈរបស់ Ron Shaffer, pers.com).

-ការអភិវឌ្ឍន៍សហគមន៍ គឺជាដំណើរការចងក្រងប្រមូលផ្តុំរវាងប្រជាពលរដ្ឋ ជាមួយអាជ្ញាធរដែនដី ដើម្បីលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចសង្គម និងវប្បធម៌(ទស្សនៈរបស់ United Nattions, 1999)។

-ការអភិវឌ្ឍន៍សហគមន៍ ត្រូវតែមានឥទ្ធិពលចូលរួមនៃការប្តេជ្ញាចិត្តរបស់សហគមន៍ នៅក្នុងការប្រើប្រាស់ធនធាន និងជំនាញផ្សេងៗអោយមានប្រសិទ្ធភាព ដើម្បីកសាងភាពរឹងមាំរបស់សហគមន៍ និងស្វែងរកបញ្ហាឱកាស(ទស្សនៈរបស់ Aspen Institute, 2000)។

ដើម្បីធ្វើការចងក្រង និងការអភិវឌ្ឍន៍សហគមន៍មួយប្រកបដោយប្រសិទ្ធភាព ខាងក្រោមនេះជាគោលការណ៍មួយចំនួន ដែលត្រូវពិចារណាលើគោលការណ៍ដូចជា: ត្រូវធ្វើការចាប់ផ្តើមពីចំណុចកសិករយកចិត្តទុកដាក់។ ការអភិវឌ្ឍន៍សហគមន៍អោយកសិករខិតខំប្រឹងប្រែងធ្វើការងារ ដែលកសិករចង់ធ្វើ ហើយជម្រុញអោយមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់របស់កសិករ ដឹកនាំនូវសកម្មភាព ដូចជា ជំនឿ ការលើកទឹកចិត្ត និងការប្តេជ្ញាចិត្តរបស់កសិករ គឺជាប្រេងរំអិលក្នុងការអភិវឌ្ឍន៍សហគមន៍។ ហើយត្រូវប្រកាន់ភាពជាម្ចាស់លើសហ-

គមន៍កក្នុងការធ្វើសេចក្តីសម្រេចចិត្តអនុវត្តការងារ និងដឹកនាំសហគមន៍ គឺជាប្រភពនៃការផ្លាស់ប្តូរ។ រីឯការចូលរួម និងការទំនាក់ទំនង យ៉ាងសកម្មក្នុងការធ្វើ និងការអនុវត្តន៍សេចក្តីសម្រេចចិត្ត ស្ថាបនានូវការលើកទឹកចិត្ត និងលើកកម្ពស់សមត្ថភាពសហគមន៍។ ព្រមទាំងការផ្តល់ឱកាសស្មើៗគ្នានៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការចូលរួម សហគមន៍។

ចំណែកឯមនុស្សខាងក្រៅសហគមន៍ដូចជា អ្នកសម្របសម្រួល និងធនធានមនុស្សត្រូវបានគេអញ្ជើញមកធ្វើការជាមួយកសិករ និងផ្តល់ជាសំណើរ ឬអនុសាសន៍ដល់កសិករ វាប្រសើរជាជាងអោយអ្នកទាំងនោះធ្វើការអោយកសិករក្នុងការផ្តល់សេវាកម្មបម្រើអោយកសិករ និងសម្រេចចិត្តជួយកសិករ។ ចំណុចសំខាន់មួយទៀតនោះ គឺការអភិវឌ្ឍន៍សកម្មភាពផ្សេងៗ លើកទឹកចិត្តដល់កសិករអោយមានភាពដឹកនាំ និងសហគ្រិនភាព។ ចំពោះអ្វីដែលសមត្ថភាពពីមុនរបស់កសិករ និងសហគមន៍របស់គាត់រស់នៅត្រូវតែបានគេទទួលស្គាល់ និងអោយតម្លៃ ដើម្បីបង្កើនឱកាសអោយពួកគាត់កសាងសមត្ថភាពបន្តទៀតអោយកាន់តែប្រសើរ។

ចំពោះទស្សនៈស្ថានភាពសេដ្ឋកិច្ចធនធានមនុស្ស និងបរិស្ថានរបស់សហគមន៍មានទំនាក់ទំនងគ្នាទៅវិញទៅមក ព្រមទាំងបង្កើតគម្រោងថ្មី ការអភិវឌ្ឍន៍សហគមន៍ជួយអោយកសិករកំណត់សាជាថ្មី នូវបញ្ហាដែលត្រូវប្រឈម និងឱកាសដើម្បីរុករកនូវជម្រើសថ្មីៗ ដើម្បីអោយមានការផ្លាស់ប្តូរអត្តចរិក និងប្រព័ន្ធការងារពិតជាមានសារៈសំខាន់ណាស់។ រីឯគំនិត និងទស្សនៈរបស់អ្នករាល់គ្នាត្រូវបានគេស្វាគមន៍ជានិច្ច ព្រោះជាមូលដ្ឋាននៃភាពជោគជ័យ ទោះបីជាមានទំហំតូចក៏ដោយ វាត្រូវតែបានគេទទួលយក និងអបអរសាទរផ្តល់នូវភាពរីករាយ និងបើកចំហរ។

គន្លឹះដើម្បីអភិវឌ្ឍន៍សហគមន៍ នឹងជួយសម្រួលសហគមន៍អោយឆ្លើយតបទៅនឹងគោលការណ៍អភិវឌ្ឍន៍ដែលគោលការណ៍នោះ ជួយដឹកនាំនូវរាល់សកម្មភាព ដ៏សមស្របសម្រាប់ស្ថានភាពជាក់ស្តែង របស់សហគមន៍ វាមានគម្រោង និងម៉ូដែលជាច្រើន ដែលបង្ហាញពីដំណើរការអភិវឌ្ឍន៍សហគមន៍ ហើយវាក៏មានភាពខុសគ្នាផងដែរ រវាងសហគមន៍ ដែលមានគម្រោងពេលអនាគតច្បាស់លាស់ និងសហគន៍ដែលពុំមានគម្រោងអភិវឌ្ឍន៍ច្បាស់លាស់ តែអាចបត់បែនតាមកាលៈទេសៈនៅពេលដែលមានបញ្ហាប្រឈមនៅពេលខាងមុខ។

ជំហានសម្រាប់ដំណើរការអភិវឌ្ឍន៍សហគមន៍ មានអត្ថប្រយោជន៍ក្នុងការអភិវឌ្ឍន៍សហគមន៍ប្រកបដោយប្រសិទ្ធភាព ប៉ុន្តែមិនមានន័យថា សហគមន៍មានអត្ថប្រយោជន៍ក្នុងការអភិវឌ្ឍន៍សហគមន៍ទាំងអស់ត្រូវតែដើរតាមជំហាននោះទេ ពោលគឺវាអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងរបស់សហគមន៍នោះថាតើចំណុចណាខ្លះនៃជំហានសម្រាប់ដំណើរការអភិវឌ្ឍន៍សមស្របទៅនឹងសហគមន៍នេះ។ ក្នុងខណៈពេលសហគមន៍ចាប់ផ្តើមដំណើរការរៀបចំមានសំណួរមួយចំនួន មានសារៈសំខាន់ចំពោះសហគមន៍ ដើម្បីធ្វើការឆ្លើយតប:

តើយើងស្ថិតនៅកន្លែងណា? តើយើងចង់អោយសហគមន៍ទៅជាយ៉ាងណា? តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីទៅដល់ចំណុចនោះ? ហើយ តើនរណាអាចជួយយើងបាន?

សំណួរទាំងអស់នេះបានផ្តល់នូវគ្រោងឆ្អឹងសម្រាប់ដំណើរការចងក្រង និងអភិវឌ្ឍន៍សហគមន៍។ វាជាការលំបាកណាស់នៅក្នុងការឆ្លើយតបសំណួរទាំងនេះ ពីព្រោះសំណង់ប្រយោគនៃចម្លើយទាំងអស់មានអត្ថន័យទូលំទូលាយបង្ហាញពីអ្វីដែលកសិករយល់ឃើញថា មានសារៈសំខាន់ចំពោះសហគមន៍របស់ពួកគេ។ ដូច្នេះចម្លើយនៃសំណួរទាំងនេះ ជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍន៍សហគមន៍។

ចំពោះសំណួរមួយទៀត ដែលគេនិយមចោទសួរគឺ "តើអ្វីជាការព្រួយបារម្ភរបស់អ្នក?" ។ ការព្រួយបារម្ភរបស់កសិកររធ្វើអោយកសិករមានកម្លាំងចិត្ត និងខិតខំប្រឹងប្រែងធ្វើការ។ ជាការសំខាន់ណាស់ ចំពោះកសិករដើម្បីធ្វើការជ្រើសរើសនូវសកម្មភាពនានា ដើម្បីអភិវឌ្ឍន៍សហគមន៍ នៅពេលដែលកសិករខ្លួនឯងដឹងពីការព្រួយបារម្ភ និងការយកចិត្តទុកដាក់របស់ខ្លួន[១៥២]។

ក្រោយពីការចោទឡើងនូវសំណួរមួយចំនួនទៅកាន់សហគមន៍ ក៏ដូចជា សមាជិករបស់សហគមន៍រួមមក គេទាមទារត្រូវតែរៀបចំផែនការ ដើម្បីឆ្លើយតបនូវបញ្ហាទាំងនោះ។ ប៉ុន្តែ ដើម្បីអោយការផ្ទេរផែនការល្អ គេត្រូវកំណត់ពីគោលដៅ និងគោលបំណងជាក់លាក់ ព្រោះទាំងនេះជាមូលដ្ឋាននៃសកម្មភាពការងារទាំងអស់ដែលគេត្រូវអនុវត្ត។ ម្យ៉ាងវាប្រាប់ពីអ្វីដែលអ្នកអភិវឌ្ឍន៍ត្រូវតែធ្វើ និងតើត្រូវធ្វើយ៉ាងដូម្តេច ដើម្បីសម្រេចនូវគោលបំណង។

គោលដៅ គឺជាឃ្លា ដែលបង្ហាញនូវទស្សនៈដ៏ទូលំទូលាយ ប៉ុន្តែ វាមានគោលបំណងជាក់លាក់។ គោលដៅបញ្ជាក់ពីក្តីសង្ឃឹមនៃក្រុមមនុស្ស ដែលត្រូវសម្រេចនៅក្នុងស្ថានភាព និងពេលវេលាកំណត់មួយ។ វាជាសំដីទូទៅដែលគេច្រើនប្រើ ដើម្បីបញ្ជាក់ពីបំណងរយៈពេលយូរដែលអាចអោយគេសម្រេចបាន។

ចំណែកគោលបំណងវិញ ត្រូវតែមានលក្ខណៈច្បាស់លាស់ អាចវាស់បាន អាចទទួលបានជោគជ័យ អាចជឿជាក់ និងមានរយៈពេលកំណត់ច្បាស់លាស់ ហើយជាពិសេស គឺត្រូវបំពេញនូវលក្ខណៈ SMART (Specific, Measurabel, Achievable, Reliable និង Time bound) ។

វាជាសំដីដែលគេនិយាយកំណត់ជាក់លាក់ ទៅលើសមិទ្ធផល ដែលក្រុមមនុស្សតាំងចិត្តសម្រេចអោយបានតាមរយៈសកម្មភាពការងារនៅក្នុងគម្រោងនីមួយៗ។ បន្ទាប់ពីចំណុចខាងលើយ យើងត្រូវធ្វើកិច្ចការអង្កេតចាំបាច់ដែលការអង្កេតដោយខ្លួនឯង(Sefl Examination) : ការអង្កេតដោយខ្លួនឯងអាចមានទម្រង់ច្រើនយ៉ាងដូចជា:

១-សិក្សារពីគម្រោង និងការជោគជ័យពីមុនមក និងពិនិត្យមើលអំពីមធ្យោបាយពីមុនមក ដែលធ្លាប់ដោះស្រាយទៅលើបញ្ហានោះ។ ២-កត់ត្រាអំពីអចលនទ្រព្យរបស់សហគមន៍ និងគូសផែនទីទំនាក់ទំនងការយល់ឃើញខុសៗគ្នា ទៅលើសហគមន៍រវាងមនុស្សចាស់ យុវវ័យ ក្រុមសហគមន៍ និងអាជ្ញាធរដែនដីដ។ ៣-ការអង្កេតពីសហគមន៍ និងត្រួតពិនិត្យជំនាញ។ ៤- ការវិភាគ SWOT ត្រូវកត់នូវចំណុចខ្លាំង ចំណុចខ្សោយរបស់

[១៥២] Shaffer, 1989 និង Kenyon, 1994

សហគមន៍ ឱកាស និងការគំរាមកំហែងទៅលើសហគមន៍។ ៥-សមាជិកនៅក្នុងសហគមន៍ត្រូវតែមានរូបភាពដែលបង្ហាញពីការដែលគេចង់អោយសហគមន៍របស់ពួកគេទៅជាយ៉ាងដូចម្តេច និងមិនចង់អោយទៅជាយ៉ាងដូម្តេច។ ៦-និន្នាការប្រមូលព័ត៌មានតាមផ្នែកមានឥទ្ធិពលទៅលើសហគមន៍ ដូចជា និន្នការលើទីផ្សារកសិករ និងមានការផ្លាស់ប្តូរខាងផ្នែកប្រជារាស្ត្រ។

២-បន្ថែមលើគំនិតនៃការអង្កេតដោយខ្លួនឯងខាងលើ ជាការចំបាច់ត្រូវផ្តោតលើចំណុចសំខាន់មួយទៀតគឺ ការរុករក(Exporation) : ដំណាក់កាលនៃការរុករកតែងតែអមជាមួយការអង្កេតដោយខ្លួនឯង។ នេះមានទំនាក់ទំនងទៅនឹងការប្រមូលព័ត៌មាន និងគំនិតថ្មីៗ។ ខាងក្រោមនេះ គឺរបៀបក្នុងការរុករកបញ្ហា:

-ការវិភាគលើកត្តាខាងក្រៅ (Environmental Scan) : ការក្រឡេកមើលមុខអំពីកត្តាខាងក្រោ ដែលអាចជះឥទ្ធិពលទៅលើសហគមន៍ ដូចជា ការផ្លាស់ប្តូរច្បាប់សង្គម ឬការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចជាដើម។

-បន្លាស់ប្តូរវាងសហគមន៍(Community Swaps) ដែលជាសមាជិកនៅក្នុងសហគមន៍មួយទៅធ្វើទស្សនៈកិច្ចលើសហគមន៍មួយទៀត តាមរយៈការចូលរួមសិក្ខាសាលា ដើម្បីរៀនផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

-ទីប្រឹក្សា និងដំបូន្មានរបស់អ្នជំនាញ

-ការបំផុសគំនិត(Brainstorming) : ការលើកឡើងនូវគំនិតជាច្រើន ដែលមានភាពច្បាស់លាស់

-ការគិតសារឡើងវិញ និងការអនុវត្តប្រកបដោយភាពច្នៃប្រឌិត។

បន្ថែមលើគំនិតនៃការរុករកដោយខ្លួនឯងខាងលើ ជាការចំបាច់ ត្រូវផ្តោតលើចំណុចសំខាន់មួយទៀតគឺការបកស្រាយ និងការកំណត់ចំណុចអាទិភាព(Interpretation and Prioritization) : ទិន្នន័យ ដែលត្រូវបានប្រមូល និងគំនិតដែលត្រូវបានកែលម្អតាមរយៈ ការអង្កេត និងរុករកដោយខ្លួនឯង(Sefl Examination) ត្រូវបានគេយកមកវិភាគ និងធ្វើការពិភាក្សាតទល់ ដើម្បីស្វែងរកចំណុចជាអាទិភាព និងដើម្បីអោយគេអាចរៀបចំដាក់សកម្មភាពអោយចំគោលដៅ នៃចំណុចអាទិភាព។

ដើម្បីកំណត់ចំណុចអាទិភាពវាមានទម្រង់យ៉ាងហោចណាស់ពីរគឺៈ ទី១-អាទិភាពដោយផ្អែកលើហេតុផល(Rational Prioritization) : ជាដំណើរការទាក់ទងទៅនឹងការវិភាគទៅលើហេតុផល តាមរយៈការពិចារណាពីមតិគាំទ្រ(Pros)និងមតិបដិសេធ(Cons) និងសារៈសំខាន់របស់បញ្ហា។ ទី២-អាទិភាពដោយផ្អែកលើការលើកទឹកចិត្ត(Prioritization by Motivation) : ជាដំណើរការទាក់ទងទៅនឹងចំណាប់អារម្មណ៍ និងការលើកទឹកចិត្តចំពោះបុគ្គលទៅលើបញ្ហា។ វាសំខាន់ណាស់ បើយើងដឹងពីចំណាប់អារម្មណ៍ និងការព្រួយបារម្ភរបស់បុគ្គលទៅនឹងបញ្ហាជាក់លាក់ណាមួយ ព្រោះវាអាចអោយគេដាក់សកម្មភាពទៅលើបញ្ហានោះទទួលបានជោគជ័យដោយសារតែមានការចូលរួមយ៉ាងស្មាហាប់ពីបុគ្គលទាំងនោះ។

បន្ថែមលើគំនិតនៃការបកស្រាយ និងការកំណត់ចំណុចអាទិភាពដោយខ្លួនឯងខាងលើ ជាការចំបាច់ត្រូវផ្តោតលើចំណុចសំខាន់មួយទៀត គឺការរៀបចំផែនការ និងដាក់សកម្មភាពទៅលើចំណុចអាទិភាព

(Planning and Action on Priorities) : មានសកម្មភាពជាច្រើនត្រូវបានគេប្រើប្រាស់តាំងពីយូរយោរ ដូចជាប្រជាជនក្នុងតំបន់បានចូលរួមត្រួតពិនិត្យ សហគមន៍របស់ពួកគេរុករកគំនិតថ្មីៗជម្រើសល្អៗ និងជ្រើសរើសតែបញ្ហាណាដែលជាគន្លឹះ ដើម្បីយកមកដោះស្រាយ។ សមាជិកខ្លះនៅក្នុងសហគមន៍បានចូលរួមនៅក្នុងសកម្មភាពដោះស្រាយបញ្ហាដ៏ជាក់លាក់នោះតាំងតែពីដំបូង ហើយត្រង់ចំណុចនេះដែរ សមាជិកក្នុងសហគមន៍ទៅនឹងការអភិវឌ្ឍន៍នូវយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហាគោលដៅ ហើយយុទ្ធសាស្ត្រទាំងនេះ គឺជាគម្រោង និងទម្រង់នៃសកម្មភាព ការធ្វើសេចក្តីសម្រេចចិត្ត និងការបែងចែកធនធាន ដើម្បីអោយលទ្ធផលទទួលបានជោគជ័យ។ លំដាប់នៃសកម្មភាពទាំងនោះរួមបញ្ចូលប្រព័ន្ធការងារ ការសិក្សាពីសមត្ថភាពដែលអាចធ្វើទៅបាន របាយការណ៍ នៃភាពរីកចម្រើន ការប្រមូលទិន្នន័យជំនួស។ល។ ក្នុងយុទ្ធសាស្ត្រនីមួយៗមានសកម្មភាពជាច្រើន ដែលសកម្មភាពទាំងនោះមានជម្រើសយ៉ាងច្រើន ដែលត្រូវធ្វើការជ្រើសរើស។

បន្ទាប់ពីចំណុចខាងលើ យើងពិនិត្យលើដំហានថ្មីមួយទៀត គឺការវិនិយោគសារជាថ្មី(Reinvestment) : ការអភិវឌ្ឍន៍សហគមន៍គ្មានថ្ងៃបញ្ចប់ទេ វាចេះតែបន្តជានិច្ចមិនមែនតែប៉ុណ្ណោះទៀតសោត សហគមន៍មានតែពង្រីមូលដ្ឋាន និងសមត្ថភាពបុគ្គល ដើម្បីអាចគ្រប់គ្រងនឹងការផ្លាស់ប្តូរនេះ។ នេះមានន័យថា សហគមន៍នឹងបន្តការវិនិយោគសារជាថ្មី តាមរយៈពេលវេលា និងការខិតខំប្រឹងប្រែង ដើម្បីអោយមានអ្នកដឹកនាំថ្មី និងការលើកទឹកចិត្តដល់សហគមន៍។ សមត្ថភាព និងសកម្មភាពរបស់សហគមន៍នឹងបន្តជំរុញសហគមន៍ឈានទៅរកការខិតខំប្រឹងប្រែងនាពេលអនាគតខាងមុខតទៅទៀត។

ការអភិវឌ្ឍន៍សហគមន៍ ជាបញ្ហាសំខាន់ណាស់ចំពោះរដ្ឋាភិបាល ក៏ដូចជាអង្គការផ្សេងៗកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង ព្រោះថា វាអាចរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជាយើង។ សហគមន៍នេះ ត្រូវបានបង្កើតដោយមានការចូលរួមរបស់សមាជិកច្រើន ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធរួមគ្នា ដើម្បីបញ្ចេញមតិក្នុងការដោះស្រាយបញ្ហាដែលនៅចំពោះមុខ។ ម្យ៉ាងវិញទៀត វាមិនមែនជារឿងងាយស្រួលទេក្នុងការអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព វាទាមទារអោយមានការចូលរួមដោយការខិតខំប្រឹងប្រែងពីសមាជិកទាំងអស់ និងកត្តាខាងក្រៅទៀត។

មានកម្លាំងជម្រុញជាច្រើននៅក្នុងការធ្វើការងាររបស់សហគមន៍ប្រកបដោយភាពងាយស្រួល ប៉ុន្តែមានកម្លាំងតែ ៣គត់ ដែលគេយល់ថា មានសារៈសំខាន់ និងផ្តល់ភាពរីកចម្រើនក្នុងសហគមន៍ក្នុងរយៈពេលវែង។ កម្លាំងទាំង ៣ នោះផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច បរិស្ថាន និងសមធម៌។

រឯបញ្ហាសេដ្ឋកិច្ច(Economy) : សេដ្ឋកិច្ចជាកម្លាំងទី១ នៃសហគមន៍។ សេដ្ឋកិច្ច ជាការគ្រប់គ្រង និងការប្រើប្រាស់ធនធាន ដែលជាសេចក្តីត្រូវការរបស់គ្រួសារ និងសហគមន៍។ តាំងពីប្រវត្តិសាស្ត្រមកពាក្យថា "សេដ្ឋកិច្ច" សំដៅទៅលើការគ្រប់គ្រងគ្រួសារមួយ។ សេដ្ឋកិច្ច ជាការប្រើប្រាស់ធនធាអោយមានប្រសិទ្ធភាព និងដោយប្រុងប្រយ័ត្ន។ បើនិយាយពីសេដ្ឋកិច្ចតំបន់ ក៏ដូចជា សេដ្ឋកិច្ចគ្រួសារដែរ រួមបញ្ចូលទៅក្នុងសហគមន៍ទាំងមូល។ ជាក់ស្តែង ការគ្រប់គ្រងគ្រួសារទាក់ទងទៅនឹងថវិកា និងការធ្វើគម្រោងការប្រើប្រាស់ធនធានរបស់អ្នក

ដើម្បីអោយដឹងប្រាកដថា នៅក្នុងផ្ទះមានធនធានដូចជា អាហារ និងខោអាវគ្រប់គ្រាន់ និងមានភ្លើងអគ្គីសនី ប្រើប្រាស់ចាំបាច់។ ការគ្រប់គ្រងគ្រួសាររួមបញ្ចូលទាំងការរៀបចំក្មេងជំនាន់ក្រោយអោយមានលក្ខណៈឯករាជ្យម្ចាស់ការលើខ្លួនឯង និងមើលថែរក្មេង ដែលពួកគេមិនអាចថែរក្សាខ្លួរបស់ពួកគេបាន។

ចំណុចសំខាន់មួយទៀត គឺបរិស្ថាន(Ecology) : បរិស្ថានជាកម្លាំងមួយទៀត នៃសហគមនន៍។ វាមានទំនាក់ទំនងយ៉ាងជិតស្និទរវាងវត្តុមានជីវិត និងបរិស្ថានជុំវិញ។ យើងទាំងអស់គ្នាដឹងនូវបរិស្ថានខ្យល់ ដី និង ទឹក ដែលបានផ្គត់ផ្គង់នូវតម្រូវការរបស់យើង។ ដោយមានការប្រើប្រាស់នូវធនធានធម្មជាតិ និងការបង្កើតនូវកាកសំណល់នោះ រាល់សហគមន៍ទាំងអស់បានបន្សល់នូវកាកសំណល់ក្នុងបរិស្ថាន។ យើងត្រូវដឹងអោយបានច្បាស់ថា ស្នើរតែរាល់សកម្មភាពរបស់សហគមន៍ និងមនុស្សគ្រប់គ្នានឹងជះឥទ្ធិពលដល់បរិស្ថាន។ សហគមន៍ ដែលមានភាពរុងរឿងក្នុងរយៈពេលយូរត្រូវកត់សំគាល់នូវសកម្មភាពណាខ្លះ និងអាចរក្សា និងបង្កើនធនធានធម្មជាតិសម្រាប់មនុស្សជំនាន់ក្រោយក្នុងពេលអនាគត។ ទោះបីជាបញ្ហាបរិស្ថានសំខាន់ក៏ដោយ តែយើងក៏មិនអាចភ្លេចបញ្ហាសមធម៌បានដែរ ពីព្រោះសមធម៌ គឺជាកម្លាំងទីបីនៃសហគមន៍។ កម្លាំងទាំងនេះបង្ហាញពីភាពស្មោះត្រង់របស់សមាជិកទាំងអស់នៅក្នុងសហគមន៍។ ជាក់ស្តែង សមាជិករាល់គ្នានៅក្នុងសហគមន៍ចែករំលែកនូវសុខមាលភាពរបស់ពួកគេ។ ប្រសិនបើសហគមន៍ទទួលជោគជ័យពួកគេទទួលផលចំណេញ។ ប្រសិនបើសហគមន៍បរាជ័យវិញ នោះពួកគេក៏ចែករំលែកនូវការខាតបង់នោះដែរ។ នៅក្នុងសង្គមជាក់ស្តែង ករណីទាំងនេះកម្រនឹងកើតមានឡើងណាស់។ តាមធម្មតា មនុស្សខ្លះមានទ្រព្យសម្បត្តិយ៉ាងសន្ធឹកសន្ធាប់នៅពេលដំណាលគ្នា ដែលអ្នកឯទៀតក្រីក្រយ៉ាងខ្លាំង។ សមធម៌ ជាសេចក្តីស្មោះត្រង់ និងទំនាក់ទំនងរវាងសមាជិក និងសមាជិក ក្រុមនិងក្រុម និងពីមួយជំនាន់ទៅមួយជំនាន។ ទីណាក៏ដោយ មានសមធម៌សេចក្តីសម្រេចចិត្ត ផ្អែកទៅលើសេចក្តីស្មោះត្រង់ និងមនុស្សរាល់គ្នាមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរណ៌ ចំណូល ភេទ អាយុ ឬសមត្ថភាព។ ទាំងអស់នេះ ធ្វើអោយមនុស្សមានឱកាសបញ្ចេញនូវយោបល់ និងត្រូវគេផ្តល់នូវកិត្តិយសអោយ។

សរុបមកកម្លាំងទាំង ៣ សេដ្ឋកិច្ច បរិស្ថានវិទ្យា និងសមធម៌ ជាគំរូមួយសម្រាប់សហគមន៍ ដើម្បីពិនិត្យពិច្ច័យគ្រោងទុកជាមុននូវជម្រើសដ៏ល្អរបស់ពួកគេ ដែលនឹងអាចប៉ះពាល់នៅពេលអនាគតរបស់សហគមន៍។ សហគមន៍អាចប្រើប្រាស់នូវគម្រោងទាំងនេះ ដើម្បីពិភាក្សាពីនយោបាយ សេដ្ឋកិច្ចរបស់ពួកគេ ប៉ះពាល់យ៉ាងណាខ្លះដល់បរិស្ថានជាតិ និងពីការធ្វើអោយជីវភាពកាន់តែប្រសើរឡើង។

បន្ថែមលើគំនិតនៃការចងក្រងជាសហគមន៍បានសម្រេចហើយ នោះជំហានបន្ទាប់ជាការចាំបាច់ត្រូវផ្តោតលើចំណុចសំខាន់មួយទៀត គឺការអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព។

គោលបំណងការអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព គឺជាការកសាងសហគមន៍អោយមានសមត្ថភាពដោយធ្វើឡើងយ៉ាងណាអោយសហគមន៍នោះមានសុខមាលភាព និងភាពរុងរឿងក្នុងរយៈពេលដ៏យូរអង្វែង។ ទោះបីជាការពិបាកក្នុងការដឹងថា សហគមន៍មួយនឹងមាននិរន្តរភាពក្នុងពេលអនាគត យើងអាចគិតទៅលើលក្ខណៈសម្បត្តិនៃសហគមន៍ ដែលអាចទទួលជោគជ័យ។ លក្ខណៈបុគ្គលជួយយើងព្យាករណ៍នូវមនុស្សម្នាក់នឹងមាន

សកម្មភាពយ៉ាងដូចម្តេចក្នុងសកម្មភាពជាក់លាក់មួយ ក៏ដូចជាលក្ខណៈរបស់សហគមន៍ជួយយើង ការដឹងនូវសហគមន៍នោះ ដំណើរការយ៉ាងម៉ែច ក្នុងពេលអនាគត។ ខាងក្រោមនេះ គឺមានលក្ខណៈ ៥ យ៉ាងដែលអាចដឹងថា សហគមន៍មាននិរន្តរភាព:

១-ការអោយតម្លៃ និងគោរពចំពោះប្រជាជន(Value and respect all people) : សហគមន៍មានចីរភាពកត់សម្គាល់ឃើញថា រាល់សមាជិកទាំងអស់មានគំនិត ថាមពល ជំនាញ និងការប៉ិនប្រសប់របស់ពួកគេ។ សមាជិកទាំងអស់ត្រូវដឹងថា ក្នុងការធ្វើអោយសហគមន៍មួយទទួលបាននូវសក្តានុពលពេញលេញ លុះត្រាតែបុគ្គលម្នាក់ៗក្នុងសហគមន៍នោះចេះជួយលើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក ដើម្បីអោយពួកគេទទួលបាននូវអ្វីដែលពួកគេចង់បាន។

២-បង្កើតជំនឿរវាងប្រជាជន និងស្ថាប័ននានា(Cultivate trusting relationship among people organization and institution) : នៅពេលសមាជិកចំណាយរយៈពេលយូរធ្វើការជាមួយគ្នាពួកគេបង្កើតនូវសម្ព័ន្ធភាព ភាពជឿជាក់ និងការគោរពចំពោះគ្នានិងគ្នា។ ពួកគេរៀនសូត្រ និងពឹងពាក់គ្នាទៅវិញទៅមក។ សម្ព័ន្ធភាពនេះបង្កើតអោយមានបណ្តាញគំនិតយោបល់ និងសំបូរធនធានទៅក្នុងសហគមន៍។ ទំនាក់ទំនងដែលទុកចិត្តគ្នាមិនអាចនរណាម្នាក់ទិញបាននោះទេ។ តាមរយៈបទពិសោធន៍របស់ពួកគេ ពួកគេអាចបង្កើតនូវការអភិវឌ្ឍន៍ដោយមានការជឿទុកចិត្ត និងការគោរពបង្កើតឡើងផងដែរ នៅពេលសមាជិកថ្មីត្រូវបានស្វាគមន៍ និងបង្កើតអារម្មណ៍មួយថា ពួកគេជាសមាជិក និងមានរង្វាន់លើកទឹកចិត្តដល់ពួកគេ។ ការបង្កើតជំនឿរវាងប្រជាជន និងស្ថាប័ននានានោះ សហគមន៍អាចផ្តល់គំនិតយោបល់ល្អៗ និងធនធានថ្មីចូលក្នុងតំបន់ភូមិសាស្ត្រកាន់តែទូលំទូលាយ។

៣-សហការគ្នា(Cooperate for common good) : ដោយសមត្ថភាព និងភាពស្ម័គ្រចិត្តនៃសមាជិកក្នុងក្រុមជួបជុំពិភាក្សាគ្នា ដើម្បីដោះស្រាយបញ្ហាជាសាធារណៈ និងដើម្បីស្វែងរកឱកាស ដែលល្អបំផុតក្នុងការពង្រឹងសហគមន៍ប្រកបដោយចីរភាព។ សហគមន៍ត្រូវរៀនពីការប្រើប្រាស់បណ្តាញព័ត៌មានទំនាក់ទំនង ដែលមានទំនុកចិត្តលើជំនាញរបស់ពួកគេ ដើម្បីទទួលបានជោគជ័យល្អបំផុតសម្រាប់សហគមន៍ទាំងមូល។ ពេលខ្លះវាមានន័យថា ត្រូវលះបង់នូវគោលបំណងផ្ទាល់ខ្លួន ដើម្បីផលប្រយោជន៍រួម។ សហគមន៍ ដែលមានសមត្ថភាពត្រូវសហប្រតិបត្តិការទៅលើគោលបំណងច្បាស់លាស់ ដែលមានការរៀបចំល្អបំផុត ដើម្បីបំបែកគំនិតល្អនោះឆ្ពោះទៅកាន់ភាពពិត និងជួយនូវភាពប្រឹងប្រែខិតខំអស់ពីសមត្ថភាពក្នុងការអភិវឌ្ឍន៍ សហគមន៍ប្រកបដោយចីរភាព។

៤-ផ្តល់ឱកាសក្នុងការទំនាក់ទំនង និងការរៀនសូត្រ (Provide opportunities for communication and learning) : យើងបង្កើតនូវជម្រើសរៀងរាល់ថ្ងៃ ហើយជម្រើសរបស់ពួកយើងហាក់ដូចជា ពោរពេញដោយគំនិត និងប្រកបដោយគតិបណ្ឌិតនៅពេលដែលយើងមានឱកាសទៀងទាក់ ដើម្បីប្រមូលព័ត៌មានរៀនតាមបទពិសោធន៍ និងធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ ការទំនាក់ទំនង និងការរៀនសូត្រកើតឡើងតាមរយៈ

កន្លែងជាច្រើនដូចជា មជ្ឈមណ្ឌលសហគមន៍រោកុន បណ្ណាល័យ សាលារៀន ទីផ្សាររបស់កសិករ ហាងកាហ្វេ និងចំណត ដែលជាកន្លែងអាចអោយកសិកររលើកទឹកចិត្តគ្នា និងពិភាក្សាគ្នាពីបញ្ហាសហគមន៍។ ម្យ៉ាងទៀត ការទំនាក់ទំនង និងការរៀនសូត្រអាចកើតឡើងផងដែរ តាមរយៈ ការឆ្លើយឆ្លងវិទ្យុ តំបន់ការជួបប្រជុំនៃក្រុមប្រជាជន វេទិការសាធារណៈ បណ្តាញកុំព្យូទ័រ និងការសែតក្នុងតំបន់។ លើសពីនេះទៀត សហគមន៍ប្រកបដោយចីរភាព នៅតែបន្តស្វែងរកនូវមធ្យោបាយណាដែលអាចបង្កើននូវការទំនាក់ទំនង និងការរៀនសូត្ររបស់ប្រជាកសិករអោយកាន់តែល្អប្រសើរ។

៥-មិនគ្រាន់តែលូតលាស់ទេ និងត្រូវស្វែងរកការអភិវឌ្ឍន៍(Seek to develop and not just grow) : ភាពខុសគ្នារវាងការអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព និងគំរូអភិវឌ្ឍន៍តាមរបៀបបែបបុរាណ គឺថា ការអភិវឌ្ឍន៍ប្រកបដោយចីរភាព វាបង្ហាញពីលក្ខណៈខុសគ្នារវាង "ការលូតលាស់" និង "ការអភិវឌ្ឍន៍"។

ការលូតលាស់វាស់ពីការកើនឡើងនូវសកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី ដោយមិនគិតថា តើសកម្មភាពនោះល្អ ឬអាក្រក់សម្រាប់មនុស្សក្នុងរយៈពេលយូរអង្វែងឡើយ។ រីឯការអភិវឌ្ឍន៍ប្រកបដោយចីរភាពវិញនាំអោយបង្កើននូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ពីមួយជំនាន់ទៅមួយជំនាន់។ ដូចដែលបានបង្ហាញពីការលូតលាស់និយាយអំពី "ការរីកធំឡើង" ឯការអភិវឌ្ឍន៍ប្រកបដោយចីរភាពវិញ និយាយអំពី "ការល្អប្រសើរឡើង"។

ប្រសិនបើសហគមន៍របស់អ្នកជ្រើសរើសអនុវត្តនូវគន្លងនៃការអភិវឌ្ឍន៍ អ្នកត្រូវកំណត់គោលដៅអោយបានច្បាស់លាស់។ ខាងក្រោមនេះ គឺជា ១០ជំហានក្នុងការចាប់ផ្តើមអភិវឌ្ឍន៍សហគមន៍របស់អ្នក

ជំហានទាំងនេះផ្តោតសំខាន់ទៅលើ ភាពទទួលខុសត្រូវសកម្មភាពដោយមានការរួបរួមគ្នា និងបន្តការរៀនសូត្រពីគ្នាទៅវិញទៅមក។ សហគមន៍អាចជ្រើសរើសប្រើប្រាស់ដំណាក់កាលនេះលើសពីក្នុងពេលតែមួយ។

១-បង្កើតក្រុមការងារ(Form an Action Team) ដំណាក់កាលទី១ ក្នុងការចាប់ផ្តើមធ្វើអោយសហគមន៍ប្រកបដោយចីរភាពអះអាងថា គឺភាពទទួលខុសត្រូវចំពោះជោគវាសនារបស់យើង ជំនួសនូវការដោះសារនៅហេតុផលថា អ្នកមិនចេះធ្វើនូវការចាប់ផ្តើមគិតថាអ្នកចេះ។ ក្រុមការងារដែលប្រកបដោយចីរភាពអាចបង្កើតតាមរយៈ ការពង្រីកនូវអង្គភាពដែលមានស្រាប់ ឬក៏ធ្វើការចាប់ផ្តើមពីពេលគ្មានអ្វីសោះ។ សមាជិកក្រុមិនច្បាស់លាស់ទេ ហើយក្រុមការងារនេះ អាចអនុញ្ញាតអោយអ្នកណាដែលមានបំណងចូលជាសមាជិកចូលរួម។ ក្រុមការងារប្រកបដោយនិរន្តរភាពទាមទារអោយមានការកែលម្អពីពេលមួយទៅពេលមួយ។ តួនាទីរបស់ក្រុមការងារ គឺបង្កើតស្ថានភាពមួយសម្រាប់សមាជិកធ្វើការដោយមានការចូលរួមដោយស្ម័គ្រចិត្ត និងរាយការណ៍ពិសេសពីសេចក្តីសម្រេចចិត្តអំពីកន្លែងដែលពួកគេចង់ទៅនៅពេលអនាគត និងធ្វើយ៉ាងណាទើបពួកគេអាចទៅទីនោះបាន។ ក្រុមការងារនឹងជួយអោយសមាជិកមករៀនជ្រើសរើសនូវដែម្រើសរបស់ពួកគេយល់ដឹងពីសារៈសំខាន់នៃសាមគ្គីភាព និងពួកគេអាចបង្កើតទីតាំងមួយច្បាស់លាស់ក្នុងការធ្វើអោយសហគមន៍មាននិរន្តរភាព។

២-ប្រាប់ពីទស្សនៈវិស័យនាពេលអនាគត(Share a Vision of the Future) : ការកសាងសហគមន៍ប្រកបដោយចីរភាពទាមទារអោយមានសេចក្តីអត់ធ្មត់ ដើម្បីជំរុញសមាជិកប្រាប់ពីទស្សនៈវិស័យនាពេលអនាគត ក្នុងការសម្រេចចិត្តផ្អែកទៅលើទស្សនៈរួមមួយ និងក្នុងការអភិវឌ្ឍន៍ធនធានធ្វើតាមទស្សនៈវិស័យនេះ។ ដើម្បីសម្រេចនូវទស្សនៈរួមមួយដែលមានភាពជាក់លាក់ ត្រូវមានការចូលរួមពិភាក្សាដោយក្រុមការងារដូចខាងក្រោមនេះ : តើអ្វីដែលសំខាន់សម្រាប់សហគមន៍យើង? តើលក្ខណៈវិនិច្ឆ័យរបស់យើងសម្រាប់សេចក្តីសម្រេចចិត្តប្រកបដោយការអភិវឌ្ឍន៍ជាអ្វី?

៣-ធ្វើអោយសហគមន៍មានការរៀនសូត្រជានិច្ច(Make Community Learning Constant) : ការផ្លាស់ប្តូរ គឺជាសកម្មភាពកើតឡើងមិនឈប់ឈរ និងជំហាននៃការផ្លាស់ប្តូរ គឺជាការបង្កើនល្បឿនអោយកើនឡើង។ សមាជិកជាច្រើនរៀនបានលទ្ធផលល្អដោយសារការធ្វើ ប៉ុន្តែសមត្ថភាពក្នុងការធ្វើបានមកពីការអនុវត្តន៍។ ក្រុមការងារជ្រើសរើស កន្លែងដែលប្រជាពលរដ្ឋរៀនពីរបៀបប្រមូល និងប្រាប់ព័ត៌មានរៀនពីអ្នកដទៃទៀត និងពិភាក្សាពីបញ្ហានយោបាយជាសាធារណៈ ហើយបញ្ហាទាំងនេះនឹងប៉ះពាល់ដល់សហគមន៍របស់ពួកគេយ៉ាងដូចម្តេចដែរ។

៤-ឆ្ពោះទៅរកសហគមន៍ (Reach out to other Communities) : មិនមែនរាល់ការសម្រេចចិត្តក្នុងការអភិវឌ្ឍន៍សហគមន៍ទាំងមូលធ្វើឡើងដោយសហគមន៍តែមួយឯកឯងនោះទេ គឺវាទាមទារអោយមានការទាក់ទងជាមួយសហគមន៍ដទៃទៀត។ ជាក់ស្តែងដូចជា បញ្ហាសេដ្ឋកិច្ចកក្នុងតំបន់ គឺត្រូវដោះឥទ្ធិពលដោយនយោបាយ និងព្រឹត្តិការណ៍ផ្សេងៗទៀត។ សហគមន៍ប្រកបដោយចីរភាពមិនអាចប្រឹងប្រែងដោយខ្លួនឯងដោយគ្មានការជួយជ្រោមជ្រែងពីសហគមន៍ផ្សេងទៀតឡើយ។ ដូច្នេះ រាល់សហប្រតិបត្តិការក្នុងចំណោមសហគមន៍ទាំងអស់ គឺសំខាន់ណាស់ក្នុងការកសាងសង្គមប្រកបដោយចីរភាព។

៥-បង្កើតផែនការសកម្មភាព(Develop an Action Plan) : សហគមន៍ត្រូវវាយតម្លៃរយៈពេល និងចំងាយ ដែលសហគមន៍អាចធ្វើការអភិវឌ្ឍន៍ដើម្បីឈានទៅរកនិរន្តរភាព។ សហគមន៍បង្កើតផែនការសកម្មភាពដោយរាយការណ៍នូវសកម្មភាព ដែលជាអាទិភាពជាក់មុន ហើយសកម្មភាពសំខាន់នេះនឹងអាចធ្វើអោយសហគមន៍មានចីរភាព។ គោលបំណងនៃការបង្កើតគម្រោងផែនការសកម្មភាព គឺដើម្បីយកនូវយោបល់រួមមួយដោយធ្វើការពិភាក្សាជ្រើសរើសនូវសកម្មភាពជាអាទិភាព និងយោងទៅលើភាពសំខាន់របស់វាងសម្រាប់ការអភិវឌ្ឍន៍សហគមន៍។ ដំណើរការនេះ គឺត្រូវធ្វើឡើងច្រើនលើកច្រើនសារ ឬក៏កែតម្រូវជាទៀងទាត់ ដើម្បីអោយសហគមន៍កាន់តែមានសភាពល្អប្រសើរឡើង។

៦-វាស់វែងការរីកចម្រើន(Measure Your Progress) : ភាពជោគជ័យ នៃការអភិវឌ្ឍន៍សហគមន៍ភាគច្រើនត្រូវវាស់ដោយការរាប់ នូវចំនួនការងារ ដែលបានបង្កើតឡើង។ សហគមន៍ប្រកបដោយចីរភាពវាស់តម្លៃសកម្មភាពសេដ្ឋកិច្ចមិនគ្រាន់តែជាលុយ ឬការងារទេ ថែមទាំងសហគមន៍នោះត្រូវបង្កើតជីវភាពរស់នៅអោយ

ប្រសើរឡើងក្នុងរយៈពេលដ៏យូរអង្វែង។ ដើម្បីវាស់វែងការកើនឡើងសហគមន៍ត្រូវដឹងពីកន្លែង ដែលពួកគេរស់នៅ និងកន្លែងដែលពួកគេចង់នៅ។

៧-ការចាត់ចែងធនធាន(Redirect Resources) : ការសម្រេចចិត្តអភិវឌ្ឍន៍ភាគច្រើនបំផុតត្រូវបានធ្វើឡើងដោយសមាជិកដែលមានចំណេះដឹង និងការយល់ដឹងខ្ពស់។ សហគមន៍ត្រូវស្វែងរកមធ្យោបាយចាត់ចែងថវិកា និងធនធានបច្ចុប្បន្នធ្វើយ៉ាងណា ដើម្បីផ្គត់ផ្គង់ ការអភិវឌ្ឍន៍មិនប្រកបដោយចីរភាពអោយក្លាយជាសហគមន៍ប្រកបដោយនិរន្តរភាព។ នេះកត់សម្គាល់ឃើញថា ត្រូវចេះអង្កេតនូវធនធានសាធារណៈ និងឯកជនដែលកំពុងតែបែងចែកនៅពេលបច្ចុប្បន្ន។ សហគមន៍ដែលអភិវឌ្ឍន៍នូវទស្សនៈជាក់លាក់ ផែនការសកម្មភាពនឹងស្មគ្រចិត្តវាស់ការលូតលាស់ផ្អែកលើបញ្ហាទាំងនេះ វាជាឧទាហរណ៍ល្អបំផុតសម្រាប់ការចាត់ចែងការអភិវឌ្ឍន៍ធនធានដែលមានស្រាប់។

៨-ការទទួលគំនិតពីសហគមន៍ (Engage th Public) : សហគមន៍ប្រកបដោយចីរភាពការពារសម្រេចចិត្តត្រូវបានធ្វើឡើងដោយមានការពិភាក្សាជាសាធារណៈជាច្រើន។ នៅពេលសហគមន៍មានបំណងរក្សាខ្លួនឯងអោយស្ថិតស្ថេរលុះត្រាសហគមន៍នោះត្រូវស្វាគមន៍ដោយក្តីស្មោះត្រង់ និងចេះប្រើប្រាស់រាល់ឱកាសក្នុងការទាក់ទងជាមួយមនុស្សថ្មី។ ការប្រជុំទាំងអស់គួរធ្វើឡើងជាសាធារណៈ និងការធ្វើឡើងនៅទីណាដែលលើកទឹកចិត្តប្រជាពលរដ្ឋអោយមានការចូលរួមបញ្ចេញយោបល់។ ការបើកចំហរ និងការទំនាក់ទំនងជាមួយសមាជិកថ្មីបង្កើតនូវប្រភពនៃគំនិតថ្មីជំនាញថ្មី ភាពបិនប្រសប់ និងភាពជាអ្នកដឹកនាំក្នុងការរក្សាក្រុមប្រតិបត្តិការអោយស្ថិតស្ថេរ។

៩-ច្នៃប្រឌិត(Be Creative) : នៅពេលសមាជិកមានបំណងចង់អភិវឌ្ឍន៍សហគមន៍ និងមានគំនិតផ្តួចផ្តើមមួយអោយមាននិរន្តរភាពពួកគេខិតខំស្វែងរកវិធីសាស្ត្រ ឬស្រាវជ្រាវមធ្យោបាយចាស់ក្នុងការអភិវឌ្ឍន៍សហគមន៍។ ដោយមានការច្នៃប្រឌិតទាក់ទងទៅនឹងការពិនិត្យ និងការអភិវឌ្ឍន៍អាស្រ័យលើគំនិតយោបល់នៃអ្នកដទៃ ក៏ដូចជាការអភិវឌ្ឍន៍គំនិតថ្មីដែរ។ សកម្មភាពរួមមាន ត្រូវរៀបរបៀបកត់សម្គាល់ បណ្តុះបណ្តាល ការគិតថ្មីៗ និងអភិវឌ្ឍន៍ ដំណើរការថ្មីសម្រាប់បញ្ចូលក្នុងសកម្មភាពនេះ។

១០-សាទរជាមួយជោគជ័យ(Celebrabte Your Success) : អភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាពទាមទារនូវការសហប្រតិបត្តិការដ៏ប្រឹងប្រែងពីបុគ្គលម្នាក់ៗ និងអង្គភាព។ ដោយសារតែការអភិវឌ្ឍន៍ប្រកបដោយចីរភាពសំដៅទៅលើរយៈពេលយូរ ជោគជ័យនឹងមិនងាយទទួលបានភ្លាមៗនោះទេ។ អ្នកស្ម័គ្រចិត្តធ្វើការងារក្នុងសហគមន៍អាចនឿយហត់ ជាពិសេសនោះនៅពេលគ្មាននរណាម្នាក់ចាប់អារម្មណ៍ទៅលើការងារដែលពួកគេខិតខំប្រឹងប្រែងយ៉ាងខ្លាំង និងការចំណាយពេលវេលាយ៉ាងច្រើន ដែលពួកគេបានលះបង់សម្រាប់ភាពរុងរឿងរបស់សហគមន៍។ វាជាបញ្ហាសំខាន់ណាស់ក្នុងការដឹកនាំសុខទុក្ខរបស់អ្នកស្ម័គ្រទាំងនេះ និងអបអរចំពោះពួកគេទោះបីជ័យជំនះនោះតូចក្តី។ ក្រុមការងារគួររៀបចំដំណើរកំសាន្ត និងផ្តល់រង្វាន់ដល់ពួកគេក្នុងការអបអរជោគជ័យ ដែលសហគមន៍ទទួលបាន។

សារៈសំខាន់នៃការបង្កើតក្រុម គឺនៅពេលដែលមនុស្សប្រុស ស្រីទាំងឡាយមានចំណាប់អារម្មណ៍ដូចគ្នា ហើយគំនិតកាន់តែប្រសើរឡើង ចំពោះអ្វីដែលពួកគេចង់ធ្វើ និងត្រូវធ្វើវាដោយវិធីណានោះពួកគេនឹងអាចរួមគ្នាបង្កើតឡើងជាក្រុមមួយ។ ដើម្បីបង្កើតក្រុមមានគោលការណ៍ជាមូលដ្ឋាន ៤ ដូចខាងក្រោមនេះ :

-ក្រុមដែលបង្កើតឡើងត្រូវមានទំហំតូចល្មម : ចំនួនសមាជិកក្រុមដែលល្អបំផុតត្រូវស្ថិតនៅក្នុងចន្លោះពី ៨-១៥នាក់ ក្នុងមួយក្រុម។ សមាជិកទាំងអស់មានឱកាសក្នុងការបញ្ចេញមតិយោបល់ និងចូលរួមទាំងកម្លាំងកាយ និងកម្លាំងប្រាជ្ញា ដើម្បីអភិវឌ្ឍន៍ក្រុមរបស់ខ្លួន។ ក្រុមដែលមានទំហំតូចមិនងាយនឹងបែកបាក់ដោយការឈ្លោះប្រកែកគ្នា ឬត្រូវគ្របសង្កត់ដោយក្រុមភាគចិត្ត។

-ក្រុមនីមួយៗត្រូវមានលក្ខណៈដូចគ្នា: មានសមាជិកទាំងអស់គួរតែជាមនុស្សដែលរស់នៅក្នុងស្ថានភាពសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា និងមានទំនាក់ទំនងសង្គមជិតស្និទ្ធជាមួយគ្នា។ លក្ខណៈដូចគ្នាទាំងអស់នេះកាត់បន្ថយបាននូវជម្លោះ ដែលអាចកើតមានឡើង ក្នុងក្រុម ហើយសមាជិកដែលមានសេរ៉ាប្រហាក់ប្រហែលគ្នា និងមានការជឿជាក់គ្នាទៅវិញទៅមកទទួលយកនូវការទទួលខុសត្រូវរួមគ្នា ដើម្បីធ្វើសកម្មភាពរបស់ពួកគេ។

-ក្រុមនីមួយៗត្រូវធ្វើការ: បង្កើតឡើងក្នុងសកម្មភាពបង្កើនប្រាក់ចំណូល សកម្មភាពបង្កើនប្រាក់ចំណូលមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍន៍ក្រុម ព្រោះសកម្មភាពទាំងនោះបង្កើតជាទ្រព្យសម្បត្តិផ្សេងៗ ដើម្បីជួយស្ថាបនាអោយមានភាពជាម្ចាស់លើខ្លួនឯង។

-ក្រុមនីមួយៗគួរតែមានលក្ខណៈស្មុគ្រចិត្ត និងប្រជាធិបតេយ្យ: សមាជិកទាំងអស់ គឺជាអ្នកសម្រេចចិត្តថា តើនរណាដែលគួរចូលរួមនៅក្នុងក្រុមជាមួយពួកគេ ហើយនរណាជាអ្នកដឹកនាំពួកគេ តើត្រូវមានក្រឹត្យក្រមអ្វីខ្លះ ដែលពួកគេត្រូវគោរពតាម និងថា តើពួកគេត្រូវធ្វើសកម្មភាពអ្វីខ្លះ។ រាល់ការសម្រេចចិត្តទាំងឡាយត្រូវតែធ្វើឡើងតាមរយៈការបោះឆ្នោតជាឯកឆ្ន័ន ឬមតិភាគច្រើន។

ការពិភាក្សាទៅលើសមាជិកភាព ការបង្កើតជាតារាងមួយ ដែលមានរាយឈ្មោះអ្នកដែលចាប់អារម្មណ៍ក្នុងការបង្កើតជាក្រុមត្រូវរំលឹកដល់ពួកគេផងដែរថា សមាជិកភាពនេះនឹងទទួលបាននូវសិទ្ធិ និងផលប្រយោជន៍មួយចំនួនដូចជា សិទ្ធិចូលរួមប្រជុំនៅក្នុងក្រុម និងសិទ្ធិទទួលបាននូវចំណែកនៃប្រាក់ចំណេញដែលបានមកពីសកម្មភាពផ្សេងៗរបស់ក្រុម។ ប៉ុន្តែសមាជិកនេះក៏ទាមទារអោយមានការបំពេញកិច្ចការមួយចំនួនដូចជា ការចូលរួមប្រជុំអោយបានទៀងទាត់បង់ប្រាក់ចូលជាសមាជិក បោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំនៅក្នុងក្រុមរួមធ្វើវិភាគទានទៀងទាត់ក្នុងមូលនិធិសន្សំរបស់ក្រុម ប្រសិនបើមានសងប្រាក់កម្ចីមកក្រុមវិញ អោយបានឆាប់រហ័ស ជួយសមាជិកផ្សេងៗទៀតនៅក្នុងក្រុមជាមួយគ្នាពេលមានការចាំបាច់។

ការជ្រើសរើសឈ្មោះសម្រាប់ក្រុមសមាជិកទាំងអស់ គួរតែជ្រើសរើសឈ្មោះសម្រាប់ក្រុមរបស់ពួកគេ។ នៅក្នុងប្រទេសខ្លះគេដាក់ឈ្មោះអោយក្រុមរបស់ពួកគេនៅបន្តក្រោយឈ្មោះភូមិ ឬទីកន្លែងដែលគេរស់នៅ។

ការសម្រេចពីពេលវេលា និងចំនួនដងដែលត្រូវប្រជុំ : ធ្វើការវិភាគសម្រាប់ប្រជុំតាមថ្ងៃ និងពេលដែលមានលក្ខណៈងាយស្រួលដល់សមាជិកទាំងអស់។ ការជួបជុំគ្នាជាញឹកញាប់ គឺចាការចាំបាច់បំផុតពិសេសក្នុង

ដំណាក់កាល់ដំបូងនៃការចងក្រងក្រុម និងការរៀនសូត្រពីគ្នាទៅវិញទៅមក បញ្ជាក់ពីតម្រូវការនៃការចូលរួមអោយបានទៀងទាត់សម្រាប់កិច្ចប្រជុំទាំងនេះ។

ការបង្កើតគោលដៅរបស់ក្រុមអោយបានច្បាស់លាស់: ត្រូវជួយសមាជិកក្រុមក្នុងការសម្រេចគោលដៅអោយបានច្បាស់លាស់សម្រាប់ក្រុមរបស់ពួកគេ ជាពិសេសនៅពេលដែលមនុស្សនៅក្នុងក្រុមបានយល់ព្រមថានឹងធ្វើការជាមួយគ្នា ដើម្បីគោលដៅដូចគ្នា អ្នកអាចជួយពួកគេបង្កើតក្រុមឯករាជ្យដោយមានការចូលរួមមួយ។

ជាដំបូងអ្នកត្រូវដើរតួនាទីសំខាន់ ក្រោយមកបន្ទាប់ពីក្រុមដែលបានបង្កើតមានបទពិសោធន៍គ្រប់គ្រាន់ហើយមានការជឿជាក់លើខ្លួនឯង ពេលនោះអ្នកគួរកាត់បន្ថយតួនាទីរបស់អ្នក ហើយចាប់ផ្តើមបង្វែរការយកចិត្តទុកដាក់ក្នុងការបង្កើតសកម្មភាព និងក្រុមផ្សេងទៀត។

អ្នកគួរតែលើកទឹកចិត្តដល់សមាជិកទាំងអស់ទាំងបុរស និងស្ត្រីអោយមានការចូលរួមចំណែកនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេចចិត្ត។ អ្នកគួរជួយសមាជិកទាំងអស់ក្នុងការចាប់យកជំនាញផ្សេងៗ។ ហើយរៀបចំការហ្វឹកហ្វឺន សិក្ខាសាលា ដើម្បីផ្លាស់ប្តូរគំនិតជាមួយក្រុមផ្សេងទៀត។

ការពិភាក្សាពីសារៈសំខាន់ នៃការចូលរួមប្រជុំរាល់កិច្ចការរបស់ក្រុមមានសារៈសំខាន់ណាស់សម្រាប់ធ្វើការពិភាក្សារៀនសូត្រពីគ្នាទៅវិញទៅមក និងការធ្វើសេចក្តីសម្រេចចិត្ត។ សមាជិកដែលមិនចូលរួមនៅក្នុងការប្រជុំមិនអាចរួមចំណែកអោយបានល្អត្រឹមត្រូវក្នុងក្រុមទេ។ ប្រសិនបើមានសមាជិកណាម្នាក់មិនអាចមកចូលរួមប្រជុំបាន ត្រូវធ្វើសេចក្តីរាយការណ៍ជាមុន ដោយប្រាប់ពីមូលហេតុដែលមិនបានចូលរួម ហើយក្រុមទាំងមូលត្រូវធ្វើការកត់ត្រាអវត្តមាននៅលើក្រដាស។

លើសពីអ្វីដែលបានបកស្រាយខាងលើ នូវចំណុចគន្លឹះដែលធ្វើអោយក្រុមឯករាជ្យទទួលបានជោគជ័យ:

១-ភាពជាអ្នកដឹកនាំ: ក្រុមដែលមានការដឹកនាំបានល្អ តែងតែទទួលបានជោគជ័យ ដូច្នេះ គេត្រូវធ្វើការជ្រើសរើសថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មការដោយប្រុងប្រយ័ត្ន គឺត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

ក-មានភាពរស់រវើក ស្វាហាប់ ហើយពូកែជំរុញទឹកចិត្តសមាជិកដទៃទៀត។ ខ-មានការគោរព ប៉ុន្តែមិនមែនការខ្មាស់អៀនទេ។ គ-ក្លាហាន ស្មោះត្រង់ និងមានការអត់ធ្មត់។ ឃ-អាចធ្វើការជាមួយអ្នកដទៃបាន។ ង-អាចទំនាក់ទំនងជាមួយអ្នកដទៃបាន។ ច-មិនមែណជាមនុស្សប្រមឹកខួប និងមិនចេះនិយាយអេចអូច។ ឆ-អាចរក្សាការសម្ងាត់របស់ក្រុម និងអោយមានការធ្វើវិភាគទាន។

ការធ្វើវិភាគទានរបស់សមាជិកទាំងឡាយចំពោះសកម្មភាពរបស់ក្រុម ជួយបង្កើតអោយមានស្មារតីជាម្ចាស់លើក្រុមរបស់ខ្លួន និងភាពរឹងមាំរបស់ក្រុម។ វិភាគទានទាំងនេះក៏អាចជួយអោយក្រុមប្រើប្រាស់សម្រាប់ការចំណាយតូចៗដូចជា សម្ភារៈសម្រាប់សរសេរ និងសោហ៊ុយដឹកជញ្ជូនសម្រាប់ការចំណាយធំៗ ដូចជា ការចាប់ផ្តើមវិនិយោគទៅលើសកម្មភាពបង្កើតប្រាក់ចំណូលជាដើម។

ការតាក់តែងលក្ខន្តិក:របស់ក្រុម: ច្បាប់កំពូល គឺជាសំណេរជាលាយលក្ខណ៍អក្សរ ដែលចែងពីគោលដៅ និងក្បួនច្បាប់សម្រាប់អនុវត្តក្នុងក្រុម។ ច្បាប់នេះជួយបញ្ចៀសមិនអោយមានជម្លោះផ្ទៃក្នុង និងកំណត់ការទទួលខុសត្រូវរបស់សមាជិកនីមួយៗអោយបានច្បាស់។

ការធ្វើបញ្ជីកត់ត្រា: ការកត់ត្រាជួយអោយក្រុមចងចាំនូវអ្វីដែលបានសម្រេចនៅពេលប្រជុំ។ ឯកសារទាំងអស់នេះមានសារៈសំខាន់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ។ គេគួរធ្វើបញ្ជីកត់ត្រាអោយបានទៀងទាត់ (ឧទាហរណ៍ ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ) ឬនៅរាល់ពេលដែលកិច្ចប្រជុំត្រូវបានគេធ្វើ ឬនៅពេលសកម្មភាពផ្សេងៗកើតមានឡើង។

សមាគមអន្តរក្រុម គឺជាតំណាងអោយក្រុមនីមួយៗ ដែលជាសមាជិក និងមានការកិច្ចទទួលខុសត្រូវចំពោះក្រុមទាំងអស់ដែលជាសមាជិកនោះ។ សមាគមនេះ គួរដើរតួនាទីក្នុងការសម្របសម្រួល និងអប់រំ ហើយអាចក្លាយទៅជាប្រភពជំនួយបច្ចេកទេស សេដ្ឋកិច្ចមាត្រដ្ឋាន និងជាអ្នកនាំផ្លូវផងដែរ។

ការបង្កើតការយល់ដឹងអំពីតួនាទីរបស់សមាគមន៍អន្តរក្រុម: ការរៀបចំសមាគមន៍អន្តរក្រុមឆាប់រហ័សពេក ឧទាហរណ៍ មិនយូរប៉ុន្មានក្រោយការបង្កើតក្រុមឯករាជ្យនីមួយៗ តែងធ្វើអោយរចនាសម្ព័ន្ធទន់ខ្សោយ ដែលមិនតំណាងអោយសេចក្តីត្រូវការរបស់ក្រុមជាសមាជិកនោះទេ។ ដូច្នេះ គេត្រូវធ្វើយឺតៗដោយផ្តោតជាដំបូងទៅលើការបង្កើតអោយមានការយល់ដឹងអំពីតួនាទីរបស់សមាគមន៍នេះក្នុងការដោះស្រាយបញ្ហារបស់ក្រុម និងសមាគមផលប្រយោជន៍នានា និងការចំណាយដែលមាននៅក្នុងសមាគមអន្តរក្រុម។

ការកំណត់គោលដៅរបស់សមាគមន៍អន្តរក្រុម: ការពិភាក្សាជាមួយគ្នា ក្រុមទាំងអស់អាចស្វែងយល់ពីសកម្មភាពទាំងឡាយ ដែលពួកគេអាចធ្វើរួមគ្នា។ សកម្មភាពខ្លះអាចផ្តល់ផលប្រយោជន៍សម្រាប់តែក្រុមមួយចំនួនតូចប៉ុណ្ណោះ។ សកម្មភាពខ្លះទៀត អាចមានលក្ខណៈធំហួសពេកសម្រាប់សមាគម ដែលពិបាកក្នុងការអនុវត្តគោលដៅដ៏ប្រសើរបំផុត គឺជាគោលដៅដែលមានលក្ខណៈប្រាកដប្រជា ដែលមានការគាំទ្រពីសំណាក់ក្រុមទាំងអស់ដែលជាសមាជិក។ សមាគមន៍អន្តរក្រុមរបស់ពួកគេទាំងនោះគួរសម្រេចថា គោលដៅមួយណាដែលត្រូវធ្វើជំបូងគេ មួយណាត្រូវធ្វើទីពីរ និងមានណាត្រូវធ្វើទីបី។

ការរៀបចំលក្ខន្តិក:របស់សមាគមន៍: លក្ខន្តិក: គឺជាសំណេរជាលាយលក្ខណ៍អក្សរដែលចែងពីគោលដៅ និងក្បួនច្បាប់នានា សម្រាប់សមាគមន៍។ លក្ខន្តិក:របស់សមាគមន៍គួរផ្តោតទៅលើប្រធានបទមួយចំនួន ដូចជា: ១-គោលដៅ និងគោលបំណងរបស់សមាគន៍។ ២-បញ្ជីដែលរៀបរាប់ពីគោលដៅសំខាន់ៗជាអាទិភាព។ ៣-ច្បាប់សម្រាប់ចូលជាសមាជិកភាពលក្ខខ័ណ្ឌនៃការជ្រើសរើស និងការបណ្តេញចេញពីសមាគមន៍តួនាទី និងការទទួលខុសត្រូវរបស់សមាជិក ដែលរួមបញ្ចូលទាំងការសងបំណុល និងការគ្រប់គ្រងប្រាក់ជាដើម។ ៤-សេចក្តីអធិប្បាយអំពីរចនាសម្ព័ន្ធចាត់តាំងរបស់សមាគមន៍។ ៥-ការជ្រើសរើសមេដឹកនាំសមាគមន៍តួនាទី និងការទទួលខុសត្រូវ ព្រមទាំងលក្ខខ័ណ្ឌការងារផ្សេងៗ។ ៦-ចំនួនដងនៃការជួបប្រជុំរបស់សមាគមន៍ និងចំនួនសមាជិកដែលត្រូវចូលរួមជាចាំបាច់ ដើម្បីអាចធ្វើសេចក្តីសម្រេចបានសម្រាប់គណៈកម្មការនីមួយៗ។ ៧-របៀបបែងចែក

ប្រាក់ចំណេញ និងការខាតបង់ធ្វើដោយក្រុមនីមួយៗ ដែលជាសមាជិកទាំងអស់របស់សមាគមន៍ និងបំណាច់ឆ្នាំ ហិរញ្ញវត្ថុនីមួយៗ និងចែងអំពីច្បាប់ទម្លាប់សម្រាប់ធ្វើការកែប្រែក្នុងនិក:របស់សមាគមន៍។

សរុបសេចក្តីមក ការបង្កើតប្រាក់ចំណូលតាមរយៈការសហការរវាងក្រុម និងក្រុមមានផលប្រយោជន៍ច្រើនជាងការប្រឹងប្រែង ដែលធ្វើដោយបុគ្គលតែម្នាក់ៗ។

ជំពូកទី១
សន្និដ្ឋាន និង អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សារស្រាវជ្រាវលើប្រធានបទនេះមក យើងអាចទាញបាននូវសេចក្តីសន្និដ្ឋានដូចតទៅ: ភាពក្រីក្រ គឺជាការខាតបង់ខាងសេដ្ឋកិច្ច ដែលធ្វើអោយសីលធម៌ធ្លាក់ចុះ និងបណ្តាលអោយមានការបែកបាក់ក្នុងសង្គម។ រាជរដ្ឋាភិបាល បានប្រកាសនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការប្រឹងប្រែងរួមគ្នាក្នុងកម្រិតជាតិ និងប្រកបដោយចីរភាព ដើម្បីកំចាត់ភាពក្រីក្រគោកយ៉ាកអោយអស់ពីកម្ពុជា ដើម្បីអោយប្រជាជនកម្ពុជាទាំងអស់អាចទទួលបានផលពីកំណើនសេដ្ឋកិច្ច និងអាចរួមចំណែកនៅក្នុងដំណើរការនៃកិច្ចអភិវឌ្ឍន៍។ ការកាត់បន្ថយភាពក្រីក្រអោយបានឆាប់រហ័ស គឺជាការចូលរួមវិភាគទានមួយដ៏មានសារៈសំខាន់នៅក្នុងដំណើរបង្រួបបង្រួមជាតិ និងការធ្វើអោយវប្បធម៌ជាតិរស់ឡើងវិញជាថ្មី និងជាគន្លឹះនៃការថែរក្សាស្ថេរភាពនយោបាយ និងស្ថេរភាពសង្គម។

នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការចាប់ផ្តើមរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម លើកទីពីរ ២០០១-២០០៥ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវយុទ្ធសាស្ត្រដ៏ចម្បងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ នោះ គឺជាការខិតខំសម្រេចអោយបាននូវ: ១-កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងរយៈពេលវែង ក្នុងអត្រាពី ៦% ទៅ ៧% ២-បែងចែកអោយសមធម៌នូវផ្លែផ្កា នៃកំណើនសេដ្ឋកិច្ចរវាងអ្នកមាននិងអ្នកគ្មាន រវាងអ្នកទីក្រុងនិងអ្នកជនបទ និងរវាងភេទខុសគ្នា និង ៣-ធានាបាននូវការប្រើប្រាស់ និងការគ្រប់គ្រងប្រកបដោយចីរភាពនៃបរិស្ថាន និងធនធានធម្មជាតិ។ បាវចនា ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺ "ការកាត់បន្ថយភាពក្រីក្រ តាមរយៈកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ក្នុងរយៈពេលវែង ដោយធានានូវចីរភាពខាងបរិស្ថាន និងសមធម៌សង្គម"។ ដូចនេះ គោលនយោបាយជួយជនក្រីក្ររបស់រាជរដ្ឋាភិបាលត្រូវតម្រង់ទិសទៅរកការបង្កើតឡើងនូវបរិស្ថានសមស្របមួយ ដើម្បីជំរុញ និងបង្កើតអោយមានកំណើនសេដ្ឋកិច្ចដោយគ្មានការរិចរិលបរិស្ថាននិងការបែងចែកចំណូលប្រកបដោយសមធម៌។ ចំណុចសំខាន់ៗនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទីពីរ ១៩៩៨-២០០៣នេះ គឺគោលបំណងកាត់បន្ថយភាពក្រីក្រតាមរយៈ : ក-ការពង្រឹងសន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម។ ខ-ការជំរុញការវិនិយោគ។ គ-កៀងគរធនធានក្នុងស្រុក។ ឃ-ជំរុញការវិនិយោគលើវិស័យអាទិភាព និងការកែលម្អវិស័យកសិកម្ម។ ង-ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងពិភពលោក។ ច-ការអភិវឌ្ឍន៍ធនធានមនុស្ស។ ឆ-ត្រូវពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយនិងសង្គមស៊ីវិល។

យុទ្ធសាស្ត្រនាពេលបច្ចុប្បន្ននេះ ក្នុងការបង្កើតកាលានុវត្តភាព គឺមានដូចតទៅ : ការពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការពន្លឿនកំណើនសេដ្ឋកិច្ច ការជំរុញការអភិវឌ្ឍន៍វិស័យឯកជន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងផ្នែកថាមពល ការធានានូវការអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវវិស័យកសិកម្ម ការកែលម្អការគ្រប់គ្រងធនធានទឹក ការជម្រុញការអភិវឌ្ឍន៍ជនបទ និងវិមជ្ឈការ ការធានានូវការគ្រប់គ្រងធនធានធម្មជាតិអោយបានល្អការលើកទឹកចិត្តបណ្តាសកម្មភាព ដែលបង្កើតប្រាក់ចំណូល ការអនុវត្តន៍គោលនយោបាយដីធ្លី និងការបង្កើនសេវាមីក្រូហិរញ្ញវត្ថុសម្រាប់ប្រជនជនក្រីក្រ។ ទោះបីជាបណ្តាកម្មវិធី ដែលមានគោលដៅច្បាស់លាស់សម្រាប់តំបន់ជនបទ អាចអោយមានផលយ៉ាងឆាប់រហ័សចំពោះប្រជាជននៅជនបទក៏ដោយ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រក៏ត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការអភិវឌ្ឍន៍នៃវិស័យឧស្សាហកម្ម និងសេវាកម្មផងដែរ។ យុទ្ធសាស្ត្ររបស់យើង គឺមិនត្រឹមតែធ្វើទំនើបភាវូបីយកម្ម នៃវិស័យកសិកម្មប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវជំរុញការអភិវឌ្ឍន៍វិស័យដទៃទៀត ដែលអាចក្លាយទៅជាក្បាលរទេះភ្លើងដ៏មានថាមពល ដើម្បីអូសទាញកម្ពុជាពីច្រវាក់ខ្នោះឃ្នាងនៃភាពក្រីក្រតោកយ៉ាកនេះ។

បន្ថយភាពងាយរងគ្រោះរបស់ពលរដ្ឋក្រីក្រដោយពង្រឹងសមត្ថភាព ដើម្បីទប់ទល់នឹងវិបត្តិពីខាងក្រៅ ហើយបង្កើតនូវចីរភាពជាទូទៅនៃជីវភាពរបស់ពួកគេ គឺជាបញ្ហាអាទិភាពមួយដោយសារក្នុងពេលកន្លងមករដ្ឋមិនទាន់បានយកចិត្តទុកដាក់អោយបានគ្រប់ជ្រុងជ្រោយចំពោះការជួយដល់ជនក្រីក្រទាំងឡាយដែលមានបំណងចង់ឈប់ប្រកបរបរកសិកម្ម។ នាពេលបច្ចុប្បន្ននេះ យើងកំពុងផ្តោតការយកចិត្តទុកដាក់ចំពោះការផ្តល់ឥណទានសម្រាប់អនុវត្តសកម្មភាពណាដែលបង្កើតប្រាក់ចំណូល ពីព្រោះបញ្ហានេះបណ្តាលអោយមានកង្វះប្រាក់កាសដែលជាមូលហេតុធ្វើអោយមានការពន្យាពេលនៃការធ្វើវិនិយោគ និង/ឬ ជាមូលហេតុអោយមានការយកដីធ្លីទៅលក់ ដើម្បីយកប្រាក់មកទប់ទល់នឹងចំណាយផ្សេងៗ។ បញ្ហានេះអាចនឹងត្រូវដោះស្រាយបានតាមរយៈការផ្តល់នូវការធានារ៉ាប់រងប្រាក់សន្សំ និងឥណទានសម្រាប់ការប្រើប្រាស់។ ម្យ៉ាងវិញទៀត រដ្ឋអាចធានាបាននូវសន្តិសុខដោយបង្កើត និងពង្រីកការអនុវត្តន៍កម្មវិធីសុវត្ថិភាពសង្គម លើកស្ទួយកិច្ចការពារបរិស្ថាន និងការដោះមីន។

រាជរដ្ឋាភិបាល ត្រូវដើរតួនាទីយ៉ាងសំខាន់កក្នុងការផ្តល់សេវា និងការបន្តបង្កើនសមត្ថភាពរបស់ស្ថាប័នដែលមានការពាក់ព័ន្ធ។ ប្រការនេះតម្រូវអោយមាការយកចិត្តទុកដាក់លើគុណភាព និងលទ្ធភាពផ្តល់សេវាជូនពលរដ្ឋក្រីក្រ និងលើឧត្តមភាពប្រៀបធៀបរបស់រដ្ឋាភិបាល របស់អង្គការមិនមែនរដ្ឋាភិបាល និងរបស់ផ្នែកឯកជនដែលជាអ្នកផ្តល់សេវាទាំងនេះ។ ជាពិសេសកិច្ចដំណើរការនេះត្រូវផ្តោតលើតួនាទីរបស់រដ្ឋាភិបាលបញ្ហាប្រសិទ្ធភាព និងបញ្ហាពាក់ព័ន្ធដទៃទៀត ដូចជា កម្រិតនៃការធ្វើវិមជ្ឈការ និងការអនុវត្តន៍កម្មវិធីកំណែទម្រង់រដ្ឋបាលរបស់រដ្ឋាភិបាលជាដើម។ ការបង្កើនចំណាយថវិកាតែមួយមុខនោះនឹងមិននាំអោយមានការកាត់បន្ថយភាពក្រីក្រឡើយ។ ដូច្នេះ រដ្ឋាភិបាល បានចាត់វិធានការផ្សេងៗ ដើម្បីធានាការផ្លាស់ប្តូរគុណភាព តាមរយៈការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យមុនចំណាយ និងការពង្រឹងសវនកម្មក្រោយចំណាយ ដើម្បីជំរុញការអភិវឌ្ឍន៍បានដល់ភូមិ-ឃុំ។ វិធានការនេះតម្រូវអោយមាននូវការកាត់បន្ថយភាពនីតីវិធីក្នុងការបើកផ្តល់ថវិកា និងផ្តល់អោយអង្គភាពចំណាយ

នៅថ្នាក់ខេត្ត និងថ្នាក់កណ្តាល នូវលទ្ធភាពក្នុងការគ្រប់គ្រងថវិកាផ្ទាល់ខ្លួន ដោយកែប្រែអង្គភាពទាំងនេះអោយទៅជាមជ្ឈមណ្ឌលគ្រប់គ្រងថវិកា។

ក្នុងរយៈពេលខ្លី និងមធ្យម រាជរដ្ឋាភិបាលនឹងអនុវត្តសកម្មភាពជាអាទិភាព សម្រាប់ អភិបាលកិច្ចល្អ ដូចតទៅ:១-បង្កើតកន្សោមអាទិភាពមន្ត្រីរាជការនៅតាមក្រសួង-ស្ថាប័ន ដើម្បីបង្កើនគុណភាពក្នុងការផ្តល់សេវាសាធារណៈ និងបង្កើនផលិតភាព។ ២-ដាក់អោយអនុវត្តនូវប្រព័ន្ធរដ្ឋបាលតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីអោយប្រជាពលរដ្ឋកាន់តែច្រើនអាចមានលទ្ធភាពទទួលបាននូវសេវាសាធារណៈសំខាន់ៗ។ ៣-បង្កើនល្បឿនកំណែទម្រង់រដ្ឋ តាមរយៈការអនុវត្តន៍ផែនការសកម្មភាពកក្នុងការកាត់រំសាយកងទ័ព កំណែទម្រង់រដ្ឋបាល និងកំណែទម្រង់សារពើពន្ធក្នុងគោលដៅពង្រឹងនីតិរដ្ឋ និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចទីផ្សារ។ ៤-អនុវត្តអោយស៊ីជម្រៅនូវកម្មវិធីកំណែទម្រង់ក្នុងវិស័យយុត្តិធម៌ និងរៀបចំកម្មវិធីជាតិសម្រាប់កំណែទម្រង់តុលាការ។ ៥-អនុវត្តវិធានការនានា ដែលមានចែងនៅក្នុងផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល។

ផ្នែកចុងក្រោយនៃជំពូកនេះ គឺបានលើកឡើងនូដំណោះស្រាយបញ្ហាដែលពាក់ព័ន្ធមួយចំនួន ដូចតទៅ: ១-ទំនាក់ទំនងជាមួយអ្នកផ្តល់ជំនួយ និងចលនាឆ្ពោះទៅរកភាពជាដៃគូ ដែលការវិវត្តន៍ក្នុងរយៈពេលវែងក្នុងចំណោមដៃគូទាំងអស់ ដូចជា រាជរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងសហគមន៍ផ្តល់ជំនួយអន្តរជាតិ និងជាពិសេស គឺជាការផ្លាស់ប្តូរបែបផែនទំនាក់ទំនងទាំងក្នុងប្រទេស និងក្រៅប្រទេស។ ការផ្លាស់ប្តូរនេះដែរ អាចប្រព្រឹត្តទៅប្រកបដោយជោគជ័យបានល្អឹកណាតែ ដៃគូទាំងអស់យល់ឃើញច្បាស់នូវទស្សនទាន ស្តីពីភាពជាដៃគូថ្មីនេះ ហើយទទួលយកនិយមន័យ និងមានការយល់ដឹងជាទូទៅ និងការទទួលយកនីតិវិធីក្នុងការអនុវត្តន៍។ នៅពេលដែលរាជរដ្ឋាភិបាលមានបំណងប្រែក្លាយពី "ការពឹងផ្អែកលើអ្នកផ្តល់ជំនួយទៅកាន់កម្មសិទ្ធិរបស់ជាតិ" យើងត្រូវប្រែក្លាយអោយបានឆាប់ពីការត្រួតពិនិត្យទៅកាន់ ការដឹកនាំ និងពីគ្រាន់តែដើរតួនាទីសម្របសម្រួលកាន់កិច្ចសហការគ្នា ដោយផ្តើមចេញពីមូលដ្ឋាននៃយន្តការសម្របសម្រួល និងគ្រប់គ្រងជំនួយក៏ដូចជាការពិភាក្សារបស់អ្នកផ្តល់ជំនួយក្នុងពេលបច្ចុប្បន្ននេះ។ ប្រការនេះនឹងអនុញ្ញាតអោយយើងឆ្លងកាត់អន្តរកាលពីដំណាក់កាលគ្រប់គ្រងដោយអន្លើៗមកកាន់ដំណាក់កាលអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ តាមកម្មវិធីច្បាស់លាស់ដោយប្រើប្រាស់ផែនការសកម្មភាពជាអាទិភាព(PAP) របស់យើងនៅក្នុងវិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ និងកសិកម្ម។ ទន្ទឹមនឹងនេះ ប្រព័ន្ធនេះបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងកម្មវិធីចំណាយសាធារណៈក្នុងរយៈពេលមធ្យម(MTEF) កម្មវិធីវិនិយោគសាធារណៈ(PIP) ដែលដំណើរការក្នុងក្របខ័ណ្ឌនៃប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ(PIMS)។ ប្រការទាំងនេះនឹងជួយសម្រួលអោយយើងឈានឡើងពីការពឹងផ្អែកទាំងស្រុងទៅកាន់ចីរភាព។ ក៏ប៉ុន្តែ ដើម្បីសម្រេចបាននូវគោលដៅនេះ រាជរដ្ឋាភិបាលកំពុងដាក់ចេញនូវវិធានការ ដើម្បីជៀសវាងនូវករណីអសកម្មនានា ដូចជា ការបាត់បង់ថវិកា និងអំពើពុករលួយក្នុងគោលដៅប្រមូលផ្តុំនូវថវិការបស់រដ្ឋ និងជំនួយពីក្រៅប្រទេសអោយនៅក្នុងកញ្ចប់តែមួយ។ ២-ការប្រមូលចំណូលបានតិចធ្វើអោយកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយភាពក្រីក្រជួយប្រទះនឹងការលំបាកយ៉ាងខ្លាំង។ ដោយសារទីចាត់ការគយ

និងរដ្ឋាករ ជាស្ថាប័នមានសមត្ថកិច្ចប្រមូលចំណូលមួយភាគធំចូលថវិការដ្ឋ រាជរដ្ឋាភិបាលបានចាត់វិធានការពង្រឹងរដ្ឋបាលគយអោយឈានដល់កម្រិតអន្តរជាតិ។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តធ្វើវិសោធនកម្មលើច្បាប់ និងលិខិតបទដ្ឋានកាត់បន្ថយនីតិវិធីគយ ប្រយុទ្ធប្រឆាំងនឹងអំពើរត់ពន្ធ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការងារធ្វើពាណិជ្ជកម្ម ការរៀបចំស្ថិតិ ការផ្តល់ព័ត៌មាន និងរបាយការណ៍ និងការរៀបចំរដ្ឋបាលគយទំនើបមួយ។ សកម្មភាពសម្រាប់រយៈពេលខ្លី និងសម្រាប់រយៈពេលមធ្យម ដែលរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តអនុវត្តន៍ ដូចមានចែងនៅក្នុងកម្មវិធីឥណទាន ការកាត់បន្ថយភាពក្រីក្រ និងកំណើន(PRGF) និងក្នុងកម្មវិធីឥណទាន កំណែទម្រង់រចនាសម្ព័ន្ធ(SAC) ត្រូវបានច្របាច់បញ្ចូលទៅក្នុងតារាងគោលនយោបាយនៃឧបសម្ព័ន្ធទី១។ សកម្មភាពនេះក៏បានឆ្លុះបញ្ចាំងនូវខ្លឹមសារសង្ខេបនៃឯកសារ ដែលរាជរដ្ឋាភិបាលបានរៀបចំសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ CGM ដែលបានប្រព្រឹត្តទៅនៅក្នុងខែឧសភា ឆ្នាំ២០០០ នាទីក្រុងប៉ារីស។ រាជរដ្ឋាភិបាលនឹងធ្វើការពិនិត្យឡើងវិញនូវតារាងគោលនយោបាយនេះ ក្នុងបរិការណ៍ នៃការឯកភាពរវាងភាគីដែលមានការពាក់ព័ន្ធនៅពេលរៀបចំឯកសារចុងក្រោយ ស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។

នៅក្នុងជំពូកទី៣ ដែលស្តីអំពី ស្ថានភាពក្រីក្រចន្លោះឆ្នាំ១៩៩៩-២០០៨ យើងអាចធ្វើការសន្និដ្ឋានបានដូចតទៅនេះ: ដោយសារស្ថានភាពភូមិសាស្ត្រធម្មជាតិរបស់ប្រទេសកម្ពុជាទទួលបាននូវលក្ខណៈអំណោយផលសម្រាប់ការអភិវឌ្ឍន៍ ទោះបីជីមានសភាពមិនល្អ ជាពិសេស និងប្រព័ន្ធធារាសាស្ត្រស្មុគស្មាញក៏ដោយ ក៏ប្រទេសកម្ពុជា មានកំពង់ផែសមុទ្រសំបូរទៅដោយវាលរាប ដែលអាចដាំដុះបាន ត្រីទឹកសាបប្រកបដោយផលិតភាពខ្ពស់ និងសម្បត្តិព្រៃឈើដ៏ធំធេង។ ប្រទេសកម្ពុជាក៏មានសក្តានុពលទេសចរណ៍ដ៏ខ្លាំងក្លាដែរ។ សំខាន់ជាងនេះទៅទៀត ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ដែលមានការលូតលាស់យ៉ាងឆាប់រហ័ស ដោយមានព្រំដែនគោកដែលអាចផ្តល់ការចូលទៅកាន់ទីផ្សារប្រទេសថៃ និងប្រទេសវៀតណាមបាន។

ភាពក្រីក្រនៃប្រទេសកម្ពុជាបច្ចុប្បន្ន គឺបណ្តាលមកពីបញ្ហាជម្លោះដិតបីទសវត្សជាមូលដ្ឋាន។ សង្គ្រាមស៊ីវិលបានចាប់ផ្តើមនៅឆ្នាំ១៩៧០ ហើយត្រូវបានបញ្ចប់ដោយជ័យជំនះរបស់ខ្មែរក្រហម(KR) ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានសម្លាប់ស្ទើរតែមួយភាគប្រាំនៃប្រជាជនកម្ពុជា ឬមួយដោយចេតនា ឬតាមរយៈគោលនយោបាយដឹកនាំខុសទិស។ នៅក្នុងទសវត្សឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានងើបឡើងវិញយ៉ាងយឺតក្នុងបរិបទនៃជម្លោះ ដែលមាន "ប្រពលភាពកម្រិតទាប" និងភាពឯកកោពីសហគមន៍អន្តរជាតិ។ ជម្លោះនេះបានបំផ្លាញគ្រប់ហេដ្ឋារចនាសម្ព័ន្ធ កម្ទេចមូលធនមនុស្សរបស់ប្រជាជាតិ និងបានធ្វើអោយទន់ខ្សោយ ឬបម្លែងស្ថាប័នសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយទាំងឡាយ។

ប្រទេសកម្ពុជា បាននឹងកំពុងអនុវត្តន៍គោលការណ៍ទាំងបី ក្នុងសម័យអន្តរកាលតាំងពីឆ្នាំ១៩៩០។ ទីមួយ ប្រទេសកម្ពុជា បានចេញផុតពីសង្គ្រាមស៊ីវិលមកសន្តិភាព។ ទីពីរ ប្រទេសកម្ពុជា បានអនុវត្តពីនយោបាយបក្សតែមួយមកពហុបក្សក្នុងសម័យអន្តរកាល។ ទីបំផុត ប្រទេសកម្ពុជាបានរួចផុតពីសេដ្ឋកិច្ចឯកកោ មានកំណើនទាបគ្រប់គ្រងដោយរដ្ឋ និងតម្រង់ទិសដើម្បីគ្រាន់តែរស់ ដែលក្នុងនោះមនុស្សភាគច្រើនស្ថិតក្នុងភាពក្រីក្រដូចគ្នា

មករកបែបជាសេដ្ឋកិច្ចទីផ្សារ ដែលបើកចំហដល់លំហូរមូលធនទំនិញ និងពលកម្មអន្តរជាតិ ដែលក្នុងនោះ កំណើនសេដ្ឋកិច្ចបានទាញប្រជាជនមួយចំនួនធំចេញពីបន្ទាត់ភាពក្រីក្រ ប៉ុន្តែវិសមភាពនេះបានកើតឡើងយ៉ាងលឿន: មនុស្សមួយចំនួនធំ មិនបានបែងចែកនៅកំណើនសេដ្ឋកិច្ចទេ ហើយអ្នកខ្លះកំពុងទទួលរងការធ្លាក់ចុះនៃកម្រិតជីវភាព។ ក្នុងសម័យអន្តរកាលនេះ ប្រភេទការងារមួយចំនួនត្រូវបានសម្រេចច្រើនជាងចំនួនប្រភេទការងារផ្សេងៗទៀត។ ទន្ទឹមនឹងនេះផងដែរ សម័យអន្តរកាលនេះ ក៏បានផ្តល់នៅទម្រង់នៃការផ្លាស់ប្តូរសង្គមកិច្ច និងសេដ្ឋកិច្ចនូវកំណើនសេដ្ឋកិច្ច ដែលមានឥទ្ធិពលខ្លាំងក្លា ប៉ុន្តែនៅតែមិនត្រូវបានយល់យ៉ាងច្បាស់លាស់នៅឡើយ។ ការផ្តល់និយមន័យដល់ពាក្យ "ក្រោយជម្លោះ" អំពើហិង្សានយោបាយ ដែលមានរយៈពេលយូរជាងការពឹងទុក មានផលប៉ះពាល់អវិជ្ជមានយ៉ាងជ្រៅដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃនេះ។ រយៈពេលជិត ៣ទសវត្ស នៃជម្លោះផ្ទៃក្នុងដែលធ្វើអោយរឹតតែមានសភាពអាក្រក់ជាងមុន ដោយសារគូប្រឆាំងក្នុងសង្គ្រាមត្រជាក់ មិនគ្រាន់តែសម្លាប់ជីវិតមនុស្ស រាប់លាននាក់ប៉ុណ្ណោះទេ ប៉ុន្តែក៏បានធ្វើអោយខូចគ្រឹះជាច្រើននៃការអភិវឌ្ឍន៍ជាតិផងដែរ។

នៅក្នុងតំបន់កំណាលនៃប្រទេសកម្ពុជា ដែលត្រូវបានធ្វើការអង្កេតម្តងនៅក្នុងឆ្នាំ១៩៩៣-១៩៩៤ និងម្តងទៀតនៅឆ្នាំ២០០៤(ក្របខ័ណ្ឌធ្វើគំរូតាមភូមិសាស្ត្រ ដែលអាចប្រៀបធៀបបាន) អត្រាភាពក្រីក្របានធ្លាក់ចុះពី៣៩%មកត្រឹម២៨%ក្នុងអំឡុងពេល ១០ឆ្នាំនេះ។

ទោះបីជាយ៉ាងនេះក៏ដោយ តំបន់ជាច់ស្រយាល និងតំបន់ខ្ពស់ផ្សេងទៀត ដែលមិនត្រូវបានធ្វើការអង្កេតនៅឆ្នាំ១៩៩៣-១៩៩៤ មាន(ហើយនៅតែមាន) ភាពក្រីក្រជាង។ យើងអាចប៉ាន់ប្រមាណបានពីអត្រាភាពក្រីក្រនៅទូទាំងប្រទេសកម្ពុជាឆ្នាំ១៩៩៣-១៩៩៤ ដោយផ្អែកលើនិន្នាការនៅក្នុងក្របខ័ណ្ឌធ្វើគំរូតាមភូមិសាស្ត្រ ដែលអាចប្រៀបធៀបបាន និងអ្វីដែលយើងបានដឹងអំពីប្រជាជន និងភាពក្រីក្រនៅក្នុងតំបន់ជាច់ស្រយាលទាំងនោះ។ ដោយប្រើប្រាស់ព័ត៌មានទាំងនេះ យើងអាចប៉ាន់ប្រមាណថា អត្រាភាពក្រីក្រនៅកម្ពុជាទាំងមូលធ្លាក់ចុះពី ៤៧% នៅឆ្នាំ១៩៩៤ (ប៉ាន់ប្រមាណថយក្រោយ) មកត្រឹម ៣៥%(ដែលបានវាស់វែង) នៅឆ្នាំ២០០៤។ ដោយសាមានមន្ទិលពីការប៉ាវ៉ាម៉ែត្រមួយចំនួន និងភាពមិនល្អិតល្អន់ក្នុងការទាញយកលទ្ធផលនេះ វាមានសុវត្ថិភាពជាង ក្នុងការនិយាយថា អត្រាភាពក្រីក្រនៅកម្ពុជានៅឆ្នាំ១៩៩៤ ស្ថិតនៅចន្លោះ ៤៥ ទៅ ៥0% ។ ដូច្នេះ យើងអាចប៉ាន់ប្រមាណថា រវាងឆ្នាំ១៩៩៤ និង ២00៤ អត្រាភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះរវាង ១0 ទៅ ១៥%។

ឥឡូវនេះទិន្នន័យនៃការអង្កេតគ្រួសារថ្មីៗ បញ្ជាក់យ៉ាងច្បាស់ថា ភាពក្រីក្របានបន្តធ្លាក់ចុះយ៉ាងខ្លាំងក្នុងទសវត្សចាប់ពីប្រទេសកម្ពុជាងើបឡើងពីជម្លោះ ហើយចាប់ផ្តើមធ្វើដំណើរលើផ្លូវអភិវឌ្ឍន៍ "ធម្មតា" មក។ ដែលរស់ក្នុងគ្រួសារ ដែលតម្លៃនៃការប្រើប្រាស់ក្នុងមនុស្សម្នាក់ស្ថិតនៅក្រោមខ្សែបន្ទាតភាពក្រីក្រនេះបានធ្លាក់ចុះ។ ការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតពិវិសាលភាពនៃការប្រែប្រួលនេះបង្ហាញថា អត្រាភាពក្រីក្រ គឺចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ផ្អែកលើការប្រើប្រាស់បានធ្លាក់ចុះពី ៤៧% នៅចន្លោះឆ្នាំ១៩៩៤ មកត្រឹម

៣៥% នៅឆ្នាំ២០០៤។ ដោយគិតពីការសង្ស័យមួយចំនួនអំពីតួលេខពិតប្រាកដនៃការរាប់ប្រជាជននៅឆ្នាំ ១៩៩៤ យើងអាចនិយាយការពារដោយមានការជឿទុកចិត្តថា ភាពក្រីក្រនៅឆ្នាំ១៩៩៤ អាចស្ថិតនៅចន្លោះ ៤៥% និង ៥០% ។ ផ្អែកលើមូលដ្ឋាននេះ យើងអាចនិយាយបានថា ភាពក្រីក្របានធ្លាក់ចុះប្រមាណពី ១០ ទៅ១៥% ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ឬប្រហែល ១% ក្នុងមួយឆ្នាំ។ ការនេះបញ្ជាក់ពីការយល់ខុស ចំពោះការចាប់អារម្មណ៍ទូទៅលើកំណើនសេដ្ឋកិច្ចថា មានឥទ្ធិពលតិចតួច ឬក៏គ្មានឥទ្ធិពលលើភាពក្រីក្រសោះ នោះ។ នេះគឺជាការចាប់អារម្មណ៍ ដែលកើតឡើងនៅពេលដែលការប៉ាន់ស្មាននានាពីភាពក្រីក្រ ដកស្រង់ចេញពី ការអង្កេតក្នុងទសវត្សឆ្នាំ៩០ ត្រូវបានយកមកប្រៀបធៀប ទោះតាមការពិត ការប៉ាន់ស្មាន ទាំងនោះមិនអាច ប្រៀបធៀបានទេ។

អត្រាភាពក្រីក្រនៅឆ្នាំ២០០៤ គឺមានប្រមាណជា ៣៥% មានន័យថា ៣៥% នៃប្រជាជនកម្ពុជា ត្រូវ បានប៉ាន់ស្មានថា រស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ។ ឯភាពក្រីក្រនៅជនបទ(៣៩%) មានកម្រិតខ្ពស់ជាង នៅទីក្រុង (៥% នៅភ្នំពេញ និងនៅតំបន់ទីប្រជុំជនផ្សេងទៀត)។

ភាពក្រីក្រនៅកម្ពុជា គឺជាអភូតហេតុជនបទយ៉ាងលើសលប់មួយ។ នៅឆ្នាំ២០០៤ ប្រហែល ៩១% នៃ ជនក្រីក្របានរស់នៅក្នុងតំបន់ជនបទ។ តំបន់ជនបទនៅក្នុងភូមិភាគទន្លេសាប និងភូមិភាគភ្នំ/ខ្ពង់រាប បានទទួល រងអត្រាភាពក្រីក្រកម្រិតខ្ពស់បំផុត និងប្រពលភាពនៃភាពក្រីក្រធ្ងន់ធ្ងរបំផុត។ អត្រាភាពក្រីក្រនៅភូមិភាគ ជនបទទន្លេសាប និងភូមិភាគជនបទភ្នំ/ខ្ពង់រាប គឺ ៤៥% និង ៥៦% តាមលំដាប់។

ការប្រើប្រាស់បន្ទាត់ភាពក្រីក្រ: ប្រៀបធៀបបន្ទាត់ភាពក្រីក្រ និងបន្ទាត់ ១ដុល្លារ ១ថ្ងៃ : ដើម្បីតាមដាន មើលភាពក្រីក្រថ្នាក់ពិភពលោក គេចាំបាច់ត្រូវមានរង្វាស់ភាពក្រីក្រ ជាច់ខាត ដែលមានលក្ខណៈជាបទដ្ឋានរួម អាចប្រៀបធៀបពីប្រទេសមួយទៅប្រទេសមួយ និងពីមួយឆ្នាំទៅមួយឆ្នាំដោយជាក់ស្តែង។ តម្រូវការអោយមាន ចំណុចសម្រេចជាអន្តរជាតិនេះបានធ្វើអោយគេប្រកាន់យកបន្ទាត់មួយ ដែលគេហៅថា "១ដុល្លារក្នុង១ថ្ងៃ" ដែលកំណត់បន្ទាត់ភាពក្រីក្រផ្អែកលើទំនិញ និងសេវាដែលអាចទិញបានសម្រាប់ ១ដុល្លារ សម្រាប់ម្នាក់ក្នុងមួយ ថ្ងៃនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៣។ ដូច្នេះ ពាក្យពេញនៃបន្ទាត់ភាពក្រីក្រអន្តរជាតិគឺ ១ដុល្លារ ១នាក់ ក្នុង១ថ្ងៃ គិតតាមអំណាចទិញខុសៗគ្នាធៀបនឹងឆ្នាំ១៩៩៣។ ដោយសារថ្លៃទំនិញ និងសេវា(ជាពិសេសថ្លៃអាហារ) នៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំ មានកម្រិតទាបជាងនៅសហរដ្ឋអាមេរិកតម្លៃពិតប្រាកដនៃប្រាក់ ១ដុល្លារ គិតតាមអំណាចទិញខុសគ្នាធៀបនឹងឆ្នាំ១៩៩៣ នៅប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយនោះមានកម្រិតស្មើនឹង ១.៣៨២រៀល ក្នុងមួយនាក់ ក្នុង ១ថ្ងៃ (ឬ ០.៣៤ដុល្លារ គិតតាមថ្លៃនៅឆ្នាំ២០០៤)។ ដូចនេះ បន្ទាត់ភាពក្រីក្រ អន្តរជាតិ ១ដុល្លារ ក្នុង ១ថ្ងៃ មានតម្លៃជាក់ស្តែងទាបជាងបន្ទាត់ភាពក្រីក្រជាតិ និងដែលត្រូវបានប្រើប្រាស់នៅ ក្នុងរបាយការណ៍នេះ គឺតម្លៃ ១.៧៥៣រៀល(០.៤៣ដុល្លារ) សម្រាប់១នាក់ក្នុង១ថ្ងៃនៅជនបទ និង ២,៣៥១ រៀល(០.៥៨ដុល្លារ)សម្រាប់១នាក់ក្នុង១ថ្ងៃនៅភ្នំពេញ។

យេនឌ័រ និងភាពក្រីក្រនៅកម្ពុជា: តាមការសិក្សាឯកសារសង្គមវិទ្យា និងនរវិទ្យាតែងតែសង្កត់ធ្ងន់លើ "សមភាពប្រៀបធៀប" រវាងបុរស និងស្ត្រីនៅកម្ពុជា ហើយចែងថា ស្ត្រីកម្ពុជាតាមប្រពៃណីកន្លងមកមានឋានៈសង្គម និងឯករាជ្យភាពច្រើនជាងស្ត្រីនៃប្រទេសមួយចំនួន ដូចជា ឥណ្ឌា និងចិន(Ledgerwood 2005)។ អាពាហ៍ពិពាហ៍ មិនតម្រូវអោយខាងស្រីជូនជំនូនទៅខាងប្រុស ហើយចំណងទាក់ទងសាច់ញាតិរវាងខាងប្រុស និងខាងស្រី និងប្រពៃណីអោយខាងប្រុសទៅនៅជាមួយឪពុកម្តាយខាងស្រី ក្រោយពេលរៀបការផ្តល់នូវការគាំទ្រខាងគ្រួសារដល់ស្ត្រី(UNDP 1998)។ ស្ត្រីចូលរួមយ៉ាងសកម្មនៅក្នុងសេដ្ឋកិច្ច ហើយពលកម្មកសិកម្មអាចបែងចែកតាមប្រភេទ ការងារសម្រាប់បុរស និងស្ត្រី (កាន់តែធ្វើដូច្នេះច្រើនឡើង)។ ភាគច្រើនស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការចាត់ចែងប្រាក់ចំណូល និងចំណាយរបស់គ្រួសារដោយមានការសម្រេចចិត្តរួមគ្នាលើបញ្ហាសេដ្ឋកិច្ចមួងៗ។

ជនជាតិភាគតិច និងភាពក្រីក្រ: ជនក្រីក្រជាងគេបំផុត និងជាក្រុមជនជាតិមានចំនួនតិចជាងគេបំផុតនៅប្រទេសកម្ពុជា គឺជាអ្នកភ្នំ(ខ្មែរលើ ជនជាតិ ឬ"ក្រុមកុលសម្ព័ន្ធ") ដែលរស់នៅជាពិសេសក្នុងតំបន់ខ្ពស់ពោរពេញដោយព្រៃឈើក្នុងខេត្តឦសាន នៃប្រទេស: រតនគីរី មណ្ឌលគីរី ក្រចេះ និងស្ទឹងត្រែង។ ក្រុមចំនួន ១៧ សំខាន់ៗ ដែលក្រុមនីមួយៗមានចំនួនសមាជិកពីរាប់រយនាក់ទៅដល់ ១៩.០០០នាក់ រួមគ្នាទៅមានប្រហែល ១០៤.០០០០នាក់ ឬតិចជាង ០,១%នៃប្រជាជនទូទាំងប្រទេស។

គ្រួសារដែលមានមេគ្រួសារជាកសិករ និងជាអ្នកបម្រើតាមផ្ទះមានទំនងជាក្រីក្រជាងគេច្រើន: អត្រាភាពក្រីក្រមានកម្រិតខ្ពស់បំផុតក្នុងចំណោមកសិករ និងអ្នកបម្រើតាមផ្ទះ។ គ្រួសារដែលមានមេគ្រួសារជាកសិករបង្កបង្កើនផលដោយផ្ទាល់ខ្លួនឯង និងជាអ្នកបម្រើតាមផ្ទះមានចំនួនលំដាប់បន្តបន្ទាប់ ៤៨% និង ១៣% នៃប្រជាជនទាំងអស់។ គ្រួសារដឹកនាំអោយអ្នកបម្រើតាមផ្ទះក៏មានអត្រាភាពក្រីក្រខ្ពស់ជាងគេបំផុតដែរក្នុងទិដ្ឋភាពក្រីក្រនៅឆ្នាំ១៩៩៤ ហើយមានចំនួនកើនឡើងក្នុងចំណោមប្រជាជនទាំងអស់(៩%នៅឆ្នាំ២០០៤)។ អត្រាភាពក្រីក្រប៉ាន់ស្មានទាបជាងគេបំផុត គឺជារបស់គ្រួសារដែលមានមេគ្រួសារជាមន្ត្រីក្នុងវិស័យសាធារណៈ។ ទម្រង់ទាំងនេះមានតួលេខដូចគ្នាយ៉ាងទូលំទូលាយជាមួយនឹងរបបគំហើញនៃទិដ្ឋភាព ភាពក្រីក្រលើកមុន។

បន្ទាប់ពីការសិក្សាលើជំពូកទី២ និងជំពូកទី៣ រួចមក យើងអាចធ្វើវិភាគលើមូលហេតុនៃភាពក្រីក្រកម្ពុជាដែលស្ថិតនៅក្នុងជំពូកទី៤ ដែលមានអត្ថន័យសង្ខេបដូចទៅ:

បញ្ហានៃភាពក្រីក្រ គឺកើតឡើងដោយសារបញ្ហាប្រឈមពីរគឺ: ១-មូលហេតុនៃនយោបាយ: សង្គ្រាម និងការផ្លាស់ប្តូររបបនយោបាយនៃការគ្រប់គ្រងញឹកញាប់ ធ្វើអោយប្រទេសគ្មានលំនឹងស្ថិរភាពនយោបាយកើតមានវិបត្តិនយោបាយរ៉ាំរ៉ៃ។ សង្គ្រាមបានបំផ្លាញសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យរបស់ជាតិអោយធ្លាក់ដុនដាប់ប្រជាជនរស់នៅគ្មានសេចក្តីសុខ ផ្លាស់ប្តូរទីលំនៅជាញឹកញាប់ទៅរកកន្លែងដែលមានសុវត្ថិភាព បាត់បង់ពេលវេលាបង្កបង្កើនផល ការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គម ហើយជាពិសេសនៅចន្លោះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩ ដែលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យ

(ប៉ុល ពត) គឺសហាវឃោរឃៅបំផ្លិចបំផ្លាញជាងពេលមានសង្គ្រាមថែមទៀត។ វិបត្តិកើងមានផ្ទួនៗសម្រាប់កម្ពុជា ធ្វើអោយមានការខ្វះស្បៀងអាហារ ដែលនាំអោយសុខមាលភាពប្រជាជនចុះដុនដាប ពោលគឺជីវិតរស់នៅមានរយៈពេលខ្លី។ សង្គ្រាមបានបន្សល់ទុកនូវភាពក្រីក្រ ជនអនាថា ជនពិការ និងស្ត្រីមេម៉ាយ ដែលធ្វើអោយបាត់បង់នូវប្រពលភាព និងភាពងាយទទួលរងគ្រោះ។ សង្គ្រាមបានគំរាមកំហែង និងបន្សល់ទុកនូវគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនផ្ទុះជាច្រើននៅលើដី ដែលប្រជាជនត្រូវការបង្កបង្កើនផល។ យោងតាមទិន្នន័យព័ត៌មាន ដែលស្រាវជ្រាវដោយស៊ីម៉ាក ដែលទើបតែបញ្ចប់ជាស្ថាពរនៅខែមេសា ឆ្នាំ២០០២ បានបង្ហាញនូវលទ្ធភាពឃើញថា មានភូមិចំនួន ៦៤២២ភូមិ ប្រមាណជា ៤៦,២%នៃភូមិទូទាំងប្រទេស ត្រូវរងនូវការគំរាមកំហែងដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបានបន្សល់ទុកដោយសារតែសង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សកន្លងមក ចំណុចដែលបង្កប់ទៅដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ១១១.២៨៧កន្លែង។ ជី ដែលសង្ស័យថា មានគ្រាប់មីននោះទំហំ ៤.៤៦៦គីឡូម៉ែត្រក្រឡា ដែលជីភាគច្រើនជាកន្លែងរស់នៅរបស់ប្រជាពលរដ្ឋ។ មានប្រជាពលរដ្ឋ ដែលរងនូវការគំរាមកំហែងពីមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ៥.១៨៦.៧៧១នាក់ ត្រូជា ៤៥,៣%នៃប្រជាពលរដ្ឋទូទាំងប្រទេស។ ទោះបីកម្ពុជាបានទទួលសន្តិភាព ១០០% ក៏ដោយក៏គ្រាប់មីនដែលនៅសេសសល់ពីសង្គ្រាមយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងព្រៃ និងស្រែចំការបានបង្ករគ្រោះថ្នាក់ជារៀងរាល់ថ្ងៃដល់ប្រជាជនស្លូតត្រង់ជាពិសេសអ្នករស់នៅតំបន់ដាច់ស្រយាល បណ្តាលអោយពួកគេក្លាយទៅជាជនពិការអស់មួយជីវិត ឬស្លាប់បាត់បង់ជីវិតយ៉ាងអាណោចអាធមជាទីបំផុត។ សង្គ្រាមនេះ គឺបានបន្សល់ទុកនូវអនុស្សាវរីយ៍មួយរយជំពូកដ៏សែនជូរចត់បំផុតដល់កូនខ្មែរជំនាន់ក្រោយ ក៏ដូចជាសង្គមខ្មែរទាំងមូល។ ព្រោះតែសង្គ្រាមធ្វើអោយប្រជាពលរដ្ឋខ្មែរយើងធ្វើការកាប់សម្លាប់គ្នាឯង ដើម្បីអោយតែឈ្នះតាមចិត្តមានៈនៃមហិច្ឆតានោះ។ ជាក់ស្តែងសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៧០-១៩៩៨ បានផ្លាស់ប្តូរបបគ្រប់គ្រងរហូតដល់ ៦របប ដែលមានៈទី១-១៩៧០-១៩៧៥ របបសាធារណរដ្ឋខ្មែរ ។ ទី២-១៩៧៥-១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យ។ ទី៣-១៩៧៥-១៩៨៩ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ទី៤-១៩៨៩-១៩៩២ របបរដ្ឋកម្ពុជា។ ទី៥-១៩៩២-១៩៩៣UNTAC។ ទី៦-១៩៩៣-បច្ចុប្បន្ន របបព្រះរាជាណាចក្រកម្ពុជា។ ចំណែកឯបញ្ហាទី២ គឺមូលហេតុនៃសង្គមៈ បញ្ហាអភិរក្សនិយមសង្គមខ្មែរយើងឃើញថា ទោះបីជាមានដំណើរប្រែប្រួលជាប្រវត្តិសាស្ត្រយ៉ាងណាក៏ដោយ ក៏សង្គមខ្មែរហាក់ដូចជាមិនសូវកម្រើកខ្លួនសោះតាំងពីច្រើនសតវត្សមកហើយ។ ព្រះពុទ្ធសាសនា ដែលតាំអោយមានឡើងជាច្រើនសតវត្សមកហើយនោះនៅតែជាសាសនារបស់ជាតិដដែល ហើយអារក្សអ្នកតាមបានរក្សាតួនាទីដ៏ប្រសើរមួយដូចពីដើម។ ភាសាខ្មែរនៅតែជាភាសាជាផ្លូវការ ការធ្វើស្រែចំការបានរួមបង្កជាសកម្មភាពដ៏សំខាន់បំផុតរបស់ប្រជាជនភាគច្រើន។ ប្រជាជននៅតែមានជំនឿតឹងពាក់ទៅលើព្រះមហាក្សត្រ ដែលជាប្រមុខរដ្ឋដើម្បីដួយរកយុត្តិធម៌ និងគ្រប់គ្រងរបស់ពួកគេថែមទៀត។ ការគោរពខ្លាចក្រែងបុគ្គលមន្ត្រីរាជការតាមឋានានុក្រមបុណ្យស័ក្តិបានកើតមាននៅគ្រប់ទីកន្លែង។ ការចូលចិត្តរៀបឬកភាពសម្បើម ដែលជាចរិកលក្ខណៈរបស់មន្ត្រី ឬអ្នកមានអំណាចទាំងឡាយសព្វថ្ងៃនេះបានស្ថិតនៅក្នុងចំណោមបុគ្គលជាច្រើនជាពិសេសពួកអ្នក

ទីក្រុងផងដែរ ដែលខ្វល់ខ្វាយតែពីរឿងបង្កើតទ្រព្យសម្បត្តិរបស់ពួកគេជានិច្ច ហើយគិតយ៉ាងម៉េចអោយតែលើសអ្នកជិតខាងរបស់ខ្លួន។ ពិតហើយចំណែកឯប្រជាកសិកររនៅតាមជនបទ ស្រែចំការពួកគេខ្វាយខ្វល់តែពីបញ្ហាអាកាសធាតុ ដូចជា ការបន់ស្រន់អារក្សអ្នកតា ឬរកព្រះមហាក្សត្រអោយជួយធ្វើពីធីបួងសួង និងពិភាល់ថាអ្វីៗ និងរៀបរយស្រួលបួលទៅតាមដំណើររបស់វាតែប៉ុណ្ណោះ។ អំពើពុករលួយ ជាបញ្ហាសំខាន់ដែលមានឥទ្ធិពលអាក្រក់ដល់អ្នកក្រីក្រ ទាំងការជះឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចដោយចីរភាព ចំណូលរបស់រដ្ឋាភិបាលនិងទាំងការចំណាយផ្ទាល់ដែលតម្រូវលើគ្រួសារ។ ការស្វែងរកសេវាកម្មអប់រំ សុខាភិបាល និងសេវាសាធារណៈផ្សេងទៀត ដែលមានទម្រង់បង់ថ្លៃឈ្នួលមិនស្របច្បាប់(តម្លៃថ្លៃ) គឺជាបន្ទុកយ៉ាងធ្ងន់របស់អ្នកក្រីក្រ។ អនក្ខរជនជារបាំងមួយ ចំពោះអ្នកក្រីក្រធ្វើអោយជីវិតរបស់ពួកគេស្ថិតនៅក្រៅដំណើរការអភិវឌ្ឍន៍ទាំងចេតនា ឬអចេតនា។ អនក្ខរជន ត្រូវបានគេមើលងាយយ៉ាងខ្លាំងក្នុងសង្គមកម្ពុជា ហើយខ្លួនឯងមានអារម្មណ៍ថា ជាអ្នកស្ថិតនៅក្រៅសង្គមដោយខ្លួនឯង។ អនក្ខរជនងាយរងនូវហានិយភ័យខ្ពស់ ដូចជា ការអូសទាញផ្សេងៗទាំងផ្លូវល្អ និងផ្លូវអាក្រក់ ដែលជាហេតុធ្វើអោយមានការប្រាស់ចាកពីក្រមសីលធម៌សង្គមធ្វើអោយមានភាពប្រកួតប្រជែងបង្កអស្ថេរភាពរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សង្គម។ ការប្រព្រឹត្តទៅនៃសេវាសុខាភិបាលសម្រាប់អ្នកក្រីក្រ និងអ្នករស់នៅក្នុងជនបទមិនសូវបានដំណើរការល្អពីព្រោះ ទាំងគ្រឿងសម្ភារៈប្រើប្រាស់ និងអ្នកផ្តល់សេវាពេទ្យផ្តោតតែលើប្រជាជនរស់នៅទីក្រុង ពុំបានយកចិត្តទុកដាក់ដល់តំបន់ជនបទដាច់ស្រយាល។ "កស្តុតាងទាំងឡាយបញ្ជាក់ថា ថវិកាដ៏មានកម្រិតរបស់ក្រសួងសុខាភិបាលត្រូវប្រើប្រាស់សម្រាប់ឧបត្ថម្ភសេវា ដែលការប្រើប្រាស់បានភាគច្រើនដោយអ្នកមានចំណូលមធ្យម និងខ្ពស់មិនមែនសម្រាប់បង្កើនគុណភាពនៃសេវាសម្រាប់អ្នកក្រីក្រ ឬការលើកទឹកចិត្តដល់អ្នកក្រីក្រដើម្បីទទួលបាននូវការព្យាបាលដ៏សមស្របនៅតាមមន្ទីពេទ្យរដ្ឋទេ។

ស្រុកជុំគីរី មានទីតាំងស្ថិតនៅប៉ែកឦសាននៃទីរួមខេត្តកំពត មានចំងាយ ៥៥គ.ម ពីទីរួមខេត្ត ដែលមានព្រំប្រទល់:

-ខាងជើងទល់នឹង ស្រុកបសែធ ខេត្តកំពង់ស្ពឺ និងស្រុកត្រាំកក់ ខេត្តតាកែវ

-ខាងត្បូងទល់នឹង ស្រុកឈូក

-ខាងកើតទល់នឹង ស្រុកត្រាំកក់ ខេត្តតាកែវ

-ខាងលិចទល់នឹង ឃុំតាកែន ស្រុកឈូក

នៅក្នុងស្រុកជុំគីរីត្រូវបានបែងចែកជា ០៧ឃុំ មានចំនួន ៣៧ភូមិ មានសាលាមត្តេយ្យ០៥កន្លែង បឋមសិក្សា២៥កន្លែង អនុវិទ្យាល័យ០៥កន្លែង វិទ្យាល័យ០១កន្លែង មណ្ឌលសុខភាព០៤កន្លែង មានប្រជាពលរដ្ឋសរុប៤៧.៥១៩នាក់ ស្រី២៤.៣២៥នាក់ ចំនួនគ្រួសារសរុប១០.១៤៧គ្រួសារ អាយុ១៨ឆ្នាំឡើង២៥.៩០១នាក់ ស្រី១៤.៤០០នាក់ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋ១៤៣នាក់ ក្នុង១គីឡូម៉ែត្រការ៉ែ។ បើប្រៀបធៀបក្នុងឆ្នាំ ២០០២ ប្រជាពលរដ្ឋមានការកើនឡើង ៤.៤២២នាក់ គិតជាមធ្យមប្រមាណជា ១,០៧០ភាគរយ ក្នុងមួយឆ្នាំ។

ចំណែកស្ថានភាពកសិកម្មនៅស្រុកជុំគីរី មានផ្ទៃដីបង្កបង្កើនផលចំនួន១១.៥០៥ហិកតាសម្រាប់ផលិតផលស្រូវធ្ងន់ ស្រូវស្រាល ស្រូវកណ្តាល និងស្រូវចំការ។ គួរអោយកត់សម្គាល់ផងដែរ ចាប់ពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦ មានការកើតឡើងនៅសត្វមមាចគ្នោតស៊ីបំផ្លាញដំណាំស្រូវនៅលើសំណាប និងសន្ធូង ដែលស្ងួងរួច ហើយធ្វើអោយផ្ទៃដីប៉ះពាល់បំផ្លាញចំនួន ៧៧.២៥ហិកតា ផ្ទៃដីសង្គ្រោះបានចំនួន ៧៤.៥ហិកតា ផ្ទៃដីខូចខាតចំនួន ២.៧៥ហិកតា ម្យ៉ាងទៀតផលប៉ះពាល់ និងការខូតខាតសន្ធូងដោយសារការខ្វះខាតទឹកនៅចុងរដូវវស្សាឆ្នាំ២០០៦ គិតត្រឹម ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៦ នេះនៅក្នុងបណ្តាឃុំទាំង ០៧ នៃស្រុកជុំគីរី។ លទ្ធផលបង្កបង្កើនផលគិតមកដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨នេះ អនុវត្តបានស្រូវប្រាំងសាបបាន ៤៧.៥ហិកតា ស្ងួងបាន១៩.៥ហិកតា ស្មើនឹង ១៧,៨៦ភាគរយ នៃផែនការស្រូវវស្សាសាបអនុវត្តបាន២៧១ហិកតា ស្ងួងបាន ១០៨០ហិកតា ស្រូវកណ្តាលអនុវត្តន៍សាបបាន១២៩ហិកតា ស្ងួងបាន២២៩ហិកតា ស្រូវចំការអនុវត្តន៍បាន ១៣ហិកតា ក្នុងនោះដំណាំរួមផ្សំមាន: ពោត=៧៥.៥ហិកតា ដំឡូងមី=៣៩ហិកតា ដំឡូងជ្វា=៣២.៥ហិកតា សណ្តែកបាយ=៤៦.៥ហិកតា សណ្តែកគ្រប់មុខ=៥៩.៥ហិកតា បន្លែគ្រប់មុខ២១ហិកតា និងដំណាំឧស្សាហកម្មរយៈពេលខ្លីរួមមាន: សណ្តែកដី=២៧.៥ហិកតា អំពៅ=៤៣ហិកតា។

ដោយឡែកនៅស្រុកជុំគីរី ជាស្រុកមួយនៃខេត្តកំពត ដែលព័ទ្ធជុំវិញដោយតំបន់ព្រៃភ្នំ សំបូរទៅដោយធនធានធម្មជាតិសព្វបែបយ៉ាង ដីមានជីជាតិល្អ មានអាងទឹក ទំនប់ ប្រឡាយ ដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រកបមុខរបរដាំដុះរបស់ពួកគាត់។ តែដោយសារការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកជុំគីរីទាំងមូលនៅតាមបទពិសោធន៍ កម្រិតទាបនៅឡើយ និងការឆ្លងកាត់នូវសង្គ្រាមជាងពីរទសវត្ស កន្លងមកធ្វើអោយជីវភាពរស់នៅរបស់ពួកគាត់ជួបប្រទះនូវភាពក្រីក្រ ដែលជាបញ្ហាប្រឈម។ លើសពីនេះទៀត ភាគច្រើនពុំបានចូលរៀនគ្រប់ៗគ្នា ហើយកុមារមិនបានចូលរៀនសុទ្ធសឹងជាកុមារ ដែលឪពុកម្តាយ និងអាណាព្យាបាលទីទ័លក្រជួបការលំបាកលំបិនបំផុតក្នុងបញ្ហាជីវភាពរបស់ពួកគាត់។ តាមការស្រង់ស្ថិតិប្រជាពលរដ្ឋក្រីក្រនៅស្រុកជុំគីរី ឆ្នាំ២០០៧ ដែលមានប្រជាពលរដ្ឋសរុបចំនួន ៩.៣៣៧គ្រួសារ មានគ្រួសារក្រីក្រចំនួន ៣៩៤ គ្រួសារ។

ដោយស្រុកជុំគីរីសំបូរទៅដោយប្រជាជនប្រកបរបរកសិកម្ម ដូចនេះផែនការកាត់បន្ថយភាពក្រីក្រស្រុកជុំគីរី តាមវិស័យកសិកម្ម ត្រូវបានផ្តោតជាសំខាន់ទៅលើ: ១-រក្សាបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសមស្រប និងគោលនយោបាយលើកទឹកចិត្ត និងបរិស្ថានដែលមានភាពអនុគ្រោះ។ ២-ពន្លឿនការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រប្រកបដោយចីរភាព រួមទាំងធានាដល់កសិករអោចគ្រប់គ្រងទឹកបានយ៉ាងខ្លាំងឡើងៗ។ ៣-អភិវឌ្ឍន៍ការដាំដុះមានផលិតភាពខ្ពស់ និងឈរលើមូលដ្ឋានដាំដំណាំច្រើនមុខ។ ៤-អនុវត្តន៍អោយបានឆាប់រហ័សនូវការចេញកម្មសិទ្ធិ និងការបែងចែកដីកសិកម្ម ដែលទទួលបានការដោះមីន។ ៥-រកទីផ្សារនាំស្រូវចេញ និងកសិផលផ្សេងទៀតទន្ទឹមនឹងការពង្រឹងការកែច្នៃកសិផល និងប្រព័ន្ធគ្រប់គ្រងគុណភាពកសិផល។ ៦-ពង្រឹងសេវា និងការគ្រប់គ្រងវិស័យកសិកម្មសំខាន់ៗរួមមាន ការផ្សព្វផ្សាយកសិកម្ម ការស្រាវជ្រាវ ការអភិវឌ្ឍន៍ផ្នែកទីផ្សារឥណទាន និង

មានការបែងចែកវត្ថុធាតុដើមកសិកម្ម។ ៧-ពង្រឹងការចិញ្ចឹមសត្វ ផ្តោតលើការថែរក្សាសុខភាពសត្វ អាហារសត្វ ការគ្រប់គ្រងកសិដ្ឋានក្នុងការចិញ្ចឹមមាន់ ការចិញ្ចឹមជ្រូក និងការផលិតចំណីសត្វ។ ៨-ការពង្រឹង ការគ្រប់គ្រង និងការដាក់អោយប្រើប្រាស់បច្ចេកទេសវិទ្យាសាស្ត្រសមស្របសម្រាប់ចិញ្ចឹមសត្វ តាមវាលស្រែ និងការចិញ្ចឹមសត្វទូទៅ។ ៩-ការពង្រឹងសមត្ថភាពរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧត្តុនិយម ទាំងនូវថ្នាក់កណ្តាល និងខេត្ត/ក្រុង។

ដើម្បីកាត់បន្ថយភាពក្រីក្រនៅស្រុកជុំគីរីមានចក្ខុវិស័យដូចចែងជាបន្តបន្ទាប់: ១-ពង្រឹងធានា សន្តិភាព សន្តិសុខ និងស្ថេរភាពសណ្តាប់ធ្នាប់សាធារណៈសង្គម និងស្ថេរភាពនយោបាយ។ ២-ពង្រឹងយុទ្ធសាស្ត្រ នៃការអភិវឌ្ឍន៍ស្រុក ដើម្បីកាត់បន្ថយភាពក្រីក្រ។ ៣-ពង្រឹងការងារអភិបាលកិច្ចល្អ ប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ៤-ខិតខំជានាសុវត្ថិភាពស្បៀង កាត់បន្ថយភាពក្រីក្រអោយនៅកម្រិតទាបបំផុតនៅក្នុងមូលដ្ឋាន។ ៥-ខិតខំទាក់ទងស្តារ កសាងហេដ្ឋារចនាសម័ន្ធ និងថែរទាំអោយមាននិរន្តរភាព។ ៦-ធ្វើអោយមានលំនឹងកាត់បន្ថយនូវការទំនាស់ដីធ្លីដោយការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ និងជាដុំ។ ៧-លើកស្ទួយកម្រិតជីវភាពរស់នៅស្ត្រី និងកុមារ ដោយទំនាក់ទំនងជាមួយអង្គការសហគមន៍ ឬក្រុមហ៊ុនអភិវឌ្ឍន៍កសិកម្ម និងកសិ-ឧស្សាហកម្មនានា ដើម្បីកាត់បន្ថយការចំណាកស្រុករបស់ប្រជាពលរដ្ឋ។ ៨-លុបបំបាត់គ្រោះអវិជ្ជា តាមផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាដល់ឆ្នាំ២០១២ មានមួយអនុវិទ្យាល័យនៅក្នុងមួយឃុំ។ ៩-រក្សាការពារខឿនវប្បធម៌ សាសនា បាវចនាជាតិ។ ១០-កំចាត់ជំងឺគ្រុនអោយអស់ក្នុងស្រុក និងកាត់បន្ថយរាល់ជម្ងឺនានា។ ១១-ពង្រឹងការងាររដ្ឋបាលមូលដ្ឋាន និងទំនាក់ទំនងជាមួយអង្គភាពស្ថាប័នពាក់ព័ន្ធ និងចុះបង្កើនការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជម្រុញក្នុងការប្រមូលពន្ធ និងចុះបញ្ជីអត្រានុកូលដ្ឋាន និង១២-ជម្រុញការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយទប់ស្កាត់អោយខាងតែបានរាល់ការជ្រៀតចូលក្នុងភូមិសាស្ត្រភូមិ ឃុំ ស្រុក ឬលួចដាំកញ្ឆា អាភៀន ជាដើម។ល។ ម្យ៉ាងទៀត ស្រុកជុំគីរីក៏មានយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ស្រុក ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈ:១-ពង្រឹង និងថែរក្សាសណ្តាប់ធ្នាប់សាធារណៈរបស់ប្រជាពលរដ្ឋជាពិសេស ចំពោះសន្តិសុខ នៃគ្រួសារនីមួយៗ កាត់បន្ថយអោយបានជាអតិបរមានូវបទល្មើសគ្រប់ប្រភេទតាមមូលដ្ឋាន។ ២-សក្តានុពលរបស់ស្រុកជុំគីរី មុខរបរសំខាន់របស់ប្រជាពលរដ្ឋ គឺធ្វើកសិកម្ម ដូច្នេះ ត្រូវធានាអោយបានពូជទឹកដី។ ៣-ពង្រឹងសកម្មភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា ដែលមានស្រាប់នៅក្នុងស្រុក និងបន្តសហការជាមួយអង្គការជាតិ និងអន្តរជាតិនានា។

ផ្នែកចុងក្រោយនៃជំពូកនេះ គឺការបកស្រាយនូវយុទ្ធវិធីមួយចំនួន ក្នុងការកាត់បន្ថយភាពក្រីក្រសម្រាប់កសិករកម្ពុជា ដែលមានដូចជា: ១-ពង្រីកវិស័យកសិកម្ម ដែលជាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ ២-ការអភិវឌ្ឍន៍កសិកម្ម គន្លឹះនៃការកាត់បន្ថយភាពក្រីក្រ ៣-បង្កើតយន្តការចាំបាច់បន្ទាន់ចូលរួមកាត់បន្ថយការលំបាករបស់កសិករ និង ៤-បណ្តុះធន្ធៈអោយមានការចងក្រងជាសហគមន៍កសិករ និងការអភិវឌ្ឍន៍។

តាមលទ្ធផលនៃការសិក្សាកន្លងមកបានបង្ហាញអោយឃើញថា ទោះបីភាពក្រីក្រនៅកម្ពុជាមានអត្រាមធ្យម២៦%ក៏ដោយ ក៏ប្រជាជនដែលរងនូវឥទ្ធិពលនេះមិនគួរបណ្តោយខ្លួនអោយកាន់តែជ្រៅឡើងៗ ដោយ

ពឹងផ្អែកលើការចាត់ចែងទាំងស្រុងពីរដ្ឋនោះទេ។ អ្នកទាំងនោះត្រូវស្វះស្វែងនៅក្នុងសហគមន៍របស់ខ្លួន ឬក្នុងកន្លែងខ្លួន រស់នៅចូលរួមជាមួយនឹងការឧបត្ថម្ភគាំទ្ររបស់ជាតិ អន្តរជាតិនានា និងអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើសកម្មភាពនៅទីកន្លែងដែលខ្លួនរស់នៅ ដើម្បីអោយទទួលបាននូវៈ ១-ការធ្វើឥណទានបណ្តាក់ទុកធនាគារស្រូវ ពលកម្មស្បៀងអាហារពិភពលោកក្នុងការជីកប្រឡាយធ្វើផ្លូវ ដើម្បីធ្វើអោយហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍របស់ខ្លួនមានភាពប្រសើរឡើង ដូចជាបានទទួលការបង្រៀនជំនាញកាត់ដេរ ជំនាញគ្រឿងម៉ាស៊ីន ជំនាញទីផ្សារ បានទទួលនូវការអប់រំសុខភាព អនាម័យពន្យាកំណើតពីបញ្ហារោគ AID បាននាំកូនតូចៗទៅចុះឈ្មោះចូលទៅរៀនសាលា និងកម្មវិធីអក្ខរកម្ម...។ល។ ២-ត្រូវស្វះស្វែងរកការងារធ្វើដោយខ្លួនឯងក្នុងសហគមន៍ ដែលគ្រួសារអ្នកមានគេត្រូវការជួលផ្សេងៗ ឬការងារតាមបណ្តារោងចក្រ សហគ្រាសទៅតាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួននៅតាមរោចក្រ កាត់ដេរ សហគ្រាសកិនស្រូវ។ល។ មិនតែប៉ុណ្ណោ ៣-ត្រូវមានការគាំទ្រយ៉ាងសកម្មនូវសេរីភាពគ្រប់គ្រាន់ក្នុងការបញ្ចេញមតិយោបល់ក្នុងការចូលរួមកសាងផែនការភូមិ ឃុំ តាមរយៈវិមជ្ឈការមានសិទ្ធិស្វ័យសម្រេចដោយខ្លួនឯង ដោយគ្មានការបង្ខិតបង្ខំពីជនណាម្នាក់ ដើម្បីចូលរួមការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន និងមានសិទ្ធិបង្កើតសហគមន៍អ្វីមួយ ដែលបម្រើអោយផលប្រយោជន៍របស់ខ្លួនក្នុងការរកប្រាក់ចំណូល ឬបញ្ចេញមតិតវ៉ារកយុត្តិធម៌សង្គមជាដើម។ នេះជាការខិតខំដោយខ្លួនឯងលើការចូលរួមមួយចំណែកក្នុងវិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច អប់រំ និងសុខាភិបាលផងដែរ។

ចំពោះរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី២ ទី៣ និងទី៤ បន្ទាប់ពីត្រូវបានបង្កើតឡើងពីការបោះឆ្នោតដែលបានរៀបចំឡើងដោយកម្ពុជាខ្លួនឯង បានកំណត់គោលនយោបាយរបស់ខ្លួន ដោយសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ការកែទម្រង់រដ្ឋ និងការកាត់បន្ថយភាពក្រីក្រ។ នេះក៏ដោយសារតែមានកត្តាអំណាយផលពីការបង្រួបបង្រួមជាតិលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការអនុវត្តន៍នូវនីតិរដ្ឋ។ នយោបាយ ដែលរាជរដ្ឋាភិបាលបានកំណត់មានការពាក់ព័ន្ធគ្នាពីមួយទៅមួយ ដូចជាគោលនយោបាយកាត់បន្ថយភាពក្រីក្រ ដែលវាពាក់ព័ន្ធទៅនឹងគោលនយោបាយកំណែទម្រង់ និងអភិបាលកិច្ចល្អជាដើម។ ដូច្នេះ ក្នុងការអនុវត្តន៍នយោបាយនេះវាទាមទារអោយមានដំណើរស៊ីសង្វាក់គ្នា ដើម្បីអោយមានភាពរលូន និងអាចសម្រេចបាននូវគោលដៅ ចំណងការសហការណ៍គ្នាពីស្ថាប័នមួយទៅស្ថាប័នមួយជាការចាំបាច់។

រដ្ឋាភិបាល បានអនុវត្តគោលនយោបាយរបស់ខ្លួនបានជាជំហានៗ និងធ្វើបានសម្រេចសមិទ្ធផលមួយចំនួន ដូចជា ការធ្វើវិមជ្ឈការដោយបានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ បានដោយជោគជ័យ ដើម្បីបែងចែកអំណាចពីរដ្ឋបាលកណ្តាលទៅរដ្ឋបាលមូលដ្ឋាន ដើម្បីអភិវឌ្ឍន៍មូលដ្ឋានរបស់គេ ការដាក់អោយដំណើរការនៅកន្សោយមអាទិភាពក្នុងការរៀបចំប្រព័ន្ធបៀវត្សថ្មី ការគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យាជាដើម។ រដ្ឋាភិបាលកំពុងដើរលើផ្លូវត្រូវក្នុងការអភិវឌ្ឍន៍ប្រទេស។ តែទោះជាយ៉ាងណាក៏រដ្ឋាភិបាលនៅមិនទាន់បានធ្វើអោយសម្រេចតាមគោលនយោបាយរបស់ខ្លួនទាំងអស់នោះទេ។ មានបញ្ហាមួយចំនួន ដែលរដ្ឋាភិបាលមិនទាន់អាចធ្វើបានដូចជា ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដែលជាឧបសគ្គធំបំផុត នៃការអភិវឌ្ឍន៍ការកែ

ទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលមិនមានសន្ធស្សន៍ទៅមុខ។យុទ្ធសាស្ត្រកំណែទម្រង់លើវិស័យទាំង ៤ របស់រដ្ឋាភិបាល មានការពាក់ព័ន្ធគ្នា ដូច្នេះ ត្រូវធ្វើអោយមានដំណើរស្របពេលជាមួយគ្នា។

លទ្ធផលនៃការសិក្សា បានបង្ហាញថា មូលហេតុដែលបណ្តាលអោយមានភាពក្រីក្រនៅកម្ពុជា យើងនោះ គឺបណ្តាលមកពីហេតុផល: ក-ហេតុផលផ្ទាល់ខ្លួនអ្នកក្រីក្រភាគច្រើននៅកម្ពុជាមានការអប់រំតិចតួច ឬគ្មានការអប់រំសោះ ទាំងចំណេះដឹងទូទៅ ទាំងបច្ចេកទេសជំនាញវិជ្ជាជីវៈ។ ការងារផលិតកម្ម ដូចជា កសិកម្មពឹងផ្អែកទាំងស្រុងទៅលើធម្មជាតិ ចំណែកឯសិប្បកម្ម និងផលិតកម្មផ្សេងៗ ច្រើនធ្វើឡើងទៅតាមទំនៀមទម្លាប់តៗគ្នា ដើម្បីជីវភាពប្រចាំថ្ងៃ។ មិនតែប៉ុណ្ណោះ ពួកគេពឹងផ្អែកទាំងស្រុងលើការងារដោយប្រើកម្លាំងបាយ។ នៅពេលសេដ្ឋកិច្ចទីផ្សារ និងបច្ចេកវិទ្យាទំនើបបានរីកដុះដាល ដែលពួកគេមិនអាចចូលចុះចំពោះមុខការងារថ្មី ដែលទាមទារជំនាញ និងការអប់រំខ្ពស់បានឡើយ។ ដូច្នេះ ពួកគេគ្មានឱកាសណាដើម្បីអោយក្លាយខ្លួនជាអ្នកមានបានឆាប់រហ័សបានឡើយ។ ខ-ការស្ថិតនៅក្រៅសង្គម អ្នកក្រីក្រនៅកម្ពុជាភាគច្រើន មានការភ័យខ្លាចក្នុងការទាក់ទងមិត្តភ័ក្តិ ឬអាជ្ញាធរព្រោះខ្មាស់អៀន ហើយគិតថា គ្មាននរណាអាចជួយពួកគាត់បានទេ។ ពួកគេកាន់តែស្ថិតនៅក្នុងភាពឯកោ និងក្តីអស់សង្ឃឹមទាល់ច្រកបាត់បង់លទ្ធភាពតស៊ូបន្តជំរុញអោយជីវិតរីកចម្រើនរុងរឿង។ ដោយហេតុនេះ គេមិនអាចសម្រេចការងារអ្វី ឬប្រើប្រាស់ឱកាសដើម្បីដោះស្រាយបញ្ហាលំបាកបានឡើយ។ សភាពការណ៍ដូច្នេះ ជាទូទៅនាំអោយអ្នកទ័លក្រក្លាយជាអ្នកសុំទាន ឬចោរលួច ឆក់ ប្លន់ បង្ខំចិត្តធ្វើជាស្រីពេស្យា ឬលក់កូនក្រមុំអោយទៅធ្វើស្រីពេស្យា ធ្វើអត្តឃាត និងធ្វើជាឧក្រិដ្ឋជន ផ្សេងទៀត។ លើសពីនេះទៀត អ្នកខ្លះក្លាយខ្លួនជាជនអនាថា គ្មានជម្រក ខ្លះរហូតដល់ដាច់បាយស្លាប់ក៏មាន។ គ-ភាពខ្ជិលច្រអូស កង្វះទ្រព្យធនធាន និងដីធ្លី អ្នកក្រីក្រជាច្រើនត្រូវបន្ទោសថា មកពីពួកគេខ្ជិលធ្វើការបានជាក្រ ទោះជាអ្នកខ្លះធ្វើការស្ទើរតែគ្មានពេលសម្រាកក៏ដោយ។ ដោយការតិះដៀលពីអ្នកដទៃ(អ្នកមានទ្រព្យធនជាងគេ) និងភាពលោភលន់ធ្វើអោយពួកគេលក់ ផ្ទះលក់ដីធ្លី ដែលជាធនធានសម្រាប់ផលិតកម្ម កសិកម្ម ឬវិនិយោគទុនទិញយក ហើយពួកគេបានថយខ្លួនបន្លាស់ទីលំនៅផ្សេង អ្នកខ្លះទៅប្រកបរបរផ្សេងខុសពីរបរដែលខ្លួនធ្លាប់មានបទពិសោធន៍។ ពួកគេភាគច្រើន មិនអាចកែប្រែជីវភាពរបស់គេអោយធូរធារបានទេ ព្រោះគេមិនចេះយកលុយដែលបានពីលក់ធនធានទាំងនោះទៅវិនិយោគលើអ្វីមួយឡើយ។ កត្តានេះហើយ ដែលធ្វើអោយអ្នកក្រីក្រ ចាប់ផ្តើមបាត់បង់ទ្រព្យសម្បត្តិដ៏សំខាន់របស់ខ្លួន គឺដីធ្លីដែលជាមធ្យោបាយផលិតកម្ម។ អ្នកខ្លះរំកិលចូលមកក្នុងក្រុង ដោយតាំងលំនៅ តំបន់អនាធិបតេយ្យ នាំអោយខូចសណ្តាប់ធ្នាប់សង្គម។ ដូច្នេះ អ្នកក្រកាន់តែក្រទៅ ហើយអ្នកមានដែលគេចេះកេង-ប្រវ័ញ្ចដោយសារដីធ្លី ឬកម្លាំងពលកម្មនោះកាន់តែមានទៅ ដែលជាហេតុនាំអោយមានគម្លាតរវាងអ្នកក្រ និងអ្នកមានក្នុងសង្គមកាន់តែរីកធំទៅៗ។ បញ្ហាទាំងនេះជាបន្ទុកយ៉ាងធ្ងន់ដល់សង្គម ដែលជាអ្នកដោះស្រាយ ពិសេសរដ្ឋាភិបាលមានការលំបាកក្នុងការដោះស្រាយពីព្រោះ រដ្ឋាភិបាលពេលខ្លះមិនអាចជួយពួកគេគ្រប់ពេលបានទេ ប្រសិនបើពួកគេមិនចេះជួយខ្លួនឯងផងទេនោះ។ ការពិតហេតុផលនេះវាពាក់ព័ន្ធទៅនឹងពួកគេខ្វះការយល់ដឹង និងបទពិសោធន៍។

ឃ- ខ្វះការយល់ដឹង អ្នកក្រីក្រភាគច្រើនមិនអាចមើលឃើញបញ្ហារបស់ខ្លួន ជាទស្សនៈទូលំទូលាយទេ ព្រោះពួកគេខ្វះការអប់រំ ខ្វះគំនិតច្នៃប្រឌិត ខ្វះប្រាជ្ញាគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាដែលពួកគេកំពុងជួបប្រទះ។ ដូចជា ករណីជាច្រើននៅក្នុងជីវភាពរស់នៅរបស់អ្នកទាំងនោះ ក្រោយពីពួកគេធ្វើការយ៉ាងលំបាក ដោយបង្ហូរញើសដើម្បីទទួលបានប្រាក់ចំណូលដ៏ស្តួចស្តើង ចំណូលមួយថ្ងៃសម្រាប់តែមួយថ្ងៃ តែពួកគេខិតខំរំលែកប្រាក់កាសនេះយកទៅផឹកស៊ី លេងល្បែង ស៊ីសង នៅពេលដែលកូនគេយំស្រែកទារកបាយនៅឯផ្ទះ។ ការលេងល្បែងនេះពេលខ្លះគាត់មានសំណាងឈ្នះ ហើយក្លាយទៅជាអ្នកមានមួយរយៈពេលតូចដែរ តែតាមធម្មតាគាត់កាន់តែក្រទៅៗ។ ង-ឥទ្ធិពលពីគ្រួសារ អ្នកដែលកើតមកក្នុងគ្រួសារឈាមជើរជាអ្នកក្រ ពិបាកនឹងរំដោះខ្លួនចេញពីភាពក្រីក្រណាស់ ពីព្រោះអ្នកជំនាន់មុនគ្មានសមត្ថភាពរំដោះកូនចៅជំនាន់ក្រោយគាត់ចេញពីគ្រោះនៃភាពក្រីក្របានឡើយ។ ពេលឪពុកម្តាយជំពាក់បំណុលគេ កូនចៅជំនាន់ក្រោយជាអ្នកត្រូវរកសងគេមិនចេះចប់។ ផ្ទុយទៅវិញវប្បធម៌របស់ខ្មែរ គ្រួសារអ្នកមាន តាមធម្មតា ពួកគេជួយញាតិមិត្ត ហើយគេខំសន្សំទ្រព្យអោយបានច្រើន ដើម្បីធ្វើជាកេរ្តិ៍មរតកសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។ អ្នកមានកូចតិច គេមានឱកាសច្រើនណាស់ដើម្បីរៀនសូត្របានខ្ពង់ខ្ពស់។ ម្យ៉ាងវិញទៀត ភាពក្រីក្រច្រើនតែធ្លាក់ទៅលើគ្រួសារណាដែលមានកូនច្រើន ជនពិការ និងជនចាស់ជរា ឬគ្រួសារដែលអ្នកដឹកនាំ គ្រួសារជាស្ត្រីមេម៉ាយ ព្រោះពួកនេះងាយរងគ្រោះជាទីបំផុត។

ច-បញ្ហាសាសនា ប្រជាជនកម្ពុជាភាគច្រើនជឿជាក់លើសាសនាអបិយ៍ជំនឿ និងកម្មផលនិយម។ អ្នកក្រភាគច្រើនយល់ថា ពួកគេក្រដោយសារ កម្មពៀរបស់គេពីអតីតកាល ឬពីជាតិមុន។ ម្ល៉ោះហើយពួកគេគ្មានសង្ឃឹម និងកម្លាំងចិត្តតស៊ូប្រឆាំងនឹងភាពក្រីក្រ ដែលកំពុងជួបប្រទះពេលបច្ចុប្បន្ននេះទេ។ ពួកគាត់បែរជាខិតខំធ្វើបុណ្យ ដើម្បីកសាងកុសលសម្រាប់ជាតិក្រោយៗទៀត គាត់មិនបានកែច្នៃជីវិតគាត់ក្នុងភាពរុងរឿងសម្រាប់បច្ចុប្បន្នឡើយ។ តាមពិតសាសនា គឺជាអត្តសញ្ញាណរបស់ប្រជាជាតិមួយ ដែលមានតម្លៃវប្បធម៌ និងអរិយធម៌របស់ជាតិយើង។ បញ្ហាទំនៀមទម្លាប់ ក្រុមកុលសម្ព័ន្ធជាជនជាតិភាគតិច ដែលរស់នៅតាមតំបន់ភ្នំ គឺជាអ្នកក្រជាប្រពៃណី ពួកគេពិបាកនឹងផ្លាស់ប្តូរ ទម្លាប់រស់នៅដោយប្រមូលផ្តុំ និងការធ្វើកសិកម្មដោយរបៀបបុរាណរបស់គេណាស់។ គេទម្លាប់រស់នៅដោយសារការបរបាញ់ ដុតព្រៃ ជាំដំណាំ សម្រាប់តែមួយចំអែតក្រពះប៉ុណ្ណោះ។ ដូច្នេះ ជំនឿស៊ុបខ្លាំងពេកទៅលើអបិយ៍ជំនឿ ក៏រួមចំណែកធ្វើអោយមានភាពក្រីក្រផងដែរ។

ឆ-ហេតុផលធម្មជាតិលក្ខខ័ណ្ឌធម្មជាតិ គឺជាហេតុផលសំខាន់ ដែលជះឥទ្ធិពលដល់ភាពក្រីក្រនៅកម្ពុជា។ ប្រជាជនកម្ពុជារស់នៅភាគច្រើនប្រកបរបរកសិកម្ម ដែលមានលក្ខណៈអន់ថយបុរាណ និងការពឹងផ្អែកទៅលើធម្មជាតិទាំងស្រុង។ នៅពេលដែលធនធានបរិស្ថានធម្មជាតិនៅកម្ពុជាត្រូវបានបំផ្លិចបំផ្លាញនោះ ជាហេតុបង្កអោយមានការប្រែប្រួលខាងធាតុអាកាស នាំអោយមានវិនាសកម្មធម្មជាតិ ដូចជា ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។ នៅកម្ពុជាអាកាសធាតុក្តៅនៅជនបទជាពិសេសនៅរដូវប្រាំងមនុស្ស សត្វ ពិបាកនឹងទ្រាំដោយសារកំដៅព្រះអាទិត្យ។ នៅតាមជនបទ ទឹកបឹងត្រពាំងរីងស្ងួតគ្មានសល់ជាហេតុធ្វើអោយមានជំងឺ និងសម្លាប់សត្វ ចិញ្ចឹមនៅតំបន់ជនបទស្ទើរតែទាំងអស់ជាពិសេសកន្លែងដែលឆ្ងាយពីទឹក។

ឈ-ហេតុផលនយោបាយ និងហេតុផលសេដ្ឋកិច្ច គឺជាផលប៉ះពាល់ដ៏សំខាន់ក្នុងការអភិវឌ្ឍន៍កម្ពុជា។ ក្នុងប្រវត្តិសាស្ត្រដ៏វែងឆ្ងាយរាប់សតវត្សកន្លងមកហើយ កម្ពុជាបានទទួលការឈឺចាប់ដោយសារសង្គ្រាម ភាពក្រីក្រ និងនយោបាយស្រឡាញ់អំណាច។ អស្ថេរភាពនយោបាយក្នុងអតីតកាលបានធ្វើអោយផ្ទៃដីប្រទេសកម្ពុជារួមតូចទៅ។ កិត្តិស័ព្ទ និងកិត្តិយសប្រជាជាតិអាប់ឱន។ ដោយសារសង្គ្រាម និងអស្ថេរភាពនយោបាយ រដ្ឋាភិបាលមានភាពទន់ខ្សោយខាងសេដ្ឋកិច្ច ខ្វះខាតថវិកាជាតិដល់ដំណើរការអភិវឌ្ឍន៍ ដែលជាឧបសគ្គក្នុងការកាត់បន្ថយភាពក្រីក្រនៅកក្នុងសង្គមកម្ពុជា។ ក្នុងការស្តារ និងកសាងប្រទេសអោយរីកចម្រើន គឺពឹងផ្អែកសំខាន់ទៅលើកត្តាសេដ្ឋកិច្ច គឺសំដៅលើកកម្ពស់ជីវភាពប្រជាជនអោយមានការរីកចម្រើនជាលំដាប់។ ដោយសារប្រទេសកម្ពុជាជួបប្រទះនូវវិបត្តិសង្គ្រាម និងវិបត្តិនយោបាយក្នុងស្រុកអូសបន្លាយជាងបីទសវត្ស គ្រប់ហេដ្ឋារចនាសម្ព័ន្ធជាតិត្រូវបានខូចខាតស្ទើរតែគ្មានសល់។ ស្ថានភាពដូចប្រទេសកម្ពុជាបានជំរុញអោយមានបម្លាស់ប្តូរនយោបាយ និងសេដ្ឋកិច្ចជាញឹកញាប់ជាហេតុធ្វើអោយមានភាពស្មុគស្មាញអូសបន្លាយនៃអន្តរកាលក្នុងដំណើរការឆ្លងកាត់ការស្តារ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ រយៈពេលអូសបន្លាយនៃអន្តរកាលនេះធ្វើអោយប្រទេសគ្មានស្ថេរភាពនយោបាយ ជាពិសេសវិស័យសេដ្ឋកិច្ចជួបប្រទះវិបត្តិ ដែលជាឱនភាពសេដ្ឋកិច្ចមួយលំបាកក្នុងការស្តារ និងជួសជុលឡើងវិញ។ កត្តាទាំងនេះបានរុញច្រានអោយភាពក្រីក្រនៅកម្ពុជាកាន់តែធ្ងន់ធ្ងរឡើងៗ។ម្យ៉ាងទៀត ហេតុផលសេដ្ឋកិច្ចនេះដែរ បានជាប់ពាក់ព័ន្ធក្នុងប្រព័ន្ធសេដ្ឋកិច្ចពិភពលោកនៅពេលដែលសេដ្ឋកិច្ចទីផ្សារកម្ពុជា និងបច្ចេកវិទ្យាថ្មីកំពុងតែកើនឡើង នោះសកម្មភាពពាណិជ្ជកម្មសេរី ក៏បើកឱកាសសម្រាប់ការប្រកួតប្រជែងយ៉ាងខ្លាំងក្លាដែរ។ ក្នុងឱការនេះដែរ អ្នកក្រកាន់តែក្រព្រោះគេគ្មានជំនាញក្នុងការធ្វើជំនួញ ហើយគេគ្មានទុន គ្មានចំណេះក្នុងការធ្វើវិនិយោគ ឬប្រកបរបរអកស៊ី។ ប្រភពទុនខ្ចីបុលតាមរយៈធនាគារមានការលំបាក ព្រោះធនាគារមិនដែលអោយអ្នកក្រីក្រខ្ចីបុលពីធនាគារទេ។ អ្នកក្រច្រើនតែជំពាក់បំណុលគេវ័ណ្ឌក រកវិធីដោះបំណុលគ្មានម្ល៉ោះហើយគាត់មិនអាចរំដោះខ្លួនចេញពីភាពទីទ័លក្របានដោយងាយឡើយ។ សម្រាប់កម្ពុជា ជាប្រទេសក្រីក្រ មានគម្លាតយ៉ាងខ្លាំងរវាងទីក្រុង និងជនបទអ្នកក្រ ដែលនៅតាមជនបទខ្វះសេវាសាធារណៈមិនដូចអ្នកមាននៅទីក្រុងទេ។ ហេដ្ឋារចនាសម្ព័ន្ធមានការខ្វះខាតអ្នកក្រមានចំពោះការចំណាយច្រើននៅក្នុងជីវិតភាពប្រចាំថ្ងៃ និងការស្វែងរកសេវាសាធារណៈដូចជា សេវាសុខភាព និងអប់រំដោះដើម។ ជាទូទៅប្រជាពលរដ្ឋភាគច្រើនអតុល្យភាពចំណូលនិងការចំណាយរួមទាំងមន្ត្រីរាជការភាគច្រើនក៏ដូច្នេះដែរ ដូចជា ការចំណាយទៅម្ហូបអាហារប្រចាំថ្ងៃ ថ្លៃទឹក ថ្លៃភ្លើង និងទៅលើសេវាផ្សេងៗទៀតទាំងទីក្រុង និងជនបទនៅមានកម្រិតខ្ពស់។ សម្រាប់ចំណូល និងចំណាយរបស់រដ្ឋាភិបាលក៏អតុល្យភាពកម្រិតខ្ពស់ដែរ។ ខ្វះសមត្ថភាពក្នុងការប្រមូលចំណូលដោយការមិនគោរពច្បាប់ និងអំពើពុករលួយ ចំណែកការចំណាយដ៏ដូច្នេះដែរ ចំណាយមិនបានបំពេញទៅតាមគោលដៅរបស់កម្មវិធី និងមិនធានាបាននូវគុណភាពដោយមានការសឹករិល ដោយអភិបាលកិច្ចទន់ខ្សោយ និងអំពើពុករលួយ។ រាល់ការចំណាយសម្រាប់ការអភិវឌ្ឍន៍របស់រដ្ឋាភិបាលត្រូវបានពឹងផ្អែក និងបំពេញបន្ថែមដោយជំនួយ និងកម្ចីពីប្រភពខាងក្រៅ ដែលជាបន្ទុកមួយយ៉ាងធ្ងន់ធ្ងរ ដល់កូនចៅទៅមនុស្សជំនាន់ក្រោយជាអ្នកដោះស្រាយ។ កត្តានេះធ្វើ

អោយសង្គមកម្ពុជា ជាពិសេសប្រជាពលរដ្ឋធ្លាក់ទៅក្នុងភាពក្រីក្រ ហើយក៏ការលំបាកកក្នុងការស្តារ និងកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គមផងដែរ។

ទោះបីមានការលំបាក និងឧបសគ្គធំធេងចំពោះមុខយ៉ាងណា ក៏រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធិលគួរជាទីលើកទឹកចិត្តមួយចំនួននៅក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ផែនការសកម្មភាពនៃអភិបាលកិច្ចល្អ គឺជាកញ្ចប់វិធានការសម្រាប់ប្រឆាំងអំពើពុករលួយ និងលុបបំបាត់ឫសគល់នៃអំពើពុករលួយ។ ការលុបបំបាត់ការកាប់ព្រៃឈើអនាធិបតេយ្យ វិធានការបង្កើនចំណូលពន្ធដារ និងការលុបបំបាត់នូវបញ្ហីខ្មោចចេញពីក្របខ័ណ្ឌសាធារណៈ ពីដួរកេងទ័ព និងការរឹបអូសយកដីធ្លី ដែលបានលក់ និងកាន់កាប់ដោយខុសច្បាប់មកជាទ្រព្យសម្បត្តិរដ្ឋវិញ គឺជាវិធានការសំដៅវាយយ៉ាងធំៗទៅលើអំពើពុករលួយ។ ចំណុចសំខាន់បំផុត ដើម្បីប្រឆាំងនឹងអំពើពុករលួយ គឺត្រូវអនុវត្តអភិបាលកិច្ចល្អអោយមានប្រសិទ្ធភាព និងអនុវត្តន៍ផែនការសកម្មភាពនៃអភិបាលកិច្ចអោយទាន់ពេលវេលា ដែលក្នុងនោះមានយុទ្ធសាស្ត្រសំខាន់ៗសម្រាប់កំណែទម្រង់សាធារណៈ វិមជ្ឈការ ការកាត់បន្ថយកងទ័ព កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ សមភាពរវាងភេទ ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយចីរភាព គឺជាអាទិភាពខ្ពស់បំផុតសម្រាប់កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ បច្ចុប្បន្ននេះ យើងមើលឃើញថា រាជរដ្ឋាភិបាលបានប្រឹងប្រែងធ្វើកិច្ចការជាច្រើន ដែលជំរុញអោយសេដ្ឋកិច្ចកាន់តែប្រសើរឡើង ហើយធ្វើអោយសង្គមមានសន្តិសុខ និងស្ថេរភាព នយោបាយល្អ ដែលជាឱមួយដ៏ល្អសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ និងដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

៥.២ អនុសាសន៍

ក្រោយពីបានសិក្សាលើប្រធានបទខាងលើរួមក ខ្ញុំបាទសូមផ្តល់ជាអនុសាសន៍ដ៏សំខាន់ចំពោះរាជរដ្ឋាភិបាលដូចតទៅ:

-គួរផ្តល់ជំនួយបច្ចេកទេសបន្ថែមទៀតដល់ដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍ ឃុំ/សង្កាត់ ដើម្បីផ្តល់ជម្រើសផ្សេងៗ ដែលអាចមានលទ្ធភាពដំណើរការបានតាមបច្ចេកទេស និងឆ្លើយតបទៅនឹងតម្រូវការ ដែលបានកំណត់។

-សហការជាមួយដៃគូ ដើម្បីកសាងឡើងនូវប្រព័ន្ធហេដ្ឋារចនាម័ន្ធទាំងឡាយ សំដៅកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានរបស់ធម្មជាតិ ដើម្បីជួយកាត់បន្ថយភាពក្រីក្រ។

-ធានាអោយមានភាពស៊ីសង្វាក់គ្នា រវាងកម្រិតនីមួយៗនៃការធ្វើផែនការ(ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង និងថ្នាក់ជាតិ)ដោយកំណត់ប្រព័ន្ធមួយ ដើម្បីធ្វើអោយផែនការឃុំ/សង្កាត់ មានភាពស៊ីសង្វាក់ជាមួយក្របខ័ណ្ឌនៃផែនការថ្នាក់លើ។

-បន្តកសាងសមត្ថភាព មិនត្រឹមតែនៅលើការធ្វើផែនការអភិវឌ្ឍន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅលើផ្នែកផ្សេងៗទៀត ដែលប៉ះពាល់ដល់អភិបាលកិច្ចល្អ ដូចជា តម្លាភាព និងការទទួលខុសត្រូវសាធារណៈ។

-ដាក់ចេញបទប្បញ្ញត្តិទាំងឡាយ ដើម្បីធានាអោយមានតម្លាភាពក្នុងការបើកផ្តល់ និងប្រើប្រាស់មូលនិធិឃុំ/សង្កាត់។ គួរកំណត់អោយមានយន្តការសម្រាប់ធ្វើសវនកម្មចំពោះមូលនិធិ ឃុំ/សង្កាត់។ កម្មវិធីប្រឆាំងអំពើពុករលួយមួយ ដែលរួមមានការអប់រំ ការបង្ការ និងការកាត់ទោស គួរដាក់ចេញយ៉ាងហោចណាស់នៅថ្នាក់មូលដ្ឋានប្រសើនបើមិនបានទៅគ្រប់កម្រិតរបស់រដ្ឋាភិបាល។

-វិមជ្ឈការមិនត្រឹមតែផ្តោតទៅលើផែនការមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតទៅលើទិដ្ឋភាពផ្សេងៗទៀតនៃអភិបាលកិច្ច ដូចជា ការលើកកម្ពស់ និងការបញ្ជ្រាបទស្សនទានផ្សេងៗ ដូចជា តម្លាភាព ការទទួលខុសត្រូវសាធារណៈ វិមជ្ឈការសារពើពន្ធ និងការកសាងសមត្ថភាពនៅក្នុងវិស័យទាំងនេះ។

លើសពីនេះទៅទៀតត្រូវពង្រឹងអភិបាលកិច្ចល្អនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសទៅទីជនបទដែលមានការអភិវឌ្ឍន៍ខ្សោយនៅឡើយ ដើម្បីចូលរួមចំណែកជួយកាត់បន្ថយភាពក្រីក្រអោយបានឆាប់ប្រកបដោយតម្លាភាព ហើយត្រូវបង្កលក្ខណៈអោយមានការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិល និងផ្នែកឯកជនដោយលើកទឹកចិត្តអោយមានការផ្លាស់ប្តូរយោបល់ និងទស្សនៈទូលំទូលាយ ហើយត្រូវមានទំនាក់ទំនងជាប្រចាំ និងចុះអប់រំអំពីវិធីដាំដុះ ការប្រើប្រាស់ដី និងបច្ចេកទេសទាន់សម័យដល់ប្រជាកសិករក្នុងការបង្កបង្កើនផលសម្រាប់ចិញ្ចឹមជីវិតអោយបានសមរម្យ។ ជាពិសេសត្រូវបង្កើតឱកាសអោយកសិករទាំងអស់បានចូលរួមអភិវឌ្ឍន៍ខ្លួនគេផ្ទាល់តែម្តង។ ចំណែកឯរាជរដ្ឋាភិបាលត្រូវបង្កើតអោយមាននូវគោលនយោបាយគាំពារអ្នកក្រ និងជនងាយរងគ្រោះទាំងអស់នៅទូទាំងប្រទេស។ ហើយចំណុចសំខាន់មួយទៀតនោះ គឺរាជរដ្ឋាភិបាលគួរតែដាក់ចេញនូវគោលនយោបាយទប់ស្កាត់មិនអោយប្រជាកសិករលក់ដី ស្រែ ចំការ ដែលជាប្រភពតែមួយគត់សម្រាប់ពួកគាត់អាស្រ័យផលចិញ្ចឹមជីវិតរៀងរាល់ឆ្នាំ។ ហើយសំខាន់ជាងនេះទៀត ត្រូវបង្កើតសហគមន៍កសិកររអោយមានទូទាំងប្រទេសតែម្តងក្នុងគោលបំណងពីរ ដែលក្នុងនោះដើម្បីប្រយោជន៍កសិករ និងដើម្បីទាក់ទាញអោយមានការវិនិយោគផងដែរ។ លើសពីនេះ រាជរដ្ឋាភិបាលត្រូវបញ្ជូលទស្សនាទានមួយដល់កសិករអោយបានយល់ច្បាស់គ្រប់គ្នាថា ដើម្បីកាត់បន្ថយភាពក្រីក្របាន ប្រជាកសិករ ត្រូវចាប់ផ្តើមអភិវឌ្ឍន៍សមត្ថភាព ចំណេះដឹង និងចំណេះធ្វើសម្រាប់ខ្លួនគាត់ម្នាក់ៗជាមុនសិន ពេលនោះហើយដែលធ្វើអោយប្រសិទ្ធភាពនៃការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល គឺជាទម្រង់រឹងមាំជួយទំលុះ ហើយបំបែកភាពក្រីក្របានយ៉ាងឆាប់រហ័ស៕

គន្ថនិទ្ទេស

I. ឯកសារដើមជាក្រម ជាច្បាប់ អនុក្រឹត្យផ្សេង:

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។

២. សាលាក្រុងភ្នំពេញ: របាយការណ៍បូកសរុបលទ្ធផលអនុវត្តការងារឆ្នាំ២០០៣ និងទិសដៅការងារឆ្នាំ២០០៤។

៣. ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល "ផែនការសកម្មភាពអភិបាលកិច្ច" ខែមេសា ឆ្នាំ២០០១ ។

៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច: យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ ។

៥. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ: ផែនការជាតិប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ២០០០-២០០៤ (១៧ មីនា ២០០០) ។

៦. រាជរដ្ឋាភិបាលកម្ពុជា"ឯកសារបឋមស្តីពី យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ភ្នំពេញ ខែតុលា ឆ្នាំ២០០០ ។

៧. រាជរដ្ឋាភិបាលកម្ពុជា: ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំ លើកទី២ (២០០១-២០០៥) ។

៨. រាជរដ្ឋាភិបាលកម្ពុជា: ឯកសារបឋមស្តីពី យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (ខែតុលា ឆ្នាំ២០០០) ។

៩. រាជរដ្ឋាភិបាល: អាទិភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច តម្រូវការជំនួយផ្លូវការសម្រាប់អភិវឌ្ឍន៍ ឆ្នាំ២០០២ ។

១០. អប់រំសុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ជាវិស័យអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល ។

១១. ទីចាត់ការគយ និងរដ្ឋការ: របាយការណ៍ប្រចាំឆ្នាំ២០០០,២០០១ ។

១២. រាជរដ្ឋាភិបាលកម្ពុជា "ឯកសារបឋមស្តីពី យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០០" ។

១៣. រាជរដ្ឋាភិបាលកម្ពុជា "យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពកក្រីក្រ" ។

១៤. រាជរដ្ឋាភិបាលកម្ពុជា "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៨-២០១០" ។

II. សុន្ទរកថា បទអន្តរាគមន៍ របាយការណ៍ និងឯកសារអន្តរជុំ:

១៥. **ហ៊ុនសែន** ថ្លែងចំពោះមុខរដ្ឋសភាអាណត្តិទី២ បង្ហាញពីកម្មវិធីនយោបាយ និងសមសភាពនៃរាជរដ្ឋាភិបាលភ្នំពេញ, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ។

១៦. សុំ ម៉ានិត ក្នុងសិក្ខាសាលាជាតិស្តីពី "ម៉ាទ្រីសផែនការសកម្មភាពសម្រាប់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ: អភិបាលកិច្ច-កំណែទម្រង់-វិសហមជ្ឈការ" ថ្ងៃទី២៨-២៩ ខែឧសភា ឆ្នាំ២០០២ ។

១៧. ទេព ជារុង ថ្លែងក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ ស្តីពីការកែរចនាសម្ព័ន្ធ សិទ្ធិអំណាច និងតួនាទីរដ្ឋបាលសាធារណៈក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ។

១៨. ទីស្តីការគណៈរដ្ឋមន្ត្រី: របាយការណ៍ស្តីពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាល ប្រចាំឆ្នាំ២០០០។

១៩. សុន គន្ធរ៉ "ការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសក្នុងការអភិវឌ្ឍន៍លើវិស័យសង្គមកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រ: ឥណទានជនបទនៅកម្ពុជា" ខែមីនា ឆ្នាំ២០០១។

២០. ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល "កំណែទម្រង់រដ្ឋបាល" អត្ថបទផ្សព្វផ្សាយជាភាសាអង់គ្លេសនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី០៤ ប៉ារីស បារាំង ថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០០០ ។

២១. សុខអាន "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រថ្លែងក្នុងសន្និបាតជាតិលើកទី២ ថ្ងៃទី១២-១៤ ខែមីនា ឆ្នាំ២០០១ ។

២២. ឯកសារសន្និបាតជាតិលើកទី២ ស្តីពី "ការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសក្នុងការអភិវឌ្ឍន៍លើវិស័យសង្គមកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រ" ថ្ងៃទី១២-១៤ ខែមីនា ឆ្នាំ២០០១ ។

២៣. សេចក្តីសម្រេចចិត្តនៃសន្និបាតជាតិលើកទី២ ថ្លែងដោយលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ ។

២៤. ការអភិវឌ្ឍន៍ដោយចីរភាពកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អនៅកម្ពុជា ភ្នំពេញ ឆ្នាំ២០០២ ។

២៥. កៅ គឹមហួន "ការអភិវឌ្ឍន៍ដោយសេរីភាព ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អនៅកម្ពុជា" ភ្នំពេញ ឆ្នាំ២០០២ ។

២៦. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: មូលនិធិរូបិយវត្ថុអន្តរជាតិ "គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៤"

២៧. ក្រសួងផែនការ(២០០០) ស្ថានភាពនៃភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៩(សេចក្តីព្រាង)។

២៨. ការវាយតម្លៃភាពក្រីក្រនៅកម្ពុជា ដោយធនាគារពិភពលោក ឆ្នាំ១៩៩៩ ។

២៩. កម្ពុជា: អភិបាលកិច្ច និងវិនិច្ឆ័យកម្មនៃអំពើពុករលួយ ធនាគារពិភពលោក ខែឧសភា ឆ្នាំ១៩៩៩ ។

៣០. ក្រសួងអភិវឌ្ឍន៍ជនបទ: សមិទ្ធិផលការងារឆ្នាំ២០០៤-២០០៧ និងទិសដៅបន្តខែឧសភា-មិថុនា ឆ្នាំ២០០៨ ។

៣១. ក្រសួងផែនការ: របាយការណ៍ឆ្នាំ១៩៩៩ ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា "សេដ្ឋកិច្ច ភូមិ និងការអភិវឌ្ឍន៍" ។

៣២. ប៊ូម និងហ្គូដវិន អ្នកនិពន្ធ Oxford University of Press EDS, AIP 1997 ។

៣៣. ឌីខេមបូឌាដេលី(The Cambodia Dialy)បកប្រែជាភាសាខ្មែរ ចេញថ្ងៃពុធ ទី០២ ខែមេសា ឆ្នាំ២០០៨។

៣៤. ធនាគារពិភពលោក "ការពិនិត្យលើការចំណាយសាធារណៈនៅកម្ពុជា ឆ្នាំ១៩៩៩" ។

៣៥. យុទ្ធសាស្ត្រជាតិ កាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-២០០៥ ។

៣៦. ព្រះរាជាណាចក្រកម្ពុជា "កម្មវិធីវិនិយោគសាធារណៈ ២០០០-២០០២" ។

៣៧. ព្រះរាជាណាចក្រកម្ពុជា "យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ" ឆ្នាំ២០០៣-២០០៥ ។

៣៨. រាជរដ្ឋាភិបាលកម្ពុជា "ឯកសារបឋមស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ឆ្នាំ២០០០ ។

៣៩. របាយការណ៍ NIS/LFS ២០០០ ។

៤0. របាយការណ៍ស្តីពីការវាយតម្លៃរបស់កម្រិតចេះអក្សរតាមតួនាទីរបស់ប្រជាជននៅកម្ពុជា នៅឆ្នាំ២០០០ (MOEY/UNESCO 2000) ។

៤១. ប្រទេសកម្ពុជា: ការកំណត់វិនិច្ឆ័យពីការអភិបាលកិច្ច និងអំពើពុករលួយ កស្តុតាងពីការអង្កេតប្រជាពលរដ្ឋ សហគ្រិន មន្ត្រីសាធារណៈ ធនាគារពិភពលោក។

៤២. សិក្ខាសាលាថ្នាក់ជាតិស្តីពីការចាប់ផ្តើមរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២: ២00១-២00៥។

៤៣. រាជរដ្ឋាភិបាលកម្ពុជា "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ" ២00៦-២0១0 ។

៤៤. របាយការណ៍ MOEYS/UNESCO 2000 ។

៤៥. អង្គការស្បៀងអាហារពិភពលោក របាការណ៍ឆ្នាំ២000 ។

៤៦. អង្គការមិត្តសំឡាញ់: ការអង្កេតស្តីពីការប្រើប្រាស់គ្រឿងញៀន ដោយក្មេងអនាថា នៅទីក្រុងភ្នំពេញ (២000) ។

៤៧. **សម្តេចតេជោ ហ៊ុន សែន** សន្និសីទ ស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២00៨ នៅសណ្ឋាគារភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២00៨ ។

៤៨. យុទ្ធសាស្ត្រក្នុងការផ្តល់ជំនួយដល់កម្ពុជា: ការកសាងមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ធនាគារពិភពលោកឆ្នាំ២000 ។

៤៩. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឧសភា ឆ្នាំ២000) យុទ្ធសាស្ត្រក្នុងវិស័យកសិកម្ម និងក្របខ័ណ្ឌគោលនយោបាយ ដើម្បីសម្រេចបាននូវសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ដោយចីរភាព ។

៥0. វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ការអភិវឌ្ឍន៍ដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អនៅកម្ពុជា ឆ្នាំ២00២ ។

៥១. WHO របាយការណ៍មិនបោះពុម្ពផ្សាយ ស្តីពីការសិក្សាលើគ្រោះមហន្តរាយនៃឃុំជ្រើសរើសមួយចំនួនក្នុងបរទេសកម្ពុជាឆ្នាំ២០០១។

III. ព្រឹត្តិប័ត្រ សារព័ត៌មាន និងទស្សនាវដ្តី:

៥២. កាសែតកម្ពុជា "រាជរដ្ឋាភិបាលអាណត្តិទី២ ១៩៩៨-២០០៣" ពេពុម្ពមានជ័យ ឆ្នាំ១៩៩៩ ។

៥៣. ទស្សនាវដ្តីប្រជាប្រិយ៍ ឆ្នាំទី៧ លេខ១៦៧ ថ្ងៃទី១-១០ ខែឧសភា ឆ្នាំ២០០១ ។

៥៤. ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា CDRI ឆ្នាំទី៣ ទី៥ ។

៥៥. កាសែតរស្មីកម្ពុជា ឆ្នាំទី១០ លេខ២៦៧១ ថ្ងៃសុក្រ ទី១០ ខែកុម្ភៈ ឆ្នាំ២០០២ ។

៥៦. កាសែតរស្មីកម្ពុជា ឆ្នាំទី១១ លេខ៣០៩២ ។

៥៧. កាសែតរស្មីកម្ពុជា: ថ្ងៃទី២៣-២៤ ខែមេសា ឆ្នាំ២០០១: "ការធ្វើសវនកម្មលើក្រុមហ៊ុនរកឃើញថាមានការបន្លំពន្ធដារខ្លាំងណាស់" ។

៥៨. ការសែតកោះសន្តិភាព លេខ៤៨៥៨ ថ្ងៃអង្គារ ទី០៨ ខែកក្កដា ឆ្នាំ២០០៣ ។

៥៩. កាសែតកោះសន្តិភាព អត្ថបទ "គំនិតដដែលៗ" លេខ ៤៨០៥ ថ្ងៃពុធ ទី០៧ ខែឧសភា ឆ្នាំ២០០៣ ។

៦០. ព័ត៌មានប្រចាំសប្តាហ៍ កញ្ចក់សង្គម លេខ១៧២ ចេញផ្សាយសម្រាប់ថ្ងៃអាទិត្យ ទី១៤ ដល់ថ្ងៃសៅរ៍ ទី២០ ខែតុលា ឆ្នាំ២០០១ ។

៦១. ព្រឹត្តិប័ត្រប្រចាំខែរបស់រាជរដ្ឋាភិបាល ឆ្នាំទី១ លេខ០២ ខែកុម្ភៈ ឆ្នាំ២០០១ ។

៦២. ព្រឹត្តិប័ត្រព័ត៌មាន ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល លេខ ០៥, ០៨, ១០, ១១, ១២, ១៣, ១៤ ។

៦៣. មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម "មគ្គុទ្ទេសអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ ថ្ងៃអាទិត្យ ទី០៣ ខែកុម្ភៈ ឆ្នាំ២០០២" លេខ ០២ ។

IIV. ស្ថាប័នឯកទេ:

៦៤. ហ៊ូ យន់ "បញ្ហាសហគមន៍នៅប្រទេសខ្មែរ" បោះពុម្ពលើកទី១ ភ្នំពេញ ១៩៥៦(និក្ខេបបទ) ។

៦៥. ក្រម ង៉ុយ "បណ្តាំក្រមង៉ុយ" បោះពុម្ពឡើងវិញដោយពុទ្ធសាសនាបណ្ឌិត ភ្នំពេញ ឆ្នាំ១៩៩៨ ។

៦៦. វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា: ទស្សនាវដ្តីវិភាគសេដ្ឋកិច្ច ឆ្នាំទី១ លេខ ១ ។

៦៧. មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ: សេដ្ឋកិច្ចវិទ្យា(១៩៩៧) ។

៦៨. មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម: "ការត្រួតពិនិត្យអំពើពុករលួយ" សៀវភៅសម្រាប់សមាជិកសភា ខែមិថុនា ឆ្នាំ២០០០ ។

៦៩. Rarticia Baars សៀវភៅ "សេចក្តីណែនាំជាក់ស្តែងស្តីពីការកាត់តែងច្បាប់" ភ្នំពេញ, ២០០១ ។

៧0. សុក ហាច និង Sarthi Acharya "របាយការណ៍ប្រចាំឆ្នាំ ស្តីពីសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០២" ។

៧១. ហេង ហុង "ឱ! លោកជំទ្បែ" ។

៧២. កម្រិតអប់រំមូលដ្ឋាន គឺពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី៩ (ការសិក្សា ៩ឆ្នាំ) ។

៧៣. ធនាគារពិភពលោក: យុទ្ធសាស្ត្រជំនួយសម្រាប់ប្រទេសកម្ពុជា(កុម្ភៈ ២០០០)។

៧៤. គាត ឈុន: បទអនុរាគមន៍របស់ឯកឧត្តម គាត ឈុន ស្តីពីជំនួយបរទេស (២៧ តុលា ១៩៩៩)។

៧៥. NICOLAS REGAUD: "កម្ពុជាក្នុងព្យុះសង្ឃរា"។

៧៦. CDRI: "ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតម្រូវចំពោះវិបត្តិ" បោះពុម្ព ខែតុលា ឆ្នាំ២០០១។

៧៧. CDRI: "ការវាយតម្លៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា" ខែមីនា ឆ្នាំ២០០២ ។

៧៨. CDRI: "ការកែទម្រង់សេដ្ឋកិច្ច ការកែម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ១៩៩៧ ។

៧៩. CDRI: (សុក ហាច, ជា ហួត និងសុិក បូរក្ស) របាយការណ៍ប្រចាំឆ្នាំស្តីពីសេដ្ឋកិច្ចកម្ពុជា ២០០១ ។

៨0. CDRI: ប្រទេសកម្ពុជា បញ្ហាប្រឈមនៃការបង្កើតការងារ ដែលមានផលិតភាព។

V. ឯសារជាភាសាបរទេស

៨១. Pool (Peter A.). "CAMBODIA", in the Encyclopedia International, Vol. 3, 1982.

៨២. Enclopaedia Britannica, Macropaedia, 15 Ed, Vol.3, USA, 1980.

៨៣. Keo Kim Hourn, Cambodia's foreign policy and ASEAN from Nonalignment to Engagement, Phnom Penh, 2002.

៨៤. Smith (Adam), The Invisible Hand of Free Enterprise, in the Principle of Macroeconomics, 4th Edition, 1983.

៨៥. May Tola, Action System of The Nation Bank of Cambodia, Jan 25, 1995.

៨៦. UNCTAD, Trade and Development Report, UN, New York, 1996.

៨៧. NBC, The Banking System in Cambodia, April 2000. Banking Supervision Department.

๘๘. GRET, CCL, IRAM, Finncial System for Rural Development, April 1996.

๘๙. Ministry of Commerce, "The Cambodia Business and Investment Handbook 2000", 2000, Phnom Penh, Blossom Lotus.

๙๐. Mekong Law Report, Cambodia Investment Guide.

๙๑. Far Eastern Economic Review, Vol. 165, No.7, Feb 21,2002.

๙๒. Customer Tariff of Cambodia 2001 ¬TMnijnaMecjPaKeRcIn RtUv)anelIkElgBn§¦.

๙๓. MARIE ALEXANDRINE MARTIN: {CMgWkm<úCa} ("LE MAL CAMBODGIEN" HISROIRE D'UNE SOCIETE TRADITIONNELLE FACEASES LEADERS POLITIQUE 1946-1987).

๙๔. HISTORY OF PHNOM PENH CITY, First Edition-March 1998.

๙๕. National Institute of Statistics: KINGDOM OF CAMBODIA STATISTICAL YEAR BOOK 2003.

๙๖. Adil Khan, M. 1996, Economic Developent, Poverly Alleviation and Governance.

๙๗. Avebury : Brookfield USA; Hong Kong; Singapore; Sydney.

๙๘. Cheema, G.Shbbir and Rondenelli Dennis A. dhoke, Neera, 1983, Decentralization and Development. Policy Implementation in Developing Countries. Beverly Hills/ London /NewDalhi.

๙๙. Guzman, Raul P.DE and Reforma, Mila A., 1993, Decentralization towards Democratization and Development. EROPA Secretariat, Manila.

๑๐๐.Rapley, Jonh, 1996, Understanding Development : Theory and Practice in the Third World. Lynne Rienner Publishers, Boulder London.

๑๐๑.Nathan Keyfitez: Toward Population Theory of Population-Development Interaction in the Sociology of Development by Roberts, B.R., Cushing, R.G., & Wood. C. (1995), UK: Edward Elger Pupblishing Limited, Vol, II, pp, 295-296